# សេចក្តីព្រាង

# ក្រមបរិស្ថាន និងធនធានធម្មជាតិ

## កំណែទី១១ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

# ដំណើរការតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ

សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលសម្រេចបានរហូតមកដល់ពេលបច្ចុប្បន្ននេះ ជាលទ្ធផលនៃការងារអស់រយៈពេលជាង២ឆ្នាំ របស់ក្រសួងបរិស្ថាន ក្រោមការផ្តួចផ្តើមគំនិតរបស់ **ឯកឧត្តម បណ្ឌិត សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ លើវិស័យបរិស្ថាន និងធនធានធម្មជាតិ ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយមានការឯកភាព និងការគាំទ្រដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបានធ្វើកិច្ចសហការផ្តល់ជំនួយបច្ចេកទេសពី ក្រុមមេធាវី វ៉ិស្ត្រ ។

ចាប់តាំងពីដើមឆ្នាំ២០១៥មក ក្រសួងបរិស្ថាន បានចាប់ផ្តើមរៀបចំឱ្យមានសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិមួយ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានក្រមបរិស្ថាន និងធនធានធម្មជាតិមួយ មានលក្ខណៈច្បាស់លាស់ និងពេញលេញគ្រប់ជ្រុងជ្រោយ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពនៃការធ្វើកំណែទម្រង់ថ្មីលើវិស័យបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឱ្យស្របតាមបរិបទនៃការរីកចំរើនរបស់ព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ជាសេចក្តីព្រាងក្រមមួយដែលមានលក្ខណៈចម្រុះ និងគ្រប់វិស័យ ដោយប្រមូលផ្តុំរាល់បទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយមានការបែងចែកជារចនាសម្ព័ន្ធត្រឹមត្រូវ ដើម្បីធានាឱ្យមានសង្គតិភាព និងភាពស៊ីសង្វាក់គ្នា និងព្រមទាំងបានបំពេញបន្ថែមនូវចំណុចខ្វះចន្លោះ ភាពមិនច្បាស់លាស់ ការត្រួតសមត្ថកិច្ចគ្នា នៃការគ្រប់គ្រងធនធានធម្មជាតិរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា គឺធ្វើយ៉ាងណាឱ្យសេចក្តីព្រាងក្រមមួយនេះ ក្លាយជាលិខិតតុបករណ៍គតិយុត្តមួយយ៉ាងសំខាន់ សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងអ្នកអនុវត្តច្បាប់ផ្សេងទៀត មានភាពងាយស្រួលក្នុងការប្រើប្រាស់ និងអនុវត្តតួនាទី ភារកិច្ចរៀងៗខ្លួន ។

ក្នុងការរៀបចំតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិនេះ ក្រសួងបរិស្ថាន បានបង្កើតក្រុមការងារចំនួន៤ ដូចខាងក្រោម ៖

១- ក្រុមការងារតាក់តែងសេចក្តីព្រាងក្រមបរិស្ថានអន្តរក្រសួង

២- ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

៣- លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

៤- ក្រុមការងារពិនិត្យ និងកែសម្រួលសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ

៥- ក្រុមការងារជំនាញបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថានចំនួន៧ មានជាអាទិ៍ ក្រុមការងារជំនាញនិរន្តរភាពទីក្រុង និងសេដ្ឋកិច្ចបៃតង ក្រុមការងារគ្រប់គ្រងសំណល់ និងការបំពុល ក្រុមការងារអភិរក្ស រុក្ខឧទ្យានសត្វព្រៃ និងជីវៈចម្រុះ ក្រុមការងារអភិរក្សបេតិកភណ្ឌ និងឧទ្យានធម្មជាតិ ក្រុមការងារគ្រប់គ្រងដីសើម និងអភិរក្សជីវៈចម្រុះទឹកសាប និងទឹកប្រៃ ក្រុមការងារគ្រប់គ្រង ការស្រាវជ្រាវ និងអាជីវកម្មរ៉ែ និងក្រុមការងារអភិរក្សកិច្ចការស្រាវជាវ អប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន ។

**ក្រុមការងារអន្តរក្រសួងទទួលបន្ទុកតាក់តែងសេចក្តីព្រាងក្រមបរិស្ថានអន្តរក្រសួង** មានភារកិច្ច និងតួនាទីសម្របសម្រួលការងារពាក់ព័ន្ធនឹងដំណើរការនៃការសម្រេចចិត្តធំៗ ពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិជាពិសេស ក្នុងករណីមានការខ្វែងគំនិតគ្នាក្នុងការបែងចែកសមត្ថកិច្ចគ្រប់គ្រងនានាលើធនធានធម្មជាតិ ។

**ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន** ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំការងារសម្របសម្រួលផ្នែកខ្លឹមសារបច្ចេកទេស ដែលសមាសភាពសមាជិកចម្រុះពីក្រសួង ស្ថាប័នរដ្ឋពាក់ព័ន្ធ ដែលសុទ្ធតែជាមន្ត្រីជំនាញបច្ចេកទេស ។

**លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមការងារតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន** មានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការងាររបស់ក្រុមការងារជំនាញបច្ចេកទេស នៃក្រុមការងារតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលមានសមាសភាពជាមេធាវី ថៅក្រមសាលាឧទ្ធរណ៍ និងអ្នកជំនាញការបច្ចេកទេសជាតិ និងអន្តរជាតិ ដែលទទួលបន្ទុកលើការងារតាក់តែងសេចក្តីព្រាងក្រមបរិស្ថានឱ្យមានលក្ខណៈជាបច្ចេកទេសច្បាប់ស្របតាមបរិបទនៃព្រះរាជាណាចក្រកម្ពុជា ។

**ក្រុមការងារជំនាញទាំង៧នៃក្រុមការងារតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន** គឺក្រុមការងារបឋម ដែលមានសមាជិកចម្រុះ ក្នុងនោះមានសមាជិកពីក្រសួងបរិស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ។ ក្រុមការងារជំនាញនេះ ដើរតួនាទីចម្បងក្នុងការស្រាវជ្រាវ និងប្រមូលមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីចងក្រងជាទិដ្ឋភាពរួមនៃគោលការណ៍បច្ចេកទេស និងបទពិសោធន៍នានាពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែង ដែលជាបញ្ហាប្រឈម ដែលត្រូវយកមកដោះស្រាយ ដោយបទប្បញ្ញត្តិនៃសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ។

ជាការកត់សម្គាល់ **ក្រុមមេធាវី វិស្ណុ** គឺជាស្ថាប័នឯកជនតែមួយគត់ ដែលជាអ្នកប្រមូលយកមតិយោបល់ជាតុចូល និងអនុសាសន៍ទាំងអស់ ដែលទទួលបានពីក្រុមការងារជំនាញបច្ចេកទេសទាំង៧ខាងលើ និងមតិយោបល់ពីសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនលើក ដើម្បីយកមករៀបចំតាក់តែង និងកែសម្រួលឱ្យចេញជារូបរាងនៃសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិទាំងស្រុង តាំងពីសេចក្តីព្រាងលើកទី១ ដែលបានចាប់ផ្តើមក្នុងឆ្នាំ២០១៥ រហូតដល់សេចក្តីព្រាងទី១០ ឆ្នាំ២០១៨នេះ ។ ក្នុងនោះដែរ ក្រុមការងារបច្ចេកនៃក្រុមមេធាវី វិស្ណុ មាន

សមាសភាពជាអាទិ៍ មេធាវី មន្ត្រីច្បាប់ ចៅក្រមជំនាញមកពីសាលាឧទ្ធរណ៍ និងអ្នកជំនាញការអន្តរជាតិ ដែលជាអ្នករៀបចំ កែសម្រួលសេចក្តីព្រាងក្រមនេះ ។ សេចក្តីព្រាងលើកទី១០នៃក្រម បានធ្វើឡើងបន្ទាប់ពីបានដាក់បញ្ចូលមតិយោបល់ដែលទទួលបានពីក្រុមការងារបច្ចេកទេស កម្មវិធីអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ ដែលហៅកាត់ថា " UNDP" និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធដទៃទៀត ។

ក្រោយពីទទួលបានមតិយោបល់ និងធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារនៃក្រុមមេធាវីវិល្ហ៊ឺ និងក្រុមការងារជំនាញបច្ចេកទេសរបស់ក្រសួងបរិស្ថាន បានសហការគ្នាក្នុងការពិនិត្យ និងដាក់បញ្ចូល នូវមតិយោបល់ និងធាតុចូលទាំងនោះ ទៅក្នុងសេចក្តីព្រាងលើកទី១០ នៃសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ រហូតមកដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ ទើបសេចក្តីព្រាងលើកទី១១នេះ សម្រេចបានជាផលផ្លែគួរឱ្យកត់សម្គាល់ ។ សម្រាប់សេចក្តីព្រាងលើកទី១១ផងដែរ ក្រសួងបរិស្ថានគ្រោងនឹងដាក់ប្រជុំអន្តរក្រសួង ដើម្បីផ្តល់មតិយោបល់ និងធាតុចូលបន្ថែមទៀត ។

ក្រោយពីទទួលបានមតិយោបល់ និងធាតុចូលពីកិច្ចប្រជុំអន្តរក្រសួង ក្រុមការងារនៃក្រុមមេធាវីវិល្ហ៊ឺ និងក្រុមការងារជំនាញរបស់ក្រសួងបរិស្ថាន គ្រោងនឹងកែសម្រួល ដោយបញ្ចូលមតិយោបល់ និងធាតុចូលពីកិច្ចប្រជុំអន្តរក្រសួង និងគ្រោងបញ្ជូនសេចក្តីព្រាងក្រមនេះ ទៅទីស្តីការគណៈរដ្ឋមន្ត្រី នាពេលខាងមុខ ដើម្បីពិនិត្យ និងកែសម្រួលបន្ថែម ។

# មាតិកា


**គន្ថីទី១ បទប្បញ្ញត្តិទូទៅ** ..... ១

មាតិកាទី១ បទប្បញ្ញត្តិទូទៅ ..... ១

ជំពូកទី១ គោលបំណង គោលដៅ និងវិសាលភាព ..... ១

ជំពូកទី២ គោលការណ៍ទូទៅ ..... ២

ជំពូកទី៣ សមត្ថកិច្ចក្រសួង ស្ថាប័នពាក់ព័ន្ធនឹងបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ..... ៥

មាតិកាទី២ ការចូលរួមជាសាធារណៈ ..... ៦

ជំពូកទី១ សិទ្ធិ និងការការពារសម្រាប់ការចូលរួមជាសាធារណៈ ..... ៦

ជំពូកទី២ ការចូលរួមជាសាធារណៈរបស់សហគមន៍ជនជាតិដើមភាគតិច ..... ៩

ជំពូកទី៣ វិធានការកាត់បន្ថយផលប៉ះពាល់ ..... ១០

មាតិកាទី៣ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន ..... ១១

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..... ១១

ជំពូកទី២ ការផ្តល់ព័ត៌មានដោយរាជរដ្ឋាភិបាល ..... ១៤

ផ្នែកទី១ ការផ្តល់ព័ត៌មានជាសាធារណៈ ..... ១៤

ផ្នែកទី២ បញ្ជីព័ត៌មានបរិស្ថានជាតិ ..... ១៥

ផ្នែកទី៣ បញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ ..... ១៦

ផ្នែកទី៤ បញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ ..... ១៦

ជំពូកទី៣ ព័ត៌មានសម្ងាត់ ..... ១៧

ជំពូកទី៤ ការស្នើសុំព័ត៌មាន ..... ១៨

ជំពូកទី៥ មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ និងរបាយការណ៍បរិស្ថានជាតិ ..... ១៩

ផ្នែកទី១ មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ ..... ១៩

ផ្នែកទី២ របាយការណ៍បរិស្ថានជាតិ ..... ២១

**គន្ថីទី២ ការវាយតម្លៃបរិស្ថាន** ..... ២២

មាតិកាទី១ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ..... ២២

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..... ២៣

ជំពូកទី២ នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ..... ២៣

មាតិកាទី២ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ............................................ ២៦

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ............................................ ២៦

ជំពូកទី២ គោលការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ............................................ ២៧

ជំពូកទី៣ អង្គភាពទទួលខុសត្រូវ ............................................ ២៨

ជំពូកទី៤ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ............................................ ៣១

ផ្នែកទី១ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងស្នើសុំ ............................................ ៣១

ផ្នែកទី២ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ .... ៤០

ផ្នែកទី៣ ការវាយតម្លៃហានិភ័យ ............................................ ៤១

ផ្នែកទី៤ ការវាយតម្លៃហានិភ័យនិរន្តរភាព ............................................ ៤៤

ផ្នែកទី៥ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះការប្រែប្រួលអាកាសធាតុ ............................................ ៤៥

ផ្នែកទី៦ ការវាយតម្លៃហេតុប៉ះពាល់សុខភាព និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្តុំ ........ ៤៥

ផ្នែកទី៧ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ............................................ ៤៧

ជំពូកទី៥ ការចូលរួមជាសាធារណៈ ............................................ ៤៧

ជំពូកទី៦ ផែនការគ្រប់គ្រងបរិស្ថាន និងការអង្កេតតាមដានគម្រោង ............................................ ៥១

មាតិកាទី៣ សវនកម្មបរិស្ថាន ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍ ............................................ ៥៤

ជំពូកទី១ សវនកម្មបរិស្ថាន ............................................ ៥៤

ជំពូកទី២ ការតែងតាំង និងលក្ខណៈសម្បត្តិរបស់សវនករបរិស្ថាន ............................................ ៥៦

**គន្ថីទី៣ ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព** ............................................ ៥៧

មាតិកាទី១ ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ............................................ ៥៧

ជំពូកទោល ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ............................................ ៥៧

មាតិកាទី២ ការអភិវឌ្ឍដោយចីរភាព ............................................ ៥៩

ជំពូកទី១ ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រការងារអភិវឌ្ឍន៍ដោយចីរភាព និងរបាយការណ៍ជាតិ ............................................ ៥៩

ជំពូកទី២ ការអភិរក្សក្រៅតំបន់ប្រព័ន្ធតំបន់ការពារធម្មជាតិ ............................................ ៥៩

មាតិកាទី៣ ការប្រែប្រួលអាកាសធាតុ ............................................ ៦០

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ............................................ ៦០

ជំពូកទី២ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ............ ៦១

ជំពូកទី៣ ការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ...................................................... ៦២
ជំពូកទី៤ ការអង្កេតតាមដាន និងការវាយតម្លៃការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ.................. ៦៥
ជំពូកទី៥ ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ .................................................................... ៦៧
ជំពូកទី៦ ក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ ................................................ ៧០
ផ្នែកទី១ ការប្រែប្រួលអាកាសធាតុនៅក្នុងថវិកាជាតិ និងថ្នាក់ក្រោមជាតិ.................................... ៧១
ផ្នែកទី២ ការវិនិយោគដែលគិតគូរចំពោះការប្រែប្រួលអាកាសធាតុពីវិស័យឯកជន ........................ ៧២
ផ្នែកទី៣ ការកៀរគរហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស......................................... ៧៣
ផ្នែកទី៤ ការលើកកម្ពស់យន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព........................................................................... ៧៣
មាតិកាទី៤ ការប្រើប្រាស់ និងផលិតកម្មដោយនិរន្តរភាព.................................................................. ៧៤
ជំពូកទោល បទប្បញ្ញត្តិទូទៅ........................................................................................... ៧៤
ផ្នែកទី១ ការលើកកម្ពស់ការប្រើប្រាស់ និងផលិតកម្មដោយនិរន្តរភាព........................................ ៧៤
ផ្នែកទី២ លទ្ធកម្មសាធារណៈដោយនិរន្តរភាព..................................................................... ៧៥
ផ្នែកទី៣ ការដាក់ស្លាកសញ្ញាមេត្រីភាពបរិស្ថាន ................................................................... ៧៨
ផ្នែកទី៤ ការវាយតម្លៃប្រសិទ្ធផលធនធាន .......................................................................... ៧៨
ផ្នែកទី៥ ការទទួលខុសត្រូវរបស់ផលិតករ ........................................................................... ៨០
មាតិកាទី៥ ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុងដោយនិរន្តរភាព............ ៨១
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ............................................................................................. ៨១
ជំពូកទី២ តួនាទី និងការទទួលខុសត្រូវ ............................................................................. ៨២
ជំពូកទី៣ ការរៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន...................... ៨៣
ជំពូកទី៤ ទីក្រុងដោយនិរន្តរភាព ..................................................................................... ៨៦
ផ្នែកទី១ ស្ថាប័នទទួលខុសត្រូវ ...................................................................................... ៨៦
ផ្នែកទី២ យន្តការទីក្រុងដោយនិរន្តរភាព............................................................................ ៨៧
មាតិកាទី៦ ទេសចរណ៍ដោយនិរន្តរភាព ............................................................................... ៨៨
ជំពូកទី១ ការអភិវឌ្ឍទេសចរណ៍ដោយនិរន្តរភាព................................................................. ៨៨
ជំពូកទី២ សហគមន៍ទេសចរណ៍ធម្មជាតិ ............................................................................ ៨៩
មាតិកាទី៧ ថាមពលដោយនិរន្តរភាព .................................................................................. ៩០

ជំពូកទី១ ថាមពលដោយនិរន្តរភាព ........ ៩០
ជំពូកទី២ ផែនការថាមពលដោយនិរន្តរភាព ........ ៩១
ជំពូកទី៣ ការលើកកម្ពស់បច្ចេកវិទ្យាថាមពលមេត្រីភាពបរិស្ថាន ........ ៩៣
ជំពូកទី៤ ការត្រួតពិនិត្យគុណភាពផលិតផលសម្រាប់ផលិតថាមពលដោយនិរន្តរភាព ........ ៩៦
ជំពូកទី៥ ក្របខ័ណ្ឌទៅតាមប្រភេទថាមពល ឬគម្រោងអគ្គិសនី ........ ៩៧
ផ្នែកទី១ ថាមពលកកើតឡើងវិញ ........ ៩៧
ផ្នែកទី២ ថាមពលនុយក្លេអ៊ែរ ........ ៩៩
ផ្នែកទី៣ ការភ្ជាប់ប្រព័ន្ធចែកចាយ និងបណ្តាញតចូល ........ ១០០
ជំពូកទី៦ ប្រសិទ្ធភាពថាមពល ........ ១០១
មាតិកាទី៨ ឧស្សាហកម្មនិស្សារណកម្មប្រកបដោយការទទួលខុសត្រូវ ........ ១០២
ជំពូកទី១ វិសាលភាព និងការរៀបចំផែនការបរិស្ថានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម ........ ១០២
ជំពូកទី២ បច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម ........ ១០៥
ជំពូកទី៣ ការប្រើប្រាស់ ស្យានីត និងបារតនៅក្នុងការធ្វើអាជីវកម្មរ៉ែមាស និងប្រាក់ ........ ១០៦
ជំពូកទី៤ ការលាតត្រដាងព័ត៌មាន ........ ១០៨
**គន្ថីទី៤ ការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព** ........ ១០៩
មាតិកាទី១ ប្រព័ន្ធតំបន់ការពារធម្មជាតិ ........ ១០៩
ជំពូកទី១ នីតិវិធីនៃការបង្កើត ការផ្លាស់ប្តូរ និងការរំសាយប្រព័ន្ធតំបន់ការពារធម្មជាតិ ........ ១០៩
ជំពូកទី២ ការគ្រប់គ្រង ការប្រើប្រាស់ និងតម្រូវការផ្សេងៗ ........ ១១២
ជំពូកទី៣ ស្ថានភាពបច្ចុប្បន្ននៃតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ........ ១១៣
មាតិកាទី២ ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ........ ១១៤
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........ ១១៤
ជំពូកទី២ ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី ........ ១១៥
ជំពូកទី៣ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ........ ១១៧
ជំពូកទី៤ ការរៀបចំផែនការប្រើប្រាស់ដី ........ ១២១
ជំពូកទី៥ ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ........ ១២៤
ជំពូកទី៦ ផែនការយុទ្ធសាស្ត្រ និងផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ........ ១២៩
ជំពូកទី៧ ការអនុញ្ញាត ការសម្រេច និងការហាមឃាត់ ........ ១៣៣

ជំពូកទី៨ ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ នៃការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ.......... ១៤០
មាតិកាទី៣ ការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ ........................................ ១៤១
ជំពូកទី១ ការបង្កើតក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ........................................ ១៤១
ជំពូកទី២ ការអនុវត្តក្របខ័ណ្ឌនៃការគ្រប់គ្រងរួមគ្នា ........................................ ១៤២
ជំពូកទី៣ រយៈពេលនៃការគ្រប់គ្រងរួមគ្នា និងសិទ្ធិលើដីធ្លី ........................................ ១៤៦
មាតិកាទី៤ ការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តរភាព ........................................ ១៤៩
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........................................ ១៤៩
ជំពូកទី២ ស្ថាប័នមានសមត្ថកិច្ច ........................................ ១៥០
ជំពូកទី៣ ការធ្វើចំណាត់ថ្នាក់ព្រៃឈើដោយនិរន្តរភាព ........................................ ១៥៣
ជំពូកទី៤ ការរៀបចំផែនការប្រើប្រាស់ និងផែនការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ........................................ ១៥៧
ជំពូកទី៥ លិខិតអនុញ្ញាត និងការសម្រេច ........................................ ១៥៩
ជំពូកទី៦ សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ........................................ ១៦១
ជំពូកទី៧ ផែនការ និងរបាយការណ៍គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ........................................ ១៦២
ជំពូកទី៨ ប្រាក់កម្រៃ និងបុព្វលាភស្តីពីព្រៃឈើ ........................................ ១៦៣
ជំពូកទី៩ យន្តការសម្រាប់គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ........................................ ១៦៥
មាតិកាទី៥ កិច្ចការពាររុក្ខជាតិព្រៃ ប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងតំបន់ទីជម្រាល ........................................ ១៦៨
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........................................ ១៦៨
ជំពូកទី២ ការធ្វើចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ ........................................ ១៧០
ជំពូកទី៣ ការហាមឃាត់សកម្មភាពប៉ះពាល់ទីជម្រកប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង និង ការប្រមូលរុក្ខជាតិព្រៃ ........................................ ១៧២
ជំពូកទី៤ ការផ្តល់លិខិតអនុញ្ញាត ការប្រមូលយក និងការធ្វើពាណិជ្ជកម្ម ........................................ ១៧២
ជំពូកទី៥ ផែនការគ្រប់គ្រង និងស្តាររុក្ខជាតិព្រៃឡើងវិញ ........................................ ១៧៥
ជំពូកទី៦ ការគ្រប់គ្រងប្រភេទរាតត្បាត ........................................ ១៧៦
ជំពូកទី៧ ការគ្រប់គ្រងរុក្ខជាតិ និងបំណែកនិស្សន្ទវត្ថុរុក្ខជាតិព្រៃកំពុងរងការគំរាមកំហែងដែលបានពី ការរឹបអូស ........................................ ១៧៩
ជំពូកទី៨ ការគ្រប់គ្រងតំបន់ទីជម្រាល ........................................ ១៨០
មាតិកាទី៦ ការគ្រប់គ្រង ការការពារ និងការអភិរក្សសត្វព្រៃ ........................................ ១៨៣

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ....................................................................................... ១៨៣
ជំពូកទី២ ការធ្វើចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ....................................................................... ១៨៥
ជំពូកទី៣ ការហាមឃាត់ចំពោះការបរបាញ់សត្វព្រៃ ................................................................ ១៨៦
ជំពូកទី៤ ករណីលើកលែងសម្រាប់ការបរបាញ់សត្វព្រៃ ........................................................... ១៨៨
ផ្នែកទី១ ការគ្រប់គ្រងលើការបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស ................................................... ១៨៨
ផ្នែកទី២ គ្រឹះស្ថានឧទ្យានសត្វព្រៃ ................................................................................ ១៩២
ជំពូកទី៥ លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ .......................................................................... ១៩៣
ជំពូកទី៦ ការហាមឃាត់ ការធ្វើអាជីវកម្ម ការជួញដូរ ការធ្វើពាណិជ្ជកម្ម សត្វព្រៃដែលបរបាញ់បាន បំណែកសរីរាង្គសត្វព្រៃ ឬផលិតផលពីសត្វព្រៃគ្រប់ប្រភេទ ........................................................ ១៩៥
ជំពូកទី៧ អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ... ១៩៧
ជំពូកទី៨ កិច្ចសហប្រតិបត្តិការអន្តរជាតិ .............................................................................. ១៩៨
ជំពូកទី៩ ផែនការគ្រប់គ្រង និងស្តារសត្វព្រៃ ......................................................................... ១៩៩
ជំពូកទី១០ ការគ្រប់គ្រងទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សហ្សែន មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និង គ្រឹះស្ថានឧទ្យានសត្វព្រៃ ................................................................................. ២០២
ជំពូកទី១១ ការគ្រប់គ្រងសត្វព្រៃ បំណែកសរីរាង្គសត្វព្រៃដែលរឹបអូសបាន ...................................... ២០៥
ជំពូកទី១២ ការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ................................................................ ២០៧
ជំពូកទី១៣ ការតាមដានសុខភាពសត្វព្រៃ ............................................................................ ២១២
មាតិកាទី៧ ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធាន តំបន់ឆ្នេរសមុទ្រ តំបន់កោះ និង សមុទ្រ ..................................................................................................... ២១៤
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........................................................................................ ២១៤
ជំពូកទី២ ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានតំបន់ឆ្នេរសមុទ្រ តំបន់កោះ និង សមុទ្រ ..................................................................................................... ២១៤
មាតិកាទី៨ ការគ្រប់គ្រងធនធានទឹកដោយនិរន្តរភាព ............................................................... ២១៩
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........................................................................................ ២១៩
ផ្នែកទី១ វិសាលភាព និងគោលការណ៍ ........................................................................... ២១៩
ផ្នែកទី២ ម្ចាស់កម្មសិទ្ធិលើទឹក និងធនធានទឹក ................................................................. ២២០
ជំពូកទី២ ការទទួលខុសត្រូវលើធនធានទឹក ...................................................................... ២២១

ផ្នែកទី១ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ....................................... ២២១
ផ្នែកទី២ ការសម្របសម្រួលរបស់រាជរដ្ឋាភិបាល ....................................... ២២៣
ជំពូកទី៣ ការរៀបចំផែនការធនធានទឹក ....................................... ២២៤
ផ្នែកទី១ ក្រសួង ស្ថាប័នទទួលបន្ទុក ....................................... ២២៤
ផ្នែកទី២ ផែនការយុទ្ធសាស្ត្រជាតិធនធានទឹក ....................................... ២២៦
ផ្នែកទី៣ ផែនការធនធានទឹកអាងទន្លេ ....................................... ២២៧
ជំពូកទី៤ ការចេញលិខិតអនុញ្ញាត ....................................... ២៣៤
ផ្នែកទី១ បទប្បញ្ញត្តិទូទៅ ....................................... ២៣៤
ផ្នែកទី២ លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ....................................... ២៣៦
ផ្នែកទី៣ សិទ្ធិទទួលបានទឹក ....................................... ២៣៦
ផ្នែកទី៤ ការការពារទន្លេ និងស្ទឹង ....................................... ២៤០
ផ្នែកទី៥ អ្នកអភិវឌ្ឍទឹកក្រោមដី ....................................... ២៤១
ផ្នែកទី៦ ការដកហូតការអនុញ្ញាត ....................................... ២៤៣
ជំពូកទី៥ ការតម្រូវឱ្យមានការអនុញ្ញាត ....................................... ២៤៣
ជំពូកទី៦ ការរៀបចំផែនការធនធានទឹកអាងទន្លេអន្តរកាល ....................................... ២៤៤
មាតិកាទី៩ និរន្តរភាពជលផល ....................................... ២៤៥
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ....................................... ២៤៥
ជំពូកទី២ ការគ្រប់គ្រងជលផលទឹកសាបដោយនិរន្តរភាព ....................................... ២៤៦
ជំពូកទី៣ ការគ្រប់គ្រងជលផលសមុទ្រដោយនិរន្តរភាព ....................................... ២៤៨
ជំពូកទី៤ វារីវប្បកម្ម ....................................... ២៥១
**គន្ថីទី៥ ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ** ....................................... ២៥២
មាតិកាទោល ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ....................................... ២៥២
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ....................................... ២៥២
ជំពូកទី២ ការហាមឃាត់ និងការអនុញ្ញាត ....................................... ២៥៣
ជំពូកទី៣ បេតិកភណ្ឌធម្មជាតិ ....................................... ២៥៤
ជំពូកទី៤ ការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ....................................... ២៥៦
ផ្នែកទី១ ក្រសួង ស្ថាប័នមានសម្ថកិច្ច ....................................... ២៥៦

ផ្នែកទី២ ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ........ ២៥៧
ជំពូកទី៥ ការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ ........ ២៦០
ជំពូកទី៦ បញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ........ ២៦១
ជំពូកទី៧ ការធ្វើចំណាត់ថ្នាក់បេតិកភណ្ឌវប្បធម៌ ........ ២៦២
ជំពូកទី៨ ការរៀបចំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌ ........ ២៦៤
ជំពូកទី៩ ការបង្កើតតំបន់បេតិកភណ្ឌទីក្រុង ........ ២៦៥
ជំពូកទី១០ កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ ........ ២៦៧
ផ្នែកទោល ការប្រទះឃើញដោយចៃដន្យនូវសម្បត្តិវប្បធម៌ ........ ២៦៧
ជំពូកទី១១ ការធ្វើកំណាយ ........ ២៦៨
ជំពូកទី១២ កំណាយបង្ការ ........ ២៧០
ជំពូកទី១៣ កិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ........ ២៧២
ជំពូកទី១៤ អង្គភាពជំនាញខាងបុរាណវិទ្យា ........ ២៧៣
ជំពូកទី១៥ ការដោះស្រាយវិវាទ និងបទបញ្ជាបន្ទាន់ ........ ២៧៤
ជំពូកទី១៦ ការលើកកម្ពស់ និងការការពារបេតិកភណ្ឌវប្បធម៌អរូបិយ ........ ២៧៥
ជំពូកទី១៧ ការអប់រំ និងការយល់ដឹង ........ ២៧៦
ជំពូកទី១៨ បទប្បញ្ញត្តិប្រឆាំងនឹងការជួញដូរសម្បត្តិវប្បធម៌ ........ ២៧៧
**គន្ថីទី៦ ការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុលបរិស្ថាន** ........ ២៧៨
មាតិកាទី១ បទប្បញ្ញត្តិទូទៅ ........ ២៧៨
ជំពូកទី១ កាតព្វកិច្ចគ្រប់គ្រងសំណល់ ........ ២៧៨
ជំពូកទី២ ការទទួលខុសត្រូវការបំពុលបរិស្ថាន ........ ២៧៩
ជំពូកទី៣ វិធានការត្រួតពិនិត្យការបំពុលបរិស្ថាន ........ ២៨០
ផ្នែកទី១ ស្តង់ដារបរិស្ថាន ........ ២៨០
ផ្នែកទី២ លិខិតអនុញ្ញាតសំណល់ ........ ២៨១
ផ្នែកទី៣ ការបង់ថ្លៃបំពុលបរិស្ថាន និងការបង់អាករបរិស្ថាន ........ ២៨២
មាតិកាទី២ ការត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់ ........ ២៨៣
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........ ២៨៣
ជំពូកទី២ ការគ្រប់គ្រងការសាយភាយសារធាតុគ្រោះថ្នាក់ ........ ២៨៤

ជំពូកទី៣ ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់ និងផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ..................... ២៨៦
ជំពូកទី៤ ការដាក់ស្លាកសញ្ញាគ្រោះថ្នាក់ ..................... ២៨៨
ជំពូកទី៥ កាតព្វកិច្ចផ្តល់ព័ត៌មានសារធាតុគ្រោះថ្នាក់ ..................... ២៨៨
ជំពូកទី៦ ការហាមឃាត់ ..................... ២៩០
មាតិកាទី៣ ការគ្រប់គ្រងសំណល់រឹង ..................... ២៩១
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..................... ២៩១
ជំពូកទី២ ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ..................... ២៩៣
ផ្នែកទី១ ស្ថាប័នទទួលខុសត្រូវ ..................... ២៩៣
ផ្នែកទី២ កាតព្វកិច្ចម្ចាស់សំរាមសំណល់រឹងទីប្រជុំជន ..................... ២៩៣
ផ្នែកទី៣ សេវាប្រមូលដឹកជញ្ជូន និងសេវាទីលានចាក់សំរាមសំណល់រឹងទីប្រជុំជន ..................... ២៩៤
ជំពូកទី៣ ការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម ..................... ២៩៤
ជំពូកទី៤ ការទាញយកធនធាន កែច្នៃ ការនាំចេញ និងនាំចូលសំណល់រឹង ..................... ២៩៥
មាតិកាទី៤ ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ..................... ២៩៦
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..................... ២៩៦
ជំពូកទី២ វិធានការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ..................... ២៩៧
ផ្នែកទី១ ការបង្កើតសំណល់គ្រោះថ្នាក់ ..................... ២៩៧
ផ្នែកទី២ សេវាប្រមូល ដឹកជញ្ជូន កែច្នៃ ប្រព្រឹត្តកម្ម កម្ទេចចោល ឬបោះបង់ចោលសំណល់ គ្រោះថ្នាក់ ..................... ២៩៨
ផ្នែកទី៣ ការនាំចូល ការនាំចេញ និងការដឹកជញ្ជូនឆ្លងកាត់ ..................... ២៩៩
ផ្នែកទី៤ ហេតុការណ៍កំពប់ ឬគ្រោះឧបទ្ទវហេតុលេចធ្លាយសំណល់គ្រោះថ្នាក់ ..................... ៣០០
ជំពូកទី៣ ការត្រួតពិនិត្យការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ..................... ៣០១
មាតិកាទី៥ ការត្រួតពិនិត្យការបំពុលទឹក ..................... ៣០២
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..................... ៣០២
ជំពូកទី២ ការគ្រប់គ្រងការបំពុលទឹកតំបន់ទឹកសាធារណៈ ..................... ៣០៣
ជំពូកទី៣ ការត្រួតពិនិត្យប្រភពបំពុលទឹកពីប្រភពជាក់លាក់ ..................... ៣០៤
ជំពូកទី៤ ការត្រួតពិនិត្យប្រភពមិនជាក់លាក់ ..................... ៣០៦
ជំពូកទី៥ ការត្រួតពិនិត្យការបំពុលសមុទ្រ ..................... ៣០៧

មាតិកាទី៦ ការត្រួតពិនិត្យការបំពុលខ្យល់.......................................................................................................៣១០
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..........................................................................................................................៣១០
ជំពូកទី២ ការបំពុលខ្យល់ពីប្រភពចល័ត........................................................................................................៣១១
ជំពូកទី៣ ការបំពុលខ្យល់ពីប្រភពអចល័ត ...................................................................................................... ៣១២
ជំពូកទី៤ ការត្រួតពិនិត្យសារធាតុបំពុលខ្យល់ក្នុងផ្សងថ្ម និងឥន្ធនៈផូស៊ីល ......................................................៣១៤
ជំពូកទី៥ ការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ ..........................................................................................៣១៥
ជំពូកទី៦ ការត្រួតពិនិត្យគុណភាពខ្យល់បរិយាកាស .......................................................................................៣១៦
ជំពូកទី៧ ការបំពុលខ្យល់ឆ្លងដែន ................................................................................................................. ៣១៧
ជំពូកទី៨ សារធាតុបំផ្លាញស្រទាប់អូហ្សូន.......................................................................................................៣១៨
មាតិកាទី៧ ការត្រួតពិនិត្យសំឡេង និងរំញ័រ ...................................................................................................៣១៩
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..........................................................................................................................៣១៩
ជំពូកទី២ ការគ្រប់គ្រងសំឡេង និងរំញ័រ........................................................................................................ ៣២០
មាតិកាទី៨ ការស្តារឡើងវិញនូវទីតាំងដែលទទួលរងការបំពុល ............................................................................ ៣២១
ជំពូកទី១ បទប្បញ្ញត្តិទូទៅ .......................................................................................................................... ៣២១
ជំពូកទី២ ការកំណត់អត្តសញ្ញាណ និងការសិក្សាទីតាំងទទួលរងការបំពុល.................................................៣២៣
ជំពូកទី៣ ការស្តារឡើងវិញ និងការអង្កេតតាមដាន.........................................................................................៣២៣
មាតិកាទី៩ ប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល ................................ ៣២៥
ជំពូកទី១ បទប្បញ្ញត្តិទូទៅ .......................................................................................................................... ៣២៥
ជំពូកទី២ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល ......... ៣២៦
មាតិកាទី១០ បុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថាន..................................................................................៣២៧
ជំពូកទោល បុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថាន.................................................................................៣២៧
**គន្ថីទី៧ ការអប់រំ ការស្រាវជ្រាវ និងការយល់ដឹងអំពីបរិស្ថាន** ................................................................. ៣២៨
មាតិកាទោល គោលនយោបាយ យុទ្ធសាស្ត្រអប់រំ ការស្រាវជ្រាវបរិស្ថាន.......................................................... ៣២៨
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ......................................................................................................................... ៣២៨
ផ្នែកទី១ វិសាលភាព និងក្រុមគោលដៅ.......................................................................................... ៣២៨
ផ្នែកទី២ គោលនយោបាយអប់រំបរិស្ថាន ....................................................................................... ៣២៨
ផ្នែកទី៣ យន្តការអប់រំបរិស្ថាន ..................................................................................................... ៣៣០

ជំពូកទី២ ការអប់រំ និងការស្រាវជ្រាវបរិស្ថាន ........ ៣៣១
ផ្នែកទី១ កម្មវិធីអប់រំ និងបណ្តុះបណ្តាលបរិស្ថាន ........ ៣៣១
ផ្នែកទី២ មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថាន ........ ៣៣៣
ផ្នែកទី៣ ការអប់រំបរិស្ថានក្នុងប្រព័ន្ធអប់រំ ........ ៣៣៤
ផ្នែកទី៤ ការស្រាវជ្រាវ និងនវានុវត្តន៍ ........ ៣៣៦
ជំពូកទី៣ ការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន ........ ៣៣៧
ផ្នែកទី១ ការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន ........ ៣៣៧
ផ្នែកទី២ ការលើកទឹកចិត្តដល់សកម្មភាពបរិស្ថាននៅគ្រឹះស្ថានសិក្សា ........ ៣៣៩
ផ្នែកទី៣ ការលើកទឹកចិត្តសកម្មភាពមេត្រីភាពបរិស្ថាន ........ ៣៤០
**គន្ថីទី៨ វិធានការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃ និងមូលនិធិផ្នែកបរិស្ថាន** ........ ៣៤២
មាតិកាទី១ វិធានការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ........ ៣៤២
ជំពូកទី១ វិធានការសេដ្ឋកិច្ច ........ ៣៤២
ជំពូកទី២ ហិរញ្ញវត្ថុ ........ ៣៤៦
មាតិកាទី២ ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាន ........ ៣៤៧
ជំពូកទី១ ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន ........ ៣៤៧
ជំពូកទី២ ការបន្តមូលនិធិបរិស្ថានដែលមានស្រាប់ និងការគ្រប់គ្រងមូលនិធិ ........ ៣៤៨
ផ្នែកទី១ ការបន្តមូលនិធិបរិស្ថានដែលមានស្រាប់ ........ ៣៤៨
ផ្នែកទី២ មូលនិធិបរិស្ថាន និងសង្គម ........ ៣៤៩
ជំពូកទី៣ ការបង្កើត និងការគ្រប់គ្រងមូលនិធិបរិស្ថាន ........ ៣៥០
ផ្នែកទី១ បរធនបាលកិច្ច ........ ៣៥០
ផ្នែកទី២ មូលនិធិសម្រាប់ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ........ ៣៥៩
ផ្នែកទី៣ មូលនិធិសម្រាប់លំហបៃតង ........ ៣៦០
ផ្នែកទី៤ មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ........ ៣៦១
ជំពូកទី៤ ហិរញ្ញប្បទានសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន ........ ៣៦៤
**គន្ថីទី៩ ការទទួលខុសត្រូវស្តារឡើងវិញ និងសំណងលើការខូចខាតបរិស្ថាន** ........ ៣៦៦
មាតិកាទោល ការស្តារឡើងវិញ និងសំណងលើការខូចខាតបរិស្ថាន ........ ៣៦៦
ជំពូកទី១ យន្តការវាយតម្លៃទំហំនៃការខូចខាតបរិស្ថាន ........ ៣៦៦

ជំពូកទី២ ការទទួលខុសត្រូវបរិស្ថាន ..... ៣៦៧
ជំពូកទី៣ ការមិនទទួលខុសត្រូវចំពោះការខូចខាតបរិស្ថាន ..... ៣៦៨
ជំពូកទី៤ សំណងការខូចខាតបរិស្ថាន ..... ៣៦៩
ជំពូកទី៥ ការរៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញ ..... ៣៧១
ជំពូកទី៦ សិទ្ធិអំណាចនៃការចេញបទបញ្ជាផ្នែករដ្ឋបាល ..... ៣៧៤
ជំពូកទី៧ ការទាមទារមកវិញនូវថ្លៃចំណាយលើការស្តារការខូចខាតបរិស្ថានឡើងវិញ ..... ៣៧៤
**គន្ថីទី១០ នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ..... ៣៧៥**
មាតិកាទី១ ការដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានចរិតលក្ខណៈរដ្ឋប្បវេណី និងរដ្ឋបាល ..... ៣៧៥
ជំពូកទី១ បណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ..... ៣៧៥
ជំពូកទី២ ភាគីនៃបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ..... ៣៧៧
ជំពូកទី៣ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ..... ៣៧៩
ជំពូកទី៤ ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្នុងប្រព័ន្ធតុលាការ ..... ៣៩២
មាតិកាទី២ ការចាត់ចែងរក្សាការពារក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ ..... ៣៩៧
មាតិកាទី៣ នីតិវិធីដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានចរិតលក្ខណៈព្រហ្មទណ្ឌ ..... ៣៩៩
ជំពូកទី១ នីតិវិធីនៃការស៊ើបអង្កេត ការស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះ ..... ៣៩៩
ជំពូកទី២ ភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ ..... ៣៩៩
មាតិកាទី៤ មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធាន ធម្មជាតិ ..... ៤០២
ជំពូកទី១ នគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ..... ៤០២
ជំពូកទី២ មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ..... ៤០៤
**គន្ថីទី១១ ទោសប្បញ្ញត្តិ ..... ៤០៦**
មាតិកាទី១ បទប្បញ្ញត្តិទូទៅ ..... ៤០៦
ជំពូកទោល ទណ្ឌកម្ម ..... ៤០៦
មាតិកាទី២ បទល្មើសពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ..... ៤១១
ជំពូកទី១ បទល្មើសពាក់ព័ន្ធនឹងការចូលរួមជាសាធារណៈ ..... ៤១២
ជំពូកទី២ បទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃ និងការអង្កេតតាមដានបរិស្ថាន ..... ៤១៣

ជំពូកទី៣ បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព ........ ៤១៨
ជំពូកទី៤ បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព ........ ៤២០
ជំពូកទី៥ បទល្មើសពាក់ព័ន្ធនឹងការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌ ធម្មជាតិ ........ ៤៣០
ជំពូកទី៦ បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ និងការបំពុល ........ ៤៣៣
ជំពូកទី៧ បទល្មើសពាក់ព័ន្ធនឹងមន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធាន ធម្មជាតិ ........ ៤៤៣
**គន្ថីទី១២ អន្តរប្បញ្ញត្តិ** ........ ៤៤៣
ជំពូកទោល អន្តរប្បញ្ញត្តិ ........ ៤៤៣
**គន្ថីទី១៣ អវសានប្បញ្ញត្តិ** ........ ៤៤៤
ជំពូកទោល អវសានប្បញ្ញត្តិ ........ ៤៤៤

# គន្ថីទី១
# បទប្បញ្ញត្តិទូទៅ
## មាតិកាទី១
## បទប្បញ្ញត្តិទូទៅ
### ជំពូកទី១
### គោលបំណង គោលដៅ និងវិសាលភាព

**មាត្រា១** ._ គោលបំណង

ក្រមនេះ មានគោលបំណងធានាពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវកិច្ចគាំពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានធម្មជាតិ ជីវៈចម្រុះ សម្បត្តិវប្បធម៌ និងការរស់នៅដោយចីរភាព ។

**មាត្រា២** ._ គោលដៅ

ក្រមនេះ មានគោលដៅ ដូចខាងក្រោម ៖

១- គាំពារបរិស្ថាន បញ្ចៀស និងកាត់បន្ថយគ្រោះមហន្តរាយ និងការខូចខាតបរិស្ថាន ។

២- ថែរក្សា ការពារ អភិរក្ស គ្រប់គ្រង និងស្តារធនធានធម្មជាតិ ជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ។

៣- លើកកម្ពស់ភាពធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងដែលមានប្រសិទ្ធភាពថាមពល និងការប្រើប្រាស់ធនធាន និងថាមពលដោយចីរភាព ។

៤- ថែរក្សា ការពារ អភិរក្ស និងលើកកម្ពស់សម្បត្តិវប្បធម៌នៃព្រះរាជាណាចក្រកម្ពុជា ។

៥- លើកកម្ពស់សុខុមាលភាពសង្គម ។

៦- លើកកម្ពស់ និងការពារសិទ្ធិរូបវន្តបុគ្គល នីតិបុគ្គល និងសមូហភាព របស់ជនជាតិដើមភាគតិចក្នុងការចូលរួមថែរក្សា ការពារ អភិរក្ស គ្រប់គ្រង និងស្តារធនធានធម្មជាតិ ។

៧- លើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ភាគី នៅក្នុងកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

៨- ដាក់បញ្ចូលនូវការយកចិត្តទុកដាក់អំពីបរិស្ថាន និងធនធានធម្មជាតិ ទៅក្នុងការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេច ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ។

៩- លើកកម្ពស់ការចូលរួមដោយតម្លាភាពរបស់ជនជាតិដើមភាគតិច និងជនងាយរងគ្រោះ និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

១០- ពង្រឹងការអនុវត្តលិខិតុបករណ៍គតិយុត្តអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

១១- អនុវត្តគោលការណ៍ច្បាប់ និងគោលនយោបាយបរិស្ថាន ដូចមានចែងនៅក្នុងក្រមនេះ ។

**មាត្រា៣** ._ វិសាលភាព

ក្រមនេះ មានវិសាលភាពអនុវត្តលើ ៖

១- រាល់សកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- គោលនយោបាយ ផែនការសកម្មភាព និងវិធានការនានាដែលពាក់ព័ន្ធនឹងបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌ ។

៣- រាល់សកម្មភាពរបស់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជនដែលធ្វើប្រតិបត្តិការទាំងក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា ដែលបង្កផលប៉ះពាល់ ឬជះឥទ្ធិពលទៅលើបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២
## គោលការណ៍ទូទៅ

**មាត្រា៤** ._ គោលការណ៍នៃការអភិវឌ្ឍន៍ដោយចីរភាព

គ្រប់សកម្មភាពអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គមទាំងអស់ ត្រូវបំពេញតម្រូវការក្នុងការអភិវឌ្ឍ និងតម្រូវការផ្នែកបរិស្ថាន របស់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត ដោយសមធម៌ និងដោយចីរភាព ដែលក្នុងនោះកិច្ចគាំពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ ជាផ្នែកដ៏ចាំបាច់នៃកិច្ចដំណើរការអភិវឌ្ឍ ហើយដែលមិនអាចចាត់ទុកជារឿងដាច់ដោយឡែកពីគ្នាបានឡើយ ។

**មាត្រា៥** ._ គោលការណ៍នៃការបញ្ចៀសការខូចខាតបរិស្ថាន និងធនធានធម្មជាតិ

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវធ្វើសកម្មភាពណាមួយ ដែលបង្ក ឬអាចបង្កការខូចខាតបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ឡើយ លើកលែងតែបុគ្គលនោះ បានចាត់វិធានការសមស្រប ក្នុងកិច្ចគាំពារបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ និងបានទប់ស្កាត់ ឬកាត់បន្ថយការខូចខាតទាំងនោះឱ្យដល់កម្រិតអប្បបរមា ។

**មាត្រា៦** ._ គោលការណ៍នៃការចូលរួមជាសាធារណៈ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលអាចទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលដោយសារការធ្វើសេចក្តីសម្រេចណាមួយទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចូលរួមផ្តល់មតិយោបល់ ឱ្យទាន់ពេលវេលា និងបន្ទាប់ពីទទួលបានព័ត៌មាន មុនពេលធ្វើសេចក្តីសម្រេច តាមរយៈដំណើរការចូលរួមពីគ្រប់បុគ្គលពាក់ព័ន្ធដោយមានតម្លាភាព និងគណនេយ្យភាព ។

**មាត្រា៧** ._ គោលការណ៍នៃការទទួលបានព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ មានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ។

រាល់ព័ត៌មានស្តីពីកិច្ចគាំពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជន ដើម្បីបង្កើតឱកាសជាអតិបរមាសម្រាប់ការចូលរួមជាសាធារណៈ នៅក្នុងការធ្វើផែនការ និងការធ្វើសេចក្តីសម្រេច ដែលបង្កផលប៉ះពាល់ដល់សង្គម និងបរិស្ថាន ។

**មាត្រា៨** ._ គោលការណ៍នៃការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ មានសិទ្ធិទទួលបាននីតិវិធីរដ្ឋបាល និងតុលាការ ឬមធ្យោបាយសមស្របដទៃទៀត ដើម្បីសម្រេចបាននូវការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ។

យន្តការដោះស្រាយវិវាទ ប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀង ត្រូវរៀបចំឡើងដើម្បីលើកកម្ពស់ការអនុវត្តច្បាប់ និងផ្តន្ទាទោសចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កការខូចខាតដល់បរិស្ថាន ធនធានធម្មជាតិ និងសង្គម និងផ្តល់សំណងសម្រាប់ការខូចខាតទាំងនោះ ។

**មាត្រា៩** ._ គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបង្កឱ្យមានការខូចខាតចំពោះបរិស្ថាន ធនធានធម្មជាតិ និងសង្គម ត្រូវទទួលបន្ទុកក្នុងការចំណាយលើការជួសជុល និងលើវិធានការទប់ស្កាត់ បញ្ចៀស និងកាត់បន្ថយការខូចខាតបរិស្ថាន ធនធានធម្មជាតិ និងសង្គម ។

**មាត្រា១០** ._ គោលការណ៍នៃការប្រុងប្រយ័ត្នជាមុន

ក្នុងករណីដែលមានការគំរាមកំហែង ឬការខូចខាតយ៉ាងធ្ងន់ធ្ងរចំពោះបរិស្ថាន ដែលមិនអាចជួសជុលឡើងវិញបាន កង្វះខាតភាពប្រាកដប្រជាផ្នែកវិទ្យាសាស្ត្រ មិនត្រូវយកមកធ្វើជាមូលហេតុក្នុងការពន្យារពេលនៃការចាត់វិធានការ ដើម្បីទប់ស្កាត់ការខូចខាតដល់បរិស្ថានបានឡើយ ។

**មាត្រា១១** ._ គោលការណ៍នៃការទប់ស្កាត់

វិធានការនៃការកាត់បន្ថយ ឬការទប់ស្កាត់ ការខូចខាតបរិស្ថាន ត្រូវធ្វើឡើងមុនពេលការខូចខាតបរិស្ថាននោះកើតឡើង ។ វិធានការនេះ ត្រូវធ្វើឡើងជាមុន ប្រសើរជាងធ្វើការជួសជុលការខូចខាត ដែលមិនអាចជួសជុលឡើងវិញបាន ។

**មាត្រា១២** ._ គោលការណ៍សមធម៌រវាងជំនាន់បច្ចុប្បន្ន និងអនាគត

សិទ្ធិក្នុងការធ្វើការអភិវឌ្ឍ ដែលអាចបង្កផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តដោយសមធម៌ ដើម្បីបំពេញតម្រូវការរបស់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត ។

**មាត្រា១៣** ._ គោលការណ៍នៃការធ្វើសេចក្ដីសម្រេចដោយផ្អែកលើភស្តុតាង

ព័ត៌មានដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន មានលក្ខណៈវិទ្យាសាស្ត្រ ឬបច្ចេកទេស និងដែលប្រមូលបានពីសហគមន៍ ចំណេះដឹងរបស់ជនជាតិដើមភាគតិច ត្រូវយកមកប្រើប្រាស់ជាមូលដ្ឋាននៃភស្តុតាង ក្នុងការធ្វើសេចក្ដីសម្រេចប្រកបដោយតម្លាភាពទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១៤** ._ គោលការណ៍សមភាពយេនឌ័រក្នុងការធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ

សមភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រីទាក់ទងនឹងការធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលបានការលើកកម្ពស់ និងការលើកទឹកចិត្ត ។

**មាត្រា១៥** ._ គោលការណ៍ប្រយោជន៍សាធារណៈ

ប្រយោជន៍សាធារណៈ ត្រូវមានឧត្តមភាពជាងប្រយោជន៍បុគ្គលឯកជន ឬនីតិបុគ្គលឯកជន នៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេច ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១៦** ._ គោលការណ៍សមាហរណកម្មផ្នែកបរិស្ថាន

គោលបំណងនៃកិច្ចគាំពារបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ត្រូវដាក់បញ្ចូលទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងការធ្វើសេចក្ដីសម្រេច ទាំងក្នុងដំណាក់កាលដំបូង និងដំណាក់កាលអនុវត្តគោលនយោបាយ និងច្បាប់ ។

**មាត្រា១៧** ._ គោលការណ៍អ្នកប្រើប្រាស់ជាអ្នកបង់ថ្លៃ

អ្នកប្រើប្រាស់ធនធានធម្មជាតិ ត្រូវបង់ថ្លៃចំណាយទាំងអស់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ ឬផលប៉ះពាល់ដែលកើតចេញពីការប្រើប្រាស់ធនធានធម្មជាតិទាំងនោះ ។

**មាត្រា១៨** ._ គោលការណ៍នៃការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់សហគមន៍ជនជាតិដើមភាគតិច

សកម្មភាព ឬគម្រោងស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃទៀតរបស់ជនជាតិដើមភាគតិច ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ជនជាតិដើមភាគតិច ។

## ជំពូកទី៣
## សមត្ថកិច្ចក្រសួង ស្ថាប័នពាក់ព័ន្ធនឹងបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា១៩** ._ ការអនុវត្តភារកិច្ច និងតួនាទី របស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត មានសិទ្ធិអំណាចក្នុងការអនុវត្តភារកិច្ច និងតួនាទីរបស់ខ្លួន ដូចមានចែងក្នុងក្រមនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យ ដែលជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ ។

ក្នុងករណីបទប្បញ្ញត្តិនៃក្រមនេះ ចែងអំពីសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ មិនស្របគ្នា ឬមានភាពមិនច្បាស់លាស់ជាមួយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យនីមួយៗផ្សេងទៀត នោះបទប្បញ្ញត្តិដែលមានចែងក្នុងក្រមនេះ ត្រូវមានអានុភាពជាង ។

**មាត្រា២០ ._** ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចធ្វើការពាក់ព័ន្ធ មានការទទួលខុសត្រូវ ដូចខាងក្រោម ៖

១- អនុវត្តបទប្បញ្ញត្តិនានានៃក្រមនេះ ។

២- ចាត់វិធានការចាំបាច់ ក្នុងការដោះដូរព័ត៌មាន ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

៣- កសាងសមត្ថភាព និងការយល់ដឹងអំពីខ្លឹមសារនៃក្រមនេះ ដល់មន្ត្រីក្រោមឱវាទ ។

៤- លើកកម្ពស់ប្រសិទ្ធភាពនៃសិទ្ធិទទួលបានព័ត៌មានបរិស្ថាន និងការចូលរួមជាសាធារណៈពាក់ព័ន្ធនឹងបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

៥- រៀបចំយន្តការដោះស្រាយវិវាទ និងផ្តល់ដំណោះស្រាយចំពោះបណ្តឹងពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ។

៦- គ្រប់គ្រងធនធានធម្មជាតិ ក្នុងករណីដែលក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតផ្តល់អំណាចឱ្យ ។

៧- សម្របសម្រួលចំពោះការរៀបចំផែនការ ការដាក់ចេញកម្មវិធី ការធ្វើសេចក្តីសម្រេច និងការអនុវត្តការងារពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធានាថាគ្រប់សកម្មភាពទាំងអស់ឆ្លើយតបទៅនឹងគោលបំណងនៃក្រមនេះ ។

## មាតិកាទី២

## ការចូលរួមជាសាធារណៈ

## ជំពូកទី១

## សិទ្ធិ និងការការពារសម្រាប់ការចូលរួមជាសាធារណៈ

**មាត្រា២១** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះសេចក្តីសម្រេច វិធានការ កិច្ចព្រមព្រៀង គោលនយោបាយ កម្មវិធី គម្រោង ផែនការ សកម្មភាព ការឯកភាព ការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងក្រមនេះ ។

**មាត្រា២២** ._ សិទ្ធិក្នុងការចូលរួមជាសាធារណៈ

រូបវន្តបុគ្គល ឬនីតិបុគ្គល មានសិទ្ធិក្នុងការចូលរួមជាសាធារណៈ តាមរយៈសកម្មភាព ដូចខាងក្រោម ៖

១- រាយការណ៍ទៅកាន់អាជ្ញាធរពាក់ព័ន្ធ និងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការធ្វើសេចក្តីសម្រេចណាមួយ ដែលអាចនឹងមានផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានធម្មជាតិ ។

២- លើកឡើងនូវសំណួរ ស្នើឱ្យមានការបកស្រាយ ធ្វើការតវ៉ា និងចូលរួមពិភាក្សា អំពីសកម្មភាព ឬសេចក្តីសម្រេចណាមួយ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ ។

៣- ដាក់ពាក្យបណ្តឹង ឬប្តឹងតវ៉ានឹងសកម្មភាព ឬសេចក្តីសម្រេច ស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងគន្ថីទី១០ នៃក្រមនេះ ។

**មាត្រា២៣** ._ សិទ្ធិទទួលបានការការពារចំពោះការគំរាមកំហែង និងការសងសឹក

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលអនុវត្តសិទ្ធិក្នុងការចូលរួមជាសាធារណៈ ដូចមានចែងក្នុងមាត្រា២២ខាងលើ ត្រូវរួចផុតពីការគំរាមកំហែង និងការសងសឹកតាមគ្រប់មធ្យោបាយនានា ។ រាល់សកម្មភាពក្នុងការចូលរួមជាសាធារណៈដោយអហិង្សា ដែលស្របតាមមាតិកានេះ មិនត្រូវទទួលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬប្រឈមនឹងបណ្តឹងទាមទារផ្នែករដ្ឋប្បវេណីណាមួយឡើយ ។

សិទ្ធិក្នុងការទទួលបានការការពារពីការគំរាមកំហែង ឬការសងសឹក ចំពោះការចូលរួមជាសាធារណៈ មិនត្រូវរួចផុតពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬកំហុសផ្នែករដ្ឋប្បវេណីឡើយ ក្នុងករណីដែលបុគ្គលដែលបានចូលរួមជាសាធារណៈប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ដូចមានចែងក្នុងក្រមនេះ ឬ ក្រមព្រហ្មទណ្ឌ ឬ ក្រមរដ្ឋប្បវេណី ឬ ច្បាប់ពាក់ព័ន្ធដទៃទៀតជាធរមាន ។

**មាត្រា២៤**._ លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ

មុននឹងធ្វើសេចក្តីសម្រេច ឬឯកភាពលើបញ្ហាណាមួយពាក់ព័ន្ធនឹងក្រមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងម្ចាស់គម្រោងទាំងអស់ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវ សម្រាប់ការចូលរួមជាសាធារណៈដូចខាងក្រោម ៖

១- អ្នកពាក់ព័ន្ធត្រូវទទួលបានការជូនដំណឹង និងពេលវេលាគ្រប់គ្រាន់ សម្រាប់ចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចដែលពាក់ព័ន្ធ ។

២- អ្នកពាក់ព័ន្ធទាំងអស់ត្រូវទទួលបានព័ត៌មានចាំបាច់ ។ ការផ្តល់ព័ត៌មានទាំងនោះត្រូវយកចិត្តទុកដាក់អំពីភាសាដែលអាចយល់បាន និងវប្បធម៌របស់អ្នកពាក់ព័ន្ធ ។

៣- ចំណេះដឹងខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ និងចំណេះដឹងលក្ខណៈប្រពៃណីនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវយកជាមូលដ្ឋានក្នុងការបង្កើតគម្រោង ផែនការសកម្មភាព និងការធ្វើសេចក្តីសម្រេច ។

៤- កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវយកចិត្តទុកដាក់អំពីតម្រូវការ និងតម្លៃ របស់អ្នកពាក់ព័ន្ធ ។

៥- អ្នកពាក់ព័ន្ធត្រូវទទួលបានពេលវេលាសមស្រប និងត្រឹមត្រូវ ដើម្បីធ្វើការវាយតម្លៃ និងឆ្លើយតបចំពោះព័ត៌មានទាក់ទងនឹងគម្រោងស្នើសុំ សកម្មភាព ផែនការ ឬសេចក្តីសម្រេចណាមួយ ។

៦- កម្រិតនៃការចូលរួមជាសាធារណៈ ត្រូវស្របតាមកម្រិតនៃការចាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ ។

៧- ដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានភាពបត់បែន និងអាចកែសម្រួលបាន ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកដែលសមហេតុផលរបស់អ្នកពាក់ព័ន្ធ ។

៨- កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានលក្ខណៈបត់បែន និងអាចសម្របសម្រួលបាន ស្របតាមការរំពឹងទុករបស់អ្នកពាក់ព័ន្ធ ។

៩- គ្រប់មតិយោបល់របស់សាធារណជន ត្រូវទទួលបានការពិចារណានៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច ។ ការទទួលយក ឬ បដិសេធចំពោះមតិយោបល់ខាងលើនេះ ត្រូវបញ្ជាក់ហេតុផលសមរម្យ ។

**មាត្រា២៥**._ នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមសាធារណៈ ។ ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ទាក់ទងនឹងវិស័យនីមួយៗរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៅក្នុងមាតិកានេះ ។

## ជំពូកទី២
## ការចូលរួមជាសាធារណៈរបស់សហគមន៍ជនជាតិដើមភាគតិច

**មាត្រា២៦** ._ ការពិគ្រោះយោបល់របស់សហគមន៍ជនជាតិដើមភាគតិច

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិច លើគោលនយោបាយ ផែនការ ឬកម្មវិធី ដែលអាចប៉ះពាល់ដោយផ្ទាល់ចំពោះ ដីធ្លី និងធនធាននានារបស់ជនជាតិដើមភាគតិច ។

**មាត្រា២៧** ._ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច មិនត្រូវឯកភាពលើគម្រោងស្នើសុំ ដែលអាចប៉ះពាល់ដោយផ្ទាល់ចំពោះដីធ្លី និងធនធានរបស់ជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយបានឡើយ ។ ការយល់ព្រមរបស់ជនជាតិដើមភាគតិចត្រូវធ្វើឡើងដោយមតិភាគច្រើនដាច់ខាតនៃជនជាតិដើមភាគតិចដែលអាចទទួលរងផលប៉ះពាល់ពីគម្រោងស្នើសុំ ឬការធ្វើសេចក្តីសម្រេចនេះ ។

**មាត្រា២៨** ._ ការចូលរួមរបស់ជនជាតិដើមភាគតិច

ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ឱកាសឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនជាតិដើមភាគតិច ដែលអាចទទួលរងផលប៉ះពាល់ពីសេចក្តីសម្រេចទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ។

ការចូលរួមត្រូវធ្វើឡើងដោយគ្មានការគំរាមកំហែង ការបោកបញ្ឆោត ឬការបង្ខិតបង្ខំ និងត្រូវផ្តល់ឱកាសឱ្យមានការចូលរួមឱ្យបានទាន់ពេលវេលា ហើយអ្នកចូលរួមត្រូវទទួលបានការជូនដំណឹងអំពីព័ត៌មានពាក់ព័ន្ធក្នុងទម្រង់ និងភាសាដែលសមស្រប ។

**មាត្រា២៩ ._** នីតិវិធីនៃការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច

នីតិវិធីនៃការពិគ្រោះយោបល់ ការចូលរួម និងយល់ព្រមចំពោះការធ្វើសេចក្តីសម្រេច ដែលប៉ះពាល់ចំពោះដីធ្លី និងធនធានរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី៣
## វិធានការកាត់បន្ថយផលប៉ះពាល់

**មាត្រា៣០ ._** លក្ខខណ្ឌតម្រូវសម្រាប់វិធានការកាត់បន្ថយផលប៉ះពាល់

ក្នុងករណីដែលការធ្វើសេចក្តីសម្រេចណាមួយ អាចបង្កឱ្យមានផលប៉ះពាល់ដល់សហគមន៍មូលដ្ឋាន ឬសហគមន៍ជនជាតិដើមភាគតិច ក្រសួង ស្ថាប័នពាក់ព័ន្ធ ឬម្ចាស់គម្រោង ត្រូវរៀបចំវិធានការកាត់បន្ថយផលប៉ះពាល់ ដោយពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ឬជនជាតិដើមភាគតិច ដើម្បីកំណត់ឱ្យច្បាស់ពីផលប៉ះពាល់នោះ និងយល់ព្រមទៅលើវិធានការណ៍កាត់បន្ថយផលប៉ះពាល់ និងការចាត់ចែងបែងចែកផលប្រយោជន៍ ។

វិធានការកាត់បន្ថយត្រូវមានលក្ខណៈសមស្រប មាននិរន្តរភាព និងមិនមានការរើសអើង និងត្រូវយកចិត្តទុកដាក់ចំពោះជនងាយរងគ្រោះ និងជនងាយរងហានិភ័យខ្ពស់ពីផលប៉ះពាល់ដែលអាចកើតឡើងពីការធ្វើសេចក្តីសម្រេចនោះ ។

**មាត្រា៣១ ._** ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត

ក្នុងករណីដែលតម្រូវឱ្យមានការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងស្នើសុំ នោះម្ចាស់គម្រោង ឬក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវផ្តល់ឱកាសឱ្យសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ចូលរួមក្នុងការពិចារណាអំពីជម្រើសផ្សេងៗ ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមានូវការតាំងទីលំនៅថ្មី ដោយគ្មានការគំរាមកំហែង កេងចំណេញ ឬការបង្ខិតបង្ខំ ។

**មាត្រា៣២ ._** ការៀបចំផែនការតាំងទីលំនៅថ្មី

ក្នុងករណីដែលការតាំងទីលំនៅថ្មី មិនអាចជៀសវាងបាន ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ឱកាសឱ្យសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ចូលរួមរៀបចំផែនការតាំងទីលំនៅថ្មី ដើម្បី ៖

១- កាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ជាអវិជ្ជមាននៃការតាំងទីលំនៅថ្មី ។

២- ទទួលបានឱកាសក្នុងការកសាងជីវភាពរស់នៅនាពេលអនាគត និងសេវាសង្គមស្មើ ឬប្រសើរជាងលក្ខខណ្ឌមុនពេលធ្វើការតាំងទីលំនៅថ្មី ។

៣- ទទួលសំណងដោយយុត្តិធម៌ សមធម៌ និងអាចទទួលយកបាន ស្របតាមតម្លៃទីផ្សារចំពោះទ្រព្យដែលបាត់បង់ និងផលប៉ះពាល់ទៅលើជីវភាពរស់នៅ ពីម្ចាស់គម្រោង ឬក្រសួងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា៣៣** ._ ការអនុញ្ញាតឱ្យត្រឡប់មកកាន់ទីតាំងដើម

ក្នុងករណីដែលមូលហេតុនៃការតាំងទីលំនៅថ្មីនោះលែងមានអត្ថិភាព ម្ចាស់គម្រោង ឬក្រសួងស្ថាប័នពាក់ព័ន្ធ អាចអនុញ្ញាតឱ្យសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រឡប់ទៅកាន់ដីធ្លីដែលពួកគាត់បានកាន់កាប់ជាលក្ខណៈប្រពៃណី ឬតាមទំនៀមទម្លាប់របស់ខ្លួនវិញ ។

## មាតិកាទី៣
## សិទ្ធិទទួលបានព័ត៌មានបរិស្ថាន
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៣៤** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តលើព័ត៌មានទាំងអស់ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ដែលត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៣៥** ._ កាតព្វកិច្ចក្នុងការបើកបង្ហាញ និងដាក់ព័ត៌មានឱ្យសាធារណជនអាចស្វែងរកបាន

គ្រប់ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបើកបង្ហាញព័ត៌មានដូចមានចែងក្នុងមាត្រា ៣៧ នៃក្រមនេះ ឱ្យសាធារណជនអាចស្វែងរកបាន មុនពេលចេញ ៖

១- សេចក្តីសម្រេច ឬការឯកភាពណាមួយ ដែលពាក់ព័ន្ធទៅនឹងបរិស្ថាន ឬធនធានធម្មជាតិ ។

២- វិធានការផ្នែករដ្ឋបាល និងវិធានការច្បាប់ ។

៣- កិច្ចព្រមព្រៀងផ្នែកបរិស្ថាន ។

៤- សំណើគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ។

៥- កម្មវិធី ផែនការ សកម្មភាព ឬសេចក្តីសម្រេចផ្សេងទៀតស្របតាមក្រមនេះ ។

ទម្រង់បែបបទ និងនីតិវិធីនៃការបើកបង្ហាញព័ត៌មាន ត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ។

**មាត្រា៣៦** ._ សិទ្ធិស្នើសុំព័ត៌មាន

បុគ្គលគ្រប់រូបមានសិទ្ធិស្នើសុំព័ត៌មានពីក្រសួង ស្ថាប័ន និងម្ចាស់គម្រោង ស្របតាមមាត្រា៣៧នៃក្រមនេះ ។

**មាត្រា៣៧** ._ ព័ត៌មានពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ

ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន និងធនធានធម្មជាតិ មានដូចខាងក្រោម ៖

១- ស្ថានភាពនៃធាតុផ្សំរបស់បរិស្ថាន រួមមាន ខ្យល់ បរិយាកាស ទឹក ដី ផ្ទៃដី តំបន់ទេសភាព និងតំបន់ធម្មជាតិ អាកាសធាតុ ជីវៈចម្រុះ និងធាតុផ្សំនៃជីវៈចម្រុះ ។

២- កត្តានានាដែលប៉ះពាល់ ឬអាចប៉ះពាល់ដល់ធាតុផ្សំទាំងឡាយនៃបរិស្ថាន ។ កត្តាទាំងនេះរួមមាន សារធាតុ ថាមពល សំឡេង វិទ្យុសកម្ម សំណល់ ការបំភាយឧស្ម័ន ការបង្ហូរចេញ និងការបញ្ចេញចោលចូលទៅក្នុងបរិស្ថាន ។

៣- វិធានការដែលប៉ះពាល់ ឬអាចប៉ះពាល់ ឬកាត់បន្ថយការប៉ះពាល់ដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ខាងលើ ។ វិធានការទាំងនេះ រួមមាន គោលនយោបាយ ច្បាប់ ផែនការ កម្មវិធី កិច្ចព្រមព្រៀងផ្នែកបរិស្ថាន និងសកម្មភាពនានា ។

៤- សនិទានភាពសម្រាប់សេចក្តីសម្រេចលើវិធានការដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើនេះ រួមមាន ការវិភាគអំពីវដ្តជីវិត ការវាយតម្លៃបរិស្ថាន ការវាយតម្លៃអំពីភាពងាយរងគ្រោះ និងការវិភាគអំពីតម្លៃនៃការខូចខាត និងផលចំណេញផ្នែកសេដ្ឋកិច្ច ។

៥- ព័ត៌មានពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

៦- ទំនាក់ទំនងជាលក្ខណៈបុគ្គល និងធុរកិច្ចរបស់ម្ចាស់គម្រោងជាមួយសហគ្រាសពាណិជ្ជកម្ម ឬស្ថាប័នផ្តល់កម្ចីជាតិ ឬអន្តរជាតិដទៃទៀត ដែលគាំទ្រដល់គម្រោង ឬសកម្មភាពដែលពាក់ព័ន្ធ តាមរយៈកម្ចីឥណទាន ឬជំនួយផ្នែកបច្ចេកទេស ។

៧- ការមិនអនុលោមតាម ឬការបំពានច្បាប់បរិស្ថាន គោលនយោបាយ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀង ។

៨- របាយការណ៍អង្កេតតាមដាន និងសវនកម្មបរិស្ថាន ។

៩- លិខិតអនុញ្ញាត និងការឯកភាពដែលតម្រូវឱ្យមាន ស្របតាមក្រមនេះ និងលក្ខខណ្ឌនានាដែលភ្ជាប់ទៅនឹងលិខិតអនុញ្ញាត និងការឯកភាពទាំងនេះ ។

១០- ព័ត៌មានទាំងឡាយស្តីពីហានិភ័យនៃអាកាសធាតុ និងបរិស្ថាន ដែលប៉ះពាល់ដល់ស្ថានភាពនៃសុខភាព និងសុវត្ថិភាពរបស់មនុស្ស ទីតាំងបេតិកភណ្ឌវប្បធម៌ និងរចនាសម្ព័ន្ធនៃសំណង់នានា ។

១១- របាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តវិធានការ ដូចមានចែងក្នុងចំណុចទី៣ខាងលើ និងការអនុវត្តកិច្ចព្រមព្រៀងបរិស្ថានពហុភាគី ។

១២- ព័ត៌មានពាក់ព័ន្ធនឹងការធ្វើចំណាត់ការនានា ទាំងនីតិវិធីរដ្ឋបាល និងតុលាការពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន ស្របតាមច្បាប់ជាធរមាន ។

១៣- រាល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៣៨** ._ ព័ត៌មានសាធារណៈ

ព័ត៌មានពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងមាត្រា៣៧ នៃមាតិកានេះ ដែលត្រូវផ្តល់ជូនទៅម្ចាស់គម្រោង ឬអង្គភាពរាជរដ្ឋាភិបាលដែលពាក់ព័ន្ធស្របតាមក្រមនេះ ត្រូវកំណត់ថាជាព័ត៌មានសាធារណៈ លើកលែងតែព័ត៌មាននោះជាព័ត៌មានសម្ងាត់ ដូចមានចែងក្នុងជំពូកទី៣ នៃមាតិកានេះ ។

**មាត្រា៣៩** ._ សិទ្ធិក្នុងការដាក់ពាក្យបណ្តឹង

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមិនពេញចិត្តចំពោះសេចក្ដីសម្រេចដែលធ្វើឡើងដោយម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ទាក់ទងនឹងការផ្ដល់ព័ត៌មានបរិស្ថាន ឬការកំណត់អំពីភាពសម្ងាត់នៃព័ត៌មានបរិស្ថានណាមួយ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ា តាមយន្តការដូចមានចែងក្នុងគន្ថីទី១០ នៃក្រមនេះ ។

## ជំពូកទី២
## ការផ្ដល់ព័ត៌មានដោយរាជរដ្ឋាភិបាល
## ផ្នែកទី១
## ការផ្ដល់ព័ត៌មានជាសាធារណៈ

**មាត្រា៤០** ._ ការផ្ដល់ព័ត៌មានជាសាធារណៈ

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្ដល់ព័ត៌មានជាសាធារណៈ ដូចមានចែងក្នុងមាត្រា៣៧នៃក្រមនេះ ។

**មាត្រា៤១** ._ ប្រព័ន្ធ និងនីតិវិធីនៃការផ្ដល់ព័ត៌មានជាសាធារណៈ

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវបង្កើតប្រព័ន្ធផ្ដល់ព័ត៌មានជាសាធារណៈ ដល់សាធារណជន ដូចមានចែងក្នុងក្រមនេះ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីនីតិវិធីផ្ដល់ព័ត៌មានជាសាធារណៈ នៅលើប្រព័ន្ធផ្ដល់ព័ត៌មានជាសាធារណៈ ។

**មាត្រា៤២** ._ នីតិវិធីនៃការសំយោគព័ត៌មាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នសមត្ថកិច្ច ដើម្បីរៀបចំនីតិវិធីនៃការសំយោគព័ត៌មានទាំងឡាយ ដែលទទួលបានពីប្រភពផ្សេងៗ និងត្រូវផ្ដល់ព័ត៌មានសំយោគនោះដល់សាធារណជន និងអ្នកធ្វើសេចក្ដីសម្រេចនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

## ផ្នែកទី២
## បញ្ជីព័ត៌មានបរិស្ថានជាតិ

**មាត្រា៤៣** ._ ការរៀបចំបញ្ជីព័ត៌មានបរិស្ថានជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំបញ្ជីព័ត៌មានបរិស្ថានជាតិ ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ និងសកម្មភាពដែលប៉ះពាល់ដល់ស្ថានភាពបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៤** ._ ប្រភេទព័ត៌មាន នៃបញ្ជីព័ត៌មានបរិស្ថានជាតិ

បញ្ជីព័ត៌មានបរិស្ថានជាតិនេះ ត្រូវដាក់បញ្ចូលនូវព័ត៌មានទាំងអស់ដែលផ្តល់ឱ្យដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ស្របតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ ។

ប្រភេទព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ រួមមាន ស្ថិតិ របាយការណ៍ និងព័ត៌មានភូមិសាស្ត្រស្តីពីបរិស្ថាន ស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងធនធានធម្មជាតិ សកម្មភាពអភិវឌ្ឍន៍ និងសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ជាអាទិ៍ ។

**មាត្រា៤៥** ._ ការទទួលបានព័ត៌មានជាសាធារណៈ ពីបញ្ជីព័ត៌មានបរិស្ថានជាតិ

បញ្ជីព័ត៌មានបរិស្ថានជាតិ ជាព័ត៌មាន ដែលសាធារណជនអាចស្វែងរកបាន លើកលែងតែព័ត៌មានទាំងឡាយណា ដែលជាព័ត៌មានសម្ងាត់ សម្រាប់ការការពារដល់ប្រភេទសត្វ និងរុក្ខជាតិព្រៃ ឬ បេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីនេះ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តល់ការបកស្រាយ និងការពន្យល់ជាលាយលក្ខណ៍អក្សរជាក់លាក់ ។

**មាត្រា៤៦** ._ នីតិវិធីប្រមូល និងចែកចាយព័ត៌មានពាក់ព័ន្ធនឹងបញ្ជីព័ត៌មានបរិស្ថានជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីប្រមូល និងចែកចាយព័ត៌មានដែល

ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបានតាមរយៈបញ្ជីព័ត៌មានបរិស្ថានជាតិពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

## ផ្នែកទី៣
## បញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ

**មាត្រា៤៧** ._ ការរៀបចំបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ ។

**មាត្រា៤៨** ._ ប្រភេទលិខិតអនុញ្ញាត

បញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ស្របតាមក្រមនេះ មានដូចខាងក្រោម ៖

១- លិខិតអនុញ្ញាត ។

២- អាជ្ញាប័ណ្ណ ។

៣- លិខិតឯកភាព ។

**មាត្រា៤៩** ._ ការស្វែងរកបាននូវបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិរបស់សាធារណជន

បញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៥០** ._ នីតិវិធីផ្សព្វផ្សាយព័ត៌មានអំពីបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីផ្សព្វផ្សាយព័ត៌មានអំពីបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ ។

## ផ្នែកទី៤
## បញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ

**មាត្រា៥១** ._ ការរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ ។

**មាត្រា៥២** ._ ប្រភេទនៃសវនកម្មបរិស្ថាន

បញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ ត្រូវរាប់បញ្ចូលគ្រប់សវនកម្មដែលតម្រូវឱ្យធ្វើលើគ្រប់សកម្មភាព ឬការអភិវឌ្ឍនានា ដូចមានចែងក្នុងក្រមនេះ និងរាល់លក្ខខណ្ឌ ដូចមានភ្ជាប់ទៅនឹងលិខិតអនុញ្ញាត ។

**មាត្រា៥៣** ._ ភាពអាចស្វែងរកបានជាសាធារណៈនៃបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ

បញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៥៤** ._ នីតិវិធីផ្សព្វផ្សាយបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីនីតិវិធីផ្សព្វផ្សាយព័ត៌មាន អំពីបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ ។

## ជំពូកទី៣
## ព័ត៌មានសម្ងាត់

**មាត្រា៥៥** ._ សិទ្ធិស្នើសុំឱ្យមានការកំណត់ជាព័ត៌មានសម្ងាត់

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលតម្រូវឱ្យផ្ដល់ព័ត៌មានពាក់ព័ន្ធដូចមានចែងក្នុងមាត្រា៣៧ នៃក្រមនេះ មានសិទ្ធិស្នើសុំទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់ទុកព័ត៌មានមួយចំនួន ឬព័ត៌មានទាំងអស់ ជាព័ត៌មានសម្ងាត់ ។

ការស្នើសុំឱ្យរក្សាភាពសម្ងាត់នេះ ត្រូវបញ្ជាក់អំពីមូលហេតុ ដែលចាត់ទុកព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ។

**មាត្រា៥៦** ._ លក្ខណៈវិនិច្ឆ័យអប្បបរមាសម្រាប់ព័ត៌មានសម្ងាត់

ការស្នើសុំចាត់ទុកព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ត្រូវបង្ហាញថាការខូចខាតដែលកើតឡើងដោយសារការបង្ហាញព័ត៌មាននោះជាសាធារណៈ មានទំហំធំជាងផលប្រយោជន៍សាធារណៈដែលត្រូវការពារ ។

**មាត្រា៥៧** ._ ការកំណត់អំពីព័ត៌មានសម្ងាត់

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសម្រេចយល់ព្រម ឬបដិសេធលើសំណើសុំចាត់ទុកព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ដោយត្រូវបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ ។ ការធ្វើសេចក្តីសម្រេចនេះ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

នីតិវិធី និងលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់ព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី៤
## ការស្នើសុំព័ត៌មាន

**មាត្រា៥៨** ._ សិទ្ធិស្នើសុំព័ត៌មានសាធារណៈ

រូបវន្តបុគ្គល ឬនីតិបុគ្គល មានសិទ្ធិស្នើសុំព័ត៌មានពីម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា៣៧ នៃក្រមនេះ លើកលែងតែព័ត៌មាននោះ ជាព័ត៌មានសម្ងាត់ ។

**មាត្រា៥៩** ._ លក្ខខណ្ឌក្នុងការបដិសេធសំណើដោយក្រសួង ស្ថាប័នពាក់ព័ន្ធ

ក្រសួង ស្ថាប័នពាក់ព័ន្ធ មានសិទ្ធិបដិសេធការស្នើសុំព័ត៌មាន ក្នុងករណី ដូចខាងក្រោម ៖

១- មិនមានព័ត៌មានដែលបានស្នើសុំ ។

២- សំណើសុំមិនមានបញ្ជាក់ហេតុផលត្រឹមត្រូវ ។

៣- សំណើសុំមានលក្ខណៈទូទៅពេក ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ មិនត្រូវបដិសេធសំណើសុំព័ត៌មាន ក្នុងករណីដូចខាងក្រោម ៖

១- ព័ត៌មានដែលបានស្នើសុំនោះធ្លាប់ត្រូវបានផ្តល់ពីមុនរួចហើយ ។

២- ព័ត៌មានដែលបានស្នើសុំនោះ មិនទាន់ចាត់ទុកថា ជាព័ត៌មានសម្ងាត់ ។

ក្នុងករណីក្រសួង ស្ថាប័នពាក់ព័ន្ធ បដិសេធសំណើសុំបង្ហាញព័ត៌មាន ដូចមានចែងក្នុងមាត្រានេះ ក្រសួង ស្ថាប័ននោះ ត្រូវបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរទៅកាន់អ្នកស្នើសុំ ។

**មាត្រា៦០** ._ លក្ខខណ្ឌក្នុងការបដិសេធសំណើដោយម្ចាស់គម្រោង

ម្ចាស់គម្រោងអាចបដិសេធចំពោះសំណើសុំបង្ហាញព័ត៌មាន ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

១- គ្មានព័ត៌មានដែលបានស្នើសុំ ។

២- សំណើសុំមិនមានបញ្ជាក់ហេតុផលត្រឹមត្រូវ ។

៣- សំណើសុំមានលក្ខណៈទូទៅពេក ។

ម្ចាស់គម្រោង មិនត្រូវបដិសេធសំណើសុំព័ត៌មាន ក្នុងករណីដូចខាងក្រោម ៖

១- ព័ត៌មានដែលបានស្នើសុំនោះធ្លាប់ត្រូវបានផ្តល់ពីមុនរួចហើយ ។

២- ឬព័ត៌មានដែលបានស្នើសុំនោះ មិនទាន់ចាត់ទុកថាជាព័ត៌មានសម្ងាត់ ។

ក្នុងករណីម្ចាស់គម្រោងបដិសេធសំណើសុំបង្ហាញព័ត៌មាន ដូចមានចែងក្នុងមាត្រានេះ ម្ចាស់គម្រោងត្រូវបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរទៅកាន់អ្នកស្នើសុំ ។

**មាត្រា៦១** ._ នីតិវិធីស្នើសុំព័ត៌មាន

ក្រសួង ស្ថាប័នពាក់ព័ន្ធអាចរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីស្នើសុំព័ត៌មាន ។

នីតិវិធីស្នើសុំព័ត៌មាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី៥
## មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ និងរបាយការណ៍បរិស្ថានជាតិ
### ផ្នែកទី១
### មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ

**មាត្រា៦២** ._ ការបង្កើតមជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតមជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៦៣** ._ ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ

ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ មានដូចខាងក្រោម ៖

១- គ្រប់គ្រងបញ្ជីព័ត៌មានបរិស្ថានជាតិ ដោយថែរក្សា និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងទទួលព័ត៌មានពាក់ព័ន្ធមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

២- មានមុខងារក្នុងការសម្រិតសម្រាំងស្ថិតិ ទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី និងព័ត៌មានផែនទី ដែលផ្តល់ឱ្យដោយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត រៀបចំ និងរក្សាបញ្ជីទិន្នន័យ ព័ត៌មានសម្រាប់ទំនាក់ទំនង និងបែបបទក្នុងសម្រាប់ការស្នើសុំទិន្នន័យ ។

៣- ធ្វើការវិភាគទិន្នន័យ ឬព័ត៌មានដែលប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

៤- ចងក្រង និងបញ្ចូលទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី និងរបាយការណ៍ពាក់ព័ន្ធនឹងការកំណត់ផែនទីបរិស្ថាន និងធនធានធម្មជាតិ ដែលរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធទៅក្នុងបញ្ជីព័ត៌មានបរិស្ថានជាតិ ។

៥- រៀបចំស្តង់ដារនានាសម្រាប់ការប្រមូល ការគ្រប់គ្រង ការវិភាគ និងការបែងចែកព័ត៌មានភូមិសាស្ត្រនៃការប្រើប្រាស់ដី ។

៦- កំណត់ទម្រង់ស្តង់ដារបច្ចេកទេសសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ទិន្នន័យ ។

៧- កំណត់ទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី ដោយមានការធានាគុណភាព និងដោយភ្ជាប់មកជាមួយនូវបណ្តុំទិន្នន័យដែលមានស្រាប់ ។

៨- ប្រមូលទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី និងទិន្នន័យពាក់ព័ន្ធនឹងវិស័យជាក់លាក់ណាមួយ ។ ការប្រមូលនេះ មិនត្រូវជាន់គ្នានឹងព័ត៌មាន ឬទិន្នន័យ ក្នុងចំណោមក្រសួង ស្ថាប័ននានាឡើយ ។

**មាត្រា៦៤** ._ ការទទួលបានព័ត៌មានជាសាធារណៈ ពីបញ្ជីព័ត៌មានបរិស្ថានជាតិ

ទិន្នន័យទាំងអស់ ដែលរៀបចំដោយមជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន លើកលែងតែទិន្នន័យ ដែលចាត់ទុកជាព័ត៌មានសម្ងាត់ សម្រាប់ការពារប្រភេទសត្វ និងរុក្ខជាតិព្រៃ ឬបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ។ ក្នុងករណីនេះ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តល់ការបកស្រាយ និងការពន្យល់ជាលាយលក្ខណ៍អក្សរជាក់លាក់ ។

**មាត្រា៦៥** ._ ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា

មជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ត្រូវទទួលខុសត្រូវ ដូចខាងក្រោម ៖

១- ផលិតទិន្នន័យ ព័ត៌មាន និងផែនទីព្រមទាំងផ្សព្វផ្សាយ និងចែករំលែកនូវព័ត៌មានទាំងនេះ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសម្រួលដល់ការបំពេញតាមតួនាទី និងភារកិច្ចពាក់ព័ន្ធទៅនឹងការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងកិច្ចគាំពារបរិស្ថានប្រកបដោយប្រសិទ្ធភាព ។

២- ផលិតទិន្នន័យ ព័ត៌មាន និងផែនទីប្រើប្រាស់ សម្រាប់ការអប់រំ និងការផ្សព្វផ្សាយជាសាធារណៈ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ កិច្ចគាំពារបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ។

៣- បង្កើតនូវនីតិវិធីនៃការគ្រប់គ្រង និងធានាបាននូវគុណភាពទិន្នន័យ និងផែនទីដែលផលិតដោយមជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ ។

៤- ផ្តល់ការថែទាំ ការប្រើប្រាស់ និងការធ្វើបច្ចុប្បន្នភាព នូវប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មានភូមិសាស្ត្រ ដែលបង្ហោះដោយមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ។

៥- លើកកម្ពស់ និងគាំទ្រកិច្ចសហប្រតិបត្តិការក្នុងការបង្កើតសំណុំទិន្នន័យ និងការវិភាគ និងការប្រើប្រាស់ទៅលើទិន្នន័យ និងព័ត៌មានភូមិសាស្ត្រក្នុងចំណោមក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ផ្នែកទី២
## របាយការណ៍បរិស្ថានជាតិ

**មាត្រា៦៦** ._ របាយការណ៍បរិស្ថានជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំរបាយការណ៍បរិស្ថានជាតិរៀងរាល់ ៥ (ប្រាំ) ឆ្នាំ ម្តង ដើម្បីបង្ហាញពីស្ថានភាព និងលក្ខខណ្ឌបរិស្ថានក្នុងព្រះរាជាណាចក្រកម្ពុជា និងភាពទាក់ទងរវាងលក្ខខណ្ឌបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ។ របាយការណ៍ បរិស្ថានជាតិ ត្រូវដាក់បញ្ចូលនូវព័ត៌មានបរិស្ថានពាក់ព័ន្ធទាំងអស់ និងត្រូវវាយតម្លៃការអនុវត្តគោលនយោបាយបរិស្ថាន និងច្បាប់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចែករំលែកព័ត៌មានពាក់ព័ន្ធនឹងសូចនាករបរិស្ថាន ឬសន្ទស្សន៍ ដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ បានយកមកប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍បរិស្ថានជាតិ ។

**មាត្រា៦៧** ._ ការរៀបចំ និងការផ្សព្វផ្សាយរបាយការណ៍បរិស្ថានជាតិ

របាយការណ៍បរិស្ថានជាតិ ត្រូវរៀបចំរៀងរាល់៥ (ប្រាំ) ឆ្នាំ ម្តង និងត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ខ្លឹមសារ និងលក្ខខណ្ឌទម្រង់នៃរបាយការណ៍បរិស្ថានជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៦៨** ._ របាយការណ៍បរិស្ថានរាជធានី ខេត្ត

របាយការណ៍បរិស្ថានរាជធានី ខេត្ត ត្រូវរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសមត្ថកិច្ច ។ របាយការណ៍បរិស្ថានរាជធានី ខេត្ត ត្រូវយកមកប្រើជាមូលដ្ឋានព័ត៌មានសម្រាប់ការរៀបចំរបាយការណ៍បរិស្ថានជាតិ ។

នីតិវិធីសម្រាប់ការរៀបចំ និងខ្លឹមសារនៃរបាយការណ៍បរិស្ថានរាជធានី ខេត្ត ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## គន្លីទី២

## ការវាយតម្លៃបរិស្ថាន

### មាតិកាទី១

### ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៦៩** ._ ក្របខ័ណ្ឌនៃការវាយតម្លៃបរិស្ថាន

រាល់ការរៀបចំគោលនយោបាយ ផែនការ និងកម្មវិធីរបស់រាជរដ្ឋាភិបាល ចាំបាច់ត្រូវដាក់បញ្ចូលការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៧០** ._ ការទទួលខុសត្រូវ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវដូចខាងក្រោម ៖

១- កំណត់វិស័យអាទិភាព ដែលតម្រូវឱ្យមានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

២- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

៣- ធ្វើការពិនិត្យ និងសម្រេចលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

៤- កំណត់គោលការណ៍ណែនាំសម្រាប់រៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

## ជំពូកទី២
## នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

**មាត្រា៧១** ._ វិសាលភាពនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវធ្វើឡើងលើគោលនយោបាយ ផែនការ និងកម្មវិធីសម្រាប់វិស័យអាទិភាពមានជាអាទិ៍ ឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូរគមនាគមន៍ និងវិស័យផ្សេងៗទៀត ។

**មាត្រា៧២** ._ ការអនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីផ្តល់នូវព័ត៌មានលម្អិតបន្ថែមទៀតស្តីពីនីតិវិធីនៃការអនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនៅក្នុងមាតិកានេះ ដែលមានជាអាទិ៍ ៖

១- ប្រតិបត្តិការលម្អិតនៃនីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

២- លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់សក្តានុពលនៃសំណើដែលអាចមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ។

៣- ការអនុវត្តបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងគន្លីទី១ មាតិកាទី២ នៃក្រមនេះ និងគន្លីទី១ មាតិកាទី៣ នៃក្រមនេះ ។

៤- និងខ្លឹមសារ និងទម្រង់ នៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៧៣ ._** នីតិវិធី

នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវដាក់បញ្ចូលនូវដំណាក់កាលដូចខាងក្រោម ៖

១- ការធ្វើចំណាត់ថ្នាក់គោលនយោបាយ ផែនការ និងកម្មវិធី ។

២- ការកំណត់វិសាលភាពគោលនយោបាយ ផែនការ និងកម្មវិធី ។

៣- ការរៀបចំរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

៤- ការធ្វើសេចក្តីសម្រេចលើរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

៥- ការតាមដានការអនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៧៤ ._** ការចូលរួមជាសាធារណៈក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវមានការចូលរួមជាសាធារណៈលើដំណាក់កាលនៃដំណើរការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៧៥ ._** សមត្ថកិច្ច

ក្រសួង ស្ថាប័នទទួលខុសត្រូវលើវិស័យអាទិភាព និងវិស័យផ្សេងៗ ត្រូវរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងដាក់ជូនក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ពិនិត្យ និងសម្រេច ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវឆ្លើយតបក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៧៦** ._ ការចូលរួមពីសំណាក់ស្ត្រី និងជនងាយរងគ្រោះ

ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវផ្តល់ឱកាសដល់ស្ត្រី កុមារ ជនពិការ ជនងាយរងគ្រោះ ចូលរួមក្នុងការកំណត់វិសាលភាពគោលនយោបាយ ផែនការ និងកម្មវិធី ដូចមានចែងក្នុងមាត្រា៧៣នៃក្រមនេះ ។

**មាត្រា៧៧** ._ ការវិភាគការប្រែប្រួលអាកាសធាតុ

ការរៀបចំរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវដាក់បញ្ចូលនូវការវិភាគការប្រែប្រួលអាកាសធាតុ ។

**មាត្រា៧៨** ._ ការអនុវត្តរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលបានឯកភាពដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

ប្រភេទគម្រោងដែលស្ថិតនៅក្រៅវិសាលភាពនៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ មិនត្រូវយកមកពិចារណាក្នុងការអនុវត្ត ។

ប្រភេទគម្រោងដែលស្ថិតក្នុងវិសាលភាពនៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវបន្តរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាតិកាទី២ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រមនេះ ។

**មាត្រា៧៩** ._ ការអង្កេតតាមដាន

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តន៍ការអង្កេតតាមដានលើគោលនយោបាយ ផែនការ និងកម្មវិធី ដូចមានចែងក្នុងរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធ្វើបញ្ជូនរបាយការណ៍អង្កេតតាមដានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ មកក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព រៀងរាល់៣ (បី) ឆ្នាំ ម្តង ។

## មាតិកាទី២
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៨០** ._ គោលបំណងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានគោលបំណងដូចខាងក្រោម ៖

១- កំណត់ឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើគម្រោងអភិវឌ្ឍន៍ទាំងសាធារណៈ និងឯកជន មុននឹងដាក់ជូនអង្គភាពមានសមត្ថកិច្ច ឬក្រសួងសាមុី និង/ឬរាជរដ្ឋាភិបាលសម្រេច ។

២- លើកកម្ពស់ការចូលរួមជាសាធារណៈ និងសិទ្ធិរបស់សាធារណជនគ្រប់រូបក្នុងការទទួលបានព័ត៌មានស្តីពីគម្រោងអភិវឌ្ឍន៍ដែលអាចបង្កហេតុប៉ះពាល់ដល់បរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួន ។

៣- ធានាការអនុវត្តសកម្មភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសមធម៌សង្គម ។

៤- លើកកម្ពស់ប្រសិទ្ធភាពនៃការបង្កើត និងតាមដានការអនុវត្តវិធានការបង្ការ បញ្ចៀស ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន ព្រមទាំងវិធានការជួសជុល ស្តារ ឬសំណងខូចខាតទាំងឡាយដែលបង្កឡើងដោយគម្រោងអភិវឌ្ឍន៍ ។

**មាត្រា៨១** ._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មាតិកានេះ កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលកើតចេញពីរាល់គម្រោងអភិវឌ្ឍន៍ទាំងសាធារណៈ និងឯកជន ដែលអាចបង្កហេតុប៉ះពាល់ដល់បរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

**មាត្រា៨២ ._** វិសាលភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តចំពោះគម្រោងអភិវឌ្ឍន៍ទាំងសាធារណៈ និងឯកជន មានជាអាទិ៍ គម្រោងស្នើសុំ គម្រោងមានស្រាប់ និងគម្រោងកំពុងដំណើរការ ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តចំពោះរាល់គម្រោងអភិវឌ្ឍន៍ ដែលមិនទាន់បានសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយរាប់បញ្ចូលទាំងគម្រោងដែលទទួលបាន ឬពុំទាន់ទទួលបានលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ សេចក្តីសម្រេចពីក្រសួង ស្ថាប័នមានសមត្ថកិច្ច អនុម័តគម្រោង ។

ក្នុងករណីដែលគម្រោងអភិវឌ្ឍន៍ អាចបង្កឱ្យមានហេតុប៉ះពាល់ឆ្លងដែនដល់បរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គម និងវប្បធម៌ ម្ចាស់គម្រោងត្រូវធ្វើការសិក្សាបន្ថែមលើហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដោយអនុលោមតាមច្បាប់ និងលិខិតុបករណ៍គតិយុត្តអន្តរជាតិ ពាក់ព័ន្ធការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដែលព្រះរាជាណាចក្រកម្ពុជា ជាសមាជិក ឬភាគី ។

**មាត្រា៨៣ ._** គម្រោងលើកលែង

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មិនអនុវត្តចំពោះគម្រោងអភិវឌ្ឍន៍ ឬសកម្មភាពរបស់រដ្ឋ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល ឬរដ្ឋសភា ហើយដែលចាត់ទុកជាគម្រោងចាំបាច់ និងបន្ទាន់ ទាក់ទងនឹងសន្តិសុខជាតិ បូរណភាពទឹកដី អធិបតេយ្យភាពជាតិ ឬគ្រោះមហន្តរាយនានា ។

## ជំពូកទី២
## គោលការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា៨៤ ._** គោលការណ៍គ្រឹះនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

រាល់គម្រោងអភិវឌ្ឍន៍ ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ជាមុនសិន មុននឹងបញ្ជូនទៅរាជរដ្ឋាភិបាលសម្រេច ។

រាល់ការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតលើគម្រោងអភិវឌ្ឍន៍នានាដោយក្រសួង ស្ថាប័នអនុម័តគម្រោង ត្រូវធ្វើឡើងអនុលោមតាមលក្ខខណ្ឌដែលកំណត់នៅក្នុងលិខិត និងវិញ្ញាបនបត្រវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬសេចក្តីសម្រេចនានាដែលផ្ទុយនឹងស្មារតីនៃបទប្បញ្ញត្តិនេះ ត្រូវទុកជាមោឃៈ ។

**មាត្រា៨៥** ._ គោលការណ៍ទូទៅនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន យកជាការបាន លុះត្រាតែកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ធ្វើឡើងស្របតាមលក្ខខណ្ឌ និងគោលការណ៍ទូទៅ ដូចមានចែងនៅក្នុងគន្ថីទី១ ជំពូកទី២នៃក្រមនេះ ។

## ជំពូកទី៣
## អង្គភាពទទួលខុសត្រូវ

**មាត្រា៨៦** ._ សមត្ថកិច្ចទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលដែលមានសមត្ថកិច្ចផ្តាច់មុខសម្រាប់គ្រប់គ្រងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

១- បង្កើតគណៈកម្មការជំនាញត្រួតពិនិត្យ តាមការចាំបាច់ ។

២- ចេញលិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬកិច្ចសន្យាការពារបរិស្ថាន ។

៣- រៀបចំនិងចេញលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់គម្រោង ។

៤- កំណត់លក្ខណៈវិនិច្ឆ័យនៃវិសាលភាពគម្រោង និងលក្ខខណ្ឌការងារ ។

៥- រៀបចំនិងចេញលិខិតបទដ្ឋានគតិយុត្តនានា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬ ផែនការគ្រប់គ្រងបរិស្ថាន ។

៦- អនុវត្តគោលការណ៍ណែនាំនានាដែលបានឯកភាព និងអនុវត្តដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬ ផែនការគ្រប់គ្រងបរិស្ថាន ។

៧- រៀបចំ និងចេញលិខិតបទដ្ឋានគតិយុត្តស្តីពីការចូលរួមជាសាធារណៈក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៨- កំណត់លក្ខខណ្ឌ លក្ខណៈសម្បត្តិ បែបបទនិងនីតិវិធីសម្រាប់ការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៩- បង្កើត និងអភិវឌ្ឍ ក្របខ័ណ្ឌច្បាប់នានា សម្រាប់អនុវត្តចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ជាអាទិ៍ លិខិតបទដ្ឋានគតិយុត្ត និងវិធីសាស្ត្រសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

១០- ចុះអង្កេតតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា៨៧**._ ការទទួលខុសត្រូវអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាសេនាធិការផ្ទាល់ របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានរចនាសម្ព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានថ្នាក់ជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

ការរៀបចំ ការប្រព្រឹត្តទៅនៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចមានចែងក្នុងគន្ថីទី២ មាតិកាទី២ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអនុវត្តភារកិច្ចដទៃទៀតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៨**._ សមត្ថកិច្ចរបស់អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសមត្ថកិច្ចដូចខាងក្រោម ៖

១- ត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងចេញលិខិតអនុញ្ញាត និងសេចក្តីសម្រេចនានាពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អនុលោមតាមច្បាប់ និងនីតិវិធី

ជាធរមានបន្ទាប់ពីមានសេចក្តីសម្រេចពីរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ធនធានធម្មជាតិ ។

២- តាមដាន ត្រួតពិនិត្យ ធ្វើអធិការកិច្ច អង្កេត ស្រាវជ្រាវ ណែនាំ និងចាត់វិធានការដោយខ្លួនឯង ឬដោយសហការជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលពាក់ព័ន្ធ ចំពោះការអនុវត្តគម្រោង និងសកម្មភាពគ្រប់ប្រភេទស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៨៩** ._ តួនាទី និងភារកិច្ច

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

១- ទទួលបន្ទុកអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រោមការត្រួតពិនិត្យពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

២- ទទួលបន្ទុកធ្វើចំណាត់ថ្នាក់គម្រោង កំណត់វិសាលភាពនៃគម្រោង និងលក្ខខណ្ឌការងារ ពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឯកសារទាំងអស់ដែលពាក់ព័ន្ធ ។

៣- ជំរុញឱ្យមានការចូលរួមជាសាធារណៈពីរូបវន្តបុគ្គល ឬនីតិបុគ្គលដែលពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ ។

៤- ចុះអង្កេត និងតាមដានរាល់សកម្មភាពរបស់គម្រោងទៅតាមផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន ក្រោយពីម្ចាស់គម្រោងទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថានដើម្បីធានាការគោរពច្បាប់ ។

**មាត្រា៩០** ._ សិទ្ធិអំណាចរបស់មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ធនធានធម្មជាតិ មានសិទ្ធិអំណាចដូចខាងក្រោម ៖

១- ធ្វើអធិការកិច្ចតាមដាន និងត្រួតពិនិត្យការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន លិខិតបទដ្ឋានគតិយុត្តនានា កិច្ចសន្យាការពារបរិស្ថាន ស្តង់ដារផែនការគ្រប់គ្រងបរិស្ថាន និងលក្ខខណ្ឌតម្រូវផ្នែកបរិស្ថានដែលពាក់ព័ន្ធផ្សេងៗទៀត ។ ក្នុងករណីចាំបាច់ អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចលើកសំណើជូនរដ្ឋមន្ត្រីទទួលបន្ទុកបរិស្ថាន និង

ធនធានធម្មជាតិដើម្បីបង្គាប់ឱ្យម្ចាស់គម្រោងផ្អាកសកម្មភាពមួយផ្នែក ឬទាំងស្រុងជាបណ្ដោះអាសន្ន ឬបិទទីតាំងជាបណ្ដោះអាសន្ន ។

២- ពិនិត្យកំណត់ត្រា ឯកសារ ទិន្នន័យអេឡិចត្រូនិក ស្ដីពីការគ្រប់គ្រងបរិស្ថាន និងកំណត់ត្រាដទៃទៀត ស្ដីពីគម្រោងអភិវឌ្ឍន៍ និងការប្រតិបត្តិគម្រោង ។

៣- ស្ដាប់ និងធ្វើកំណត់ហេតុស្ដាប់ចម្លើយរបស់កម្មករ និយោជិត តំណាងម្ចាស់គម្រោង និងបុគ្គលពាក់ព័ន្ធនានា ។

៤- បង្គាប់ឱ្យកម្មករ និយោជិត អភិបាល អ្នកតំណាងស្របច្បាប់ និងភ្នាក់ងារនៃគម្រោងអភិវឌ្ឍន៍ ផ្ដល់នូវរាល់ព័ត៌មាន ឯកសារជាលាយលក្ខណ៍អក្សរ ផែនការក៏ដូចជាកំណត់ត្រាគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ។

៥- មានសិទ្ធិចុះឆែកឆេរទីតាំងគម្រោង និងចាប់យកវត្ថុតាង ក្នុងករណីដែលសង្ស័យថាមានអំពើល្មើសនឹងច្បាប់ ឬបទប្បញ្ញត្តិនានាស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ។

៦- ធ្វើកំណត់ហេតុឆែកឆេរ និងចាប់យកវត្ថុតាងនានា ដើម្បីកសាងសំណុំរឿងនៃការប្រព្រឹត្តល្មើសនឹងច្បាប់នេះ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន ។

៧- ជួបប្រជុំជាមួយប្រធានក្រុមប្រឹក្សាភិបាល តំណាងស្របច្បាប់ និងកម្មករ និយោជិតនៃគម្រោងយ៉ាងតិច ១ (មួយ) ឆ្នាំម្ដង ដើម្បីធ្វើការវាយតម្លៃការអនុវត្តច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត ។

## ជំពូកទី៤
## កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
### ផ្នែកទី១
### ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងស្នើសុំ

**មាត្រា៥១** ._ ការធ្វើចំណាត់ថ្នាក់គម្រោង

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ចំណាត់ថ្នាក់គម្រោងអភិវឌ្ឍន៍ ដើម្បីតម្រូវឱ្យម្ចាស់គម្រោងរៀបចំនូវឯកសារ ដូចខាងក្រោម ៖

១- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

២- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ។

៣- កិច្ចសន្យាការពារបរិស្ថាន ។

ប្រភេទគម្រោងដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានអាចកំណត់ចំណាត់ថ្នាក់គម្រោងបន្ថែមទៀត ដោយផ្អែកលើទំហំនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩២** ._ ការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់គម្រោង

ក្នុងករណីដែលមានការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់គម្រោង ដោយប្រការណាមួយនោះ លិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន និងលក្ខខណ្ឌទាំងអស់ដែលចែងក្នុងវាក្យខណ្ឌនេះ ត្រូវផ្ទេរទៅម្ចាស់ថ្មីដោយស្វ័យប្រវត្តិ ។

កិច្ចសន្យាផ្ទេរ ឬការផ្លាស់ប្តូរម្ចាស់គម្រោងទាក់ទងនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសុពលភាពអនុវត្ត លុះត្រាតែការផ្ទេរ ឬការផ្លាស់ប្តូរនោះទទួលបានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៣** ._ លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ

លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវធ្វើឡើងសម្រាប់ ៖

១- គម្រោងដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

២- ឬគម្រោងដែលទទួលបានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ហើយលទ្ធផលនៃការសិក្សានេះពិនិត្យឃើញថាមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម ហើយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ តម្រូវឱ្យមានការសិក្សារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

នៅពេលដែលគម្រោងស្នើសុំ តម្រូវឱ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំលក្ខខណ្ឌការងារដោយអនុលោមតាមបទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ រួចដាក់សុំការអនុម័តជាស្ថាពរ ពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ផ្អែកលើលក្ខខណ្ឌការងារដែលទទួលបានការឯកភាព ។

**មាត្រា៩៤** ._ លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង

លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវធ្វើឡើងសម្រាប់ ៖

១- គម្រោងនានាដែលមានរៀបរាប់ក្នុងលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

២- ឬគម្រោងនានា ដែលបានរៀបចំជាកិច្ចសន្យាការពារបរិស្ថាន ហើយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ តម្រូវឱ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ។

នៅពេលដែលគម្រោងស្នើសុំតម្រូវឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនោះ ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំសេចក្តីព្រាងលក្ខខណ្ឌការងារ ដោយអនុលោមតាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ រួចដាក់សុំការអនុម័តជាស្ថាពរពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ផ្អែកលើលក្ខខណ្ឌការងារដែលទទួលបានការឯកភាព ។

**មាត្រា៩៥** ._ ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាក្រុមហ៊ុនទីប្រឹក្សា ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវតែមានរចនាសម្ព័ន្ធគ្រប់គ្រងដែលមានប្រធាន និងបុគ្គលិកជាសញ្ជាតិខ្មែរ និងមានប្រធានក្រុមការងារជាទីប្រឹក្សាដែលទទួលបាននីតិសម្បទាពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

រូបវន្តបុគ្គលជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានគ្រប់រូប ត្រូវចុះបញ្ជីនៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិជាមុនសិន មុននឹងប្រកបវិជ្ជាជីវៈរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមួយក្រុមហ៊ុនទីប្រឹក្សា ។

ក្រុមហ៊ុន ឬរូបវន្តបុគ្គលជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលមានសញ្ជាតិបរទេសអាចចូលរួមសហការជាមួយនឹងក្រុមហ៊ុនទីប្រឹក្សាក្នុងស្រុកសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន តាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

វិញ្ញាបនបត្រនៃការចុះបញ្ជីផ្តល់នីតិសម្បទាជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានសុពលភាពអតិបរមា ៥ (ប្រាំ) ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន ។

លក្ខណៈសម្បត្តិ បែបបទ លក្ខខណ្ឌ និងនីតិវិធីសម្រាប់ចុះបញ្ជីដើម្បីទទួលបាននីតិសម្បទាជាទីប្រឹក្សាត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលសម្រាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏ដូចជាការបន្តសុពលភាពនៃការចុះបញ្ជីសាជាថ្មី ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៦**._ មតិយោបល់របស់គណៈកម្មការជំនាញត្រួតពិនិត្យ

រាល់គម្រោងអភិវឌ្ឍន៍នានាដែលតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញចាំបាច់ត្រូវមានមតិបច្ចេកទេសរបស់គណៈកម្មការជំនាញត្រួតពិនិត្យ ។

គណៈកម្មការជំនាញត្រួតពិនិត្យនេះ រួមមានសមាសភាពនៃមន្ត្រីបច្ចេកទេសមកពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងអ្នកជំនាញឯករាជ្យ ដែលមានគុណវុឌ្ឍិ និងបទពិសោធន៍សមស្របក្នុងការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

សមាជិកគណៈកម្មការជំនាញត្រួតពិនិត្យនេះ អាចមានការប្រែប្រួលពីគម្រោងមួយទៅគម្រោងមួយតាមការជ្រើសរើសរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាស្រ័យទៅតាមទិដ្ឋភាពបច្ចេកទេសនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

តួនាទី និងភារកិច្ចនៃគណៈកម្មការជំនាញត្រួតពិនិត្យនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៧** ._ នីត្យានុកូលភាពនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង អាចយកជាបានការលុះត្រាតែ ៖

១- របាយការណ៍នោះត្រូវបានរៀបចំឡើងដោយក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

២- របាយការណ៍នោះត្រូវតាក់តែងឡើងស្របតាមនីតិវិធី លក្ខខណ្ឌ និងលិខិបទដ្ឋានគតិយុត្តដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ។

**មាត្រា៩៨** ._ ការតម្រូវឱ្យធ្វើកិច្ចសន្យាការពារបរិស្ថាន

កិច្ចសន្យាការពារបរិស្ថាន ត្រូវធ្វើឡើងសម្រាប់គម្រោងនានាដែលមានរៀបរាប់ក្នុងលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬគម្រោងដែលមានទំហំហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គមតិចតួច ។

នៅពេលដែលគម្រោងស្នើសុំត្រូវធ្វើត្រឹមកិច្ចសន្យាការពារបរិស្ថាន ម្ចាស់គម្រោងត្រូវចុះកិច្ចសន្យាការពារបរិស្ថាន ដោយត្រូវភ្ជាប់ជាមួយគោលការណ៍បច្ចេកទេស មានជាអាទិ៍ ផែនការគ្រប់គ្រងបរិស្ថាន និងឯកសារពាក់ព័ន្ធ រួចដាក់សុំការអនុម័តជាស្ថាពរពីរដ្ឋមន្ត្រីទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ តាមសំណើរបស់អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

គំរូកិច្ចសន្យាការពារបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៩ .**_ រយៈពេលនៃការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវពិនិត្យ និងផ្តល់យោបល់ លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានរបាយការណ៍នោះ ។ រយៈពេល ៩០ (កៅសិប) ថ្ងៃនេះ ត្រូវអស់សុពលភាព នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិបានផ្តល់យោបល់របស់ខ្លួន ទោះបីជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬជាយោបល់បង្គាប់ឱ្យមានការកែតម្រូវ ឬកែសម្រួលលើរបាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ខាងលើ ត្រូវចាប់ផ្តើមរាប់សាជាថ្មី នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិទទួលបានពាក្យស្នើសុំឱ្យពិនិត្យ ព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ ឬណែនាំដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិបានផ្តល់ជូនកាលពីពេលមុនៗ ។

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវចំពោះព្យសនកម្មនានាដែលបង្កឡើងដោយកំហុសរបស់ខ្លួនដែលបណ្តាលមកពីការយឺតយ៉ាវ ឬការខកខានមិនបានធ្វើការកែសម្រួលឱ្យត្រូវតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំខាងលើ ។

**មាត្រា១០០ .**_ រយៈពេលនៃការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានរបាយការណ៍នោះ ។ រយៈពេល ៦០ (ហុកសិប) ថ្ងៃនេះ ត្រូវអស់សុពលភាព នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ បានផ្តល់យោបល់របស់ខ្លួន ទោះបីជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬជាយោបល់បង្គាប់ឱ្យមានការកែប្រែ ឬកែសម្រួល ឬ កែតម្រូវ លើរបាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ខាងលើ ត្រូវចាប់ផ្តើមរាប់សាជាថ្មី នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ទទួលបាន

ពាក្យស្នើសុំឱ្យពិនិត្យ ព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ បានផ្តល់ជូននាពេលមុនៗ ។

ម្ចាស់គម្រោងត្រូវទទួលខុសត្រូវចំពោះព្យសនកម្មនានា ដែលបង្កឡើងដោយកំហុសរបស់ខ្លួន នាំឱ្យមានការយឺតយ៉ាវ ឬការខកខានមិនបានធ្វើការកែសម្រួលឱ្យត្រូវតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំខាងលើ ។

**មាត្រា១០១** ._ រយៈពេលនៃការពិនិត្យ និងផ្តល់យោបល់លើកិច្ចសន្យាការពារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីពិនិត្យ ផ្តល់យោបល់ ឯកភាព បដិសេធ ឬតម្រូវឱ្យកែសម្រួល ឬកែតម្រូវ លើកិច្ចសន្យាការពារបរិស្ថាន ។ រយៈពេលនេះគិតចាប់ពីកាលបរិច្ឆេទដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ទទួលបានពាក្យសុំពិនិត្យលើកិច្ចសន្យាការពារបរិស្ថាន និងឯកសារពាក់ព័ន្ធ ។

**មាត្រា១០២** ._ កិច្ចប្រជុំពិគ្រោះយោបល់

ក្នុងអំឡុងពេលនៃការពិនិត្យ និងផ្តល់យោបល់ ដូចមានចែងក្នុងមាត្រា៩៩ និង មាត្រា១០០ នៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង បន្ទាប់ពី ៖

១- ស្តាប់ និងពិចារណាលើបទបង្ហាញ និងការការពារជាផ្លូវការរបស់ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ។

២- ពិចារណាលើមតិយោបល់ របស់អ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល និងមតិសាធារណជនពាក់ព័ន្ធ ។

៣- ពិចារណាមតិរបស់គណៈកម្មការជំនាញត្រួតពិនិត្យដែលបានស្នើឡើង សម្រាប់តែករណីរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវ ក្នុងការរៀបចំឱ្យមានដំណើរការចូលរួមជាសាធារណៈ ប្រកបដោយសមធម៌ ដោយអញ្ជើញតំណាងក្រសួង ស្ថាប័ន

ពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ សង្គមស៊ីវិល និងអ្នកដែលទទួលរងការប៉ះពាល់ឱ្យចូលរួមផ្តល់មតិយោបល់ចំពោះគម្រោងដែលបានស្នើឡើងនោះ ។

**មាត្រា១០៣**._ ការឯកភាព បដិសេធ ឬកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង

ការផ្តល់យោបល់ឯកភាព បដិសេធ ឬកែតម្រូវផ្សេងៗទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវធ្វើឡើងដោយពិចារណាលើគុណសម្បត្តិ និងគុណវិបត្តិខាងផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ តាមរយៈការពិនិត្យជាអាទិ៍ វិសាលភាពនៃគម្រោង ទីតាំងភូមិសាស្ត្រ សក្តានុពលនៃហេតុប៉ះពាល់ លក្ខណៈពិសេសដទៃទៀតរបស់គម្រោងនីមួយៗ និងប្រសិទ្ធភាពនៃការអនុវត្តវិធានការគ្រប់គ្រង និង/ឬការពារគុណភាពបរិស្ថាន និងកាត់បន្ថយហេតុប៉ះពាល់ចំពោះសង្គម អនុលោមតាមកម្រិតវិវឌ្ឍន៍នៃបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវចេញលិខិតនិងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង នៃគម្រោងនោះដោយភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិបដិសេធលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវបញ្ជាក់ពីហេតុផលនៃសេចក្តីសម្រេចរបស់ខ្លួន ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ផ្តល់យោបល់ឱ្យធ្វើការកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង នោះក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវភ្ជាប់ហេតុផល និងចង្អុលបង្ហាញដោយច្បាស់ៗនូវចំណុចត្រូវកែតម្រូវ ។

**មាត្រា១០៤ ._** ការផ្តល់លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះគម្រោងស្ថិតក្នុងទីតាំងតំបន់ជនជាតិដើមភាគតិច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មុនធ្វើការសម្រេចផ្តល់លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍ ដែលមានទីតាំងស្ថិតក្នុងតំបន់ជនជាតិដើមភាគតិច ដោយមានការចូលរួមពីគណៈកម្មការជំនាញត្រួតពិនិត្យ ឬអ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចលើវិធានការកាត់បន្ថយ ត្រូវធ្វើការយកចិត្តទុកដាក់ និងពិចារណាខ្ពស់ចំពោះគម្រោងនោះដើម្បីបញ្ចៀស ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន ជាអាទិ៍ វប្បធម៌ ទំនៀមទម្លាប់ប្រពៃណី ការប្រកបរបរចិញ្ចឹមជីវិត ទ្រព្យសម្បត្តិ ដល់សហគមន៍ជនជាតិដើមភាគតិច ។

**មាត្រា១០៥ ._** ការបដិសេធ ឬកែតម្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើសេចក្តីសម្រេចបដិសេធ ឬសេចក្តីបង្គាប់ឱ្យមានការកែតម្រូវជាលាយលក្ខណ៍អក្សររបស់ខ្លួន រួមទាំងហេតុផល ឬលក្ខខណ្ឌ និង/ឬចំណុចនានាដែលត្រូវកែតម្រូវជូនទៅម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវធ្វើលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមទាំងកិច្ចសន្យាការពារបរិស្ថាន ជូនដល់ម្ចាស់គម្រោង និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធជាអាទិ៍ ក្រសួង ស្ថាប័នអនុម័តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ រាជធានី ខេត្ត ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្សព្វផ្សាយសេចក្តីសម្រេចឯកភាពរបស់ខ្លួន រួមទាំងផែនការគ្រប់គ្រងបរិស្ថាន និងលក្ខខណ្ឌពាក់ព័ន្ធខាងលើ ជូនដល់សាធារណជនតាមរយៈការដាក់បង្ហោះនៅលើគេហទំព័ររបស់ខ្លួន និង/ឬ តាមរយៈការបោះពុម្ពផ្សាយតាមសារព័ត៌មាន យោងតាមការចាំបាច់ ។

**មាត្រា១០៦ ._** ការហាមឃាត់ចំពោះសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង

ម្ចាស់គម្រោងមិនត្រូវចាប់ផ្តើមសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង មុនពេលទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ ក្នុងករណីដែលគម្រោងអភិវឌ្ឍន៍គ្មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិមានសិទ្ធិសម្រេចផ្អាកសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោងទាំងស្រុង ។

រាល់កិច្ចព្រមព្រៀងសម្បទាន ដែលផ្តល់ជូនដោយរាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាផ្លូវការ ដោយភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា១០៧ ._** សុពលភាពលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសុពលភាព សម្រាប់រយៈពេលវដ្តនៃគម្រោង ។

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិពិនិត្យឃើញថាមានការផ្លាស់ប្តូរផែនការមេ និង/ឬ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ពុំមានលក្ខណៈសមស្រប ឬមិនមានប្រសិទ្ធភាពក្នុងការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិមានសិទ្ធិតម្រូវឱ្យម្ចាស់គម្រោង រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឡើងវិញ និង/ឬធ្វើបច្ចុប្បន្នភាពរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដើម្បីទទួលបានជាថ្មីនូវលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ។

## ផ្នែកទី២
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ

**មាត្រា១០៨ ._** ការធ្វើចំណាត់ថ្នាក់គម្រោងដែលមានស្រាប់និងកំពុងដំណើរការ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំពាក់ព័ន្ធការធ្វើចំណាត់ថ្នាក់ប្រភេទ គម្រោងដែលមានស្រាប់និងកំពុងដំណើរការ ដែលមិនទាន់បានអនុវត្តការវាយតម្លៃហេតុ

ប៉ះពាល់បរិស្ថាន ដើម្បីតម្រូវឱ្យម្ចាស់គម្រោងទាំងនោះ រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ។

គោលការណ៍ណែនាំត្រូវបោះពុម្ពផ្សព្វផ្សាយក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីពេលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិសម្រេចលើលិខិតបទដ្ឋានគតិយុត្តទាំងនេះ ។

**មាត្រា១០៩** ._ សុពលភាពនៃការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ម្ចាស់គម្រោង ត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឱ្យបានចប់សព្វគ្រប់លើគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ ហើយត្រូវដាក់ឯកសារទាំងនេះទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីពិនិត្យ ផ្តល់យោបល់ ក្នុងរយៈពេលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងជំពូកទី៤ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃមាតិកាទី៣ គន្ថីទី២ នៃក្រមនេះ ។

## ផ្នែកទី៣
## ការវាយតម្លៃហានិភ័យ

**មាត្រា១១០** ._ វិសាលភាពនៃការអនុវត្ត

ការវាយតម្លៃហានិភ័យ ត្រូវធ្វើឡើងដោយម្ចាស់គម្រោង និងបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ច មុននឹងចេញសេចក្តីសម្រេច និងការឯកភាពទាំងអស់ រួមមាន ការចេញលិខិតអនុញ្ញាត ឬការឯកភាពនៅក្រោមក្រមនេះសម្រាប់សកម្មភាព ឬ គម្រោងដែលអាចមានហេតុប៉ះពាល់បរិស្ថានគួរឱ្យកត់សម្គាល់ ។

ការវាយតម្លៃហានិភ័យជាផ្នែកមួយនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា១១១ ._** គោលដៅនៃការវាយតម្លៃហានិភ័យ

ការវាយតម្លៃហានិភ័យ ត្រូវប្រើប្រាស់ដើម្បី ៖

១- កំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យដែលអាចកើតឡើងចំពោះបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្ស ដែលបណ្តាលមកពីការសម្រេចចិត្ត ការងកភាព សកម្មភាព ឬគម្រោង ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

២- កំណត់អត្តសញ្ញាណ និង វាយតម្លៃហានិភ័យជាក់ស្តែង ចំពោះបរិស្ថាន សុវត្ថិភាព សាធារណៈ និងសុខភាពមនុស្ស ដែលបណ្តាលមកពីការធ្វើសេចក្តីសម្រេច ការងកភាព សកម្មភាព ឬគម្រោង ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

៣- កំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យដែលអាចកើតឡើង ឬហានិភ័យជាក់ស្តែង ចំពោះបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្ស ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា១១២ ._** គោលបំណង

ការវាយតម្លៃហានិភ័យ ត្រូវអនុវត្តដើម្បី ៖

១- កំណត់អត្តសញ្ញាណ និងផ្តល់អាទិភាពដល់សកម្មភាពនានាដែលត្រូវអនុវត្ត ។

២- ជួយនៅក្នុងការបែងចែកធនធានដើម្បីកាត់បន្ថយជាអប្បរមានូវការខូចខាតបរិស្ថាន ។

៣- កំណត់អំពីកម្រិតនៃការស្តារឡើងវិញដែលចាំបាច់ ដើម្បីជួសជុលហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ។

៤- កំណត់អំពីពេលវេលាដែលការស្តារឡើងវិញអាចត្រូវបានបញ្ចប់ និងបំពេញចប់សព្វគ្រប់ ។

៥- ធានាតម្កល់ថវិកា ឬធានារ៉ាបរងលើការគ្រប់គ្រងហានិភ័យដែលបង្កឡើងដោយសកម្មភាព ឬគម្រោង ។

៦- ជូនដំណឹងដល់សាធារណជន ។

៧- និងទប់ស្កាត់ និងកាត់បន្ថយជាអប្បបរមានូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ។

**មាត្រា១១៣ ._** លក្ខខណ្ឌតម្រូវសម្រាប់ទីប្រឹក្សាដែលមានការទទួលស្គាល់

រាល់ការវាយតម្លៃហានិភ័យទាំងអស់ ត្រូវរៀបចំដោយក្រុមហ៊ុនទីប្រឹក្សាដែលមានការទទួលស្គាល់ ឬដែលទទួលបានការឯកភាព ដើម្បីអនុវត្តការងារនេះពីសំណាក់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ។

**មាត្រា១១៤** ._ លិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហានិភ័យ មានជាអាទិ៍ គោលការណ៍ណែនាំស្តីពីខ្លឹមសារ និងទម្រង់នៃរបាយការណ៍វាយតម្លៃហានិភ័យ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងលក្ខណៈសម្បត្តិដែលតម្រូវឱ្យមានសម្រាប់ទីប្រឹក្សាវាយតម្លៃហានិភ័យដែលមានការទទួលស្គាល់ និងដែលទទួលបានការឯកភាព ដោយប្រើប្រាស់នូវទម្លាប់អនុវត្តដ៏ប្រសើរបំផុត និងគោលការណ៍ផ្នែកវិទ្យាសាស្ត្រ និងគោលការណ៍វាយតម្លៃហានិភ័យ ដែលត្រឹមត្រូវ ។

**មាត្រា១១៥** ._ របាយការណ៍

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវធានាថា របាយការណ៍នៃលទ្ធផលនៃការវាយតម្លៃហានិភ័យនីមួយៗ ត្រូវបានរៀបចំ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហានិភ័យ ។ របាយការណ៍វាយតម្លៃហានិភ័យបែបនេះត្រូវរៀបចំ និងសម្រេចជាចុងក្រោយដោយទីប្រឹក្សា ដែលមានការទទួលស្គាល់ ឬទទួលបានការឯកភាព ក្នុងការអនុវត្តការងារបែបនេះ ពីសំណាក់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា១១៦** ._ ការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យដោយក្លែងបន្លំ

ទីប្រឹក្សារៀបចំរបាយការណ៍វាយតម្លៃហានិភ័យ ត្រូវទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យស្របគោលការណ៍ ដែលបានចែងក្នុងមាត្រា១១១ មាត្រា១១២ និងមាត្រា១១៤ ។

**មាត្រា១១៧** ._ ការទទួលបានព័ត៌មាន

ប្រព័ន្ធគ្រប់គ្រងទិន្នន័យអំពីសកម្មភាពនៃការវាយតម្លៃហានិភ័យទាំងអស់ និងរបាយការណ៍វាយតម្លៃហានិភ័យដែលត្រូវបានបញ្ចប់ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ដោយក្រសួង

ស្ថាប័នទទួលបន្ទុកបរិស្ថាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យបែបនេះត្រូវរក្សាដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ផ្នែកទី៤
## ការវាយតម្លៃហានិភ័យនិរន្តរភាព

**មាត្រា១១៨** ._ ការវាយតម្លៃហានិភ័យនិរន្តរភាព

រាល់ស្ថាប័នហិរញ្ញវត្ថុ និងនីតិបុគ្គល ដែលផ្តល់ការធានាផ្នែកហិរញ្ញវត្ថុ ការធានារ៉ាប់រងហិរញ្ញវត្ថុ ឬកម្ចី ចំពោះសកម្មភាព ឬគម្រោង ត្រូវអនុវត្តការវាយតម្លៃហានិភ័យនិរន្តរភាព ដើម្បីកំណត់ថាសកម្មភាព ឬគម្រោងដែលបានស្នើឡើង ត្រូវបានវាយតម្លៃ និងពិចារណា ដោយពេញលេញអំពីហេតុប៉ះពាល់បរិស្ថានដែលអាចកើតឡើងនៅក្នុងការរចនា ការគ្រប់គ្រងបរិស្ថាន ប្រតិបត្តិការ និងការបិទសកម្មភាព ឬគម្រោងដែលបានស្នើឡើង ។

**មាត្រា១១៩** ._ ការវាយតម្លៃថ្លៃចំណាយ

ការវាយតម្លៃហានិភ័យនិរន្តរភាព ត្រូវធានាថា ការសិក្សាបុរេលទ្ធភាពសម្រាប់សកម្មភាព ឬគម្រោង ដែលបានស្នើឡើង មានដាក់បញ្ចូលនូវថ្លៃចំណាយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមបញ្ចូល ថ្លៃចំណាយជានិរន្តរ៍នៃផែនការគ្រប់គ្រងបរិស្ថាន ការទទួលខុសត្រូវទាំងអស់សម្រាប់ការដោះស្រាយ និងសំណងសម្រាប់ការខូចខាតបរិស្ថាន ការបង់ប្រាក់ទាំងអស់ដែលតម្រូវឱ្យមានសម្រាប់សេវាប្រព័ន្ធអេកូឡូស៊ី និងការធានាផ្នែកហិរញ្ញវត្ថុដែលគ្រប់គ្រាន់សម្រាប់ការបិទ ការស្តារឡើងវិញ ការជួសជុល ឬការបញ្ចប់គម្រោង តាមភាពចាំបាច់ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ដែលពាក់ព័ន្ធ ។

**មាត្រា១២០** ._ ការទទួលខុសត្រូវនៅក្នុងករណីដែលគ្មានការវាយតម្លៃហានិភ័យនិរន្តរភាព

រាល់ស្ថាប័នហិរញ្ញវត្ថុ និងនីតិបុគ្គល ដែលផ្តល់ការធានាផ្នែកហិរញ្ញវត្ថុ ការធានារ៉ាប់រងហិរញ្ញវត្ថុ ឬកម្ចី ចំពោះសកម្មភាព ឬគម្រោង ដែលមិនអនុវត្តការវាយតម្លៃហានិភ័យនៃនិរន្តរភាព ត្រូវទទួលខុស

ត្រូវចំពោះការខូចខាត ឬសំណងលើការខូចខាត សម្រាប់ហេតុប៉ះពាល់ដែលគួរឱ្យកត់សម្គាល់លើបរិស្ថាន ដែលបង្កឡើងដោយសមកម្មភាព ឬគម្រោងនានា ។

## ផ្នែកទី៥
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា១២១ .**_ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះការប្រែប្រួលអាកាសធាតុ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវដាក់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់នៃគម្រោងស្នើសុំដែលបង្កឱ្យមានការប្រែប្រួលអាកាសធាតុរួមមាន ការគណនាបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោងអភិវឌ្ឍន៍ រួមបញ្ចូលការវិភាគលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។

ម្ចាស់គម្រោងត្រូវសិក្សាអំពីជម្រើសថាមពលនានា ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាប និងសិក្សាអំពីតម្រូវការក្នុងការកាត់បន្ថយការប្រែប្រួលចំពោះការផ្គត់ផ្គង់ទឹក ដែលបណ្តាលមកពីកត្តាអាកាសធាតុ ។

**មាត្រា១២២ .**_ ការវិភាគ និងវាយតម្លៃពីសក្តានុពលហេតុប៉ះពាល់ចំពោះការប្រែប្រួលអាកាសធាតុ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវវិភាគ និងវាយតម្លៃពី ភាពងាយរងគ្រោះនៃគម្រោង ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងសកម្មភាពរបស់គម្រោងទៅលើបរិស្ថានសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដើម្បីសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច ដោយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ។

ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវដាក់បញ្ចូលនូវការវាយតម្លៃ ហានិភ័យ ភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីស្នើនូវវិធានការកាត់បន្ថយហេតុប៉ះពាល់នូវហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងដាក់បញ្ចូលនូវរាល់ផែនការ ឆ្លើយតបបន្ទាន់ និងជម្រើសបច្ចេកវិទ្យា ។

## ផ្នែកទី៦
## ការវាយតម្លៃហេតុប៉ះពាល់សុខភាព និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្តុំ

**មាត្រា១២៣ .**_ ការវាយតម្លៃហេតុប៉ះពាល់សុខភាព

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវរាប់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់សុខភាពដែលមានជាអាទិ៍ ៖

១- ទិន្នន័យមូលដ្ឋានស្ដីពីសុខភាពនៅក្នុងតំបន់គម្រោង និងរបស់ប្រជាជនដែលរងហេតុប៉ះពាល់ ។

២- ការពិព័ណ៌នា អំពីហេតុប៉ះពាល់នៃគម្រោងដែលអាចមាន ដោយសារការសាងសង់លំហូរប្រជាជន និងការផ្លាស់ប្ដូរចំពោះបរិស្ថាន ។

៣- វិធានការកាត់បន្ថយហេតុប៉ះពាល់ ដើម្បីកាត់បន្ថយ ឬលុបបំបាត់ហេតុប៉ះពាល់អវិជ្ជមាននៃគម្រោង និងវិធានការដែលត្រូវដាក់ឱ្យអនុវត្តដោយម្ចាស់គម្រោង ដើម្បីកែលម្អសុខភាពរបស់សហគមន៍មូលដ្ឋាន ។

៤- បញ្ហានានាទាក់ទងនឹងការអង្កេតតាមដានសុខភាព និងការគ្រប់គ្រងហេតុប៉ះពាល់ដែលនៅសល់ក្នុងរយៈពេលខ្លី និងវែង សម្រាប់គម្រោង ។

**មាត្រា១២៤ .**_ ការវិភាគពីហានិភ័យនៃការវាយតម្លៃហេតុប៉ះពាល់សុខភាព

ការវាយតម្លៃហេតុប៉ះពាល់សុខភាព ម្ចាស់គម្រោងត្រូវ ៖

១- លើកផែនការគ្រប់គ្រងសុវត្ថិភាព និងសុខភាពជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សុខភាព សម្រាប់បរិស្ថានការងារ ដោយវិភាគពីហានិភ័យដែលពាក់ព័ន្ធ និងប្រភេទនៃកត្តាគ្រោះថ្នាក់ក្នុងទីតាំងគម្រោងជាអាទិ៍ កត្តាគ្រោះថ្នាក់ផ្នែករូបសាស្ត្រ គីមីសាស្ត្រ ជីវសាស្ត្រ និងវិទ្យុសកម្ម ។

២- កំណត់ និងវាយតម្លៃពីគ្រោះហានិភ័យ និងសក្ដានុពលនៃហេតុប៉ះពាល់ទៅលើសុវត្ថិភាព និងសុខភាព របស់សហគមន៍ក្នុងដំណាក់កាលរចនាគម្រោង សាងសង់គម្រោង ប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង ព្រមទាំងលើកវិធានការការពារ និងផែនការគ្រប់គ្រងហេតុប៉ះពាល់នៅក្នុងដំណាក់កាលទាំងនេះ ។

**មាត្រា១២៥ .**_ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្ដុំ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវវិភាគនិងវាយតម្លៃពីបណ្ដុំនៃហេតុប៉ះពាល់ដែលបង្កឡើងដោយគម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគត នៅជុំវិញនៃទីតាំង

គម្រោងទាំងនោះ ដែលអាចបង្កើតឱ្យមានហេតុប៉ះពាល់គួរឱ្យកត់សម្គាល់ដល់បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

នៅក្នុងរបាយការណ៍វាយតម្លៃបណ្តុំនៃហេតុប៉ះពាល់ ម្ចាស់គម្រោងត្រូវវាយតម្លៃសមត្ថភាពនៃធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដើម្បីគិតគូរអំពីហេតុប៉ះពាល់បន្ថែម ផ្អែកលើកត្តាពេលវេលា ស្ថានភាពភូមិសាស្ត្រ និងសកម្មភាពរបស់គម្រោងនានាដែលនៅជុំវិញទីតាំងគម្រោង ។

ម្ចាស់គម្រោងត្រូវពិចារណាអំពី ជម្រើសនៃវិធានការកាត់បន្ថយបណ្តុំនៃហេតុប៉ះពាល់ផ្សេងៗ ដើម្បីកាត់បន្ថយ ឬបញ្ចៀសបណ្តុំនៃហេតុប៉ះពាល់ដែលគួរឱ្យកត់សម្គាល់ទាំងនោះ ។

## ផ្នែកទី៧
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន

**មាត្រា១២៦** ._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន

គម្រោងដែលអាចមានហេតុប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដោយអនុលោមតាមច្បាប់ និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក ឬភាគី ។ ក្នុងករណីនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវបញ្ចូលក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យកំណត់ពីសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និងឈានទៅដល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

បែបបទ និងនីតិវិធី នៃការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី៥
## ការចូលរួមជាសាធារណៈ

**មាត្រា១២៧** ._ គោលបំណងនៃការចូលរួមជាសាធារណៈ

គោលបំណងចម្បងនៃការចូលរួមជាសាធារណៈ ត្រូវធានាថា អ្នកដែលទទួលរងហេតុប៉ះពាល់ និងអ្នកពាក់ព័ន្ធ ៖

១- បានទទួលដំណឹងគ្រប់ជ្រុងជ្រោយអំពីគម្រោង ។

២- មានឱកាសចូលរួមក្នុងកិច្ចពិភាក្សា និងកិច្ចដំណើរការនៃការធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនឹងគម្រោង ។

៣- មានឱកាសចូលរួមក្នុងការអង្កេតតាមដានគម្រោង ។

ម្ចាស់គម្រោងដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវដាក់បញ្ចូលការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ ពីរដ្ឋបាលថ្នាក់មូលដ្ឋាន សង្គមស៊ីវិល តំណាងសហគមន៍ ប្រជាពលរដ្ឋដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ទៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅដំណាក់កាលរៀបចំផែនការគម្រោង ដើម្បី ៖

១- កំណត់ផ្នែកដែលមានសារៈសំខាន់ផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

២- ប្រមូលមតិយោបល់ពីអ្នកពាក់ព័ន្ធ និងដាក់បញ្ចូលមតិយោបល់ទាំងនោះ ទៅក្នុងកិច្ចដំណើរការនៃការធ្វើសេចក្ដីសម្រេច ។

៣- ពិនិត្យគម្រោងស្នើសុំ និងពន្យល់ពីហេតុប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

៤- ពិចារណាជម្រើសដទៃទៀត និងវិធានការកាត់បន្ថយហេតុប៉ះពាល់នានា ។

នីតិវិធីនៃការចូលរួមជាសាធារណៈ នៅក្នុងដំណាក់កាលសិក្សាពិគ្រោះយោបល់ ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការអង្កេតតាមដានគម្រោង ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១២៨**._ មតិយោបល់របស់សាធារណជន

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវ ៖

១- កត់ត្រាទុកនូវយោបល់របស់សាធារណជនដែលបានចូលរួម នៅក្នុងដំណាក់កាលរៀបចំផែនការ និងដំណាក់កាលអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

២- ផ្ដោតលើបញ្ហានានា ដែលលើកឡើងដោយស្ត្រី និងបណ្ដាជនដែលអាចទទួលរងគ្រោះខ្លាំងបំផុត ពីផលប៉ះពាល់ដែលអាចកើតមានពីគម្រោងដែលបានស្នើឡើង ។

៣- ដាក់បញ្ចូលនូវសេចក្តីលម្អិត អំពីហេតុប៉ះពាល់របស់គម្រោងដល់សាធារណជន និងការទទួលយក ឬបដិសេធសំណើរបស់សាធារណជន ។

៤- ផ្តល់ហេតុផលនៃការបដិសេធឱ្យបានច្បាស់លាស់ នៅក្នុងករណីដែលម្ចាស់គម្រោងបដិសេធសំណើរបស់សាធារណជន ។

**មាត្រា១២៩** ._ ការពិគ្រោះយោបល់ជាមុននិងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយដល់សហគមន៍

កិច្ចដំណើរការចូលរួមសាធារណៈត្រូវធានាថា មានការការពិគ្រោះយោបល់ជាមុនពីសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើង ដោយផ្អែកលើការពិគ្រោះយោបល់ជាមុន និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយ ។

ក្នុងវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននេះ ម្ចាស់គម្រោងត្រូវ ៖

១- កំណត់វិធានការនានា ក្នុងការលើកកម្ពស់ជីវភាព និងជួយដល់អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ។

២- ធានាថា អ្នកដែលទទួលរងផលប៉ះពាល់ បានចូលរួមក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មី ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឱ្យបានកម្រិតអប្បបរមា ក្នុងការធានាថាសំណងលើការបាត់បង់ទ្រព្យសម្បត្តិ ត្រូវបានដោះស្រាយដោយយុត្តិធម៌សមស្របជាមុនសិន និងដែលទទួលយកបានតាមតម្លៃទីផ្សារ ហើយវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានមានលក្ខណៈត្រឹមត្រូវ ។

ក្នុងករណីដែលសហគមន៍ដែលរងផលប៉ះពាល់ មិនយល់ស្របចំពោះវិធានការកាត់បន្ថយនានាដែលម្ចាស់គម្រោងបានស្នើខាងលើ គម្រោងអភិវឌ្ឍន៍នៅតែបន្តដដែល ប៉ុន្តែម្ចាស់គម្រោងត្រូវកំណត់រកវិធានការកាត់បន្ថយផលហេតុប៉ះពាល់ផ្សេងទៀត ឬដោះស្រាយរាល់ហេតុប៉ះពាល់នោះដល់សហគមន៍ ។

នីតិវិធីនៃការដោះស្រាយសំណងដល់សហគមន៍ដែលទទួលរងផលប៉ះពាល់ និងនីតិវិធីនៃការផ្លាស់ប្តូរ លំនៅថ្មី ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

បែបបទ និងនីតិវិធីនៃការទូទាត់សំណងការខូចខាត ដល់សហគមន៍ទទួលរងផលប៉ះពាល់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធនធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា១៣០** ._ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយចំពោះជនជាតិដើមភាគតិច

ការចូលរួមជាសាធារណៈសម្រាប់សហគមន៍ជនជាតិដើមភាគតិច កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវតម្រូវឱ្យម្ចាស់គម្រោងជូនដំណឹងដល់សហគមន៍អំពីវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើង មុនពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវបញ្ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ ម្ចាស់គម្រោងត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សហគមន៍ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ក្នុងការពិចារណាលើវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើងនោះ ។

សហគមន៍ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ត្រូវឯកភាពលើវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើងនោះ ដោយពុំមានទទួលរងសម្ពាធ ឬការបង្ខិតបង្ខំពីរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយនោះឡើយ ។

សហគមន៍ជនជាតិដើមភាគតិចដែលពាក់ព័ន្ធមានសិទ្ធិទទួលបាននូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ចំពោះគម្រោងអភិវឌ្ឍន៍ណាមួយដែលប៉ះពាល់ផ្ទាល់ដល់ដីធ្លីរបស់សហគមន៍ ។

**មាត្រា១៣១** ._ ការចូលរួមជាសាធារណៈលើវិធានការកាត់បន្ថយ

កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវស្វែងរកនូវការយល់ព្រមពីអ្នកទទួលរងផលប៉ះពាល់ពីគម្រោង ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើង ។ ម្ចាស់គម្រោងត្រូវផ្តល់នូវសេចក្តីព្រាងនៃផែនការគ្រប់គ្រងបរិស្ថាន ដែលត្រូវអនុញ្ញាតឱ្យមានការចូលរួមជាសាធារណៈ នៅក្នុងដំណើរការអង្កេតតាមដាន និងការគោរពតាមលក្ខខណ្ឌដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវពិចារណាអំពីមតិយោបល់នានា របស់អ្នកទទួលរងផលប៉ះពាល់ ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើង ។

**មាត្រា១៣២** ._ ការផ្សព្វផ្សាយជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធានាថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងឯកសារពាក់ព័ន្ធ រួមមាន លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយអ្នកពាក់ព័ន្ធ និងសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង អាចទទួលបានព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ ។

ម្ចាស់គម្រោងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ តាមរយៈគេហទំព័ររបស់ខ្លួន យ៉ាងហោចណាស់នូវឯកសារថតចម្លងនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ផែនទី និងផែនការនៃគម្រោង ព្រមទាំងបណ្ដាវិធានការកាត់បន្ថយហេតុប៉ះពាល់នៃគម្រោងដែលត្រូវបានស្នើឡើង ។

នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី៦
## ផែនការគ្រប់គ្រងបរិស្ថាន និងការអង្កេតតាមដានគម្រោង

**មាត្រា១៣៣** ._ ការត្រួតពិនិត្យ និងអង្កេតតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាអាជ្ញាធរត្រួតពិនិត្យលើផែនការគ្រប់គ្រងបរិស្ថាន និងអង្កេតតាមដានសកម្មភាពអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ ។

**មាត្រា១៣៤** ._ ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវរៀបចំដោយម្ចាស់គម្រោង ។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃការការពារ វិធានការកាត់បន្ថយ ការអង្កេតតាមដាន និងការគ្រប់គ្រង ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយអនុលោមតាមការវិវឌ្ឍន៍ជាក់ស្តែងនៃស្តង់ដារបរិស្ថាន ឬការអនុវត្តជាក់ស្តែងដែលទទួលស្គាល់ជាទូទៅក្នុងវិស័យនីមួយៗ ឬការប្រែប្រួលស្ថានភាពផ្សេងៗនៃគម្រោង ។

**មាត្រា១៣៥** ._ ប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុង

រាល់គម្រោងអភិវឌ្ឍន៍ និងអ្នកប្រតិបត្តិការគម្រោង ត្រូវបង្កើតក្រុមការងារទទួលបន្ទុកត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុង ដែលត្រូវធានាឱ្យមាននូវនីតិវិធី និងវិធីសាស្ត្រអង្កេតតាមដានដោយខ្លួនឯង ដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ក្នុងករណីហេតុប៉ះពាល់បរិស្ថាន មានទំហំធំជាងហេតុប៉ះពាល់ដែលត្រូវបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ តម្រូវឱ្យចាត់វិធានការកែតម្រូវហេតុប៉ះពាល់ភ្លាមៗ ឬកែតម្រូវផែនការគ្រប់គ្រងបរិស្ថាន ។

ផែនការគ្រប់គ្រងបរិស្ថានដែលបានកែតម្រូវរួច និងកម្មវិធីអង្កេតតាមដាន ត្រូវទទួលបានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ រយៈពេលកំណត់ ដើម្បីធ្វើការកែតម្រូវ ឬកែលម្អជាថ្មីឡើងវិញ ត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយភាគីពាក់ព័ន្ធ ។

ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានរៀងរាល់ ៣ (បី) ខែ ឬ៦ (ប្រាំមួយ) ខែ ម្តង ហើយបញ្ជូនមកអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីពិនិត្យ និងវាយតម្លៃ ។ អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសិទ្ធិចុះត្រួតពិនិត្យដល់កន្លែង និងផ្ទៀងផ្ទាត់លទ្ធផលនៃការអង្កេតតាមដានរបស់ម្ចាស់គម្រោង ។

**មាត្រា១៣៦** ._ សិទ្ធិរាយការណ៍ពីបញ្ហាបរិស្ថាន

អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធនានា ត្រូវមានសិទ្ធិរាយការណ៍ពីបញ្ហា និងក្តីកង្វល់បរិស្ថាន និងសង្គម ជូនដល់ម្ចាស់គម្រោង និងដាក់បណ្តឹងទៅស្ថាប័នមានសមត្ថកិច្ច ។

ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវឆ្លើយតបចំពោះបណ្តឹង ឬញត្តិ ហើយដោះស្រាយបញ្ហាបរិស្ថាន និងសង្គមដែលពាក់ព័ន្ធតាមពេលវេលាកំណត់សមស្រប និងផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែង ។

បែបបទ និងនីតិវិធីនៃការដោះស្រាយបណ្តឹង ឬញត្តិនេះត្រូវកំណត់យោងតាមនីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានចែងក្នុងក្រមនេះ ។

**មាត្រា១៣៧** ._ ការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន

គម្រោងអភិវឌ្ឍន៍នីមួយៗ ត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោង ដូចតទៅ ៖

១- របាយការណ៍រៀងរាល់ ៣ (បី) ខែ ឬ ៦ (ប្រាំមួយ) ខែដែលរាយកាណ៍ពីលទ្ធផលទាំងអស់នៃការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថាន ដែលត្រូវបញ្ជូនទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

២- ក្នុងរយៈពេល ៣ (បី) ខែ ឬ ៦ (ប្រាំមួយ) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំហិរញ្ញវត្ថុនីមួយៗ ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ដែលដាក់បញ្ចូលមតិយោបល់របស់សវនករស្តីពីបរិស្ថាន ។

៣- ផ្តល់សំណៅរបាយការណ៍បរិស្ថានប្រចាំឆ្នាំ នៃគម្រោងដល់សាធារណជន តាមការស្នើសុំដោយឥតគិតថ្លៃ ។

៤- ផ្តល់សំណៅអេឡិចត្រូនិក ដែលត្រូវបង្ហោះលើគេហទំព័រជាសាធារណៈរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងដោយម្ចាស់គម្រោង នៅលើគេហទំព័រសាធារណៈ ។

**មាត្រា១៣៨** ._ ការៀបចំបញ្ជូនរបាយការណ៍ប្រចាំត្រីមាស ឬឆមាស

គម្រោងអភិវឌ្ឍន៍ ដែលមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបញ្ជូនរបាយការណ៍ប្រចាំត្រីមាស ឬប្រចាំឆមាស ទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាក់ទងនឹងការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ម្ចាស់គម្រោង ត្រូវសិក្សាឡើងវិញនូវរាល់ចំណុចខ្វះខាតក្នុងរបាយការណ៍ប្រចាំត្រីមាស ឬឆមាសដែលអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានពិនិត្យ និងផ្តល់យោបល់ ហើយត្រូវបញ្ចូលចំណុចខ្វះខាតនេះក្នុងរបាយការណ៍ប្រចាំត្រីមាស ឬឆមាសបន្ទាប់រួចបញ្ចូលមកអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពិនិត្យ និងវាយតម្លៃឡើងវិញ ។ ម្ចាស់គម្រោងមានកាតព្វកិច្ចត្រូវរាយការណ៍

ភ្លាមៗ អំពីផលប៉ះពាល់បរិស្ថានអវិជ្ជមានដល់អាជ្ញាធរដែលពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច និងដល់សាធារណជន ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន ឬសង្គម ។

ម្ចាស់គម្រោង ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាននៃគម្រោងដល់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ តាមការស្នើសុំរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## មាតិកាទី៣
## សវនកម្មបរិស្ថាន ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍
## ជំពូកទី១
## សវនកម្មបរិស្ថាន

**មាត្រា១៣៩** ._ សវនកម្មបរិស្ថាន

ការអនុវត្តគម្រោង ឬសកម្មភាពណាមួយដែលទទួលបានការឯកភាព ឬលិខិតអនុញ្ញាតត្រូវមានការធ្វើសវនកម្មបរិស្ថាន ដែលមានលក្ខណៈឯករាជ្យនិងត្រូវបានចងក្រងទុកជាឯកសារ ។

ការធ្វើសវនកម្មបរិស្ថានមានដូចខាងក្រោម ៖

១- ពិនិត្យ និងបញ្ជាក់ពីគម្រោង ឬសកម្មភាពណាមួយដែលអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

២- កំណត់បង្ហាញផលប៉ះពាល់បរិស្ថានរបស់គម្រោង ឬសកម្មភាពមួយ ។

៣- កំណត់ និងបង្ហាញពីវិធានការណាមួយដែលអាចអនុវត្តបាន ដើម្បីធ្វើការកែតម្រូវឱ្យស្របតាមលក្ខខណ្ឌតម្រូវ ។

៤- កាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាអប្បបរមា ។

**មាត្រា១៤០** ._ វិសាលភាពនៃគម្រោង ឬសកម្មភាពដែលត្រូវធ្វើសវនកម្មបរិស្ថាន

គម្រោង ឬសកម្មភាពដែលជាកម្មវត្ថុនៃការធ្វើសវនកម្មបរិស្ថាន និងនីតិវិធីនៃការធ្វើសវនកម្មបរិស្ថាន រួមបញ្ចូល រយៈពេលជាក់លាក់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១៤១** ._ គម្រោងតម្រូវធ្វើសវនកម្មបរិស្ថានខាងក្រៅ

គម្រោងនានាដែលត្រូវបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិស្តីពីបញ្ជីនៃគម្រោងដែលតម្រូវឱ្យមានការធ្វើសវនកម្មបរិស្ថានខាងក្រៅ ត្រូវធ្វើសវនកម្មដោយសវនករបរិស្ថានខាងក្រៅ ដែលមានលក្ខណៈសម្បត្តិដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្តីពីការធ្វើសវនកម្មបរិស្ថានខាងក្រៅ ។

សវនករបរិស្ថានខាងក្រៅ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

១- ជួយជ្រោមជ្រែងក្នុងការកត់ត្រាកំណត់ត្រាបរិស្ថានឱ្យបានត្រឹមត្រូវនិងពេញលេញ។

២- ផ្តល់មតិយោបល់សវនកម្មវិជ្ជាជីវៈមានជាអាទិ៍ របាយការណ៍បរិស្ថានដែលបង្ហាញនូវទិដ្ឋភាពពេញលេញ និងសមស្របអំពីការគ្រប់គ្រងបរិស្ថាននៃគម្រោង ឬប្រតិបត្តិការរបស់គម្រោង ។

៣- ពិនិត្យភាពគ្រប់គ្រាន់នៃការអនុវត្ត នីតិវិធីនៃការគ្រប់គ្រង និងការអង្កេតតាមដានបរិស្ថានផ្ទៃក្នុង ព្រមទាំងការផ្តល់អនុសាសន៍ដើម្បីកែលម្អ ។

៤- ផ្តល់ព័ត៌មានអំពីភាពមិនប្រក្រតី និងការខ្វះចន្លោះក្នុងការគ្រប់គ្រងបរិស្ថានផ្ទៃក្នុងរបស់ខ្លួន ។

សំណៅមួយច្បាប់នៃរបាយការណ៍សវនកម្ម ដែលធ្វើឡើងដោយសវនករបរិស្ថានខាងក្រៅ ត្រូវប្រគល់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១៤២** ._ ការចំណាយចំពោះការធ្វើសវនកម្មបរិស្ថាន

រាល់ការចំណាយដែលទាក់ទិនជាមួយការធ្វើសវនកម្មបរិស្ថាន ត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់ប្រតិបត្តិករ ឬម្ចាស់គម្រោង ។

**មាត្រា១៤៣** ._ ការខកខាន មិនបានធ្វើតាមបទបញ្ជា ឬលក្ខខណ្ឌតម្រូវ

ក្នុងករណីដែលគម្រោង ឬសកម្មភាពណាមួយ ខកខានមិនបានធ្វើតាមបទបញ្ជា ឬលក្ខខណ្ឌតម្រូវក្នុងការធ្វើសវនកម្មបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬសវនករបរិស្ថានដែលត្រូវបានទទួលស្គាល់ និងបានតែងតាំងដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវបាន

អនុញ្ញាតឱ្យធ្វើសវនកម្មបរិស្ថាន និងអាចចូលទៅកាន់ទីតាំង ដើម្បីធ្វើសវនកម្មបរិស្ថានលើគម្រោង ឬសកម្ម ភាពណាមួយនោះ ។

ម្ចាស់គម្រោង ឬប្រតិបត្តិករ គម្រោង ឬសកម្មភាពត្រូវផ្តល់ជូន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានវិញសម្រាប់ការចំណាយដែលទាក់ទងទៅនឹងសវនកម្មបរិស្ថាន ដែលធ្វើឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬសវនករបរិស្ថានដែលបានតែងតាំងដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១៤៤** ._ ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលតម្រូវឱ្យមានការឯកភាព ឬលិខិតអនុញ្ញាត ស្របតាមក្រមនេះ ត្រូវអនុវត្តការអង្កេតតាមដាន និងរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

**មាត្រា១៤៥** ._ ដំណោះស្រាយផលប៉ះពាល់

ក្នុងករណីដែលសវនកម្មបរិស្ថានបង្ហាញឱ្យឃើញថា ផលប៉ះពាល់របស់គម្រោង និងឬសកម្មភាពនោះធំជាងអ្វីដែលបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬផែនការគ្រប់គ្រងបរិស្ថានដែលពាក់ព័ន្ធ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវចាត់វិធានការភ្លាមៗ ដើម្បីដោះស្រាយផលប៉ះពាល់ទាំងនោះ និងបញ្ជាឱ្យធ្វើការកែតម្រូវលើផែនការគ្រប់គ្រងបរិស្ថានឱ្យបានសមស្រប ដើម្បីបញ្ចៀសផលប៉ះពាល់នៅពេលអនាគត ។

**មាត្រា១៤៦** ._ សិទ្ធិទទួលបានព័ត៌មាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវដាក់របាយការណ៍សវនកម្មបរិស្ថានឱ្យសាធារណជនអាចស្វែងរកបាន ក្រោយពេលដែលសវនកម្មបរិស្ថាននោះ ត្រូវបានដាក់បញ្ជូនទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី២
## ការតែងតាំង និងលក្ខណៈសម្បត្តិរបស់សវនករបរិស្ថាន

**មាត្រា១៤៧**._ លក្ខខណ្ឌតម្រូវក្នុងការទទួលបាននីតិសម្បទា

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលបាននីតិសម្បទា ជាសវនករបរិស្ថាន ស្របតាមមាតិកានេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ត្រូវទទួលបានការអនុញ្ញាតឱ្យអនុវត្តសវនកម្មបរិស្ថាន ។

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលអនុវត្តសវនកម្មបរិស្ថាន ត្រូវទទួលនីតិសម្បទា និងការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នីតិវិធី និងគោលការណ៍ណែនាំក្នុងការទទួលស្គាល់សវនកម្មបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## គន្ថីទី៣
## ការគ្រប់គ្រងបរិស្ថាន និងយន្តការថែរក្សា
## មាតិកាទី១
## ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
## ជំពូកទោល
## ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

**មាត្រា១៤៨**._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តលើសកម្មភាព ការគ្រប់គ្រង និងការកាត់បន្ថយគ្រោះមហន្តរាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៤៩**._ កិច្ចសហការលើការគ្រប់គ្រងគ្រោះមហន្តរាយ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវគាំទ្រ និងសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បី ៖

១- រៀបចំការគ្រប់គ្រង និងការកាត់បន្ថយ គ្រោះមហន្តរាយ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្ស ។

២- ត្រៀមបង្ការ និងកាត់បន្ថយ មុនពេលមានគ្រោះមហន្តរាយ ការឆ្លើយតបសង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ និងការស្តារឡើងវិញ ក្រោយពេលមានគ្រោះមហន្តរាយ ។

៣- វាយតម្លៃមូលហេតុនៃឫសគល់នៃភាពងាយរងគ្រោះចំពោះគ្រោះមហន្តរាយ ដែលអាចកើតឡើង និងបានកើតឡើងរួចមកហើយ ។

៤- ពង្រឹងសមត្ថភាពស្ថាប័នដើម្បីគ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយ ។

៥- ធ្វើការជាមួយសហគមន៍មូលដ្ឋាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីបង្កើតភាពធន់ទ្រាំរបស់សហគមន៍មូលដ្ឋានទៅនឹងគ្រោះមហន្តរាយ រួមមានជាអាទិ៍ ផលប៉ះពាល់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៥០** ._ ការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយដែលប៉ះពាល់ដល់បរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវគាំទ្រ និងសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដើម្បី ៖

១- រៀបចំផែនការកាត់បន្ថយគ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្សដែលប៉ះពាល់ដល់បរិស្ថាន ។

២- រៀបចំផែនការត្រៀមបម្រុង និងផែនការឆ្លើយតបសង្គ្រោះបន្ទាន់សម្រាប់គ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្សដែលប៉ះពាល់ដល់បរិស្ថាន ។

៣- រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហានិភ័យ និងបច្ចេកទេស ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៥១** ._ ការបណ្តុះបណ្តាល និងការអប់រំ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវគាំទ្រ និងសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បី ៖

១- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការគ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយ ។

២- រៀបចំ និងផ្តល់ការបណ្តុះបណ្តាល និងការអប់រំអំពីការគ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយ ។

៣- និងលើកទឹកចិត្តឱ្យមានការចូលរួមទប់ស្កាត់ គ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយ ។

**មាត្រា១៥២ ._** ការពិគ្រោះយោបល់ស្ដីពីការគ្រប់គ្រង និងកាត់បន្ថយហានិភ័យ

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្ត និងផែនការគ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយ ដែលបង្កឡើងដោយមនុស្ស ឬធម្មជាតិ ដែលបង្កផលប៉ះពាល់ដល់បរិស្ថាន ។

## មាតិកាទី២
## ការអភិវឌ្ឍដោយចីរភាព
## ជំពូកទី១
## ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រការងារអភិវឌ្ឍន៍ដោយចីរភាព និងរបាយការណ៍ជាតិ

**មាត្រា១៥៣ ._** ការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍ដោយចីរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានតួនាទីសហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍ដោយចីរភាព ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានតួនាទីសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើការតាមដាន និងត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា១៥៤ ._** ការរៀបចំរបាយការណ៍ជាតិស្ដីពីការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានតួនាទីសហការនិងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំរបាយការណ៍ជាតិ អំពីការអនុវត្តអនុសញ្ញាសហប្រជាជាតិ ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិ ។

## ជំពូកទី២
## ការអភិរក្សក្រៅតំបន់ប្រព័ន្ធតំបន់ការពារធម្មជាតិ

**មាត្រា១៥៥ ._** ការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់បង្កើតសារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិ សួនរុក្ខឧទ្យាន និងតិណាល័យ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានតួនាទីរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់បង្កើតសារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិ សួនរុក្ខឧទ្យាន សួនរុក្ខជាតិ តិណាល័យ និងធនាគារហ្សែន ការអភិរក្សជីវៈចម្រុះតាមវាលស្រែ និងក្រៅតំបន់ការពារធម្មជាតិ ដើម្បីលើកកម្ពស់ការអភិរក្ស ការសិក្សាស្រាវជ្រាវ និងការអប់រំផ្សព្វផ្សាយបង្កើនចំណេះដឹងដល់សាធារណជន ។

**មាត្រា១៥៦ ._** ការរៀបចំគោលនយោបាយ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវធនធានជីវៈចម្រុះ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានតួនាទីក្នុងការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ ធនធានជីវៈចម្រុះ និងជីវសុវត្ថិភាពសម្រាប់ការអភិវឌ្ឍដោយចីរភាព ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានតួនាទីសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យតាមដានប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត ។

## មាតិកាទី៣
## ការប្រែប្រួលអាកាសធាតុ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១៥៧ ._** វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តលើរាល់សកម្មភាព គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៥៨ ._** ភារកិច្ច និងតួនាទីរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានភារកិច្ច និងតួនាទី ដូចខាងក្រោម ៖

១- សម្របសម្រួល និងអនុវត្តការឆ្លើយតបរបស់ព្រះរាជាណាចក្រកម្ពុជា ចំពោះការប្រែប្រួលអាកាសធាតុ និងរៀបចំរបាយការណ៍ និងផ្តល់អនុសាសន៍ស្តីពីការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ដើម្បីដាក់ជូនទៅរាជរដ្ឋាភិបាល ។

២- ដឹកនាំកិច្ចចរចាជាលក្ខណៈអន្តរជាតិ និងការរៀបចំរបាយការណ៍ទៅកាន់ស្ថាប័នអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

៣- ដឹកនាំក្នុងការរៀបចំវិធានការ កម្មវិធី និងគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ។

៤- ដឹកនាំក្នុងការរៀបចំក្របខ័ណ្ឌសម្រាប់សកម្មភាពនៃការប្រែប្រួលអាកាសធាតុ និងកៀរគរធនធាន ដើម្បីឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ។

៥- ផ្តល់ការគាំទ្រ និងសម្របសម្រួលផ្នែកបច្ចេកទេសទៅដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងការអនុវត្តវិធានការ កម្មវិធី និងគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ ។

៦- សម្របសម្រួលជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងការគ្រប់គ្រង និងដាក់ឱ្យសាធារណជនអាចស្វែងរកបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ។

## ជំពូកទី២
## គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា១៥៩ ._** ការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំ ធ្វើបច្ចុប្បន្នភាព និងសម្របសម្រួលលើការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុថ្នាក់ជាតិរយៈពេលវែង ដើម្បីធ្វើការដោះស្រាយអំពី ៖

១- វិធានការពាក់ព័ន្ធសម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ។

២- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

៣- ការផ្តល់ហិរញ្ញប្បទានលើការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាព ។

ការរៀបចំខាងលើនេះ ត្រូវធ្វើឡើងឱ្យស្របតាមគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខី ។

**មាត្រា១៦០** ._ ការធ្វើផែនការយុទ្ធសាស្ត្រជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការ ដោយសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវដាក់បញ្ចូលការយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិដែលពាក់ព័ន្ធ និងដាក់ចេញនូវគោលការណ៍ណែនាំស្តីពីការដាក់បញ្ចូលការយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ ឱ្យទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា១៦១** ._ ផែនការ និងថវិកាតាមវិស័យ

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវកំណត់ ដាក់បញ្ចូល និងអនុវត្តសកម្មភាពឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ចូលទៅក្នុងផែនការតាមវិស័យ ថវិកា និងក្នុងក្របខ័ណ្ឌនៃការអង្កេតតាមដានការអនុវត្ត ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុដែលចេញដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងស្របតាមកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខី ។

**មាត្រា១៦២** ._ ការរៀបចំផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគ

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ នៅក្នុងគ្រប់ផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគ ។

រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជាមួយមន្ទីររាជធានី ខេត្តចំណុះឱ្យក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ត្រូវដាក់បញ្ចូលផលប៉ះពាល់ និងវិធានការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុទៅក្នុងគ្រប់ផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគ រួមមានការរៀបចំផែនការប្រើប្រាស់ដីធ្លី និងត្រូវរៀបចំ និងអនុវត្តផែនការ និងយុទ្ធសាស្ត្រនានា ដើម្បីឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ស្របតាមគោលនយោបាយជាតិពាក់ព័ន្ធស្តីពីការប្រែប្រួលអាកាសធាតុ ។

## ជំពូកទី៣
## ការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា១៦៣**._ ការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ត្រូវសម្រប សម្រួលជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ដូច ខាងក្រោម ៖

១- ការចាត់វិធានការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ មានជាអាទិ៍ ៖

- វាយតម្លៃភាពងាយរងគ្រោះនៃប្រព័ន្ធជីវសាស្ត្រ សង្គម និងសេដ្ឋកិច្ច ចំពោះការប្រែប្រួលអាកាសធាតុ រួមមាន វិស័យដែលងាយទទួលរងបញ្ហាអាកាសធាតុ និងតំបន់ភូមិសាស្ត្រដែលងាយទទួលរងគ្រោះមហន្តរាយ ដែលទាក់ទងនឹងអាកាសធាតុ និងកំណត់ឱកាសសម្រាប់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ

- រៀបចំ និងអនុវត្តហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ទ្រាំទៅនឹងអាកាសធាតុ និងដែលបញ្ចេញកាបូនទាប រួមមាន សម្រាប់វិស័យកសិកម្ម ជលផល ដឹកជញ្ជូន និងថាមពល

- រៀបចំ និងអនុវត្តវិធានការគ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិ ដើម្បីបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ

- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្តល់ព័ត៌មានជាមុន និងការផ្សព្វផ្សាយព័ត៌មានអាកាសធាតុទាន់ពេលវេលា

- លើកកម្ពស់ទម្លាប់នៃការរស់នៅដោយចីរភាព ដែលបង្កើនភាពធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ

- ធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាថាមពល ទឹក ដឹកជញ្ជូន សុខភាព និងអនាម័យ ដែលមានតម្លៃសមរម្យអាចទទួលយកបាន ។

២- ចាត់វិធានការកាត់បន្ថយការប្រែប្រួលអាកាសធាតុ មានជាអាទិ៍ ៖

- លើកកម្ពស់ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធផលថាមពល

- លើកកម្ពស់ការអភិវឌ្ឍ និងការប្រើប្រាស់ថាមពលកកើតឡើងវិញគ្រប់វិស័យទាំងអស់

- បង្កើនផលិតកម្មថាមពលតាមបណ្តាញវិមជ្ឈការ ដែលមានភាពធន់ទ្រាំ និងផលិតកម្មថាមពលក្រៅបណ្តាញ

- លើកកម្ពស់ការអភិវឌ្ឍ និងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ និងការប្រើប្រាស់ការដឹកជញ្ជូនដែលសន្សំសំចៃឥន្ធនៈ និងការដឹកជញ្ជូនដែលបញ្ចេញកាបូនទាប

- បង្កើនគម្របព្រៃឈើ និងលើកកម្ពស់ការគ្រប់គ្រងព្រៃឈើដោយចីរភាព និងយន្តការលើកកម្ពស់ការអភិរក្សព្រៃឈើ

- និងលើកកម្ពស់ទម្លាប់គ្រប់គ្រងការប្រើប្រាស់ដីដោយត្រឹមត្រូវ ដើម្បីការពារអាងស្រូបកាបូន និងដាក់កម្រិតលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។

៣- អនុវត្តនូវសកម្មភាពបន្ថែម មានជាអាទិ៍ ៖

- ពង្រឹងសមត្ថភាពស្ថាប័ន និងបច្ចេកទេស ដើម្បីឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

- ពង្រឹងចំណេះដឹងអំពីទម្លាប់ និងបច្ចេកវិទ្យានានាក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលស័ក្តិសមបំផុតចំពោះបរិបទកម្ពុជា

- លើកកម្ពស់ការស្រាវជ្រាវ ការផ្ទេរបច្ចេកវិទ្យា ការអប់រំ និងកិច្ចសហការអន្តរជាតិ នៅក្នុងគ្រប់វិស័យនៃការប្រែប្រួលអាកាសធាតុ

- លើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីការប្រែប្រួលអាកាសធាតុ

- កៀរគរហិរញ្ញវត្ថុអាកាសធាតុ ។

**មាត្រា១៦៤** ._ កិច្ចសហការ និងភាពជាដៃគូ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវ ៖

១- សម្របសម្រួលកិច្ចសហការអន្តរក្រសួង និងការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។

២- បង្កើតភាពជាដៃគូ និងអនុស្សារណៈយោគយល់សម្រាប់ការអនុវត្ត និងពង្រីកបន្ថែមនូវការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិ ។

**មាត្រា១៦៥** ._ ការធ្វើសេចក្តីសម្រេច និងសកម្មភាពអនុវត្ត

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវ ៖

១- ដាក់បញ្ចូលការយកចិត្តទុកដាក់អំពីការប្រែប្រួលអាកាសធាតុ ទៅក្នុងការរៀបចំ សកម្មភាពអនុវត្ត និងកិច្ចដំណើរការនៃការធ្វើការធ្វើសេចក្តីសម្រេច មានជាអាទិ៍ ការវាយតម្លៃ បរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

២- យកចិត្តទុកដាក់អំពីផលប៉ះពាល់នៃសកម្មភាព ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការ ប្រឈមទៅនឹងហានិភ័យអាកាសធាតុ និងសមត្ថភាពបន្សាំ ។

## ជំពូកទី៤
## ការអង្កេតតាមដាន និងការវាយតម្លៃការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា១៦៦**._ ក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃថ្នាក់ជាតិ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវ រៀបចំ និងចាត់ចែងឱ្យមានក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃថ្នាក់ជាតិមួយ ដើម្បីតាមដានវឌ្ឍន ភាពក្នុងការដោះស្រាយបញ្ហាប្រឈមដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ និងជូនដំណឹង អំពីការពិនិត្យ និងការធ្វើបច្ចុប្បន្នភាព នៃការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ។

ក្របខ័ណ្ឌនៃការអង្កេតតាមដាន និងការវាយតម្លៃថ្នាក់ជាតិស្តីពីការឆ្លើយតបចំពោះការប្រែ ប្រួលអាកាសធាតុ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយ ចីរភាព ។

**មាត្រា១៦៧** ._ ក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃតាមវិស័យ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយមានការគាំទ្រពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំ និងចាត់ចែងឱ្យមានក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលបរិស្ថាន តាម វិស័យនីមួយៗ ដើម្បីតាមដានប្រសិទ្ធភាពនៃវិធានការឆ្លើយតប ដែលមានកំណត់នៅក្នុងផែនការឆ្លើយ តបចំពោះការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ។

ក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ត្រូវ កំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា១៦៨** ._ សកម្មភាពអង្កេតតាមដាន និងវាយតម្លៃ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសម្របសម្រួល និងអនុវត្តសកម្មភាពអង្កេតតាមដាន និងវាយតម្លៃពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជាមួយមន្ទីររាជធានី ខេត្ត ចំណុះឱ្យស្ថាប័នមានសមត្ថកិច្ច និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវអនុវត្តសកម្មភាព អង្កេតតាមដាន និងវាយតម្លៃការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ស្របទៅតាមលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិស្តីពីក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុ តាមវិស័យនីមួយៗ ។

**មាត្រា១៦៩**._ ការរៀបចំរបាយការណ៍ស្តីពីការអង្កេតតាមដាន និងការវាយតម្លៃ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំរបាយការណ៍ទៅកាន់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ស្តីពី ៖

១- សូចនាករពាក់ព័ន្ធសម្រាប់ក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃថ្នាក់ជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ។

២- ក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុតាមវិស័យ នីមួយៗដែលពាក់ព័ន្ធ ។

៣- ក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃដទៃទៀត ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវវាយការណ៍ជូនរាជរដ្ឋាភិបាល និងដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានអំពីរបាយការណ៍ទាំងនេះ ។

**មាត្រា១៧០**._ កាតព្វកិច្ចរៀបចំរបាយការណ៍ជាអន្តរជាតិ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវទទួលខុសត្រូវចំពោះការរៀបចំរបាយការណ៍ និងបញ្ជូនទៅកាន់អង្គការអន្តរជាតិ ស្តីពីការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី មានជាអាទិ៍ របាយការណ៍ជាតិ របាយការណ៍បច្ចុប្បន្នភាពរៀងរាល់ ២ (ពីរ) ឆ្នាំ ម្តង និងរបាយការណ៍ស្តីពីការអនុវត្តការរួមវិភាគទានដែលកំណត់នៅថ្នាក់ជាតិ នៅក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៅក្នុងការរៀបចំរបាយការណ៍ទៅកាន់អង្គការអន្តរជាតិ ស្តីពីការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៧១ ._** ការរៀបចំលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការអង្កេតតាមដាន ការរៀបចំរបាយការណ៍ និងការផ្ទៀងផ្ទាត់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំ និងគ្រប់គ្រងយន្តការពាក់ព័ន្ធនឹងការអង្កេតតាមដាន ការរៀបចំរបាយការណ៍ និងការផ្ទៀងផ្ទាត់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីប្រភពនានា និងការស្រូបយកឧស្ម័នផ្ទះកញ្ចក់តាមរយៈអាងស្រូបកាបូន រួមមានយន្តការបង់ថ្លៃដោយផ្អែកលើលទ្ធផល ។

លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវអនុលោមតាមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ និងលក្ខខណ្ឌតម្រូវនៃយន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព ។

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំបង្កើតនីតិវិធី ដែលទាក់ទងទៅនឹងការកំណត់វិធានការ ការរៀបចំរបាយការណ៍ និងការផ្ទៀងផ្ទាត់ ស្របតាមលិខិតបទដ្ឋានគតិយុត្ត ស្តីពីការអង្កេតតាមដាន ការរៀបចំរបាយការណ៍ ការផ្ទៀងផ្ទាត់ និងការវាយតម្លៃ ។

**មាត្រា១៧២ ._** ការដាក់បញ្ចូលក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុ

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវដាក់បញ្ចូលក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ទៅក្នុងលិខិតបទដ្ឋានគតិយុត្តរួម ស្តីពីការអង្កេតតាមដាន និងការវាយតម្លៃការប្រែប្រួលអាកាសធាតុ ។

## ជំពូកទី៥
## ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ

**មាត្រា១៧៣ ._** សកម្មភាព និងព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវប្រមូល ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធទៅនឹងការអនុវត្តការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការប្រែប្រួលអាកាសធាតុ ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្នុងការប្រមូលធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុ ដែលពាក់ព័ន្ធទៅនឹងវិស័យរបស់ខ្លួន ។

**មាត្រា១៧៤** ._ ការគ្រប់គ្រងព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការផលិត និងការគ្រប់គ្រងទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៧៥** ._ កិច្ចព្រមព្រៀងស្តីពីការផលិត និងការចែករំលែកទិន្នន័យ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អាចចុះកិច្ចព្រមព្រៀងស្តីពីការផលិត និងការចែករំលែកទិន្នន័យជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងនីតិបុគ្គលដទៃទៀត ដើម្បីពង្រឹង និងបង្កើនសិទ្ធិទទួលបានទិន្នន័យ និងព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធនឹងការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៧៦** ._ ការរៀបចំរបាយការណ៍ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងនីតិបុគ្គលដទៃទៀត ដោយសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវ ៖

១- រៀបចំរបាយការណ៍ស្តីពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមវិស័យ និងតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

២- រៀបចំរបាយការណ៍ស្តីពីការកាត់បន្ថយការបញ្ចេញឧស្ម័នដែលកើតចេញពីយន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព រួមមានយន្តការបង់ថ្លៃដោយផ្អែកលើលទ្ធផល ។

ការរៀបចំរបាយការណ៍ខាងលើនេះ ត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងមាត្រា១៧៩ នៃក្រមនេះ ។

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំរបាយការណ៍ជូនក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ស្តីពីវឌ្ឍនភាពនៃការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៧៧** ._ ប្រព័ន្ធព័ត៌មានដែលសាធារណជនអាចស្វែងរកបាន

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានដែលសាធារណជនអាចស្វែងរកបាន ដើម្បីប្រមូលផ្តុំព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ដែលផលិតដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងនីតិបុគ្គលពាក់ព័ន្ធ ។

**មាត្រា១៧៨** ._ ការរៀបចំបញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំ និងគ្រប់គ្រងបញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ដែលសាធារណជនអាចស្វែងរកបាន ស្របតាមវិធីសាស្ត្រ និងការណែនាំពាក់ព័ន្ធ ។

**មាត្រា១៧៩** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីការប្រមូលការផលិត និងការធានាគុណភាព និងបញ្ជូនទិន្នន័យសារពើភណ្ឌ ដែលទាក់ទងនឹងប្រភេទនៃអាងស្រូបកាបូន និងប្រភពនៃការបញ្ចេញកាបូន កម្រិតបរិមាណព្រៃឈើ ការប្រមូលទិន្នន័យសកម្មភាព និងលក្ខខណ្ឌ តម្រូវនៃការរៀបចំរបាយការណ៍ ។

**មាត្រា១៨០** ._ ការរៀបចំរបាយការណ៍ស្តីពីបញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំរបាយការណ៍ស្តីពីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ពីប្រភពបញ្ចេញ និងអាងស្រូបកាបូន ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពក្នុងការរៀបចំរបាយការណ៍ពីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ពីប្រភពបញ្ចេញ និងអាងស្រូបកាបូន ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងម្ចាស់គម្រោង ត្រូវផ្តល់ព័ត៌មាន និងទិន្នន័យសម្រាប់ការរៀបចំបញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ដែលកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា១៨១ ._** បញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំ និងគ្រប់គ្រងបញ្ជីថ្នាក់ជាតិសម្រាប់ គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលសាធារណជនអាចស្វែងរកបាន ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងម្ចាស់គម្រោង ត្រូវផ្តល់ឯកសារអំពីគម្រោងជូនក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

បញ្ជីថ្នាក់ជាតិនេះ ត្រូវដាក់បញ្ចូលនូវ ៖

១- បញ្ជីនានាដែលមានស្រាប់ ស្របតាមយន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាពដែលពាក់ព័ន្ធ រួមមានយន្តការបង់ថ្លៃដោយផ្អែកលើលទ្ធផល ។

២- យន្តការឥណទានកាបូនដទៃទៀត ដែលស្របតាមលក្ខខណ្ឌតម្រូវក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៨២ ._** ការដាក់បញ្ចូលព័ត៌មានទៅក្នុងបញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការដាក់បញ្ចូលព័ត៌មានទៅក្នុងបញ្ជីថ្នាក់ជាតិនៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ស្របតាមបទប្បញ្ញត្តិ និងការណែនាំអន្តរជាតិពាក់ព័ន្ធ ។

**មាត្រា១៨៣ ._** ការអនុវត្តតាមបញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

អ្នកចូលរួមទាំងអស់នៅក្នុងយន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព និងយន្តការដទៃទៀតដែលមិនត្រូវបានរៀបចំឡើងក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ស្តីពីការដាក់បញ្ចូលព័ត៌មានទៅក្នុងបញ្ជីព័ត៌មានថ្នាក់ជាតិ សម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។

## ជំពូកទី៦

## ក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ

**មាត្រា១៨៤ ._** ការរៀបចំក្របខ័ណ្ឌហិរញ្ញប្បទាន

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំ និងគ្រប់គ្រងក្របខ័ណ្ឌហិរញ្ញប្បទាន សម្រាប់សកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ។

ក្របខ័ណ្ឌនេះ ត្រូវដាក់បញ្ចូលនូវ ៖

១- ការវិភាគអំពីតម្រូវការហិរញ្ញប្បទាន ។

២- យុទ្ធសាស្ត្រក្នុងការបំពេញតម្រូវការហិរញ្ញប្បទាននេះ តាមរយៈការប្រើប្រាស់ប្រភពហិរញ្ញវត្ថុក្នុងស្រុក និងក្រៅស្រុកដែលអាចស្វែងរកបាន ។

៣- វិធានការនៃការអភិវឌ្ឍសមត្ថភាព ។

៤- កំណែទម្រង់ស្ថាប័ន ឬយន្តការហិរញ្ញវត្ថុ ដើម្បីធ្វើការកៀរគរ និងគ្រប់គ្រងហិរញ្ញវត្ថុទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៨៥ ._** ក្រុមប្រឹក្សាពិគ្រោះយោបល់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចតែងតាំងក្រុមប្រឹក្សាពិគ្រោះយោបល់មួយ ដើម្បីរៀបចំ និងគ្រប់គ្រងក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់សកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចមានចែងក្នុងមាត្រា១៨៤ នៃក្រមនេះ ។

សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

## ផ្នែកទី១
## ការប្រែប្រួលអាកាសធាតុនៅក្នុងថវិកាជាតិ និងថ្នាក់ក្រោមជាតិ

**មាត្រា១៨៦ ._** ការប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការរៀបចំថវិកាជាតិ និងថ្នាក់ក្រោមជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីក្រុម

ប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់ និងដំណោះស្រាយផ្សេងៗនៃការប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការរៀបចំថវិកាជាតិ និងថ្នាក់ក្រោមជាតិ ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវផ្តល់ឱ្យក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវការវិភាគអំពីហានិភ័យ និងអាទិភាពនៃការប្រែប្រួលអាកាសធាតុប្រចាំឆ្នាំ ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវយកចិត្តទុកដាក់ និងដាក់បញ្ចូលនូវ ៖

១- ការវិភាគអំពីហានិភ័យ និងអាទិភាពនេះ ទៅក្នុងលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំថវិកាប្រចាំឆ្នាំ ។

២- គោលការណ៍ណែនាំស្តីពីការដាក់បញ្ចូលផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ ទៅក្នុងនីតិវិធី និងការណែនាំស្តីពីការរៀបចំផែនការថវិកា ។

**មាត្រា១៨៧ ._** ការប្រែប្រួលអាកាសធាតុនៅក្នុងការលើកសំណើសុំថវិកា

ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដាក់បញ្ចូលនូវផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ នៅក្នុងការលើកសំណើសុំថវិការបស់ខ្លួន ស្របតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី២
## ការវិនិយោគដែលគិតគូរចំពោះការប្រែប្រួលអាកាសធាតុពីវិស័យឯកជន

**មាត្រា១៨៨ ._** ការលើកកម្ពស់ការវិនិយោគដែលគិតគូរចំពោះការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ អំពីវិធានការសារពើពន្ធ បទប្បញ្ញត្តិ ស្តង់ដារ និងយន្តការ ដែលផ្អែកលើទីផ្សារ ដើម្បីលើកកម្ពស់ការវិនិយោគដែលគិតគូរចំពោះការប្រែប្រួលអាកាសធាតុ ។

## ផ្នែកទី៣
## ការកៀរគរហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស

**មាត្រា១៨៩ ._** ការសម្របសម្រួលអំពីហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសម្របសម្រួលលើការកៀរគរហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស ឱ្យមានប្រសិទ្ធផល និងប្រសិទ្ធភាពបំផុត និងសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចាំបាច់ ។

ក្នុងករណីចាំបាច់ណាមួយដែលអាចឈានទៅដល់ការប្រើប្រាស់ហិរញ្ញប្បទាន ជាឥណទានពីដៃគូអភិវឌ្ឍន៍សម្រាប់ការប្រែប្រួលអាកាសធាតុ ត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយអនុវត្តតាមខ្លឹមសារនៃឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល ។

**មាត្រា១៩០ ._** ការត្រួតពិនិត្យហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវត្រួតពិនិត្យហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស និងធានាឱ្យមានការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ ទៅក្នុងកិច្ចចរចាជាមួយនឹងដៃគូអភិវឌ្ឍន៍ ។

## ផ្នែកទី៤
## ការលើកកម្ពស់យន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព

**មាត្រា១៩១ ._** យន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវពិនិត្យ ឯកភាព និងផ្តល់សុពលភាពចំពោះគម្រោងទាំងអស់ ដែលស្នើសុំការគាំទ្រពីរាជរដ្ឋាភិបាល ដើម្បីចូលរួមនៅក្នុងយន្តការទូទាត់ថ្លៃលក់កាបូនដែលរួមមានជាអាទិ៍ យន្តការនានាដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីស ។

**មាត្រា១៩២ ._** ការលើកកម្ពស់ការចូលរួមនៅក្នុងយន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការ

បញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវលើកកម្ពស់ការចូលរួមនៅក្នុងយន្តការទូទាត់ថ្លៃលក់កាបូនតាមរយៈ ៖

១- ការចេញគោលការណ៍ណែនាំ ស្ដីពីការទទួលបានហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុតាមរយៈការចូលរួមនៅក្នុងយន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព និងសហការជាមួយ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចាំបាច់ ។

២- ការរក្សា និងការផ្សព្វផ្សាយព័ត៌មានស្ដីពីប្រភពជម្រើសអាទិភាពផ្សេងៗ និងសក្ដានុពលសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័ន ។

៣- ការរក្សា និងការផ្សព្វផ្សាយព័ត៌មានស្ដីពីការកាត់បន្ថយការបញ្ចេញឧស្ម័ននៃគម្រោងដែលចូលរួមក្នុងយន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព តាមរយៈបញ្ជីថ្នាក់ជាតិស្ដីពីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ រួមមានព័ត៌មានអំពីទំហំនៃការផ្ដល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ ដែលប្រមូលបាន តាមរយៈការចូលរួមនៅក្នុងយន្តការដែលរួមវិភាគទានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រការអភិវឌ្ឍដោយចីរភាព ។

## មាតិកាទី៤
## ការប្រើប្រាស់ និងផលិតកម្មដោយនិរន្តរភាព
## ជំពូកទោល
## បទប្បញ្ញត្តិទូទៅ
## ផ្នែកទី១
## ការលើកកម្ពស់ការប្រើប្រាស់ និងផលិតកម្មដោយនិរន្តរភាព

**មាត្រា១៩៣ .**_ ការប្រើប្រាស់ដោយនិរន្តរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងការប្រើប្រាស់ដោយនិរន្តរភាព ។ អគ្គលេខា

ធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវរៀបចំនីតិវិធី និងបែបបទនៃការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ។

**មាត្រា១៩៤** ._ ផលិតកម្មដោយនិរន្តរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងផលិតកម្មដោយនិរន្តរភាព ។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវរៀបចំនីតិវិធី និងបែបបទនៃការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ។

**មាត្រា១៩៥** ._ ការវាយតម្លៃបច្ចេកវិទ្យាមេត្រីភាពបរិស្ថាន

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពដោយសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតយន្តការសម្រាប់ការផ្ទៀងផ្ទាត់ វាយតម្លៃ និងទទួលស្គាល់បច្ចេកវិទ្យាមេត្រីភាពបរិស្ថានដោយផ្អែកលើការអនុវត្តល្អៗ ស្របតាមបរិបទជាតិ និងអន្តរជាតិ ។

**មាត្រា១៩៦** ._ ការចុះបញ្ជីបច្ចេកវិទ្យាមេត្រីភាពបរិស្ថាន

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំបញ្ជី និងនីតិវិធីនៃការចុះបញ្ជីបច្ចេកវិទ្យាមេត្រីភាពបរិស្ថាន ។

## ផ្នែកទី២
## លទ្ធកម្មសាធារណៈដោយនិរន្តរភាព

**មាត្រា១៩៧** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មដោយនិរន្តរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មដោយនិរន្តរភាព ។

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំនីតិវិធី និងបែបបទស្តីពីលទ្ធកម្មដោយនិរន្តរភាព ។

**មាត្រា១៩៨ ._** គោលបំណង

លិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មដោយនិរន្តរភាព ត្រូវ ៖

១- លើកទឹកចិត្តចំពោះប្រសិទ្ធផលធនធាន ។

២- កំណត់ប្រភេទ និងលំដាប់អាទិភាពនៃផលិតផល និងសេវាកម្ម ដែលរួមមានបច្ចេកវិទ្យាមេត្រីភាពបរិស្ថាន សុវត្ថិភាព បរិស្ថាន និងហិរញ្ញវត្ថុបៃតង ។

៣- កំណត់នូវលក្ខណៈវិនិច្ឆ័យបរិស្ថានអប្បបរមា និងលក្ខខណ្ឌតម្រូវសម្រាប់ប្រតិបត្តិ ។

៤- កំណត់នូវលក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍សម្រាប់ប្រភេទនៃផលិតផល សេវាកម្ម និងទំហំនៃលទ្ធកម្ម ។

៥- ផ្តល់ការណែនាំសម្រាប់ការជ្រើសរើសអ្នកផ្គត់ផ្គង់ដែលមានលក្ខណៈសមស្រប ។

៦- ផ្តល់ការណែនាំសម្រាប់ការធ្វើសេចក្តីសម្រេច ដោយយកចិត្តទុកដាក់ដល់បរិស្ថាន មានជាអាទិ៍ ការថ្លឹងថ្លែងរវាងលក្ខណៈវិនិច្ឆ័យបរិស្ថានជាមួយនឹងលក្ខណៈវិនិច្ឆ័យនៃការទិញ រួមមានការគិតគូរដល់សេដ្ឋកិច្ច តម្លៃ ការប្រតិបត្តិការងារ និងគុណភាព ។

៧- កំណត់ឱ្យមានទណ្ឌកម្មសម្រាប់អ្នករំលោភបំពានទៅលើលក្ខខណ្ឌតម្រូវសម្រាប់ដំណើរការនៃផលិតកម្ម និងសេវាកម្មដែលត្រូវយកចិត្តទុកដាក់ដល់បរិស្ថាន ។

៨- កំណត់ឱ្យបានច្បាស់នូវវិធានការសម្រាប់ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវក្នុងការងារលទ្ធកម្ម ដើម្បីលើកទឹកចិត្ត និងជួយដល់អ្នកពាក់ព័ន្ធក្នុងការទទួលខុសត្រូវចំពោះការអនុវត្តលទ្ធកម្មដោយនិរន្តរភាព ។

**មាត្រា១៩៩ ._** ការអនុវត្តលិខិតបទដ្ឋានគតិយុត្តស្តីពីទម្លាប់នៃការធ្វើលទ្ធកម្ម

ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងអ្នកពាក់ព័ន្ធដែលទទួលខុសត្រូវទៅលើការងារលទ្ធកម្ម ត្រូវដាក់បញ្ចូលការអនុវត្តលទ្ធកម្មចំពោះទំនិញ និងសេវាកម្ម ទៅក្នុងលិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មដោយនិរន្តរភាព ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្ម ។

**មាត្រា២០០ ._** ការបញ្ចូលទម្លាប់នៃការអនុវត្តលទ្ធកម្មដោយនិរន្តរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធានាថា គ្រប់ក្រសួង ស្ថាប័ន វិស័យឯកជន និងអ្នកពាក់ព័ន្ធ

ដែលទទួលខុសត្រូវទៅលើការងារលទ្ធកម្ម បានបញ្ចូល និងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីការធ្វើលទ្ធកម្មដោយនិរន្តរភាព ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធត្រូវរៀបចំបែបបទ និងនីតិវិធីដើម្បីវាយតម្លៃការអនុវត្តលទ្ធកម្មដោយនិរន្តរភាព ដើម្បីជាមូលដ្ឋានក្នុងការផ្តល់ការលើកទឹកចិត្តសមស្រប ។

**មាត្រា២០១** ._ របាយការណ៍ប្រចាំឆ្នាំ

ក្រសួង ស្ថាប័នទទួលបន្ទុកការងារលទ្ធកម្មដោយនិរន្តរភាព ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំមួយស្តីពីការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការធ្វើលទ្ធកម្មដោយនិរន្តរភាព ។ របាយការណ៍នេះត្រូវបញ្ចូលចំណុចដូចតទៅ ៖

១- បញ្ជីនៃផលិតផល និងសេវាកម្មមេត្រីភាពបរិស្ថាន ។

២- ការវិភាគលើការអនុវត្តលក្ខណៈវិនិច្ឆ័យមេត្រីភាពបរិស្ថាន ។

៣- ផែនការប្រចាំឆ្នាំទាំងឡាយសម្រាប់ការធ្វើបញ្ជីលទ្ធកម្មនៃផលិតផល និងសេវាកម្មមេត្រីភាពបរិស្ថាន ជាអាទិភាព ។

ក្រសួង ស្ថាប័នទទួលបន្ទុកការងារលទ្ធកម្មដោយនិរន្តរភាព ត្រូវផ្តល់របាយការណ៍នេះ ទៅឱ្យក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២០២** ._ ការវាយតម្លៃនៃការអនុវត្ត

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវប្រើប្រាស់លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ និងព័ត៌មានរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តលទ្ធកម្មដោយនិរន្តរភាព ដើម្បីកំណត់នូវបញ្ហា និងប្រសិទ្ធផល នៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា២០៣** ._ ផលិតផលមេត្រីភាពបរិស្ថាន

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសម្របសម្រួល និងលើកទឹកចិត្តចំពោះក្នុងការផ្សព្វផ្សាយ ការទិញ ការប្រើប្រាស់ ការនាំចូល និងការនាំចេញផលិតផលមេត្រីភាពបរិស្ថាន ដែលជាកម្មវត្ថុនៃការអនុវត្តលទ្ធកម្មដោយនិរន្តរភាព ។

## ផ្នែកទី៣
## ការដាក់ស្លាកសញ្ញាមេត្រីភាពបរិស្ថាន

**មាត្រា២០៤ ._** ស្លាកសញ្ញាមេត្រីភាពបរិស្ថាន

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំស្តង់ដារមេត្រីភាពបរិស្ថានដើម្បីជាមូលដ្ឋានក្នុងការផ្តល់ស្លាកសញ្ញាមេត្រីភាពបរិស្ថានលើផលិតផល និងសេវាកម្ម ។

**មាត្រា២០៥ ._** ប្រភេទផលិតផល និងសេវាកម្ម

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវកំណត់ប្រភេទផលិតផល និងសេវាកម្ម លក្ខណៈវិនិច្ឆ័យ និងស្តង់ដារមេត្រីភាពបរិស្ថាន ការវាយតម្លៃលើសំណើសុំដាក់ស្លាកសញ្ញា ការចេញវិញ្ញាបនបត្របញ្ជាក់ និងការធ្វើសវនកម្ម និងវិធាននៃការប្រើប្រាស់ ។

ការកំណត់អំពីការដាក់ស្លាកសញ្ញាមេត្រីភាពបរិស្ថាន និងព័ត៌មានស្តីពីបន្ទុកបរិស្ថាននៅលើផលិតផល និងសេវាកម្មតាមប្រភេទនានា ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា២០៦ ._** បញ្ជីសារពើភណ្ឌផលិតផល និងសេវាកម្ម

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវធានាផ្សព្វផ្សាយនូវបញ្ជីសារពើភណ្ឌផលិតផល និងសេវាកម្មដែលទទួលបានវិញ្ញាបនកម្មមេត្រីភាពបរិស្ថានជាសាធារណៈ ។

## ផ្នែកទី៤
## ការវាយតម្លៃប្រសិទ្ធផលធនធាន

**មាត្រា២០៧ ._** វិសាលភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវធ្វើការវាយតម្លៃពីប្រសិទ្ធផលធនធាន ចំពោះនីតិបុគ្គលតាមវិស័យនីមួយៗដែលបានប្រើប្រាស់ធនធាន ហើយបង្កឱ្យមានផលប៉ះពាល់បរិស្ថាន ។

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត បែបបទ និងនីតិវិធីសម្រាប់ការវាយតម្លៃប្រសិទ្ធផលធនធាន ។

ការចេញលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណដែលពាក់ព័ន្ធនឹងការប្រើប្រាស់ និងផលិតកម្មនិរន្តរភាពចំពោះវិស័យពាក់ព័ន្ធ អាចធ្វើទៅបាន លុះត្រាតែមានការឯកភាពលើការវាយតម្លៃប្រសិទ្ធផលធនធាន ។

**មាត្រា២០៨ ._** ទីប្រឹក្សាវាយតម្លៃប្រសិទ្ធផលធនធាន

ការវាយតម្លៃប្រសិទ្ធផលធនធាន ត្រូវបានធ្វើឡើងដោយទីប្រឹក្សាវាយតម្លៃប្រសិទ្ធផលធនធាន ដែលត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ លក្ខណៈសម្បត្តិនៃទីប្រឹក្សាវាយតម្លៃ និងតម្លៃនៃការវាយតម្លៃ ត្រូវកំណត់ ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា២០៩ ._** របាយការណ៍នៃការវាយតម្លៃប្រសិទ្ធផលធនធាន

របាយការណ៍វាយតម្លៃប្រសិទ្ធផលធនធាន ត្រូវដាក់ជូនក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមនីតិវិធីជាធរមាន ។

**មាត្រា២១០ ._** ការវាយតម្លៃលើរបាយការណ៍

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការវាយតម្លៃ និងផ្តល់ការឯកភាពលើរបាយការណ៍វាយតម្លៃប្រសិទ្ធផលធនធាន ស្របតាមលក្ខខណ្ឌតម្រូវ និងស្តង់ដារ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា២១១ ._** ការធ្វើសវនកម្មប្រសិទ្ធផលធនធាន

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើសវនកម្មប្រសិទ្ធផលធនធានរបស់នីតិបុគ្គលពាក់ព័ន្ធ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការវាយតម្លៃ

ប្រសិទ្ធផលធនធាន និងការអនុវត្តវិធានការកាត់បន្ថយដែលបានកំណត់ ស្របតាមបទប្បញ្ញត្តិស្តីពីសវនកម្មបរិស្ថាន ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍ក្នុងគន្លឹះទី២ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា២១២** ._ គោលការណ៍ណែនាំ ការបណ្តុះបណ្តាល និងការសម្របសម្រួល

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវ ៖

១- រៀបចំ គោលការណ៍ណែនាំ ទាក់ទងនឹងប្រសិទ្ធផលធនធាន ការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ពីការប្រើប្រាស់ផលិតផល និងផលិតកម្មមេត្រីភាពបរិស្ថាន ។

២- បង្កើតគេហទំព័រព័ត៌មានស្តីពីផលិតកម្មមេត្រីភាពបរិស្ថាន និងប្រសិទ្ធផលធនធាន ។

៣- ផ្តល់ការបណ្តុះបណ្តាល និងបង្កើតបណ្តាញផ្សព្វផ្សាយលទ្ធផលស្តីពីផលិតកម្មមេត្រីភាពបរិស្ថាន ។

៤- ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ។

៥- សម្របសម្រួលការទទួលបានហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ ការវិនិយោគលើបច្ចេកវិទ្យាមេត្រីភាពបរិស្ថាន ។

## ផ្នែកទី៥
## ការទទួលខុសត្រូវរបស់ផលិតករ

**មាត្រា២១៣** ._ ការទទួលខុសត្រូវបន្ថែមរបស់ផលិតករ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតកម្មវិធី ដើម្បីជំរុញឱ្យផលិតករមានការទទួលខុសត្រូវចំពោះសំណល់ដែលបញ្ចេញក្រោយពីអ្នកប្រើប្រាស់បានប្រើប្រាស់រួច ។ កម្មវិធីនេះរួមមាន ៖

១- ការចូលរួមជាកាតព្វកិច្ច និងដោយស្ម័គ្រចិត្ត ក្នុងការទទួលខុសត្រូវរបស់ផលិតករដែលអនុវត្តលើ ផលិតផល ក្រុមផលិតផល និងលំហូរសំណល់ ។

២- គោលដៅសម្រាប់ការប្រមូល ការកែច្នៃ ការចម្រាញ់ និងការប្រើប្រាស់ឡើងវិញ ។

៣- កូតាសម្រាប់ការយកផលិតផលត្រលប់មកវិញ ។

៤- ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនៅក្នុង ខ្សែសង្វាក់នៃការផ្គត់ផ្គង់ រួមមានផលិតករក្នុងស្រុក និងអ្នកនាំចូលផលិតផល និងគ្រឿងបច្ចេកវិទ្យាពីបរទេស ។

៥- ការអភិវឌ្ឍសមត្ថភាពសម្រាប់អ្នកពាក់ព័ន្ធ ។

៦- ការទទួលខុសត្រូវរបស់ផលិតករ និងក្រុមគោលដៅផ្សេងទៀតដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ។

## មាតិកាទី៥
## ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុង ដោយនិរន្តរភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា២១៤** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះ មានវិសាលភាពលើការគ្រប់គ្រង និងការប្រើប្រាស់ដី និងធនធានដី ដែលយកចិត្តទុកដាក់ដល់បរិស្ថាន ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២១៥** ._ ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុងនិរន្តរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលនយោបាយ និងផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុងនិរន្តរភាព ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវរៀបចំបែបបទ និងនីតិវិធី នៃការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុងដោយនិរន្តរភាពដោយបញ្ចូលចំណុច ដូចមានចែងខាងក្រោម ៖

១- ការអភិរក្សបរិស្ថាន និងគោលបំណងអភិវឌ្ឍន៍ដោយនិរន្តរភាព ។

២- យន្តការសម្រាប់ការការពារ គ្រប់គ្រង និងកាត់បន្ថយហានិភ័យបរិស្ថាន ។

៣- ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានពីការគ្រប់គ្រង និងប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន ។

**មាត្រា២១៦ ._** ការប្រើប្រាស់ព័ត៌មាន និងទិន្នន័យវិទ្យាសាស្ត្រសម្រាប់ការរៀបចំផែនការ និងវិធាន
ការគ្រប់គ្រង

ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងវិធានការគ្រប់គ្រងទីក្រុងដោយនិរន្តរភាព ត្រូវផ្អែកលើព័ត៌មាន និងទិន្នន័យវិទ្យាសាស្ត្រជាក់លាក់ ។

## ជំពូកទី២
## តួនាទី និងការទទួលខុសត្រូវ

**មាត្រា២១៧ ._** សមត្ថកិច្ចនៃការគ្រប់គ្រងការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគររូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវមានសមត្ថកិច្ចគ្រប់គ្រងលើការប្រើប្រាស់ដី និងសំណង់ដើម្បីធានាបាននូវការអភិវឌ្ឍ និងការប្រើប្រាស់ដី និងធនធានដីប្រកបដោយប្រសិទ្ធភាព និរន្តរភាព សមធម៌ សុខដុមនីយកម្ម និងសមាហរណកម្ម ។

**មាត្រា២១៨ ._** សមត្ថកិច្ចទទួលបន្ទុកលើការចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការឯកភាព

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគររូបនីយកម្ម និងសំណង់មានសមត្ថកិច្ចទទួលបន្ទុកលើការចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការឯកភាពលើការអភិវឌ្ឍ និងការប្រើប្រាស់ដី និងធនធានដី ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តបរិស្ថានពាក់ព័ន្ធ ។

**មាត្រា២១៩ ._** លក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំគោលការណ៍ណែនាំ និងលក្ខខណ្ឌតម្រូវ នៃការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវពិនិត្យទៅលើលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការអភិវឌ្ឍន៍ និងការប្រើប្រាស់ដី និងធនធានដី ដែលបានស្នើដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសុំការឯកភាព ។

## ជំពូកទី៣

## ការរៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន

**មាត្រា២២០ ._** លក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកលើការរៀបចំផែនការប្រើប្រាស់ដី នៅក្នុងតំបន់នៃសំណើគម្រោងអភិវឌ្ឍន៍ កម្មវិធី ឬផែនការ ត្រូវធានាថាការរៀបចំផែនការប្រើប្រាស់ដីនោះ បានបំពេញតាមលក្ខខណ្ឌតម្រូវពេញលេញដូចខាងក្រោម ៖

១- មានកិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើផែនការប្រើប្រាស់ដីរបស់ម្ចាស់គម្រោង ។

២- ទទួលបាននូវការព្រមព្រៀងជាមុនពីសហគមន៍ជនជាតិដើមភាគតិច ក្នុងករណីដែលសិទ្ធិលើការគ្រប់គ្រង និងប្រើប្រាស់ដីរបស់ពួកគេ ទទួលរងការប៉ះពាល់ពីគម្រោងសកម្មភាព កម្មវិធី ឬផែនការ ។

៣- មានការបញ្ជាក់អំពីភាពត្រឹមត្រូវរបស់គម្រោង សកម្មភាព កម្មវិធី និងផែនការដែលបានស្នើសុំ ជាមួយនឹងផែនការគ្រប់គ្រងការប្រើប្រាស់ដី ផែនការមេស្តីពីការប្រើប្រាស់ដី និងផែនការយុទ្ធសាស្ត្រទីក្រុងដោយនិរន្តរភាព ។

៤- មានការស្រាវជ្រាវ និងការទទួលបាននូវទិន្នន័យលម្អិត នៅទីតាំងជាក់លាក់អំពីលក្ខណៈពិសេសនៃតំបន់ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដី រួមមានបញ្ជីសារពើភណ្ឌធនធានដី ការប្រើប្រាស់ដីបច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធ ស្ថានភាពប្រជាសាស្ត្រសិទ្ធិកាន់កាប់ដី រួមទាំងសិទ្ធិជាលក្ខណៈប្រពៃណី រចនាសម្ព័ន្ធសង្គម រុក្ខជាតិ ការធ្វើចលនាឆ្លងដែនរបស់សត្វព្រៃ ការរំខានដោយធម្មជាតិ មុខងារធារាសាស្ត្រ ចរន្តថាមពល និងរាល់ព័ត៌មានពាក់ព័ន្ធទាំងឡាយ ។

៥- មានការប្រើប្រាស់បច្ចេកវិទ្យាសមស្របក្នុងការកំណត់ផែនទី តំបន់ទេសភាព រួមមានការកំណត់ទីតាំង ការវាយតម្លៃពីធនធានធម្មជាតិ និងសេវាកម្មពាក់ព័ន្ធទៅនឹងធនធានធម្មជាតិ ទិន្នន័យនៃការប្រើប្រាស់ដី សិទ្ធិកាន់កាប់ដី និងតំបន់បេតិកភណ្ឌវប្បធម៌ដែលស្ថិតនៅក្នុងតំបន់អភិវឌ្ឍន៍ជាដើម ។

៦- ផ្តល់ដំណោះស្រាយសមស្របក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។

៧- មានការផ្តល់ដំណោះស្រាយទៅលើការបង្ករគ្រោះទឹកជំនន់ និងមានភ្ជាប់ទៅដោយផែនការនានា សម្រាប់ ៖

- ការបង្ហូរសំណល់រាវចេញចូលទាំងអស់ ទាំងនៅខាងក្នុង និងក្រៅតំបន់អភិវឌ្ឍ ឬតំបន់នៃផែនការប្រើប្រាស់ដី

- ហានិភ័យនៃការបំពុលទឹកក្រោមដី និងទឹកលើដី ក៏ដូចជាបញ្ហាពាក់ព័ន្ធ និងការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញសំណល់រាវ

- ការដាក់កម្រិត និងការគ្រប់គ្រងលំហូរសំណល់រឹង និងសំណល់រាវ រួមមានទីតាំងនានានៃការបញ្ចេញចោលជាដើម ។

៨- បញ្ចូលនូវវិធានការនៃការលើកកម្ពស់ការគ្រប់គ្រងដោយនិរន្តរភាពលើព្រៃឈើនៅក្នុងទីតាំងប្រតិបត្តិការគម្រោង សកម្មភាព ឬកម្មវិធី ។

៩- ដាក់បញ្ចូល និងប្រើប្រាស់នូវប្រព័ន្ធចំណត និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ប្រកបដោយប្រសិទ្ធផល នៅក្នុងទីតាំងប្រតិបត្តិការ ។

១០- ដាក់បញ្ចូលនូវគោលដៅ និងវិធានការកាត់បន្ថយផលប៉ះពាល់ ដែលគម្រោងសកម្មភាព កម្មវិធី ឬផែនការ រួមមាន ៖

- ដីរដ្ឋដែលបានកំណត់ជា តំបន់បេតិកភណ្ឌ ឬតំបន់ប្រវត្តិសាស្ត្រ ឬតំបន់វប្បធម៌ជាតិ

- របៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- តំបន់ទាំងឡាយដែលបានកាន់កាប់ និងស្ថិតនៅក្រោមការប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់ជនជាតិដើមភាគតិច

- តំបន់រ៉ាមសារ

- តំបន់បេតិកភណ្ឌអង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ សង្គម វិទ្យាសាស្ត្រ និងវប្បធម៌

- តំបន់ទាំងឡាយដែលត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ថាជាតំបន់ដែលមានទឹកសាប និងទឹកសមុទ្រសំខាន់ៗ ឬប្រព័ន្ធអេកូឡូស៊ីនៃតំបន់សមុទ្រ ឬតំបន់អភិរក្សទេសភាព ប្រភេទសត្វ និងរុក្ខជាតិ និងជីវៈចម្រុះដែលមានតម្លៃខ្ពស់ ឬតំបន់ដែលមានតម្លៃអភិរក្សប្រព័ន្ធអេកូឡូស៊ី

- តំបន់ដទៃទៀតដែលត្រូវបានកំណត់សម្រាប់ការការពារ ឬជាតំបន់ពិសេសដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

១១- លក្ខខណ្ឌតម្រូវក្នុងការដោះស្រាយគោលដៅ និងវិធានការសម្រាប់ការថែរក្សា នូវតម្លៃធនធានប្រវត្តិសាស្ត្រ វប្បធម៌ ឬធនធានធម្មជាតិ ដែលស្ថិតនៅក្នុងទីតាំងប្រតិបត្តិការ ។

១២- លក្ខខណ្ឌតម្រូវក្នុងការដោះស្រាយ និងទទួលយកគ្រប់កាតព្វកិច្ច និងការទទួលខុសត្រូវចម្បងក្នុងពេលអភិវឌ្ឍន៍ និងប្រតិបត្តិស្របតាមគោលការណ៍អ្នកបំពុលត្រូវបង់ថ្លៃចំណាយ ។

១៣- លក្ខខណ្ឌតម្រូវដែលបង្ហាញពីលំហបៃតងដែលមានទំហំសមស្រប ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដោយឡែក ដើម្បីកំណត់លក្ខខណ្ឌតម្រូវសម្រាប់លំហបៃតង ។

ក្នុងករណីដែលគម្រោង សកម្មភាព កម្មវិធី ឬផែនការដែលបានស្នើសុំនោះ មិនតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតម្រូវឱ្យគម្រោង សកម្មភាព កម្មវិធី ឬផែនការដែលបានស្នើសុំ បំពេញតាមលក្ខខណ្ឌតម្រូវខ្លះៗ ដូចមានចែងខាងលើ ។

**មាត្រា២២១** ._ ថ្លៃ និងបន្ទុកសេវា

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវយកកម្រៃសេវាសមស្រប ដើម្បីទ្រទ្រង់កិច្ចការរដ្ឋបាល ដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យ និងវាយតម្លៃលក្ខខណ្ឌតម្រូវនៃការប្រើប្រាស់ដី ស្របតាមមាតិកានេះ ។

កម្រៃសេវានេះ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២២២** ._ ការកែសម្រួលផែនការប្រើប្រាស់ដី

ក្នុងករណីដែលម្ចាស់គម្រោង ឬអាជ្ញាធរពាក់ព័ន្ធ មានបំណងកែសម្រួលផែនការប្រើប្រាស់ដី ម្ចាស់គម្រោង ឬអាជ្ញាធរពាក់ព័ន្ធដែលធ្វើការស្នើសុំកែសម្រួល ត្រូវផ្តល់ឯកសារដែលមានបញ្ជាក់ពីព័ត៌មានដូចខាងក្រោម ៖

១- ត្រូវមានហេតុផលផ្នែកសេដ្ឋកិច្ចសង្គម និងវិទ្យាសាស្ត្រ ដែលនាំឱ្យមានការកែសម្រួលផែនការប្រើប្រាស់ដី ។

២- បង្ហាញពីការខិតខំដើម្បីរក្សានូវស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន ។

៣- បង្ហាញពីផលប៉ះពាល់ទៅលើរបរចិញ្ចឹមជីវិតរបស់សហគមន៍ និងធុរកិច្ចនានាដោយសារការកែសម្រួលលើចំណាត់ថ្នាក់នៃការប្រើប្រាស់ដីដែលទទួលបានការអនុញ្ញាត ។

៤- បង្ហាញព័ត៌មានផ្សេងៗទៀតដែលចាំបាច់ក្នុងការផ្តល់ភាពសមហេតុផលនៃសំណើដែលបានស្នើសុំ ។

**មាត្រា២២៣** ._ លក្ខខណ្ឌតម្រូវសម្រាប់លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រឯកភាព

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ត្រូវធានាថាគ្រប់លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រឯកភាពអនុលោមទៅតាមលក្ខខណ្ឌតម្រូវនៃផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន ផែនការគ្រប់គ្រងដីដែលបានឯកភាព និងគោលនយោបាយគ្រប់គ្រងដីដទៃៗទៀត ។

គ្រប់រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវធ្វើសកម្មភាពដែលស្របទៅតាមផែនការប្រើប្រាស់ដីដែលបានឯកភាពរួចរាល់ ។

ក្នុងករណីមិនទាន់មានផែនការគ្រប់គ្រងដីជាមគ្គុទេសក៍ ផែនការមេស្តីពីការប្រើប្រាស់ដី ឬផែនការប្រើប្រាស់ដីនៅឡើយ នោះការផ្តល់អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រឯកភាពសម្រាប់ការអភិវឌ្ឍ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវនៃការប្រើប្រាស់ដីស្របតាមក្រមនេះ ។

## ជំពូកទី៤
## ទីក្រុងដោយនិរន្តរភាព
### ផ្នែកទី១
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា២២៤** ._ ផែនការយុទ្ធសាស្ត្រទីក្រុងដោយនិរន្តរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន

និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងដោយនិរន្តរភាព ។

**មាត្រា២២៥** ._ សមត្ថកិច្ចទទួលខុសត្រូវ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុវត្ត តាមភារកិច្ច និងការទទួលខុសត្រូវ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រទីក្រុងដោយនិរន្តរភាព ។

## ផ្នែកទី២
## យន្តការទីក្រុងដោយនិរន្តរភាព

**មាត្រា២២៦** ._ យន្តការទីក្រុងដោយនិរន្តរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំបង្កើតយន្តការទីក្រុងដោយនិរន្តរភាព ។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំបែបបទ និងនីតិវិធីក្នុងការបង្កើតយន្តការនេះ ដែលមានដូចខាងក្រោម ៖

១- រៀបចំផែនការទីក្រុង និងការដឹកជញ្ជូន ។

២- រៀបចំផ្នែកថាមពល និងផលិតកម្ម ។

៣- រៀបចំការគ្រប់គ្រងសំណល់ និងភាពងាយរងគ្រោះទីក្រុង ។

៤- រៀបចំលំហសាធារណៈ បេតិកភណ្ឌវប្បធម៌ និងបរិស្ថានសំណង់ ។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវ នៃការអនុវត្តយន្តការទីក្រុងដោយនិរន្តរភាព ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តតាមសំណើរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា២២៧** ._ ការរៀបចំផែនការសកម្មភាពទីក្រុងដោយនិរន្តរភាព

រដ្ឋបាលរាជធានី និងក្រុងតាមបណ្ដាខេត្ត ត្រូវបង្កើតផែនការសកម្មភាពសម្រាប់ទីក្រុងនិរន្តរភាព ស្របតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ ចក្ខុវិស័យ គោលដៅ និងស្ថានភាពជាក់ស្ដែងនៃរដ្ឋបាលរាជធានី ឬក្រុងនីមួយៗ ។

ផែនការសកម្មភាពទីក្រុងនិរន្តរភាពសម្រាប់រដ្ឋបាលរាជធានី ឬក្រុងនីមួយៗ ត្រូវអនុវត្តតាមដំណើរការ និងលក្ខខណ្ឌតម្រូវ ស្របតាមផែនការយុទ្ធសាស្ត្រទីក្រុងដោយនិរន្តរភាព ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្ររដ្ឋបាលរាជធានី និងក្រុងក្នុងការបង្កើតផែនការសកម្មភាពទីក្រុងដោយនិរន្តរភាព ។

**មាត្រា២២៨ ._** ការកែសម្រួលផែនការសកម្មភាពទីក្រុងដោយនិរន្តរភាព

រដ្ឋបាលរាជធានី និងក្រុងតាមបណ្ដាលខេត្ត ដោយមានការឯកភាពពីក្រសួង ស្ថាប័នមានសមត្ថកិច្ច មានសិទ្ធិស្នើឱ្យមានការត្រួតពិនិត្យឡើងវិញ និងធ្វើការកែសម្រួលផែនការសកម្មភាព ទីក្រុងដោយនិរន្តរភាព អាស្រ័យតាមការប្រែប្រួលស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ច ប្រជាសាស្ត្រ និងសង្គម ។

## មាតិកាទី៦
## ទេសចរណ៍ដោយនិរន្តរភាព
## ជំពូកទី១
## ការអភិវឌ្ឍទេសចរណ៍ដោយនិរន្តរភាព

**មាត្រា២២៩ ._** វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើគម្រោងអភិវឌ្ឍន៍ទេសចរណ៍ទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរួមបញ្ចូលគម្រោងដែលស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

**មាត្រា២៣០ ._** ការពិនិត្យនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍

រាល់គម្រោង ឬសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ដែលកំពុងអនុវត្តបច្ចុប្បន្ន ត្រូវតម្រូវឱ្យធ្វើការពិនិត្យលើនិរន្តរភាព ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកទេសចរណ៍ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីបែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យស្ដីពីការពិនិត្យលើនិរន្តរភាព ។

**មាត្រា២៣១** ._ ការវាយតម្លៃប្រសិទ្ធផលធនធាន

រាល់សកម្មភាព ឬគម្រោងអភិវឌ្ឍន៍ទេសចរណ៍ ដែលបង្កផលប៉ះពាល់ដល់បរិស្ថាន ដែលលើសពីកម្រិតដែលបានអនុញ្ញាត ឬឯកភាព ឬដែលមិនបានអនុលោមស្តង់ដារនានា នៃការវាយតម្លៃនិរន្តរភាព ត្រូវតម្រូវឱ្យធ្វើការវាយតម្លៃប្រសិទ្ធផលធនធាន ស្របតាមបទប្បញ្ញត្តិ ក្នុងគន្ថីទី៣ មាតិកាទី៨ នៃក្រមនេះ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកទេសចរណ៍ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីការវាយតម្លៃប្រសិទ្ធផលធនធានសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ ។

## ជំពូកទី២
## សហគមន៍ទេសចរណ៍ធម្មជាតិ

**មាត្រា២៣២** ._ សហគមន៍ទេសចរណ៍ធម្មជាតិ

រាល់គម្រោងសហគមន៍ទេសចរណ៍ធម្មជាតិ ដែលបានស្នើសុំនៅក្នុងសមាសភាគប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្ដីពីការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ ដូចមានចែងក្នុងគន្ថីទី៤ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា២៣៣** ._ តម្លៃចូលទស្សនា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចយកថ្លៃចូលទស្សនាពីគម្រោងសហគមន៍ទេសចរណ៍ធម្មជាតិ ដែលស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ ត្រូវកំណត់ពីកាលវិភាគសម្រាប់ការបង់ថ្លៃចូលទស្សនា ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវគ្រប់គ្រង និងប្រើប្រាស់តម្លៃចូលទស្សនា សម្រាប់តំបន់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ។

**មាត្រា២៣៤** ._ ទេសចរណ៍ធម្មជាតិ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុក បរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកទេសចរណ៍ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យទេសចរណ៍ធម្មជាតិ ។

បែបបទ និងនីតិវិធីនៃការគ្រប់គ្រងវិស័យទេសចរណ៍ធម្មជាតិ ត្រូវស្របតាមស្តង់ដារទេសចរណ៍ធម្មជាតិថ្នាក់ជាតិ និងអន្តរជាតិ ។

## មាតិកាទី៧
## ថាមពលដោយនិរន្តរភាព
## ជំពូកទី១
## ថាមពលដោយនិរន្តរភាព

**មាត្រា២៣៥** ._ វិសាលភាព

មាតិកានេះ អនុវត្តលើការផលិត និងការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនីដោយនិរន្តរភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២៣៦** ._ គោលការណ៍ថាមពលដោយនិរន្តរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ និងនីតិបុគ្គលសាធារណៈ ត្រូវអនុវត្តគោលការណ៍ថាមពលដោយនិរន្តរភាព ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវធានាថារាល់គម្រោងអភិវឌ្ឍន៍របស់នីតិបុគ្គលឯកជន ត្រូវអនុវត្តគោលការណ៍ថាមពលដោយនិរន្តរភាព ។

**មាត្រា២៣៧** ._ ថាមពលដោយនិរន្តរភាព

គោលបំណងនៃការសម្រេចបានថាមពលដោយនិរន្តរភាព មានដូចខាងក្រោម ៖

១- ការគាំទ្រ និងការលើកកម្ពស់គម្រោង និងថាមពលដោយនិរន្តរភាព ។

២- ការពិចារណាទៅលើការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា ចំពោះក្របខ័ណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

៣- ការអនុម័តយកគម្រោងថាមពលដោយនិរន្តរភាព ។

៤- ការផ្តល់អាទិភាពចំពោះការវិនិយោគក្នុងគម្រោងថាមពលដោយនិរន្តរភាព ។

៥- ការលើកកម្ពស់បច្ចេកវិទ្យា ដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន ។

៦- ផ្តល់ការគាំទ្រចំពោះប្រភពថាមពល និងបណ្តាញអគ្គិសនីខ្នាតតូច ។

៧- ការលើកកម្ពស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល និងប្រព័ន្ធផលិត និងស្តុកអគ្គិសនីតាមផ្ទះ ។

## ជំពូកទី២
## ផែនការថាមពលដោយនិរន្តរភាព

**មាត្រា២៣៨** ._ ផែនការយុទ្ធសាស្ត្រជាតិស្តីពីថាមពល និងអគ្គិសនីដោយនិរន្តរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីថាមពល និងអគ្គិសនីដោយនិរន្តរភាព ។ ផែនការនេះ ត្រូវរៀបចំការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ស្របតាមបទប្បញ្ញត្តិក្នុងគន្ថីទី២ មាតិកាទី១នៃក្រមនេះ ។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីថាមពល និងអគ្គិសនីដោយនិរន្តរភាព មានគោលដៅធានានិរន្តរភាពថាមពលសម្រាប់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២៣៩** ._ ធាតុផ្សំនៃផែនការ

បែបបទ និងនីតិវិធីនៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីថាមពល និងអគ្គិសនីដោយនិរន្តរភាព មានធាតុផ្សំដូចមានចែងខាងក្រោម ៖

១- ការស្រាវជ្រាវលើការបង្កើតគោលនយោបាយស្តីពីស្តង់ដារថាមពលកកើតឡើងវិញ ។

២- ការវាយតម្លៃស្ថានភាពបច្ចុប្បន្ននៃថាមពល និងការផលិតអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធបណ្ដាញចែកចាយ ។

៣- ការពិពណ៌នាអំពីគម្រោងដែលមានសក្ដានុពល សម្រាប់ផ្គត់ផ្គង់ថាមពល ការផលិតអគ្គិសនី និងការចែកចាយអគ្គិសនី ។

៤- បង្កើតថាមពលដោយនិរន្តរភាពចំពោះតំបន់គោលដៅ ។

៥- ការពិនិត្យសំណល់ដែលកើតចេញពីគម្រោងថាមពលកកើតឡើងវិញ និងរៀបចំផែនការគ្រប់គ្រង ឬកែច្នៃសំណល់ដែលកើតចេញពីការអភិវឌ្ឍថាមពលកកើតឡើងវិញ ។

៦- ការវិភាគផលប៉ះពាល់បរិស្ថាននៃគម្រោងផលិតថាមពល និងអគ្គិសនី ។

៧- រៀបចំផែនការប្រើប្រាស់ធនធានរួម ដោយគិតគូរអំពីតម្លៃចំណាយ និងផលចំណេញ ។

**មាត្រា២៤០** ._ ការអនុវត្តផែនការ

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ត្រូវទទួលខុសត្រូវក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្ដីពីថាមពល និងអគ្គិសនីដោយនិរន្តរភាព ។

**មាត្រា២៤១** ._ តំបន់ហាមឃាត់មិនឱ្យមានគម្រោងថាមពល

មិនត្រូវអនុញ្ញាតឱ្យមានគម្រោងថាមពលនៅក្នុង ៖

១- ទីតាំងវប្បធម៌ប្រវត្តិសាស្ត្រ ឬបេតិកភណ្ឌវប្បធម៌ ។

២- របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ។

៣- តំបន់ដែលគ្រប់គ្រង និងប្រើប្រាស់ដោយជនជាតិដើមភាគតិច នឹងការប្រើប្រាស់ជាប្រពៃណីរបស់ជនជាតិដើមភាគតិច ។

៤- តំបន់រ៉ាមសារ ។

៥- តំបន់បេតិកភណ្ឌរបស់អង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ សង្គម វិទ្យាសាស្ត្រ និងវប្បធម៌ ។

៦- តំបន់ផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល ។

## ជំពូកទី៣
## ការលើកកម្ពស់បច្ចេកវិទ្យាថាមពលមេត្រីភាពបរិស្ថាន

**មាត្រា២៤២** ._ ការលើកកម្ពស់បច្ចេកវិទ្យាថាមពលមេត្រីភាពបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ត្រូវពិនិត្យគម្រោងថាមពលនីមួយៗ ដើម្បីធានាថា គម្រោងនេះ អនុវត្តបច្ចេកវិទ្យាថាមពលប្រកបដោយប្រសិទ្ធផល ការបញ្ចេញកាបូនទាប និងសំណល់ទាប ។ ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ត្រូវពិនិត្យគម្រោងថាមពលនីមួយៗ ដោយប្រើប្រាស់បច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងការអនុវត្តល្អៗជាអន្តរជាតិ នៅក្នុងវិស័យថាមពលពាក់ព័ន្ធ ។

**មាត្រា២៤៣** ._ បច្ចេកវិទ្យាល្អបំផុតដែលអាចស្វែងរកបាន និងជម្រើសដែលមានផលប៉ះពាល់ទាប

ស្របតាមបទប្បញ្ញត្តិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគន្ថីទី២ មាតិកាទី២ នៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មិនត្រូវឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ សម្រាប់គម្រោងណាមួយដែលប្រើប្រាស់បច្ចេកវិទ្យា ដែលមិនមែនជាបច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបាន ឬដែលអាចផ្តល់ផលប៉ះពាល់ដល់បរិស្ថានច្រើនជាងជម្រើសដែលអាចស្វែងរកបានណាមួយឡើយ ។ ម្ចាស់គម្រោង អាចត្រូវបានតម្រូវឱ្យដាក់បញ្ចូលនូវការរចនាដែលជាជម្រើសដែលមានប្រសិទ្ធផលជាង និងបង្កឱ្យមានសំណល់ និងការបំភាយតិច ខណៈពេលដែលសម្រេចបាននូវគោលបំណងនៃគម្រោង ។

**មាត្រា២៤៤** ._ ការលើកកម្ពស់ការផ្គត់ផ្គង់អគ្គិសនី

រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងនីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ត្រូវជំរុញ និងលើកកម្ពស់ដល់ការផ្គត់ផ្គង់អគ្គិសនី ដែលចេញមកពីបណ្តាញតចូលជាតិ និងមកពីប្រភពអគ្គិសនីវិមជ្ឈការ ដែលត្រូវបានផលិតឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន ។ អ្នកប្រើប្រាស់អគ្គិសនី ត្រូវបានលើកទឹកចិត្ត និងលើកកម្ពស់ឱ្យដំឡើងបច្ចេកវិទ្យាវិមជ្ឈការ សម្រាប់បំពេញតម្រូវការនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីរបស់ខ្លួន ។

អ្នកប្រើប្រាស់អគ្គិសនី មិនត្រូវបានបង្ខំឱ្យប្រើប្រាស់អគ្គិសនី ដែលបានមកពីប្រភពនៃការផលិតថាមពលជាក់លាក់ណាមួយទេ ។

**មាត្រា២៤៥ ._** ការលើកកម្ពស់ការផ្គត់ផ្គង់អគ្គិសនីខ្នាតតូច និងបណ្តាញតចូលខ្នាតតូច

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្រចំពោះការផ្គត់ផ្គង់អគ្គិសនីខ្នាតតូច និងការផ្គត់ផ្គង់អគ្គិសនីតាមបណ្តាញតូច ។ ប្រតិបត្តិករបណ្តាញអគ្គិសនីខ្នាតតូច ត្រូវមានជម្រើសដូចខាងក្រោម ៖

១- បន្តផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ និងមានអត្ថិភាពស្របគ្នាជាមួយបណ្តាញតចូលជាតិ ។

២- បន្តផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ និងលក់អគ្គិសនីដែលលើស ឬដែលមិនទាន់បានលក់ ទៅកាន់បណ្តាញតចូលជាតិ នៅចំណុចអន្តរបណ្តាញ និងទាញយកថាមពលមកពីបណ្តាញអគ្គសនីខ្នាតតូច ។

ក្នុងករណីដែលបណ្តាញតចូលខ្នាតតូចភ្ជាប់ជាមួយបណ្តាញតចូលជាតិ ដើម្បីលក់អគ្គិសនីដែលសល់ ប្រតិបត្តិករនៃបណ្តាញអគ្គិសនីខ្នាតតូច ត្រូវចុះកិច្ចសន្យាទិញលក់ថាមពលជាមួយនីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ។

**មាត្រា២៤៦ ._** សិទ្ធិក្នុងការផ្ទេរកម្មសិទ្ធិ

ប្រតិបត្តិករនៃបណ្តាញតចូលខ្នាតតូច ត្រូវមានសិទ្ធិជាឯកតោភាគីក្នុងការធ្វើសេចក្តីសម្រេចក្នុងការផ្ទេរកម្មសិទ្ធិនៃការផ្គត់ផ្គង់ និងទ្រព្យសម្បត្តិនៃការផលិតទាំងអស់នៃបណ្តាញតចូលខ្នាតតូចទៅឱ្យនីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ។ តម្លៃនៃប្រតិបត្តិការផ្ទេរកម្មសិទ្ធិ ត្រូវស្របតាមតម្លៃទីផ្សារនៃទ្រព្យសម្បត្តិដែលត្រូវផ្ទេរនោះ តាមការព្រមព្រៀងរវាងគូភាគី ។

**មាត្រា២៤៧ ._** ការផលិតថាមពលអគ្គិសនីកកើតឡើងវិញតាមផ្ទះ

ការផលិតថាមពលអគ្គិសនីកកើតឡើងវិញតាមផ្ទះ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតណាមួយពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការដំឡើងឡើយ ដរាបណាគ្រួសារនោះប្រើប្រាស់ឧបករណ៍ដែលមានការទទួលស្គាល់ ដោយអនុលោមតាមលក្ខខណ្ឌនានានៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

**មាត្រា២៤៨ ._** ថាមពលនិរន្តរភាពរបស់ធុរកិច្ច និងសហគមន៍

ធុរកិច្ច ឬសហគមន៍ដែលបង្កើតប្រព័ន្ធថាមពលដោយនិរន្តរភាព សម្រាប់ការផ្គត់ផ្គង់អគ្គិសនីផ្ទាល់ខ្លួន មានសិទ្ធិតភ្ជាប់ទៅកាន់បណ្ដាញតចូលដែលមានស្រាប់ ទៅតាមការព្រមព្រៀងរបស់អ្នកពាក់ព័ន្ធ ។

**មាត្រា២៤៩** ._ លក្ខខណ្ឌសម្រាប់លិខិតអនុញ្ញាត

រាជរដ្ឋាភិបាល មិនត្រូវរៀបចំលក្ខខណ្ឌតម្រូវក្នុងការទទួលលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ ដើម្បីរារាំង ៖

១- ធុរកិច្ច និងសហគមន៍ ឬអ្នកអភិវឌ្ឍន៍ដែលជាភាគីទីបី ដែលមានកិច្ចព្រមព្រៀងជាមួយធុរកិច្ច ឬសហគមន៍មិនឱ្យធ្វើការអភិវឌ្ឍថាមពលនិរន្តរភាពតែមួយ សម្រាប់បទប្បញ្ញត្តិពាក់ព័ន្ធនឹងអគ្គិសនីទៅកាន់អ្នកប្រើប្រាស់ ដរាបណា ៖

- ធុរកិច្ច និងសហគមន៍ ឬអ្នកអភិវឌ្ឍន៍ដែលជាភាគីទីបី ប្រើប្រាស់ឧបករណ៍ដែលមានវិញ្ញាបនបត្រទទួលស្គាល់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ
- ធុរកិច្ច និងសហគមន៍ ឬអ្នកអភិវឌ្ឍន៍ដែលជាភាគីទីបីប្រើប្រាស់បច្ចេកទេសជាក់លាក់ដើម្បីធានាថា អគ្គិសនីដែលដាក់បញ្ចូលទៅក្នុងបណ្ដាញតចូល គឺមានកម្រិតអប្បបរមា ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធពីការខូចខាតដែលបន្តកើនឡើង ។

២- នីតិបុគ្គលឯកជនមិនឱ្យធ្វើការអភិវឌ្ឍថាមពលនិរន្តរភាព ក្នុងព្រះរាជាណាចក្រកម្ពុជា ។

នីតិបុគ្គលឯកជនមិនត្រូវបានដាក់កម្រិតនូវចំនួននៃលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ ដែលពួកគេទទួលបានពីអាជ្ញាធរទទួលបន្ទុកក្នុងការធ្វើនិយ័តកម្ម ការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនី សម្រាប់គម្រោងខ្នាតតូច ដោយមានសមត្ថភាពផលិតក្រោម ៥ (ប្រាំ) ម៉េហ្កាវ៉ាត់ ។

នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ត្រូវធ្វើនិយ័តកម្មការដាក់បញ្ចូលអគ្គិសនីទៅក្នុងបណ្ដាញតចូលដើម្បីធានានូវភាពអាចទុកចិត្តបាន និងសុវត្ថិភាព ។

**មាត្រា២៥០** ._ ការហាមឃាត់លើឯកសិទ្ធិ

រាជរដ្ឋាភិបាលត្រូវកំណត់មិនឱ្យមាននីតិបុគ្គលឯកជនណាមានឯកសិទ្ធិលើសពីអ្នកដទៃទៀតឡើយ រួមបញ្ចូល នៅក្នុងការធានានូវលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណទាំងអស់ និងនៅក្នុងការចរចាអំពីលក្ខខណ្ឌនានានៃកិច្ចសន្យា ដែលបានឯកភាពជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

សេចក្តីសម្រេចទាំងអស់ សម្រាប់ការផ្តល់លិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ និងការធ្វើឱ្យទៅជាផ្លូវការនូវលក្ខខណ្ឌពាក់ព័ន្ធដទៃទៀតសម្រាប់កិច្ចសន្យា ត្រូវធ្វើឡើងដោយផ្អែកលើភស្តុតាងផ្នែកបច្ចេកទេស និងសេដ្ឋកិច្ច ដូចត្រូវបានទទួលយកនៅក្រោមការអនុវត្តល្អៗជាអន្តរជាតិ ។

នៅពេលជ្រើសរើសនីតិបុគ្គលឯកជនដើម្បីអភិវឌ្ឍថាមពល ឬផលិតអគ្គិសនី ឬគម្រោងចែកចាយអគ្គិសនីដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលត្រូវដាក់បញ្ចូលជាចាំបាច់ក្នុងដំណើរការនៃការដាក់ពាក្យសុំនូវលទ្ធភាពសម្រាប់ការក្រកូតប្រជែងលក្ខណៈបើកចំហ និងនីតិបុគ្គលឯកជនដទៃទៀត ក្នុងការដាក់បញ្ជូននូវសំណើ ដោយធានាថានីតិបុគ្គលឯកជនទាំងនោះ អាចមានលទ្ធភាព និងពេលវេលាសមរម្យ ក្នុងការរៀបចំសំណើរបស់ពួកគេ ។

## ជំពូកទី៤
## ការត្រួតពិនិត្យគុណភាពផលិតផលសម្រាប់ផលិតថាមពលដោយនិរន្តរភាព

**មាត្រា២៥១** ._ អង្គភាពឯករាជ្យ

អាជ្ញាធរទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ត្រូវបង្កើតអង្គភាពឯករាជ្យ នៅក្នុងរយៈពេល១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃអនុម័តនៃក្រមនេះ ដើម្បីត្រួតពិនិត្យគុណភាពនៃឧបករណ៍ផលិតថាមពល ដែលត្រូវបានផ្គត់ផ្គង់ និងប្រើប្រាស់សម្រាប់ទីផ្សារជាតិ ដើម្បីធានាថាឧបករណ៍ទាំងនេះអនុលោមតាមស្តង់ដារសុខភាព សុវត្ថិភាពនិងស្តង់ដារបរិស្ថាន ។ អង្គភាពឯករាជ្យ ដែលត្រូវបានបង្កើតឡើង ត្រូវទទួលភារកិច្ចក្នុងការអនុវត្តសវនកម្ម ការធ្វើតេស្ត និងការបញ្ជាក់លើឧបករណ៍ទាំងនេះ ។

**មាត្រា២៥២** ._ ការបញ្ជាក់អំពីគុណភាព

អង្គភាពឯករាជ្យ ត្រូវផ្ទៀងផ្ទាត់ថា គុណភាពនៃផលិតផលដែលត្រូវបានលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការផលិតថាមពល ទទួលបាននូវការបញ្ជាក់អំពីគុណភាព មុនពេលដែលផលិតផលទាំងនោះត្រូវបានធ្វើពាណិជ្ជកម្ម ។ ការបញ្ជាក់នេះអាចត្រូវបានត្រួតពិនិត្យដោយអង្គការស្តង់ដារអន្តរជាតិ ។

ផ្នែកគយ ត្រូវធ្វើការផ្ទៀងផ្ទាត់ចំពោះឧបករណ៍ដែលនាំចូល ។ អង្គភាពឯករាជ្យ ត្រូវធ្វើការផ្ទៀងផ្ទាត់សម្រាប់ផលិតផលថ្នាក់ជាតិ មុនពេលធ្វើពាណិជ្ជកម្ម ទៅកាន់សាធារណជន ។

**មាត្រា២៥៣**._ ការធានាស្តង់ដារ

អង្គភាពឯករាជ្យ ត្រូវត្រួតពិនិត្យ និងធានាថា ស្តង់ដារលើផលិតផលថាមពលកកើតឡើងវិញ ត្រូវបានបំពេញ និងអនុលោមតាមស្តង់ដារតម្រូវ ។ អ្នកធានា ត្រូវទទួលខុសត្រូវជាអប្បបរមាក្នុងការសងមកវិញនូវផលិតផលដល់អ្នកប្រើប្រាស់នោះក្នុងរយៈពេលសមស្រប ទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាធានា នៅក្នុងករណីមានវិការៈ ដំណើរការមិនល្អ ឬខកខានមិនបានអនុលោមតាមស្តង់ដារ ។

## ជំពូកទី៥
## ក្របខ័ណ្ឌទៅតាមប្រភេទថាមពល ឬគម្រោងអគ្គិសនី
### ផ្នែកទី១
### ថាមពលកកើតឡើងវិញ

**មាត្រា២៥៤**._ ករណីលើកលែងផ្នែកពន្ធ

គ្រប់សម្ភារនានា ដែលប្រើសម្រាប់តែការដំឡើងប្រព័ន្ធថាមពលកកើតឡើងវិញ ត្រូវទទួលបានការលើកទឹកចិត្ត ស្របតាមបទប្បញ្ញត្តិស្តីពីការវិនិយោគជាធរមាន ។

**មាត្រា២៥៥**._ ការគ្រប់គ្រងការប្រើប្រាស់អគ្គិសនីបន្ថែមតាមបណ្តាញតចូល

នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ត្រូវគ្រប់គ្រងការផ្គត់ផ្គង់អគ្គិសនីបន្ថែម ដូចជាអគ្គិសនីតាមបណ្តាញតចូល ដោយតភ្ជាប់ទៅនឹងប្រព័ន្ធដំឡើងថាមពលពន្លឺព្រះអាទិត្យតាមដំបូល ។ រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន ដែលជាម្ចាស់ដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមដំបូលសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន មានសិទ្ធិតភ្ជាប់ទៅនឹងបណ្តាញតចូល ។

អាជ្ញាធរទទួលបន្ទុកក្នុងការធ្វើនិយ័តកម្ម ការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនី ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ក្របខ័ណ្ឌ ស្តង់ដារ និងផ្តល់ការអនុញ្ញាតឱ្យមានការទិញលក់ថាមពលកកើតឡើងវិញ ក្រោយពីក្រមនេះចូលជាធរមានក្នុងរយៈពេលមួយឆ្នាំ ។

**មាត្រា២៥៦**._ យន្តការទូទាត់រង្វាស់អគ្គិសនី

អាជ្ញាធរទទួលបន្ទុកក្នុងការធ្វើនិយ័តកម្ម ការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនី ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីយន្តការទូទាត់រង្វាស់អគ្គិសនី សម្រាប់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមដំបូល ដែលភ្ជាប់ទៅបណ្តាញតចូល ។

លិខិតបទដ្ឋានគតិយុត្តស្តីពីយន្តការទូទាត់រង្វាស់អគ្គិសនី ត្រូវកំណត់អត្រាតម្លៃអគ្គិសនីសម្រាប់លក់ទៅកាន់នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ។ អ្នកទទួលផលអាចបង់ថ្លៃប្រើប្រាស់អគ្គិសនីទៅតាមអ្វីដែលបង្ហាញលើនាឡិកាទូទាត់រង្វាស់អគ្គិសនីនោះ ។

នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនីត្រូវទទួលខុសត្រូវលើការអនុវត្តលិខិតបទដ្ឋានគតិយុត្តស្តីពីយន្តការទូទាត់រង្វាស់អគ្គិសនី ។

ត្រូវមានកិច្ចព្រមព្រៀងស្តីពីការដំឡើងនាឡិកាទូទាត់រង្វាស់អគ្គិសនី និងការចេញវិក្កយបត្រប្រចាំខែរវាងនីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី និងម្ចាស់អគារ ឬកន្លែងផ្គត់ផ្គង់ថាមពលពន្លឺព្រះអាទិត្យ ។

**មាត្រា២៥៧**._ សិទ្ធិក្នុងការតភ្ជាប់ទៅនឹងបណ្តាញតចូល

កន្លែងផ្គត់ផ្គង់ ដែលត្រូវប្រតិបត្តិដោយសហគមន៍ ឬសហគ្រាសទាំងឡាយ ទាំងដែលប្រើបន្ទះពន្លឺព្រះអាទិត្យ ឬប្រើកញ្ចក់ពន្លឺព្រះអាទិត្យក្តី ត្រូវទទួលបានការអនុញ្ញាតស្របច្បាប់ឱ្យតចូល និងផ្ទេរភ្លើងចូលទៅក្នុងបណ្តាញតចូល ។

នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី អាចជាកម្មសិទ្ធិករ ប្រតិបត្តិករ និងអ្នកថែរក្សាកន្លែងផ្គត់ផ្គង់ថាមពលពន្លឺព្រះអាទិត្យ និងត្រូវមានសិទ្ធិជួលបន្តនូវសិទ្ធិប្រតិបត្តិការ និងថែរក្សាកន្លែងទាំងនោះ ។

**មាត្រា២៥៨**._ ប្រព័ន្ធអនុគ្រោះពន្ធសាកល្បងលើថាមពលកកើតឡើងវិញ

អាជ្ញាធរទទួលបន្ទុកក្នុងការធ្វើនិយ័តកម្ម ការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនី ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីប្រព័ន្ធអនុគ្រោះពន្ធសាកល្បងលើថាមពលកកើតឡើងវិញ ក្នុង

រយៈពេល១ (មួយ) ឆ្នាំ ដែលក្នុងនោះ រាជរដ្ឋាភិបាលត្រូវផ្តល់ជាអត្រាថេរមួយសម្រាប់ការជាវអគ្គិសនីដែលកកើតឡើងវិញពីកន្លែងផ្តល់ថាមពលពន្លឺព្រះអាទិត្យ ឬប្រព័ន្ធផលិតថាមពលដែលកកើតឡើងវិញ ។

ប្រព័ន្ធនេះ ត្រូវមានគោលបំណងធានាឱ្យបាននូវកម្រិតថ្លៃថាមពលសម្រាប់មួយរយៈពេលណាមួយក្នុងគោលបំណងកាត់បន្ថយថ្លៃដែលត្រូវបង់ដោយអ្នកប្រើប្រាស់ចុងក្រោយ និងសម្រួលដល់ការស្តារឡើងវិញនូវចំណាយវិនិយោគរបស់ម្ចាស់គម្រោង និងចំណាយថែទាំ ។

លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវបង្កើតជាតារាងពន្ធថេរមួយដែលត្រូវបង់ថ្លៃប្រើប្រាស់អគ្គិសនីដែលកកើតឡើងវិញក្នុងមួយរយៈពេលនៃការសាកល្បង ។

## ផ្នែកទី២
## ថាមពលនុយក្លេអ៊ែរ

**មាត្រា២៥៩** ._ ការគ្រប់គ្រងថាមពលនុយក្លេអ៊ែរ

ថាមពលនុយក្លេអ៊ែរ ត្រូវបង្កើតឡើងដោយស្ថិតនៅក្រោមការគ្រប់គ្រង និងកម្មសិទ្ធិរបស់រាជរដ្ឋាភិបាលតែមួយប៉ុណ្ណោះ និងដោយមានការគ្រប់គ្រង និងប្រតិបត្តិការតាមស្តង់ដារអន្តរជាតិនៃការការពារផ្នែកសុខភាព សុវត្ថិភាព និងបរិស្ថាន ។

រាជរដ្ឋាភិបាល ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីថាមពលនុយក្លេអ៊ែរ និងសុវត្ថិភាព ។ លិខិតបទដ្ឋានគតិយុត្ត ត្រូវរួមមានលក្ខខណ្ឌតម្រូវសម្រាប់រចនាសម័ន្ធ និងការរៀបចំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ធ្វើការត្រួតពិនិត្យគម្រោងផលិតថាមពលនុយក្លេអ៊ែរនានា ។

រាជរដ្ឋាភិបាល មិនត្រូវទទួលយកសំណល់ថាមពលនុយក្លេអ៊ែរពីប្រទេសដទៃជាដាច់ខាត ទោះបីតាមលក្ខខណ្ឌ ឬកាលៈទេសៈបែបណាក៏ដោយ ។

**មាត្រា២៦០** ._ ការបណ្តុះបណ្តាលស្តីពីថាមពលនុយក្លេអ៊ែរ

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពលនុយក្លេអ៊ែរ ត្រូវរៀបចំកម្មវិធី មួយដើម្បីផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកខ្លួន និងស្ថាប័នដទៃទៀត ដោយសហការជាមួយនឹងអង្គភាពថាមពលអាតូមអន្តរជាតិ និងភាគីពាក់ព័ន្ធដទៃទៀត ។

**មាត្រា២៦១ ._** ការអភិវឌ្ឍចំណេះដឹងស្តីពីថាមពលអាតូមិចសម្រាប់គោលបំណងសន្តិភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំកម្មវិធីស្រាវជ្រាវ ដើម្បីកំណត់អត្តសញ្ញាណថាមពលនុយក្លេអ៊ែរមេត្រីភាពបរិស្ថាន និងមានលក្ខណៈច្នៃប្រឌិតថ្មី ដើម្បីវាយតម្លៃផលប៉ះពាល់ដែលអាចកើតឡើងនៃការអភិវឌ្ឍថាមពលនុយក្លេអ៊ែរចំពោះបរិស្ថាន និងដើម្បីកំណត់អំពីការបោះបង់ចោលតាមលក្ខណៈត្រឹមត្រូវនូវសំណល់វិទ្យុសកម្ម ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវរៀបចំកម្មវិធីអប់រំ និងបណ្តុះបណ្តាល មជ្ឈមណ្ឌលព័ត៌មាននុយក្លេអ៊ែរ និងមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ និងបច្ចេកវិទ្យានុយក្លេអ៊ែរសម្រាប់គោលបំណងសន្តិភាព និងដើម្បីកសាងធនធានមនុស្ស និងលើកកម្ពស់ជំនាញដល់បុគ្គលិកផ្នែករដ្ឋបាលវិទ្យាសាស្ត្រ និងបច្ចេកទេស ។

## ផ្នែកទី៣
## ការភ្ជាប់ប្រព័ន្ធចែកចាយ និងបណ្តាញតចូល

**មាត្រា២៦២ ._** លក្ខខណ្ឌតម្រូវនៃប្រសិទ្ធផលនៃប្រព័ន្ធចែកចាយ

គម្រោងបណ្តាញចរន្តនានា ត្រូវប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធផល ដើម្បីកាត់បន្ថយការបាត់បង់អគ្គិសនី ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវបដិសេធចោលការឯកភាពទាំងឡាយលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងករណីមិនមានការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធផលខ្ពស់បំផុត ដែលមាននៅពេលដាក់ពាក្យសុំ ។ បច្ចេកវិទ្យាដែលប្រើប្រាស់ ត្រូវតែជាបច្ចេកវិទ្យាដែលមានលក្ខណៈប្រកួតប្រជែងផ្នែកបរិស្ថាន និងសេដ្ឋកិច្ច ដោយធៀបទៅនឹងការបាត់បង់ផលអគ្គិសនី ដែលបច្ចេកវិទ្យានោះជួយបញ្ចៀស ។

**មាត្រា២៦៣ ._** បច្ចេកវិទ្យាគមនាគមន៍ឌីជីថល

ដើម្បីបើកឱ្យផលិតថាមពលកកើតជាថ្មី តភ្ជាប់ទៅកាន់បណ្តាញតចូល និងការប្រើប្រាស់អគ្គិសនីបានពីធនធានដោយមាននិរន្តរភាព និងប្រសិទ្ធផល រាជរដ្ឋាភិបាល ត្រូវបង្កើតបណ្តាញតចូលដែលប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ឌីជីថល ដើម្បីរកឱ្យឃើញ និងធ្វើសកម្មភាពឆ្លើយតប ចំពោះការប្រែប្រួលដែលកើតមាននៅក្នុងមូលដ្ឋានដោយសារការប្រើប្រាស់ និងការផលិតថាមពល ។

រាជរដ្ឋាភិបាល ត្រូវបង្កើតកម្មវិធីអនុវត្តបច្ចេកវិទ្យានេះនៅតាមបណ្តាញអគ្គិសនីជាតិ ឱ្យបានឆាប់ទៅតាមតម្រូវការនៃបច្ចេកវិទ្យា ។ ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ត្រូវរៀបចំកម្មវិធីសាកល្បងមួយឱ្យបានរួចជាស្រេច ដើម្បីអនុវត្តក្នុងរយៈពេល ៣ (បី) ឆ្នាំ ក្រោយពីក្រមនេះចូលជាធរមាន ។

ថ្លៃចំណាយដើម្បីអនុវត្តបច្ចេកវិទ្យាបណ្តាញតចូល និងនីតិវិធីទាំងឡាយដែលត្រូវអនុវត្ត ត្រូវផ្សព្វផ្សាយដល់អ្នកប្រើប្រាស់បណ្តាញតចូលទាំងអស់ដោយស្មើភាពគ្នា ។

**មាត្រា២៦៤** ._ ការពង្រីកបណ្តាញតចូល

យោងតាមការពិចារណាផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម រាជរដ្ឋាភិបាល អាចបញ្ឈប់រាល់ការពង្រីកបណ្តាញតចូលទៅកាន់តំបន់ជាក់លាក់ណាមួយក្នុងប្រទេស ។ ក្នុងករណីនេះ រាជរដ្ឋាភិបាល ត្រូវលើកកម្ពស់ និងអនុវត្តកម្មវិធីនានា ដើម្បីផ្តល់ដំណោះស្រាយបែបវិមជ្ឈការ ដល់ក្រុមគ្រួសារទាំងឡាយ ផ្អែកតាមតម្រូវការរបស់អ្នកប្រើប្រាស់ចុងក្រោយ ទាំងការផលិតថាមពល និងការផលិតអគ្គិសនី ។

**មាត្រា២៦៥** ._ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន

អាជ្ញាធរពាក់ព័ន្ធត្រូវចែកចាយជាសាធារណៈនូវព័ត៌មានអំពីរ៉ុល និងគុណភាពអគ្គិសនីដែលបានផ្គត់ផ្គង់ ឬផ្តល់ទៅឱ្យបណ្តាញតចូល ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។ អាជ្ញាធរដែលទទួលបន្ទុក ត្រូវធ្វើការចេញផ្សាយអំពីគុណភាពអគ្គិសនី និងរ៉ុលអគ្គិសនី ដើម្បីការពារការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធចែកចាយ ឬការអាក់ខានក្នុងការផ្តល់សេវាកម្ម ។

## ជំពូកទី៦
## ប្រសិទ្ធភាពថាមពល

**មាត្រា២៦៦** ._ ប្រព័ន្ធគ្រប់គ្រងថាមពល និងអគ្គិសនី

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីប្រព័ន្ធគ្រប់គ្រងថាមពល និងអគ្គិសនី ដោយផ្អែកលើស្តង់ដារនៃអង្គការស្តង់ដារអន្តរជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ក្រសួង ស្ថាប័នទាំងអស់ស្តីពីការអនុលោមតាមផែនការប្រសិទ្ធផល ព្រមទាំងការអនុវត្តតាមស្តង់ដារនៃគណៈកម្មការបច្ចេកទេសអេឡិចត្រូនិកអន្តរជាតិ និងផែនការ និងគោលនយោបាយប្រសិទ្ធផល និងសម្រាប់ការពង្រឹងការអនុវត្តស្តង់ដារគណៈកម្មការបច្ចេកទេសអេឡិចត្រូនិក ។

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ជាសាធារណៈអំពីវឌ្ឍនភាពនៃប្រសិទ្ធផលថាមពល ដើម្បីធានាឱ្យបាននូវការអនុលោមតាមស្តង់ដារប្រសិទ្ធផលថាមពល ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាននៃគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## មាតិកាទី៨
## ឧស្សាហកម្មនិស្សារណកម្មប្រកបដោយការទទួលខុសត្រូវ
### ជំពូកទី១
### វិសាលភាព និងការរៀបចំផែនការបរិស្ថានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម

**មាត្រា២៦៧** ._ វិសាលភាព

មាតិកានេះមានវិសាលភាព អនុវត្តលើធនធានឧស្សាហកម្មនិស្សារណកម្ម រួមមាន ប្រេង ឧស្ម័ន រ៉ែ ដែក វត្ថុធាតុភូគព្ភវិទ្យាផ្សេងៗ ដែលយកចេញពីដី និងពីប្រភពផ្សេងៗទៀត ដែលបង្កើតឡើងដោយឧបករណ៍គតិយុត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

មាតិកានេះ ក៏មានវិសាលភាពអនុវត្តផងដែរលើការរុករក ការធ្វើអាជីវកម្ម ការបិទ និងការស្តារឡើងវិញនូវគម្រោងឧស្សាហកម្មនិស្សារណកម្ម ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីការវាយតម្លៃ និងអង្កេតតាមដានបរិស្ថាននៃគន្ថីទី២ លើកលែងតែមាត្រា២៧១ និង២៧២ នៃក្រមនេះ ដែលអនុវត្តលើគ្រប់ឧស្សាហកម្មនិស្សារណកម្ម ។

**មាត្រា២៦៨** ._ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ត្រូវរៀបចំការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រតាមវិស័យសម្រាប់ការរុករក ឬការធ្វើអាជីវកម្មនៃធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិក្នុងគន្លឹទី២ មាតិកាទី១នៃក្រមនេះ ។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលរៀបចំឡើងក្រោមជំពូកនេះ តម្រូវឱ្យកំណត់អត្តសញ្ញាណ និងផ្តល់ក្របខ័ណ្ឌសម្រាប់ម្ចាស់គម្រោងដើម្បីដាក់បញ្ចូលទៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការអភិវឌ្ឍគម្រោង ដូចខាងក្រោម ៖

១- លក្ខខណ្ឌតម្រូវនៃការអភិរក្សជីវៈចម្រុះ និងទេសភាព ។

២- ការគំរាមកំហែងចំពោះប្រភេទជិតផុតពូជ ជម្រក និងតម្លៃអភិរក្សប្រព័ន្ធអេកូឡូស៊ី ។

៣- ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

**មាត្រា២៦៩ ._** ការរុករក និងធ្វើអាជីវកម្មដែលមានស្រាប់

សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗដែលការរុករក ឬការធ្វើអាជីវកម្មបានកើតឡើងមុនពេលចូលជាធរមាននៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ត្រូវបញ្ចប់ និងដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនីមួយៗ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្លឹទី១ មាតិកាទី៣នៃក្រមនេះ នៅក្នុងរយៈពេល២ (ពីរ) ខែក្រោយការចូលជាធរមាននៃក្រមនេះ ។

**មាត្រា២៧០ ._** ការរុករកនិងការធ្វើអាជីវកម្មថ្មី

សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗដែលការរុករក ឬការធ្វើអាជីវកម្មមិនបានកើតឡើងមុនពេលចូលជាធរមាននៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ត្រូវបញ្ចប់ និងដាក់ឱ្យសាធារណជនអាចរកបាននូវការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនីមួយៗ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានក្នុងគន្លឹទី១ មាតិកាទី៣នៃក្រមនេះ មុនពេល ៖

១- ផ្តល់ការឯកភាពលើលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណសម្រាប់ការរុករក ឬការធ្វើអាជីវកម្មនានា ។

២- ចាប់ផ្តើមការរុករក ឬការធ្វើអាជីវកម្ម ។

**មាត្រា២៧១ ._** ការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងធ្វើជាលក្ខណៈសិប្បកម្ម

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងធ្វើជាលក្ខណៈសិប្បកម្មដើម្បី ៖

១- ចែងពីសិទ្ធិនៃការធ្វើអាជីវកម្មរ៉ែខ្នាត និងធ្វើជាលក្ខណៈសិប្បកម្មទៅកាន់ប្រជាពលរដ្ឋ ។

២- ធានាថាសកម្មភាពនៃការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងលក្ខណៈសិប្បកម្មធ្វើឡើងដោយនិរន្តរភាពបរិស្ថាន សុវត្ថិភាព និងប្រសិទ្ធផល ។

៣- ជំរុញ និងអនុវត្តតាមស្តង់ដារ និងការអនុវត្តដ៏ល្អបំផុតជាអន្តរជាតិ ក្នុងការគ្រប់គ្រងការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងលក្ខណៈសិប្បកម្ម ។

៤- បង្កើតដំណើរការនៃការកំណត់តំបន់សម្រាប់ការធ្វើអាជីវកម្មរ៉ែលក្ខណៈសិប្បកម្មដោយមានកិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ។

៥- តម្រូវ និងផ្តល់ជំនួយសម្រាប់អ្នកធ្វើអាជីវកម្មរ៉ែលក្ខណៈសិប្បកម្មក្នុងការបង្កើត និងអនុវត្តផែនការសុវត្ថិភាព និងសន្តិសុខ ។

**មាត្រា២៧២** ._ តំបន់ហាមឃាត់ចំពោះគម្រោងឧស្សាហកម្មនិស្សារណកម្ម

មិនត្រូវអនុញ្ញាតឱ្យមានគម្រោងឧស្សាហកម្មនិស្សារណកម្ម នៅក្នុង ៖

១- ដីសាធារណៈរបស់រដ្ឋដែលត្រូវបានកំណត់ជាទីតាំងវប្បធម៌ ប្រវត្តិសាស្ត្រ ឬបេតិកភណ្ឌវប្បធម៌ ។

២- តំបន់ស្នូល ឬតំបន់អភិរក្សនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

៣- តំបន់ដែលជនជាតិដើមភាគតិចរស់នៅ ឬប្រើប្រាស់ជាលក្ខណៈប្រពៃណី លើកលែងតែក្នុងករណីដែលមានការយល់ព្រមជាមុនដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ។

៤- តំបន់រ៉ាមសារ ។

៥- ទីតាំងនៃអង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ សង្គម វិទ្យាសាស្ត្រ និងវប្បធម៌ ។

៦- តំបន់ទាំងឡាយណាដែលលិខិតបទដ្ឋានគតិយុត្ត កំណត់ថាមាន ៖

- ប្រព័ន្ធអេកូឡូស៊ីទឹកសាប ទឹកសមុទ្រ ឬឆ្នេរសំខាន់
- តម្លៃអភិរក្សទេសភាពខ្ពស់ ជីវៈចម្រុះ ប្រភេទសត្វ និងរុក្ខជាតិ ឬតម្លៃអភិរក្សប្រព័ន្ធអេកូឡូស៊ី ។

## ជំពូកទី២
## បច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម

**មាត្រា២៧៣ .**_ ភារកិច្ចក្នុងការបញ្ចៀសការខូចខាតបរិស្ថាន

ម្ចាស់គម្រោង ត្រូវប្រើប្រាស់បច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងការអនុវត្តល្អៗ ដើម្បីបញ្ចៀសការបង្កឱ្យមានការបំពុល ឬការខូចខាតដល់បរិស្ថាន និងដើម្បីបង្កើនប្រសិទ្ធផលជាអតិបរមា នៅពេលអនុវត្តសកម្មភាពឧស្សាហកម្មនិស្សារណកម្ម ។

**មាត្រា២៧៤ .**_ បញ្ជីនៃបច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងការអនុវត្តល្អៗ

ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរក្សាបញ្ជីនៃបច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងការអនុវត្តល្អៗ សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗ ។

ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ត្រូវ ៖

១- ចាប់ផ្តើមចងក្រងនូវបញ្ជីបឋមនៃបច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងចាប់ផ្តើមការពិគ្រោះយោបល់ជាសាធារណៈអំពីបញ្ជីដែលបានស្នើសុំ នៅក្នុងរយៈពេល ១ (មួយ) ខែ ក្រោយពេលក្រមនេះចូលជាធរមាន ។

២- បញ្ចប់ និងបោះពុម្ពផ្សាយនូវបញ្ជីនៃបច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី៣ នៅក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា២៧៥ .**_ បញ្ជីនៃការធ្វើបច្ចុប្បន្នភាពនៃបញ្ជីបច្ចេកវិទ្យាដែលល្អបំផុតដែលអាចស្វែងរកបាន

ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើបច្ចុប្បន្នភាពនូវបញ្ជីនៃបច្ចេកវិទ្យាដ៏ល្អបំផុតដែលអាចស្វែងរកបាន សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗ យ៉ាងហោចណាស់រៀងរាល់ ២ (ពីរ) ឆ្នាំម្តង ។

**មាត្រា២៧៦ .**_ លក្ខខណ្ឌតម្រូវក្នុងការបញ្ចៀសការខូចខាតបរិស្ថាន

ស្របតាមបច្ចេកវិទ្យាដ៏ល្អបំផុតដែលមាននៅក្នុងបញ្ជី ម្ចាស់គម្រោងនៃគម្រោងឧស្សាហកម្ម និស្សារណកម្ម ត្រូវ ៖

១- គ្រប់គ្រងឱ្យបានសមស្របនូវសំណល់ថ្ម និងសំណល់ផ្សេងទៀត ដើម្បីធានាឱ្យបាននូវស្ថិរភាពខាងផ្នែករចនាសម្ព័ន្ធត្រួតពិនិត្យការបញ្ចេញ និងទប់ស្កាត់ផលប៉ះពាល់ដែលអាចកើតឡើង នៃការហូរជាតិអាស៊ីតចេញពីរ៉ែ ការលេចចេញនូវសារធាតុលោហៈ និងការបាត់បង់ការគ្រប់គ្រងកុំឱ្យប៉ះពាល់ដល់បរិស្ថាន ។

២- បញ្ចៀសការសាងសង់អាងស្តុកសំណល់រ៉ែ នៅជិតទន្លេ ឬសមុទ្រ ដែលមានជម្រៅរាក់ពេក ។

៣- ពិចារណាអំពីការសាងសង់នូវអាងស្តុកសំណល់រ៉ែ ដែលមិនបញ្ចេញសំណល់ទឹករួមបញ្ចូល ការស្តុកទឹកជាអចិន្ត្រៃយ៍ ក្រោយពីការបញ្ចប់គម្រោង ។

## ជំពូកទី៣
## ការប្រើប្រាស់ ស្យានីត និងបារតនៅក្នុងការធ្វើអាជីវកម្មរ៉ែមាស និងប្រាក់

**មាត្រា២៧៧ .**_ ការចេញវិញ្ញាបនបត្រសុវត្ថិភាពស្យានីត និងបារត

ម្ចាស់គម្រោងនៃគម្រោងអាជីវកម្មរ៉ែមាស និងប្រាក់ ត្រូវផ្តល់ឯកសារ ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីបញ្ជាក់ថា ស្យានីត និងបារត ដែលត្រូវប្រើប្រាស់នៅក្នុងប្រតិបត្តិការនៃការធ្វើអាជីវកម្មរ៉ែមាស និងប្រាក់ ត្រូវបានជាវនៅក្នុងលក្ខណៈដែលមានសុវត្ថិភាព និងមិនប៉ះពាល់ដល់បរិស្ថាន ។

**មាត្រា២៧៨ .**_ ការទទួលខុសត្រូវ

កិច្ចព្រមព្រៀងទិញលក់ ឬកិច្ចព្រមព្រៀងដទៃទៀត និងការរៀបចំរវាងអ្នកផលិត អ្នកចែកចាយ អ្នកដឹកជញ្ជូន ប្រតិបត្តិករ ឬម្ចាស់គម្រោង ត្រូវចែងអំពីការទទួលខុសត្រូវទាក់ទងនឹងសុវត្ថិភាព សន្តិសុខ ការទប់ស្កាត់ការបញ្ចេញ ការបណ្តុះបណ្តាល និងការឆ្លើយតបចំពោះភាពអាសន្នទាក់ទងនឹងការប្រើប្រាស់ស្យានីត និងបារត នៅក្នុងគម្រោងអាជីវកម្មរ៉ែមាស និងប្រាក់ ។

**មាត្រា២៧៩ .**_ លក្ខខណ្ឌតម្រូវសម្រាប់ការប្រើប្រាស់ស្យានីត និងបារត

សម្រាប់ស្បានីត និងបារត ដែលត្រូវប្រើប្រាស់នៅក្នុងគម្រោងអាជីវកម្មរ៉ែមាស និងប្រាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធានាថា កន្លែងដែលរក្សាទុកសារធាតុទាំងនេះ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងស្បានីត អន្តរជាតិ និងគោរពតាមលក្ខខណ្ឌតម្រូវ ដូចខាងក្រោម ៖

១- ការដាក់ចុះ ការធ្វើសន្និធិ និងឧបករណ៍សម្រាប់លាយ ត្រូវបានរចនា និងធ្វើប្រតិបត្តិការ ស្របតាមការអនុវត្តផ្នែកវិស្វកម្មដែលត្រឹមត្រូវ និងទទួលយកបាន ក៏ដូចជា ការត្រួតពិនិត្យគុណភាព និងនីតិវិធីនៃការធានាគុណភាព និងវិធានការការពារការបញ្ចេញ និង វិធានការទប់ទល់ ។

២- ការដាក់ចុះ ការធ្វើសន្និធិ និងឧបករណ៍សម្រាប់លាយ ត្រូវបានធ្វើប្រតិបត្តិការដោយប្រើប្រាស់ការធ្វើអធិការកិច្ច ការថែទាំដែលមានការការពារ និងផែនការបម្រុងទុកជាមុន ដើម្បីការពារ និងទប់មិនឱ្យរាលដាលនូវការបញ្ចេញ និងត្រួតពិនិត្យ និងឆ្លើយតបចំពោះភាពងាយរងគ្រោះរបស់កម្មករ ។

៣- ឧបករណ៍ស្បានីត និងបារត ត្រូវធ្វើប្រតិបត្តិការ និងអង្កេតតាមដាន ដើម្បីការពារសុខភាព និងសុវត្ថិភាពកម្មករ ហើយត្រូវវាយតម្លៃជាប្រចាំនូវប្រសិទ្ធភាពនៃវិធានការសុខភាព និងសុវត្ថិភាព ។

៤- ប្រព័ន្ធគ្រប់គ្រង និងប្រតិបត្តិការ ត្រូវរចនា និងអនុវត្ត ដើម្បីការពារសុខភាពមនុស្ស និងបរិស្ថាន រួមមានផែនការជាយថាភាព និងផែនការអធិការកិច្ច និងនីតិវិធីថែទាំតាមលក្ខណៈការពារ ។

៥- កម្មវិធីគ្រប់គ្រងទឹកលក្ខណៈគ្រប់ជ្រុងជ្រោយ ត្រូវអនុវត្តដើម្បីការពារពីការបញ្ចេញដោយគ្មានចេតនា ។

៦- វិធានការក្នុងការការពារប្រភេទសត្វ និងរុក្ខជាតិពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងនៃដំណើរការស្បានីត និងបារត ត្រូវបានអនុវត្ត ។

៧- វិធានការក្នុងការការពារប្រភេទសត្វ និងរុក្ខជាតិពីការបញ្ចេញចោលដោយផ្ទាល់ និងប្រយោល នៃដំណើរការស្បានីត និងបារត ត្រូវទៅក្នុងទឹកលើដី ត្រូវបានអនុវត្ត ។

៨- កម្មវិធីអង្កេតតាមដាន ដើម្បីវាយតម្លៃផលប៉ះពាល់នៃការប្រើប្រាស់ ស្បានីត និងបារត លើប្រភេទសត្វ និងរុក្ខជាតិ និងគុណភាពទឹកលើដីនិងក្រោមដី ត្រូវបានអនុវត្ត ។

៩- ផែនការ និងនីតិវិធីឆ្លើយតបចំពោះគ្រោះបន្ទាន់ ដើម្បីឆ្លើយតបចំពោះភាពងាយរងគ្រោះរបស់កម្មករចំពោះ ស្បានីត និងបារត ត្រូវបានបង្កើត និងអនុវត្ត ។

១០- នីតិវិធីសម្រាប់ការជូនដំណឹងបន្ទាន់ផ្ទៃក្នុង និងខាងក្រៅ និងការរាយការណ៍ ត្រូវបានអនុវត្ត ។

១១- ការចូលរួមពេញលេញរបស់អ្នកពាក់ព័ន្ធត្រូវបានអនុវត្ត សម្រាប់សហគមន៍ ដើម្បីធ្វើការប្រាស្រ័យទាក់ទងអំពីបញ្ហានានានៃការបារម្ភ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈក្នុងគន្ថីទី១ មាតិកាទី២ នៃក្រមនេះ ។

១២- ព័ត៌មានស្តីពីប្រតិបត្តិការ និងព័ត៌មានបរិស្ថានដែលសមរម្យទាក់ទងនឹងការគ្រប់គ្រងស្បានីត និងបារត ត្រូវដាក់ឱ្យអ្នកពាក់ព័ន្ធអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីការទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## ជំពូកទី៤
## ការលាតត្រដាងព័ត៌មាន

**មាត្រា២៨០** ._ ព័ត៌មានពាក់ព័ន្ធ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធានាថា ព័ត៌មានលម្អិតនៃគម្រោងឧស្សាហកម្មនិស្សារណកម្មនីមួយៗ រួមបញ្ចូល ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ផែនការគ្រប់គ្រងបរិស្ថាន សវនកម្មបរិស្ថាន របាយការណ៍អង្កេតតាមដានបរិស្ថាន និងកិច្ចព្រមព្រៀងដទៃទៀតរវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងម្ចាស់គម្រោង ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ និងត្រូវផ្តល់ព័ត៌មានជូនសហគមន៍ និងអ្នកមានលំនៅឋានអចិន្ត្រៃយ៍ នៅក្នុងលក្ខណៈមួយដែលងាយយល់ និងនៅក្នុងភាសា និងទម្រង់ដែលសមស្រប ។

**មាត្រា២៨១** ._ ការដាក់កំហិតលើភាពសម្ងាត់

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធានាថា គ្មានព័ត៌មានណាមួយទាក់ទងនឹងគម្រោងឧស្សាហកម្មនិស្សារណកម្ម ត្រូវចាត់ទុកជាព័ត៌មានសម្ងាត់ឡើយ នៅក្នុងករណីដែលព័ត៌មាននោះទាក់ទងទៅនឹងសុខភាពមនុស្ស ឬបរិស្ថាន ស្របតាមបទប្បញ្ញត្តិស្តីពីការទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## គន្ថីទី៤
## ការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព
## មាតិកាទី១
## ប្រព័ន្ធតំបន់ការពារធម្មជាតិ
## ជំពូកទី១
## នីតិវិធីនៃការបង្កើត ការផ្លាស់ប្តូរ និងការរំសាយប្រព័ន្ធតំបន់ការពារធម្មជាតិ

**មាត្រា២៨២** ._ សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ប្រព័ន្ធតំបន់ការពារធម្មជាតិ មានជាអាទិ៍ តំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះ តំបន់អភិរក្សពិសេស និងតំបន់អភិរក្សដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២៨៣** ._ ការបង្កើតប្រព័ន្ធតំបន់ការពារធម្មជាតិ

ប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននិរន្តរភាពនៃជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានដោយនិរន្តរភាព ដែលជាមូលដ្ឋានគ្រឹះនៃសុខុមាលភាពសាធារណៈ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីការបង្កើតសមាសភាគ ប្រព័ន្ធតំបន់ការពារធម្មជាតិគ្រប់ប្រភេទ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

តំបន់អភិរក្ស ដែលបានបង្កើតឡើងតាមលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត រួមមានសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍ជលផល តំបន់ការពារបេតិកភណ្ឌវប្បធម៌ និងតំបន់អភិរក្សធនធានធម្មជាតិផ្សេងទៀតនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវបានរាប់បញ្ចូលទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចចុះកិច្ចព្រមព្រៀងជាមួយប្រទេសដទៃដើម្បីបង្កើត និងគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិឆ្លងដែន ។

**មាត្រា២៨៤** ._ ការបង្កើតតំបន់អភិរក្សពិសេស

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអាចបង្កើត កែសម្រួល ឬរៀបចំតំបន់អភិរក្សពិសេស ដែលមានសារៈសំខាន់ថ្នាក់ជាតិ ឬអន្តរជាតិ ជាតំបន់បេតិកភណ្ឌថ្នាក់តំបន់ ឬពិភពលោក តំបន់ដីសើម

ឬឧបនីយជីវមណ្ឌល ឬតំបន់ពិសេសផ្សេងៗទៀត ដោយមានលក្ខណៈវិនិច្ឆ័យ ដូចមានចែងនៅក្នុងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិ ។

តំបន់ទាំងឡាយណាដែលបានដាក់បញ្ចូលជាតំបន់បេតិកភណ្ឌថ្នាក់តំបន់ ឬពិភពលោក តំបន់ដីសើម ឬឧបនីយជីវមណ្ឌល ឬតំបន់ពិសេសផ្សេងៗទៀត រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវគ្រប់គ្រង និងអភិរក្សតំបន់ទាំងនោះ ឱ្យស្របតាមនីតិវិធី និងបទប្បញ្ញត្តិ ។

តំបន់ពិសេសៗទាំងនេះ ដែលមានចែងដោយសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តតាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា២៨៥** ._ ការបង្កើតតំបន់ការពារធម្មជាតិ និងអចលនទ្រព្យរបស់ជនជាតិដើមភាគតិច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ សម្រាប់តំបន់ណាដែលមានសារៈសំខាន់ជារួម ឬតំបន់ដែលមានសារៈប្រយោជន៍សំខាន់ដល់សហគមន៍ ជនជាតិដើមភាគតិច តាមការស្នើសុំរបស់សហគមន៍ជនជាតិដើមភាគតិច ។

**មាត្រា២៨៦** ._ នីតិវិធីនៃការបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ពាក្យស្នើសុំបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានខ្លឹមសារ ដូចខាងក្រោម៖

១- សេចក្តីពិពណ៌នាផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងតំបន់ស្នើសុំ ដែលមានផែនទីកំណត់ពីមាត្រដ្ឋាន ត្រឹមត្រូវ និងច្បាស់លាស់ និងមានបញ្ជាក់អំពីទីតាំង ព្រំប្រទល់ ទំហំ និងប្រវត្តិនៃតំបន់នោះ ដែលបានរៀបរាប់នៅក្នុងផែនការប្រើប្រាស់ដីដែលពាក់ព័ន្ធ ។

២- ការវាយតម្លៃអំពីការប្រើប្រាស់ដី និងធនធានធម្មជាតិដែលមានស្រាប់ នៅក្នុងតំបន់ស្នើសុំ ។

៣- សេចក្តីលម្អិតអំពីការកែប្រែទៅលើការប្រើប្រាស់ដី ដែលត្រូវកើតឡើងបន្ទាប់ពីមានការបង្កើតជាសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៤- សេចក្តីលម្អិតអំពីសារៈសំខាន់នៃតំបន់ស្នើសុំ ពាក់ព័ន្ធទៅនឹងតម្លៃជីវសាស្ត្រ ភូមិសាស្ត្រ ភូគព្ភសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងតម្លៃអភិរក្ស ។

៥- សេចក្តីលម្អិតអំពីកម្រិតនៃការបែងចែកប្រព័ន្ធអេកូឡូស៊ី និងជម្រកសត្វ ក្នុងតំបន់ស្នើសុំ និងហានិភ័យនានាដល់តម្លៃអភិរក្ស នៅពេលកំពុងរៀបចំពាក្យស្នើសុំ ។

៦- ចរិតលក្ខណៈ និងទម្រង់នៃការបន្លាស់ទី និងចលនារបស់ប្រភេទសត្វសំខាន់ៗ និង ការ វាយតម្លៃអំពីផលប៉ះពាល់ដែលជាសក្តានុពល ទៅលើប្រភេទសត្វទាំងនោះ ក្នុងករណីមិនមានការបង្កើតតាមការស្នើសុំ ។

៧- ការប៉ាន់ប្រមាណអំពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដែលតំបន់ស្នើសុំនោះបង្កើតឱ្យមាន ឬនឹងមាន ។

៨- ការវាយតម្លៃអំពីផលប៉ះពាល់អវិជ្ជមានដោយការប្រែប្រួលអាកាសធាតុ ទៅលើតំបន់ស្នើសុំ ។

៩- សេចក្តីពន្យល់អំពីរបៀបដែលបានស្នើសុំ ជួយសម្រេចបាននូវគោលដៅដូចបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ ។

១០- លទ្ធផលនៃកិច្ចពិគ្រោះយោបល់ជាមួយតំណាងអាជ្ញាធរថ្នាក់ជាតិ និងក្រោមជាតិ ដែលមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដែលរស់នៅក្នុង ឬជាប់ទៅនឹងតំបន់ស្នើសុំ ។

១១- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធទៅនឹងតំបន់ស្នើសុំ ។

រាល់ព័ត៌មានដែលត្រូវមាននៅក្នុងពាក្យស្នើសុំបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវផ្អែកលើឯកសារអំពីលទ្ធផលនៃការស្រាវជ្រាវ និងផ្អែកលើការពិនិត្យជាក់ស្តែងទៅលើទីតាំងនៃតំបន់ស្នើសុំ ។

**មាត្រា២៨៧** ._ ការទទួលខុសត្រូវក្នុងការបង្កើត និងគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវទទួលខុសត្រូវក្នុងការបង្កើត និងគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលបង្កើតឡើងដោយថ្នាក់ជាតិ ។ ការបង្កើត ឬពង្រីកនូវប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិថ្មី ឬមានស្រាប់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគិតយុត្តតាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការបង្កើត និងគ្រប់គ្រងតំបន់ការពារធម្មជាតិ ថ្នាក់ក្រោមជាតិ ។ ការបង្កើត ឬពង្រីកនូវប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ក្រោមជាតិថ្មី ឬមានស្រាប់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តតាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ដំណើរការនៃការបង្កើត ឬពង្រីកប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា២៨៨** ._ ការផ្លាស់ប្តូរចំណាត់ថ្នាក់ និងរំសាយប្រព័ន្ធតំបន់ការពារធម្មជាតិ

ការផ្លាស់ប្តូរចំណាត់ថ្នាក់ និងរំសាយផ្នែកណាមួយ ឬទាំងស្រុងនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលបានបង្កើតដោយថ្នាក់ជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តតាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយត្រូវមានលទ្ធផលសិក្សាស្រាវជ្រាវ និងវាយតម្លៃ ស្តីពីការបាត់បង់មុខងារប្រព័ន្ធជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងលំនឹងបរិស្ថានដែលមិនអាចស្តារឡើង វិញបាន ។

ការផ្លាស់ប្តូរចំណាត់ថ្នាក់ ឬរំសាយផ្នែកណាមួយ ឬទាំងស្រុងនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលបានបង្កើតដោយថ្នាក់ក្រោមជាតិត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តតាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយត្រូវមានលទ្ធផលសិក្សាស្រាវជ្រាវ វាយតម្លៃស្តីពី ការបាត់បង់មុខងារប្រព័ន្ធជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងលំនឹងបរិស្ថានមិនអាចស្តារឡើងវិញបានតាម រយៈរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ដំណើរការនៃការផ្លាស់ប្តូរចំណាត់ថ្នាក់ ឬរំសាយមួយផ្នែក ឬទាំងស្រុង នៃប្រព័ន្ធតំបន់ការពារ ធម្មជាតិ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី២
## ការគ្រប់គ្រង ការប្រើប្រាស់ និងគម្រោងការផ្សេងៗ

**មាត្រា២៨៩** ._ ការរៀបចំ និងការអនុវត្ត

តំបន់ការពារធម្មជាតិ ត្រូវរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដី កំណត់បែងចែកតំបន់គ្រប់គ្រង ធ្វើចំណាត់ថ្នាក់ និងរៀបចំផែនការគ្រប់គ្រងស្របតាមការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដី ការកំណត់បែងចែកតំបន់គ្រប់គ្រង ការធ្វើចំណាត់ ថ្នាក់ និងការរៀបចំផែនការគ្រប់គ្រងនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ មុនពេលក្រមនេះចូលជាធរមាន នៅតែមានសុពលភាព និងត្រូវចាត់ទុកថាស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ ។

ការរៀបចំផែនការប្រើប្រាស់ដី ការកំណត់បែងចែកតំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់ និងការ រៀបចំផែនការគ្រប់គ្រងសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ មុនពេលក្រមនេះចូលជាធរមាន នៅតែមាន សុពលភាព ហើយក៏ត្រូវដាក់បញ្ចូលនូវលក្ខខណ្ឌនានានៃក្រមនេះ ។

តំបន់ទាំងឡាយ ស្ថិតនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលត្រូវធ្វើការគ្រប់គ្រងរួមគ្នាដោយអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីការរៀបចំផែនការប្រើប្រាស់ដី ការកំណត់បែងចែកតំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់ និងការរៀបចំផែនការគ្រប់គ្រង ។

**មាត្រា២៩០**._ ការហាមឃាត់ចំពោះសកម្មភាពពាណិជ្ជកម្ម ឬសកម្មភាពអភិវឌ្ឍន៍

ហាមឃាត់សកម្មភាពពាណិជ្ជកម្ម ឬអភិវឌ្ឍន៍ថ្មីៗណាមួយ នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ រហូតដល់ពេលការរៀបចំផែនការប្រើប្រាស់ដី ការកំណត់បែងចែកតំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់ និងការរៀបចំផែនការគ្រប់គ្រងត្រូវបានបញ្ចប់ លើកលែងតែមានចែងច្បាស់លាស់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ការចេញនូវលិខិតបទដ្ឋានគតិយុត្តដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវធ្វើឡើងបន្ទាប់ពីមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់សកម្មភាពពាណិជ្ជកម្ម ឬសកម្មភាពអភិវឌ្ឍន៍ ហើយត្រូវស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី៣
## ស្ថានភាពបច្ចុប្បន្ននៃតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ

**មាត្រា២៩១**._ ការបន្តនីត្យានុកូលភាពនៃតំបន់ការពារធម្មជាតិ

តំបន់ការពារធម្មជាតិថ្នាក់ជាតិដែលបានបង្កើត ស្របតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនៅតែរក្សានីត្យានុកូលភាពពេញលេញ រួមទាំងស្ថានភាពជាក់ស្តែង មានជាអាទិ៍ព្រំប្រទល់ការការពារ និងការគ្រប់គ្រង ។

ការរៀបចំផែនការប្រើប្រាស់ដី ការកំណត់បែងចែកតំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់ និងការរៀបចំផែនការគ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ត្រូវអនុវត្តដូចខាងក្រោម៖

១- រៀបចំ តាមតំបន់នីមួយៗ ។

២- រៀបចំដោយមានការបញ្ចូលរួមគ្នាជាមួយ របៀងអភិរក្សជីវៈចម្រុះ ។

៣- រៀបចំតំបន់ពាក់ព័ន្ធរួមគ្នា ចំណុចទី១ និងទី២ ។

៤- រៀបចំតាមដំណើរការនៃការគ្រប់គ្រងរួមគ្នានៃតំបន់ណាមួយ ។

**មាត្រា២៩២ .**_ ការបន្តនីត្យានុកូលភាព នៃរបៀងអភិរក្សជីវៈចម្រុះ

របៀងអភិរក្សជីវៈចម្រុះដែលបានបង្កើត ស្របតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត នៅតែរក្សានីត្យានុកូលភាពតាមច្បាប់ពេញលេញ រួមទាំងស្ថានភាពជាក់ស្តែងមានជាអាទិ៍ព្រំប្រទល់ ការការពារ និង ការគ្រប់គ្រង ។

ការរៀបចំផែនការប្រើប្រាស់ដី ការកំណត់បែងចែកតំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់ និងការរៀបចំផែនការគ្រប់គ្រងក្នុងរបៀងអភិរក្សជីវៈចម្រុះ ត្រូវអនុវត្តដូចខាងក្រោម ៖

១- រៀបចំតាមរបៀងអភិរក្សជីវៈចម្រុះនីមួយៗ ។

២- រៀបចំដោយមានការបញ្ចូលរួមគ្នាជាមួយ តំបន់ការពារធម្មជាតិ ។

៣- រៀបចំតាមដំណើរការ នៃការគ្រប់គ្រងរួមគ្នា នៃតំបន់ណាមួយ ។

## មាតិកាទី២
## ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា២៩៣ .**_ គោលបំណង

ប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានគោលបំណងគ្រប់គ្រង ដូចខាងក្រោម ៖

១- អភិរក្សជីវៈចម្រុះ សត្វព្រៃ និងធនធានធម្មជាតិ ។

២- អភិរក្សប្រព័ន្ធអេកូឡូស៊ី ផលធនធានធម្មជាតិ និងសេវាកម្ម ។

៣- អភិវឌ្ឍជីវភាពសហគមន៍មូលដ្ឋាន ។

**មាត្រា២៩៤ .**_ វិសាលភាព

មាតិកាទី២នេះ មានវិសាលភាពអនុវត្តលើការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ នៅប្រព័ន្ធតំបន់ការពារធម្មជាតិ តំបន់ធម្មជាតិបម្រុងទុកសម្រាប់ការពារ និងអភិរក្សធម្មជាតិ រួមទាំងតំបន់ដីសើម តំបន់ឆ្នេរ តំបន់កោះ និងតំបន់ជីវៈចម្រុះសមុទ្រ ។

មាតិកាទី២នេះមានវិសាលភាពអនុវត្ត នៅតំបន់គ្រប់គ្រងព្រៃឈើដោយនិរន្តរភាពស្របតាមបទប្បញ្ញត្តិ ដូចមានចែងនៅក្នុងក្រមនេះ ។

## ជំពូកទី២
## ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី

**មាត្រា២៩៥ .**_ ការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់អត្តសញ្ញាណប្រព័ន្ធអេកូឡូស៊ីទាំងអស់តាមការវាយតម្លៃជាលក្ខណៈប្រព័ន្ធ ស្របតាមប្រព័ន្ធវាយតម្លៃតាមស្តង់ដារអន្តរជាតិ និងត្រូវបញ្ចូលលទ្ធផលនៃការកំណត់អត្តសញ្ញាណទាំងនោះចូលទៅក្នុងផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ប្រព័ន្ធអេកូឡូស៊ីនីមួយៗ ត្រូវកំណត់ប្រភេទស្របតាមលក្ខណៈវិនិច្ឆ័យនៃប្រព័ន្ធអេកូឡូស៊ី តាមចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការអនុវត្តតាមលក្ខណៈវិនិច្ឆ័យ និងការធ្វើចំណាត់ថ្នាក់ក្រុមប្រភេទ នៃបញ្ជីក្រហមស្តីពីប្រព័ន្ធអេកូឡូស៊ី និងនីតិវិធីស្តីពីការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីការរៀបចំបង្កើតបញ្ជីថ្នាក់ជាតិ ស្តីពីប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែងនិងដំណើរការនៃការពិនិត្យ និងការធ្វើបច្ចុប្បន្នភាព ។

បន្ទាប់ពីការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី បានបង្ហាញថា មានប្រព័ន្ធអេកូឡូស៊ី កំពុងរងការគំរាមកំហែងទាំងស្រុង ឬកំពុងរងការគំរាមកំហែងធ្ងន់ធ្ងរ ឬមានទីជម្រកសត្វ រុក្ខជាតិព្រៃ នៃក្រុមប្រភេទទី១ ឬទី២ ស្របតាមបញ្ជី ជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ឬបញ្ជីអន្តរជាតិផ្សេងទៀត ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ នោះក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការស្នើសុំកំណត់ប្រព័ន្ធអេកូឡូស៊ីនោះ ជាសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

**មាត្រា២៩៦ .**_ ផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដៃគូបច្ចេកទេសពាក់ព័ន្ធ ត្រូវបង្កើតផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ បន្ទាប់ពីមានការវាយតម្លៃបង្ហាញថា កំពុងរងគ្រោះថ្នាក់ ឬជិតរងការគំរាមកំហែង នៃចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀត ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

ផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ ត្រូវមានរយៈពេល ១០ (ដប់) ឆ្នាំ ។

ខ្លឹមសារនៃផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា២៩៧** ._ ការវាយតម្លៃរបៀងអភិរក្សជីវៈចម្រុះ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំឱ្យមានការវាយតម្លៃនានាពាក់ព័ន្ធនឹងដែនដី ដែនទឹក ធនធានធម្មជាតិ និងការតាំងទីលំនៅរបស់ប្រជាជន នៅក្នុងគ្រប់របៀងអភិរក្សជីវៈចម្រុះ ។

ក្នុងករណីដែលលទ្ធផលនៃការវាយតម្លៃបង្ហាញថា មានតំបន់ណាមួយ ដែលស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ មានប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែងទាំងស្រុង ឬរងការគំរាមកំហែងធ្ងន់ធ្ងរ ឬមាន ទីជម្រកសត្វព្រៃ នៃក្រុមប្រភេទទី១ និងទី២ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំការស្នើសុំ បង្កើតតំបន់ទាំងនោះទៅជាសមាភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចបង្កើតលិខិតបទដ្ឋានគតិយុត្តដែលកំណត់អំពីលក្ខខណ្ឌនៃការវាយតម្លៃជាក់លាក់ទៅលើរបៀងអភិរក្សជីវៈចម្រុះ ។

ក្នុងករណីការវាយតម្លៃបានកំណត់ថា តំបន់ណាមួយនៅក្នុងរបៀងអភិរក្សជីវៈចម្រុះដែលបានចុះបញ្ជីងាយរងគ្រោះថ្នាក់ ឬកំពុងរងការគំរាមកំហែង ឬជាទីជម្រកប្រភេទសត្វ ដូចបានកំណត់ក្នុងចំណាត់ថ្នាក់ ក្រុមទី៣ នោះត្រូវអនុវត្តតាមមាត្រា២៩៦នៃក្រមនេះ ។

គ្រប់ផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ ដូចបានកំណត់ក្នុងមាតិកានេះ និងផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទដូចបានកំណត់ក្នុងគន្លឹនេះ ត្រូវដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ ។

## ជំពូកទី៣
## ក្រសួង ស្ថាប័នមានសមត្ថកិច្ច

**មាត្រា២៩៨** ._ ក្រសួង ស្ថាប័នមានសមត្ថកិច្ច

ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមបទប្បញ្ញត្តិដូច មានចែងក្នុងក្រមនេះ ។

ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវធានានូវសិទ្ធិរបស់សហគមន៍មូលដ្ឋានជនជាតិដើម ភាគតិច និងសាធារណៈជន ក្នុងការ ៖

១- ទទួលបានការចូលរួម ពិគ្រោះយោបល់ និងធ្វើសេចក្តីសម្រេចលើការងារគ្រប់គ្រង និងអភិរក្សជីវៈចម្រុះដោយនិរន្តរភាព ។

២- ផ្តល់ការយល់ព្រម ស្របតាមគោលការណ៍ យល់ព្រមជាមុន ដោយសេរី បន្ទាប់ពី ទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ដូចមានចែងនៃក្រមនេះ ។

៣- ចូលរួមពេញលេញក្នុងការរៀបចំផែនការ ការគ្រប់គ្រងនិងប្រើប្រាស់ដោយនិរន្តរ ភាព នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៤- ធានាអ្នកមូលដ្ឋានប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយ ភាពសមស្រប និងសម ធម៌ ស្របតាមលក្ខខណ្ឌនៃការធ្វើចំណាត់ថ្នាក់ កំណត់តំបន់គ្រប់គ្រង និងតំបន់ហាមឃាត់ ។

នៅក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឬមានទំនាក់ទំនងផលប្រយោជន៍សម្ងហាភាព ការពិគ្រោះយោបល់ ត្រូវអនុវត្ត ដើម្បីធានានូវសិទ្ធិ និងផលប្រយោជន៍ រួមបញ្ចូលសិទ្ធិតាមបែបប្រពៃណី ទំនៀមទម្លាប់ ត្រូវបានដោះស្រាយឱ្យបានត្រឹមត្រូវ ។

សកម្មភាពគ្រប់គ្រង និងអភិរក្ស នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលបានបង្កើតឡើងដទៃ ទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានជាអាទិ៍ ៖

១- បញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះប្រព័ន្ធតំបន់ការពារធម្មជាតិទាំងអស់ រហូតដល់ ការគ្រប់គ្រងរួមគ្នាត្រូវបានបង្កើតនៅក្នុងផ្នែកណាមួយនៃតំបន់ទាំងពីរនេះ និងត្រូវគ្រប់គ្រង ស្រប តាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

២- ប្រព័ន្ធតំបន់ការពារធម្មជាតិ ឬផ្នែកណាមួយនៃតំបន់ទាំងនេះ ដែលមិនមែនជាកម្មវត្ថុ នៃការគ្រប់គ្រងរួមគ្នា ត្រូវបន្តគ្រប់គ្រង ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា២៩៩ .**_ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ

នៅក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវបំពេញការទទួលខុសត្រូវសំខាន់ៗជាអាទិ៍ ៖

១- ផ្តល់នូវក្របខ័ណ្ឌទូទៅ ត្រួតពិនិត្យនិងគ្រប់គ្រង និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ ដំណើរការទូទៅសម្រាប់ការអភិវឌ្ឍ ការរៀបចំផែនការប្រើប្រាស់ដី ការកំណត់បែងចែកតំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់ និងការរៀបចំផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

២- ធានាឱ្យបាននូវការអង្កេត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រងប្រព័ន្ធតំបន់ ការពារធម្មជាតិ ។

៣- រៀបចំ និងបង្កើតកម្មវិធីស្វ័យគ្រប់គ្រងហិរញ្ញវត្ថុដោយនិរន្តរភាពសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

៤- ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់ការគាំទ្រដល់ដំណើរការ បញ្ចូលសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍នេសាទ តំបន់ដទៃទៀត ចូលទៅក្នុងក្របខ័ណ្ឌទូទៅនៃការប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៥- ដឹកនាំ និងគាំទ្រដល់ការល្បាត ការអង្កេតតាមដាន ការស៊ើបអង្កេត និងការពង្រឹងការ អនុវត្តច្បាប់នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៦- ដឹកនាំ និងអនុវត្តការងារបច្ចេកទេស ក្នុងការសិក្សា ការស្រាវជ្រាវ ការរៀបចំរបាយការណ៍ និងការលើកកម្ពស់ការយល់ដឹង ដើម្បីពង្រឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍប្រព័ន្ធ តំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព ។

៧- ដឹកនាំ និងអនុវត្តការងារផ្សេងៗទៀតពាក់ព័ន្ធនឹងធនធានធម្មជាតិដូចមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា៣០០ .**_ សិទ្ធិរបស់មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ

នៅក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិ មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិ និងការទទួលខុសត្រូវដូចខាងក្រោម ៖

១- អនុវត្តជាប្រចាំនូវការងារល្បាត អង្កេតតាមដាន ស៊ើបអង្កេត និងពង្រឹងការអនុវត្តសកម្មភាព ការងារផ្សេងៗទៀត ។

២- ធ្វើអធិការកិច្ច ត្រួតពិនិត្យ និងចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារពាក់ព័ន្ធដទៃទៀត ។

៣- ចាត់វិធានការបង្ការ ទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃ ។

៤- ត្រួតពិនិត្យការនាំចេញ នាំចូលនូវរុក្ខជាតិ សត្វព្រៃ គ្រាប់ពូជ និងសំណាករុក្ខជាតិ និង សត្វព្រៃដែលយកចេញ ឬចូលក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៥- លើកកម្ពស់ការអប់រំ និងការផ្សព្វផ្សាយដល់សាធារណជន និងសហគមន៍ ជនជាតិដើមភាគតិច ។

៦- បំពេញមុខងារមានតួនាទី ភារកិច្ច ជាមន្ត្រីនគរបាលយុត្តិធម៌លើវិស័យការងារបរិស្ថាន និង ធនធានធម្មជាតិ ។

៧- ប្រតិបត្តិការងារពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធចំពោះការបង្កើត និងការគ្រប់គ្រង ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៨- អនុលោម កាតព្វកិច្ចនៃការទទួលបានហិរញ្ញប្បទានសម្រាប់រៀបចំ បង្កើតប្រព័ន្ធតំបន់ការពារ ធម្មជាតិ ។

៩- សហការជាមួយសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិដៃគូបច្ចេកទេសដែលមានបទពិសោធន៍លើការងារស្រាវជ្រាវ ការពារ និងការងារគ្រប់គ្រងធនធានធម្មជាតិ និងអង្គភាពមានភារកិច្ចអភិរក្សធនធានធម្មជាតិព្រមទាំងអ្នកពាក់ព័ន្ធ ដើម្បីបង្កើតការគ្រប់គ្រងរួមគ្នាលើតំបន់ការពារធម្មជាតិ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

១០- និងសិទ្ធិ និងភារកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៣០១ .**_ ការទទួលខុសត្រូវរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទី និងការទទួលខុសត្រូវ ដូចខាងក្រោម ៖

១- គាំទ្រដល់នាយកប្រព័ន្ធតំបន់ការពារធម្មជាតិ ដៃគូបច្ចេកទេស និងអ្នកពាក់ព័ន្ធ ដើម្បីរៀបចំ ផែនការប្រើប្រាស់ដី កំណត់បែងចែកតំបន់គ្រប់គ្រង និងរៀបចំផែនការ គ្រប់គ្រងប្រព័ន្ធតំបន់ ការពារធម្មជាតិ ដែលបានបង្កើតដោយថ្នាក់ជាតិ ។

២- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូបច្ចេកទេស ដែលមានបទពិសោធន៍ ស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងអ្នកពាក់ព័ន្ធ ដើម្បីអនុវត្តសកម្មភាព ការងារនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ រួមទាំងសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី សកម្មភាពកំណត់ បែងចែកតំបន់គ្រប់គ្រង ការអង្កេតតាមដាន ត្រួតពិនិត្យ និងការស្រាវជ្រាវជីវៈចម្រុះ ទេសចរណ៍ធម្មជាតិ និងការអប់រំ ព្រមទាំងការឃាត់ខ្លួន និងការចោទប្រកាន់ជនប្រព្រឹត្តបទល្មើសធនធានធម្មជាតិ ។

៣- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងការអភិរក្ស និងការគ្រប់គ្រងប្រព័ន្ធ តំបន់ការពារធម្មជាតិ ដោយសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ មូលដ្ឋាន ។

៤- ធ្វើអធិការកិច្ច អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារពាក់ព័ន្ធនឹងប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលបានបង្កើតដោយថ្នាក់ជាតិ និងចូលរួមនៅក្នុងសកម្មភាពពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងបរិស្ថាន និងអភិរក្សធនធានធម្មជាតិ ។

៥- ចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬឯកសារពាក់ព័ន្ធនឹងប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលបង្កើតដោយថ្នាក់ក្រោមជាតិ ។

៦- អនុវត្តជាប្រចាំនូវការល្បាត ការអង្កេតតាមដាន ការស៊ើបអង្កេត និងពង្រឹងការអនុវត្តគ្រប់ សកម្មភាពដទៃទៀត ។

៧- សហការជាមួយសហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច ស្ថាប័នថ្នាក់ជាតិ ដៃគូបច្ចេកទេសលើការងារស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងអ្នកពាក់ព័ន្ធ ដើម្បីបង្កើតការគ្រប់គ្រងរួមគ្នាលើតំបន់ទាំងនេះ ដូចមានចែងក្នុងក្រមនេះ ។

៨- អនុវត្តការងារផ្សេងទៀត ដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងក្របខ័ណ្ឌគោលនយោបាយវិមជ្ឈការលើការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា៣០២** ._ តម្រូវការបទពិសោធន៍ និងការបណ្តុះបណ្តាល

ថ្នាក់ដឹកនាំ អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងនាយក នាយករង តំបន់ការពារធម្មជាតិ និងមន្ត្រីបច្ចេកទេសទីវាល នៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោម ៖

១- មានកម្រិតបណ្តុះបណ្តាលជំនាញពាក់ព័ន្ធបរិស្ថាន ឬធនធានធម្មជាតិ ។

២- មានបទពិសោធន៍ជំនាញបច្ចេកទេស និងគ្រប់គ្រងក្នុងវិស័យបរិស្ថាន ធនធានធម្មជាតិ ព្រៃឈើ ជលផល ការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរិស្ថាន និងធនធានធម្មជាតិ ឬជំនាញផ្សេងទៀតពាក់ព័ន្ធបរិស្ថាន និងធនធានធម្មជាតិ ។

ថ្នាក់ដឹកនាំ អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងនាយក នាយករង តំបន់ការពារធម្មជាតិ និងមន្ត្រីបច្ចេកទេសទីវាលត្រូវបំពេញវគ្គសិក្សា និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី៤
## ការរៀបចំផែនការប្រើប្រាស់ដី

**មាត្រា៣០៣**._ លក្ខខណ្ឌចាំបាច់សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ

ប្រព័ន្ធតំបន់ការពារធម្មជាតិ ចាំបាច់ត្រូវរៀបចំផែនការប្រើប្រាស់ដី ដែលជាសមាសភាគដ៏សំខាន់មួយ និងជាឧបករណ៍ជំនួយដល់ដំណើរការនៃការរៀបចំផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ផែនការប្រើប្រាស់ដីនៃតំបន់នីមួយៗ ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ ២០ (ម្ភៃ) ឆ្នាំ ម្តង ឬមុនកាលកំណត់ក្នុងករណីចាំបាច់ ។

**មាត្រា៣០៤**._ លក្ខខណ្ឌតម្រូវក្នុងការរៀបចំផែនការប្រើប្រាស់ដី

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច ត្រូវរៀបចំផែនការប្រើប្រាស់ដីក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ការរៀបចំផែនការប្រើប្រាស់ដីត្រូវរៀបចំដោយពិគ្រោះយោបល់ជាមួយអ្នកបច្ចេកទេស ដែលមានបទពិសោធន៍លើការងារស្រាវជ្រាវ ការពារ អភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ និងអ្នក ពាក់ព័ន្ធមានជាអាទិ៍សមាជិកគណៈកម្មការនិងសមាជិក តំបន់គ្រប់គ្រងរួមគ្នា និងសហគមន៍មូលដ្ឋាន ដែលស្ថិតនៅក្នុងតំបន់រៀបចំផែនការប្រើប្រាស់ដី ។

ចំពោះតំបន់គ្រប់គ្រងរួមគ្នា ការរៀបចំផែនការប្រើប្រាស់ដី ក៏ជាផ្នែកមួយនៃដំណើរការនៃ ការគ្រប់គ្រងរួមគ្នា ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងតំបន់គ្រប់គ្រងរួមគ្នាត្រូវរៀបចំឡើងដូចខាងក្រោម ៖

១- ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងតំបន់គ្រប់គ្រងរួមគ្នាអាចរៀបចំមុន ឬដាច់ដោយឡែក ពីការរៀបចំផែនការប្រើប្រាស់ដី ដូចមានចែងនៅក្នុងក្រមនេះ ។

២- ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងតំបន់គ្រប់គ្រងរួមគ្នាអាចរៀបចំក្នុងពេលជាមួយគ្នា ឬរួមបញ្ចូលគ្នាជាមួយផែនការប្រើប្រាស់ដីដែលមានចែងនៅក្នុងក្រមនេះ ។

៣- ឬការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងតំបន់គ្រប់គ្រងរួមគ្នាមុន និងក្រោយត្រូវឱ្យមានសង្គតិភាពជាមួយការរៀបចំផែនការប្រើប្រាស់ដី ដូចមានចែងនៅក្នុងក្រមនេះ ។

ការរៀបចំផែនការប្រើប្រាស់ដី និងការកំណត់ បែងចែកតំបន់គ្រប់គ្រងនិងផែនការគ្រប់គ្រង ដែលស្ថិតនៅក្រោមក្រមនេះ ត្រូវធ្វើឱ្យអស់ពីលទ្ធភាពដែលអាចធ្វើទៅបាន និងមានសង្គតិភាពជាមួយនឹងផែនការប្រើប្រាស់ដី ការកំណត់ បែងចែកតំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងដែលបានរៀបចំពីមុនមកស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣០៥** ._ ការងាររៀបចំផែនការប្រើប្រាស់ដី

ការងាររៀបចំផែនការប្រើប្រាស់ដីក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវអនុវត្ត ដូចខាងក្រោម ៖

១- ពិគ្រោះយោបល់ជាមួយអ្នកជំនាញអភិរក្សធនធានធម្មជាតិ និងដី អ្នកបច្ចេកទេសដែលមានបទពិសោធន៍លើការងារស្រាវជ្រាវ ការពារ អភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ និងលើការងាររៀបចំផែនការប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច និងអ្នកពាក់ព័ន្ធ ។

២- សិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យស្តីពីរូបសាស្រ្ត ជីវសាស្រ្ត សង្គម និងសេដ្ឋកិច្ចសារពើភណ្ឌដី ការប្រើប្រាស់ដីបច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធ ប្រជាសាស្រ្ត ធនធានធម្មជាតិ ជីវៈចម្រុះ កម្មសិទ្ធិដីធ្លី សិទ្ធិប្រពៃណី រចនាសម្ព័ន្ធសង្គម កត្តាជីវភាពរស់នៅជាប្រពៃណី គ្រោះធម្មជាតិ ជលវិទ្យា ថាមពល សត្វព្រៃ និងចលនាបន្លាស់ទី និងទិន្នន័យផ្សេងៗទៀត ។

៣- រៀបចំផែនទីប្រើប្រាស់ដីដូចជារូបសណ្ឋាននៃការប្រើប្រាស់ដី កម្មសិទ្ធិដី តំបន់បេតិកភណ្ឌ វប្បធម៌ និងជីវសាស្រ្តសំខាន់ៗដែលស្ថិតនៅក្នុង និងនៅក្បែរប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៤- ប្រមូលទិន្នន័យស្តីពីសក្តានុពលនៃការប្រើប្រាស់ដី និងហេតុប៉ះពាល់បរិស្ថានដែលអាចវាយតម្លៃបានលើសក្តានុពលនៃការប្រើប្រាស់ដី តម្លៃសេដ្ឋកិច្ចនៃធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី នៅក្នុង ឬនៅក្បែរប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៥- កំណត់បញ្ហាបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលមានទំនាក់ទំនងនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការគ្រប់គ្រងបរិស្ថានដោយនិរន្តរភាព ។

**មាត្រា៣០៦**._ ការរៀបចំផែនទីប្រើប្រាស់ដី

បន្ទាប់ពីបានរៀបចំផែនការប្រើប្រាស់ដី ត្រូវរៀបចំផែនទីប្រើប្រាស់ដី ដែលសម្រេចដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងតម្កល់ទុកនៅអង្គភាពទទួលបន្ទុកលើការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងស្ថាប័ន ឬអង្គភាពពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣០៧**._ ដំណើរការ និងលក្ខណៈវិនិច្ឆ័យនៃការរៀបចំផែនការប្រើប្រាស់ដី

ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅតំបន់ការពារធម្មជាតិ និងរបៀបអភិរក្សជីវៈចម្រុះត្រូវកំណត់តំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់តំបន់គ្រប់គ្រង និងផែនការគ្រប់គ្រង ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធអាចកំណត់ពីទំហំនៃការរៀបចំផែនការប្រើប្រាស់ដី ដោយមានការពិចារណាទៅលើធនធាន ពេលវេលានិងការសហការជាមួយដៃគូបច្ចេកទេស ស្របទៅតាមករណី និងភាពអាចព្យាករណ៍បាននៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

លក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងជំពូកនេះ មិនត្រូវធ្វើឱ្យយឺតយ៉ាវដល់ការកំណត់តំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់តំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងទាំងមូលសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

**មាត្រា៣០៨**._ សំណើកែសម្រួលផែនការប្រើប្រាស់ដី

សំណើកែសម្រួលផែនការប្រើប្រាស់ដី នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានឯកសារដូចខាងក្រោម ៖

១- មានទិន្នន័យប្រែប្រួលរូបសាស្ត្រដី ជីជាតិដី និងសេដ្ឋកិច្ចសង្គម ។

២- ស្ថានភាពនៃការប្រើប្រាស់ដីធ្លីបច្ចុប្បន្ន ។

៣- ត្រូវស្របទៅតាមចំណាត់ថ្នាក់នៃការប្រើប្រាស់ដីបច្ចុប្បន្ន ដោយធានាឱ្យបានការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ទំនៀមទម្លាប់នៃការប្រើប្រាស់ដី និងមិនមាន ផលប៉ះពាល់ដល់តំបន់ដែលមានតម្លៃអភិរក្សខ្ពស់ ។

៤- ការបាត់បង់តម្លៃនៃការអភិរក្ស និងប្រព័ន្ធអេកូឡូស៊ី ។

៥- ព័ត៌មានសមហេតុសមផលផ្សេងៗទៀត ។

សំណើក្នុងការធ្វើការកែសម្រួលផែនការប្រើប្រាស់ដីក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ ។

ការកែសម្រួលផែនការប្រើប្រាស់ដី ត្រូវមានសេចក្តីសម្រេចពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី៥
## ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

**មាត្រា៣០៩** ._ ប្រភេទតំបន់ការពារធម្មជាតិ

ប្រភេទតំបន់ការពារធម្មជាតិ ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិដែលមានជាធរមាន ។

គោលដៅ និងផែនការគ្រប់គ្រងប្រភេទតំបន់ខាងលើ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៣១០** ._ ការគ្រប់គ្រងរួមគ្នាលើតំបន់បេតិកភណ្ឌវប្បធម៌

ក្នុងករណីដែលនៅក្នុងតំបន់ការពារធម្មជាតិមានតំបន់ដែលកំណត់ថាជាតំបន់បេតិកភណ្ឌវប្បធម៌ នោះតំបន់ការពារបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើការគ្រប់គ្រងរួមគ្នារវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវសហការគ្នាក្នុងការរៀបចំផែនការគ្រប់គ្រងតំបន់បេតិកភណ្ឌវប្បធម៌ ។

**មាត្រា៣១១** ._ ការកំណត់តំបន់គ្រប់គ្រង

ស្របតាមលទ្ធផលនៃដំណើរការរៀបចំផែនការប្រើប្រាស់ដី ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវកំណត់តំបន់គ្រប់គ្រងសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

តំបន់គ្រប់គ្រងទាំងនេះត្រូវកំណត់ដោយផ្អែកលើទីតាំងជាក់លាក់ ហើយត្រូវពិចារណាអំពីប្រភេទ និងកម្រិតតំបន់គ្រប់គ្រងនីមួយៗរួមបញ្ចូលទាំងតំបន់ និងអនុតំបន់គ្រប់គ្រង ដែលមានលក្ខណៈសមស្រប ។

ការកំណត់តំបន់គ្រប់គ្រង ត្រូវមានការចូលរួមពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធដែលមានបទពិសោធន៍ស្រាវជ្រាវ ការពារ អភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដូចមានចែងក្នុងគន្លីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ ផ្តល់ឱកាសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ក្នុងការចូលរួមដំណើរការ នៃការកំណត់តំបន់គ្រប់គ្រង ។

តំបន់គ្រប់គ្រងត្រូវកំណត់ ទៅតាមទីតាំងជាក់លាក់ដូចខាងក្រោម ៖

១- តំបន់ស្នូល ៖ តំបន់គ្រប់គ្រងដែលមានតម្លៃនៃការអភិរក្សខ្ពស់ សម្រាប់ធនធានធម្មជាតិ មានប្រភេទសត្វ រុក្ខជាតិដែល ជិតផុតពូជ កម្រ ទទួលរងគ្រោះថ្នាក់ ការគំរាមកំហែង និងមាន ប្រព័ន្ធអេកូឡូស៊ីផុយស្រួយ ។

២- តំបន់អភិរក្ស ៖ ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់តំបន់ស្នូល ដែលមានតម្លៃខាងការអភិរក្ស ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាព ធម្មជាតិ ។

៣- តំបន់ប្រើប្រាស់ដោយចីរភាព ៖ តំបន់គ្រប់គ្រង ដែលមានសក្តានុពលសេដ្ឋកិច្ច និងមាន តម្លៃសម្រាប់ការអភិរក្ស និងប្រព័ន្ធអេកូឡូស៊ី ដែលមានសក្តានុពល ក្នុងការចូលរួមចំណែក លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចប្រកបដោយនិរន្តរភាព ។

៤- តំបន់សហគមន៍ ៖ តំបន់គ្រប់គ្រង សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃសហគមន៍ មូលដ្ឋាន និងជនជាតិដើមភាគតិចដែលមានសកម្មភាពកំពុងប្រើប្រាស់ និងមានស្រាប់រួមមានដីលំនៅឋាន វាលស្រែ វាលស្មួនដំណាំ ឬចម្ការវិលជុំ ។

**មាត្រា៣១២ ._** តំបន់ស្នូលនៃឧបនីយជីវមណ្ឌល

តំបន់ស្នូលនៃឧបនីយជីវមណ្ឌល ត្រូវបានបែងចែកជា៣ តំបន់គ្រប់គ្រងដូចខាងក្រោម ៖

១- តំបន់ស្នូល ៖ សំដៅដល់ប្រព័ន្ធអេកូឡូស៊ីដែលត្រូវបានការពារតឹងរ៉ឹង និងជាតំបន់ដែលជួយអភិរក្សតំបន់ទេសភាព ប្រព័ន្ធអេកូឡូស៊ី សត្វ និងរុក្ខជាតិ និងការប្រែប្រួលសេនេទិច ។

២- តំបន់ទ្រនាប់ ៖ សំដៅដល់តំបន់ដែលនៅជុំវិញ ឬដែលតភ្ជាប់ទៅនឹងតំបន់ស្នូល ហើយប្រើសម្រាប់សកម្មភាពពាក់ព័ន្ធនឹងអេកូឡូស៊ី ដែលទ្រទ្រង់ដល់ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ការអង្កេតតាមដាន ការបណ្តុះបណ្តាល និងការអប់រំ ។

៣- អន្តរតំបន់ ៖ ជាផ្នែកមួយនៃតំបន់បម្រុងទុក ដែលអនុញ្ញាតឱ្យមានសកម្មភាពជាអតិបរមា ដែលនាំឱ្យមានការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ច នាំទៅរកចីរភាពផ្នែកអេកូឡូស៊ី វប្បធម៌ និងសង្គម ។

**មាត្រា៣១៣ ._** ការផ្លាស់ប្តូរ និងការកំណត់តំបន់គ្រប់គ្រងឡើងវិញ

រាល់ការស្នើសុំផ្លាស់ប្តូរ និងកំណត់តំបន់គ្រប់គ្រងឡើងវិញ សម្រាប់តំបន់ការពារធម្មជាតិត្រូវដាក់ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីធ្វើការពិចារណា និងសម្រេច ដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ។

ការស្នើសុំនេះ ត្រូវមានខ្លឹមសារ ដូចខាងក្រោម ៖

១- សេចក្តីពិពណ៌នាផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងតំបន់គ្រប់គ្រងដែលស្នើសុំផ្លាស់ប្តូរ ដែលមានផែនទីកំណត់ពីមាត្រដ្ឋានត្រឹមត្រូវ និងច្បាស់លាស់ ។

២- សេចក្តីលម្អិតអំពីការផ្លាស់ប្តូរទៅលើការប្រើប្រាស់ដី ដែលត្រូវកើតឡើងបន្ទាប់ពីមានការ ផ្លាស់ប្តូរ និងការកំណត់តំបន់គ្រប់គ្រងឡើងវិញ ។

៣- បញ្ជាក់ហេតុផលផ្នែកវិទ្យាសាស្ត្រ និងផ្នែកសេដ្ឋកិច្ចសង្គម សម្រាប់ការស្នើសុំផ្លាស់ប្តូរ និងកំណត់តំបន់គ្រប់គ្រងឡើងវិញ ។

៤- កិច្ចខិតខំប្រឹងប្រែងកន្លងមកក្នុងការរក្សានូវសភាពដើមនៃតំបន់គ្រប់គ្រង ។

៥- របៀបដែលការកែប្រែ និងកំណត់តំបន់គ្រប់គ្រងឡើងវិញ លើកកម្ពស់ដល់ជីវភាពរស់នៅ និងសិទ្ធិប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

៦- របៀបនៃការទូទាត់សម្រាប់ការផ្លាស់ប្តូរ និងការកំណត់តំបន់គ្រប់គ្រងឡើងវិញ ។

៧- លទ្ធផលនៃកិច្ចពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដែលទទួលរងផលប៉ះពាល់រួមទាំងឯកសារដែលបញ្ជាក់ពីការយល់ព្រមរបស់សហគមន៍ទាំងនេះ ។

៨- រាល់ព័ត៌មានផ្សេងទៀត តាមការតម្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៣១៤** ._ ការកំណត់តំបន់ សម្រាប់សកម្មភាពពាណិជ្ជកម្ម

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធ ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង នៅក្នុងផ្នែកណាមួយនៃប្រព័ន្ធតំបន់ការពារធម្មជាតិ អាចកំណត់ផ្នែកជាក់លាក់នៃតំបន់ប្រើប្រាស់ដោយចីរភាព ឬតំបន់សហគមន៍នោះដែលមានសក្តានុពលសេដ្ឋកិច្ច និងតម្លៃអភិរក្ស និងប្រព័ន្ធអេកូឡូស៊ីទាប សម្រាប់សកម្មភាពពាណិជ្ជកម្ម ។

ដំណើរការនៃការកំណត់តំបន់ សម្រាប់សកម្មភាពពាណិជ្ជកម្ម និងសេចក្តីលម្អិត នៃការរៀបចំតំបន់ ត្រូវលាតត្រដាង ឱ្យសាធារណជនទទួលបានព័ត៌មាន និងឱកាសផ្តល់មតិយោបល់ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣១៥** ._ ផែនទីនៃប្រព័ន្ធតំបន់ការពារធម្មជាតិនីមួយៗ

នៅពេលបញ្ចប់ដំណើរការនៃការកំណត់តំបន់គ្រប់គ្រងត្រូវរៀបចំបង្កើត នូវផែនទីសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដែលមានការចូលរួមពីអង្គភាពពាក់ព័ន្ធ ។ ព្រំប្រទល់ និងតំបន់គ្រប់គ្រងនីមួយៗ ត្រូវដាក់ផ្សព្វផ្សាយជាសាធារណៈដល់អ្នកពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣១៦** ._ ការធ្វើបច្ចុប្បន្នភាពលើការកំណត់តំបន់គ្រប់គ្រង និងការធ្វើផែនទី

ការធ្វើផែនទី និងការកំណត់តំបន់គ្រប់គ្រងនីមួយៗទៅតាមទីតាំងជាក់លាក់ ត្រូវធ្វើបច្ចុប្បន្នភាពតាមករណីចាំបាច់ ។

**មាត្រា៣១៧** ._ ការកែសម្រួលចំណាត់ថ្នាក់តំបន់គ្រប់គ្រង

ការកែសម្រួលចំណាត់ថ្នាក់តំបន់គ្រប់គ្រងនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ឬផ្នែកណាមួយនៃតំបន់ទាំងនេះ ពីតំបន់ដែលមានកម្រិតការពារខ្ពស់ ទៅជាតំបន់ដែលមានកម្រិតការពារទាប ផ្អែកតាមហេតុផលដូចខាងក្រោម ៖

១- ផ្អែកលើមូលហេតុផ្នែកវិទ្យាសាស្ត្រ សេដ្ឋកិច្ច និងសង្គម សម្រាប់កែប្រែចំណាត់ថ្នាក់តំបន់គ្រប់គ្រង ។

២- កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដើម្បីរក្សាស្ថានភាព កម្រិតចំណាត់ថ្នាក់ធនធានធម្មជាតិ បច្ចុប្បន្ននៃតំបន់គ្រប់គ្រង ។

៣- ផ្អែកលើការលើកកម្ពស់ជីវភាពរស់នៅ និងសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋាន ។

៤- ការបាត់បង់តម្លៃនៃការអភិរក្ស និងប្រព័ន្ធអេកូឡូស៊ី ។

៥- ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ និងសហគមន៍មូលដ្ឋាន ដែលទទួលរងផលប៉ះពាល់ ចំពោះការកែសម្រួលចំណាត់ថ្នាក់នេះ ។

៦- ព័ត៌មានដទៃទៀតដែលចាំបាច់សម្រាប់ការកែសម្រួលចំណាត់ថ្នាក់នេះ ។

ការកែសម្រួល ចំណាត់ថ្នាក់តំបន់គ្រប់គ្រងនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

រាល់ការកែសម្រួលចំណាត់ថ្នាក់តំបន់គ្រប់គ្រង ត្រូវមានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ បន្ទាប់ពីបានសម្រេចដោយបង្ហាញពីការពិចារណាដោយប្រុងប្រយ័ត្នពីឯកសារដែលបានផ្សព្វផ្សាយនេះ ។

**មាត្រា៣១៨**._ សកម្មភាពពាណិជ្ជកម្មនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍

ស្របតាមផែនការគ្រប់គ្រងនៃមាតិកានេះ ឬផែនការគ្រប់គ្រងរួមគ្នានៃមាតិកាទី២ នៃគន្ថីនេះ អាជ្ញាធរគ្រប់គ្រងពាក់ព័ន្ធ សម្រាប់សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ អាចកំណត់យកផ្នែកណាមួយនៃតំបន់ប្រើប្រាស់ដោយចីរភាព ឬតំបន់សហគមន៍ ដែលមានសក្តានុពលផ្នែកសេដ្ឋកិច្ច និងតម្លៃប្រព័ន្ធអេកូឡូស៊ី និងតម្លៃនៃការអភិរក្សទាប ធ្វើជាតំបន់សម្រាប់សកម្មភាពពាណិជ្ជកម្ម ។

បន្ទាប់ពីមានការកំណត់ដូចខាងលើ និងនៅមុនពេលផ្តល់ការអនុញ្ញាតសម្រាប់សកម្មភាពពាណិជ្ជកម្មបែបនេះ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលពាក់ព័ន្ធត្រូវ ៖

១- បើកកិច្ចពិគ្រោះយោបល់សមរម្យជាមួយអ្នកពាក់ព័ន្ធ ។

២- បើកបង្ហាញឱ្យភាគីពាក់ព័ន្ធ បានដឹងអំពីការរៀបចំឱ្យមានថវិកា និងចំណូល ដូច បានព្យាករពីសកម្មភាពពាណិជ្ជកម្ម ដែលបានស្នើសុំ ។

**មាត្រា៣១៩ ._** ដីសម្បទានសេដ្ឋកិច្ច

សម្រាប់ដីសម្បទានសេដ្ឋកិច្ចដែលនៅជាធរមាន ហើយដែលស្ថិតនៅក្នុង ឬជាប់ទៅនឹង សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយ ក្រសួង ស្ថាប័នទទួលបន្ទុកព្រៃឈើ ត្រូវប្រើប្រាស់ដើម្បីលើកកម្ពស់គោល បំណងនៃប្រព័ន្ធតំបន់ការពារធម្មជាតិបាន ដូចបានកំណត់ក្នុងមាតិកានេះ ។

**មាត្រា៣២០ ._** ការលុបចោលនូវសម្បទានដីសេដ្ឋកិច្ច

ក្រោយពីសម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ ត្រូវបានលុបចោលដីសម្បទាន សេដ្ឋកិច្ចនោះ ត្រូវកំណត់ចូលទៅក្នុងតំបន់គ្រប់គ្រង ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ក្រោយពីសម្បទានដីសេដ្ឋកិច្ចនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ ត្រូវបានលុបចោលក្រសួង ស្ថាប័ន ទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវចាត់វិធានការ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ក្រោយពីសម្បទានដីសេដ្ឋកិច្ចនៅក្រៅប្រព័ន្ធតំបន់ការពារ ធម្មជាតិត្រូវបាន លុបចោល ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចធ្វើការស្នើសុំកំណត់តំបន់សម្បទានដីសេដ្ឋកិច្ច ដែលបានលុបចោល ជាសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

## ជំពូកទី៦
## ផែនការយុទ្ធសាស្ត្រ និងផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

**មាត្រា៣២១ ._** ផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានតួនាទីរៀបចំផែនការយុទ្ធសាស្ត្រ ប្រព័ន្ធ តំបន់ការពារធម្មជាតិ ។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវស្របតាមផែនការប្រើប្រាស់ដី និងមាន សង្គតិភាព ជាមួយនឹង យុទ្ធសាស្ត្រ និងផែនការជាតិនានា ដោយមានការពិគ្រោះយោបល់ជាមួយអ្នក ពាក់ព័ន្ធ ។

ផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានគោលដៅសម្រេចបាននូវបរិមាណតំណាងប្រភេទប្រព័ន្ធអេកូឡូស៊ី ដែលស្ថិតនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ នៃដែនសមុទ្រ ដែនទឹកសាប និងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម ៖

១- រៀបចំគោលដៅកំណត់បរិមាណតំណាងប្រភេទប្រព័ន្ធអេកូឡូស៊ីនៃប្រព័ន្ធអេកូឡូស៊ីទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- រក្សា និងធ្វើការជួសជុលប្រព័ន្ធតំបន់ការពារធម្មជាតិទាំងមូល និងតំបន់នីមួយៗដោយឡែក ។

៣- រៀបចំ និងអនុវត្តតាមគោលនយោបាយគ្រប់គ្រង គោលការណ៍ណែនាំ និងផែនការនានា ។

៤- គ្រប់គ្រងដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។

៥- អភិវឌ្ឍសមត្ថភាពគ្រប់គ្រងដោយចីរភាព និងឱ្យបានគ្រប់គ្រាន់ ។

៦- ធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ និងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងបង្កើនឱ្យមានការចូលរួមធ្វើអភិបាលកិច្ចពីសហគមន៍មូលដ្ឋាន ។

៧- បញ្ចូលវិធីសាស្ត្រនៃការគ្រប់គ្រងរួមគ្នា និងវិធីសាស្ត្រនៃការគ្រប់គ្រងបែបនវានុវត្តន៍ផ្សេងទៀតទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៨- រៀបចំធនធានចីរភាពហិរញ្ញវត្ថុសម្រាប់ការរៀបចំ និងការថែរក្សាប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៩- ធ្វើការស្រាវជ្រាវនៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងរៀបចំឱ្យមានប្រព័ន្ធទិន្នន័យដែលងាយស្រួលប្រើប្រាស់ ដែលក្នុងនោះត្រូវមានលទ្ធផលស្រាវជ្រាវ និងព័ត៌មាន អំពីមុខងារ តួនាទី តម្លៃ និងលក្ខខណ្ឌតម្រូវពាក់ព័ន្ធទៅនឹងប្រព័ន្ធតំបន់ការពារធម្មជាតិ និងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

១០- ពង្រឹងបន្ថែមកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តច្បាប់ស្តីពីតំបន់ការពារធម្មជាតិរួមគ្នារវាងថ្នាក់ជាតិ និងក្រោមជាតិ ។

**មាត្រា៣២២ .**_ ការពិនិត្យឡើងវិញ និងការកែសម្រួលផែនការយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានតួនាទីពិនិត្យ និងកែសម្រួល

ផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិនៅរៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង ឬធ្វើការកែសម្រួលនៅពេលមានករណីចាំបាច់ ដើម្បីបំពេញតាមគោលបំណង និងគោលដៅនៃការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ការពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

១- មានការវិវត្តទៅលើព័ត៌មានផ្នែកវិទ្យាសាស្ត្រ និងការយល់ដឹងផ្នែកធនធានធម្មជាតិជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងបេតិកភណ្ឌវប្បធម៌នៃព្រះរាជាណាចក្រកម្ពុជា ។

២- មានការលេចឡើងថ្មីនូវការរងគ្រោះថ្នាក់ដល់ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៣- មានការធ្វើបច្ចុប្បន្នភាពទៅលើយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ ។

**មាត្រា៣២៣** ._ ផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

ប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវអនុលោមតាមផែនការ កម្មវិធី និងផែនការគ្រប់គ្រងតាមតំបន់នីមួយៗ ដោយផ្អែកលើមូលដ្ឋាននៃទីតាំងជាក់លាក់ ស្របតាមប្រព័ន្ធតំបន់ការពារធម្មជាតិ និងការកំណត់អំពីការគ្រប់គ្រងរួមគ្នា ។

ប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលត្រូវបានបង្កើតបន្ថែមទៀត ដែលស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ អាចត្រូវអនុលោមតាមផែនការគ្រប់គ្រងដាច់ដោយឡែក ផ្អែកលើមូលដ្ឋានផែនការកម្មវិធីគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ។ ផែនការគ្រប់គ្រងតំបន់នីមួយៗ ត្រូវមានបញ្ចូលនៅក្នុងផែនការកម្មវិធីគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ។ ផែនការគ្រប់គ្រងតំបន់នីមួយៗដែលកំពុងអនុវត្តមុនពេលក្រមនេះចូលជាធរមាន នៅតែមាននីត្យានុកូលភាពអនុវត្ត និងមានលក្ខណៈសម្បត្តិសិក្សាដាក់បញ្ចូលទៅក្នុងផែនការកម្មវិធីគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

តំបន់ការពារធម្មជាតិដែលបង្កើតថ្មី ដែលមិនស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ ត្រូវអនុលោមតាមផែនការគ្រប់គ្រងដាច់ដោយឡែកតាមតំបន់នីមួយៗ ។

**មាត្រា៣២៤** ._ ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

ប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវទទួលបានសិទ្ធិគ្រប់គ្រងរួមគ្នា ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

តំបន់គ្រប់គ្រងរួមគ្នាដែលត្រូវបានបង្កើតឡើងនៅក្នុងផ្នែកណាមួយនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវគ្រប់គ្រង ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣២៥** ._ ការរៀបចំផែនការគ្រប់គ្រង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិតាមទីតាំង និងស្ថានភាពជាក់ស្តែង ដោយអនុលោមតាមផែនការយុទ្ធសាស្រ្តសម្រាប់គ្រប់គ្រង ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវដាក់បញ្ចូលនូវការ ពិពណ៌នាអំពីតម្លៃជីវៈចម្រុះ វប្បធម៌ ធម្មជាតិ និងមុខងារប្រព័ន្ធអេកូឡូស៊ី ការវិភាគអំពីការគំរាមកំហែង និងហានិភ័យនៃផលប៉ះពាល់លើតម្លៃទាំងនេះ ដោយដាក់ចេញនូវគោលបំណងជាយុទ្ធសាស្រ្ត និងសកម្មភាពគ្រប់គ្រងសំខាន់ៗ និងអាទិភាព ។

ដំណើរការនៃការរៀបចំផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូបច្ចេកទេសដែលមានបទពិសោធន៍ ពាក់ព័ន្ធធនធានធម្មជាតិ ម្ចាស់សម្បទានដីសេដ្ឋកិច្ច សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ដែលរស់នៅក្នុង ឬក្បែរប្រព័ន្ធតំបន់ការពារធម្មជាតិ និងអ្នកពាក់ព័ន្ធ ។

ផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវកែសម្រួលជារៀង រាល់ ១០ (ដប់) ឆ្នាំម្តងគិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬតាមការចាំបាច់ ។ ផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិត្រូវ កែសម្រួល ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣២៦** ._ ការបន្តសុពលភាព

សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទ តំបន់ទទួលស្គាល់ តាមប្រពៃណី និងសហគមន៍មូលដ្ឋានដទៃទៀតដែលមានស្រាប់ នៅពេល ក្រមនេះចូលជាធរមាន ត្រូវបន្តសុពលភាព សិទ្ធិ ការទទួលខុសត្រូវ និងកាតព្វកិច្ចទាំងអស់ ស្របច្បាប់ លើកលែងតែ ឬរហូតដល់ពេលដែលសហគមន៍នីមួយៗ អាចត្រូវបានការបញ្ចូលទៅក្នុង ឬប្រែក្លាយទៅជា តំបន់គ្រប់គ្រងរួមគ្នា ដូចមានចែងនៅក្នុងក្រមនេះ ។

# ជំពូកទី៧
# ការអនុញ្ញាត ការសម្រេច និងការហាមឃាត់

**មាត្រា៣២៧**._ សិទ្ធិអំណាចក្នុងការចេញលិខិតអនុញ្ញាត ចុះកិច្ចព្រមព្រៀង និងកិច្ចសន្យា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានសិទ្ធិចេញលិខិតអនុញ្ញាត ចុះកិច្ចព្រមព្រៀង ឬកិច្ចសន្យាសម្រាប់ការអភិរក្សនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។ ការចេញលិខិតអនុញ្ញាត កិច្ចព្រមព្រៀង ឬកិច្ចសន្យា ត្រូវស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣២៨**._ សកម្មភាពអភិវឌ្ឍន៍ដែលត្រូវបានហាមឃាត់ក្នុងតំបន់គ្រប់គ្រង នៃប្រព័ន្ធតំបន់ការពារធម្មជាតិ

សកម្មភាព ដែលត្រូវហាមឃាត់ក្នុងតំបន់គ្រប់គ្រងនៃប្រព័ន្ធតំបន់ការពារធម្មជាតិរួមមាន៖

១- តំបន់ស្នូល ៖ ហាមឃាត់ចំពោះសកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ មានជាអាទិ៍ ការរុករករ៉ែ ការបូមច្រោះ និងការទាញយកខ្សាច់ ការផលិតអគ្គិសនី ប្រព័ន្ធបញ្ជូន ឬចែកចាយអគ្គិសនី ការប្រើយានយន្តដឹកជញ្ជូន គ្រឿងម៉ាស៊ីន ដំណាំកសិកម្ម វារីវប្បកម្មគ្រប់ប្រភេទ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងធនធានទឹក រួមមាន ប្រព័ន្ធធារាសាស្ត្រ និងទំនប់ទឹកធារាសាស្ត្រគ្រប់ប្រភេទ ការប្រើប្រាស់ដើម្បីចិញ្ចឹមជីវិត និងជាលក្ខណៈប្រពៃណី ឬការចិញ្ចឹមសត្វ ។

ការចេញចូលតំបន់ស្នូលត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ នៅក្នុងករណីដែលទាក់ទងនឹងសន្តិសុខជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកសន្តិសុខ និងការពារជាតិ ត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ នៅពេលដែលការចេញចូលនេះមានការចាំបាច់ និងត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

២- តំបន់អភិរក្ស ៖ ហាមឃាត់ចំពោះការរុករករ៉ែ ការបូមច្រោះ និងការទាញយកខ្សាច់ ការផលិតអគ្គិសនី ប្រព័ន្ធបញ្ជូន ឬចែកចាយអគ្គិសនី ការប្រើយានយន្តដឹកជញ្ជូន គ្រឿងម៉ាស៊ីន ដំណាំកសិកម្ម វារីវប្បកម្មគ្រប់ប្រភេទ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងធនធានទឹក រួមមាន ប្រព័ន្ធធារាសាស្ត្រ និងទំនប់ទឹកគ្រប់ប្រភេទនិងគ្រប់សកម្មភាពពាណិជ្ជកម្មទាំងអស់ លើកលែងតែទេសចរណ៍ធម្មជាតិដែលមានផលប៉ះពាល់តិចតួចប៉ុណ្ណោះ ។

ការចេញចូលតំបន់អភិរក្សត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ នៅក្នុងករណីដែលទាក់ទងនឹងសន្តិសុខជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកសន្តិសុខ និងការពារជាតិ ត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ នៅពេលដែលការចេញចូលនេះមានការចាំបាច់ និងត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

៣- តំបន់ប្រើប្រាស់ដោយចីរភាព ៖ ហាមឃាត់គ្រប់សកម្មភាពពាណិជ្ជកម្ម ដែលនាំឱ្យមានការផ្លាស់ប្តូរប្រភេទចំណាត់ថ្នាក់ដីព្រៃឈើ ឬធ្វើមានការប្រែប្រួលគម្របព្រៃឈើ ។

៤- និងតំបន់សហគមន៍ ៖ ហាមឃាត់គ្រប់សកម្មភាពទាំងអស់ ដែលនាំឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ការការពារ និងអភិរក្សជីវៈចម្រុះ ។

ផែនការគ្រប់គ្រងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ និងផែនការគ្រប់គ្រងតំបន់គ្រប់គ្រងនៃតំបន់ស្នូលនៃឋបនីយជីវមណ្ឌល និងផែនការគ្រប់គ្រងរួមគ្នា ដូចមានចែងក្នុងមាតិកាទី២ នៃគន្លីនេះ អាចកំណត់អំពីការហាមឃាត់នូវសកម្មភាពជាក់លាក់ និងការចេញចូលក្នុងតំបន់គ្រប់គ្រង ។

**មាត្រា៣២៩** ._ សកម្មភាពអភិវឌ្ឍន៍ដែលត្រូវបានអនុញ្ញាតក្នុងតំបន់គ្រប់គ្រង នៃប្រព័ន្ធតំបន់ការពារធម្មជាតិ

សកម្មភាពដែលអាចត្រូវបានអនុញ្ញាតនៅក្នុងតំបន់គ្រប់គ្រងនៃប្រព័ន្ធតំបន់ការពារធម្មជាតិ រួមមាន ៖

១- តំបន់ស្នូល ៖ អនុញ្ញាតចំពោះការងារស្រាវជ្រាវ ការងារឃាមល្បាត សំណង់ដែលមិនអចិន្ត្រៃយ៍ សំណង់សមស្របតាមតំបន់ ដែលបម្រើឱ្យការងារគ្រប់គ្រង និងការងារស្រាវជ្រាវ ។

២- តំបន់អភិរក្ស ៖ អនុញ្ញាតចំពោះ ការងារស្រាវជ្រាវ ការងារឃាមល្បាត និងប្រតិបត្តិការទេសចរណ៍ធម្មជាតិដែលអាចមានហេដ្ឋារចនាសម្ព័ន្ធធម្មជាតិតូចតាច និង មានផលប៉ះពាល់តិចតួច ការប្រមូលផលឈើ អុស និងអនុផលព្រៃឈើ ជាលក្ខណៈគ្រួសារ ឬលក្ខណៈប្រពៃណី សំណង់សមស្របតាមតំបន់ ដែលបម្រើឱ្យការងារគ្រប់គ្រង និងការងារស្រាវជ្រាវត្រូវស្ថិតក្រោមការត្រួតពិនិត្យ ឬត់ចត់បំផុតរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

៣- តំបន់ប្រើប្រាស់ដោយចីរភាព ៖ អនុញ្ញាតចំពោះសកម្មភាពអភិវឌ្ឍន៍ដូចមាននៅក្នុងតំបន់អភិរក្ស និងលើសពីនេះ រួមមាន ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត តាមតំបន់សម្រាប់ប្រតិបត្តិការទេសចរណ៍ធម្មជាតិ ការចិញ្ចឹមសត្វ ការប្រើប្រាស់ដើម្បីចិញ្ចឹមជីវិត សកម្មភាពប្រមូលផលនិងផលិតខ្នាតតូចរួមមាន កសិកម្ម ព្រៃឈើ និងរុក្ខវប្បកម្មរបស់សហគមន៍ និងការប្រមូលយកផល និងអនុផលព្រៃឈើ កសិកម្មចិញ្ចឹមជីវិតជាលក្ខណៈគ្រួសារ ឬលក្ខណៈប្រពៃណី និងការដំឡើងបណ្ដាញអគ្គិសនី ។ ការធ្វើពាណិជ្ជកម្ម ផល-អនុផលព្រៃឈើ ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ត្រូវអនុលោមទៅតាមផែនការគ្រប់គ្រង ដោយមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

៤- តំបន់សហគមន៍ ៖ អនុញ្ញាតចំពោះសកម្មភាពអភិវឌ្ឍន៍ដូចមាននៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងលើសពីនេះ រួមមាន ដីភូមិករ និងការតាំងទីលំនៅស្រាប់ ចម្ការវិលជុំ ដីកសិកម្ម ដីស្រែ ដីដាំដំណាំ ដីចម្ការ និងដីសំណង់សាធារណៈ ។ អាចអនុញ្ញាតឱ្យមានការអភិវឌ្ឍ និងការវិនិយោគនៅក្នុងតំបន់នេះបាន តាមការស្នើសុំរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រោយពីមានការពិគ្រោះ យោបល់ពីបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និង សហគមន៍មូលដ្ឋានដោយ អនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន ។

ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់សហគមន៍ ត្រូវមាន ការបញ្ជាក់យល់ព្រមជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ផែនការគ្រប់គ្រងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ និងផែនការគ្រប់គ្រងតំបន់គ្រប់គ្រងនៃតំបន់ស្នូលនៃបបនីយជីវមណ្ឌល និងផែនការគ្រប់គ្រងរួមគ្នា ដូចមានចែងក្នុងមាតិកាទី២ នៃគន្ថីនេះ អាចកំណត់អំពីការអនុញ្ញាតសម្រាប់សកម្មភាពជាក់លាក់ និងការចេញចូលក្នុងតំបន់គ្រប់គ្រង ។

**មាត្រា៣៣០** ._ ការយកចេញ ការយកចូល និងការបង្កាត់ពូជ

រាល់សំណើសុំយកចេញ យកចូល នៃសត្វ រុក្ខជាតិ គ្រាប់ពូជ និងសំណាកគ្រប់ប្រភេទ និងការបង្កាត់ពូជទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានការឯកភាពជាមុនពី ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយធ្វើការសិក្សាស្រាវជ្រាវ វិភាគឱ្យបានគ្រប់ជ្រុងជ្រោយ ដោយអនុលោមតាមបទប្បញ្ញត្តិ នៃក្រមនេះ ។

**មាត្រា៣៣១** ._ លក្ខខណ្ឌតម្រូវសម្រាប់ការស្រាវជ្រាវ ការវិភាគ និងការវាយតម្លៃ

រាល់ការនាំចេញ ការនាំចូល ឬការដោះដូរ នៃសត្វ រុក្ខជាតិ គ្រាប់ពូជ និងសំណាកគ្រប់ប្រភេទ ដែលពុំមានលក្ខណៈពាណិជ្ជកម្មរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសដទៃ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចសិក្សាពីលទ្ធភាពផ្តល់ និងផ្តល់ការអនុញ្ញាតទៅលើសកម្មភាព ស្នើសុំក្នុងករណីសកម្មភាពស្នើសុំនេះ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា៣៣២** ._ ការហាមឃាត់ចំពោះសកម្មភាពបង្កឱ្យមានភ្លើងឆេះព្រៃ

ហាមឃាត់ចំពោះសកម្មភាពបង្កឱ្យមានភ្លើងឆេះព្រៃនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ការប្រើប្រាស់ភ្លើងក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានហាមឃាត់ លើកលែងតែដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ផ្លូវភ្លើង ឬអនាម័យព្រៃ ដោយមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៣៣៣** ._ ការហាមឃាត់ចំពោះសកម្មភាពនេសាទ

ការនេសាទនៅក្នុងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ ត្រូវហាមឃាត់ ។

ការនេសាទនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិត្រូវហាមឃាត់ ចំពោះការប្រើប្រាស់ឧបករណ៍ ឬសារធាតុរួមមាន សារធាតុពុល សារធាតុគីមី ការឆក់ ស្បៃមុង គ្រឿងផ្ទុះ ស្នួរមផ្សំជាមួយគ្រឿងផ្ទុះ មងឬអួនដែលមានក្រឡាតូចជាង ១ (មួយ) សង់ទីម៉ែត្រកន្លះ សំណាញ់ដែលមានភ្លើងព័ទ្ធជុំវិញ និងឧបករណ៍ ឬសារធាតុផ្សេងទៀតដែលច្បាប់ហាមឃាត់ ។

ការដាក់រនាំង ឬឧបសគ្គរាំង នៅក្នុងប្រព័ន្ធផ្លូវទឹក ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលរាំងផ្លូវធ្វើដំណើររបស់មច្ឆជាតិ ដោយគ្មានលិខិតអនុញ្ញាតត្រូវហាមឃាត់ ។

ការបង្ហូរ ការប៉ុនប៉ងបង្ហូរ ការធ្វើឱ្យរីងទឹកនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ក្នុងគោលបំណងចាប់ ឬសម្លាប់មច្ឆជាតិ ត្រូវហាមឃាត់ ។

ការធ្វើឱ្យខូចខាតកន្លែងពង កូនមច្ឆជាតិ នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវហាមឃាត់ ។

ការបង្កើត ឬការធ្វើប្រតិបត្តិការវារីវប្បកម្ម នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ត្រូវហាមឃាត់។ ដំណើរការវារីវប្បកម្មក្នុងតំបន់ទាំងនេះត្រូវមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន

និងធនធានធម្មជាតិ និងត្រូវអនុលោមតាមការអង្កេតតាមដាន ដើម្បីធានាថាមិនមានផលប៉ះពាល់អវិជ្ជមានណាមួយនៅជុំវិញតំបន់នោះ ។

**មាត្រា៣៣៤**._ ការការពារប្រឆាំងនឹងការបំផ្លិចបំផ្លាញ

រាល់ការអនុវត្តសកម្មភាព ដែលបង្កការខូចខាត ឬគ្រោះថ្នាក់ ដែលបណ្តាលមកពីការទន្ទ្រានយកដីដោយខុសច្បាប់ ការប្រមូល ការឈូសឆាយ ការធ្វើអាជីវកម្ម ការបំពុលនៅក្នុងតំបន់ដែលមានធនធានជីវៈចម្រុះដ៏មានតម្លៃ ភ្លើងឆេះព្រៃ ការធ្វើកសិកម្មពនេចរ និងកសិកម្មបែបពាណិជ្ជកម្ម ការចម្លងជំងឺ និងសត្វល្អិតចង្រៃ ដែលរួមមាន ប្រភេទរុក្ខជាតិ ឬសត្វ ដែលរាតត្បាត ត្រូវហាមឃាត់ ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ការអនុវត្តសកម្មភាពដែលបង្កឱ្យមានការបំផ្លិចបំផ្លាញ ការខូចខាត ឬគ្រោះថ្នាក់ ដែលត្រូវហាមឃាត់ មានជាអាទិ៍ ៖

១- ការដកចេញ ឬ បំផ្លាញគំនូសសម្គាល់ព្រំប្រទល់ ឬបង្គោលសម្គាល់ព្រំប្រទល់ផ្លូវការ ឬ ការដាក់ជំនួសនូវគំនូសសម្គាល់ព្រំប្រទល់ ឬបង្គោលសម្គាល់ព្រំប្រទល់ឯកជន ។

២- ការប្រមូលផល និងអនុផលព្រៃឈើ ផលិតផលជលផល និងធនធានធម្មជាតិ នៅក្នុងលក្ខណៈមួយ ដែលរំលោភបំពានលើសិទ្ធិដែលមានការទទួលស្គាល់ ឬបានអនុញ្ញាត ដោយច្បាប់ និងផែនការគ្រប់គ្រង ឬដោយបុគ្គលដែលគ្មានលិខិតអនុញ្ញាតដែលផុតសុពលភាព ។

៣- ការកាប់ឆ្ការរំលំ ក្រៀវ កាប់បំផ្លាញ ឬបំពុល រុក្ខជាតិ ឬដើមឈើ ឬគាស់រំលើងគល់ឈើ ដោយគ្មានលិខិតអនុញ្ញាត ឬមានលិខិតអនុញ្ញាត ផុតសុពលភាព ។

៤- ការចាប់ ប្រមាញ់ ប្រមូល និងយាយីរំខានស៊ុតសត្វ កូនសត្វ និងសត្វស្លាបតាមគ្រប់មធ្យោបាយ ។

៥- ការបំផ្លាញគុណភាពទឹកគ្រប់រូបភាព ការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការបោះបង់ចោលសំណល់រឹង និងរាវចូលក្នុងទឹក ឬលើដី និងការប្រើប្រាស់ឧបករណ៍ឆក់ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីការការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វ ដូចមានចែងក្នុងក្រមនេះ ។

៦- ការយកអន្ទាក់ ឬសម្ភារផលិតអន្ទាក់ អង្គប់ កាំភ្លើងបាញ់សត្វ និងសម្ភារផ្សេងទៀតដែលប្រើប្រាស់ក្នុងការបំផ្លាញ ឬសម្លាប់សត្វព្រៃ នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

៧- ការប្រមាញ់សត្វព្រៃនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

៨- ការស្តុកទុក ការទិញ ការលក់ ការកាន់កាប់ ការធ្វើពាណិជ្ជកម្ម ការបង្កាត់ពូជ ការរក្សាទុក ការថែរក្សាឱ្យស្ថិតស្ថេរ ការដឹកជញ្ជូន ការប្រើប្រាស់ ការស្តុក និងការប្រើប្រាស់ដទៃទៀតនៃសត្វព្រៃ មានចែងក្នុងបទប្បញ្ញត្តិស្តីពីការការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វ ដូចមានចែងក្នុងក្រមនេះ ។

៩- ការបំផ្លាញព្រៃធម្មជាតិ វាលស្មៅធម្មជាតិ ដីសើម រុក្ខជាតិ និងទីជម្រកសត្វព្រៃ ។

១០- ការនាំយកចូល ឬការលែងឱ្យពពួកសត្វ ឬរុក្ខជាតិ រួមមាន សត្វពាហនៈ និងឆ្កែចូលទៅក្នុងតំបន់ស្នូល ឬតំបន់អភិរក្ស ។

១១- ការបង្កាត់ពូជនៃប្រភេទសត្វព្រៃ ឬមច្ឆជាតិ ។

១២- ការអនុវត្តនូវការនេសាទខុសច្បាប់ ការធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិ ទាំងក្នុងដែនទឹកសាប និងទឹកប្រៃ ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ទន្លេ និងដីសើម ។

១៣- ការបង្កើតមូលដ្ឋានកែច្នៃខ្លឹមចន្ទន៍ ម្រះព្រៅភ្នំ វល្លិរមៀត ឬអនុផលព្រៃឈើផ្សេងទៀត និងការធ្វើវារីវប្បកម្មទឹកសាប ទឹកប្រៃ ដែលអាចបង្កការបំពុល ឬផលប៉ះពាល់បែបបំផ្លិចបំផ្លាញជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ។

១៤- សកម្មភាពរុករក ស្រាវជ្រាវរ៉ែ រួមមាន ការស្ទាបស្ទង់ ការធ្វើតេស្ត ការរុករក និងការទាញយករ៉ែនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

១៥- ការបូម ឬការទាញយកខ្សាច់ និងរ៉ែ ឬធនធានផ្សេងទៀត ពីទន្លេ និងច្រាំងទន្លេ ឬតំបន់ឆ្នេរនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

១៦- ការអភិវឌ្ឍទំនប់ទឹក ឬធារាសាស្ត្រខ្នាតតូច នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

១៧- ទទួលភារកិច្ចផ្សេងៗទៀត ។

**មាត្រា៣៣៥**._ ការហាមឃាត់ចំពោះការកែច្នៃ និងប្រតិបត្តិការលើធនធានធម្មជាតិ

ការកែច្នៃ និងប្រតិបត្តិការលើធនធានធម្មជាតិ ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវហាមឃាត់ លើកលែងតែការកែច្នៃ និងប្រតិបត្តិការលើធនធានធម្មជាតិនោះ ស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ដោយមានការអនុញ្ញាត លើកលែងដែលមានចែងក្នុងមាត្រា៣៣៦ នៃក្រមនេះ ។ ការកែច្នៃវល្លិរមៀត និងម្រះព្រៅ ត្រូវបានហាមឃាត់ នៅក្នុងគ្រប់កន្លែង ទាំងអស់នៃ ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ការទាក់ចាប់ ការចិញ្ចឹម ការស្តុក ការបង្កាត់ពូជ ការថែរក្សាឬការចិញ្ចឹមសត្វព្រៃក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ឬសម្រាប់គោលបំណងក្រៅពីការអភិរក្សដទៃៗទៀត ដែលស្ថិតនៅក្នុង ប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវហាមឃាត់ ។

ការដឹកជញ្ជូនធនធានធម្មជាតិ ដោយខុសច្បាប់ ឬលិខិតអនុញ្ញាតផុតសុពលភាព ត្រូវហាមឃាត់ ។

**មាត្រា៣៣៦** ._ ការប្រមូលផលជ័រឈើ

ការប្រមូលផលជ័រឈើ នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវហាមឃាត់ ក្នុងករណីគ្មានលិខិតអនុញ្ញាត ។

បុគ្គលដែលទទួលបានលិខិតអនុញ្ញាតក្នុងការប្រមូលផលជ័រឈើ ត្រូវមានលិខិតអនុញ្ញាតភ្ជាប់មកជាមួយ នៅពេលចូលទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ និងតម្រូវមានការត្រួតពិនិត្យពីមន្ត្រីក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

លិខិតអនុញ្ញាតក្នុងការប្រមូលផលជ័រឈើ អនុញ្ញាតដល់អ្នកប្រើប្រាស់ដែលកំណត់អត្តសញ្ញាណច្បាស់លាស់ ក្នុងការប្រមូលផលជ័រឈើនៅក្នុងតំបន់ជាក់លាក់នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ស្របតាមសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច ។

រូបវន្តបុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតប្រមូលផលជ័រឈើត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅអង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នៅក្នុងរយៈពេល ១ (មួយ) ខែ នៃការទទួលបានពាក្យស្នើសុំ ប្រមូលជ័រឈើក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានពិនិត្យ និងទទួលបានការសម្រេច នៅក្នុងករណីសមស្រប និងត្រូវចេញលិខិតអនុញ្ញាតដោយអង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

លិខិតអនុញ្ញាតត្រូវផ្តល់ជូនជាអាទិភាព ចំពោះសមាជិកនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលបានប្រមូលជ័រឈើរួចហើយ ជាផ្នែកមួយនៃជីវភាពរស់នៅរបស់ខ្លួន នៅមុនពេលក្រមនេះចូលជាធរមាន ។

មិនផ្តល់ជូនលិខិតអនុញ្ញាតប្រមូលផលជ័រឈើដល់បុគ្គល ដែលបានធ្វើសកម្មភាពខុសច្បាប់ មិន រាងចាល ពាក់ព័ន្ធធនធានធម្មជាតិនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

មិនផ្តល់ជូនលិខិតអនុញ្ញាត ប្រមូលផលជ័រឈើចំពោះបុគ្គល ដែលអង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានហេតុផលសមរម្យក្នុងការជឿជាក់ ឬមានភស្តុតាងដើម្បីបញ្ជាក់ថាបុគ្គលនោះបានចូលរួម ឬមានការពាក់ព័ន្ធជាមួយនឹងបទល្មើសធនធានធម្មជាតិដោយមិនរាងចាល ។

ការផ្ទេរលិខិតអនុញ្ញាតក្នុងការប្រមូលផលជ័រឈើពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតត្រូវហាមឃាត់ ។

លិខិតអនុញ្ញាតប្រមូលផលជ័រឈើមានសុពលភាពរយៈពេល១ (មួយ)ឆ្នាំ បន្ទាប់មកលិខិតអនុញ្ញាតនេះ ត្រូវធ្វើការពិនិត្យឡើងវិញ និងបន្តជាថ្មីជារៀងរាល់ឆ្នាំ ដោយអង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីបាត់លិខិតអនុញ្ញាតប្រមូលផលជ័រឈើ អ្នកកាន់កាប់លិខិតអនុញ្ញាតនោះត្រូវជូនដំណឹងដល់អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ប្រសិនបើសមរម្យ ត្រូវផ្អាក ឬបញ្ឈប់រាល់សកម្មភាពប្រមូលផលជ័រឈើ រហូតដល់មានលិខិតអនុញ្ញាតជាថ្មី ។

អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចផ្អាក ឬមោឃភាពលិខិតអនុញ្ញាតប្រមូលផលជ័រឈើ ដែលត្រូវកត់ត្រាទុកជាលាយលក្ខណ៍អក្សរ ដោយមានមូលហេតុត្រឹមត្រូវ ។

**មាត្រា៣៣៧** ._ ទេសចរណ៍ធម្មជាតិមានលក្ខណៈពាណិជ្ជកម្ម

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍មូលដ្ឋាន ដែលប្រតិបត្តិការទេសចរណ៍ធម្មជាតិជាលក្ខណៈពាណិជ្ជកម្ម ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានកិច្ចព្រមព្រៀង ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិបន្ទាប់ពីបានសម្រេចឯកភាព ។

នៅពេលពិចារណាអំពីសំណើសុំប្រតិបត្តិការទេសចរណ៍ធម្មជាតិជាលក្ខណៈពាណិជ្ជកម្ម ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

## ជំពូកទី៨
## ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃនៃការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

**មាត្រា៣៣៨** ._ ការត្រួតពិនិត្យលើផែនការគ្រប់គ្រង

ការត្រួតពិនិត្យលើផែនការគ្រប់គ្រង ប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានសូចនាករសម្រាប់ការសម្រេចបាននូវគោលបំណងអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះ តម្លៃប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅដោយចីរភាព ។ របាយការណ៍ស្ដីពីវឌ្ឍនភាពនៃការសម្រេចបាននូវសូចនាករទាំងនេះ ត្រូវផ្សព្វផ្សាយជូនសាធារណជន ។

**មាត្រា៣៣៩ .**_ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការពង្រឹងការអនុវត្តច្បាប់

ប្រព័ន្ធតំបន់ការពារធម្មជាតិត្រូវដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់គ្រប់គ្រង និងតាមដានត្រួតពិនិត្យលើការពង្រឹងការអនុវត្តច្បាប់ និងការល្បាត ។ ទិន្នន័យបែបនេះនឹងដាក់ឱ្យសាធារណជនស្វែងរកបាន ។

## មាតិកាទី៣
## ការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ
## ជំពូកទី១
## ការបង្កើតក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

**មាត្រា៣៤០ .**_ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះតំបន់ទាំងឡាយ ដែលអាចទទួលបានការអនុវត្តតាមការគ្រប់គ្រងរួមគ្នា ។ ប្រព័ន្ធតំបន់ការពារធម្មជាតិ សហគមន៍តំបន់ការពារធម្មជាតិ សមាគមព្រៃឈើ សហគមន៍នេសាទ និងសហគមន៍នានាដែលបានដាក់ពាក្យស្នើសុំការកំណត់ជាសហគមន៍ព្រៃឈើពីមុនរួចហើយ ឬដែលបានត្រៀមឯកសារបំណងនឹងដាក់ពាក្យស្នើសុំការកំណត់ជាសហគមន៍ព្រៃឈើ ដីបម្រុងទុករបស់ជនជាតិដើមភាគតិច ឬដីជាលក្ខណៈប្រពៃណីដទៃទៀត លើដីសាធារណៈរបស់រដ្ឋ ដែលមានតម្លៃអភិរក្ស និងតម្លៃប្រព័ន្ធអេកូឡូស៊ី ត្រូវមានសិទ្ធិទទួលបានការគ្រប់គ្រងស្របតាមគោលការណ៍នៃការគ្រប់គ្រងរួមគ្នាដូចមានចែងក្នុងមាតិកានេះ ។

**មាត្រា៣៤១ .**_ គោលការណ៍

ការគ្រប់គ្រងរួមគ្នា ជាវិធាននៃការគ្រប់គ្រងធនធានធម្មជាតិ និងធនធានដី ក៏ដូចជាការអភិវឌ្ឍជីវភាពរស់នៅ ដែលក្នុងនោះរដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានត្រូវបែងចែកតួនាទី ភារកិច្ច និងការទទួលខុសត្រូវក្នុងកិច្ចការពារ អភិរក្ស គ្រប់គ្រង ស្តារឡើងវិញ និងការប្រើប្រាស់ធនធានធម្មជាតិ និងជីវៈចម្រុះដោយនិរន្តរភាព ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា៣៤២**.‗ ការបន្តយន្តការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍

តំបន់គ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ មានជាអាទិ៍ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទដែលមានស្រាប់ ឬកំពុងដំណើរការរៀបចំពេល ក្រមនេះចូលជាធរមាន សហគមន៍ទាំងនោះ នៅតែមានសុពលភាពស្របតាមច្បាប់ដែលមានជាធរមាន ។

នៅពេលមានការដាក់បញ្ចូលគ្នា ឬការប្តូរពីសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទទៅជាតំបន់គ្រប់គ្រងរួមគ្នា ពេលនោះតំបន់គ្រប់គ្រងរួមគ្នានេះ ត្រូវបានទទួលស្គាល់ដោយស្វ័យប្រវត្តិតាមរយៈលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នាដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី២
## ការអនុវត្តក្របខ័ណ្ឌនៃការគ្រប់គ្រងរួមគ្នា

**មាត្រា៣៤៣**.‗ សិទ្ធិក្នុងការគ្រប់គ្រងរួមគ្នា

សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច រួមទាំងអ្នកពាក់ព័ន្ធ ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ មានសិទ្ធិរៀបចំ និងធ្វើការគ្រប់គ្រងរួមគ្នាលើតំបន់ដែលត្រូវធ្វើការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៤៤**.‗ ការរៀបចំការគ្រប់គ្រងរួមគ្នា

ក្នុងដំណើរការរៀបចំការគ្រប់គ្រងរួមគ្នា តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ លក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ដែលក្នុងនោះរួមមាន ការរៀបចំផែនការប្រើប្រាស់ដីតាមតំបន់ និងការកំណត់តំបន់គ្រប់គ្រងរួមគ្នា លក្ខខណ្ឌតម្រូវនៃភាពស្របច្បាប់របស់សហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា និងលក្ខខណ្ឌតម្រូវដទៃទៀតស្តីពីការគ្រប់គ្រងរួមគ្នា ។

ការរៀបចំការគ្រប់គ្រងរួមគ្នា ត្រូវចែងអំពី ៖

១- រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងរួមគ្នា ។

២- សមាជិកភាព និងសិទ្ធិក្នុងការបោះឆ្នោតរបស់គ្រប់សមាជិកតំបន់គ្រប់គ្រងរួមគ្នា ដោយយកចិត្តទុកដាក់ដល់ទំនាក់ទំនង និងការប្រើប្រាស់ធនធានធម្មជាតិ និងប្រពៃណីប្រើប្រាស់ដីរបស់ជនជាតិដើមភាគតិច ។

៣- ការរៀបចំផែនការប្រើប្រាស់ដី ការកំណត់តំបន់គ្រប់គ្រងសម្រាប់តំបន់គ្រប់គ្រងរួមគ្នា និង ផែនការគ្រប់គ្រងរួមគ្នា ។ រាល់ការរៀបចំផែនការប្រើប្រាស់ដី ការកំណត់សហគមន៍គ្រប់គ្រង និងការរៀបចំផែនការគ្រប់គ្រងរួមគ្នា ត្រូវធ្វើឡើង ស្របតាមផែនការប្រើប្រាស់ដី ការកំណត់តំបន់គ្រប់គ្រង និងការរៀបចំផែនការគ្រប់គ្រង ដូចមានចែងក្នុងក្រមនេះ ។

៤- ការរៀបចំផែនការគ្រប់គ្រងរួមគ្នា ត្រូវមានបមាណីយមួយ ស្របតាមធនធាន និងសមត្ថភាពរបស់សហគមន៍មូលដ្ឋាន ដែលឆ្លុះបញ្ចាំងពីចំណេះដឹង និងទស្សនវិស័យនៃសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអ្នកទទួលខុសត្រូវបឋមក្នុងការអនុវត្តការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៤៥**._ ការគាំទ្រទៅលើការគ្រប់គ្រងរួមគ្នា

ក្នុងដំណើរការរៀបចំការគ្រប់គ្រងរួមគ្នា តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចូលរួមសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវគាំទ្រដល់ការរៀបចំលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។

តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងអាជ្ញាធរមូលដ្ឋាន អាចទទួលយកយោបល់បច្ចេកទេសពីដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ដើម្បីរៀបចំលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៤៦**._ ការពិនិត្យឡើងវិញលើការរៀបចំការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវពិនិត្យឡើងវិញលើការរៀបចំ ការគ្រប់គ្រងរួមគ្នាស្របតាមលក្ខណៈវិនិច្ឆ័យ និងនីតិវិធីជាក់លាក់ ហើយត្រូវធ្វើការឆ្លើយតបទៅកាន់ អ្នកស្នើសុំក្នុងរយៈពេល ៣ (បី) ខែ បន្ទាប់ពីបានទទួលសំណើ ។ ក្របខ័ណ្ឌសម្រាប់ការឆ្លើយតបមានដូចតទៅ ៖

១- ការសម្រេចដំបូងលើការអនុវត្តនៃការគ្រប់គ្រងរួមគ្នានៅក្នុងតំបន់ដែលបានស្នើសុំ ។

២- ការសម្រេចដំបូងលើការអនុវត្ត នៃការគ្រប់គ្រងរួមគ្នាក្នុងតំបន់ដែលបានស្នើសុំ បន្ទាប់ពីបានផ្តល់មតិរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិទៅលើការរៀបចំការគ្រប់គ្រងរួមគ្នា ។

៣- សេចក្តីណែនាំដល់អ្នកស្នើសុំឱ្យធ្វើការកែប្រែសម្រាប់ការលើកសំណើជាថ្មី ។

ក្នុងករណីត្រូវលើកសំណើជាថ្មីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវពិនិត្យឡើងវិញ លើការរៀបចំការគ្រប់គ្រងរួមគ្នាដែលបានកែប្រែ ក្នុងរយៈពេល ៣ (បី) ខែ បន្ទាប់ពីបានទទួលសំណើ ។

ឯកសារអំពីការរៀបចំការគ្រប់គ្រងរួមគ្នា ត្រូវផ្សព្វផ្សាយឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣៤៧** ._ កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា

បន្ទាប់ពីមានការឯកភាពទៅលើការរៀបចំការគ្រប់គ្រងរួមគ្នា គណៈកម្មការគ្រប់គ្រងរួមគ្នា ត្រូវចុះកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នាជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និង/ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ។ កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ត្រូវមានចែងអំពីតួនាទី និងការទទួលខុសត្រូវច្បាស់លាស់របស់អ្នកពាក់ព័ន្ធទៅនឹងតំបន់គ្រប់គ្រងរួមគ្នាដែលបានទទួលការឯកភាពនោះ ។

កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ដែលត្រូវអនុវត្តទៅតាមលក្ខខណ្ឌ ដូចបានកំណត់ក្នុងក្រមនេះ ។

ឯកសារពាក់ព័ន្ធទៅនឹងការឯកភាពលើការរៀបចំនានាពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា អាចធ្វើការផ្សព្វផ្សាយដល់សាធារណជន ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣៤៨** ._ ការទទួលស្គាល់ស្របច្បាប់លើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា

ការឯកភាពលើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា បង្កើតបានជាការទទួលស្គាល់តាមផ្លូវច្បាប់សម្រាប់តំបន់គ្រប់គ្រងរួមគ្នា ។ តំបន់គ្រប់គ្រងរួមគ្នា រក្សាបាននូវភាពស្របច្បាប់ ដែលអាស្រ័យទៅតាមការអនុវត្តតួនាទីគ្រប់គ្រងរួមគ្នា ។

គណៈកម្មការគ្រប់គ្រងរួមគ្នា មានសិទ្ធិ និងកាតព្វកិច្ច ជាអាទិ៍ សិទ្ធិក្នុងការគ្រប់គ្រងថវិកា សិទ្ធិចុះកិច្ចព្រមព្រៀង ប្រតិបត្តិការ និងសិទ្ធិបង្កើតចំណូល រួមទាំងសិទ្ធិនិងកាតព្វកិច្ចផ្សេងៗទៀត ដែលមានចែងក្នុងក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៣៤៩** ._ បទប្បញ្ញត្តិអនុវត្តលើការគ្រប់គ្រងរួមគ្នា

ការអនុវត្តទៅលើការគ្រប់គ្រងរួមគ្នា ត្រូវស្ថិតនៅក្រោមការតាមដាន ត្រួតពិនិត្យ ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ គណៈកម្មការគ្រប់គ្រងរួមគ្នា ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដែលពណ៌នាអំពីសកម្មភាព លទ្ធផល និងសមិទ្ធផលដែលសម្រេចបាននៃគោលដៅ និងសូចនាករ មកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៣៥០** ._ ការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិក្នុងការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា និងគណៈកម្មការគ្រប់គ្រងរួមគ្នាបន្ទាប់ពីបានកំណត់ថាការ គ្រប់គ្រងរួមគ្នា មិនត្រូវបានអនុវត្តស្របតាមផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ហើយការមិនអនុលោមតាមបែបនោះ នាំឱ្យមានការបំពានលក្ខខណ្ឌនៃផែនការគ្រប់គ្រងរួមគ្នា ឬមានការបំពានច្បាប់ធ្ងន់ធ្ងរបានកើតឡើងក្នុងពេលអនុវត្ត ។

នៅមុនពេលបញ្ចប់កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ភាគីពាក់ព័ន្ធត្រូវជួបគ្នាដោះស្រាយបញ្ហាដោយស្មារតីស្មោះត្រង់ និងសុចរិត ។ គណៈកម្មការគ្រប់គ្រងរួមគ្នា ត្រូវមានសិទ្ធិតវ៉ាទៅនឹងសេចក្តីសម្រេចបញ្ចប់កិច្ចព្រមព្រៀង ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣៥១** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា មានជាអាទិ៍ តួនាទី សិទ្ធិ ការទទួលខុសត្រូវ លក្ខខណ្ឌជ្រើសរើស នីតិវិធីនៃការពិនិត្យឡើងវិញទៅលើការរៀបចំការគ្រប់គ្រងរួមគ្នា និងនីតិវិធីនៃការកំណត់តំបន់គ្រប់គ្រងរួមគ្នា ។

**មាត្រា៣៥២**._ ការលើកកម្ពស់ និងការគាំទ្រដល់ការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវលើកកម្ពស់ និងគាំទ្រដំណើរការអនុវត្តការគ្រប់គ្រងរួមគ្នាក្នុងតំបន់គ្រប់គ្រងរួមគ្នា ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា៣៥៣**._ សកម្មភាពដែលបានហាមឃាត់

ហាមដាច់ខាតមិនឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលប្រព្រឹត្តផ្ទុយនឹងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នាដែលបានព្រមព្រៀងគ្នា និងការទទួលខុសត្រូវ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនោះ ។

## ជំពូកទី៣
## រយៈពេលនៃការគ្រប់គ្រងរួមគ្នា និងសិទ្ធិលើដីធ្លី

**មាត្រា៣៥៤**._ អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា

ក្រោយពេលទទួលបានការឯកភាពលើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា គណៈកម្មការគ្រប់គ្រងរួមគ្នា មានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើដីរដ្ឋនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ។

អាណត្តិនៃការកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើដីរដ្ឋនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា មិនត្រូវរារាំងសិទ្ធិរបស់មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មិនឱ្យចូល និងអនុវត្តការងាររបស់ខ្លួន នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ។

គណៈកម្មការគ្រប់គ្រងរួមគ្នា ពុំមានសិទ្ធិក្នុងការលក់ ផ្ទេរសិទ្ធិនៃការកាន់កាប់ ប្រើប្រាស់ អាស្រ័យផលលើដីរដ្ឋនេះទៅឱ្យតតិយជន ឬនីតិបុគ្គលណាមួយឡើយ ប៉ុន្តែគណៈកម្មការគ្រប់គ្រងរួមគ្នាមានសិទ្ធិក្នុងការផ្ទេរការកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលទៅឱ្យសមាជិកដទៃទៀត ដែលរស់នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៥៥**._ ខ្លឹមសារនៃអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា

អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា រួមមានសិទ្ធិរបស់សហគមន៍នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ក្នុងការរស់នៅ អភិរក្ស គ្រប់គ្រង ប្រើប្រាស់ និងទទួលផលពីការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ស្របតាមលក្ខណៈប្រពៃណី នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា និងផែនការគ្រប់គ្រងរួមគ្នាដែលទទួលបានការឯកភាព ។

គណៈកម្មការគ្រប់គ្រងរួមគ្នា ដែលទទួលបានអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា មានសិទ្ធិក្នុងការហាមឃាត់បុគ្គលណាម្នាក់ មិនឱ្យធ្វើសកម្មភាពណាមួយ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីគណៈកម្មការគ្រប់គ្រងរួមគ្នា ដូចខាងក្រោម ៖

១- ចេញចូលតំបន់គ្រប់គ្រងរួមគ្នា ។

២- ធ្វើសកម្មភាពពាណិជ្ជកម្មនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ។

៣- ឬប្រើប្រាស់ធនធាននៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ចំពោះបុគ្គលដែលមិនមែនជាសមាជិកសហគមន៍គ្រប់គ្រងរួមគ្នា ។

សំណើស្នើសុំចេញចូល និងប្រើប្រាស់ធនធាននៅក្នុងតំបន់គ្រប់គ្រងរួមគ្នារបស់អ្នកក្រៅ ដែលមិនមែនជាសមាជិកសហគមន៍គ្រប់គ្រងរួមគ្នា ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្ដីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាននៃក្រមនេះ ។

**មាត្រា៣៥៦** ._ រយៈពេលនៃអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា

រយៈពេលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា មានសុពលភាពដូចគ្នាទៅនឹងរយៈពេលនៃតំបន់គ្រប់គ្រងរួមគ្នា ។

**មាត្រា៣៥៧** ._ ការលុបចោលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា

ការលុបចោលកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា ឬតំបន់គ្រប់គ្រងរួមគ្នា នាំឱ្យមានការលុបចោលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា ។

ប៉ុន្តែក្នុងករណីដែលភាគីណាមួយដែលមិនមែនជាសហគមន៍ មិនគោរពតាមផែនការគ្រប់គ្រងរួមគ្នា និងវិធាន និងបទប្បញ្ញត្តិផ្សេងទៀតស្ដីពីការគ្រប់គ្រងរួមគ្នា ឬកិច្ចព្រមព្រៀងស្ដីពីការគ្រប់គ្រងរួមគ្នា មិននាំឱ្យមានការលុបចោលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នានោះទេ ។

**មាត្រា៣៥៨** ._ សិទ្ធិបន្ថែមលើអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា

អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា ត្រូវជាសិទ្ធិបន្ថែមលើសិទ្ធិដទៃទៀតដែលសហគមន៍ជនជាតិដើមភាគតិចទទួលបាន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា៣៥៩ ._** សិទ្ធិប្រើប្រាស់ដីសម្ហូហភាពក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

បន្ទាប់ពីបានកំណត់ជាតំបន់គ្រប់គ្រងរួមគ្នា ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ សហគមន៍ទាំងឡាយ ដែលមានទីតាំងនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា អាចមានសិទ្ធិប្រើប្រាស់ដីសមូហភាព ក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា តាមរយៈពេលដែលបានកំណត់សម្រាប់តំបន់គ្រប់គ្រងរួមគ្នា ។

ទោះបីមានលក្ខខណ្ឌតម្រូវ ឬការចុះបញ្ជីបន្ថែមណាមួយត្រូវធ្វើឡើងក្តី សិទ្ធិប្រើប្រាស់ដី ក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា មិនអាចបំពានបានឡើយ ។

**មាត្រា៣៦០ ._** សិទ្ធិ និងការដាក់កំហិតលើសិទ្ធិប្រើប្រាស់ដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

សិទ្ធិប្រើប្រាស់ដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា មានជាអាទិ៍ សិទ្ធិស្នាក់នៅ សិទ្ធិអភិរក្ស សិទ្ធិគ្រប់គ្រង របស់សហគមន៍នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា និងសិទ្ធិក្នុងការទទួលប្រយោជន៍ពីការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាពស្របតាមសិទ្ធិដីធ្លីជាលក្ខណៈប្រពៃណី និងទំនៀមទម្លាប់នៃការប្រកបរបរចិញ្ចឹមជីវិតតាមបែបប្រពៃណី នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា និងសិទ្ធិក្នុងការហាមឃាត់ ឬដាក់កំហិតលើសិទ្ធិប្រើប្រាស់តំបន់ របស់មនុស្សពីក្រៅតំបន់ ស្របតាមផែនការគ្រប់គ្រងរួមគ្នាដែលបានទទួលការអនុម័ត ។

សិទ្ធិប្រើប្រាស់ដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា មិនមែនជាសិទ្ធិក្នុងការលក់ ឬផ្ទេរកម្មសិទ្ធិទៅលើដីទាំងឡាយដែលត្រូវបានកំណត់ចូលទៅក្នុងតំបន់គ្រប់គ្រងរួមគ្នានោះទេ ។

**មាត្រា៣៦១ ._** រយៈពេលនៃសិទ្ធិប្រើប្រាស់ដី

រយៈពេលនៃសិទ្ធិប្រើប្រាស់ដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ត្រូវកំណត់តាមរយៈពេលនៃតំបន់គ្រប់គ្រងរួមគ្នា ដូចមានចែងក្នុងកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៦២ ._** ការដកហូតសិទ្ធិប្រើប្រាស់ដី

សិទ្ធិប្រើប្រាស់ដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ត្រូវដកហូតពីសហគមន៍ទាំងឡាយណាដែលមិនបានបំពេញតាមផែនការគ្រប់គ្រងរួមគ្នា វិធាន និងបទប្បញ្ញត្តិដទៃទៀតនៃការគ្រប់គ្រងរួមគ្នា ប៉ុន្តែការមិនបានអនុលោមតាមផែនការគ្រប់គ្រងរួមគ្នា  វិធាន និងបទប្បញ្ញត្តិដទៃទៀតនៃការគ្រប់គ្រងរួមគ្នារបស់ភាគីណាមួយ ក្រៅពីសហគមន៍ ដូចជាការមិនបានអនុលោមតាម ដែលនាំឱ្យមានការបញ្ចប់កិច្ចព្រម

ព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ស្របតាមក្រមនេះ មិនត្រូវនាំឱ្យមានការដកហូតនូវសិទ្ធិប្រើប្រាស់ដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នារបស់សហគមន៍នោះទេ ។

សិទ្ធិប្រើប្រាស់ដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នានេះ មិនអាចផ្ទេរទៅឱ្យបុគ្គលណាមួយ ឬសហគមន៍ណាផ្សេងឡើយ ។

**មាត្រា៣៦៣** ._ សិទ្ធិបន្ថែមលើសិទ្ធិប្រើប្រាស់ដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

សិទ្ធិប្រើប្រាស់ដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ជាសិទ្ធិបន្ថែមទៅលើសិទ្ធិដទៃទៀតរបស់សហគមន៍ជនជាតិដើមភាគតិចដែលអាចទទួលបាន ដូចជា សិទ្ធិនានា ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា៣៦៤** ._ ផលប៉ះពាល់លើការកំណត់តំបន់ការពារធម្មជាតិ

ការបង្កើតប្រព័ន្ធតំបន់ការពារធម្មជាតិ នាពេលបច្ចុប្បន្ន ឬអនាគត នៅតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឬមានការពាក់ព័ន្ធបែបសម្ងហភាព ឬប្រយោជន៍សម្ងហភាព មិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិដីធ្លីនាបច្ចុប្បន្ន ឬអនាគតរបស់ជនជាតិដើមភាគតិចដែល ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## មាតិកាទី៤
## ការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តរភាព
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៣៦៥** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តលើធនធានព្រៃឈើ ដែលគ្រប់គ្រងដោយនិរន្តរភាព ដែលត្រូវបានកំណត់នៅក្នុងតំបន់ព្រៃឈើដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ជាដែនព្រៃឈើដែលមានទីតាំងនៅក្នុង និងក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ។

**មាត្រា៣៦៦ ._** គោលដៅ

មាតិកានេះ មានគោលដៅកំណត់ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តរភាព រួមមាន ការគ្រប់គ្រង ការប្រមូលផល ការអភិវឌ្ឍ ការប្រើប្រាស់ និងការអភិរក្សតំបន់ព្រៃឈើ ដើម្បីថែរក្សា និងជំរុញឱ្យសម្រេចបានផ្នែកសេដ្ឋកិច្ចរយៈពេលយូរអង្វែង និងផលប្រយោជន៍សង្គម រួមមាន សុខុមាលភាពរបស់ប្រជាពលរដ្ឋ គុណភាពបរិស្ថាន ទិន្នផល និងទីផ្សារដោយនិរន្តរភាព ។

**មាត្រា៣៦៧ ._** គោលបំណង

ការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តរភាព ត្រូវគ្រប់គ្រងស្របតាមគោលបំណង និងគោលការណ៍ ដែលមានចែងក្នុងក្រមនេះ និងគោលបំណងជាក់លាក់ ដូចខាងក្រោម ៖

១- បម្រុងទុកសម្រាប់ផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន ។

២- អភិរក្ស លើកស្ទួយ និងស្តារតម្លៃជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ។

៣- ធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅក្នុងតំបន់សហគមន៍មូលដ្ឋាន និងបេតិកភណ្ឌវប្បធម៌ ។

៤- លើកកម្ពស់ការអភិវឌ្ឍដោយនិរន្តរភាព ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៣៦៨ ._** តួនាទី និងភារកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចទាក់ទងនឹងការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តរភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវ ៖

១- គ្រប់គ្រង ការពារ អភិរក្ស ត្រួតពិនិត្យ ស្តារឡើងវិញ និងអនុវត្តការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព ដែលរួមមានការរៀបចំផែនការ ការផ្តល់លិខិតអនុញ្ញាត ការគ្រប់គ្រង និងការត្រួតពិនិត្យគោលការណ៍បច្ចេកទេសព្រៃឈើដោយនិរន្តរភាព ។

២- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីសម្រាប់ពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធភាព ។

៣- សិក្សា និងប្រមូលទិន្នន័យព្រៃឈើទាក់ទងនឹងគោលដៅវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីបង្កើតម៉ាទ្រីក និងបមាណីយ និងបង្កើតផែនការគ្រប់គ្រងសម្រាប់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

៤- ធានានូវការវាយតម្លៃពេញលេញ និងទាន់ពេលវេលាសម្រាប់ធនធានព្រៃឈើទាំងអស់ និងការអភិវឌ្ឍផ្សេងៗទាក់ទងទៅនឹងសកម្មភាពដែលអាចមានផលប៉ះពាល់សង្គម និងបរិស្ថាន មុននឹងឯកភាពទៅលើសកម្មភាពទាំងនោះ ។

៥- រៀបចំសំណើសម្រាប់ការបង្កើត ការផ្លាស់ប្តូរ និងការរំសាយ ក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពស្របទៅនឹងអនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងអន្តរជាតិនានា និងលិខិតបទដ្ឋានគតិយុត្ត ។

៦- លើកកម្ពស់ការអប់រំ និងការផ្សព្វផ្សាយព័ត៌មានទៅកាន់សាធារណជន ដើម្បីបង្ហាញពីសារៈសំខាន់នៃការគ្រប់គ្រង ការថែរក្សា និងការការពារធនធានព្រៃឈើ ក៏ដូចជាដើម្បីលើកទឹក ចិត្តឱ្យមានការចូលរួមក្នុងការអភិរក្ស និងការការពារធនធានធម្មជាតិក្នុងតំបន់ព្រៃឈើដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព ។

៧- ស្តារនូវប្រព័ន្ធអេកូឡូស៊ីដីព្រៃរេចរឹល និងដាំឈើឡើងវិញ ដើម្បីលើកកម្ពស់ និងសម្រេចបាននូវការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ ដោយរួមបញ្ចូលនូវតួនាទីនៃការអភិរក្ស គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងការបង្កើនសន្និធិកាបូនក្នុងវិស័យព្រៃឈើ និងទិសដៅអភិរក្សដទៃទៀត ដោយពិចារណាអំពីលក្ខណៈវិនិច្ឆ័យ ដូចជាការវាយតម្លៃធនធានគម្របព្រៃឈើ និងការវាយតម្លៃការប្រែប្រួលការប្រើប្រាស់ដីព្រៃឈើ ស្របតាមនិយមន័យព្រៃឈើ ។

៨- កំណត់ន័យច្បាស់លាស់ នៃស្ថានភាពស្របច្បាប់នៃដីទាំងអស់ដែលត្រូវបានចាត់ជាដីព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ដែលរួមមានសិទ្ធិកាន់កាប់ដីជាប្រពៃណីនិង សិទ្ធិប្រើប្រាស់ដែលមានស្រាប់ ។

៩- កំណត់ព្រំប្រទល់ដែនព្រៃឈើ និងចុះបញ្ជិកាដីព្រៃឈើ វិភាគ និងរក្សាទុកទិន្នន័យ និងធ្វើបច្ចុប្បន្នភាពទិន្នន័យ ដើម្បីរៀបចំគោលការណ៍ណែនាំ សម្រាប់ប្រើប្រាស់ ដើម្បីធ្វើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

១០- បង្កើត និងអនុវត្តវិធានការ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ដើម្បីការពារព្រៃឈើជាលក្ខណៈប្រព័ន្ធ ពីការប្រើប្រាស់ធនធានដែលគ្មានការអនុញ្ញាត ឬមិនស្របច្បាប់ ការតាំងទីលំនៅនិងសកម្មភាពមិនស្របច្បាប់ដទៃទៀត ។

១១- ធ្វើការពិគ្រោះយោបល់លើគម្រោងស្ថាបនាផ្លូវសាធារណៈ និងផ្លូវព្រៃ នៅក្នុងតំបន់ព្រៃឈើ ។

១២- ផ្សព្វផ្សាយជាសាធារណៈ និងអនុវត្តតម្លាភាពពេញលេញនៅគ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

១៣- ចូលរួមនៅក្នុងកម្មវិធីផ្តល់វិញ្ញាបនបត្រគ្រប់គ្រង និងផលិតផលព្រៃឈើអន្តរជាតិ ។

១៤- ធ្វើឱ្យប្រសើរឡើងនូវការពង្រឹងការអនុវត្ត តាមរយៈការសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

១៥- ធ្វើការអង្កេតតាមដាន ទប់ស្កាត់ បង្ក្រាប និងរៀបចំរបាយការណ៍បទល្មើស ។

១៦- អភិវឌ្ឍសមត្ថភាពនៃការឆ្លើយតបជាបន្ទាន់ និងចាត់វិធានការទាន់ពេលវេលាបន្ទាប់ពីទទួលបានព័ត៌មានអំពីបទល្មើសព្រៃឈើ ។

១៧- ពង្រាយនូវសមត្ថភាពរហ័សទាក់ទងនឹងព័ត៌មានបទល្មើសព្រៃឈើ ។

១៨- និងទាក់ទងជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចនៅគ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

**មាត្រា៣៦៩**._ ភារកិច្ចក្នុងការអភិរក្ស និងស្តារព្រៃឈើឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឱ្យប្រសើរឡើងវិញនូវកិច្ចគាំពារ  ការអភិរក្ស និងការស្តារឡើងវិញនូវតម្លៃបរិស្ថានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលស្ថិតក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព និងត្រូវចៀសវាងការជួសជុល និងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានចំពោះ ៖

១- ព្រៃឈើដែលមានផលប៉ះពាល់តំបន់ទីជម្រាល ។

២- គុណភាពបរិស្ថាននៃដី ទឹក និងខ្យល់ ។

៣- គុណភាពអេកូឡូស៊ី និងប្រព័ន្ធអេកូឡូស៊ី ។

៨- សមត្ថភាពរស់រានរបស់សត្វ និងរុក្ខជាតិព្រៃ ជាពិសេសប្រភេទសត្វ និងរុក្ខជាតិព្រៃកម្រ ឬប្រភេទសត្វ និងរុក្ខជាតិព្រៃ តាមតំបន់ជាក់លាក់ ។

**មាត្រា៣៧០**._ ភារកិច្ចផ្សេងទៀត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានា ៖

១- ផលិតផលត្រូវបានប្រមូលនៅកម្រិត ឬក្រោមកម្រិតដែលអាចមាននិរន្តរភាព ។

២- ការកែច្នៃ សេវា និងតម្លៃបន្ថែមត្រូវបានប្រើប្រាស់ នៅកន្លែងដែលអាចធ្វើទៅបាន ។

៣- ការចូលរួមក្នុងកម្មវិធីផលិតផលព្រៃឈើអន្តរជាតិ និងវិញ្ញាបនបត្រគ្រប់គ្រងព្រៃឈើដោយមានការគាំទ្រពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

៤- ការអនុវត្តនីតិវិធីរក្សាភស្តុតាង ត្រូវបានអនុវត្តសម្រាប់ផលិតផលដែលមិនត្រូវបានប្រើប្រាស់ក្នុងស្រុក ។

## ជំពូកទី៣
## ការធ្វើចំណាត់ថ្នាក់ព្រៃឈើដោយនិរន្តរភាព

**មាត្រា៣៧១**._ ការធ្វើចំណាត់ថ្នាក់ព្រៃឈើ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់អត្តសញ្ញាណ ធ្វើចំណាត់ថ្នាក់ និងធ្វើផែនទីព្រៃឈើ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

ការធ្វើចំណាត់ថ្នាក់ត្រូវផ្អែកលើ ទិន្នន័យ បច្ចុប្បន្នភាពផែនទី ការវាយតម្លៃវិទ្យាសាស្ត្រ ត្រូវផ្អែកលើ ៖

១- មុខងារអេកូឡូស៊ីព្រៃឈើ សេដ្ឋកិច្ច និងសង្គម ។

២- ភាពសម្បូរបែបនៃព្រៃឈើ ដែលកំណត់ដោយរចនាសម្ព័ន្ធសារពន្ធរុក្ខជាតិព្រៃ ។

៣- មុខងារ និងសារៈសំខាន់នៃតំបន់ ។

៤- តំបន់សក្តានុពលសន្និធិកាបូនព្រៃឈើ និងទិសដៅកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការកាប់បំផ្លាញព្រៃឈើ ការរេចរឹលព្រៃឈើ និងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ការអភិរក្ស ការធ្វើឱ្យប្រសើរឡើង សន្និធិកាបូនព្រៃឈើតាមរយៈរេដបូក ។

៥- តំបន់សក្តានុពលសម្រាប់រក្សាប្រភពទឹក និងទីជម្រាល ។

៦- ការពិគ្រោះយោបល់ជាមួយប្រជាសហគមន៍មូលដ្ឋាន ។

៧- លក្ខខណ្ឌពាក់ព័ន្ធផ្សេងទៀត ត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្ត ។

ការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តរភាព ត្រូវបានធ្វើចំណាត់ថ្នាក់ជាព្រៃឯកជន ព្រៃផ្តល់ផលដោយនិរន្តរភាព ព្រៃស្តារឡើងវិញ ព្រៃបម្រុងទុក និងសម្បទានដីសេដ្ឋកិច្ច ៖

១- ព្រៃឯកជន ៖ ជាប្រភេទដីព្រៃឈើទាំងឡាយ ដែលស្ថិតក្រោមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យដីឯកជន ។

២- ព្រៃផ្តល់ផលដោយនិរន្តរភាព ៖ ជាដីសាធារណៈរបស់រដ្ឋ មានជាអាទិ៍ ចម្ការព្រៃដាំ ចម្ការពូជ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ ព្រៃគុប ព្រៃសម្បទាន និងដីព្រៃទាំងឡាយ ដែលអាចធ្វើការដាំដុះព្រៃឈើបាន ។

៣- ព្រៃស្តារឡើងវិញ ៖ ជាដីសាធារណៈរបស់រដ្ឋ ជាដីព្រៃបាត់បង់ និងរេចរឹល ព្រៃឈើ និងដីដាំស្តារព្រៃឈើឡើងវិញដែលបង្កើតគម្របព្រៃឈើដោយធម្មជាតិ ឬសិប្បនិម្មិត ។

៤- ព្រៃបម្រុងទុក ៖ ជាដីសាធារណៈរបស់រដ្ឋទាំងឡាយណា ដែលការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ មានដូចជា ៖

- ព្រៃជម្រកជីវៈចម្រុះ
- ព្រៃសម្រាប់សិក្សា ស្រាវជ្រាវ
- ព្រៃការពារតំបន់ទីជម្រាល និងប្រភពទឹក
- សួនរុក្ខសាស្ត្រ
- ព្រៃកីឡាប្រមាញ់
- ព្រៃជំនឿសាសនា
- និងផ្ទៃដីព្រៃបម្រុងទុកសម្រាប់ការអភិរក្សនាពេលអនាគត ។

៥- សម្បទានដីសេដ្ឋកិច្ច ៖

សម្បទានដីសេដ្ឋកិច្ច មិនមែនជា ៖

- ដីដែលស្ថិតនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ

- រាល់ដីសាធារណៈរបស់រដ្ឋ ដែលមានតម្លៃ ការពារ និងអភិរក្ស ឬតម្លៃប្រព័ន្ធអេកូឡូស៊ីរួចហើយ

- ដីបម្រុងទុករបស់ជនជាតិដើមភាគតិចជាលក្ខណៈប្រពៃណីដទៃទៀត ឬដីរបស់ជនជាតិដើមភាគតិច ។

ប្រភេទដីខាងលើនេះ មិនត្រូវបានធ្វើចំណាត់ថ្នាក់ ស្របតាមក្រមនេះ ឬត្រូវបានរាប់បញ្ចូលទៅក្នុងផែនការប្រើប្រាស់ដីធ្លី នៃព្រៃឈើដែលត្រូវបានគ្រប់គ្រងដោយនិរន្តរភាពឡើយ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចបង្កើតចំណាត់ថ្នាក់ព្រៃឈើបន្ថែមសម្រាប់ព្រៃដែល ត្រូវបានគ្រប់គ្រងដោយនិរន្តរភាពមានជាអាទិ៍ ព្រៃលំហែកម្សាន្ត ព្រៃសហគមន៍ផ្តល់ផល ព្រៃពិសោធន៍ និងព្រៃស្តារឡើងវិញ ។ ចំណាត់ថ្នាក់ព្រៃឈើបន្ថែម ត្រូវទទួលការវាយតម្លៃស្របតាមគោលការណ៍និរន្តរភាពសារៈសំខាន់ផ្នែកស្រាវជ្រាវ និងគោលដៅនៃផែនការគ្រប់គ្រង ។

**មាត្រា៣៧២**._ ការផលិតផែនទីសម្រាប់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

ការអនុវត្តសកម្មភាពគ្រប់គ្រងធនធានព្រៃឈើ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលបន្ទុករៀបចំផលិតផែនទីព្រៃឈើ ដូចខាងក្រោម ៖

១- ផែនទីតំបន់ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

២- ផែនទីវាយតម្លៃធនធានគម្របព្រៃឈើ និងប្រែប្រួលដីព្រៃឈើ ។

៣- ផែនទីចំណាត់ថ្នាក់ព្រៃឈើ ។

៤- ផែនទីវាយតម្លៃសន្និធិកាបូនព្រៃឈើ ។

៥- ផែនទីសារពើភណ្ឌព្រៃឈើ ។

៦- ផែនទីផ្ទៃរងទឹកភ្លៀង ទីជម្រាល និងចំណាត់ថ្នាក់ទីជម្រាល ។

៧- ផែនទីវត្តមាន ទីជម្រកសត្វព្រៃ និងជីវៈចម្រុះ ។

៨- ផែនទីចម្ការឈើដាំ និងឈើពូជ ។

៩- ផែនទីរោងសន្និធិ រោងចក្រច្នៃឈើ ។

១០- ផែនទីកសាងផ្លូវកាត់តំបន់ព្រៃឈើ និងផែនទីសក្តានុពលផ្សេងទៀត ។

**មាត្រា៣៧៣**._ ផែនទីប្រើប្រាស់ដីព្រៃឈើ និងការចុះបញ្ជិកា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលបន្ទុកដឹកនាំផលិតទិន្នន័យ និងផែនទីប្រើប្រាស់ដីព្រៃឈើសម្រាប់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដោយសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើ និង ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដោយមានកិច្ចពិគ្រោះយោបល់ជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវសិក្សាវាយតម្លៃ និងកំណត់ព្រំប្រទល់ដែនព្រៃឈើ ដើម្បីចុះបញ្ជិកាដីព្រៃឈើជាតិ ដោយយោងតាមការបែងចែកចំណាត់ថ្នាក់និងការផលិតផែនទីប្រើប្រាស់ដីព្រៃឈើ ។

ផែនទីប្រើប្រាស់ដីនេះ ត្រូវរៀបចំផលិតរួចរាល់មុននឹងផ្តល់ជូនលិខិតអនុញ្ញាត ផលិតកម្ម ឬការប្រើប្រាស់ដទៃទៀត នៅក្នុងតំបន់ព្រៃឈើ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣៧៤**._ ការគ្រប់គ្រងទិន្នន័យ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយរដ្ឋបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានដែលមានសមត្ថកិច្ច ដៃគូអភិវឌ្ឍន៍ ត្រូវបង្កើត ប្រមូល ចងក្រងព័ត៌មាន ទិន្នន័យមូលដ្ឋាន ធនធានព្រៃឈើ និងរក្សាទុកទិន្នន័យទាំងនេះដើម្បីរៀបចំផែនការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

**មាត្រា៣៧៥**._ ការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃឈើ

រាល់សំណើសុំធ្វើការកែប្រែ ចំណាត់ថ្នាក់ព្រៃឈើដែលត្រូវបានគ្រប់គ្រង ដោយនិរន្តរភាព ឬផ្នែកណាមួយ ត្រូវរៀបចំឯកសារ ដែលចែងលម្អិតដូចខាងក្រោម ៖

១- ហេតុផលវិទ្យាសាស្ត្រ និងសេដ្ឋកិច្ចសង្គម សម្រាប់ការកែប្រែចំណាត់ថ្នាក់ដែលត្រូវស្នើសុំ ។

២- កិច្ចប្រឹងប្រែងដែលធ្វើឡើងដើម្បីរក្សាស្ថានភាពនៃការធ្វើចំណាត់ថ្នាក់នាពេលថ្មីៗ ។

៣- លក្ខណៈនៃការកែប្រែ ចំណាត់ថ្នាក់ ត្រូវលើកស្ទួយជីវភាពរស់នៅ និងសិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន ។

៤- លទ្ធផលរំពឹងទុកនៃការកើនឡើងក្នុងតម្លៃអភិរក្ស និងប្រព័ន្ធអេកូឡូស៊ី ឬតាមមធ្យោបាយណាមួយដែលធ្វើឱ្យបាត់បង់តម្លៃអភិរក្ស និងប្រព័ន្ធអេកូឡូស៊ី ត្រូវធ្វើការទូទាត់សងមកវិញនូវតម្លៃខូចខាតទាំងនោះ ។

៥- ការពិគ្រោះយោបល់សមស្របជាមួយអ្នកពាក់ព័ន្ធណាមួយ និងសហគមន៍មូលដ្ឋាន ដែលរងផលប៉ះពាល់ រួមមានការយល់ព្រមជាមុនពីសហគមន៍នោះទៅលើការកែប្រែដែលបានស្នើឡើង ។

៦- ព័ត៌មានផ្សេងៗខាងលើ ត្រូវបានកែសម្រួល ឱ្យស្របទៅតាមសំណើសុំ ។

រាល់សំណើសុំកែប្រែ ការបែងចែកចំណាត់ថ្នាក់ព្រៃឈើ ដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព ឬផ្នែកណា ត្រូវស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

ការឯកភាពលើការកែសម្រួលចំណាត់ថ្នាក់ព្រៃឈើ ត្រូវទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

## ជំពូកទី៤
## ការរៀបចំផែនការប្រើប្រាស់ និងផែនការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

**មាត្រា៣៧៦**._ ការរៀបចំផែនការប្រើប្រាស់ និងផែនការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធដែល មានសមត្ថកិច្ចគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ត្រូវរៀបចំផែនការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាពរយៈពេល ៥ (ប្រាំ) ឆ្នាំ និងផែនការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពរយៈពេល ៥ (ប្រាំ) ឆ្នាំ ឬតាមការចាំបាច់ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំកិច្ចពិគ្រោះយោបល់ដោយឡែក និងពិសេសសម្រាប់តំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឬដែលមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍សម្ងហភាពរបស់ជនជាតិដើមភាគតិច ដើម្បីបញ្ជាក់ថាមានការឱ្យតម្លៃចំពោះផលប្រយោជន៍ និងសិទ្ធិជាលក្ខណៈប្រពៃណី និងទំនៀមទម្លាប់របស់ពួកគេ ។

សេចក្ដីលម្អិត និងដំណើរការសម្រាប់ការរៀបចំ និងអនុវត្តផែនការ គ្រប់គ្រងរួមគ្នាសម្រាប់តំបន់ព្រៃឈើនីមួយៗ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៣៧៧**._ ផែនការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាព

ផែនការប្រើប្រាស់ធនធានព្រៃឈើដោយនិរន្តរភាព ត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម ៖

១- ប្រភេទ បរិមាណនិងគុណភាពព្រៃឈើ ដោយផ្អែកលើទិន្នន័យសារពើភណ្ឌព្រៃឈើ ។

២- តម្លៃអេកូឡូស៊ីព្រៃឈើ ។

៣- ទីតាំងរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងតម្រូវការសម្រាប់ជីវភាពរស់នៅ ។

៤- ផ្នែកខាងក្រៅនៃប្រតិបត្តិការវិជ្ជមាន និងអវិជ្ជមាន ។

**មាត្រា៣៧៨** ._ ខ្លឹមសារនៃផែនការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាព

ផែនការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាព ត្រូវរួមមានកត្តាដូចខាងក្រោម ៖

១- ការគ្រប់គ្រងតំបន់សម្បទានដីសេដ្ឋកិច្ច ។

២- ការធ្វើរុក្ខវប្បកម្ម រួមមានការប្រមូលផលប្រចាំឆ្នាំដែលអនុញ្ញាតនៅក្នុងតំបន់គ្រប់គ្រងផ្សេងៗគ្នា ។

៣- ការដាំដើមឈើ ការដាំស្តារព្រៃឈើឡើងវិញ និងចម្ការឈើនៅក្នុងតំបន់ព្រៃរេចរឹល ។

៤- ការត្រួតពិនិត្យតាមដានព្រៃឈើ និងការពង្រឹងការអនុវត្តច្បាប់ ។

៥- ត្រូវមានការចូលរួមពីសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងព្រៃឈើ ។

**មាត្រា៣៧៩** ._ សម្បទានដីសេដ្ឋកិច្ច

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ច និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ត្រូវធានាថា រាល់សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ត្រូវបានគ្រប់គ្រង ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

បន្ថែមទៅលើការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ការគ្រប់គ្រងរាល់សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ដែលជាប់គ្នា ឬស្ថិតនៅក្នុងផ្នែកមួយនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវស្របតាមការចាត់ចែង និងការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធដែលទទួលខុសត្រូវទៅលើតំបន់ទាំងនោះ ស្របតាមគោលបំណងគ្រប់គ្រង និងការអភិរក្សទូលំទូលាយ ។

## ជំពូកទី៩
## លិខិតអនុញ្ញាត

**មាត្រា៣៨០ .**_ សកម្មភាពពាក់ព័ន្ធ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើឱ្យធ្វើសកម្មភាពណាមួយខាងក្រោមក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ច ៖

១- ផលិតផលដែលបានពីផល-អនុផលព្រៃឈើសម្រាប់ការប្រើប្រាស់ផ្នែកពាណិជ្ជកម្ម ។

២- ការគ្រប់គ្រងផល-អនុផលព្រៃឈើ សម្រាប់ការប្រើប្រាស់ផ្នែកពាណិជ្ជកម្ម ។

៣- ការប្រមូលផល និងលក់ផល-អនុផលព្រៃឈើ សម្រាប់គោលបំណងពាណិជ្ជកម្ម ស្របតាមកូតាប្រមូលផលប្រចាំឆ្នាំ ដែលត្រូវធ្វើការប្រាក់កក់ ដើម្បីធានានូវការបង់ថ្លៃប្រាក់កម្រៃ និងបុព្វលាភ ដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

៤- ការដឹកជញ្ជូនផល-អនុផលព្រៃឈើ ស្របតាមកូតាដឹកជញ្ជូនប្រចាំឆ្នាំ ដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

៥- ការនាំចេញផល-អនុផលព្រៃឈើ ស្របតាមកូតានាំចេញប្រចាំឆ្នាំ ដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

៦- ការប្រើប្រាស់ព្រៃឈើដើម្បី ស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ឬបច្ចេកទេស ដែលរួមមានការដកហូតសម្រាប់គោលបំណងស្រាវជ្រាវរុក្ខវប្បកម្ម ឬការធ្វើឱ្យប្រសើរឡើងវិស័យព្រៃឈើ ការអប់រំ ឬការបណ្តុះបណ្តាលកសិកម្ម គោលបំណងធារាសាស្ត្រ និងកសិកម្ម ដោយផ្អែកលើកិច្ចព្រមព្រៀងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក និងឧត្តុនិយម ការបង្កើត សួនរុក្ខជាតិព្រៃ ថ្នាលសម្រាប់ដំណុះពូជ ឬស្ថានីយ៍ពិសោធន៍ ឬដើម្បីបង្កើតការកម្សាន្តទេសចរណ៍ ធម្មជាតិ ឬការថតភាពយន្ត ឬភាពយន្តឯកសារ ។

៧- ការបង្កើតទីតាំងរោងសន្និធិដើម្បីលក់ និងចែកចាយផល-អនុផលព្រៃឈើ ។

៨- ការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ ។

៩- ការបង្កើតឡដុតផ្សេងៗ ដែលប្រើប្រាស់វត្ថុធាតុដើមជាផល-អនុផលព្រៃឈើ ។

១០- ផលិតធ្យូង និងឈើអុស ។

១១- ការធ្វើសកម្មភាពផ្នែកពាណិជ្ជកម្មផ្សេងៗ ត្រូវស្របទៅនឹងក្រមនេះ ។

១២- សកម្មភាពពាណិជ្ជកម្ម ទាំងឡាយដែលមានទីតាំងស្ថិតនៅ ក្នុងដីព្រៃផ្តល់ផល ដោយនិរន្តរភាព ត្រូវមានលិខិតអនុញ្ញាតជាមុន ។

គ្រប់ពាក្យសុំលិខិតអនុញ្ញាតស្របតាមមាត្រានេះ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៃក្រមនេះ ។

រាល់ពាក្យសុំលិខិតអនុញ្ញាតដូចមានចែងក្នុងមាត្រានេះ ត្រូវស្របតាមបទប្បញ្ញត្តិ ដែលមានចែង ក្នុងក្រមនេះ ។

**មាត្រា៣៨១**._ ការពិចារណាលើពាក្យស្នើសុំលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមាន សមត្ថកិច្ចពិនិត្យពាក្យស្នើសុំលិខិតអនុញ្ញាត ត្រូវ ៖

១- មានសង្គតិភាពជាមួយគោលបំណងអភិរក្សទេសភាពនៅជុំវិញ ។

២- មានការគាំទ្រ និងជួយបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។

៣- មានការចូលរួមចំណែកក្នុងកិច្ចការពារតម្លៃជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ។

៤- មានសង្គតិភាពជាមួយផែនការប្រើប្រាស់ដីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងផែនការ គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

៥- អនុវត្តទម្លាប់ល្អនៅក្នុងដំណាក់កាលរៀបចំគម្រោង ប្រតិបត្តិការគម្រោង និងបិទ គម្រោង ។

៦- បំពេញលក្ខខណ្ឌផ្សេងៗទៀត តាមស្ថានភាពជាក់ស្តែង ។

**មាត្រា៣៨២**._ ការពិគ្រោះយោបល់

មុននឹងធ្វើការសម្រេចលើពាក្យសុំលិខិតអនុញ្ញាត ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើ ដោយនិរន្តរភាពត្រូវធ្វើការពិគ្រោះយោបល់មួយជាមួយដៃគូបច្ចេកទេសពាក់ព័ន្ធ ដែលមានបទពិសោធន៍ សិក្សាស្រាវជ្រាវ ការការពារ និងគ្រប់គ្រងធនធានធម្មជាតិ ។ ភាគីពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ និងសហគមន៍មូលដ្ឋាន ត្រូវបង្ហាញពីការរៀបចំហិរញ្ញវត្ថុ និងប៉ាន់ប្រមាណប្រាក់ចំណូលដែលបានមកពី សកម្មភាពពាណិជ្ជកម្មទាំងនោះ ។

ដំណើរការដាក់ពាក្យសុំលិខិតអនុញ្ញាត និងការសម្រេច និងសេចក្ដីលម្អិត នៃសំណើសុំដែលបានឯកភាពរួច លើសកម្មភាពពាណិជ្ជកម្មក្នុងតំបន់ព្រៃឈើគ្រប់គ្រងដោយនិរន្តរភាព ត្រូវធ្វើការផ្សព្វផ្សាយដល់សាធារណៈជន ស្របតាមបទប្បញ្ញត្តិ នៃក្រមនេះ ។

សេចក្ដីលម្អិតអំពីដំណើរការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត និងការសម្រេចសម្រាប់គ្រប់សកម្មភាពទាំង អស់ក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ត្រូវមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី៦
## សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី

**មាត្រា៣៨៣** ._ គោលបំណង

សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅក្នុង ឬក្បែរតំបន់ព្រៃឈើនោះរដ្ឋ ត្រូវទទួលស្គាល់ និងធានានូវសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណីក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព សម្រាប់គោលដៅទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា និងការរស់នៅ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣៨៤** ._ សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី

សិទ្ធិអ្នកប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចសម្រាប់ផល-អនុផលព្រៃឈើ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតនោះទេ ។

សិទ្ធិអ្នកប្រើប្រាស់ជាលក្ខណៈប្រពៃណី រួមមាន ៖

១- ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការប្រមូលទឹកឃ្មុំ ការចោះយកជ័រទឹក និងការប្រមូលអនុផលព្រៃឈើដទៃៗទៀត ។

២- ការប្រើប្រាស់ឈើដើម្បីសាងសង់លំនៅឋាន ក្រោលសត្វ របង និងធ្វើឧបករណ៍កសិកម្ម ។

៣- ការកាត់ស្មៅ និងការព្រលែងសត្វពាហនៈឱ្យស៊ីចំណីក្នុងព្រៃ ។

៤- ការប្រើប្រាស់ ផល-អនុផលព្រៃឈើឱ្យ ស្របតាមការប្រើប្រាស់ជាលក្ខណៈគ្រួសារ និងជាប្រពៃណី ។

៥- សិទ្ធិដោះដូរ ឬលក់អនុផលព្រៃឈើមិនតម្រូវឱ្យមានលិខិតអនុញ្ញាតនោះទេ ប្រសិនបើសកម្មភាពទាំងនោះមិនបង្កការគំរាមកំហែងគួរឱ្យកត់សម្គាល់ដល់និរន្តរភាពព្រៃឈើ ។ អតិថិជន ឬតតិយជនដែលទទួលបានអនុផលព្រៃឈើពីសហគមន៍មូលដ្ឋាន សម្រាប់គោលបំណងពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាត ស្របតាមបញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី៧
## ផែនការ និងរបាយការណ៍គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

**មាត្រា៣៨៥**._ វិសាលភាពនៃផែនការគ្រប់គ្រង

ផែនការគ្រប់គ្រងព្រៃឈើត្រូវបង្កើតឡើងសម្រាប់រាល់សកម្មភាពពាណិជ្ជកម្មទាំងអស់ដែលធ្វើឡើងចំពោះព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ដែលត្រូវសមាមាត្រទៅនឹងទំហំអាំងតង់ស៊ីតេ និងហានិភ័យសកម្មភាពពាណិជ្ជកម្មទាំងនោះ ។ ផែនការគ្រប់គ្រង ត្រូវអនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ដោយផ្អែកលើព័ត៌មានអង្កេតតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីលើកកម្ពស់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

**មាត្រា៣៨៦**._ ខ្លឹមសារនៃផែនការគ្រប់គ្រង

ផែនការគ្រប់គ្រងព្រៃឈើត្រូវ ៖

១- កំណត់និយមន័យនៃតំបន់ជាក់លាក់ ដែលអនុលោមទៅតាមសកម្មភាពពាណិជ្ជកម្មដែលរួមមានការពិពណ៌នា និងទីតាំងនៃសកម្មភាពជាក់លាក់ដែលគ្រោងទុក ។

២- កំណត់នូវគោលដៅ គោលបំណង និងលទ្ធផល នៃសកម្មភាពពាណិជ្ជកម្ម ទាក់ទងនឹងធនធានដែលត្រូវបានប្រើប្រាស់ និងលក្ខណៈវិនិច្ឆ័យសង្គម និងចំណូល ។

៣- កំណត់តួនាទី និងការទទួលខុសត្រូវសម្រាប់អ្នកពាក់ព័ន្ធ ។

៤- កំណត់កូតា សម្រាប់ការប្រមូលផល-អនុផលព្រៃឈើ ។

៥- កំណត់កាលបរិច្ឆេទ និង ពេលវេលាសម្រាប់ការអនុវត្ត ។

៦- រៀបចំថវិកា ។

៧- កំណត់ការអនុវត្តការគ្រប់គ្រង ឱ្យល្អបំផុត ដើម្បីប្រើប្រាស់ និងសកម្មភាពដែលត្រូវចៀសវាង ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

៨- កំណត់ផែនការប្រើប្រាស់ នៃការអនុវត្តរុក្ខវប្បកម្ម ។

៩- កំណត់នីតិវិធីសម្រាប់វិញ្ញាបនបត្រផលិតផលព្រៃឈើ ប្រសិនបើអាចអនុវត្តបាន ។

១០- កំណត់ការកែច្នៃ និងការដឹកជញ្ជូនផលិតផលព្រៃឈើ ។

១១- កំណត់នីតិវិធីសម្រាប់ការអង្កេតតាមដាន ត្រួតពិនិត្យការវាយតម្លៃ និងការរៀបចំរបាយការណ៍ ។

**មាត្រា៣៨៧**._ របាយការណ៍គ្រប់គ្រងព្រៃឈើ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំរបាយការណ៍គ្រប់គ្រងព្រៃឈើប្រចាំឆ្នាំ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចពាក់ព័ន្ធ ។

ផែនការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាព ផែនការគ្រប់គ្រង និងរបាយការណ៍គ្រប់គ្រងព្រៃឈើ ត្រូវដាក់ផ្សព្វផ្សាយជាសាធារណៈ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី៨
## ប្រាក់កម្រៃ និងបុព្វលាភស្តីពីព្រៃឈើ

**មាត្រា៣៨៨**._ ប្រាក់កម្រៃ និងបុព្វលាភ

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រមូលផល-អនុផលព្រៃឈើ ក្នុងគោលបំណងពាណិជ្ជកម្មក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ត្រូវបង់ថ្លៃប្រាក់កម្រៃ និងបុព្វលាភ ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចទទួលខុសត្រូវលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

វិធានសម្រាប់ការវាយតម្លៃគុណភាព និងបរិមាណ រួមមាន តម្រូវការការវាយតម្លៃមុននឹងធ្វើការដឹកជញ្ជូន ។ វិធីសាស្ត្រក្នុងការបង់ថ្លៃ និងវិក័យប័ត្រប្រាក់ចំនូល ពីប្រាក់កម្រៃ និងបុព្វលាភ លើផល-អនុផលឈើ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ច ។

**មាត្រា៣៨៩**._ ការបែងចែកប្រាក់កម្រៃ និងបុព្វលាភ

ផ្នែកមួយ នៃប្រាក់កម្រៃ និងបុព្វលាភ ដែលប្រមូលបាន ត្រូវបែងចែកឱ្យសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធទៅតាមចំនួនកំណត់ ដោយលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើ ដោយនិរន្តរភាព ក្រោយទទួលបានការពិនិត្យ និងឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណែកប្រាក់កម្រៃ និងបុព្វលាភនៅសល់ ទាំងអស់ត្រូវបង់ចូលក្នុងថវិកាជាតិ ។

**មាត្រា៣៩០** ._ សកម្មភាពពាក់ព័ន្ធ

ការបង់ថ្លៃប្រាក់កម្រៃ និងបុព្វលាភ មិនតម្រូវសម្រាប់ ៖

១- ការប្រមូលផល-អនុផលព្រៃឈើពីព្រៃឯកជន ។

២- ការប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ឬការប្រើប្រាស់ជាលក្ខណៈប្រពៃណីក្នុងសហគមន៍គ្រប់គ្រងរួមគ្នា ដែលស្ថិតក្រោមកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៩១** ._ គោលដៅវិទ្យាសាស្ត្រ

ផល-អនុផលព្រៃឈើ ប្រមូលបានមកពីតំបន់ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពសម្រាប់គោលដៅវិទ្យាសាស្ត្រ មិនតម្រូវឱ្យបង់ថ្លៃប្រាក់កម្រៃ និងបុព្វលាភទេ ។

**មាត្រា៣៩២** ._ ពេលកំណត់ក្នុងការបង់ថ្លៃ

ប្រាក់កម្រៃ និងបុព្វលាភស្តីពីព្រៃឈើដែលអាចអនុវត្តបាន ត្រូវបង់មុននឹងការផ្ទេរ ឬលក់ផលព្រៃឈើ ឬសិទ្ធិទៅកាន់ភាគីទីបី ។

**មាត្រា៣៩៣** ._ ការពន្យារពេលក្នុងការបង់ថ្លៃ

ក្នុងករណីដែលអ្នកកាន់លិខិតអនុញ្ញាតមិនបង់ប្រាក់កម្រៃ និងបុព្វលាភទៅតាមកាលបរិច្ឆេទកំណត់តាមការព្រមព្រៀងគ្នា ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ត្រូវមានអំណាចក្នុងការរឹបអូសផល-អនុផលព្រៃឈើ និងឃាត់ផលទាំងនោះទុកជាទ្រព្យសម្បត្តិរដ្ឋ រហូតដល់មានការដោះស្រាយផ្នែកច្បាប់រួចរាល់ ។

ការពន្យារពេលក្នុងការបង់ថ្លៃប្រាក់កម្រៃ ឬបុព្វលាភ អាចត្រូវឯកភាព ស្របតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

**មាត្រា៣៩៤ .**_ នីតិវិធីនៃការបង់ប្រាក់កម្រៃ

នីតិវិធីសម្រាប់ការបង់ប្រាក់កម្រៃត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ច ។

## ជំពូកទី៩
## យន្តការសម្រាប់គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

**មាត្រា៣៩៥ .**_ យន្តការរេដបូក

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ មានតួនាទី និងភារកិច្ចអនុវត្តយន្តការរេដបូក ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ចេញពីការបាត់បង់ និងរេចរឹលព្រៃឈើ តាមរយៈការលើកកម្ពស់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ការអភិរក្ស និងបង្កើនសន្និធិកាបូនព្រៃឈើ ។

**មាត្រា៣៩៦ .**_ ការដាំស្តារឡើងវិញ និងការធ្វើឱ្យប្រសើរឡើងនូវព្រៃឈើ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចត្រូវដាំស្តារព្រៃឈើឡើងវិញ និងធ្វើឱ្យប្រសើរឡើងនូវតម្លៃប្រព័ន្ធអេកូឡូស៊ី និងជីវៈ ចម្រុះក្នុងតំបន់ដែលមានទីតាំងស្ថិតក្នុងព្រៃឈើទាំងមូល ។

រាល់គម្រោងដែលត្រូវបានការឯកភាពក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពត្រូវអនុវត្តឱ្យស្របតាមមាតិកានេះ និងត្រូវដាំស្តារព្រៃឈើឡើងវិញ ក្នុងតំបន់ដីព្រៃបាត់បង់ និងដីព្រៃរេចរឹល ឬតំបន់ដែលមានទំហំស្មើតំបន់សកម្មភាពពាណិជ្ជកម្ម ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការគ្នាបង្កើតយន្តការដើម្បីប្រតិបត្តិការ លើកកម្ពស់ ជំរុញការដាំស្តារព្រៃឈើឡើងវិញក្នុងតំបន់ដីព្រៃបាត់បង់ និងដីព្រៃរេចរឹល ។ យន្តការនេះត្រូវបង្កើតឡើង ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា៣៩៧**._ ការដាំដុះដើមឈើ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍បច្ចេកទេសដើម្បីកំណត់វិធាននានា ស្ដីពីការដាំដុះដើមឈើ ដើម្បីលើកទឹកចិត្តដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងការដាំ និងរក្សាការដាំដុះដើមឈើ ដែលអនុវត្តតាមគោលការណ៍ និងបមាណីយសម្រាប់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងសមស្របទៅនឹងគោលដៅបរិស្ថានទេសភាព សង្គម និងសេដ្ឋកិច្ច ។

**មាត្រា៣៩៨**._ និរន្តរភាពធ្យូង និងឈើថាមពល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវលើកកម្ពស់ផលិតកម្ម និងការប្រើប្រាស់ធ្យូង និងឈើថាមពលពីចម្ការព្រៃឈើដាំ និងសំណល់នានាដើម្បីធានាការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព តាមរយៈការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធសម្រាប់ផលិតករ ដែលទទួលបានការអនុញ្ញាត ។

ការលើកទឹកចិត្តនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធលើការគ្រប់គ្រង ព្រៃឈើដោយនិរន្តរភាព ។

**មាត្រា៣៩៩**._ ការទប់ស្កាត់ និងការត្រួតពិនិត្យភ្លើងឆេះព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់តំបន់សម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ ការទប់ស្កាត់ភ្លើងឆេះព្រៃ និងបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងភ្លើងឆេះព្រៃ សម្រាប់ការអនុវត្តក្នុងតំបន់ព្រៃឈើ ។

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវមានកាតព្វកិច្ចការពារថែរក្សា និងទប់ស្កាត់ភ្លើងឆេះព្រៃ ។

**មាត្រា៤០០**._ ការផ្ដល់វិញ្ញាបនបត្រព្រៃឈើតាមស្តង់ដារអន្តរជាតិ និងការគ្រប់គ្រង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ មានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព អាចរៀបចំលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងនីតិវិធីនៃកម្មវិធីផលិតផលព្រៃឈើអន្តរជាតិ និងវិញ្ញាបនបត្រគ្រប់គ្រងព្រៃឈើ និងការអនុវត្តនីតិវិធីតាមដាន និងវាយត្រាលើឈើហ៊ុប ផលិតផលឈើ និងសាច់ឈើ និងអនុផលព្រៃឈើ រឹបអូស ឬឃាត់ទុកផលដែលមិនត្រូវបានប្រើប្រាស់សម្រាប់ក្នុងស្រុក ។

**មាត្រា៤០១ .**_ កម្មវិធីពង្រឹងការអនុវត្តច្បាប់ អភិបាលកិច្ច និងពាណិជ្ជកម្ម

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ត្រូវបង្កើត និងអនុវត្តកម្មវិធីពង្រឹងការអនុវត្តច្បាប់ អភិបាលកិច្ច និងពាណិជ្ជកម្ម ដើម្បីពង្រឹងការគ្រប់គ្រង ការការពារ និងការអភិវឌ្ឍព្រៃឈើ ដោយនិរន្តរភាព តម្លាភាព យុត្តិធម៌ និងប្រកបដោយប្រសិទ្ធភាព ។

គោលបំណងជាក់លាក់នៃកម្មវិធីពង្រឹងការអនុវត្តច្បាប់ អភិបាលកិច្ច និងពាណិជ្ជកម្មត្រូវ ៖

១- ពង្រឹងការអនុវត្តច្បាប់ដោយធ្វើការតាមដាន ត្រួតពិនិត្យ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់សកម្មភាពព្រៃឈើខុសច្បាប់ ។

២- បង្កើត និងអនុវត្តច្បាប់ និងគោលនយោបាយសមស្រប ។

៣- ជំរុញអភិបាលកិច្ចល្អតាមរយៈការបង្កើនសមត្ថភាពក្នុងការគ្រប់គ្រង ។

៤- បញ្ជ្រាបការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាព សិទ្ធិជាសាធារណៈ និងកាតព្វកិច្ច ។

៥- កែលម្អការកសាងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់នៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចទទួលបន្ទុកលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

៦- អនុវត្តតាមវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការតាមដាន ត្រួតពិនិត្យ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់សកម្មភាពព្រៃឈើខុសច្បាប់ ។

៧- លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនៃការពង្រឹងការអនុវត្តច្បាប់ព្រៃឈើដល់សាធារណជន ។

**មាត្រា៤០២ .**_ ប្រព័ន្ធផ្តល់លិខិតអនុញ្ញាត និងការអង្កេតតាមដានទូទាំងប្រទេស

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវរៀបចំប្រព័ន្ធផ្តល់លិខិតអនុញ្ញាត និងការតាមដានទូទាំងប្រទេស ដើម្បីតាមដានផលិតកម្ម និងការប្រើប្រាស់នូវរាល់ផលិតផលព្រៃឈើដែលចេញពីតំបន់ព្រៃឈើគ្រប់គ្រងដោយនិរន្តរភាព ។

ការអនុវត្តតាមប្រព័ន្ធតាមដានជាលក្ខខណ្ឌតម្រូវសម្រាប់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើប្រតិបត្តិការ ត្រូវស្របតាមលិខិតអនុញ្ញាត ដូចមានចែងក្នុងក្រមនេះ ។

ការរៀបចំប្រព័ន្ធផ្តល់លិខិតអនុញ្ញាត និងការតាមដានទូទាំងប្រទេស ត្រូវសម្រេចក្នុងរយៈពេលសមស្របបន្ទាប់ពីក្រមនេះចូលជាធរមាន ។

**មាត្រា៤០៣ ._** យន្តការមូលនិធិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព អាចរក្សាយន្តការមូលនិធិពាក់ព័ន្ធដែលមានស្រាប់ ឬបង្កើតយន្តការមូលនិធិថ្មីទៅតាមតម្រូវការ ដើម្បីអនុវត្ត ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## មាតិកាទី៥
## កិច្ចការពាររុក្ខជាតិព្រៃ ប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងតំបន់ទីជម្រាល
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៤០៤ ._** តួនាទី និងភារកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

១- រៀបចំ ត្រួតពិនិត្យគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធ ការគ្រប់គ្រងរុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ី ។

២- សិក្សា តាមដាន និងវាយតម្លៃ តម្លៃផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន របស់រុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ី ។

៣- សិក្សាវាយតម្លៃ និងគ្រប់គ្រងប្រភេទរាតត្បាត មិនមានដើមកំណើតក្នុងស្រុក ឬដែលមិនមានក្នុងធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤- រៀបចំបញ្ជីចាត់ថ្នាក់ គ្រប់គ្រង និងការពាររុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ី ជាពិសេសប្រភេទកំពុងរងការគំរាមកំហែង ។

៥- រៀបចំចុះបញ្ជីថ្នាក់ជាតិសម្រាប់ប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង និងត្រូវបានចុះក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ។

៦- ចាត់វិធានការ និងយន្តការសម្រាប់ការអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់រុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព ។

៧- ចាត់វិធានការ និងយន្តការទប់ស្កាត់រាល់ការគំរាមកំហែង ទប់ស្កាត់ការបាត់បង់រុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ី ។

៨- ស្តារឡើងវិញនូវរុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ី ដែលកំពុងរងការគំរាមកំហែង និងបាត់បង់ ។

៩- សិក្សាវាយតម្លៃ និងគ្រប់គ្រងប្រភេទរាតត្បាតដែលមិនមានដើមកំណើតក្នុងស្រុក ឬដែលមិនមានក្នុងធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

១០- ចងក្រង គ្រប់គ្រង និងផ្សព្វផ្សាយប្រព័ន្ធទិន្នន័យរុក្ខជាតិព្រៃ និងព័ត៌មានប្រព័ន្ធអេកូឡូស៊ី ។

**មាត្រា៤០៥ ._** កិច្ចសហការរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវសហការ និងចែករំលែកទិន្នន័យ និងព័ត៌មានអំពីបទល្មើសរុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែង ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

កិច្ចសហការ និងចែករំលែកព័ត៌មានរួមមាន ៖

១- លទ្ធផលនៃការស៊ើបអង្កេតថ្នាក់ជាតិ និងថ្នាក់អន្តរជាតិស្តីពីការជួញដូរ និងដឹកជញ្ជូនរុក្ខជាតិព្រៃ និងប្រភេទឈើខុសច្បាប់ ។

២- របាយការណ៍នៃការរឹបអូសរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង និងប្រភេទឈើខុសច្បាប់ ដូចមានចែងនៅក្នុងក្រមនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

៣- ឯកសារបណ្តឹងផ្លូវច្បាប់ពាក់ព័ន្ធនឹងរុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែង ។

# ជំពូកទី២
# ការធ្វើចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ

**មាត្រា៤០៦ .**_ បញ្ជីប្រភេទរុក្ខជាតិព្រៃថ្នាក់ជាតិ រួមទាំងប្រភេទដែលកំពុងរងការគំរាមកំហែង និងត្រូវការពារ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកត់ត្រា និងគ្រប់គ្រងបញ្ជីចំណាត់ថ្នាក់រុក្ខជាតិព្រៃថ្នាក់ជាតិ រួមទាំងប្រភេទដែលកំពុងរងការគំរាមកំហែង សម្រាប់គ្រប់គ្រង និងការពារ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា៤០៧ .**_ ចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ

រុក្ខជាតិព្រៃ ដែលមានក្នុងបញ្ជីជាតិសម្រាប់ប្រភេទនីមួយៗ ដែលកំពុងរងគ្រោះថ្នាក់ ត្រូវបានបែងចែកជា៤ ចំណាត់ថ្នាក់ដូចខាងក្រោម ៖

១- ចំណាត់ថ្នាក់ទី១ ៖ គ្រប់ប្រភេទ រុក្ខជាតិព្រៃទាំងអស់ ដែលបានកំណត់ជាប្រភេទផុតពូជទាំងស្រុងពីក្នុងធម្មជាតិ ប្រភេទជិតផុតពូជ ឬប្រភេទកំពុងរងគ្រោះថ្នាក់ខ្លាំង ។

២- ចំណាត់ថ្នាក់ទី២ ៖ គ្រប់ប្រភេទរុក្ខជាតិព្រៃជាតិទាំងអស់ ដែលបានកំណត់ជាប្រភេទងាយទទួលរងគ្រោះថ្នាក់ និងប្រភេទជិតទទួលរងការគំរាមកំហែង ។

៣- ចំណាត់ថ្នាក់ទី៣ ៖ គ្រប់ប្រភេទរុក្ខជាតិព្រៃទាំងអស់ ដែលបានកំណត់ជាប្រភេទមិនទាន់ទទួលរងការគំរាមកំហែង ឬប្រភេទសម្បូរ ។

៤- ចំណាត់ថ្នាក់ទី៤ ៖ គ្រប់ប្រភេទរុក្ខជាតិព្រៃទាំងអស់ដែលពុំទាន់ធ្វើការចាត់ថ្នាក់ ។

ក្នុងករណីមានចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃណាមួយមិនទាន់ធ្វើការចាត់ថ្នាក់ ឬរកឃើញថ្មីហើយមិនទាន់បានចាត់ថ្នាក់ ត្រូវធ្វើបច្ចុប្បន្នភាពកំណត់បញ្ចូលទៅក្នុងក្រុមចំណាត់ថ្នាក់ទាំង៤ ចំណាត់ថ្នាក់ខាងលើ ទៅតាមស្ថានភាពជាក់ស្តែង និងមានការពិគ្រោះយោបល់ជាមួយដៃគូ និងអ្នកជំនាញការបច្ចេកទេស ។

ការកំណត់និយមន័យ និងលក្ខណៈវិនិច្ឆ័យរបស់ចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃនីមួយៗខាងលើ ត្រូវផ្អែកតាមស្ថានភាពជាក់ស្តែង និងស្របតាមលក្ខណៈវិទ្យាសាស្ត្រ ។ និយមន័យ និងលក្ខណៈ

វិនិច្ឆ័យរបស់ចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤០៨ ._** ការធ្វើបច្ចុប្បន្នភាពបញ្ជីចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃថ្នាក់ជាតិ

ការធ្វើបច្ចុប្បន្នភាពបញ្ជីចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃថ្នាក់ជាតិ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងមាត្រា៤០៧ និងស្ថានភាពជាក់ស្តែង ។

បច្ចុប្បន្នភាពបញ្ជីចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃថ្នាក់ជាតិ ត្រូវទទួលស្គាល់ដោយលិខិតបទដ្ឋានគតិយុត្ត និងត្រូវធ្វើការផ្សព្វផ្សាយដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្ត ។

**មាត្រា៤០៩ ._** សំណើសុំធ្វើបច្ចុប្បន្នភាពបញ្ជី ឬចំណាត់ថ្នាក់រុក្ខជាតិព្រៃ

ការស្នើសុំធ្វើបច្ចុប្បន្នភាពលើចំណាត់ថ្នាក់ ឬបន្ថែមចំណាត់ថ្នាក់ទៅក្នុងបញ្ជីសម្រាប់ប្រភេទរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ត្រូវធ្វើឡើងទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នីតិវិធីនៃការស្នើសុំពិនិត្យ និងសម្រេចទៅលើការស្នើសុំ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤១០ ._** ការដំឡើងចំណាត់ថ្នាក់នៃប្រភេទរុក្ខជាតិព្រៃ

គ្រប់ប្រភេទរុក្ខជាតិព្រៃ អាចត្រូវដំឡើងចំណាត់ថ្នាក់នៃប្រភេទរុក្ខជាតិព្រៃ ដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម ៖

១- កម្រិតហានិភ័យនៃការគំរាមកំហែងខ្ពស់ដល់បរិមាណនៃរុក្ខជាតិព្រៃទាំងនោះ ។

២- ស្ថានភាពប្រភេទរុក្ខជាតិព្រៃទាំងនោះស្របតាមលក្ខណៈវិនិច្ឆ័យ ដែលកំពុងរងគ្រោះថ្នាក់ឈានទៅរកការវិនាសផុតពូជ ឬជិតផុតពូជ ។

៣- មានតម្លៃបេតិកភណ្ឌវប្បធម៌ ឬសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ។

នីតិវិធីនៃការដំឡើងថ្នាក់ និងការកែប្រែចំណាត់ថ្នាក់នៃក្រុមប្រភេទរុក្ខជាតិព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី៣
## ការហាមឃាត់សកម្មភាពប៉ះពាល់ទីជម្រកប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង និងការប្រមូលរុក្ខជាតិព្រៃ

**មាត្រា៤១១ .**_ សកម្មភាពហាមឃាត់ដែលប៉ះពាល់ដល់ទីជម្រកប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង

សកម្មភាពបំផ្លិចបំផ្លាញ ឬធ្វើឱ្យប្រែប្រួលទីជម្រកធម្មជាតិរបស់ប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែងដោយផ្ទាល់ ឬប្រយោល ដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ត្រូវបានហាមឃាត់ លើកលែងតែស្របតាមបទប្បញ្ញត្តិ ដូចមានចែងនៅក្នុងជំពូកទី៤ នៃមាតិកានេះ ។

**មាត្រា៤១២ .**_ សកម្មភាពហាមឃាត់ចំពោះប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង

សកម្មភាពប្រមូល បំផ្លិចបំផ្លាញ ប្រើប្រាស់ លក់ ធ្វើជំនួញ ឬដឹកជញ្ជូនរុក្ខជាតិព្រៃ ឬបំណែករុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង ដូចមានចែងក្នុងបញ្ជីប្រភេទរុក្ខជាតិព្រៃថ្នាក់ជាតិ ត្រូវបានហាមឃាត់ លើកលែងតែបទប្បញ្ញត្តិ ដូចមានចែងនៅក្នុងជំពូកទី៤ នៃមាតិកានេះ ។

**មាត្រា៤១៣ .**_ សកម្មភាពហាមឃាត់នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ

សកម្មភាពប្រមូល ឬបំផ្លិចបំផ្លាញរុក្ខជាតិព្រៃ នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានហាមឃាត់ លើកលែងតែបទប្បញ្ញត្តិ ដូចមានចែងនៅក្នុងជំពូកទី៤ នៃមាតិកានេះ ឬស្របតាមផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ ឬរបៀងអភិរក្សជីវៈចម្រុះ ។

## ជំពូកទី៤
## ការផ្ដល់លិខិតអនុញ្ញាត ការប្រមូលយក និងការធ្វើពាណិជ្ជកម្ម

**មាត្រា៤១៤ .**_ ការមិនចេញលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មិនត្រូវចេញលិខិតអនុញ្ញាតក្រោមមាតិកានេះ ក្នុងករណីដែលមិនមានព័ត៌មានផ្នែកវិទ្យាសាស្ត្របញ្ជាក់គ្រប់គ្រាន់ ។

**មាត្រា៤១៥** ._ ការលើកលែងលិខិតអនុញ្ញាត

សកម្មភាពខាងក្រោមនេះ មិនតម្រូវឱ្យមានលិខិតអនុញ្ញាត ៖

១- ការប្រមូល ការធ្វើពាណិជ្ជកម្ម ការដឹកជញ្ជូន និងការប្រើប្រាស់ប្រភេទរុក្ខជាតិព្រៃ ក្នុងចំណាត់ថ្នាក់ប្រភេទទី៣ និងទី៤ សម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារ និងជាលក្ខណៈប្រពៃណីតែប៉ុណ្ណោះ ។

២- ការប្រមូលផល-អនុផលព្រៃឈើ ពីចម្ការដាំដុះលើដីឯកជន ។

**មាត្រា៤១៦** ._ តម្រូវឱ្យមានលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចផ្តល់លិខិតអនុញ្ញាតការជួញដូរ ឬការដឹកជញ្ជូនរុក្ខជាតិព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ប្រភេទទី១ និងទី២ សម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារ និងជាឱសថ ។

ការផ្តល់លិខិតអនុញ្ញាតណាមួយនៅក្រោមជំពូកនេះ ត្រូវមានចែងអំពីការដាក់កំហិតសមរម្យទៅលើកម្រិត និងក្របខ័ណ្ឌពេលវេលា ដែលសកម្មភាពទាំងនោះត្រូវបានអនុវត្តនៅក្រោមការអនុញ្ញាតនេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់ធម្មជាតិ ឬការស្តារឡើងវិញ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាត លក្ខណៈវិនិច្ឆ័យ និងបទប្បញ្ញត្តិនានា ។

**មាត្រា៤១៧** ._ លិខិតអនុញ្ញាតសម្រាប់ពាណិជ្ជកម្មអន្តរជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តល់លិខិតអនុញ្ញាតសម្រាប់គ្រប់សកម្មភាពពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិទៅលើប្រភេទរុក្ខជាតិព្រៃ ដែលមានក្នុងបញ្ជីចំណាត់ថ្នាក់ប្រភេទទី១ ទី២ និងទី៣ និងសំណាករុក្ខជាតិព្រៃទាំងនោះ ដូចខាងក្រោម ៖

១- ការថែរក្សា ។

២- ការដឹកជញ្ជូន ។

៣- ការតាំងពិព័រណ៍ ។

៤- ការធ្វើសន្និធិ ។

៥- ការផ្តល់ជាអំណោយថ្នាក់រដ្ឋ ។

៦- ការចូលរួមសកម្មភាពអន្តរជាតិ ដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្ដីពីលក្ខខណ្ឌតម្រូវនិងនីតិវិធីនៃការផ្ដល់លិខិតអនុញ្ញាតសម្រាប់ពាណិជ្ជកម្មអន្តរជាតិនេះ ។

**មាត្រា៤១៨**._ ការផ្ដល់លិខិតអនុញ្ញាតសម្រាប់គោលបំណងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចផ្ដល់ការអនុញ្ញាតពិសេស នៅក្នុងប្រមូលប្រភេទរុក្ខជាតិព្រៃ ដែលមានក្នុងបញ្ជីចំណាត់ថ្នាក់ប្រភេទទី១ ទី២ ឬទី៣ ពីកន្លែងណាមួយសម្រាប់គោលបំណងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ក្នុងករណីការប្រមូលនោះមិនបង្កផលប៉ះពាល់ដល់ការអភិរក្សសារព័ន្ធរុក្ខជាតិព្រៃនៅក្នុងតំបន់ និងព្រះរាជាណាចក្រកម្ពុជា ។

លិខិតអនុញ្ញាតដែលត្រូវបានផ្ដល់សម្រាប់គោលបំណង វិទ្យាសាស្ត្រ អាចផ្ដល់ឱ្យបានតែស្ថាប័នណាដែលតំណាងឱ្យស្ថាប័នសិក្សា ស្ថាប័នស្រាវជ្រាវ អង្គការអភិរក្ស អគារសន្និធិរុក្ខជាតិព្រៃស្ងួតសម្រាប់ការសិក្សាស្រាវជ្រាវ ឬសួនភូគតាមសាស្ត្រតែប៉ុណ្ណោះ ។

នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការផ្ដល់ការអនុញ្ញាតសម្រាប់គោលបំណងផ្នែកស្រាវជ្រាវ វិទ្យាសាស្ត្រ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤១៩**._ ព័ត៌មានវិទ្យាសាស្ត្រមិនគ្រប់គ្រាន់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចបដិសេធក្នុងការផ្ដល់លិខិតអនុញ្ញាតពិសេសនៅក្រោមជំពូកនេះ ក្នុងករណីដែលមិនមានព័ត៌មានវិទ្យាសាស្ត្រគ្រប់គ្រាន់ ដើម្បីធ្វើការកំណត់អំពីផលប៉ះពាល់នៃសកម្មភាពទៅលើប្រភេទរុក្ខជាតិព្រៃដែលទទួលរងការគំរាមកំហែង ។

ក្នុងករណីដែលលិខិតអនុញ្ញាត ត្រូវបានផ្ដល់សម្រាប់គោលបំណងវិទ្យាសាស្ត្រ មិនមានព័ត៌មានវិទ្យាសាស្ត្រគ្រប់គ្រាន់ ដើម្បីធ្វើការកំណត់ច្បាស់លាស់ក៏ដោយ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចប្រើប្រាស់ការវិនិច្ឆ័យដែលល្អបំផុតរបស់ខ្លួន ដើម្បីដាក់កំហិតទៅលើកម្រិតនៃការប្រមូល ដែលនឹងកាត់បន្ថយលទ្ធភាព ដែលសកម្មភាពទាំងនេះ នឹងបង្កឱ្យមានការផុតពូជនៃរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង ឬបង្កការខូចខាតដែលមិនអាចជំនួសបាន ។

**មាត្រា៤២០**._ លិខិតអនុញ្ញាតប្រមូលប្រភេទរុក្ខជាតិព្រៃ

ការស្នើសុំលិខិតអនុញ្ញាតប្រមូលយករុក្ខជាតិព្រៃ ត្រូវដាក់សំណើសុំមកអង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិថ្នាក់ក្រោមជាតិ ក្នុងករណីមានការស្នើសុំប្រមូលប្រភេទរុក្ខជាតិព្រៃ ។

នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការស្នើសុំ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤២១**._ ការព្យួរ ឬការលុបចោលលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរក្សាសិទ្ធិអំណាចនៅក្នុងការព្យួរជាបណ្ដោះអាសន្ន ឬមិនមានការកំណត់ ឬលុបចោល នូវលិខិតអនុញ្ញាតដែលបានផ្ដល់នៅក្រោមជំពូកនេះ ដែលផ្អែកទៅលើទិន្នន័យថ្មីៗ ព័ត៌មានវិទ្យាសាស្ត្រ ឬការគំរាមកំហែងដែលបានរកឃើញថ្មីៗទៅលើប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង និងទីជម្រករបស់វា ។

## ជំពូកទី៥
## ផែនការគ្រប់គ្រង និងស្ដាររុក្ខជាតិព្រៃឡើងវិញ

**មាត្រា៤២២**._ ផែនការគ្រប់គ្រង និងស្ដាររុក្ខជាតិព្រៃឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំផែនការគ្រប់គ្រង និងស្ដាររុក្ខជាតិព្រៃ សារព័ន្ធរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែងឡើងវិញ រយៈពេល ខ្លី មធ្យម និងវែង នូវប្រភេទដែលកំពុងរងការគំរាមកំហែងមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានកំណត់ក្នុងចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ ដូចមានចែងក្នុងក្រមនេះ ។

ផែនការគ្រប់គ្រង និងស្ដាររុក្ខជាតិព្រៃ ត្រូវរៀបចំឡើងក្នុងរយៈពេលខ្លី មធ្យម និងវែង ហើយអាចគ្របដណ្ដប់ទៅលើប្រភេទរុក្ខជាតិព្រៃច្រើនប្រភេទ និងរួមបញ្ចូលទាំងប្រភេទសត្វព្រៃផងដែរ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត និងអ្នកជំនាញបច្ចេកទេស ដើម្បីរៀបចំផែនការគ្រប់គ្រង និងស្ដាររុក្ខជាតិព្រៃ សារព័ន្ធរុក្ខជាតិព្រៃ ដែលកំពុងរងការគំរាមកំហែងឡើងវិញ ។

ផែនការគ្រប់គ្រង និងស្ដារប្រភេទរុក្ខជាតិព្រៃ សារព័ន្ធរុក្ខជាតិព្រៃឡើងវិញ អាចត្រូវបញ្ចូលទៅក្នុងផែនការគ្រប់គ្រងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងតំបន់គ្រប់គ្រងរួមគ្នា ។

**មាត្រា៤២៣ .**_ ខ្លឹមសារនៃផែនការគ្រប់គ្រង និងការស្តាររុក្ខជាតិព្រៃឡើងវិញ

ផែនការគ្រប់គ្រង និងស្តាររុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែងឡើងវិញ ត្រូវកំណត់ខ្លឹមសារជាក់លាក់ដូចខាងក្រោម ៖

១- គោលបំណង លក្ខណៈវិនិច្ឆ័យ វិធានការ និងលទ្ធផលរំពឹងទុក ។

២- សកម្មភាពគ្រប់គ្រង និងអភិរក្សដើម្បីធានានូវមុខងារ និងតួនាទីក្នុងប្រព័ន្ធអេកូឡូស៊ី ។

៣- ការគំរាមកំហែងដោយផ្ទាល់ និងប្រយោល និងវិធានការឆ្លើយតប និងចាំបាច់ក្នុងការកាត់បន្ថយការគំរាមកំហែង និងធានាសុវត្ថិភាពប្រភេទទាំងនេះ ។

៤- ទីជម្រកសំខាន់ៗ ឬពិសេសសម្រាប់ការអភិរក្ស ។

៥- ការបញ្ជ្រាបទៅក្នុងផែនការគ្រប់គ្រង ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៦- ការបញ្ជ្រាបយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ ។

៧- ពេលវេលា និងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្ត ។

**មាត្រា៤២៤ .**_ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើការស្តាររុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង

គម្រោង ផែនការ ឬសកម្មភាពស្តាររុក្ខជាតិព្រៃឡើងវិញត្រូវ ៖

១- ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាតិកាទី៣ គន្ថីទី២ នៃក្រមនេះ ក្នុងករណីដែលមានផលប៉ះពាល់ខ្លាំងដល់ទីជម្រក មុខងារ និងតួនាទីប្រព័ន្ធអេកូឡូស៊ី ។

២- បញ្ជាក់ថានឹងមិនបំផ្លិចបំផ្លាញប្រភេទរុក្ខជាតិព្រៃ ដែលកំពុងរងការគំរាមកំហែងដែលមានស្រាប់ ឬមិនរារាំងដល់ប្រភេទរុក្ខជាតិព្រៃ ដែលនឹងត្រូវស្តារឡើងដោយធម្មជាតិ ។

**មាត្រា៤២៥ .**_ ការរៀបចំរបាយការណ៍ និងការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយអ្នកពាក់ព័ន្ធត្រូវរៀបចំប្រព័ន្ធអង្កេតតាមដាន និងការរៀបចំរបាយការណ៍អំពីការអនុវត្តផែនការគ្រប់គ្រង និងស្តារប្រភេទរុក្ខជាតិព្រៃ សារព័ន្ធរុក្ខជាតិព្រៃ ឡើងវិញ ។

## ជំពូកទី៦
## ការគ្រប់គ្រងប្រភេទរាតត្បាត

**មាត្រា៤២៦** ._ បញ្ជីប្រភេទរាតត្បាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំ កត់ត្រា និងគ្រប់គ្រង បញ្ជីប្រភេទរាតត្បាត នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្រោយពេលក្រមនេះចូលជាធរមាន ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវពិនិត្យផ្ទៀងផ្ទាត់បញ្ជីប្រភេទរាតត្បាត មុនដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

ប្រភេទរាតត្បាតសំដៅទៅលើប្រភេទទាំងឡាយណាដែលមិនមានដើមកំណើតនៅក្នុងទីតាំង ឬប្រព័ន្ធអេកូឡូស៊ីជាក់លាក់ណាមួយ និងមានសមត្ថភាព និង/ឬ និន្នាការក្នុងការរីករាលដាលទៅដល់កម្រិតមួយដែលអាចបង្កការខូចខាតដល់បរិស្ថាន សេដ្ឋកិច្ច និងសុខភាពមនុស្ស ។

ត្រូវហាមឃាត់ការនាំចូលប្រភេទរាតត្បាតទាំងឡាយណាដែលមិនមានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤២៧** ._ ផែនការគ្រប់គ្រងប្រភេទរាតត្បាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំផែនការគ្រប់គ្រងប្រភេទរាតត្បាតរយៈពេលខ្លី មធ្យម និងវែង ដោយពិចារណាទៅលើផលប៉ះពាល់អវិជ្ជមាន និងហានិភ័យចំពោះសត្វ រុក្ខជាតិព្រៃ បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី សុខភាព សង្គម និងសេដ្ឋកិច្ច ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត និងអ្នកជំនាញបច្ចេកទេស ត្រូវរៀបចំផែនការគ្រប់គ្រងប្រភេទរាតត្បាត ដើម្បីកំណត់ ៖

១- ផ្លូវដែលប្រភេទរុក្ខជាតិព្រៃរាតត្បាតនោះចូលមកកាន់ព្រះរាជាណាចក្រកម្ពុជា ។

២- វិធីនៃការគ្រប់គ្រងប្រភេទរុក្ខជាតិព្រៃដែលរាតត្បាតទាំងនោះ មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៣- វិធីលុបបំបាត់ប្រភេទរុក្ខជាតិព្រៃដែលរាតត្បាត និងបង្កមហន្តរាយ ។

**មាត្រា៤២៨** ._ ខ្លឹមសារនៃផែនការគ្រប់គ្រងប្រភេទរាតត្បាត

ផែនការគ្រប់គ្រងប្រភេទរាតត្បាត ត្រូវកំណត់ខ្លឹមសារជាក់លាក់ ដូចខាងក្រោម ៖

១- គោលបំណង លក្ខណៈវិនិច្ឆ័យ វិធានការ សូចនាករតាមដាន និងលទ្ធផលរំពឹងទុក ។

២- សកម្មភាពគ្រប់គ្រង វិធានការ វិធីសាស្ត្រកំចាត់ ទប់ស្កាត់ និងរារាំងប្រភេទរាតត្បាត ។

៣- ទំហំ ទីតាំង ភូមិសាស្ត្រ ប្រភព និងប្រភេទរបស់ប្រភេទរាតត្បាត ។

៤- ធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងទីជម្រកសំខាន់ៗ ឬពិសេស នៅទីតាំងត្រូវគ្រប់គ្រងប្រភេទរាតត្បាត ។

៥- ផ្លូវចម្លងដោយផ្ទាល់ និងប្រយោល និងវិធានការឆ្លើយតប និងចាំបាច់ក្នុងការទប់ស្កាត់ និងរារាំងប្រភេទរាតត្បាត ។

៦- ការបញ្ជ្រាបយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ ។

៧- ពេលវេលា និងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្ត ។

**មាត្រា៤២៩** ._ បញ្ជីសម្រាប់ប្រភេទ រុក្ខជាតិព្រៃដែលរាតត្បាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំបញ្ជីថ្នាក់ជាតិសម្រាប់ប្រភេទ រុក្ខជាតិព្រៃរាតត្បាត ដែលមាន ឬអាចបង្កគ្រោះថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានការនាំចូលប្រភេទរុក្ខជាតិព្រៃទាំងនោះ មកក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤៣០**._ ផែនការលុបបំបាត់ប្រភេទរុក្ខជាតិព្រៃដែលរាតត្បាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបផែនការលុបបំបាត់ប្រភេទរុក្ខជាតិព្រៃរាតត្បាត ដើម្បីលុបបំបាត់ និងកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ពីប្រភេទរុក្ខជាតិព្រៃ ដែលរាតត្បាតទៅលើបរិស្ថាន សេដ្ឋកិច្ច និងសុខភាពមនុស្ស ។

**មាត្រា៤៣១** ._ លក្ខខណ្ឌតម្រូវនៃការអនុញ្ញាត និងការហាមឃាត់

ការនាំចូលប្រភេទរុក្ខជាតិព្រៃដែលរាតត្បាតណាមួយចូលទៅក្នុងបរិស្ថានធម្មជាតិក្រៅពីតំបន់ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ត្រូវហាមឃាត់ចំពោះការនាំចូលប្រភេទរុក្ខជាតិព្រៃរាតត្បាត ទៅក្នុងផ្នែកណាមួយនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

## ជំពូកទី៧
## ការគ្រប់គ្រងរុក្ខជាតិ និងបំណែកនិស្សន្ទវត្ថុរុក្ខជាតិព្រៃកំពុងរងការគំរាមកំហែងដែលបានពីការរឹបអូស

**មាត្រា៤៣២ .**_ ការគ្រប់គ្រងរុក្ខជាតិព្រៃកំពុងរងការគំរាមកំហែងដែលបានរឹបអូស ឬផលដែលបានកើតចេញពីរុក្ខជាតិព្រៃដែលបានរឹបអូស

គ្រប់រុក្ខជាតិព្រៃកំពុងរងការគំរាមកំហែង ឬផលដែលបានកើតចេញពីរុក្ខជាតិព្រៃដែលបានរឹបអូស នៃក្រមនេះត្រូវ ៖

១- ករណីសំណាករស់ ៖ ក្នុងករណីដែលអាចធ្វើទៅបាន ត្រូវយករុក្ខជាតិព្រៃទាំងនេះទៅទីជម្រកដើមដែលសមស្របរបស់វាវិញ ឬត្រូវប្រគល់ឱ្យទៅស្ថាប័នសមស្របណាមួយក្នុងគោលបំណងបង្កាត់ ផ្សាំ ឬសិក្សាស្រាវជ្រាវ ។ ស្ថាប័នសមស្រប រួមមានស្ថាប័នសិក្សា ស្ថាប័នស្រាវជ្រាវ អង្គការអភិរក្ស កន្លែងរក្សាសំណាករុក្ខជាតិព្រៃ ឬរុក្ខឧទ្យាន ។

២- ករណីរុក្ខជាតិព្រៃងាប់ ឬនិស្សន្ទវត្ថុមិនអាចផ្សាំបាន ត្រូវរក្សាទុក ស្តុកទុក ឬបំផ្លាញចោល ដែលគោរពទៅតាមនីតិវិធីដែលបានឯកភាពដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៣៣ .**_ ការគ្រប់គ្រងភស្តុតាងមុនបញ្ចប់បណ្តឹង

រាល់វត្ថុតាង និងនិស្សន្ទវត្ថុ ត្រូវរក្សាទុកប្រកបដោយសុវត្ថិភាពដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយគោរពទៅតាមការគ្រប់គ្រង និងនីតិវិធីសមស្រប រហូតដល់ពេលចេញសាលក្រមពីតុលាការ ។

**មាត្រា៤៣៤ .**_ ការគ្រប់គ្រងភស្តុតាងបន្ទាប់ពីបញ្ចប់បណ្តឹង ឬមានការអនុញ្ញាតពីតុលាការ

នៅពេលដែលបណ្តឹងនៅតុលាការត្រូវបានបញ្ចប់ គ្រប់សម្ភារ រុក្ខជាតិព្រៃ បំណែករុក្ខជាតិព្រៃ ឬនិស្សន្ទវត្ថុរុក្ខជាតិព្រៃដែលរឹបអូសបាន ត្រូវបញ្ជូនទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ សម្រាប់ជាប្រយោជន៍សាធារណៈ ។

## ជំពូកទី៨
## ការគ្រប់គ្រងតំបន់ទីជម្រាល

**មាត្រា៤៣៥**._ វិសាលភាព

ជំពូកនេះមានវិសាលភាពអនុវត្តលើ ការគ្រប់គ្រងតំបន់ទីជម្រាល ប្រកបដោយនិរន្តរភាពដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងមានមនសិការទទួលខុសត្រូវ សំដៅផ្តល់ផលប្រយោជន៍ដល់សង្គម សេដ្ឋកិច្ច និងបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានតួនាទីអនុវត្តនៅក្នុង និងក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ វិស័យឯកជន និងសហគមន៍មូលដ្ឋាន ដោយលើកកម្ពស់តួនាទី និងការចូលរួមរបស់បុរស និងស្ត្រីក្នុងការគ្រប់គ្រង និងការប្រើប្រាស់ធនធាន នៅក្នុងតំបន់ទីជម្រាល ។

**មាត្រា៤៣៦**._ គោលការណ៍ទូទៅ

ធ្វើសមាហរណកម្មការងារនៃក្រសួង ស្ថាប័ន និងវិស័យពាក់ព័ន្ធនានា រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន សហគ្រាស សហគមន៍ សមាគម ដៃគូ ឬគម្រោងអភិវឌ្ឍន៍ និងសង្គមស៊ីវិល សំដៅគ្រប់គ្រងតំបន់ទីជម្រាលប្រកបដោយនិរន្តរភាព ។

ធានាឱ្យការងារគ្រប់គ្រងតំបន់ទីជម្រាល ស្ថិតនៅជាផ្នែកមួយនៃការអភិវឌ្ឍ សេដ្ឋកិច្ច សង្គម និងមានលក្ខណៈបត់បែនទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងតំបន់ទីជម្រាលនីមួយៗ ។

ការធ្វើសេចក្តីសម្រេចក្នុងការគ្រប់គ្រងតំបន់ទីជម្រាល ត្រូវធានាឱ្យមានការចូលរួមពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ និងប្រកបដោយសមភាពយេនឌ័រ ។

**មាត្រា៤៣៧**._ ការធ្វើចំណាត់ថ្នាក់តំបន់ទីជម្រាល

ការចាត់ថ្នាក់តំបន់ទីជម្រាល ត្រូវធ្វើឡើងដោយមានការចូលរួមពីក្រសួង ស្ថានប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាន ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានផ្សេងៗ នៅក្នុងតំបន់ទីជម្រាល ។ ការចាត់ថ្នាក់តំបន់ទីជម្រាលត្រូវផ្អែកលើ ៖

១- លក្ខណៈរូបសាស្ត្រ និងស្ថានភាពភូមិសាស្ត្រដី ។

២- កម្រិតជម្រាល រយៈកម្ពស់ ប្រភេទដី ទម្រង់ដី និងហានិភ័យនៃការហូរច្រោះដី ។

៣- បរិមាណ គុណភាព និងកម្រិតលំហូរទឹកនៅគ្រប់ពេល រដូវ ប្រចាំឆ្នាំ ។
៤- បរិមាណ និងគុណភាពព្រៃឈើ និងគម្របរុក្ខជាតិព្រៃផ្សេងៗទៀត ។
៥- ការប្រើប្រាស់ មុខងារ និងសក្តានុពលនៃតំបន់ទីជម្រាល ។
៦- ផ្ទៃអាងរងទឹកភ្លៀងក្នុងតំបន់ទីជម្រាល ។

**មាត្រា៤៣៨ .**_ យន្តការសម្របសម្របសម្រួលគ្រប់គ្រងតំបន់ទីជម្រាលថ្នាក់ជាតិ

យន្តការសម្របសម្របសម្រួលគ្រប់គ្រងតំបន់ទីជម្រាលថ្នាក់ជាតិ ត្រូវបង្កើតឡើងក្នុងទិសដៅសម្របសម្រួលគ្រប់គ្រងលើកិច្ចប្រតិបត្តិការ និងរៀបចំយន្តការ សម្រាប់ការងារគ្រប់គ្រងតំបន់ទីជម្រាល និងផ្ទៃអាងរងទឹកភ្លៀង អាងទន្លេ ដោយមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា៤៣៩ .**_ យន្តការគ្រប់គ្រងតំបន់ទីជម្រាលថ្នាក់ក្រោមជាតិ

យន្តការគ្រប់គ្រងតំបន់ទីជម្រាលថ្នាក់ក្រោមជាតិ ត្រូវបង្កើតឡើងស្របតាមស្ថានភាពជាក់ស្តែងនៃតំបន់ទីជម្រាលនោះដោយមានការចូលរួមពី មន្ទីរ ស្ថាប័ន អង្គភាព និងវិស័យពាក់ព័ន្ធនានា អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ វិស័យឯកជន ដៃគូ ឬគម្រោងអភិវឌ្ឍន៍ សហគមន៍ សមាគម សង្គមស៊ីវិល និងប្រជាជនដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានរស់នៅ ឬមានសកម្មភាពនៅក្នុងតំបន់ទីជម្រាល ។

**មាត្រា៤៤០ .**_ ការប្រតិបត្តិក្នុងការគ្រប់គ្រងតំបន់ទីជម្រាល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានតួនាទី និងភារកិច្ចក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងវិស័យពាក់ព័ន្ធនានារបស់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន ដៃគូ ឬគម្រោងអភិវឌ្ឍន៍ សហគ្រាស សហគមន៍ សមាគម សង្គមស៊ីវិល និងប្រជាជនដែលកំពុងរស់នៅ និងមានសកម្មភាពក្នុងតំបន់ទីជម្រាលនីមួយៗ ។ ផែនការគ្រប់គ្រងតំបន់ទីជម្រាលនីមួយៗ ត្រូវផ្អែកលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការអភិរក្សធនធានធម្មជាតិដែលមានស្រាប់។

ការកំណត់ព្រំប្រទល់តំបន់ទីជម្រាល ត្រូវមានចំណុចសម្គាល់នៅលើទីតាំងជាក់ស្តែង ដោយរៀបចំជាផែនទីដោយមានកំណត់ចំណុចនិយាមកាច្បាស់លាស់ ផ្អែកលើបទដ្ឋានបច្ចេកទេស និងមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ។

**មាត្រា៤៤១ .**_ ផែនការគ្រប់គ្រងព្រៃឈើដែលស្ថិតនៅក្នុងតំបន់ទីជម្រាល

ផែនការគ្រប់គ្រងព្រៃឈើដែលស្ថិតនៅក្នុងតំបន់ទីជម្រាលត្រូវបញ្ជាក់ពី:

១- សកម្មភាពទាំងឡាយដែលបានអនុញ្ញាតកន្លងមក និងមានទីតាំងស្ថិតនៅក្នុង ឬក្បែរតំបន់ទីជម្រាល ។

២- ទំហំ និងបរិមាណនៃការដកហូតផល-អនុផលព្រៃឈើដែលអនុញ្ញាតនៅក្នុងតំបន់ទីជម្រាល ។

៣- ទីតាំងដែលត្រូវស្តារព្រៃឈើឡើងវិញ ដោយការដាំឈើប្រភេទពាណិជ្ជកម្មបញ្ចូលក្នុងព្រៃ ក្រោយអាជីវកម្មប្រមូលផលឈើ ការដាំឈើ និងការដាំឈើឡើងវិញ នៅក្នុងតំបន់ទីជម្រាល ។

**មាត្រា៤៤២ .**_ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព

ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ សម្រាប់គ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវរៀបចំផែនការគ្រប់គ្រងតំបន់ទីជម្រាលដោយមានចែងពីខ្លឹមសារដែលបញ្ជាក់ពីប្រភេទនៃសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលត្រូវបានអនុញ្ញាតនៅតាមផ្នែកនីមួយៗ របស់តំបន់ទីជម្រាល ឱ្យសមស្របតាមលិខិតបទដ្ឋានរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៤៣ .**_ ការអង្កេតតាមដាន ការវាយតម្លៃ និងការធ្វើបច្ចុប្បន្នភាព

ផែនការគ្រប់គ្រងតំបន់ទីជម្រាល ត្រូវមានការអង្កេតតាមដាន និងវាយតម្លៃជាប្រចាំលើការអនុវត្តផែនការទាំងនេះ ដោយប្រើប្រាស់សូចនាករ ដែលមានលក្ខណៈសមស្របសម្រាប់តំបន់ទីជម្រាលនីមួយៗ ។

ការអង្កេតតាមដាន និងវាយតម្លៃផែនការ ត្រូវធ្វើឡើងដោយមានការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងតំបន់ទីជម្រាល ហើយលទ្ធផលនៃការអង្កេតតាមដាន ត្រូវរៀបចំឱ្យបានត្រឹមត្រូវ និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងនោះ ។

ផែនការគ្រប់គ្រងតំបន់ទីជម្រាល ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយឈរលើមូលដ្ឋាន នៃលទ្ធផលនៃការអង្កេតតាមដាន និងវាយតម្លៃផែនការទាំងនោះ ។

## មាតិកាទី៦
## ការគ្រប់គ្រង ការការពារ និងការអភិរក្សសត្វព្រៃ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៤៤៤** ._ សត្វព្រៃ

សត្វព្រៃ សំដៅដល់ពពួកសត្វព្រៃ នៃព្រះរាជាណាចក្រកម្ពុជា ទោះបីមានដើមកំណើតក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ។

សត្វព្រៃគ្រប់ប្រភេទ ជាសមាសភាគនៃធនធានធម្មជាតិ និងជាសម្បត្តិរដ្ឋ ។

**មាត្រា៤៤៥** ._ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានតួនាទី និងការទទួលខុសត្រូវរួមក្នុងការគ្រប់គ្រង ការការពារ និងការអភិរក្ស សត្វព្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ តួនាទី និងការទទួលខុសត្រូវនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៤៤៦** ._ ភារកិច្ចរបស់ក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចដូចតទៅ ៖

១- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធី គ្រប់គ្រង ការការពារ និងការអភិរក្សសត្វព្រៃ ។

២- បង្កើតនិងអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការគ្រប់គ្រង និងផែនការសកម្មភាពអភិរក្សប្រភេទសត្វព្រៃ ដែលទទួលរងការគំរាមកំហែង ស្របតាមលិខិតបទដ្ឋានគតិយុត្ត ឬអនុសញ្ញាអន្តរជាតិ ។

៣- តាមដាន ស្រាវជ្រាវ ទប់ស្កាត់បទល្មើសសត្វព្រៃគ្រប់ប្រភេទ ទាំងនៅក្នុង និងក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ រួមទាំងការនាំចេញ ការនាំចូល ការធ្វើសន្និធិ ការចរាចរ ការធ្វើអាជីវកម្ម ការប្រើប្រាស់សត្វព្រៃ និងការបរិភោគសាច់សត្វព្រៃ ដែលត្រូវបានប្រមូលផលដោយគ្មានលិខិតអនុញ្ញាត ។

៤- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា ស៊ើបអង្កេតតាមដាន ត្រួតពិនិត្យ និងចងក្រងសំណុំរឿង បទល្មើសសត្វព្រៃ តាមនីតិវិធី និងលិខិតបទដ្ឋានគតិយុត្ត ។

៥- បង្កើត គ្រប់គ្រង និងរក្សាប្រព័ន្ធទិន្នន័យ ពាក់ព័ន្ធនឹងបទល្មើសសត្វព្រៃ ។

៦- ពង្រឹងយន្តការមានស្រាប់ដើម្បីទប់ស្កាត់ការជួញដូរសត្វព្រៃ និង បង្កើតវិធីសាស្ត្រថ្មីបន្ថែមទៀត សម្រាប់ប្រយុទ្ធប្រឆាំងនឹងបទល្មើសសត្វព្រៃឆ្លងដែន ឬប្រើប្រាស់ព្រះរាជាណាចក្រកម្ពុជាជាគោលដៅ ឆ្លងកាត់ទៅកាន់ប្រទេសដទៃទៀត ។

៧- ធ្វើបច្ចុប្បន្នភាព ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ។

៨- បង្កើត និងអនុវត្ត កម្មវិធីការពារ អភិរក្ស ពិនិត្យតាមដាន និងស្រាវជ្រាវសត្វព្រៃ ដែលជាប្រភេទទទួលរងការគំរាមកំហែង ។

៩- រៀបចំលិខិត បទដ្ឋានគតិយុត្ត ការងារគ្រប់គ្រង និងការចេញលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ សម្រាប់ជនជាតិដើមភាគតិច ឬសហគមន៍មូលដ្ឋាន ដែលរស់នៅក្នុង ឬ ក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ។

១០- ពិនិត្យឡើងវិញ បដិសេធ ឬអនុញ្ញាត ការប្រមាញ់សត្វព្រៃ តាមលក្ខខណ្ឌដូចមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ។

១១- ត្រួតពិនិត្យ តាមដាន និង/ឬចេញបទបញ្ជា ប្រតិបត្តិការនៅឧទ្យានសត្វព្រៃ មជ្ឈមណ្ឌលបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះ និងផ្តល់នីតិសម្បទាដល់សត្វព្រៃ និងកន្លែងប្រមូលផលសត្វព្រៃដើម្បីធ្វើអាជីវកម្ម ។

១២- ពិនិត្យឡើងវិញ បដិសេធ ឬ អនុញ្ញាត សំណើចាប់សត្វព្រៃរស់ សម្រាប់គោលបំណងបង្កាត់ពូជដើម្បីអភិរក្ស ។

១៣- ធានាថា លិខិតអនុញ្ញាតទាំងអស់ និងរាល់ដំណើរការផ្តល់លិខិតអនុញ្ញាត ត្រូវមានតម្លាភាព និងត្រូវបានផ្សព្វផ្សាយជូនដល់សាធារណជន ។

១៤- អភិវឌ្ឍយុទ្ធសាស្ត្រតាមដាន និងថែទាំសុខភាពសត្វព្រៃ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងសម្របសម្រួលឱ្យមានការឆ្លើយតប ចំពោះករណីជំងឺរាតត្បាត ជំងឺឆ្លង និងសុខភាពសត្វព្រៃ ។

១៥- អាចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អ្នកពាក់ព័ន្ធ និងចូលរួមនៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

១៦- លើកកម្ពស់ការអប់រំជាសាធារណៈ និងកម្មវិធីផ្សព្វផ្សាយ ដែលបង្ហាញពីសារៈសំខាន់នៃការគ្រប់គ្រង ការការពារ និងការអភិរក្ស សត្វព្រៃដោយនិរន្តរភាព ។

១៧- ត្រូវហាមឃាត់ចំពោះការបំផ្លាញ ឬការកែប្រែទីជម្រកធម្មជាតិរបស់ប្រភេទសត្វព្រៃ ដោយគ្មានការអនុញ្ញាត ។

**មាត្រា៤៤៧**._ ភារកិច្ច អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ

ភារកិច្ចរបស់អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី២
## ការធ្វើចំណាត់ថ្នាក់ប្រភេទសត្វព្រៃ

**មាត្រា៤៤៨**._ បញ្ជីប្រភេទសត្វព្រៃដែលទទួលរងការគំរាមកំហែង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំ រក្សា កំណត់ត្រា ឬធ្វើបច្ចុប្បន្នភាព បញ្ជីស្ដីពីប្រភេទសត្វព្រៃដែលទទួលរងការគំរាមកំហែង ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា៤៤៩**._ ការចាត់ថ្នាក់ ប្រភេទសត្វព្រៃ

ការចាត់ថ្នាក់ ប្រភេទសត្វព្រៃ ត្រូវផ្អែកតាមស្ថានភាពជាក់ស្ដែង និងលក្ខណៈជីវសាស្ត្រប្រភេទសត្វព្រៃ ដោយត្រូវមានលក្ខណៈវិនិច្ឆ័យ ស្របតាមលិខិតបទដ្ឋានគតិយុត្ត ។ ចំណាត់ថ្នាក់ប្រភេទសត្វព្រៃមាន ៖

១- ចំណាត់ថ្នាក់ទី ១ ៖ គ្រប់ប្រភេទសត្វព្រៃទាំងអស់ ដែលជាប្រភេទផុតពូជពីក្នុងធម្មជាតិ ជិតផុតពូជ ឬកំពុងរងគ្រោះថ្នាក់ ។

២- ចំណាត់ថ្នាក់ទី ២ ៖ គ្រប់ប្រភេទសត្វព្រៃទាំងអស់ ដែលជាប្រភេទងាយរងគ្រោះថ្នាក់ ប្រភេទជិតទទួលរងការគំរាមកំហែង ។

៣- ចំណាត់ថ្នាក់ទី ៣ ៖ គ្រប់ប្រភេទសត្វព្រៃទាំងអស់ ដែលមានដោយសម្បូរបង្គួរ ។

៤- ចំណាត់ថ្នាក់ទី ៤ ៖ គ្រប់ប្រភេទសត្វព្រៃទាំងអស់ ដែលពុំទាន់ចាត់ថ្នាក់ ។

ប្រភេទសត្វព្រៃដែលត្រូវដាក់បញ្ចូលក្នុងចំណាត់ថ្នាក់ណាមួយ អាចពិភាក្សាជាមួយដៃគូ ឬអ្នកពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៤៥០** ._ ការធ្វើបច្ចុប្បន្នភាពទៅលើបញ្ជី សម្រាប់ប្រភេទសត្វ

បញ្ជីប្រភេទសត្វព្រៃ ត្រូវធ្វើបច្ចុប្បន្នភាព ក្នុងករណីមានប្រភេទសត្វព្រៃ ដែលត្រូវបានរកឃើញក្នុងព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើស្ថានភាពជាក់ស្តែង លក្ខណៈជីវសាស្ត្រ និងលក្ខណៈវិនិច្ឆ័យ ស្របតាមលិខិតបទដ្ឋានគតិយុត្ត និង/ឬអនុសញ្ញាអន្តរជាតិ ។

**មាត្រា៤៥១** ._ ការស្នើសុំធ្វើបច្ចុប្បន្នភាព

រូបវន្តបុគ្គល ឬនីតិបុគ្គលអាចដាក់ពាក្យស្នើសុំទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីពិគ្រោះយោបល់ក្នុងការពិនិត្យ លើកសំណើសុំធ្វើបច្ចុប្បន្នភាពបញ្ជី និង/ឬចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ។

នីតិវិធីនៃការស្នើសុំការពិនិត្យ និងសម្រេចទៅលើការស្នើសុំ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៥២** ._ ការផ្លាស់ប្តូរចំណាត់ថ្នាក់ ប្រភេទសត្វព្រៃ

សត្វព្រៃគ្រប់ប្រភេទ អាចត្រូវធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ៖

១- កម្រិតហានិភ័យនៃការគំរាមកំហែងខ្ពស់ដល់បរិមាណនៃពពួកសត្វ ព្រៃទាំងនោះ ។

២- ស្ថានភាពជាក់ស្តែង និងលក្ខណៈវិនិច្ឆ័យនៃពពួកសត្វ ដែលកំពុងរងគ្រោះថ្នាក់ឈានទៅរកការផុតពូជ ឬជិតផុតពូជ ។

៣- មានតម្លៃបេតិកភណ្ឌវប្បធម៌ ប្រព័ន្ធអេកូឡូស៊ី ឬសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ។

## ជំពូកទី៣
## ការហាមឃាត់ចំពោះការបរបាញ់សត្វព្រៃ

**មាត្រា៤៥៣**._ ការហាមឃាត់ទូទៅ

រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវបានហាមឃាត់ការបរបាញ់ ការទាក់ ការដាក់អន្ទាក់ ការចាប់ ការបំពុល ការសម្លាប់ សត្វព្រៃ នៅលើដីឯកជន នៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចខាងក្រោម ៖

១- ចំពោះប្រភេទសត្វព្រៃ ដូចមានចែងក្នុងចំណាត់ថ្នាក់ទី១ និងចំណាត់ថ្នាក់ទី២ លើកលែងតែករណី ដូចបានកំណត់ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

២- ប្រភេទសត្វព្រៃ ដូចមានចែងក្នុងចំណាត់ថ្នាក់ទី៣ ដោយប្រើមធ្យោបាយដែលត្រូវបានហាមឃាត់ដោយច្បាប់ ។

៣- លើកលែងប្រភេទសត្វព្រៃដូចបានកំណត់នៅក្នុងចំណាត់ថ្នាក់ទី៣ ដែលស្ថិតនៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលប្រើប្រាស់ដោយសហគមន៍មូលដ្ឋានជាលក្ខណៈគ្រួសារ និងប្រពៃណី ដោយមានលិខិតអនុញ្ញាតមានសុពលភាព ស្របតាមក្រមនេះ ។

រូបវន្តបុគ្គល ឬនីតិបុគ្គល ហាមផលិត ធ្វើជាម្ចាស់ កែច្នៃ ទិញ ជួញដូរ ដឹកជញ្ជូន ដាក់អន្ទាក់ អង្គប់ និងសំណាញ់នៅជាប់នឹងដី ឬលើអាកាស ប្រើអាវុធកែច្នៃ ថ្នាំពុល និងមធ្យោបាយផ្សេងទៀត ដែលត្រូវបានហាមឃាត់ដោយច្បាប់ ។

រូបវន្តបុគ្គល ឬនីតិបុគ្គល ហាមបរបាញ់ តាមចាប់ ឬរំខានសត្វព្រៃដោយប្រើយានយន្តគ្រប់ប្រភេទ មិនថាលើទឹក លើដី ឬលើអាកាស ។

**មាត្រា៤៥៤**._ ការហាមឃាត់ការបរបាញ់ ការទាក់ ការចាប់ ការបំពុល និងការសម្លាប់សត្វព្រៃ ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ

ការបរបាញ់ ការទាក់ ការចាប់ ការបំពុល និងការសម្លាប់សត្វព្រៃ ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានហាមឃាត់ ដូចខាងក្រោម ៖

១- ចំពោះប្រភេទសត្វព្រៃដូចមានចែងក្នុងចំណាត់ថ្នាក់ទី១ និងចំណាត់ថ្នាក់ទី២ ។

២- ចំពោះប្រភេទសត្វព្រៃ ដូចមានចែងក្នុងចំណាត់ថ្នាក់ទី៣ ដោយប្រើមធ្យោបាយដែលត្រូវបានហាមឃាត់ដោយច្បាប់ ។

៣- ការបរបាញ់ដោយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដោយពុំមានលិខិតអនុញ្ញាតកំណត់កូតាឱ្យបរបាញ់ ដែលកំណត់ដោយ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

៤- ការកាន់កាប់ ផលិត រក្សាទុក ដឹកជញ្ជូន ឬនាំយក ឧបករណ៍ ដែលអាចប្រើប្រាស់សម្រាប់បរបាញ់សត្វព្រៃ តាមមធ្យោបាយគ្រប់រូបភាព ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ មានជាអាទិ៍ អន្ទាក់ អង្គប់ កាំភ្លើង ឬអាវុធកែច្នៃ ខ្សែលួស ខ្សែប្រៅ្យាំងកង់ ឬខ្សែប្រៅ្យាំងម៉ូតូ ឧបករណ៍ឆក់ សំណាញ់ ឬឧបករណ៍ផ្សេងទៀត ។

៥-រូបវន្តបុគ្គល ឬនីតិបុគ្គល ដឹកជញ្ជូន ឬយកធ្វើជាកម្មសិទ្ធិ ចំពោះសត្វព្រៃក្នុងចំណាត់ថ្នាក់ទី៤ ដោយគ្មានលិខិតអនុញ្ញាតបរបាញ់ និងគ្មានលិខិតអនុញ្ញាតដឹកជញ្ជូន ។

៦-ទាក់ចាប់ ប្រមូល ទិញ សត្វព្រៃដោយខុសច្បាប់ពីក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ សម្រាប់គោលដៅបង្កើត ឬរក្សាទុកក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ គ្រឹះស្ថានឧទ្យានសត្វព្រៃ ការចាប់ប្រមូលមករក្សាទុកជាឯកជន ។

៧-លើកលែងការ យកសត្វព្រៃសម្រាប់គោលដៅបង្កើត ឬរក្សាទុកក្នុងកន្លែង បង្កាត់ពូជអភិរក្ស ដែលត្រូវបានអនុញ្ញាតដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ។

៨- សត្វឆ្កែ សត្វចិញ្ចឹម ចូលទៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

## ជំពូកទី៤
## ករណីលើកលែងសម្រាប់ការបរបាញ់សត្វព្រៃ
## ផ្នែកទី១
## ការគ្រប់គ្រងលើការបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស

**មាត្រា៤៥៥ .**_ ការកំណត់ការគ្រប់គ្រងលើការបង្កគ្រោះដល់ជីវិតមនុស្ស

ក្នុងករណីសត្វព្រៃ បង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចចាត់វិធានការសមស្រប ក្នុងករណីចាំបាច់អាចសម្លាប់សត្វព្រៃដែលបង្កហេតុនោះ ។

**មាត្រា៤៥៦ .**_ សេចក្តីសម្រេច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ  ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការត្រួតពិនិត្យសត្វព្រៃដែលបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស ដោយធ្វើការពិចារណាទៅលើសុវត្ថិភាព សុខុមាលភាពសត្វព្រៃ និងតម្លៃ សត្វព្រៃសម្រាប់ការអភិរក្ស ។

**មាត្រា៤៥៧ .**_ វិធីសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំវិធីសាស្ត្រក្នុងការគ្រប់គ្រងប្រភេទសត្វព្រៃបង្កគ្រោះថ្នាក់ ស្របតាមលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាដល់សុខុមាលភាពរបស់សត្វព្រៃ និងការកាត់បន្ថយហានិភ័យទៅលើសត្វព្រៃដទៃទៀត ឬជីវិតមនុស្ស ។

**មាត្រា៤៥៨ .**_ កាតព្វកិច្ចក្នុងការសម្លាប់ ឬបំផ្លាញចោលសត្វព្រៃ

សត្វព្រៃ ដែលបានបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិតមនុស្ស ត្រូវបានអនុញ្ញាតឱ្យសម្លាប់ ឬធ្វើឱ្យរបួស  ករណីសត្វរងរបួសមិនអាចជាសះស្បើយវិញបាន ត្រូវទុកជាទ្រព្យសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញ ឬសម្លាប់ ស្របតាមលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៤៥៩ .**_ ប្រភេទសត្វក្នុងចំណាត់ថ្នាក់ទី១ និងចំណាត់ថ្នាក់ទី២

ការគ្រប់គ្រង ប្រភេទសត្វព្រៃ ស្ថិតនៅក្នុងចំណាត់ថ្នាក់ទី១ ឬចំណាត់ថ្នាក់ទី២ ដែលអាចបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៦០ .**_ ប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី៣ និងចំណាត់ថ្នាក់ទី៤

ការគ្រប់គ្រងប្រភេទសត្វព្រៃស្ថិតនៅក្នុង ចំណាត់ថ្នាក់ទី៣ ឬចំណាត់ថ្នាក់ទី៤ ដែលអាចបង្កគ្រោះថ្នាក់ ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័ន អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៦១ .**_ ប្រភេទសត្វព្រៃដែលមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ប្រភេទសត្វព្រៃ ស្ថិតនៅក្នុងចំណាត់ថ្នាក់ទី១ ឬចំណាត់ថ្នាក់ទី២ និងមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា  ដែលអាចបង្កគ្រោះថ្នាក់ ឬរាតត្បាតដល់ជីវៈចម្រុះ ត្រូវធ្វើការគ្រប់គ្រងទាំងនៅក្នុង ឬក្រៅតំបន់នៃប្រព័ន្ធតំបន់ការពារធម្មជាតិ ឬដីឯកជន ហើយក្នុងករណីមានសកម្មភាពបង្កគ្រោះថ្នាក់នៅក្រោមផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៦២ .**_ ការចាប់សត្វព្រៃរស់សម្រាប់គោលដៅអភិរក្ស

ការចាប់សត្វព្រៃ រស់តាមប្រភេទដូចបានកំណត់ក្នុងចំណាត់ថ្នាក់ណាមួយ នៃបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ សម្រាប់គោលដៅបង្កាត់ពូជ អភិរក្ស ឬការគ្រប់គ្រងលើការងារអភិរក្ស ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ពាក្យស្នើសុំការអនុញ្ញាត ត្រូវបង្ហាញពីសារៈប្រយោជន៍ និងត្រូវអនុវត្តតាមនីតិវិធី ដោយត្រូវគិតពីសុខុមាលភាព ការចាប់ ការដឹកជញ្ជូន និងការចិញ្ចឹម ។

**មាត្រា៤៦៣ .**_ ការគ្រប់គ្រងលើការងារអភិរក្ស

ការគ្រប់គ្រងលើការងារអភិរក្ស មាន ៖

១- ការប្តូរទីកន្លែងសម្រាប់សត្វព្រៃប្រភេទណាមួយទៅរកទីជម្រកសមស្រប ក្នុងគោលបំណងស្តារសត្វព្រៃប្រភេទនោះឡើងវិញ ការដាក់ចិញ្ចឹមឡើងវិញ ឬការបំពេញបន្ថែមនូវក្រុមសត្វព្រៃ ឬដើម្បីទប់ស្កាត់ការវិនាសផុតពូជ ដែលមិនអាចជៀសវាងបាននៃក្រុមសត្វព្រៃទាំងនោះ ។

២- ការស្រាវជ្រាវ ឬការគ្រប់គ្រងក្រុមភាវរស់ ដោយពុំចាំបាច់សម្លាប់ ឬបំផ្លាញសត្វព្រៃ ។

៣- ការចាប់សត្វព្រៃសម្រាប់គោលដៅ ធ្វើឱ្យមានលំនឹង និងបង្កាត់ពូជដើម្បីអភិរក្សប្រភេទសត្វដែលទទួលរងការគំរាមកំហែង នៅក្នុងកន្លែងបង្កាត់ពូជ ដើម្បីអភិរក្ស ដែលបានចុះបញ្ជី ។

**មាត្រា៤៦៤ .**_ ការបន្លាស់ទីកន្លែង

ការបន្លាស់ទីកន្លែង និងការចាប់សត្វព្រៃសម្រាប់ការបង្កាត់ពូជដើម្បីអភិរក្ស ឬគ្រប់គ្រងលើការងារអភិរក្សប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី១ ឬចំណាត់ថ្នាក់ទី២អាចអនុញ្ញាតដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយស្របជាមួយផែនការគ្រប់គ្រង និងស្តារប្រភេទសត្វព្រៃ ។

**មាត្រា៤៦៥ .**_ ការបង្ខាំងសត្វព្រៃ និងការអង្កេតតាមដានពីសុខភាព

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវត្រួតពិនិត្យសត្វព្រៃ ក្នុងពេលធ្វើការបង្ខាំងសត្វព្រៃ និងការអង្កេតតាមដានពីសុខភាព ក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ នៅមុនពេលដែលសត្វព្រៃទាំងនោះត្រូវ បានប្តូរទីតាំង ឬនាំមកបញ្ចូល ឬផ្ទេររវាងទីបង្ខាំង និងជម្រកធម្មជាតិ ឬរវាង

កសិដ្ឋានចិញ្ចឹមសត្វព្រៃ កន្លែងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ ។ ក្រោយពីការធ្វើការបង្ខាំងសត្វព្រៃ និងការអង្កេតតាមដានពីសុខភាព ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការបញ្ជាក់ ដូចខាងក្រោម ៖

១- សត្វព្រៃត្រូវបានធ្វើការបង្ខាំង និងការអង្កេតតាមដានពីសុខភាព មិនឱ្យលើសពី១៤ (ដប់បួន) ថ្ងៃ និងត្រូវពិនិត្យនៅមុនពេលប្តូរទីតាំង នាំចូលទៅវិញ ឬផ្ទេរ ។

២- សត្វព្រៃនោះមិនបង្ហាញពីរោគសញ្ញាជំងឺ ឬមានរបួស ។

៣- សត្វព្រៃនោះត្រូវមានស្លាកសម្គាល់ ខុសគ្នារវាងសត្វដែលមានសុខភាពល្អ និងសត្វដែលមានជំងឺ ។

៤- សត្វព្រៃនោះត្រូវបានពិនិត្យសុខភាព ហើយឃើញថា មិនមានជំងឺដែលគួរឱ្យកត់សម្គាល់ណាមួយទេ ។

៥- ត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ ក្រសួង ស្ថាប័ន អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្នុងករណីដែលសត្វព្រៃនោះបាន ឆ្លងជំងឺ ឬស្លាប់ នៅក្នុងដំណើរការនៃការធ្វើចត្តាឡីស័ក ។

**មាត្រា៤៦៦** ._ វិធីសាស្ត្រអង្កេតតាមដានសុខភាពសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវ ៖

១- កំណត់អត្តសញ្ញាណជំងឺសត្វព្រៃ និងត្រូវផ្សព្វផ្សាយជាសាធារណៈអំពីជំងឺដែលបានរកឃើញ ។

២- រៀបចំវិធីសាស្ត្រអង្កេតតាមដានសុខភាព និងជំងឺសត្វព្រៃ ។

៣- ស៊ើបអង្កេត ចងក្រងឯកសារ និងឆ្លើយតបចំពោះការរាតត្បាតនៃជំងឺសត្វព្រៃ ។

៤- រាយការណ៍ឱ្យបានទាន់ពេលវេលាអំពីលទ្ធផលនៃសិក្សា ការអង្កេតតាមដានសុខភាពសត្វព្រៃ និងការស៊ើបអង្កេតជំងឺសត្វព្រៃ ។

**មាត្រា៤៦៧** ._ ការតាមដានសុខភាពសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចតម្រូវឱ្យអ្នកកាន់កាប់លិខិតអនុញ្ញាតបរបាញ់ ប្រមូល ទិញសត្វព្រៃ ប្រគល់នូវសំណាកសត្វព្រៃដែលបរបាញ់ ឬប្រមូលបានដើម្បី

ធ្វើការអង្កេតតាមដានពីសុខភាពសត្វព្រៃ ។

## ផ្នែកទី២
## គ្រឹះស្ថានឧទ្យានសត្វព្រៃ

**មាត្រា៤៦៨ .**_ លក្ខខណ្ឌតម្រូវ

គ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវស្នើសុំអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត សម្រាប់ការបង្កើតគ្រឹះស្ថានឧទ្យានសត្វព្រៃ និងការនាំចូល ការនាំចេញសត្វព្រៃ របស់គ្រឹះស្ថានឧទ្យានសត្វព្រៃ ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

តារាងតម្លៃ អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត យោងតាមចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងអាចពិគ្រោះយោបល់ ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ។ ប្រាក់ចំណូលដែលប្រមូលបានពីការ ចេញអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាត សម្រាប់ប្រើប្រាស់ គាំទ្រដល់ការអភិរក្សសត្វព្រៃ និងជីវៈចម្រុះ រួមទាំងការអនុវត្តផែនការស្តារ និងគ្រប់គ្រងសត្វព្រៃ ឬការប្រើប្រាស់ដទៃទៀត ត្រូវមានគោលដៅអភិរក្ស ។

**មាត្រា៤៦៩ .**_ ការហាមឃាត់

ត្រូវហាមឃាត់ចំពោះការបរបាញ់ ការទាក់ ការចាប់ ការបំពុល ឬការប្រមូលសត្វព្រៃ ពីព្រៃធម្មជាតិ នូវប្រភេទ ដូចបានកំណត់ក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ នៃបញ្ជីចំណាត់ថ្នាក់សត្វព្រៃ សម្រាប់បម្រើឱ្យគ្រឹះស្ថានឧទ្យានសត្វព្រៃ លើកលែងមានការអនុញ្ញាតពិសេសពីរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា៤៧០ .**_ ការស្នើសុំ

ការស្នើសុំការប្រមូល ការទាក់ ការចាប់សត្វព្រៃ តាមប្រភេទដូចបានកំណត់ ក្នុងបញ្ជីចំណាត់ថ្នាក់ទី៣ ចំណាត់ថ្នាក់ទី៤ សម្រាប់គោលដៅរបស់គ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៧១ .**_ ការផ្តល់ និងការផ្អាកបណ្តោះអាសន្ននៃលិខិតអនុញ្ញាត

ក្រសួង ស្ថានប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចផ្តល់ លិខិតអនុញ្ញាត ឱ្យគ្រឹះស្ថានឧទ្យានសត្វព្រៃ ធ្វើអាជីវកម្មសត្វព្រៃ ស្របតាមនីតិវិធី លិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

ការផ្អាកបណ្តោះអាសន្ន ឬបិទទីតាំង ឬប្រមូលដកហូតសត្វព្រៃ ក្នុងបរិវេណ និងក្នុងគ្រឹះស្ថានឧទ្យានសត្វព្រៃ ក្នុងករណីដែលប្រតិបត្តិករ ឬម្ចាស់គ្រឹះស្ថានឧទ្យាន សត្វព្រៃមិនអនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី៥
## លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ

**មាត្រា៤៧២** ._ លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ

ការបរបាញ់សត្វព្រៃដូចបានកំណត់នៅក្នុងបញ្ជីចំណាត់ថ្នាក់ទី៣ ចំណាត់ថ្នាក់ទី៤ ត្រូវហាមឃាត់ ប្រសិនបើគ្មានលិខិតអនុញ្ញាត ។

លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ អាចអនុញ្ញាតបានតែនៅតាមតំបន់ជាក់លាក់ណាមួយ ដូចជាតំបន់សហគមន៍មូលដ្ឋាន តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់គ្រប់គ្រងរួមគ្នា នៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

**មាត្រា៤៧៣** ._ កាតព្វកិច្ចនៃការបរបាញ់

អ្នកបរបាញ់ ត្រូវយកលិខិតអនុញ្ញាតបរបាញ់តាមខ្លួនជានិច្ច និងបង្ហាញលិខិតអនុញ្ញាតបរបាញ់ដល់អាជ្ញាធរមានសមត្ថកិច្ច មុនចូលក្នុងតំបន់អនុញ្ញាតឱ្យបរបាញ់ ។

ក្រសួង ស្ថាប័នអង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចតម្រូវឱ្យអ្នកកាន់កាប់លិខិតអនុញ្ញាតបរបាញ់ ផ្តល់គំរូសំណាក ឬផ្នែកណាមួយនៃសត្វព្រៃដែលបាញ់បាន ក្នុងគោលបំណងសិក្សាស្រាវជ្រាវ ឬអង្កេតតាមដានសុខភាពសត្វព្រៃ ដោយគ្មានសំណងលើការយក ឬផ្តល់គំរូសំណាកផ្នែកណាមួយនៃសត្វព្រៃនោះ ។

**មាត្រា៤៧៤ ._** ការដាក់ពាក្យស្នើសុំ

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងស្នើសុំលិខិតអនុញ្ញាតបរបាញ់ ត្រូវដាក់ពាក្យស្នើសុំទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ពាក្យស្នើសុំលិខិតអនុញ្ញាតបរបាញ់នៅក្នុងតំបន់សហគមន៍មូលដ្ឋាន តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់គ្រប់គ្រងរួមគ្នា នៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានត្រួតពិនិត្យ និងផ្តល់ការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ពាក្យស្នើសុំលិខិតអនុញ្ញាតបរបាញ់នៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានត្រួតពិនិត្យ និងផ្តល់ការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៧៥ ._** ការចេញលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ រៀបចំបង្កើតទម្រង់បែបបទ នៃការស្នើសុំលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ និងផ្តល់លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ ។

ការផ្តល់ ការដកហូត ឬមោឃភាពនៃលិខិតអនុញ្ញាតបរបាញ់សត្វ ត្រូវធ្វើឡើង ដូចខាងក្រោម ៖

១- ត្រូវផ្តល់លិខិតអនុញ្ញាត ដោយមានតម្លាភាព ។

២- អាចផ្តល់ លិខិតអនុញ្ញាតបានតែមួយ ចំពោះ មួយគ្រួសារ ឬមួយក្រុម ។

៣- មិនផ្តល់លិខិតអនុញ្ញាត ដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានប្រវត្តិពាក់ព័ន្ធនឹងការបរបាញ់ខុសច្បាប់កន្លងមក ។

៤- ហាមឃាត់ការផ្ទេរលិខិតអនុញ្ញាត ឬលក់សិទ្ធិបរបាញ់សត្វព្រៃ ពីបុគ្គលម្នាក់ ទៅបុគ្គលម្នាក់ផ្សេងទៀត ។

៥- មានសុពលភាពមិនលើសពី៣ (បី) ខែ ចំពោះលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ ។ អ្នកបរបាញ់អាចស្នើសុំបន្តលិខិតអនុញ្ញាតបរបាញ់ សត្វព្រៃ ដោយភ្ជាប់ជាមួយលិខិតអនុញ្ញាតដែលហួសសុពលភាព ។

ក្នុងករណីបាត់លិខិតអនុញ្ញាត អ្នកកាន់កាប់លិខិតអនុញ្ញាតត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៧៦ ._** ការដកហូត និងការផ្អាកលិខិតអនុញ្ញាតបរបាញ់

អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចផ្អាក ឬដកហូតលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ ចំពោះការប្រព្រឹត្តល្មើសផ្ទុយពីសិទ្ធិ ដែលបានអនុញ្ញាត ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៤៧៧ ._** ប្រព័ន្ធគ្រប់គ្រងទិន្នន័យ

អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ គណៈកម្មការគ្រប់គ្រងរួមគ្នា និងនាយកតំបន់ការពារធម្មជាតិ ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ និងអ្នកបរបាញ់ ក្នុងគោលដៅអង្កេត តាមដាន ត្រួតពិនិត្យ និងនិយ័តកម្មទៅលើសកម្មភាពបរបាញ់សត្វព្រៃ ។

ឯកសារថតចម្លងប្រព័ន្ធគ្រប់គ្រងទិន្នន័យត្រូវផ្ញើជូន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ រៀងរាល់៦ (ប្រាំមួយ) ខែ ម្តង ។

ព័ត៌មានប្រព័ន្ធគ្រប់គ្រងទិន្នន័យ អាចអនុញ្ញាតឱ្យសាធារណជនរកបាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី៦
## ការហាមឃាត់ ការធ្វើអាជីវកម្ម ការជួញដូរ ការធ្វើពាណិជ្ជកម្មសត្វព្រៃដែលបរបាញ់បាន បំណែកសរីរាង្គសត្វព្រៃ ឬផលិតផលពីសត្វព្រៃគ្រប់ប្រភេទ

**មាត្រា៤៧៨ ._** សកម្មភាពហាមឃាត់

ហាមឃាត់ការជួញដូរ ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំចេញបន្ត ការកាន់កាប់ ការលក់ ការទិញ ការផ្ទេរ ការធ្វើសន្និធិ ការផ្តល់ជាអំណោយ ការបរិភោគ ការចិញ្ចឹម និងការប្រើប្រាស់តាមរូបភាពពាណិជ្ជកម្ម នូវបំណែកសរីរាង្គសត្វព្រៃ និងផលិតផលពីសត្វព្រៃគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាត ។

ហាមឃាត់រាល់ការផ្តល់ព័ត៌មានផ្សព្វផ្សាយ ឬការផ្សព្វផ្សាយ សម្រាប់លក់សត្វព្រៃ វត្ថុតាំងលម្អបំណែកសរីរាង្គសត្វព្រៃ សាច់សត្វព្រៃ ឬផលិតផលពីសត្វព្រៃ គ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាត ។

ការផលិតផលិតផលក្លែងក្លាយ ដែលមានការផ្សព្វផ្សាយថាជាផលិតផលពីសត្វព្រៃ ឬបំណែកសរីរាង្គសត្វ ត្រូវចាត់ទុកជាបទល្មើស ដូចគ្នានឹងបទល្មើសដែលពាក់ព័ន្ធនឹងសត្វព្រៃ និងបំណែកសរីរាង្គសត្វព្រៃពិតប្រាកដផងដែរ ។

**មាត្រា៤៧៩ ._** ការហាមឃាត់សកម្មភាពចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវបានអនុញ្ញាតឱ្យទិញ ទទួល ឬធ្វើលទ្ធកម្មសត្វព្រៃរស់ ឬសត្វព្រៃស្លាប់ បំណែកសរីរាង្គសត្វព្រៃ ឬសាច់សត្វព្រៃគ្រប់ប្រភេទ លើកលែងតែមានការអនុញ្ញាត ។

បំណែកសរីរាង្គសត្វព្រៃ សំដៅដល់ផ្នែក ឬសមាសធាតុ ឬផលិតផលណាមួយនៃសត្វព្រៃ ទោះជាសត្វព្រៃចិញ្ចឹម ឬនៅក្នុងព្រៃ រួមទាំងការប្រើប្រាស់បំណែកសរីរាង្គ សំណាក ឬផ្នែកទាំងមូលនៃសត្វព្រៃ ។

**មាត្រា៤៨០ ._** ការធ្វើពាណិជ្ជកម្មក្នុងស្រុក

ត្រូវហាមឃាត់រាល់ការធ្វើពាណិជ្ជកម្មក្នុងស្រុកទៅលើប្រភេទសត្វព្រៃ ដូចមានក្នុងបញ្ជីចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ចំណាត់ថ្នាក់ទី៣ លើកលែងតែការធ្វើពាណិជ្ជកម្មសត្វព្រៃ ដែលមានប្រភពចេញពីកសិដ្ឋានចិញ្ចឹមសត្វព្រៃ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ៖

១- ការផលិតនូវផលិតផលដែលមានវត្ថុធាតុនៃសំណាកប្រភេទសត្វព្រៃ ចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ឬចំណាត់ថ្នាក់ទី៣ ។

២- ដាក់លក់ ឬផ្សព្វផ្សាយដើម្បីលក់ទំនិញ ណាមួយដែលមានវត្ថុធាតុ នៃសំណាកប្រភេទសត្វព្រៃ នៃចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ឬចំណាត់ថ្នាក់ទី៣ ។

៣- ផ្តល់សេវាផលិតសត្វព្រៃសិប្បនិម្មិត ដែលមានវត្ថុធាតុ នៃសំណាកប្រភេទសត្វព្រៃ ចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ឬចំណាត់ថ្នាក់ទី៣ ។

៤- ទិញ ទទួល យកមកធ្វើជាកម្មសិទ្ធិ កាន់កាប់ ចម្អិន ឬលក់សាច់សត្វព្រៃ នៃចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ឬចំណាត់ថ្នាក់ទី៣ លើកលែងតែចំពោះកសិដ្ឋានចិញ្ចឹមសត្វព្រៃដែលត្រូវបានអនុញ្ញាត មានសុពលភាពដែលអនុញ្ញាតឱ្យលក់សាច់សត្វព្រៃ ចិញ្ចឹមក្នុងកសិដ្ឋានដែលមានក្នុងបញ្ជីចំណាត់ថ្នាក់ទី៣ ឬចំណាត់ថ្នាក់ទី៤ ប៉ុណ្ណោះ ។

៥- ធ្វើសកម្មភាពទាំងឡាយ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់សំណាកប្រភេទសត្វព្រៃ ដែលហាមឃាត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៨១ ._** លិខិតអនុញ្ញាតសម្រាប់ពាណិជ្ជកម្មអន្តរជាតិ

ត្រូវមានលិខិតអនុញ្ញាត សម្រាប់សកម្មភាពពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិ ទៅលើប្រភេទសត្វព្រៃ ដែលមានក្នុងបញ្ជី ចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ និងចំណាត់ថ្នាក់ទី៣ ឬសំណាកសត្វព្រៃទាំងនោះ ដូចខាងក្រោម ៖

១- ការកាន់កាប់ ។

២- ការដឹកជញ្ជូន ។

៣- ការតាំងពិព័រណ៍ ។

៤- ការធ្វើសន្និធិ ឬការរក្សាទុក ។

៥- ការផ្តល់ជាអំណោយ ។

៦- សកម្មភាពដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិទៅលើសំណាក បំណែកសរីរាង្គសត្វព្រៃ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតសម្រាប់ពាណិជ្ជកម្មអន្តរជាតិទៅលើប្រភេទសត្វព្រៃ ។

**មាត្រា៤៨២ ._** លិខិតអនុញ្ញាតសម្រាប់ការផ្លាស់ប្តូរផ្នែកវិទ្យាសាស្ត្រ ការតាំងពិព័រណ៍ និងអំណោយថ្នាក់រដ្ឋ

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតសម្រាប់ការផ្លាស់ប្តូរផ្នែកវិទ្យាសាស្ត្រ ការតាំងពិព័រណ៍ និងអំណោយថ្នាក់រដ្ឋ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី៧
## អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

**មាត្រា៤៨៣ ._** ការអនុវត្តលើប្រភេទសត្វព្រៃ

យោងតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទ

សត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងក្រមនេះ អាចអនុវត្តចំពោះប្រភេទសត្វព្រៃ នៅក្នុង ៖

១- ឧបសម្ព័ន្ធ១ នៃអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលកំពុងរងគ្រោះថ្នាក់ ។

២- ឧបសម្ព័ន្ធ២ នៃអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលកំពុងរងគ្រោះថ្នាក់ ។

៣-ឧបសម្ព័ន្ធ៣ នៃអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលកំពុងរងគ្រោះថ្នាក់។

**មាត្រា៤៨៤** ._ ការហាមឃាត់

ហាមឃាត់ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមិនបានអនុវត្តតាមអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ នូវសកម្មភាពដូចខាងក្រោម ៖

១- ការនាំចូល ការនាំចេញ នូវប្រភេទសត្វព្រៃ ពីក្រៅប្រទេស មកក្នុងប្រទេស ឬពីក្នុងប្រទេស ទៅក្រៅប្រទេស ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

២- ការនាំចេញបន្ត ផ្ទេរ ឬដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅកាន់បរទេសនូវប្រភេទសត្វព្រៃ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី៨
## កិច្ចសហប្រតិបត្តិការអន្តរជាតិ

**មាត្រា៤៨៥** ._ កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការបង្ក្រាបបទល្មើសសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវសហការ ផ្តល់ព័ត៌មានទៅឱ្យអាជ្ញាធរ អនុវត្តច្បាប់នៃរដ្ឋ ឬប្រទេសពាក់ព័ន្ធ ដើម្បីទប់ស្កាត់ កំណត់អត្តសញ្ញាណ និងបង្ក្រាបបទល្មើសសត្វព្រៃនៅក្រោមយុត្តាធិការនៃរដ្ឋ ឬប្រទេសពាក់ព័ន្ធ ។

**មាត្រា៤៨៦ ._** ការស៊ើបអង្កេតនិងនីតិវិធី

ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ អាចសហការជាមួយអាជ្ញាធរពង្រឹងការអនុវត្តច្បាប់អន្តរជាតិ និងអង្គការអន្តរជាតិថ្នាក់តំបន់ សម្រាប់កិច្ចការ ដែលមានដូចតទៅ ៖

១- ផ្តល់ភស្តុតាងជាឯកសារ សក្ខីកម្ម សាក្សី សារធាតុផ្សេងៗ និងការធ្វើបទបង្ហាញបកស្រាយ សម្រាប់ការវិភាគ និងការស៊ើបអង្កេត ។

២- ការផ្តល់ ឬការដោះដូរបុគ្គលិក មន្ត្រី រួមទាំងមន្ត្រីជំនាញ និងមន្ត្រីមុខងារផ្សេងៗ ។

៣- ការស៊ើបអង្កេត ឬការស៊ើបអង្កេតរួមគ្នា ។

៤- ការចាត់នីតិវិធី ។

៥- ផ្តល់ជំនួយផ្សេងទៀតតាមការស្នើសុំសម្រាប់ករណីនីមួយៗ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិអាចចរចា និងចុះកិច្ចព្រមព្រៀងជំនួយផ្នែកច្បាប់ទៅវិញទៅមក ជាមួយអាជ្ញាធរអនុវត្តច្បាប់នៃរដ្ឋ ឬប្រទេសផ្សេងទៀត ឬអង្គការអន្តរជាតិ ។

## ជំពូកទី៩
## ផែនការស្តារ និងគ្រប់គ្រងសត្វព្រៃ

**មាត្រា៤៨៧ ._** ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃសម្រាប់ប្រភេទចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ដែលមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ផែនការនេះ ត្រូវមានរយៈពេលវែង យ៉ាងតិច ១០ (ដប់) ឆ្នាំ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានភារកិច្ចសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញ ក្នុងការបង្កើតផែនការស្តារ និងគ្រប់គ្រង ប្រភេទសត្វព្រៃ ដោយមានកិច្ចពិគ្រោះយោបល់ជាសាធារណៈ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ ត្រូវមានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ជាអង្គភាពអនុវត្ត ដែលជាសេនាធិការរបស់ក្រសួង ស្ថាប័នទទួលបន្ទុក បរិស្ថាន និងធនធានធម្មជាតិ មានតួនាទី សហការជាមួយក្រសួង ស្ថាប័ន និងដៃគូ ពាក់ព័ន្ធដើម្បីអនុវត្តការងារអភិរក្សសត្វព្រៃ ។

**មាត្រា៤៨៨ .**_ លក្ខខណ្ឌ នៃផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ ៖

១- សកម្មភាពការពារនិងអភិរក្ស នៅក្នុងផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ ។

២- ទីជម្រកសំខាន់ៗសម្រាប់ការអភិរក្សប្រភេទសត្វព្រៃ មានវិធានការគ្រប់គ្រងទៅតាមប្រភេទទីជម្រក និងតំបន់ក្នុងគោលដៅការពារ និងអភិរក្ស ។

៣- សកម្មភាព គ្រប់គ្រងទីជម្រក និងតំបន់ទេសភាពនៅក្នុងផែនការស្តារ និងគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៤- សូចនាករ ដែលអាចវាស់វែងបាន ដែលអាចធ្វើឱ្យប្រភេទគោលដៅ មានភាពប្រសើរឡើង ។ ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ ត្រូវកំណត់ពេលវេលា និងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តសកម្មភាព និង វិធានការនានា ។

៥- ការបន្លាស់ទីកន្លែង វិធានការអភិរក្សក្រៅជម្រកដើម ការបង្កាត់ពូជដើម្បីអភិរក្ស និងការស្តារឡើងវិញសម្រាប់ការអភិរក្ស ។

**មាត្រា៤៨៩ .**_ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោង ផែនការ ឬសកម្មភាពស្តារសត្វព្រៃ ដែលអាចប៉ះពាល់ដល់ទីជម្រក ប្រភេទសត្វព្រៃចំណាត់ថ្នាក់ទី១ និងចំណាត់ថ្នាក់ទី២ ។

ក្នុងករណីមានប្រភេទសត្វព្រៃដែលទទួលរងការគំរាមកំហែង ប៉ុន្តែមិនទាន់មានការរៀបចំផែនការស្តារ និងគ្រប់គ្រងនៅឡើយ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោង ផែនការស្តារ ឬសកម្មភាព ដែលអាចមានផលប៉ះពាល់ដល់ប្រភេទសត្វព្រៃទាំងនោះ ត្រូវបង្ហាញថាគម្រោង ផែនការស្តារ ឬសកម្មភាពដែលត្រូវធ្វើ មិនប៉ះពាល់ដល់ចំនួនសត្វព្រៃក្នុងទីជម្រកធម្មជាតិ ។

**មាត្រា៤៩០ ._** ការរៀបចំរបាយការណ៍ និងការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចមានកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ លើការអនុវត្តតាមប្រព័ន្ធអង្កេតតាមដាន ប្រកបដោយប្រសិទ្ធភាព នូវស្ថានភាពប្រភេទសត្វព្រៃ ដែលបានកំណត់ក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ដែលបានស្តារដល់កម្រិត ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ និងអាចត្រូវបានធ្វើបច្ចុប្បន្នភាព ផ្លាស់ប្តូរចំណាត់ថ្នាក់ប្រភេទសត្វព្រៃ នៃបញ្ជីចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវចេញរបាយការណ៍ជាសាធារណៈ អំពីប្រភេទក្នុងចំណាត់ថ្នាក់ទី១ និងទី២ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៤៩១ ._** ការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ផ្តល់លិខិតអនុញ្ញាតសម្រាប់គម្រោងស្តារសត្វព្រៃ ឬសកម្មភាពដែលពាក់ព័ន្ធ នឹងការកំណត់ប្រភេទចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ត្រូវពិនិត្យទៅលើផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ និងផែនការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ មុននឹងផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ។

**មាត្រា៤៩២ ._** ការអង្កេតតាមដានស្ថានភាពនៃប្រភេទសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ សហការជាមួយអ្នកពាក់ព័ន្ធ ត្រូវផ្តល់ការអង្កេតតាមដាន លើស្ថានភាពនៃប្រភេទសត្វព្រៃ ក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ រហូតដល់រយៈពេល៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីស្ថានភាពនៃប្រភេទទាំងនោះ បានប្តូរមកចំណាត់ថ្នាក់ទី៣ ឬចំណាត់ថ្នាក់ទី៤ ស្របតាមលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៤៩៣ ._** ការបង់ថ្លៃសំណងជួសជុលស្តារខូចខាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ការបង់ថ្លៃសំណងជួសជុលស្តារការខូចខាត ដែលបង្កដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កការខូចខាតដល់សត្វព្រៃ ។ ថវិកាដែលប្រមូលបានពីការបង់ថ្លៃសំណងជួសជុលស្តារការខូចខាត ត្រូវប្រើប្រាស់សម្រាប់ការអនុវត្តផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី១០
## ការគ្រប់គ្រងទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សហ្សែន មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និង គ្រឹះស្ថានឧទ្យានសត្វព្រៃ

**មាត្រា៤៩៤** ._ ការចុះបញ្ជី

គ្រប់ទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សធនធានហ្សែន មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និង គ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវចុះបញ្ជី និងមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ធនធានធម្មជាតិ ។

**មាត្រា៤៩៥** ._ ការហាមឃាត់

ត្រូវហាមរាល់ការបង្ខាំង ការចិញ្ចឹម ការបម្រើការងារ ឬលម្អ នូវប្រភេទសត្វព្រៃ ដូចបានកំណត់ ក្នុងបញ្ជីចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ចំណាត់ថ្នាក់ទី៣ ចំណាត់ថ្នាក់ទី៤ នៅក្រៅមជ្ឈមណ្ឌល សង្គ្រោះសត្វព្រៃ ទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សហ្សែន ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ លើកលែងតែ មានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៩៦** ._ ការអនុញ្ញាត

រាល់ទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សធនធានហ្សែន មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះ ស្ថាន ឧទ្យានសត្វព្រៃ ដែលមានផែនការរក្សាទុកសត្វព្រៃគ្រប់ប្រភេទ ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៩៧** ._ ការធ្វើអធិការកិច្ច

ទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សធនធានហ្សែន មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថាន ឧទ្យានសត្វព្រៃ ត្រូវស្ថិតនៅក្រោមក្របខ័ណ្ឌអធិការកិច្ចនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ធនធានធម្មជាតិ ។

**មាត្រា៤៩៨** ._ ការដកហូតនិងបញ្ឈប់បណ្ដោះអាសន្ន

ការបង្ខាំង រក្សា ឬប្រមូលទុកសត្វព្រៃ ដែលផ្ទុយនឹងខ្លឹមសារលិខិតអនុញ្ញាត ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិដកហូតលិខិតអនុញ្ញាត ឬបញ្ឈប់ប្រតិបត្តិការបណ្តោះអាសន្ន និងរឹបអូសរាល់សត្វព្រៃ ។

**មាត្រា៤៩៩** ._ ការអង្កេតតាមដាននិងធ្វើកំណត់ត្រា

ប្រតិបត្តិករ ឬម្ចាស់ទីតាំងបង្កាត់ពូជអភិរក្ស អភិរក្សហ្សែន មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ គ្រឹះស្ថានឧទ្យានសត្វព្រៃ មានភារកិច្ចធ្វើកំណត់ត្រាអំពីកាលបរិច្ឆេទ ការកើត ការស្លាប់ ការផ្ទេរសត្វព្រៃ ដូចបានកំណត់ក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ចំណាត់ថ្នាក់ទី៣ និងចំណាត់ថ្នាក់ទី៤ ។ ព័ត៌មានទាំងនេះ ត្រូវរាយការណ៍ជូនអង្គភាពទទួលបន្ទុកបរិស្ថាន និង ធនធានធម្មជាតិ នៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ពេលចុះត្រួតពិនិត្យ ។ សត្វព្រៃដែលមិនបានចុះកំណត់ត្រា ត្រូវរាប់ថាជាសត្វព្រៃ ដែលទទួលបានមកដោយខុសច្បាប់ ។

**មាត្រា៥០០** ._ ការផ្ទេរ ឬការប្តូរទីតាំងសត្វព្រៃ

រាល់ការផ្ទេរ ឬការប្តូរទីតាំងសត្វព្រៃ ដែលបានកំណត់ ក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ចំណាត់ថ្នាក់ទី៣ ចំណាត់ថ្នាក់ទី៤ ត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនភ្ជាប់ជាមួយ និងត្រូវជូនដំណឹងជាមុនមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ការផ្ទេរ ឬការប្តូរទីទីតាំងសត្វព្រៃ ពីទីកន្លែងមួយ ទៅកន្លែងមួយទៀត ត្រូវមានកំណត់ត្រាច្បាស់លាស់ហើយត្រូវជូនដំណឹង និងផ្តល់ឯកសារដល់ ក្រុមពង្រឹងការអនុវត្តច្បាប់ នៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីត្រួតពិនិត្យ ។

**មាត្រា៥០១** ._ ការបោះបង់ចោលបំណែកសាច់ សំណាក ឬវត្ថុតាំងលម្អនៃសត្វព្រៃ

ការបោះបង់ចោលបំណែកសរីរាង្គ សាច់ សំណាក ឬវត្ថុតាំងលម្អ នៃសត្វព្រៃ ដែលបង្ខាំង ឬចិញ្ចឹមត្រូវធ្វើឡើង ស្របតាមលិខិតបទដ្ឋានគតិយុត្ត ។ ការរក្សាទុកសរីរាង្គ ទាំងមូល ឬជាផ្នែកនៃសត្វព្រៃ ក្នុងទីតាំងបង្កាត់ពូជអភិរក្ស អភិរក្សធនធានហ្សែន មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥០២ ._** លក្ខខណ្ឌនៃការព្យាបាលសត្វព្រៃ និងទីកន្លែង

សត្វព្រៃដែលបានបង្ខាំង នៅតាមទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សធនធានហ្សែន មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ គ្រឹះស្ថានឧទ្យានសត្វព្រៃ ឬកន្លែងសន្និធិសត្វព្រៃ ត្រូវទទួលការថែទាំប្រកបដោយមនុស្សធម៌ ដោយអនុលោមតាមពិធីសារនៃសុខុមាលភាពសត្វ ឬលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៥០៣ ._** ការរឹបអូសសត្វព្រៃ

នៅពេលដែលរបបអាហារ ទ្រុង ទីបង្ខាំង ការចិញ្ចឹម សុខភាព ឬការចិញ្ចឹមសត្វព្រៃ ពុំស្របតាមលក្ខខណ្ឌតម្រូវផ្សេងទៀតសម្រាប់សត្វព្រៃ មិនត្រូវបានអនុវត្តបានគ្រប់គ្រាន់ ទៅតាមបមាណីយ ដែលបានឯកភាព នោះក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិរឹបអូសសត្វព្រៃទាំងអស់ និងឧបករណ៍ពាក់ព័ន្ធ មកជាសម្បត្តិរដ្ឋ ។

**មាត្រា៥០៤ ._** លក្ខណៈធម្មជាតិរបស់សត្វព្រៃ

ទីកន្លែងដែលអនុវត្តការបង្កាត់ពូជអភិរក្ស និងអភិរក្សធនធានហ្សែនសត្វព្រៃ ក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ចំណាត់ថ្នាក់ទី៣ ចំណាត់ថ្នាក់ទី៤ ត្រូវធានាឱ្យបាននូវលក្ខណៈធម្មជាតិរបស់សត្វព្រៃ និងទម្លាប់ និងទ្រុងមានលក្ខណៈសមស្របតាមបមាណីយដែលអាចទទួលយកបានសម្រាប់ សុខុមាលភាពរបស់សត្វ ស្របតាមលិខិតបទដ្ឋានគតិយុត្ត ។

ទីកន្លែងដែលអនុវត្តការបង្កាត់ពូជអភិរក្ស និងអភិរក្សធនធានហ្សែន ត្រូវរៀបចំសៀវភៅកំណត់ត្រា សម្រាប់ប្រភេទសត្វព្រៃ ដោយបញ្ជាក់ពីកម្មវិធីបង្កាត់ពូជ ការចិញ្ចឹម ស្របតាមលិខិតបទដ្ឋានគតិយុត្ត ។

ប្រភេទនៃការបន្តពូជទាំងអស់ គ្រប់ព្រឹត្តិការណ៍បង្កាត់ពូជ និងពពួកពូជតែមួយ ត្រូវធ្វើការកត់ត្រាឱ្យបានត្រឹម ត្រូវនូវចំនួនសត្វព្រៃមេបាដើម និងកូនដែលកើតពីមេបាដើម ។ កូនដែលកើតពីមេបាដើម ត្រូវដាក់សញ្ញាសម្គាល់ជាអចិន្ត្រៃយ៍ ដែលអាចសម្គាល់បាន ដើម្បីកត់ត្រាពីភាគរយ និងដើមកំណើត ។

**មាត្រា៥០៥ ._** ប្រព័ន្ធគ្រប់គ្រងទិន្នន័យ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំ និងគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទិន្នន័យ សម្រាប់ការអង្កេតតាមដាន ត្រួតពិនិត្យ និងការគ្រប់គ្រងសត្វព្រៃ ដែលត្រូវបង្ខាំង និងទីតាំងបង្ខាំង ។

**មាត្រា៥០៦ ._** ការដោះលែងសត្វព្រៃ

ទីកន្លែងដែលមានសត្វព្រៃរស់នៅដោយការបង្ខាំង ឬបានកើតក្នុងទីបង្ខាំង ហើយមានការកំណត់ឱ្យដោះលែងជាបន្តបន្ទាប់ ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ នៅមុនការដោះលែង ត្រូវពិនិត្យសុខភាពសត្វព្រៃទាំងនោះ កំណត់អត្តសញ្ញាណ និងរៀបចំកន្លែងដោះលែង ដោយសម្របតាមលក្ខណៈធម្មជាតិនៃសត្វព្រៃដែលត្រូវដោះលែង និងការអង្កេតតាមដាន ត្រួតពិនិត្យ ក្រោយការដោះលែង ក្នុងករណីចាំបាច់ ។

## ជំពូកទី១១
## ការគ្រប់គ្រងសត្វព្រៃ បំណែកសរីរាង្គសត្វព្រៃដែលរឹបអូសបាន

**មាត្រា៥០៧ ._** នីតិវិធីគ្រប់គ្រងសត្វព្រៃ និងបំណែកសរីរាង្គសត្វព្រៃ

គ្រប់សត្វព្រៃ ឬបំណែកសរីរាង្គសត្វព្រៃដែលរឹបអូសបាន ដូចមានចែងក្នុងក្រមនេះ ត្រូវអនុវត្តតាមកត្តាណាមួយ ដូចខាងក្រោម ៖

១- សត្វព្រៃរស់ ហើយមានដើមកំណើតក្នុងស្រុក ត្រូវវាយតម្លៃសុខភាព និង ភាពសមស្របនានា មុនដោះលែងចូលទៅក្នុងព្រៃធម្មជាតិ ។ ក្នុងករណីមិនសមស្រប ត្រូវបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ដែលមានការអនុញ្ញាត ដើម្បីព្យាបាល និងថែទាំ ។

២- សត្វព្រៃស្លាប់បំណែកសរីរាង្គ ឬសំណាកសត្វព្រៃ អាចបំផ្លាញចោល ឬរក្សាទុក ត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្ត កំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

៣- សត្វរស់មិនមានដើមកំណើតក្នុងព្រះរាជាណាចក្រកម្ពុជា អាចបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ដែលមានការអនុញ្ញាត ប៉ុន្តែក្នុងករណីចាំបាច់ អាចផ្តល់ទៅកន្លែងដើមវិញ ឬអាចចាត់វិធានការតាមស្ថានភាពជាក់ស្តែង ។

**មាត្រា៥០៨ ._** វត្ថុតាង

ក្នុងករណីដែលត្រូវរក្សាទុកវត្ថុតាងដែលរឹបអូសបានទុកជាភស្តុតាងសម្រាប់បន្តនីតិវិធីច្បាប់ រាល់សត្វព្រៃ ដែលស្លាប់ បំណែកសរីរាង្គ ឬសំណាកសត្វព្រៃ ដូចបានកំណត់ក្នុងចំណាត់ថ្នាក់ទី១ ចំណាត់

ថ្នាក់ទី២ ចំណាត់ថ្នាក់ទី៣ ត្រូវរក្សាទុកទីសុវត្ថិភាព នៅទីតាំង ដែលមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ រហូតដល់បញ្ចប់នីតិវិធីច្បាប់ ។

មិនត្រូវរក្សាទុកជាភស្តុតាងសម្រាប់អនុវត្តនីតិវិធី នូវសត្វព្រៃរស់ ក្រៅពីភស្តុតាងជារូបភាព និងឯកសារ ផ្លូវច្បាប់ដែលពាក់ព័ន្ធនោះឡើយ ។ សត្វព្រៃរស់ដែលរឹបអូសបានត្រូវទទួលការ ថែទាំសង្គ្រោះបន្ទាន់ និងជំនួយបឋម ហើយអាចប្រគល់ទៅឱ្យមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ដែលមានការអនុញ្ញាតទទួលថែទាំ ។

នៅពេលនីតិវិធីបានបញ្ចប់ ឬមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច រាល់វត្ថុតាងសត្វព្រៃស្លាប់ ឬបំណែកសរីរាង្គសត្វព្រៃ ដូចបានកំណត់ក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ចំណាត់ថ្នាក់ទី៣ ត្រូវប្រគល់ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីរៀបចំចាត់ចែងតាមនីតិវិធី ។

**មាត្រា៥០៩ ._** ការរៀបចំរបាយការណ៍តាមអនុសញ្ញាស្តីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដែលបានធ្វើការរឹបអូសប្រភេទសត្វព្រៃ និងជិតផុតពូជ ដូចបានកំណត់ក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ជាសត្វព្រៃទាំងមូល ឬជាបំណែកសរីរាង្គសត្វព្រៃ ត្រូវរៀបចំសេចក្តីរាយការណ៍ ជូនដល់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងអាជ្ញាធរ ឬសមត្ថកិច្ចគ្រប់គ្រង ដែលទទួលបន្ទុកលើអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ប្រចាំប្រទេសសាមី ។

អាជ្ញាធរគ្រប់គ្រងដែលទទួលបន្ទុកលើអនុសញ្ញាស្តីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ប្រចាំប្រទេសសាមី ត្រូវធ្វើសេចក្តីរាយការណ៍ជូនដល់លេខាធិការដ្ឋានសម្រាប់អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ស្របតាមកាតព្វកិច្ចស្តីពីការរាយការណ៍ ដូចបានកំណត់នៅក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ។

ក្នុងករណីមានប្រភេទសត្វព្រៃ ដែលបានកំណត់ក្នុងអនុញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ជាប្រភេទចំណាត់ថ្នាក់កំពុងរងគ្រោះថ្នាក់ ត្រូវបានរឹបអូសក្នុងពេលកំពុងឆ្លងកាត់ ឬកំពុងចែកចាយក្នុងព្រះរាជាណាចក្រកម្ពុជា នោះក្រសួង ស្ថាប័នទទួលបន្ទុក

បរិស្ថាន និងធនធានធម្មជាតិ អាចរក្សា ឬចាត់វិធានការបំផ្លាញវត្ថុតាងដែលរឹបអូសបាន ស្របតាមលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៥១០** ._ កិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់អន្តរជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិអាចធ្វើការចចារ និងកំណត់អំពីកិច្ចព្រមព្រៀងនានាជាមួយអាជ្ញាធរពង្រឹងការអនុវត្តច្បាប់អន្តរជាតិ ឬអង្គការអន្តរជាតិ ថ្នាក់តំបន់ ក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការពង្រឹង ការអនុវត្តច្បាប់អន្តរជាតិដើម្បីទប់ស្កាត់ កំណត់អត្តសញ្ញាណ និងបង្ក្រាបបទល្មើសដែលពាក់ព័ន្ធសត្វព្រៃ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី១២
## ការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វព្រៃ

**មាត្រា៥១១** ._ ការហាមឃាត់

ត្រូវហាមឃាត់ចំពោះ ៖

១- ការចិញ្ចឹម ការថែរក្សា ការបង្កាត់ពូជ ការធ្វើសន្និធិ ឬការរក្សាទុក សម្រាប់គោលបំណង ពាណិជ្ជកម្មចំពោះសត្វព្រៃនៃចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ។

២- ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វព្រៃ ដើម្បីចិញ្ចឹម ថែរក្សា បង្កាត់ពូជ ធ្វើសន្និធិ ឬរក្សាទុកសត្វព្រៃ ក្នុងបរិវេណដែលមានចម្ងាយ តិចជាង ២០ (ម្ភៃ) គីឡូម៉ែត្រ ពីសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៣- ការនាំយកសត្វព្រៃដែលចាប់បានពីព្រៃ ចូលទៅក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ។ កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវមានតែប្រភេទសត្វព្រៃដែលយកមកពីកសិដ្ឋានចិញ្ចឹមសត្វព្រៃដទៃទៀត ដែលមានលិខិតអនុញ្ញាតតែប៉ុណ្ណោះ ។

**មាត្រា៥១២** ._ ការចេញលិខិតអនុញ្ញាតសម្រាប់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

កសិដ្ឋានចិញ្ចឹមសត្វព្រៃសម្រាប់គោលបំណងពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នីតិវិធី នៃការចេញលិខិតអនុញ្ញាតសម្រាប់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥១៣** ._ កាតព្វកិច្ចរបស់ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃដែលមានលិខិតអនុញ្ញាត ត្រូវមានកាតព្វកិច្ចថែទាំងសត្វព្រៃ ក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ដូចខាងក្រោម ៖

១- ការដឹកជញ្ជូន ការផ្ទេរសត្វព្រៃពីកសិដ្ឋានចិញ្ចឹមសត្វព្រៃមួយទៅកសិដ្ឋានចិញ្ចឹមសត្វព្រៃមួយទៀត ត្រូវមានលិខិតអនុញ្ញាត ។

២- រៀបចំទីជម្រក ទីធ្លា អាហារទឹកឱ្យបានគ្រប់គ្រាន់ ស្របតាមលក្ខណៈជីវសាស្ត្ររបស់សត្វព្រៃ ។

៣- រៀបចំទីបង្ខាំងទុកឱ្យមានអនាម័យ និងមានលក្ខណៈសមស្រប និងមានការសម្អាតជាប្រចាំ ។

៤- រៀបចំការគ្រប់គ្រងសត្វព្រៃ សុខុមាលភាពសត្វព្រៃ សត្តឃាតសត្វព្រៃ ស្របតាមលិខិតបទដ្ឋានគតិយុត្ត ។

៥- ត្រូវទប់ស្កាត់សត្វព្រៃពីការរត់គេចពីទីតាំងរក្សាទុក ចូលទៅក្នុងព្រៃធម្មជាតិ ។ ក្នុងករណីមានសត្វព្រៃរត់គេច ត្រូវជូនដំណឹងដល់មន្ទីរទទួលបន្ទុកបរិស្ថានខេត្តភ្លាម និងត្រូវស្វែងរក និងចាប់មកវិញ ។

៦- ក្នុងករណីប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានសត្វព្រៃថែទាំមិនជិតដល់ និងប៉ះពាល់ដល់សុខុមាលភាពសត្វព្រៃ ឬដឹកជញ្ជូនសត្វព្រៃមិនបានត្រឹមត្រូវ និងលក្ខខណ្ឌផ្សេងទៀត អង្គភាពនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចដកហូត ឬលុបលិខិតអនុញ្ញាត និង/ឬអាចផ្អាកសកម្មភាពកសិដ្ឋានចិញ្ចឹមសត្វព្រៃ នោះជាបណ្ដោះអាសន្ន ឬជាស្ថាពរ ។

៧- លក្ខខណ្ឌតម្រូវដទៃទៀត ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥១៤** ._ ការធ្វើអធិការកិច្ច ការព្យួរ និងការដកហូតអាជ្ញាប័ណ្ណកសិដ្ឋានចិញ្ចឹមសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវធ្វើអធិការកិច្ចកសិដ្ឋានចិញ្ចឹមសត្វព្រៃជាទៀងទាត់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចព្យួរ ឬដកហូតអាជ្ញាប័ណ្ណកសិដ្ឋាន ចិញ្ចឹមសត្វព្រៃណាដែលមិនគោរពតាមលក្ខខណ្ឌនៃការអនុញ្ញាត ឬការហាមឃាត់ដទៃទៀតដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នីតិវិធីនៃការធ្វើអធិការកិច្ច ការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណសម្រាប់កសិដ្ឋានចិញ្ចឹមសត្វព្រៃត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥១៥** ._ ការធ្វើកំណត់ត្រា កសិដ្ឋានចិញ្ចឹមសត្វព្រៃ

អ្នកប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវធ្វើ និងរក្សាកំណត់ត្រាអំពីសត្វដែលបានចិញ្ចឹម និងកើតក្នុងកសិដ្ឋានតាមទម្រង់បែបបទដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នីតិវិធី និងបែបបទនៃការធ្វើកំណត់ត្រាអំពីសត្វព្រៃនៅក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥១៦** ._ ការលក់សត្វព្រៃចិញ្ចឹម និងផលិតផលសត្វព្រៃ

ហាមឃាត់ការលក់ ការដូរ ការទិញ ឬការធ្វើអាជីវកម្មសត្វព្រៃដែលបានចិញ្ចឹម និងផលិតផលសត្វព្រៃ ដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដូចខាងក្រោម ៖

១- ការលក់ ការដូរ ការទិញ ឬការធ្វើអាជីវកម្មសត្វព្រៃរស់ ស្លាប់ ឬដែលបានសម្លាប់ ដល់បុគ្គលណាមួយ ក្រៅពីកសិដ្ឋានចិញ្ចឹមសត្វព្រៃ ដែលមានការអនុញ្ញាត ។

២- រាល់ប្រតិបត្តិការពាណិជ្ជកម្មពាក់ព័ន្ធនឹងសត្វព្រៃ សំណាក ផលិតផលសត្វព្រៃ ដែលបានពីកសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវមានកំណត់ត្រា ដែលនឹងត្រូវធ្វើអធិការកិច្ចដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥១៧** ._ ការបង្ខាំងសត្វដោយឡែក និងការអង្កេតតាមដានពីសុខភាព

ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវអនុវត្តការបង្ខាំងសត្វព្រៃដោយឡែក និងការអង្កេតតាមដានពីសុខភាព មុនការដាក់បញ្ចូលសត្វព្រៃថ្មីចូលទៅក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ។

នីតិវិធីនៃការអង្កេតតាមដាន សុខភាពសត្វ និងការបង្ការសត្វព្រៃដោយឡែក ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីរកឃើញថា មានសត្វព្រៃស្លាប់នៅក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹម សត្វព្រៃ ត្រូវរាយការណ៍ជាបន្ទាន់ទៅស្ថាប័ន អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ ត្រូវធ្វើអធិការកិច្ច ទទួលសំណាក និង/ឬបោះបង់ចោលសត្វព្រៃស្លាប់នៅក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ក្របខ័ណ្ឌតាមដានជំងឺសត្វព្រៃនៅនឹងកន្លែង ត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

១- ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវធ្វើបញ្ជី និងចេញផ្សាយនូវប្រភេទជំងឺដែលស្ថិតក្នុងការតាមដាន ក្រោមកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

២- ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវរាយការណ៍ជាបន្ទាន់ទៅ ស្ថាប័ន អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

៣- មិនអនុញ្ញាតឱ្យ ប្រតិបត្តិករ ឬ ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ រក្សា បិទបាំង ដឹកជញ្ជូន លក់ ផ្ទេរ ធ្វើប្រទានកម្ម ឬប្រើប្រាស់សត្វព្រៃនៅពេលបានដឹង ឬសង្ស័យថាសត្វព្រៃទាំងនោះផ្ទុកជំងឺស្ថិតក្នុងការតាមដាន ឬដែលបានដឹងថាស្លាប់ ដោយមូលហេតុមិនច្បាស់លាស់ក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ។

៤- ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និង/ឬ បទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ ។

៥- កសិដ្ឋានចិញ្ចឹមសត្វព្រៃ អាចត្រូវបិទជាបណ្ដោះអាសន្ន ឬជាស្ថាពរ ក្នុងករណីដែលប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃនោះ មិនអនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬពិធីសារស្ដីពីការតាមដានជំងឺ ។

**មាត្រា៥១៨** ._ លក្ខខណ្ឌអប្បបរមា

ដោយមានការពិគ្រោះជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវបង្កើតលក្ខខណ្ឌអប្បបរមាសម្រាប់រៀបចំ និងដំណើរការកសិដ្ឋានចិញ្ចឹមសត្វព្រៃ ស្របតាមលិខិតបទដ្ឋានគតិយុត្ត ឬពិធីសារស្ដីពីការចិញ្ចឹម និងសុខុមាលភាពសត្វព្រៃ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចត្រួតពិនិត្យកសិដ្ឋានចិញ្ចឹមសត្វព្រៃតាមការចាំបាច់ ។

ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃមិនអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិអាចដកហូត លិខិតអនុញ្ញាត និងទទួលទណ្ឌកម្មបន្ថែម ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៥១៩** ._ លក្ខខណ្ឌទូទៅ

ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃដែលមានលិខិតអនុញ្ញាត ត្រូវថែទាំសត្វព្រៃដូចខាងក្រោម ៖

១- ការដឹកជញ្ជូន ឬការផ្ទេរសត្វព្រៃចេញពីកសិដ្ឋានចិញ្ចឹមសត្វព្រៃមួយ ទៅកសិដ្ឋានចិញ្ចឹមសត្វព្រៃមួយទៀត ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត ឬពិធីសារស្តីពីការដឹកជញ្ជូនសត្វព្រៃ ។

២- ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវរៀបចំទីជម្រក ទីធ្លា អាហារ និងទឹកឱ្យបានគ្រប់គ្រាន់ ហើយទីបង្ខាំងត្រូវមានលក្ខណៈសមស្រប និងមានការសម្អាតជាប្រចាំ ។

៣- ករណីប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានសត្វព្រៃថែទាំមិនដិតដល់ និងប៉ះពាល់សុខុមាលភាពសត្វព្រៃ ឬ ដឹកជញ្ជូនសត្វព្រៃមិនបានត្រឹមត្រូវ តាមលក្ខខណ្ឌផ្សេងទៀត ក្រសួង ស្ថាប័ន អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចដកហូតលិខិតអនុញ្ញាត និង/ឬអាចឈានការបិទកសិដ្ឋានចិញ្ចឹមសត្វព្រៃនោះជាបណ្តោះអាសន្ន ឬជាស្ថាពរ ។

**មាត្រា៥២០** ._ ការទប់ស្កាត់ការរត់គេចសត្វព្រៃ

ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ មិនត្រូវធ្វេសប្រហែសឱ្យសត្វព្រៃរបស់ខ្លួន រួច ឬគេចពីការបង្ខាំង ឬព្រលែងចូលទៅក្នុងព្រៃ។

ក្នុងករណីមានការរួចពីការបង្ខាំង នោះប្រតិបត្តិករ ឬម្ចាស់កសិដ្ឋាន ត្រូវ ៖

១- ជូនដំណឹងជាបន្ទាន់ដល់ ក្រសួង ស្ថាប័ន អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

២- ត្រូវសហការជាមួយ ក្រសួង ស្ថាប័ន អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ តាមចាប់យកមកមកបង្ខាំងវិញ ។

**មាត្រា៥២១** ._ ការសម្លាប់ដោយសត្វធម៌

ការសម្លាប់សត្វព្រៃចិញ្ចឹម ត្រូវអនុវត្តដោយសត្វធម៌ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការសម្លាប់សត្វព្រៃចិញ្ចឹម ។

**មាត្រា៥២២** ._ ការដឹកជញ្ជូន

ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានសត្វព្រៃ ត្រូវដឹកជញ្ជូនសត្វព្រៃដែលត្រូវបង្ខាំង ស្របតាមនីតិវិធី និងលិខិតបទដ្ឋានគតិយុត្ត កំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥២៣** ._ ការមិនទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មិនទទួលខុសត្រូវ ក្នុងករណីដូចខាងក្រោម ៖

១- រាល់ការខូចខាតទ្រព្យសម្បត្តិ ឬការប៉ះពាល់ទាំងឡាយណាដែលបង្កដោយសត្វព្រៃចិញ្ចឹម ឬដោយការរួចពីការបង្ខាំងរបស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ។

២- រាល់ការបាត់បង់ ឬការស្លាប់សត្វព្រៃចិញ្ចឹមណាមួយ មិនថាដោយការរួច ឬការស្លាប់ដោយសារជំងឺ បើទោះជាក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចតម្រូវឱ្យមានការសម្លាប់សត្វព្រៃ ចិញ្ចឹមណាមួយដែលរួច ឬដោយសារស្ថានភាពនៃជំងឺក៏ដោយ ។

**មាត្រា៥២៤** ._ ការស្នើសុំលិខិតអនុញ្ញាតឡើងវិញរបស់ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

ប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ដែលកំពុងមានប្រតិបត្តិការ បន្ទាប់ពីក្រមនេះចូលជាធរមានត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតថ្មីក្នុងរយៈពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃដោយ អនុវត្តតាម លិខិតបទដ្ឋានគតិយុត្ត និង/ឬលក្ខខណ្ឌនៃបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី១៣
## ការតាមដានសុខភាពសត្វព្រៃ

**មាត្រា៥២៥** ._ វិធីសាស្ត្រអង្កេតតាមដានសុខភាពសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធត្រូវ ៖

១- កំណត់អត្តសញ្ញាណជំងឺសត្វព្រៃ និងផ្សព្វផ្សាយជាសាធារណៈ អំពីជំងឺដែលបានរកឃើញ ។

២- រៀបចំវិធីសាស្ត្រអង្កេតតាមដានសុខភាព និងជំងឺសត្វព្រៃ ។

៣- អង្កេតតាមដាន ចងក្រងឯកសារ និងឆ្លើយតបចំពោះការរាតត្បាតនៃជំងឺសត្វព្រៃ ។

៤- របាយការណ៍អំពីលទ្ធផលនៃការសិក្សាអង្កេតតាមដានសុខភាព និងជំងឺសត្វព្រៃ ។

**មាត្រា៥២៦** ._ ការតាមដានសុខភាពសត្វព្រៃ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចតម្រូវឱ្យអ្នកកាន់កាប់លិខិតអនុញ្ញាតបរបាញ់ ប្រមូលយកសត្វព្រៃ សំណាកសត្វព្រៃ  ប្រគល់សំណាកសត្វព្រៃដែលបរបាញ់ ឬប្រមូលបាន ដើម្បីធ្វើការអង្កេតតាមដានពីសុខភាពសត្វព្រៃ ដោយមិនទទួលបានសំណងណាមួយឡើយ ។

**មាត្រា៥២៧** ._ ការបង្ខាំងសត្វព្រៃដោយឡែក

មុនការប្តូរទីតាំង ឬផ្ទេរសត្វព្រៃរវាងទីបង្ខាំង និងតំបន់ព្រៃនោះ សត្វព្រៃត្រូវមានការញែកដោយឡែក និងមានការអង្កេតតាមដាន ដោយក្រសួង ស្ថាប័ន អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមលិខិតបទដ្ឋានគតិយុត្ត និងផ្តល់ការបញ្ជាក់ដូចតទៅ ៖

១- សត្វព្រៃត្រូវបានបង្ខាំងទុកដោយឡែកក្នុងរយៈពេលមួយចាំបាច់ ហើយមានការត្រួតពិនិត្យពីអង្គភាពនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មុនពេលដោះលែង ។

២- សត្វព្រៃទាំងឡាយមិនបានបង្ហាញសញ្ញាសម្គាល់ណាមួយថាមានរបួស ឬជំងឺនោះទេ ។

៣- សត្វព្រៃ ត្រូវបានធ្វើអត្តសញ្ញាណដោយឡែកៗ ហើយមានភាពវិជ្ជមាន ។

៤- សត្វព្រៃ ត្រូវបានពិនិត្យ ឬពិសោធន៍ ហើយមិនមានជំងឺដែលគួរឱ្យកង្វល់ ។

៥- ករណីមានសត្វព្រៃចិញ្ចឹមណាមួយកើតជំងឺ ឬស្លាប់ក្នុងពេលញែកដោយឡែក ក្រសួង ស្ថាប័ន អង្គភាពទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវជូនដំណឹងជាសាធារណៈ ។

## មាតិកាទី៧
## ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធាន
## តំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៥២៨** _ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តលើតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥២៩** _ គោលបំណង

មាតិកានេះមានគោលបំណង ដើម្បីគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រប្រកបដោយនិរន្តរភាព ។

## ជំពូកទី ២
## ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ

**មាត្រា៥៣០** _ តួនាទី និងការទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្ត ត្រូវទទួលខុសត្រូវក្នុងការចាត់តាំង គ្រប់គ្រង ការពារ និងអភិរក្សធនធានធម្មជាតិតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ។

**មាត្រា៥៣១** _ តួនាទី និងភារកិច្ចរបស់គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ

គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ មានភារកិច្ចគ្រប់គ្រង ត្រួតពិនិត្យ និងចេញបទប្បញ្ញត្តិពាក់ព័ន្ធនឹងសកម្មភាព និងការអភិវឌ្ឍ ដែលបង្កផលប៉ះពាល់ចំពោះតំបន់ឆ្នេរ រួមមាន ៖

១- កំណត់តំបន់គ្រប់គ្រងនៅក្នុងតំបន់ឆ្នេរ និងការអភិវឌ្ឍតំបន់ឆ្នេរ ។

២- កំណត់វិធានការក្នុងការអភិរក្សបរិស្ថាន ធនធានធម្មជាតិ និងការអភិវឌ្ឍ ។

៣- កំណត់យុទ្ធសាស្ត្រនៃការកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុតំបន់ឆ្នេរ ។

៤- គ្រប់គ្រងធនធានធម្មជាតិ និងសកម្មភាពក្នុងតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ។

៥- គ្រប់គ្រង ត្រួតពិនិត្យការបំពុលបរិស្ថាន ធនធានធម្មជាតិ ដែលមានប្រភពមកពីដី រួមមាន សារធាតុបំពុលរឹង រាវ សារធាតុបំពុលតាមខ្យល់ ដែលអាចជ្រាបចូលទៅក្នុងដែនទឹកតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ។

៦- ការពារ និងស្តារឡើងវិញតំបន់ឆ្នេរសមុទ្រ និងតំបន់កោះ ដោយកាត់បន្ថយការហូរច្រោះ និងផលប៉ះពាល់ផ្សេងទៀត ។

៧- អប់រំ ផ្សព្វផ្សាយ លើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

៨- អនុវត្តតាមវិធានការចាំបាច់ដទៃទៀត ដើម្បីគ្រប់គ្រង និងអភិវឌ្ឍដោយចីរភាពនៃតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ដោយពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥៣២** _ ការរៀបចំគោលនយោបាយ និងផែនការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំគោលនយោបាយ ផែនការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ។

បែបបទ និងនីតិវិធី នៃការរៀបចំគោលនយោបាយ និងផែនការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៥៣៣** _ ផែនការមេសម្រាប់រៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផែនការមេសម្រាប់គ្រប់គ្រងតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ។

**មាត្រា៥៣៤** _ ការរៀបចំផែនទីភូមិសាស្ត្រតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ ត្រូវរៀបចំផែនទីភូមិសាស្ត្រតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ។

**មាត្រា៥៣៥** _ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិរក្ស ការស្តារឡើងវិញ និងការគ្រប់គ្រងធនធានតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស ធនធានធម្មជាតិ និងស្តារធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ដោយសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ។

ការរៀបចំផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត មានគោលបំណងដូចខាងក្រោម ៖

១- គ្រប់គ្រង អភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព ។

២- អប់រំ ផ្សព្វផ្សាយ លើកទឹកចិត្តចំពោះការចូលរួមជាសាធារណៈ ។

៣- លើកវិធានការបន្សាំ ភាពធន់ទ្រាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ។

៤- រៀបចំផែនការប្រើប្រាស់ដី និងការកំណត់តំបន់គ្រប់គ្រងនៅក្នុងតំបន់ឆ្នេរ ។

៥- ចាត់វិធានការត្រួតពិនិត្យការបំពុលទឹកពីប្រភពខាងលើចូលទៅក្នុងតំបន់ឆ្នេរសមុទ្រ និងតំបន់កោះ ។

៦- ចាត់វិធានការក្នុងការការពារ និងស្តារឡើងវិញនូវផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង ។

៧- ចាត់វិធានការ ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៥៣៦** _ គោលការណ៍ណែនាំបច្ចេកទេស

បែបបទ នីតិវិធី និងគោលការណ៍ណែនាំបច្ចេកទេស ស្តីពីការគ្រប់គ្រងធនធានតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ត្រូវរៀបចំដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥៣៧**._ ការរៀបចំ និងការបង្កើតតំបន់ការពារធម្មជាតិពាក់ព័ន្ធតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ

ការបង្កើតតំបន់ការពារធម្មជាតិពាក់ព័ន្ធតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ត្រូវផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ លក្ខណៈវិនិច្ឆ័យ គោលបំណងនៃការគ្រប់គ្រង សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ សិទ្ធិកាន់កាប់ដីធ្លី និងកត្តាពាក់ព័ន្ធផ្សេងទៀត ។

ការបង្កើតតំបន់ការពារធម្មជាតិពាក់ព័ន្ធតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ត្រូវភ្ជាប់មកជាមួយនូវ៖

១- ការអធិប្បាយអំពីសារៈសំខាន់ខាងផ្នែកជីវៈចម្រុះ សណ្ឋានដី ភូគព្ភសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងការអភិរក្ស ។

២- ការអធិប្បាយអំពីលក្ខណៈច្បាប់នៃតំបន់ដែលត្រូវបង្កើត ភ្ជាប់ជាមួយនូវផែនទី ដែលបញ្ជាក់ពីទីតាំង ព្រំប្រទល់ និងទំហំ ។

៣- ការបញ្ជាក់ពីគោលបំណងនៃការគ្រប់គ្រងតំបន់ដែលត្រូវបង្កើត និងការគំរាមកំហែង ។

៤- ការសិក្សាលើការប្រើប្រាស់ធនធានធម្មជាតិ ដីធ្លី សេដ្ឋកិច្ចសង្គម ។

៥- របាយការណ៍អំពីលទ្ធផលនៃការពិគ្រោះយោបល់ ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ។

ការបង្កើតតំបន់ការពារធម្មជាតិពាក់ព័ន្ធតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥៣៨**._ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើការអនុវត្តផែនការយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រង អភិរក្ស និងស្ដារធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ។

**មាត្រា៥៣៩** ._ សកម្មភាពដែលអាចមានផលប៉ះពាល់អវិជ្ជមានចំពោះតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ

ការផ្ដល់ការឯកភាពចំពោះសកម្មភាពអភិវឌ្ឍន៍នៅតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ត្រូវធ្វើឡើង ស្របតាមវិធានដែលកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ៖

១- សកម្មភាព ឬគម្រោងស្នើសុំដោយរូបវន្តបុគ្គល ឬនីតិបុគ្គលស្របតាមផែនការប្រើប្រាស់ដី ដូចមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ។

២- សកម្មភាព ឬគម្រោងស្នើសុំដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវដាក់បញ្ចូលនូវវិធានក្នុងការបញ្ចៀស និងកាត់បន្ថយដល់កម្រិតអប្បបរមានូវផលប៉ះពាល់ចំពោះតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ។

៣- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និង ហានិភ័យគ្រោះមហន្តរាយ ត្រូវបានព្យាករណ៍ទុក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការហូរច្រោះ គ្រោះថ្នាក់ដោយទឹកជំនន់ និងភាពរាំងស្ងួត នៅតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ដោយរៀបចំនីតិវិធីនៃការជម្លៀសប្រជាពលរដ្ឋ និងការពារហេដ្ឋារចនាសម្ព័ន្ធ ។

៤- ផលប៉ះពាល់ពីការបញ្ចេញសំណល់រឹង សំណល់រាវ ចូលក្នុងតំបន់ឆ្នេរ ត្រូវបានកាត់បន្ថយដល់កម្រិតអប្បបរមា ឬបញ្ចៀសដោយមានការគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធផល ។

៥- ការងារចាក់បំពេញ ដើម្បីយកដីមកប្រើប្រាស់ ត្រូវបានកាត់បន្ថយឱ្យដល់កម្រិតអប្បបរមា ។

៦- លក្ខណៈវិនិច្ឆ័យដទៃទៀត ដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥៤០** ._ សកម្មភាពហាមឃាត់

សកម្មភាព ការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធ អាជីវកម្មរ៉ែ និងគម្រោងវិនិយោគ ដែលបង្កឱ្យមានការបាត់បង់ ឬការខូចខាតធនធានតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ត្រូវហាមឃាត់នៅក្នុងតំបន់ដូចខាងក្រោម ៖

១- ជម្រកសត្វសមុទ្រ និងប្រភេទសត្វកម្រ ។

២- តំបន់ស្មៅសមុទ្រ និងផ្កាថ្ម ។

៣- តំបន់ប្រភពចំណីសត្វព្រៃ និងមច្ឆជាតិ ។

៤- តំបន់ព្រៃកោងកាង ។

៥- តំបន់បង្កកំណើតមច្ឆជាតិទឹកសាប និងទឹកសមុទ្រ និងធនធានជលផលដទៃទៀត ។

## មាតិកាទី៨
## ការគ្រប់គ្រងធនធានទឹកដោយនិរន្តរភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ
## ផ្នែកទី១
## វិសាលភាព និងគោលការណ៍

**មាត្រា៥៤១** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះធនធានទឹកទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥៤២** ._ គោលការណ៍នៃការគ្រប់គ្រងធនធានទឹករួមគ្នា

ទឹក និងធនធានទឹក ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការអភិវឌ្ឍដោយផ្អែកលើគោលការណ៍ដូចខាងក្រោម ៖

១- សមធម៌សង្គម ៖ ធ្វើឱ្យមានសមភាពនៃការទទួលបានទឹក សម្រាប់អ្នកប្រើប្រាស់ទាំងអស់ ដោយយកចិត្តទុកដាក់ ចំពោះក្រុមមនុស្សដែលមិនសូវបានទទួលការយកចិត្តទុកដាក់ និងដែលមិនមានតំណាងគ្រប់គ្រាន់ ក្នុងការទទួលបានទឹកក្នុងបរិមាណ និងគុណភាពគ្រប់គ្រាន់ ដើម្បីទ្រទ្រង់សុខុមាលភាព ។

២- ប្រសិទ្ធផលសេដ្ឋកិច្ច ៖ ផ្តល់ផលប្រយោជន៍ខ្ពស់បំផុតឱ្យទៅអ្នកប្រើប្រាស់ជាអតិបរមា សម្រាប់ធនធានហិរញ្ញវត្ថុ និងធនធានទឹកដែលបានប្រើប្រាស់ ។

៣- និរន្តរភាពអេកូឡូស៊ី ៖ តម្រូវឱ្យធ្វើការបែងចែងទឹកគ្រប់គ្រាន់ ដើម្បីធ្វើឱ្យមាននិរន្តរភាពនៃមុខងារតាមធម្មជាតិនៃពពួកសត្វ និង រុក្ខជាតិដែលទទួលការគំរាមកំហែង និងប្រព័ន្ធអេកូឡូស៊ី ។

**មាត្រា៥៤៣** ._ កត្តាដែលត្រូវពិចារណាសម្រាប់ការអនុវត្ត

នៅពេលអនុវត្តការគ្រប់គ្រងធនធានទឹកជាលក្ខណៈអន្តរវិស័យ ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក និងឧត្តុនិយម ត្រូវពិចារណាចំណុចដូចខាងក្រោម ៖

១- គ្រប់ទិដ្ឋភាពនៃធនធានទឹក ។

២- ទំនាក់ទំនងរវាងធនធានទឹក និងសមាសភាគដទៃទៀតនៃបរិស្ថានធម្មជាតិ រួមមាន ដីធ្លី ជលផល រុក្ខជាតិ សត្វ ជាអាទិ៍ ។

៣- លក្ខខណ្ឌតម្រូវសម្រាប់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋ និងបរិស្ថានធម្មជាតិឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ។

**មាត្រា៥៤៤** ._ ការសហការរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ដែលទទួលខុសត្រូវលើការប្រើប្រាស់ទឹក ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានវារីជាតិ ដោយនិរន្តរភាពលើធនធានសត្វ និងរុក្ខជាតិក្នុងទឹកដែលមានជីវិត និងប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ ត្រូវសហការអនុវត្តការគ្រប់គ្រងធនធានទឹកជាលក្ខណៈរួមគ្នា ។

**មាត្រា៥៤៥** ._ ការរួមចំណែករបស់អ្នកពាក់ព័ន្ធ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវសហការជាមួយនីតិបុគ្គលសាធារណៈ និងឯកជន ដើម្បីគ្រប់គ្រង វិនិយោគ ធ្វើអាជីវកម្ម អភិរក្ស និងអភិវឌ្ឍធនធានទឹក ។

## ផ្នែកទី២
## ម្ចាស់កម្មសិទ្ធិលើទឹក និងធនធានទឹក

**មាត្រា៥៤៦** ._ កម្មសិទ្ធិលើធនធានទឹក

ទឹក និងធនធានទឹកទាំងអស់ ជាសម្បត្តិរដ្ឋ ។

**មាត្រា៥៤៧** ._ ការបែងចែកទឹក

ការបង្វែរទឹកឆ្លងដែនចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាត និងការឯកភាពពីរាជរដ្ឋាភិបាល និងមានការអនុម័តយល់ព្រមដោយស្ថាប័ននីតិបញ្ញត្តិ ។

## ជំពូកទី២
## ការទទួលខុសត្រូវលើធនធានទឹក
### ផ្នែកទី១
### ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៥៤៨ .**_ ភារកិច្ច និងតួនាទីរបស់ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹកត្រូវ ៖

១- គ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងធនធានទឹកនៃក្រមនេះ ។

២- ធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការបំពេញមុខងារ ។

**មាត្រា៥៤៩ .**_ បញ្ជីសារពើភណ្ឌធនធានទឹកថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរក្សាទុកនូវរាល់បញ្ជីសារពើភណ្ឌធនធានទឹកថ្នាក់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥៥០ .**_ ទិន្នន័យធនធានទឹក

ទិន្នន័យស្ដីពីបរិមាណ និងគុណភាពទឹក និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងទឹក ដែលប្រមូលបានដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ស្របតាមស្តង់ដារបច្ចេកទេស ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

ទិន្នន័យពាក់ព័ន្ធនឹងធនធានទឹក ត្រូវដាក់បញ្ជូនទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យ៉ាងហោចណាស់ ១ (មួយ) ឆ្នាំម្តង ។

**មាត្រា៥៥១ .**_ ទិន្នន័យដែលអាចស្វែងរកបាន

ទិន្នន័យ និងព័ត៌មាន ដូចមានចែងក្នុងមាត្រា៥៥០ ខាងលើនេះ ត្រូវផ្ដល់ជូនបានដោយឥតគិតថ្លៃដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ ក្នុងទិសដៅបម្រើផលប្រយោជន៍សាធារណៈ លើកលែងតែព័ត៌មានសម្ងាត់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចតម្រូវឱ្យមានការបង់ថ្លៃ ចំពោះពាក្យស្នើសុំទាំងឡាយ ដែលធ្វើឡើងក្នុងគោលបំណងអាជីវកម្ម ។

**មាត្រា៥៥២** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចរៀបចំលិខិតបទដ្ឋានគតិយុត្ត ដោយដាក់បញ្ចូល នូវចំណុចដូចខាងក្រោម ៖

១- តំបន់ហាមឃាត់ការប្រើប្រាស់ទឹក ឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ។

២- ការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការយកទឹក ឬ ប្រើប្រាស់ធនធានទឹក ។

៣- ការបង្កើត និងការគ្រប់គ្រងអាជ្ញាធរអាងទន្លេ ។

៤- បញ្ហាជាអាទិភាពសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការធនធានទឹកអាងទន្លេ ។

៥- ការលើកទឹកចិត្តឱ្យមានការស្រាវជ្រាវ ឬការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ ដែលនឹងរួមចំណែកក្នុងការកាត់បន្ថយសំណល់ និងកែលម្អគុណភាពទឹក និងបង្កើនប្រសិទ្ធផលនៃការប្រើប្រាស់ទឹក ។

៦- ការលើកទឹកចិត្ត និងមិនលើកទឹកចិត្ត ទាក់ទងនឹងយន្តការហិរញ្ញវត្ថុ រួមមានការប្រើប្រាស់ប្រាក់កម្រៃ និងតារាងថ្លៃតាមអត្រាថយចុះ ដើម្បីលើកទឹកចិត្តឱ្យមានការប្រើប្រាស់ទឹកដោយប្រសិទ្ធផល ។

៧- ការបង្កើត និង គ្រប់គ្រងសមាគមកសិករប្រើប្រាស់ប្រើប្រាស់ទឹក ។

៨- ការប្រកាសស្តីពីតំបន់ប្រើប្រាស់ទឹក ដែលត្រូវការពារធម្មជាតិ ។

៩- ការកំណត់ និងគ្រប់គ្រងតំបន់ការពារគ្រោះទឹកជំនន់ ។

១០- ការលុប ឬផ្លាស់ប្តូរលំហូរទឹកតាមធម្មជាតិ ។

១១- ការរៀបចំបទប្បញ្ញត្តិស្តីពីការអភិវឌ្ឍទឹកក្រោមដី និងឧស្សាហកម្មអភិវឌ្ឍន៍ទឹកក្រោមដី រួមមាន៖

- គុណវុឌ្ឍិសម្រាប់អ្នកមៅការជីកអណ្តូង និងអ្នកដំឡើងអណ្តូងខួង
- លក្ខខណ្ឌតម្រូវដែលបញ្ជាក់ថា ម៉ាស៊ីនខួងអណ្តូងបានធ្វើប្រតិបត្តិការ ស្របតាមវិញ្ញាបនបត្រនៃអ្នកកាន់កាប់លិខិតអនុញ្ញាតខួងអណ្តូង

- ការយកសំណាក ធ្វើតេស្ត វិភាគ សិក្សា និងដាក់បញ្ចូលទិន្នន័យអណ្ដូងខួង និង បញ្ជូនទិន្នន័យទាំងនេះទៅក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក

- ការស្តារអណ្តូងឡើងវិញ និងវិធីសាស្ត្រ និងលក្ខខណ្ឌតម្រូវ ដែលត្រូវអនុវត្ត ចំពោះប្រតិបត្តិការស្តារអណ្តូងឡើងវិញ

- សកម្មភាពជួសជុលអណ្តូង

- ការត្រួតពិនិត្យអណ្តូង

- វិធីសាស្ត្រនៃការខួង និងការជីកអណ្តូង និងការកំណត់ប្រភពទឹកក្រោមដី

- វិធានការ និងការប្រុងប្រយ័ត្នជាមុន ដែលត្រូវអនុវត្តមុនពេល និងក្នុងអំឡុងពេលនៃការខួង ការជីក និងការកែលម្អអណ្តូង

- គោរពតាមការថែរក្សានានាសម្រាប់អណ្តូង ដែលមិនដំណើរការ

- ជួសជុល និងថែទាំអណ្តូងមិនដំណើរការ

- ការថែទាំ និងធ្វើប្រតិបត្តិជួសជុលអណ្តូងជាប្រចាំ ។

១២- ការកំណត់បន្ទុកសេវា និងថ្លៃចំណាយនានា សម្រាប់ការគ្រប់គ្រងធនធានទឹក ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## ផ្នែកទី២
## ការសម្របសម្រួលរបស់រាជរដ្ឋាភិបាល

**មាត្រា៥៥៣ ._** គណៈកម្មាធិការជាតិគ្រប់គ្រង និងរៀបចំផែនការអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងគណៈកម្មាធិការជាតិទន្លេមេគង្គ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងរៀបចំផែនការអាងទន្លេ ។

**មាត្រា៥៥៤ ._** ភារៈកិច្ច និងតួនាទីរបស់គណៈកម្មាធិការជាតិគ្រប់គ្រង និងរៀបចំផែនការអាងទន្លេ

គណៈកម្មាធិការជាតិគ្រប់គ្រង និងរៀបចំផែនការអាងទន្លេ មានភារកិច្ច និងតួនាទីដូចខាងក្រោម ៖

១- សម្របសម្រួល និងត្រួតពិនិត្យលើការរៀបចំផែនការយុទ្ធសាស្ត្រជាតិធនធានទឹក សម្រាប់គោលបំណងនៃការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ ។

២- អង្កេតតាមដាន និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិធនធានទឹក ។

៣- សម្រុះសម្រួល និងដោះស្រាយទំនាស់ក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និង ការអភិវឌ្ឍអាងទន្លេ ។

៤- និងអនុវត្តកិច្ចការដទៃទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។

**មាត្រា៥៥៥ .**_ សិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមប្រើប្រាស់ អភិវឌ្ឍ និងគ្រប់គ្រងទន្លេអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិ និងកាតព្វកិច្ចចាត់ចែងចំណែកសមស្រប និងដោយស្មើភាព ក្នុងការប្រើប្រាស់ ការអភិវឌ្ឍ និងការគ្រប់គ្រងទន្លេអន្តរជាតិ ក្នុងទឹកដីរបស់ខ្លួន ស្របតាមសិទ្ធិ និង កាតព្វកិច្ច ដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

**មាត្រា៥៥៦ .**_ ការប្រើប្រាស់ដែលសមស្រប និងមានប្រសិទ្ធភាពបំផុត

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវយកចិត្តទុកដាក់ឱ្យមានការប្រើប្រាស់ទឹកអាងទន្លេ មេគង្គលើគ្រប់វិស័យ ស្របតាមគោលការណ៍របស់គណៈកម្មាធិការជាតិទន្លេមេគង្គ ។

## ជំពូកទី៣
## ការរៀបចំផែនការធនធានទឹក
## ផ្នែកទី១
## ក្រសួង ស្ថាប័នទទួលបន្ទុក

**មាត្រា៥៥៧ .**_ ផែនការយុទ្ធសាស្ត្រធនធានទឹកថ្នាក់ជាតិ និងផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំសម្រាប់ការបែងចែក និងការគ្រប់គ្រង ធនធានទឹកដោយនិរន្តរភាព ដើម្បីបំពេញតាមតម្រូវការទឹកក្នុងពេលអនាគត តាមរយៈការរៀបចំ ផែនការយុទ្ធសាស្ត្រធនធានទឹកថ្នាក់ជាតិ និងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៥៥៨ .**_ ការចូលរួមរបស់អ្នកពាក់ព័ន្ធ

នៅក្នុងការរៀបចំផែនការធនធានទឹកជាយុទ្ធសាស្ត្រថ្នាក់ជាតិ និងផែនការធនធានទឹកនៃអាងទន្លេ ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវសហការជាមួយគ្រប់ភាគីដែលពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ មានជាអាទិ៍ អាជ្ញាធរថ្នាក់ក្រោមជាតិ វិស័យឯកជន ក្រុមអ្នកទទួលប្រយោជន៍ និងនីតិបុគ្គលផ្សេងៗទៀត ។

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រធនធានទឹកថ្នាក់ជាតិ និងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៥៥៩** ._ ការធ្វើប្រតិភូកម្មអំណាច

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចធ្វើប្រតិភូកម្មអំណាចឱ្យអាជ្ញាធរអាងទន្លេ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រធនធានទឹកថ្នាក់ជាតិ និងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៥៦០** ._ ការរៀបចំ និងអនុវត្តផែនការធនធានទឹកអាងទន្លេ

អាជ្ញាធរអាងទន្លេ ដែលទទួលបន្ទុកក្នុងការរៀបចំ និងអនុវត្តផែនការធនធានទឹកអាងទន្លេស្របតាមមាត្រា៥៥៧ នៃក្រមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានានៃមាតិកានេះ ។

**មាត្រា៥៦១** ._ ព័ត៌មានសម្រាប់គោលបំណងនៃការរៀបចំផែនការ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវប្រមូលយក រក្សាទុក និងប្រើប្រាស់ព័ត៌មានសម្រាប់គោលបំណងនៃការរៀបចំផែនការដោយ ៖

១- ធ្វើការផ្ទៀងផ្ទាត់ជាប្រចាំ និងរក្សាទុកកំណត់ត្រា អំពីបរិមាណ និងគុណភាពទឹក ។

២- ប្រមូលព័ត៌មានអំពីតម្រូវការទឹក និងព័ត៌មានស្តីពីផលប៉ះពាល់នៃការគ្រប់គ្រងទឹកចំពោះប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ធនធានជលផលទឹកសាប និងសមុទ្រ និងប្រភេទសត្វ និងរុក្ខជាតិដែលរងការគំរាមកំហែង ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ។

៣- ប្រមូលព័ត៌មានអំពីតម្រូវការទឹកនាពេលអនាគត ។

៤- ធ្វើការកែលម្អជាប្រចាំចំពោះបណ្តាញជាតិសម្រាប់ការអង្កេតតាមដាន ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធ ។

**មាត្រា៥៦២** ._ ក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចេកទេស

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចេកទេស ។

សមាសភាពនៃក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចេកទេស ត្រូវមានអ្នកជំនាញបច្ចេកទេស ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ។ គុណវុឌ្ឍិនៃអ្នកជំនាញបច្ចេកទេស ត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

អ្នកជំនាញបច្ចេកទេស ត្រូវធ្វើការផ្តល់យោបល់លើ ៖

១- សេចក្តីព្រាងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិធានទឹក និងសេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ។

២- វិសោធនកម្ម ឬបច្ចុប្បន្នភាព នៃផែនការយុទ្ធសាស្ត្រថ្នាក់ជាតិធានទឹក និងផែនការធនធានទឹកអាងទន្លេ ។

៣- ការផ្តល់សិទ្ធិអំណាចផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## ផ្នែកទី២
## ផែនការយុទ្ធសាស្ត្រជាតិធនធានទឹក

**មាត្រា៥៦៣** ._ គោលដៅនៃផែនការយុទ្ធសាស្ត្រជាតិធនធានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំផែនការយុទ្ធសាស្ត្រជាតិធនធានទឹក ដែលកំណត់អំពី ៖

១- សន្តិសុខនៃការផ្គត់ផ្គង់ទឹករយៈពេលវែង ។

២- និរន្តរភាពនៃធនធានទឹក ។

៣- កិច្ចការពារប្រព័ន្ធអេកូឡូស៊ី ដែលពឹងផ្អែកលើលំហូរទឹក និងបរិស្ថាន ។

៤- ការបែងចែក និងប្រើប្រាស់ធនធានទឹកដោយប្រសិទ្ធភាព និងយុត្តិធម៌ ដើម្បីទប់ស្កាត់គ្រោះមហន្តរាយ និងវិវាទ ។

**មាត្រា៥៦៤** ._ លក្ខខណ្ឌតម្រូវនៃផែនការយុទ្ធសាស្ត្រជាតិធនធានទឹក

ផែនការយុទ្ធសាស្ត្រជាតិធនធានទឹក ត្រូវដាក់បញ្ចូលចំណុចដូចខាងក្រោម ៖

១- ការកំណត់អត្តសញ្ញាណប្រព័ន្ធអេកូឡូស៊ី និងប្រភេទសត្វ រុក្ខជាតិ ទទួលរងការគំរាមកំហែង ដែលពឹងផ្អែកលើលំហូរទឹក និងបរិស្ថាន ។

២- ការព្យាករណ៍ទុកលើតម្រូវការទឹករយៈពេលវែង ។

៣- កំណត់អត្តសញ្ញាណលើនិន្នាការអាកាសធាតុ និងធាតុអាកាសរយៈពេលវែង ។

៤- ការព្យាករណ៍ពីភាពអាចស្វែងរកបាន និងការប្រែប្រួលទឹកនាពេលអនាគត ។

៥- ជម្រើសដើម្បីបំពេញតម្រូវការទឹកនាពេលអនាគត ។

៦- ជម្រើសសម្រាប់ការគ្រប់គ្រងការបំពេញតម្រូវការទឹកនាពេលអនាគត ។

៧- ការកំណត់អាទិភាពនៃការប្រើប្រាស់ទឹក ។

៨- កំណត់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមិនរាំងស្ទះដល់លំហូរបរិស្ថាន និងមានលំហូរផ្លូវទឹកគ្រប់គ្រាន់សម្រាប់ការធ្វើនាវាចរណ៍ ។

៩- យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះរាំងស្ងួត ។

១០- យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះទឹកជំនន់ ។

១១- និងគោលបំណងនៃការអនុវត្តការគ្រប់គ្រងគុណភាពទឹក ។

## ផ្នែកទី៣
## ផែនការធនធានទឹកអាងទន្លេ

**មាត្រា៥៦៥ .**_ គោលដៅនៃផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំផែនការធនធានទឹកអាងទន្លេដើម្បី ៖

១- កំណត់ភាពអាចស្វែងរកបានទឹកសម្រាប់គោលបំណងនីមួយៗ ។

២- ផ្តល់ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ទឹកដោយនិរន្តរភាព ។

៣- កំណត់អាទិភាព និងយន្តការសម្រាប់ដោះស្រាយតម្រូវការទឹកនាពេលអនាគត ។

៤- ផ្តល់ក្របខ័ណ្ឌសម្រាប់បង្កើតការបែងចែកទឹក ។

៥- ផ្តល់ក្របខ័ណ្ឌសម្រាប់ការបែងចែកទឹក ។

៦- ផ្តល់ក្របខ័ណ្ឌសម្រាប់ស្តារឡើងវិញតំបន់ដែលទទួលរងការហូតហែង ដែលកើតឡើងនៅក្នុងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ឬទន្លេ ដើម្បីកាត់បន្ថយការបាត់បង់ធនធានទឹក ។

**មាត្រា៥៦៦** ._ ទឹកក្រោមដី

ផែនការធនធានទឹកអាងទន្លេ ត្រូវកំណត់ក្របខ័ណ្ឌគ្រប់គ្រងលើការការទាញយកទឹកពីក្រោមដី នៅក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យល់ឃើញថាមានហានិភ័យណាមួយកើតឡើង ដោយការទាញយកទឹក ឬការប្រើប្រាស់ទឹកក្រោមដី ក្នុងតំបន់ណាមួយ អាចបង្កផលប៉ះពាល់ចំពោះ ៖

១- ភាពអាចស្វែងរកបានទឹកសម្រាប់អ្នកប្រើប្រាស់បច្ចុប្បន្ន ។

២- តម្រូវការទឹកសម្រាប់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ។

៣- គុណភាពទឹក ។

៤- ការសម្រេចបានតាមគោលបំណង ឬលទ្ធផលរំពឹងទុក ដែលបានកំណត់នៅក្នុងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៥៦៧** ._ ការប្រកាសផ្អាកការអភិវឌ្ឍជាបណ្តោះអាសន្ន

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ជូនដំណឹងអំពីការរៀបចំផែនការធនធានទឹកអាងទន្លេ ការផ្អាកជាបណ្តោះអាសន្នចំពោះការអភិវឌ្ឍនៅក្នុងតំបន់ជម្រាលនៃអាងទន្លេនោះ ត្រូវមានសុពលភាពរហូតដល់ពេលដែល ៖

១- ផែនការធនធានទឹកទទួលការឯកភាព ។

២- ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ជូនដំណឹងអំពីការលុបចោល ការរៀបចំផែនការធនធានទឹកអាងទន្លេវិញ ។

**មាត្រា៥៦៨** ._ វិធាននៃការផ្អាកការអភិវឌ្ឍជាបណ្តោះអាសន្ន

ក្នុងករណីដែលមានការផ្អាកការអភិវឌ្ឍជាបណ្តោះអាសន្ន ដូចមានចែងក្នុងមាត្រា៥៦៧ នៃក្រមនេះមានសុពលភាព នោះ ៖

១- មិនអនុញ្ញាតឱ្យមានការដាក់ពាក្យស្នើសុំអភិវឌ្ឍ ឬធ្វើការពិចារណា ឬផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំអភិវឌ្ឍឡើយ ទោះបីជាការដាក់ពាក្យស្នើសុំធ្វើឡើង មុនពេលការផ្អាកជាបណ្តោះអាសន្ននោះមានសុពលភាពក៏ដោយ ។ មិនអនុញ្ញាតឱ្យមានដំណើរការអភិវឌ្ឍឡើយ នៅក្នុងករណីដែលការអនុញ្ញាតនោះ អាចបង្កផលប៉ះពាល់ ដូចខាងក្រោម ៖

- កំណើនបរិមាណទឹក ដែលត្រូវយកមកប្រើប្រាស់

- ការផ្លាស់ប្តូរទីតាំង ដែលត្រូវយកទឹកមកប្រើប្រាស់
- កំណើនអត្រាទឹក ដែលត្រូវយកមកប្រើប្រាស់
- ការផ្លាស់ប្តូរចំពោះលក្ខខណ្ឌលំហូរទឹក ដែលត្រូវយកមកប្រើប្រាស់
- ការផ្លាស់ប្តូរចំពោះគោលដៅ នៃការយកទឹកមកប្រើប្រាស់ ។

២- ការងារថ្មីមិនត្រូវអនុញ្ញាតឱ្យចាប់ផ្តើមដំណើរការឡើយនៅក្នុងតំបន់ហាមឃាត់ជាបណ្តោះអាសន្ន ។

៣- ការងារដែលបានចាប់ផ្តើមដំណើរការរួចហើយ អាចអនុញ្ញាតឱ្យដំណើរការរហូតដល់បញ្ចប់ ប៉ុន្តែត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក និងត្រូវគោរពតាមកាលបរិច្ឆេទនៃការបញ្ចប់ និងលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

៤- ការងារបញ្ចប់រួចហើយ មិនត្រូវពង្រីកបន្ថែម ឬផ្លាស់ប្តូរឡើយ ។

**មាត្រា៥៦៩** ._ សុពលភាពនៃផែនការធនធានទឹកអាងទន្លេ

អាងទន្លេមួយ អាចមានផែនការធនធានទឹកអាងទន្លេតែមួយប៉ុណ្ណោះ លើកលែងមានការរៀបចំផែនការដាច់ដោយឡែក សម្រាប់ធនធានទឹកដីលើ និងទឹកក្រោមដី ។

**មាត្រា៥៧០** ._ លក្ខខណ្ឌតម្រូវនៃផែនការធនធានទឹកអាងទន្លេ

សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ត្រូវ ៖

១- កំណត់អំពីគោលបំណងនៃសេចក្តីព្រាងផែនការ ។

២- ដាក់បញ្ចូលផែនទីនៃតំបន់រៀបចំផែនការដែលបានស្នើឡើង ។

៣- ចែងអំពីធនធានទឹក និងគោលបំណងនៃការអនុវត្តសេចក្តីព្រាងផែនការចំពោះធនធានទឹកនោះ ។

៤- កំណត់អាទិភាពនៃអ្នកប្រើប្រាស់ធនធានទឹក និងធនធានទឹក សម្រាប់បំពេញតម្រូវការចាំបាច់របស់មនុស្ស និងប្រព័ន្ធអេកូឡូស៊ី មុននឹងបែងចែកទឹក និងធនធានទឹកទៅឱ្យអ្នកប្រើប្រាស់ក្នុងគោលដៅផ្សេងទៀត ។

៥- កំណត់លទ្ធផលរំពឹងទុក ដែលទាក់នឹងអេកូឡូស៊ី ប្រព័ន្ធអេកូឡូស៊ីដែលស្ថិតក្នុងសមាសភាគរបស់វា ដែលរួមមាន ទឹកក្រោមដី អាងបង្ហូរទឹក ល្អាងទឹកក្រោមដី និងអនុល្អាងទឹកក្រោមដី និងប្រភពទឹកផ្សេងៗ សម្រាប់ការគ្រប់គ្រងទឹកដោយនិរន្តរភាព ។

៦- ប្រើប្រាស់ព័ត៌មានល្អបំផុតដែលអាចស្វែងរកបាន និងកំណត់យុទ្ធសាស្ត្រដើម្បីសម្រេចបានលទ្ធផលរំពឹងទុក ។

៧- កំណត់យុទ្ធសាស្ត្រសម្រាប់ការរៀបចំការបែងចែកទឹក សម្រាប់តំបន់គម្រោងដែលបានស្នើឡើង ។

៨- កំណត់អំពីវិធានគ្រប់គ្រងបរិស្ថាន និងវិធានចែករំលែកទឹក ។

៩- កំណត់អត្តសញ្ញាណហេដ្ឋារចនាសម្ព័ន្ធទឹក ។

១០- កំណត់អត្តសញ្ញាណនៃកម្រិតផ្គត់ផ្គង់ទឹកពេញលេញសម្រាប់ទំនប់ទឹក រួមមានហេដ្ឋារចនាសម្ព័ន្ធដូចមានកំណត់នៅក្នុងចំណុចទី៩ ខាងលើ ។

១១- កំណត់លក្ខខណ្ឌតម្រូវនៃការអង្កេតតាមដានទឹក និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងការរៀបចំរបាយការណ៍ ដែលអាចដាក់បញ្ចូលនូវសូចនាករសុខភាពអាងទន្លេ ដើម្បីជួយក្នុងការវាយតម្លៃប្រសិទ្ធភាពនៃយុទ្ធសាស្ត្រគ្រប់គ្រង ដើម្បីសម្រេចបាននូវលទ្ធផលដែលបានរំពឹងទុក ដូចមានកំណត់នៅក្នុងចំណុចទី៥ខាងលើ ។

១២- កំណត់ពីលក្ខខណ្ឌតម្រូវនៃការរៀបចំរបាយការណ៍តាមពេលកំណត់ ។

១៣- ដាក់បញ្ចូលតារាងពេលវេលានៃយន្តការ សម្រាប់ការអនុវត្តសេចក្តីព្រាងផែនការ ។

១៤- ដាក់បញ្ចូលព័ត៌មានអំពីទឹកដែលមិនទាន់បានបែងចែក សម្រាប់គោលបំណងនៃការប្រើប្រាស់ក្នុងពេលអនាគត និងអាទិភាព និងដំណើរការសម្រាប់ការបែងចែក ឬបម្រុងទុក ។

១៥- រៀបចំដំណើរសម្រាប់ការផ្តល់ ការបម្រុងទុក ឬ ការគ្រប់គ្រងទឹក ដែលមិនទាន់បានបែងចែក ។

១៦- កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការកែតម្រូវលើសេរភាព ក្នុងករណីចាំបាច់ ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនៃផែនការ ។

១៧- និងកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ដោះស្រាយភាពហួតហែង ដែលបានកើតឡើងនៅក្នុងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ។

**មាត្រា៥៧១** ._ ផែនការទន្លេមេគង្គ

ផែនការធនធានទឹកអាងទន្លេ ដែលអនុវត្តចំពោះធនធានទឹកទន្លេមេគង្គ ត្រូវពិចារណាអំពី ៖

១- ចរន្តលំហូរទឹកឆ្លងដែនចូលមកកាន់ព្រះរាជាណាចក្រកម្ពុជា ។

២- លក្ខខណ្ឌតម្រូវផ្លូវច្បាប់ ឬស្មើភាពគ្នា សម្រាប់ចរន្តលំហូរទឹកឆ្លងដែនផ្នែកខាងក្រោមនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីច្បាប់នៃការប្រើប្រាស់ផ្លូវទឹកអន្តរជាតិដែលមិនពាក់ព័ន្ធនឹងការធ្វើនាវាចរណ៍ ។

៣- បញ្ហាបរិស្ថានឆ្លងដែនដទៃៗទៀត ។

៤- និងអត្ថិភាព ប្រតិបត្តិការ និងលក្ខខណ្ឌតម្រូវ នៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលទាក់ទងនឹងទន្លេមេគង្គ ។

**មាត្រា៥៧២** ._ សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ

សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ត្រូវផ្តល់នូវក្របខ័ណ្ឌសម្រាប់ការបង្កើតសិទ្ធិទទួលបានទឹក ដោយកំណត់នូវចំណុចដូចខាងក្រោម ៖

១- គោលដៅនៃលំហូរបរិស្ថាន ។

២- គោលបំណងសន្តិសុខនៃសិទ្ធិទទួលបានទឹក ។

៣- សូចនករនៃការអនុវត្តសម្រាប់គោលបំណងនៃលំហូរបរិស្ថាន និងគោលបំណងសន្តិសុខនៃសិទ្ធិទទួលបានទឹក ។

៤- អាទិភាពសម្រាប់ការផ្តល់សិទ្ធិទទួលបានទឹក ។

**មាត្រា៥៧៣** ._ ការពិចារណាសម្រាប់សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវពិចារណាទៅលើចំណុចខាងក្រោម នៅពេលរៀបចំសេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ៖

១- បរិមាណ និងគុណភាពទឹក នៅក្នុងតំបន់ផែនការ ។

២- គោលបំណង និងអាទិភាព ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយនិរន្តរភាព ។

៣- ផែនការថ្នាក់តំបន់ សម្រាប់តំបន់នោះ ។

៤- រយៈពេល ប្រេកង់ ទំហំ និងការកំណត់ពេលនៃលំហូរទឹក ដែលមានសារៈសំខាន់ក្នុងការគាំទ្រប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រភេទសត្វ រុក្ខជាតិ ដែលស្ថិតក្នុងស្ថានភាពគ្រោះ

ថ្នាក់ និងការទទួលរងការគំរាមកំហែង ដូចបានវាយតម្លៃដោយប្រើព័ត៌មានវិទ្យាសាស្ត្រល្អបំផុត ដែលអាចស្វែងរកបាន ។

៥- ការជន់លិច និងការស្រកទៅវិញដែលមានប្រយោជន៍ សម្រាប់គាំទ្រប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រភេទសត្វ រុក្ខជាតិ ដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងការទទួលរងការគំរាមកំហែង ។

៦- កម្រិតទឹកក្រោមដី និងដំណើរការហូរទឹកពីលើដីទៅក្រោមដី ដែលមានសារៈសំខាន់ក្នុងការគាំទ្រប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រភេទសត្វ រុក្ខជាតិ ដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងការទទួលរងការគំរាមកំហែង ។

៧- ការចូលរួមគ្រប់គ្រងទឹកនៃទីជម្រក ឬប្រព័ន្ធពាក់ព័ន្ធ ដែលរួមមាន ព្រៃឈើ និងដីសើម ដែលគាំទ្រដល់គោលបំណងនៃផែនការធនធានទឹកអាងទន្លេ ។

៨- សិទ្ធិដែលមានស្រាប់ក្នុងការទទួលបាន និងប្រើប្រាស់ទឹក ។

៩- តម្រូវការទឹកនាពេលអនាគតរបស់ព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន តម្រូវការផ្នែកវប្បធម៌ សេដ្ឋកិច្ច បរិស្ថាន និងសង្គម ។

១០- គុណតម្លៃផ្នែកវប្បធម៌ សេដ្ឋកិច្ច បរិស្ថាន និងសង្គម ។

១១- ការវាយតម្លៃផ្នែកបច្ចេកទេសសម្រាប់សេចក្ដីព្រាងផែនការ ។

១២- ផលប៉ះពាល់នៃសេចក្ដីព្រាងផែនការទៅលើទឹក ដែលមិនបានកំណត់នៅក្នុងសេចក្ដីព្រាងផែនការ ។

១៣- ផលប៉ះពាល់នៃការយក ឬប្រើប្រាស់ទឹកដែលមិនមានកំណត់នៅក្នុងសេចក្ដីព្រាងផែនការ ទៅលើទឹកដែលមានកំណត់នៅក្នុងសេចក្ដីព្រាងផែនការ ។

១៤- យុទ្ធសាស្ត្រ និងគោលនយោបាយគ្រប់គ្រងធនធានដោយនិរន្តរភាព សម្រាប់អាងទន្លេ ឬអាងទឹកក្រោមដី និងតំបន់ឆ្នេរពាក់ព័ន្ធ ។

១៥- ការដាក់បញ្ជូនមតិយោបល់លើសំណើសេចក្ដីព្រាងផែនការទាំងអស់ ។

១៦- ផលប្រយោជន៍សាធារណៈ ។

**មាត្រា៥៧៤** ._ ការជូនដំណឹងនៃសេចក្ដីព្រាងផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវជូនដំណឹងទៅក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាធារណជន នៅពេលដែលសេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ត្រូវបានរៀបចំរួច ដោយបញ្ជាក់អំពី ៖

១- ទីកន្លែងដែលអាចទទួលបានសំណៅនៃសេចក្តីព្រាងផែនការ ។

២- ការដាក់បញ្ជូនមតិយោបល់ជាលាយលក្ខណ៍អក្សរលើសេចក្តីព្រាងផែនការ របស់រូបវន្តបុគ្គល ឬនីតិបុគ្គលពាក់ព័ន្ធ ។

៣- កាលបរិច្ឆេទ នៃការដាក់បញ្ជូនមតិយោបល់លើសេចក្តីព្រាងផែនការ ដែលត្រូវធ្វើឡើងយ៉ាងហោចណាស់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ក្រោយពីថ្ងៃជូនដំណឹងជាសាធារណៈ និងទីកន្លែង និងបុគ្គលដែលត្រូវទទួលការដាក់បញ្ជូនមតិយោបល់នោះ ។

**មាត្រា៥៧៥** ._ ការពិចារណាទៅលើមតិយោបល់សាធារណជន

មុននឹងបញ្ចប់ផែនការធនធានទឹកអាងទន្លេ ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវពិចារណាលើរាល់ការដាក់បញ្ជូនមតិយោបល់ទាំងអស់ ទាក់ទងនឹងសេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៥៧៦** ._ ផែនការចុងក្រោយ

ផែនការធនធានទឹកអាងទន្លេចុងក្រោយ មិនមានអនុភាពអនុវត្តនោះទេ លុះត្រាតែទទួលបានការឯកភាពពីរាជរដ្ឋាភិបាល ។

**មាត្រា៥៧៧** ._ ផែនការដែលទទួលបានការឯកភាព

ផែនការធនធានទឹកអាងទន្លេដែលទទួលបានការឯកភាព ត្រូវអស់សុពលភាពក្រោយរយៈពេល ១០ (ដប់) ឆ្នាំ លើកលែងតែមុនរយៈពេលនេះ ផែនការនោះត្រូវបាន ៖

១- និរាករណ៍ ។

២- ឬជំនួសដោយផែនការធនធានទឹកមួយផ្សេងទៀត ដែលបានចាប់ផ្តើមអនុវត្ត និងដែលកំណត់ថាជាផែនការជំនួស ។

**មាត្រា៥៧៨** ._ ការកែប្រែ និងការរៀបចំផែនការថ្មី

ក្រសួង ស្ថាប័ន ទទួលបន្ទុកធនធានទឹក អាចធ្វើការកែប្រែ ឬរៀបចំផែនការធនធានទឹកអាងទន្លេថ្មីមួយដើម្បីជំនួសផែនការដែលមានស្រាប់ ដោយខ្លួនឯង ឬតាមរយៈការស្នើសុំពីអ្នកពាក់ព័ន្ធដទៃទៀត ។

**មាត្រា៥៧៩** ._ ការធ្វើយុត្តិកម្មសម្រាប់ការកែប្រែ ឬការរៀបចំផែនការថ្មី

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចកែប្រែ ឬរៀបចំផែនការធនធានទឹកអាងទន្លេថ្មីស្របតាមមាត្រា៥៧៨ នៃក្រមនេះ នៅក្នុងករណីដែល ៖

១- លទ្ធផលរំពឹងទុកនៃផែនការធនធានទឹកអាងទន្លេ មិនអាចសម្រេចបាន ។

២- ឬគោលបំណងនៃផែនការធនធានទឹកអាងទន្លេ ឬយុទ្ធសាស្ត្រដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនៅក្នុងផែនការ លែងមានលក្ខណៈសមស្របសម្រាប់តំបន់ផែនការនោះទៀតហើយ ។

**ជំពូកទី៤**

**ការចេញលិខិតអនុញ្ញាត**

**ផ្នែកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា៥៨០** ._ សិទ្ធិប្រើប្រាស់ធនធានទឹក

បុគ្គលគ្រប់រូបមានសិទ្ធិយក និងប្រើប្រាស់ធនធានទឹក ដោយពុំចាំបាច់មានលិខិតអនុញ្ញាតចំពោះចំណុចដូចខាងក្រោម ៖

១- តម្រូវការចាំបាច់របស់មនុស្សជាមូលដ្ឋាន រួមមាន ការហូបចុក បោកគក់ ការងូតអនាម័យ ការស្រោចស្រពសួនច្បារ និងដំណាំ ឬគោលបំណងជាលក្ខណៈគ្រួសារដទៃទៀត។

២- ការពន្លត់អគ្គិភ័យ និងគោលបំណងនៃការសង្គ្រោះបន្ទាន់ដទៃទៀត ។

**មាត្រា៥៨១** ._ ការការពារសិទ្ធិស្របច្បាប់របស់បុគ្គលដទៃ

ការយក និងការប្រើប្រាស់ធនធានទឹក មិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់បុគ្គលដទៃនោះឡើយ ។

**មាត្រា៥៨២ ._** ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដី

ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដី មានសិទ្ធិប្រមូលយក និងប្រើប្រាស់ទឹកភ្លៀង និងទឹកដែលហូរទៅតាមធម្មជាតិកាត់លើដីកម្មសិទ្ធិ ដោយពុំចាំបាច់មានលិខិតអនុញ្ញាត ។

ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដីផ្នែកខាងក្រោមមានសិទ្ធិយក និងប្រើប្រាស់បាននូវបរិមាណទឹកដែលហូរពីដីខាងលើ ប៉ុន្តែបុគ្គលនោះពុំមានសិទ្ធិរារាំងចរន្តទឹកហូរដោយការសាងសង់ផ្លូវ របង ទំនប់ រនាំង ឬត្រពាំង ដែលរារាំងដល់ចរន្តទឹកធម្មជាតិ ។

**មាត្រា៥៨៣ ._** សកម្មភាពដែលតម្រូវឱ្យមានលិខិតអនុញ្ញាត

ត្រូវហាមឃាត់ចំពោះការធ្វើសកម្មភាពដូចខាងក្រោម លើកលែងតែមានលិខិតអនុញ្ញាត ៖

១- ការប្រើប្រាស់ទឹក ការបង្វែរទឹក និងការយកទឹក មិនស្របតាមគោលបំណងមាត្រា ៥៨០ មាត្រា៥៨១ និងមាត្រា៥៨២ នៃក្រមនេះ ។

២- ការសាងសង់ ឬប្រតិបត្តិការ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលនាំឱ្យមានការប្រើប្រាស់ ការបង្វែរទឹក និងការយកទឹក មិនស្របតាមគោលបំណងមាត្រា៥៨០ មាត្រា៥៨១ និង មាត្រា៥៨២ នៃក្រមនេះ ។

៣- ការទាញយកខ្សាច់ ដី ថ្ម ក្រួស រ៉ែ ប្រេងកាត និងឧស្ម័ន ពីបាត ច្រាំង ឬឆ្នេរសមុទ្រ ទន្លេ ស្ទឹង ព្រែក អូរ បឹងបួ ។

៤-ការលុប ការរៀបចំប្រព័ន្ធលំហូរទឹក ការជីកប្រឡាយ ការបង្វែរទឹកនៃទន្លេ ស្ទឹង ព្រែក អូរ បឹងបួ ប្រឡាយ អាងទឹក ប្រភពទឹកស្អាត និងអាងទឹកធម្មជាតិ ។

**មាត្រា៥៨៤ ._** កម្រិតនៃការប្រើប្រាស់ ការបង្វែរទឹក និងការយកធនធានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីកម្រិតនៃការប្រើប្រាស់ ការបង្វែរទឹក និងការយកធនធានទឹក សម្រាប់គោលបំណងណាមួយដោយពុំចាំបាច់មានលិខិតអនុញ្ញាត ស្របតាមមាត្រា៥៨៣ នៃក្រមនេះ ។

**មាត្រា៥៨៥ ._** ការផ្តល់ការឯកភាពលើការស្នើសុំលិខិតអនុញ្ញាត

ការផ្តល់ការឯកភាពលើការស្នើសុំលិខិតអនុញ្ញាត ត្រូវគោរពតាមលក្ខខណ្ឌតម្រូវនានាដែលកំណត់ដោយក្រមនេះ ។

## ផ្នែកទី២
## លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ

**មាត្រា៥៨៦** ._ ការចេញលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវចេញលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ស្របតាមផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៥៨៧** ._ គោលបំណងនៃលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ

លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ត្រូវផ្តល់សិទ្ធិឱ្យអ្នកកាន់នូវលិខិតអនុញ្ញាតនោះ ប្រើប្រាស់ទឹកទៅតាមកម្រិត និងបរិមាណមួយដែលចាំបាច់សម្រាប់ប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធទឹក ។

**មាត្រា៥៨៨** ._ លក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីលក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ។

## ផ្នែកទី៣
## សិទ្ធិទទួលបានទឹក

**មាត្រា៥៨៩** ._ បញ្ជីសិទ្ធទទួលបានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរក្សាទុកនូវបញ្ជីសិទ្ធិទទួលបានទឹក ។

ព័ត៌មានដែលត្រូវដាក់បញ្ចូលទៅក្នុងសិទ្ធិទទួលបានទឹក ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៥៩០** ._ លក្ខខណ្ឌសម្រាប់សិទ្ធិទទួលបានទឹក

ការប្រើប្រាស់ទឹក ការបង្វែរទឹក និងការយកធនធានទឹក អាចធ្វើឡើងសិទ្ធិទទួលបានទឹកដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

**មាត្រា៥៩១** ._ សិទ្ធិស្របច្បាប់ក្នុងការទទួលបានទឹក

ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដី អាចដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹកទៅក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ដើម្បីយកទឹកមកប្រើប្រាស់ពី ៖

១- ប្រភពទឹកនានា បឹងបួ ឬប្រភពទឹកក្រោមដី ដែលស្ថិតនៅលើ ឬនៅជាប់ដីណាមួយ ។

២- អាងទឹកក្រោមដី ។

៣- លំហូរទឹកកាត់តាមដី ។

៤- ហេដ្ឋារចនាសម្ព័ន្ធ ដែលអនុវត្តតាមលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ អាចផ្គត់ផ្គង់ទឹកដល់ដីដែលពាក់ព័ន្ធបាន ។

**មាត្រា៥៩២** ._ នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីនីតិវិធី និងលក្ខខណ្ឌតម្រូវក្នុងការដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹក ។

**មាត្រា៥៩៣** ._ ការជូនដំណឹងជាសាធារណៈ

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹកយល់ឃើញថា មានព័ត៌មានគ្រប់គ្រាន់សម្រាប់ផ្តល់ការឯកភាពលើពាក្យស្នើសុំសិទ្ធិទទួលបានទឹក ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវជូនដំណឹងជាសាធារណៈអំពីពាក្យស្នើសុំនោះ ដោយបញ្ជាក់អំពី ៖

១- ព័ត៌មានលម្អិតនៃពាក្យស្នើសុំនោះ ។

២- ទីកន្លែងដែលត្រូវពិនិត្យលើពាក្យស្នើសុំនោះ ។

៣- កាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹកជាលាយលក្ខណ៍អក្សរ ដែលបានបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យ៉ាងហោចណាស់ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីមានការជូនដំណឹងជាសាធារណៈ ។

**មាត្រា៥៩៤** ._ នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់ការឯកភាព ឬបដិសេធ

នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់ការឯកភាព ឬបដិសេធ ចំពោះសិទ្ធិទទួលបានទឹក ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៥៩៥** ._ អញ្ញត្តិកម្មសម្រាប់លំហូរបរិស្ថាន

លំហូរបរិស្ថាន ត្រូវអនុវត្តតាមបរិមាណជាអតិបរមានៃការបែងចែងទឹក ។

**មាត្រា៥៩៦** ._ ការប្រកាសអំពីសិទ្ធិទទួលបានទឹក

មុនការិយបរិច្ឆេទជលសាស្ត្រនីមួយៗ ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវប្រកាសអំពីសិទ្ធិទទួលបានទឹកសម្រាប់ឆ្នាំបន្ទាប់ ស្របតាមប្រភេទអាទិភាព និងវិធាននៃការបែងចែងទឹក ដែលកំណត់នៅក្នុងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៥៩៧** ._ សិទ្ធិទទួលបានទឹកដែលបានប្រកាសរួច

សិទ្ធិទទួលបានទឹកដែលបានប្រកាសរួច ៖

១- ត្រូវបញ្ជាក់អំពីភាគរយនៃបរិមាណជាផ្លូវការ អំពីសិទ្ធិទទួលបានទឹកដែលត្រូវអនុវត្តសម្រាប់ការិយបរិច្ឆេទជលសាស្ត្រនីមួយៗ ។

២- ត្រូវសម្រេចនៅមុនការិយបរិច្ឆេទជលសាស្ត្រ ដែលត្រូវប្រកាសពាក់ព័ន្ធនឹងសិទ្ធិទទួលបានទឹក ។

៣- ត្រូវកំណត់ស្របតាមបរិមាណទឹកដែលមានតាមរដូវកាល ចំពោះសិទ្ធិទទួលបានទឹក ។

៤- អាចកើនឡើងនូវបរិមាណទឹកក្នុងអំឡុងពេលនៃការិយបរិច្ឆេទជលសាស្ត្រ ។

៥- អាចខុសគ្នាទៅតាមតាមអនុតំបន់នៃអាងទន្លេ ។

៦- អាចធ្វើឡើងខុសគ្នាទៅតាមសិទ្ធិទទួលបានទឹកដូចបានកំណត់ក្នុងក្រុមអាទិភាព ។

៧- មិនសំដៅដល់ការចេញអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត សម្រាប់ការផ្គត់ផ្គង់ទឹកតាមទីប្រជុំជន ឬទីក្រុង ។

**មាត្រា៥៩៨** ._ សិទ្ធិទទួលបានទឹកដែលកំណត់ក្នុងផែនការធនធានទឹកអាងទន្លេ

ផែនការធនធានទឹកអាងទន្ល ត្រូវកំណត់អំពីសិទ្ធិទទួលបានទឹក ៖

១- ការយកទឹកត្រូវអនុវត្តតាមផែនការធនធានទឹកអាងទន្លេ ។

២- ក្នុងករណីមានភាពមិនស្របគ្នារវាងផែនការធនធានទឹកអាងទន្លេ និងសិទ្ធិទទួលបានទឹក នោះផែនការធនធានទឹកអាទន្លេត្រូវមានឧត្តមានុភាព ។

៣- សិទ្ធិទទួលបានទឹក មិនអាចមានការកែប្រែណាមួយដែលនាំឱ្យកាត់បន្ថយ ឬមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលក្ខខណ្ឌនៃការយកទឹកក្នុងអំឡុងពេលអនុវត្តផែនការឡើយ លើកលែងតែមានការយល់ព្រមលើសំណងការខូចខាត ដែលក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹកផ្តល់ឱ្យ ។

**មាត្រា៥៩៩** ._ ការកែសម្រួលទៅលើបរិមាណជាផ្លូវការ

បរិមាណជាផ្លូវការក្នុងការបែងចែងទឹក និងលក្ខខណ្ឌផ្សេងទៀត អាចត្រូវធ្វើការកែសម្រួលនៅចុងបញ្ចប់នៃផែនការធនធានទឹកអាងទន្លេ ដែលត្រូវអនុវត្ត ។

ការកែសម្រួលទៅលើបរិមាណជាផ្លូវការក្នុងការបែងចែងទឹក និងលក្ខខណ្ឌផ្សេងទៀតខាងលើនេះ មិនមានការសងសំណងការខូចខាតនោះទេ ។

**មាត្រា៦០០** ._ ការព្រមព្រៀងផ្គត់ផ្គង់ស្របតាមការអនុញ្ញាតសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ

ក្នុងករណីដែលលិខិតអនុញ្ញាតណាមួយ អនុញ្ញាតឱ្យប្រើប្រាស់ធនធានទឹកដែលផ្គត់ផ្គង់លើហេដ្ឋារចនាសម្ព័ន្ធ ដែលកំពុងធ្វើប្រតិបត្តិការនៅក្រោមលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ អ្នកកាន់កាប់លិខិតអនុញ្ញាតប្រើប្រាស់ធនធានទឹក និងអ្នកកាន់លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ត្រូវចុះកិច្ចព្រមព្រៀងផ្គត់ផ្គង់ធនធានទឹកជាមួយគ្នា លើកលែងតែភាគីទាំងពីរជានីតិបុគ្គលតែមួយ ។

**មាត្រា៦០១** ._ កិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំកិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកមួយសម្រាប់ការស្តុកទុក និង/ឬការចែកចាយទឹកដល់អ្នកកាន់អាជ្ញាប័ណ្ណទឹក និងលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានទឹក ។

កិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹក អាចមានលក្ខណៈខុសគ្នាពីទីតាំងមួយទៅទីតាំងមួយ ។

**មាត្រា៦០២** ._ ពាក្យសុំកិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹក

កិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកសម្រាប់ទីតាំងចំពោះសិទ្ធិទទួលបានទឹកនោះ ត្រូវអនុវត្ត ចំពោះសិទ្ធិទទួលបានទឹក លើកលែងតែមានកិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកដែលបាន ៖

១- យល់ស្របរវាងអ្នកកាន់លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ និងអ្នកកាន់សិទ្ធិទទួលបានទឹក ។

២- និងដាក់បញ្ជូនទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

## ផ្នែកទី៤
## ការការពារទន្លេ និងស្ទឹង

**មាត្រា៦០៣ ._** សកម្មភាពដែលទទួលបានការអនុញ្ញាត

បុគ្គលគ្រប់រូបអាចដាក់ពាក្យសុំលិខិតអនុញ្ញាតទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ដើម្បីធ្វើសកម្មភាពដូចខាងក្រោម ៖

១- ការជីកផ្លូវទឹក បឹង ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក ។

២- និងចាក់បំពេញលុបផ្លូវទឹក បឹងធម្មជាតិ ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក ។

**មាត្រា៦០៤ ._** នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យសុំលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធី និងលក្ខខណ្ឌតម្រូវ សម្រាប់ការដាក់ពាក្យសុំលិខិតអនុញ្ញាត ។

**មាត្រា៦០៥ ._** ការជូនដំណឹងជាសាធារណៈ

នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យល់ថាមានព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើសេចក្តីសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាត ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹកត្រូវជូនដំណឹងជាសាធារណៈ អំពីពាក្យស្នើសុំលិខិតអនុញ្ញាត ដូចខាងក្រោម ៖

១- ព័ត៌មានលម្អិតនៃពាក្យស្នើសុំលិខិតអនុញ្ញាតនោះ ។

២- ទីកន្លែងដែលត្រូវពិនិត្យលើពាក្យសុំលិខិតអនុញ្ញាតនោះ ។

៣- កាលបរិច្ឆេទ នៃការដាក់ពាក្យសុំលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដែលបានបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យ៉ាងហោចណាស់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ក្រោយពីថ្ងៃជូនដំណឹងជាសាធារណៈ ។

**មាត្រា៦០៦** ._ នីតិវិធី និងការពិចារណាចំពោះការឯកភាព ឬបដិសេធ

នីតិវិធី និងលក្ខខណ្ឌនៃការផ្តល់ឯកភាព ឬការបដិសេធលើពាក្យសុំលិខិតអនុញ្ញាតត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

## ផ្នែកទី៥
## អ្នកអភិវឌ្ឍន៍ទឹកក្រោមដី

**មាត្រា៦០៧** ._ ការដាក់ពាក្យសុំ

បុគ្គលគ្រប់រូបអាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ដូចខាងក្រោម ៖

១- អ្នកខួងអណ្តូងខួង ។

២- អ្នកជីកអណ្តូងខួង ។

៣- អ្នកដំឡើងម៉ាស៊ីនបូមទឹកក្រោមដី ។

**មាត្រា៦០៨** ._ នីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីនីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ ។

**មាត្រា៦០៩** ._ នីតិវិធីសម្រាប់ការឯកភាព ឬបដិសេធ

នីតិវិធី និងលក្ខខណ្ឌសម្រាប់ការឯកភាព ឬបដិសេធលើពាក្យស្នើសុំវិញ្ញាបនបត្រ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៦១០** ._ លក្ខខណ្ឌនានានៃវិញ្ញាបនបត្រ

លក្ខខណ្ឌនានានៃវិញ្ញាបនបត្រ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៦១១** ._ នីតិវិធីក្នុងការលុបចោលវិញ្ញាបនបត្រ

នីតិវិធីក្នុងការលុបចោលវិញ្ញាបនបត្រត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៦១២** ._ ភស្តុតាងនៃវិញ្ញាបនបត្រ

មន្ត្រីមានសមត្ថកិច្ច អាចតម្រូវឱ្យរូបវន្តបុគ្គលផ្តល់ភស្តុតាងជាវិញ្ញាបនបត្រ សម្រាប់ការធ្វើអធិការកិច្ច ក្នុងករណីដែលមន្ត្រីមានសមត្ថកិច្ចនោះ សង្ស័យថាមាន ៖

១- ការខួង ការជីក ការធ្វើឱ្យជ្រៅ ការពង្រីក ឬការដាក់បំពង់ទប់ដី ក្នុងប្រតិបត្តិការធ្វើអណ្តូងស្នប់ ។

២- ការដកចេញ ការដាក់ជំនួស ការប្តូរ ឬការជួសជុលបំពង់ទប់ដី និងបំពង់ហ្វីលក្នុងប្រតិបត្តិការធ្វើអណ្តូងស្នប់ ។

៣- បញ្ឈប់ដំណើរការនៃការធ្វើអណ្តូងខួង ។

៤- ការដំឡើង ការដាក់ជំនួស ការប្តូរ ឬការដកចេញម៉ូទ័របូមទឹកពីអណ្តូងស្នប់ ។

**មាត្រា៦១៣** ._ សកម្មភាពដែលត្រូវហាមឃាត់

ត្រូវហាមឃាត់ចំពោះ រាល់សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយពុំមានវិញ្ញាបនបត្រសម្រាប់មន្ត្រីអធិការកិច្ច ដើម្បីចុះធ្វើអធិការកិច្ច ។

**មាត្រា៦១៤** ._ លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍

បុគ្គលគ្រប់រូបដែលធ្វើការទាក់ទងនឹងអណ្តូងខួង សម្រាប់គោលបំណងមុខរបរ ឬអាជីវកម្ម ត្រូវរៀបចំរបាយការណ៍ ទៅក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

ព័ត៌មានលម្អិតសម្រាប់ដាក់បញ្ចូលក្នុងរបាយការណ៍ ត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៦១៥** ._ កំណត់ត្រាសកម្មភាព

អ្នកកាន់វិញ្ញាបនបត្រត្រូវរក្សាទុកព័ត៌មានអំពីសកម្មភាពដែលខ្លួនបានអនុវត្ត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

អ្នកកាន់វិញ្ញាបនបត្រត្រូវផ្តល់ព័ត៌មានដូចមានចែងក្នុងកថាខណ្ឌខាងលើ ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ក្នុងករណីមានការស្នើសុំ ។

## ផ្នែកទី៦
## ការដកហូតការអនុញ្ញាត

**មាត្រា៦១៦** ._ លក្ខខណ្ឌសម្រាប់ការដកហូតការអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីលក្ខខណ្ឌ និងនីតិវិធីសម្រាប់ការដកហូតការអនុញ្ញាត ។

## ជំពូកទី៥
## ការតម្រូវឱ្យមានការអនុញ្ញាត

**មាត្រា៦១៧** ._ ការអនុញ្ញាតចំពោះការផ្គត់ផ្គង់ និងប្រើប្រាស់ទឹក

បុគ្គលគ្រប់រូបមិនត្រូវអនុញ្ញាតឱ្យយក ផ្គត់ផ្គង់ ឬប្រើប្រាស់ទឹក លើកលែងតែទទួលបានការអនុញ្ញាត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៦១៨** ._ ការរំលោភបំពានទៅលើលិខិតអនុញ្ញាត

អ្នកកាន់លិខិតអនុញ្ញាត មិនត្រូវបំពានទៅលើលក្ខខណ្ឌដូចបានកំណត់នៅក្នុងលិខិតអនុញ្ញាតនោះទេ ។

**មាត្រា៦១៩** ._ ការចេញចូលបរិវេណដីឯកជន របស់មន្ត្រីមានសមត្ថកិច្ច

ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដីឯកជន មិនត្រូវបដិសេធមិនឱ្យមន្ត្រីដែលមានសមត្ថកិច្ចនៃក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ចេញចូលដីឯកជនរបស់ខ្លួនដើម្បីបំពេញភារកិច្ចក្នុងការធ្វើការសិក្សាផ្នែកបច្ចេកទេស ការវាយតម្លៃ ឬការអង្កេតតាមដាន លើកលែងតែ ៖

១- ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក មិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដីឯកជន ។

២- ឬមន្ត្រីមានសមត្ថកិច្ចមិនបានផ្តល់ភស្តុតាងអំពីអត្តសញ្ញាណ និងពុំមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

## ជំពូកទី៦
## ការរៀបចំផែនការធនធានទឹកអាងទន្លេអន្តរកាល

**មាត្រា៦២០** ._ បញ្ជីសកម្មភាពអាទិភាពសម្រាប់ការរៀបចំផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំតារាងពេលវេលាសម្រាប់ការអនុវត្តលើការរៀបចំផែនការធនធានទឹកអាងទន្លេ ក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយក្រមនេះចូលជាធរមាន ។

**មាត្រា៦២១** ._ ករណីលើកលែងចំពោះសិទ្ធិទទួលបានទឹក

បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹក ដោយពុំចាំបាច់មានលិខិតអនុញ្ញាតចំពោះសកម្មភាពដូចខាងក្រោម ៖

១- ការស្រោចស្រពដីនៃតំបន់ទាំងមូលដែលតិចជាង ១០ (ដប់) ហិកតា ។

២- ការផ្គត់ផ្គង់ទឹកស្អាត ដែលប្រើប្រាស់ទឹក តិចជាង ៥០ (សែសិប) ម៉ែត្រគូប ក្នុងមួយថ្ងៃ ។

៣- ឬថាមពលវារីអគ្គិសនីដើរដោយលំហូរទឹកទន្លេ ឬបច្ចេកទេសថាមពលវារីអគ្គិសនីដែលមិនតម្រូវឱ្យមានការបង្ខាំង ការបង្វែរ ឬការទាញយកទឹកមកប្រើ ។

**មាត្រា៦២២** ._ ការអនុលោមតាមវិធានច្បាប់របស់នីតិបុគ្គល

នីតិបុគ្គលដែលធ្វើសកម្មភាព ដូចមានចែងក្នុងជំពូកទី៤ នៃមាតិកានេះ ដោយពុំមានការអនុញ្ញាតជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវអនុវត្តតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងជំពូកទី៤ នៃមាតិកានេះ។

**មាត្រា៦២៣** ._ ការកំណត់អំពីច្រាំងទន្លេ ឬឆ្នេរសមុទ្រ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីចម្ងាយ និងលក្ខណៈរូបសាស្ត្រនៃច្រាំងទន្លេ និងឆ្នេរសមុទ្រ និងសមាសភាគនៃអាងទន្លេ ។

## មាតិកាទី៩
## និរន្តរភាពជលផល
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៦២៤**._ ក្របខ័ណ្ឌនិរន្តរភាពនៃធនធានជលផល

ការគ្រប់គ្រងធនធានជលផលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវថែងអំពី ៖

១- ការដាក់បញ្ចូលនូវគោលបំណងនិងគោលការណ៍អភិរក្សបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ទៅក្នុងជលផល និងការគ្រប់គ្រងធនធានជលផល ។

២- ការដាក់បញ្ចូលនូវបទប្បញ្ញត្តិនៃការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ទៅក្នុងរដ្ឋបាលជលផល និងការគ្រប់គ្រងធនធានជលផល ។

៣- ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ និងផលវិបាកផ្នែកបរិស្ថាននៃការអភិវឌ្ឍវារីវប្បកម្ម ។

**មាត្រា៦២៥**._ ធនធានដែលអាចទទួលបាន

អង្គភាពទទួលបន្ទុកជលផល និងគ្រប់គ្រងធនធានជលផល ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន ៖

១- ការអនុវត្ត និងការបកស្រាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងជលផលឱ្យស្របទៅនឹងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ តាមការចាំបាច់។

២- ការអនុវត្តក្របខ័ណ្ឌរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ជលផល ដោយយោងទៅលើក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវជលផល របស់ព្រះរាជាណាចក្រកម្ពុជា ។

៣- អង្គភាពទទួលបន្ទុកជលផល និងសកម្មភាពគ្រប់គ្រងធនធានជលផល ដែលធ្វើឡើងដោយអង្គភាពទទួលបន្ទុកជលផល និងក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងអង្គភាពទទួលបន្ទុកជលផលអាចធ្វើប្រតិភូកម្មសមត្ថកិច្ច ភារកិច្ច និងការទទួលខុសត្រូវទាក់ទងនឹងធនធានជលផល ឬតំបន់គ្រប់គ្រងភូមិសាស្ត្រ និងរដ្ឋបាលដែលមានធនធានជលផល ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងអង្គភាពទទួលបន្ទុកជលផលត្រូវសហការគ្នាដើម្បី គ្រប់គ្រងធនធានជលផលទាំងនោះ និងតំបន់គ្រប់គ្រងភូមិសាស្ត្រ និងរដ្ឋបាលដោយប្រសិទ្ធភាព និងនិរន្តរភាព ។

**មាត្រា៦២៦**._ ការអភិរក្ស និងវិធានការគ្រប់គ្រងធនធានជលផល

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបង្កើត និងអនុវត្តវិធានការអភិរក្ស និងគ្រប់គ្រងដើម្បីទប់ស្កាត់បង្ក្រាបការនេសាទលើសកម្រិត និងការនេសាទក្នុងលក្ខណៈបំផ្លាញសម្រាប់សន្និធិជលផល ឬសន្និធិចម្រុះ និងដើម្បីធានានូវសន្តិសុខស្បៀង ចំណូល និងការងារ ។

វិធានការគ្រប់គ្រងធនធានជលផលនោះត្រូវ ៖

១- ផ្អែកលើភស្តុតាងបច្ចេកទេស និងវិទ្យាសាស្ត្រដែលមាន ។

២- គាំទ្រការស្រាវជ្រាវបែបវិទ្យាសាស្ត្រដែលកំពុងបន្ត និងការប្រមូលទិន្នន័យ ។

## ជំពូកទី២
## ការគ្រប់គ្រងជលផលទឹកសាបដោយនិរន្តរភាព

**មាត្រា៦២៧**._ លិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រទៅដល់ការអភិរក្ស និងការគ្រប់គ្រងជលផលទឹកសាបដោយនិរន្តរភាព ដែលរួមមាន ៖

១- សហគមន៍ជលផល ជលផលស្រែត្រពាំង វាលភក់ ល្បាប់ ត្រី សហគមន៍ ការគ្រប់គ្រងសហគមន៍ជលផល និងការចែករំលែកផលប្រយោជន៍សហគមន៍ ស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព និងការគ្រប់គ្រងរួមគ្នា ដូចមានចែងក្នុងក្រមនេះ ។

២- ដាក់បញ្ចូលនូវទិន្នន័យស្តីពីធនធានទឹក គុណភាព និងលំហូរទឹក ការបោះបង់ចោលស្តុកជីវៈចម្រុះ និងកត្តាពាក់ព័ន្ធបរិស្ថានដទៃទៀត ទៅក្នុងអង្គភាពទទួលបន្ទុកជលផល និងការគ្រប់គ្រងធនធានជលផល ។

៣- យុទ្ធសាស្ត្រ និងឧបករណ៍គ្រប់គ្រងដើម្បីអភិរក្សជីវៈចម្រុះ ដែលរួមមាន ប្រភេទសត្វ រុក្ខជាតិដែលមិនមែនជាគោលដៅ ទីជម្រកវារីជាតិ ដែលរួមមានវាលទំនាបដែលលិចទឹកនៅរដូវទឹកឡើង បឹង អន្លង់ ថ្មខ្សាច់នៅបាតផ្លូវទឹកហូរ ព្រៃលិចទឹក សារព័ន្ធរុក្ខជាតិ ផ្នែកនៅតាមមាត់ទន្លេ និងប្រព័ន្ធអេកូឡូស៊ី ។

៤- ការធ្វើផែនទី និងការអង្កេតតាមដានធនធានជលផល ដែលរួមមានទីជម្រកចាំបាច់ផលិតកម្មជលផល លក្ខខណ្ឌតម្រូវនៃលំហូរជលវិទ្យា និងតំបន់ផ្នែកនៅតាមមាត់ស្ទឹងបឹងសំខាន់។

៥- ការផ្តល់ជូននូវព័ត៌មានជលផល ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

៦- សកម្មភាពដែលត្រូវបានហាមឃាត់ក្នុងជលផលទឹកសាប ដែលរួមមាន ការហាមឃាត់ការប្រមូលផល នូវប្រភេទសត្វ រុក្ខជាតិដែលជិតផុតពូជ និងរងការគំរាមកំហែង ដែលមានក្នុងបញ្ជីថ្នាក់ជាតិ និងអន្តរជាតិ ។

៧- ប្រភេទឧបករណ៍នេសាទ ដែលត្រូវបានហាមឃាត់ក្នុងការលក់ កាន់កាប់ ឬប្រើប្រាស់ក្នុងជលផលទឹកសាប ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត ។

៨- ទាក់ទិននឹងផលស្តុកធនធានជលផលបន្លាស់ទី កិច្ចសហប្រតិបត្តិការផ្ទាល់ ឬជាមួយដៃគូអភិវឌ្ឍន៍ថ្នាក់តំបន់ អន្តរជាតិ និងអ្នកពាក់ព័ន្ធ នៅតាមបណ្តោយទន្លេមេគង្គ ដែលមានទស្សនៈក្នុងការធានានូវការអភិរក្ស និងការលើកកម្ពស់សមិទ្ធផលទិន្នផលប្រកបដោយនិរន្តរភាពនៃប្រភេទសត្វ រុក្ខជាតិទាំងនោះពាសពេញតំបន់របស់ពួកគេ ។

៩- លក្ខណៈវិនិច្ឆ័យសម្រាប់ការអភិរក្ស និងការស្តារឡើងវិញនៃជម្រកវារីជាតិដែលរួមមានការគ្រប់គ្រងការបំពុល និងការថែរក្សាតំណភ្ជាប់រវាងទីជម្រកវារីជាតិ ។

១០- ការអង្កេតតាមដានទៅលើផលប៉ះពាល់មកពីហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក ដែលរួមមានបន្លាស់ទីមច្ឆជាតិ ដំណើរចាក់គរកករ និងសីតុណ្ហភាពទឹក ។

១១- អង្កេតតាមដានផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ទៅលើធនធានជលផល ។

១២- វិធីសាស្ត្រសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃឧបករណ៍នេសាទថ្មី និងវិធីសាស្ត្រ មុននឹងអនុញ្ញាត ឬហាមឃាត់ការប្រើប្រាស់ទាំងនោះ ។

# ជំពូកទី៣
## ការគ្រប់គ្រងជលផលសមុទ្រដោយនិរន្តរភាព

**មាត្រា៦២៨ ._** លិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំ លិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រនូវការអភិរក្ស និងការគ្រប់គ្រងដោយនិរន្តរភាពនៃជលផលសមុទ្រ ដែលរួមមានដូចខាងក្រោម ៖

១- និយ័តកម្ម និងកម្រិតទៅលើការទទួលបានធនធានជលផលសមុទ្រក្នុងទឹក ក្រោមសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ដោយជលយានសម្រាប់នេសាទ ដែលមានសញ្ជាតិខ្មែរ និងបរទេស តាមរយៈការធ្វើកំណត់ត្រា និងការផ្តល់អាជ្ញាប័ណ្ណជលយានសម្រាប់នេសាទ និងការបង្កើតកិច្ចព្រមព្រៀងការទទួលបានការនេសាទ និងការពង្រឹងការអនុវត្ត ។

២- ការប្រមូលទិន្នន័យ ស្តីពីកិច្ចខិតខំប្រឹងប្រែងផ្នែកជលផលសមុទ្រ ការចាប់ និងការចូលចត ដែលធ្វើឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រមូលផលធនធានធម្មជាតិ ឬទិញធនធានជលផល ដែលប្រមូលបានពីជលផលសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជា។

៣- ការការពារពីសកម្មភាពនេសាទដែលប៉ះពាល់ជាអវិជ្ជមានទៅលើតំណភ្ជាប់ នៃជម្រកបាតសមុទ្រសំខាន់ៗ ដែលរួមមានព្រៃកោងកាង និងវាលភក់ ស្មៅសមុទ្រ និងផ្កាថ្ម និងតំបន់ថ្មប៉ប្រះទឹក ។

៤- ការការពារពីសកម្មភាពនេសាទ និងមិនមែននេសាទ ដូចជាការចាក់បំពេញដី ដំណើរចាក់គរកករ ការបោះចោលសំណល់ និងការប្រើអួន ។

៥- ការបង្កើត និងការគ្រប់គ្រង តំបន់គ្រប់គ្រងជលផលសមុទ្រ ដើម្បីធ្វើនិយ័តកម្មទៅលើសកម្មភាពនេសាទ និងការពារទីជម្រក ព្រៃកោងកាង និងវាលភក់ ផ្កាថ្ម និងផ្កាថ្មប៉ប្រះទឹក និងស្មៅសមុទ្រ ។

៦- ការគ្រប់គ្រងសហគមន៍នេសាទ និងតំបន់ នេសាទសហគមន៍ និងការចែករំលែកផលប្រយោជន៍សហគមន៍ ។

៧- ទាក់ទិននឹងផលស្តុកធនធានជលផលបន្លាស់ទី កិច្ចសហប្រតិបត្តិការផ្ទាល់ឬជាមួយដៃគូអភិវឌ្ឍន៍ថ្នាក់តំបន់ ឬអន្តរជាតិ អ្នកពាក់ព័ន្ធ និងរដ្ឋពាក់ព័ន្ធដែលមានទស្សនៈក្នុងការធានា

នូវការអភិរក្ស និងការលើកកម្ពស់សមិទ្ធផល នៃទិន្នផលប្រកបដោយនិរន្តរភាព នៃប្រភេទសត្វ រុក្ខជាតិទាំងនោះពាសពេញប្រភេទរបស់ពួកគេ ។

៨- សកម្មភាពដែលត្រូវបានហាមឃាត់ក្នុងជលផលសមុទ្រ ដែលរួមមាន ការហាមឃាត់ ការប្រមូលផល ការទិញ ការធ្វើជាកម្មសិទ្ធិ ផៃ និងការផ្តល់ជូនដើម្បីលក់ប្រភេទសត្វ រុក្ខជាតិ ដែលជិតផុតពូជ និងត្រូវបានគំរាមកំហែង ស្របតាមច្បាប់ជាតិ និងអន្តរជាតិ ឬតារាងប្រភេទសត្វ រុក្ខជាតិទាំងនោះដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។

៩- ប្រភេទឧបករណ៍នេសាទ ដែលត្រូវបានហាមឃាត់ក្នុងការលក់ ធ្វើជាកម្មសិទ្ធិ ឬប្រើប្រាស់ក្នុងជលផលសមុទ្រ ។

១០- ការនាំចូលមកព្រះរាជាណាចក្រកម្ពុជា នូវធនធានជលផលសមុទ្រ តម្រូវឱ្យអ្នកនាំចូលបញ្ជាក់ថាធនធានបែបនោះត្រូវបានប្រមូលផល ស្របតាមច្បាប់ជលផលនៃប្រទេសដែលជាអ្នកប្រមូលផលផ្ទាល់ ។

១១- ការគ្រប់គ្រង សមត្ថភាពនេសាទ តាមរយៈការត្រួតពិនិត្យការអង្កេតតាមដាន និងការឃ្លាំមើល ។

១២- ការទប់ស្កាត់ការនេសាទខុសច្បាប់ មិនបានរាយការណ៍ និងមិនបានធ្វើនិយ័តកម្ម ។

១៣- កម្រិតផលនេសាទដោយការចាប់ប្រមូលនៃប្រភេទសត្វ រុក្ខជាតិដែលមិនមែនជាគោលដៅ ដែលមិនរួមបញ្ចូល សត្វស្លាបសមុទ្រ ថនិកសត្វសមុទ្រ អណ្តើកសមុទ្រ តាមរយៈការប្រើប្រាស់ឧបករណ៍ញែកចេញនូវផលនេសាទសមុទ្រ និងកម្មវិធីអ្នកសង្កេតការណ៍ ។

១៤- ការស្រាវជ្រាវជលផលសមុទ្រ ។

**មាត្រា៦២៩**._ ផែនការគ្រប់គ្រងជលផល

រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធសហគមន៍ សហគមន៍នេសាទ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតផែនការគ្រប់គ្រងជលផលលើឧបករណ៍នេសាទ និងប្រភេទជាក់លាក់ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រដែលមាន និងចំណេះដឹងមូលដ្ឋានដូចខាងក្រោម ៖

១- រដូវ និងតំបន់បិទសកម្មភាពនេសាទ ។

២- សេចក្តីលម្អិតនៃជលផលពាក់ព័ន្ធ ដែលរួមមានចំនួននៃជលយាននេសាទដែលពាក់ព័ន្ធ ប្រភេទ និងបរិមាណ នៃឧបករណ៍នេសាទដែលត្រូវប្រើប្រាស់ ប្រភេទសត្វ រុក្ខជាតិសមុទ្រដែលត្រូវប្រមូលផល តំបន់ហាមឃាត់ និងចម្ងាយភូមិសាស្ត្រនៃជលផល ។

៣- ការប្រមាណនៃទិន្នផលផលដោយនិរន្តរភាពពីសកម្មភាពជលផល និងលក្ខខណ្ឌអាចកើតមាន ដែលរួមមានសេចក្តីសង្ខេបព័ត៌មានដែលត្រូវបានប្រើប្រាស់ក្នុងការកំណត់នេះ ។

៤- កំណត់អំពីវិធានការអភិរក្ស និងគ្រប់គ្រង ដែលត្រូវបានអនុវត្តចំពោះជលផល ដើម្បីកាត់បន្ថយការនេសាទលើសការកំណត់ និងការនេសាទមានលក្ខណៈបំផ្លាញ មានជាអាទិ៍ការប្រើប្រាស់ឧបករណ៍អួន ។

៥- ដំណើរការសម្រាប់អង្កេតតាមដាន និងការត្រួតពិនិត្យជាថ្មីទៅលើផែនការគ្រប់គ្រងជលផល ត្រូវមានការសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ សហគមន៍ និងសហគមន៍នេសាទ ។

**មាត្រា៦៣០ .**_ វិធានការអភិរក្ស និងការគ្រប់គ្រង

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តនូវវិធានការអភិរក្ស និងគ្រប់គ្រង ដើម្បីធានានូវនិរន្តរភាព នៃធនធានជលផលសមុទ្រ ៖

១- កម្រិត និងកូតាមួយៗប្រចាំថ្ងៃ ក្នុងរយៈពេលយូរ សម្រាប់ប្រភេទសត្វ រុក្ខជាតិសមុទ្រជាក់លាក់ ។

២- កម្រិតទំហំ និងទម្ងន់អប្បបរមា និងអតិបរមាសម្រាប់ប្រភេទសត្វ រុក្ខជាតិសមុទ្រក្រោម ឬលើ ក្នុងករណីដែលមិនត្រូវបានអនុញ្ញាតឱ្យមានការប្រមូលផល ។

៣- ប្រព័ន្ធចូលដែលកម្រិតរួច ទាក់ទងនឹងការប្រមូលផលធនធានជលផលសមុទ្រជាក់លាក់ សន្និធិ ឬសន្និធិចម្រុះ ឬទាក់ទងនឹងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ។

៤- ការបិទតាមរដូវកាល នូវធនធានជលផលជាក់លាក់ណាមួយ សន្និធិ សន្និធិចម្រុះ ឬទាក់ទងនឹងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ។

៥- ការបិទតំបន់ជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នសម្រាប់ការប្រមូលផលធនធានជលផលសមុទ្រជាក់លាក់ សន្និធិ ឬសន្និធិស្មុគស្មាញ ឬទាក់ទងនឹងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ។

៦- ការកម្រិតទៅលើប្រភេទ ទំហំ និងចំនួនឧបករណ៍ដែលត្រូវបានប្រើប្រាស់សម្រាប់ការប្រមូលផលធនធានជលផលសមុទ្រជាក់លាក់ ឬការប្រើប្រាស់របស់ពួកគេទាក់ទងនឹងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ។

**មាត្រា៦៣១ ._** របាយការណ៍ប្រចាំឆ្នាំ

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃធនធានជលផល សមុទ្រ ដោយយោងលើផ្កាថ្ម និងផ្កាថ្មប៉ប្រ៉ះទឹក ថ្នាលស្មៅសមុទ្រ ព្រៃកោងកាង និងវាលភក់ និងវិភាគ លើតំណភ្ជាប់ទៅកាន់ការប្រែប្រួលអាកាសធាតុ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី៤
## វារីវប្បកម្ម

**មាត្រា៦៣២ ._** យុទ្ធសាស្ត្រវារីវប្បកម្មជាតិ

ការអភិវឌ្ឍ យុទ្ធសាស្ត្រ និងការកែសម្រួលផែនការ និងគោលនយោបាយអង្គភាពទទួលបន្ទុក ជលផលត្រូវពិចារណាទៅលើបញ្ហាដូចខាងក្រោម ៖

១- ភាពជិតបំផុតទៅលើអន្តរសកម្មភាពជាមួយតំបន់ប្រព័ន្ធអេកូឡូស៊ីសំខាន់ ឬតម្លៃអភិរក្សខ្ពស់ ។

២- គុណភាពទឹកនៅជុំវិញ ការរៀបចំការគ្រប់គ្រង គុណភាពទឹក និងការរៀបចំការ គ្រប់គ្រងធនធានទឹក ។

៣- ការប្រើប្រាស់ទឹកផ្សេងទៀតដែលអាចត្រូវប៉ះពាល់ដោយវារីវប្បកម្ម ដែលមិនត្រូវបាន កំណត់ដោយសហគមន៍មូលដ្ឋាន ។

៤- ធនធានជលផល ដែលជាគោលដៅម្ហូបអាហារសុវត្ថិភាព និងនិរន្តរភាព ។

**មាត្រា៦៣៣ ._** វិធានការចៀសវាង និងកាត់បន្ថយ

ក្រសួង ស្ថាប័នពាក់ព័ន្ធអាចបង្កើតវិធានការដើម្បីចៀសវាង ឬកាត់បន្ថយ ហេតុប៉ះពាល់បរិស្ថាន នៃវារីវប្បកម្ម ដូចខាងក្រោម ៖

១- ធានានូវការអនុវត្ត ទម្លាប់វារីវប្បកម្មល្អ និងវិធានការជីវៈសុវត្ថិភាព ។

២- ប្រភេទ វិធីសាស្ត្រ និងតំបន់វារីវប្បកម្មដែលអនុញ្ញាតរួច ។

៣- លក្ខខណ្ឌតម្រូវនៃការអង្កេតតាមដាន និងការរៀបចំរបាយការណ៍បរិស្ថាន ។

៤- ការប្រើប្រាស់សន្និធិកែច្នៃធនធានហ្សែន ប្រភេទសត្វ រុក្ខជាតិក្រៅប្រទេស ប្រភេទ សត្វ រុក្ខជាតិក្នុងស្រុក មច្ឆជាតិតូចៗ និងការប្រើប្រាស់ចំណីអាហារកែច្នៃហ្សែន ។

៥- នីតិវិធីសម្រាប់ការជ្រើសរើសកន្លែងសម្រាប់ត្រីមេពូជជ្រក និងផលិតកម្ម ពង កូនញាស់ និងកូនត្រី ដើម្បីចៀសវាង និងកាត់បន្ថយហានិភ័យចំពោះ ប្រព័ន្ធអេកូឡូស៊ីវារីជាតិ ។

៦- ការប្រើប្រាស់នៃវិធីព្យាបាល អរម៉ូន ថ្នាំផ្សះ និងគីមី ឬវិធីសាស្ត្រត្រួតពិនិត្យជំងឺ ។

៧- វិញ្ញាបនបត្រគំរូសម្រាប់ប្រតិបត្តិការវារីវប្បកម្ម មច្ឆា ផលិតផលជលផល រួមបញ្ចូលទាំងប្រភព និងគុណភាពចំណីគោលការណ៍ណែនាំដើម្បីធ្វើឱ្យប្រសើរឡើងការតាមដានអត្តសញ្ញាណកម្មប្រភពដើមនៃមច្ឆា និងផលិតផលជលផល ។

## គន្ថីទី៥
## ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ
## មាតិកាទោល
## ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៦៣៤** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ក្នុងគោលដៅថែរក្សា ការពារ អភិរក្ស និងអភិវឌ្ឍ ឱ្យបានគង់វង្ស និងដោយចីរភាព ។

**មាត្រា៦៣៥** ._ តម្លៃនៃបេតិកភណ្ឌវប្បធម៌

បេតិកភណ្ឌវប្បធម៌ ជាសម្បត្តិវប្បធម៌ ដែលត្រូវបានបង្កើតឡើង ឬរកឃើញនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលមានតម្លៃប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬសាសនា ទោះជាកម្មសិទ្ធិឯកជនក្តី ឬកម្មសិទ្ធិសាធារណៈក្តី ដែលត្រូវការពារដើម្បីបម្រើឱ្យប្រយោជន៍សាធារណៈ ។

**មាត្រា៦៣៦** ._ អាយុកាល និងប្រភេទបេតិកភណ្ឌវប្បធម៌

បេតិកភណ្ឌវប្បធម៌ដូចមានចែងក្នុងមាត្រា៦៣៥ ត្រូវមានអាយុកាល យ៉ាងតិច ៥០ (ហាសិប) ឆ្នាំ ឬតិចជាង ៥០ (ហាសិប) ឆ្នាំ នៅក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌

បានកំណត់ថាមានតម្លៃពិសេសសម្រាប់អត្តសញ្ញាណជាតិ ហើយត្រូវស្ថិតនៅក្នុងប្រភេទណាមួយ ដូចខាងក្រោម ៖

១- បុរាណស្ថាន ៖ ប្រាសាទបុរាណ ទីសក្ការបូជា វត្តអារាម សំណង់អគារ ឬលំនៅឋានចាស់ៗ ស្នាដៃគំនូរ ឬចម្លាក់នៅលើជញ្ជាំងភ្នំ លំនៅឋានល្អាងភ្នំ ទីបញ្ចុះសពបុរាណ ទីក្រុងបុរាណ ទីប្រជុំជន ឬភូមិឋានបុរាណ ផ្លូវគមនាគមន៍ ប្រព័ន្ធផ្លូវទឹក ស្ពាន ស្រះ បារាយណ៍ ទំនប់ធារាសាស្ត្របុរាណ ។

២- វត្ថុបុរាណ ៖ រូបចម្លាក់ ផ្ទាំងចម្លាក់ ផ្ទាំងគំនូរវិចិត្រកម្ម ដែលគូរដោយដៃលើវត្ថុធាតុផ្សេងៗ រូបប្រថាប់ ផ្ទាំងសិលាចារឹកនៅដាច់តែឯង ឬជាប់លើថ្មដែលជាចំណែកនៃប្រាសាទ សំណេរលើវត្ថុធាតុផ្សេងៗ សាស្ត្រាស្លឹករឹត ក្បួន ក្រាំង គម្ពីរ សំណៅដើមនៃការផ្តុំ ឬតម្លើងជាវត្ថុសិល្បៈគ្រប់រូបភាពសម្ភារជាគ្រឿងរណ្តាប់បម្រើឱ្យពិធីសាសនា ឬគោរពបូជាផ្សេងៗ សម្ភារប្រើប្រាស់ក្នុងផ្ទះ សម្ភារកសិកម្ម ឧបករណ៍ភ្លេង ឧបករណ៍នេសាទ ឧបករណ៍ពេទ្យ គ្រឿងសាស្ត្រាវុធ គ្រឿងសង្ហារឹម គ្រឿងអលង្កា មធ្យោបាយធ្វើដំណើរ ឬដឹកជញ្ជូនតាមផ្លូវគោក និងតាមផ្លូវទឹក ។

៣- ស្នាដៃប្រវត្តិសាស្ត្រ ៖ សម្បត្តិវប្បធម៌ទាំងឡាយដែលឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រមានដូចជា ប្រវត្តិនៃបច្ចេកវិទ្យា ប្រវត្តិខាងយោធា ឬសង្គម ប្រវត្តិទាក់ទងនឹងអ្នកដឹកនាំ អ្នកប្រាជ្ញ សិល្បករជាតិ រួមទាំងប្រវត្តិទាក់ទងនឹងព្រឹត្តិការណ៍ជាតិសំខាន់ៗ ។

៤- ឯកសារកម្រ ៖ សៀវភៅ ប័ណ្ណសារផ្សេងៗជាខ្សែអាត់សំឡេង ជារូបថត ឬជាខ្សែភាពយន្ត លិខិត កំណត់ត្រា ប្រកាស ក្រឹត្យច្បាប់ តែមប្រៃសណីយ៍ តែមសារពើពន្ធ ។

៥- ចំណេះជំនាញ ៖ វិជ្ជាពេទ្យបុរាណ វិធីផ្សំថ្នាំ វិធីព្យាបាលជំងឺ ចំណេះវិជ្ជាសំណង់ វិជ្ជាមន្តអាគម វិជ្ជាធ្វើសឹកសង្គ្រាម វិជ្ជាទាក់ដំរី ចំណេះដឹងខាងតារាសាស្ត្រ ខាងពិធីសាសនា ឬគោរពបូជាផ្សេងៗ វិជ្ជាទស្សន៍ទាយ វិជ្ជាចារយ័ន្ត ។

៦- សិល្បៈសម្តែង ៖ សិល្បៈទស្សនីយភាព តន្ត្រី ល្បែងប្រជាប្រិយ ពិធីបុណ្យ ។

៧- ប្រភេទបេតិកភណ្ឌវប្បធម៌ដទៃទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី២
## ការហាមឃាត់ និងការអនុញ្ញាត

**មាត្រា៦៣៧** ._ គម្រោង និងសកម្មភាពដែលតម្រូវឱ្យមានលិខិតអនុញ្ញាត

រាល់គម្រោង ឬសកម្មភាពទាំងឡាយណា ដែលអាចបង្កផលប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌ ឬបេតិកភណ្ឌធម្មជាតិ ដែលបានចុះក្នុងបញ្ជី ឬមិនទាន់បានចុះនៅក្នុងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ និងទីតាំងដែលសង្ស័យថាមានបេតិកភណ្ឌវប្បធម៌ ត្រូវទទួលលិខិតអនុញ្ញាតជាមុនសិនពីក្រសួងស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ មុននឹងចាប់ផ្ដើមអនុវត្តការងាររបស់ខ្លួន ។

**មាត្រា៦៣៨** ._ ការហាមឃាត់ចំពោះការធ្វើឱ្យខូចខាត ឬការបំផ្លិចបំផ្លាញ

ត្រូវហាមឃាត់ចំពោះសកម្មភាពដែលបង្កឱ្យមានការខូចខាត ឬការបំផ្លិចបំផ្លាញបេតិកភណ្ឌវប្បធម៌ ឬវត្ថុបុរាណ ដែលមានចុះនៅក្នុងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ លើកលែងតែមានការអនុញ្ញាត ពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

## ជំពូកទី៣
## បេតិកភណ្ឌធម្មជាតិ

**មាត្រា៦៣៩** ._ បេតិកភណ្ឌធម្មជាតិ

បេតិកភណ្ឌធម្មជាតិសំដៅលើទម្រង់ធម្មជាតិនៃដែនដី ទាំងនៅដែនគោក និងដែនទឹក ដែលបង្កបង្កើតឡើងដោយកត្តារូបសាស្ត្រ ភូគព្ភសាស្ត្រ ជីវសាស្ត្រ ឬដោយមនុស្ស ដែលឆ្លុះបញ្ចាំងអំពីដំណាក់កាលវិវត្តន៍នៃធម្មជាតិ ឬអារ្យធម៌និងមានតម្លៃប្រវត្តិសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ ឬសោភ័ណ ។ កិច្ចការពារបេតិកភណ្ឌធម្មជាតិត្រូវបម្រើឱ្យប្រយោជន៍សាធារណៈ ។

**មាត្រា៦៤០** ._ ប្រភេទបេតិកភណ្ឌធម្មជាតិ

បេតិកភណ្ឌធម្មជាតិ ត្រូវចាត់ជាប្រភេទ ដូចខាងក្រោម ៖

១- តំបន់បេតិកភណ្ឌធម្មជាតិ ។

២- ឧទ្យានបេតិកភណ្ឌធម្មជាតិ ។

៣- សួនប្រវត្តិសាស្ត្រ ។

បេតិកភណ្ឌធម្មជាតិដូចមានចែងខាងលើនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែកតាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៦៤១** ._ តំបន់បេតិកភណ្ឌធម្មជាតិ

តំបន់បេតិកភណ្ឌធម្មជាតិសំដៅលើដែនដី ដែលបង្កើតឡើងដោយធម្មជាតិ ប្រមូលផ្តុំទៅដោយអម្បូរសត្វ និងរុក្ខជាតិ ធនធានព្រៃឈើ ធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី ឬប្រភពទឹក ដែលមានសារៈប្រយោជន៍ខាងសត្តវិទ្យា បាសាណីភូតវិទ្យា ភូតគាមវិទ្យា ជីវៈវិទ្យា សោភ័ណ ឬជំនឿ ។

តំបន់បេតិកភណ្ឌធម្មជាតិ អាចរួមបញ្ចូលនូវធនធានវប្បធម៌ ទាំងរូបី និងអរូបី ។

**មាត្រា៦៤២** ._ ឧទ្យានបេតិកភណ្ឌធម្មជាតិ

ឧទ្យានបេតិកភណ្ឌធម្មជាតិសំដៅលើដែនដី ដែលបង្កើតឡើងដោយធម្មជាតិ និងមនុស្ស ជាទីកន្លែងដែលប្រមូលផ្តុំទៅដោយព្រៃឈើ ធនធានជីវៈចម្រុះ អម្បូរសត្វ និងរុក្ខជាតិ និងធនធានវប្បធម៌ ដែលជាអត្តសញ្ញាណទឹកដី តំបន់ ឬទីប្រជុំជន និងមានតម្លៃខាងប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ សាសនា ឬសោភ័ណ ។

**មាត្រា៦៤៣** ._ សួនប្រវត្តិសាស្ត្រ

សួនប្រវត្តិសាស្ត្រសំដៅលើទីកន្លែង ជាលម្ហបៃតង ដែលរៀបចំឡើងដោយមនុស្សនៅតាមទីក្រុង ឬទីប្រជុំជន ឬនៅតាមលំនៅឋានសាធារណៈ ឬឯកជន បង្ហាញឱ្យឃើញអំពីស្នាដៃ ភាពប៉ិនប្រសប់ និងគំនិតច្នៃប្រឌិត ដែលមានតម្លៃខាងប្រវត្តិសាស្ត្រ សិល្បៈ ឬសោភ័ណ និងមានសារៈប្រយោជន៍សម្រាប់ការលម្អ ការកំសាន្ត និងការសិក្សាស្រាវជ្រាវ ។

**មាត្រា៦៤៤** ._ លក្ខណៈវិនិច្ឆ័យនៃបេតិកភណ្ឌធម្មជាតិ

លក្ខណៈវិនិច្ឆ័យនៃបេតិកភណ្ឌធម្មជាតិ មានដូចខាងក្រោម ៖

១- លក្ខណៈពិសេសពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ ដូចជា ប្រវត្តិនៃដើមកំណើត ដោយកត្តាភូគព្ភសាស្ត្រ រូបសាស្ត្រ ឬជីវសាស្ត្រ ឬដោយអន្តរាគមន៍ពីមនុស្ស ឬសហាគមន៍មនុស្ស ។

២- ទីជម្រកនៃអម្បូរសត្វ និងរុក្ខជាតិ ដូចជាប្រភេទកម្រ ជិតផុតពូជ ឬកំពុងរងការគំរាមកំហែង ។

៣- ជម្រកសត្វនៃប្រភេទមួយ ឬច្រើន ដែលពង្រីកវិសាលភាពទៅតំបន់ផ្សេងៗ ។

៤- តំបន់ប្រភពទឹក ឬទឹកធ្លាក់ និងតំបន់ព្រៃឈើ ដែលរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី និងបង្កើតទេសភាពប្លែកៗ សម្រាប់ការកំសាន្ត ។

៥- តំបន់ប្រើប្រាស់ក្នុងគោលដៅអភិរក្សជីវៈចម្រុះ អភិរក្សប្រភេទសត្វ និងរុក្ខជាតិកម្រ ។

៦- ជម្រកផ្កាថ្ម ឬរុក្ខជាតិសមុទ្រ ឬសម្បុកពង-កូននៃមច្ឆជាតិ ឬជម្រកនៃប្រភេទសត្វសមុទ្រ ដែលផ្ដល់សារៈប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ ការអភិរក្ស និងការកំសាន្ត ។

៧- ដែនដីរៀបចំដោយមនុស្ស សម្រាប់ជាទីកន្លែងដាំដុះនូវពូជរុក្ខជាតិផ្សេងៗ ឬចិញ្ចឹមសត្វព្រៃ ដើម្បីបម្រើឱ្យការកំសាន្ត ឬការសិក្សាស្រាវជ្រាវ ។

៨- ដែនដី ឬទីកន្លែង ដែលបញ្ជាក់អំពីអត្តសញ្ញាណ ឬប្រវត្តិ នៃទីក្រុង ឬទីប្រជុំជន ឬតំបន់ណាមួយ ។

## ជំពូកទី៤
## ការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌
### ផ្នែកទី១
### ក្រសួង ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៦៤៥** ._ សមត្ថកិច្ចការងារគ្រប់គ្រងបេតិកភណ្ឌវប្បធម៌

ការងារគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ លើកលែងតែមានច្បាប់ ឬបទប្បញ្ញត្តិណាដែលចែងផ្ទុយពីក្រមនេះ ។

**មាត្រា៦៤៦** ._ តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវអនុវត្តតួនាទី និងភារកិច្ចដូចខាងក្រោម ៖

១- ថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌវប្បធម៌ឱ្យបានគង់វង្ស ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដោយឡែកផ្សេងទៀតដែលនៅជាធរមាន ។

២- អនុវត្តគោលនយោបាយ ដែលដាក់ចេញដោយក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ក្នុងការការពារ ថែរក្សា និងលើកតម្លៃ បេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៤៧ ._** ការលើកសំណើសុំបញ្ចូលទីតាំងតំបន់បេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវលើកសំណើទៅក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ អំពីបំណងស្នើសុំដាក់បញ្ចូលទីតាំងវប្បធម៌ណាជាតំបន់ការពារបេតិកភណ្ឌវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៧៤ ។

**មាត្រា៦៤៨ ._** ការរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ សហគមន៍នានា ត្រូវរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ សម្រាប់បុរាណស្ថាន ឬសម្បត្តិវប្បធម៌ណា ដែលបានចុះនៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ តំបន់ការពារបេតិកភណ្ឌវប្បធម៌ ឬតំបន់បេតិកភណ្ឌទីក្រុង ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៃក្រមនេះ ។

**មាត្រា៦៤៩ ._** ការយកចិត្តទុកដាក់អំពីផលប៉ះពាល់នៃទីតាំងបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់នៃទីតាំងបេតិកភណ្ឌវប្បធម៌ ចំពោះសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

**មាត្រា៦៥០ ._** ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការពិគ្រោះយោបល់ជាមួយ សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច មុននឹងធ្វើសេចក្តីសម្រេចទាក់ទងនឹងបេតិកភណ្ឌវប្បធម៌ ដែលអាចប៉ះពាល់ដល់ពួកគាត់ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៃក្រមនេះ ។

## ផ្នែកទី២
## ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

**មាត្រា៦៥១ ._** តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវមានដំណើរការឡើងវិញ និងត្រូវមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

១- កំណត់អត្តសញ្ញាណ ការពារ ថែរក្សា ធ្វើកំណត់ត្រា និងលើកកម្ពស់កិច្ចការពារបេតិកភណ្ឌវប្បធម៌ សម្រាប់ជំនាន់បច្ចុប្បន្ន និងអនាគត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- បង្កើតគោលនយោបាយស្តីពីកិច្ចការពារ និងលើកស្ទួយបេតិកភណ្ឌវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា ។

៣- បង្កើត និងរៀបចំផែនការយុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដើម្បីការពារ លើកស្ទួយ និងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ។

៤- ការពារទ្រព្យសម្បត្តិវប្បធម៌បុរេប្រវត្តិសាស្ត្រ និងប្រវត្តិសាស្ត្រ និងវត្ថុបុរាណនៃធម្មជាតិរូបសាស្ត្រ ។

៥- គ្រប់គ្រង និងត្រួតពិនិត្យតំបន់នានា នៅទីកន្លែងណាដែលវិមាន ឬបូជនីយដ្ឋានដែលបានចុះបញ្ជីរួចស្ថិតនៅ រួមជាមួយការប្រមូលផ្តុំនៃវត្ថុសិល្បៈនានា ដែលមានការទាក់ទងទៅនឹងវិមាន ឬបូជនីយដ្ឋានទាំងនេះ ។

៦- ផ្តល់ការអនុញ្ញាតសម្រាប់ការស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យាទាំងអស់ ការងារអភិរក្ស និងសកម្មភាពដទៃទៀត ដែលទាក់ទងទៅនឹងទីតាំងបូជនីយដ្ឋាន និងទ្រព្យសម្បត្តិវប្បធម៌របស់ជាតិ ។

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវជួបប្រជុំជាទៀងរាល់ ៦ (ប្រាំមួយ) ខែ ម្តង ដើម្បីតាមដានការអនុវត្ត ប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងការពារបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៥២** ._ សមាជិកនៃក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវមានសមាជិកដូចខាងក្រោម ៖

១- នាយករដ្ឋមន្ត្រី ជាប្រធាន ។

២- រដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ជាអនុប្រធាន ។

៣- រដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង ជាសមាជិក ។

៤- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក ។

៥- រដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬតំណាង ជាសមាជិក ។

៦- រដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង ជាសមាជិក ។

៧- រដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម និងសិប្បកម្ម ឬតំណាង ជាសមាជិក ។

៨- រដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង ជាសមាជិក ។

៩- រដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកទេសចរណ៍ ឬតំណាង ជាសមាជិក ។

១០- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬតំណាង ជាសមាជិក ។

១១- ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ឬតំណាង ជាសមាជិក ។

ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ ជាសេនាធិការឱ្យក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៥៣**._ កិច្ចសហការរវាងក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ និងនីតិបុគ្គលដទៃទៀត ក្នុងការ ៖

១- អនុវត្តគោលនយោបាយក្នុងការលើកស្ទួយបេតិកភណ្ឌវប្បធម៌ ។

២- រៀបចំមធ្យោបាយ ដើម្បីអនុញ្ញាតឱ្យសាធារណជនអាចចូលទៅកាន់បេតិកភណ្ឌវប្បធម៌ ។

៣- តែងតាំងបុគ្គលិកត្រួតពិនិត្យ និងបុគ្គលិកដទៃទៀត ដើម្បីអនុវត្តការងារនេះ ។

៤- រៀបចំបណ្តាញអ្នកទេសចរណ៍ ។

៥- លើកកម្ពស់តម្លៃវប្បធម៌ ដោយកៀរគរមូលនិធិដែលចាំបាច់ អប់រំដល់សាធារណជន បុគ្គលិកបណ្តុះបណ្តាល និងអនុវត្តការស្រាវជ្រាវអំពីបេតិកភណ្ឌរូបសាស្ត្រ វប្បធម៌ និងប្រវត្តិសាស្ត្រ ។

៦- ផ្តល់ការធានាទាក់ទងនឹងការទទួលខុសត្រូវ និងកាតព្វកិច្ចផ្នែកគ្រប់គ្រង ដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីវប្បធម៌ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

៧- ចាត់វិធានការចាំបាច់ ដើម្បីអនុវត្តគម្រោង និងសកម្មភាពដទៃទៀត ដែលទាក់ទងនឹងការការពារ ការថែរក្សា ការស្តារឡើងវិញ និងការលើកស្ទួយបេតិកភណ្ឌជាតិ ។

៨- បង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ចំពោះការការពារបេតិកភណ្ឌវប្បធម៌ ។

## ជំពូកទី៥
## ការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ

**មាត្រា៦៥៤** ._ សមត្ថកិច្ចការងារគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ

ការងារគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ លើកលែងតែមានច្បាប់ ឬបទប្បញ្ញត្តិណាដែលចែងផ្ទុយពីក្រមនេះ ។

**មាត្រា៦៥៥** ._ តួនាទី និងភារកិច្ចក្នុងការថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តតួនាទី និងភារកិច្ចក្នុង ការថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌធម្មជាតិឱ្យបានគង់វង្ស ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដោយឡែក ដែលនៅជាធរមាន ។

**មាត្រា៦៥៦** ._ ការរៀបចំបង្កើតបញ្ជីបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំបង្កើតបញ្ជីបេតិកភណ្ឌធម្មជាតិ ដើម្បីកត់ត្រាបញ្ចូលនូវប្រភេទនៃបេតិកភណ្ឌធម្មជាតិ និងទិន្នន័យខាងវិទ្យាសាស្ត្រ ដែលបម្រើឱ្យការសិក្សាស្រាវជ្រាវ និងអភិរក្ស ។

**មាត្រា៦៥៧** ._ ការរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានការចូលរួមពិគ្រោះយោបល់ពីសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ត្រូវរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ ស្របតាមច្បាប់ជាតិ និងអន្តរជាតិ ពាក់ព័ន្ធនឹងកិច្ចការពារ ថែរក្សា និងអភិរក្សធនធានធម្មជាតិ និងស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៃក្រមនេះ ។

**មាត្រា៦៥៨** ._ ការយកចិត្តទុកដាក់អំពីផលប៉ះពាល់នៃទីតាំងបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់នៃទីតាំងបេតិកភណ្ឌធម្មជាតិទៅលើសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ទៅលើជំនឿ មុខរបរ និងការគ្រប់គ្រងដីធ្លី ។

**មាត្រា៦៥៩ .**_ ការលើកទឹកចិត្តក្នុងការចូលរួមថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវលើកទឹកចិត្តដល់សហគមន៍មូលដ្ឋាន ឬជនជាតិដើមភាគតិច ឱ្យចូលរួមក្នុងកិច្ចការថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌធម្មជាតិ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៃក្រមនេះ ។

**មាត្រា៦៦០ .**_ ការផ្តល់អាទិភាពក្នុងការអភិវឌ្ឍមុខរបររបស់សហគមន៍មូលដ្ឋាន ឬជនជាតិដើមភាគតិច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តល់អាទិភាពក្នុងការអភិវឌ្ឍមុខរបរ ដល់សហគមន៍មូលដ្ឋាន ឬជនជាតិដើមភាគតិច ដែលស្ថិតក្នុង ឬក្បែរតំបន់បេតិកភណ្ឌធម្មជាតិ ។

**មាត្រា៦៦១ .**_ ការដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌ និងសម្បត្តិវប្បធម៌ក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវដាក់បញ្ចូលទីតាំងបេតិកភណ្ឌវប្បធម៌ និងសម្បត្តិវប្បធម៌ទាំងឡាយ ដែលមានក្នុងតំបន់នោះ ។

## ជំពូកទី៦
## បញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌

**មាត្រា៦៦២ .**_ ការរៀបចំបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ ដែលមានលក្ខណៈវិទ្យាសាស្ត្រសម្រាប់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៦៦៣ .**_ ការផ្ទៀងផ្ទាត់ឡើងវិញនូវបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌

បញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ ត្រូវធ្វើការផ្ទៀងផ្ទាត់ឡើងវិញយ៉ាងហោចណាស់ រាល់ ៥ (ប្រាំ) ឆ្នាំម្តង ។

**មាត្រា៦៦៤**._ ការចុះក្នុងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវចុះបញ្ជីសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៣៦ ទៅក្នុងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ ។

បញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ ត្រូវបញ្ជាក់អំពីស្ថានភាពគ្រោះថ្នាក់នៃសម្បត្តិវប្បធម៌ណាដែលតម្រូវឱ្យធ្វើការសង្គ្រោះបន្ទាន់ ។

បែបបទ និងនីតិវិធីនៃការរៀបចំ និងការចុះក្នុងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ ត្រូវអនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន ។

**មាត្រា៦៦៥**._ ការការពារស្របច្បាប់ចំពោះសម្បត្តិវប្បធម៌

សម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៣៦ ដែលត្រូវបានចុះក្នុងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ ត្រូវទទួលបាននូវការការពារ ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

## ជំពូកទី៧
## ការធ្វើចំណាត់ថ្នាក់បេតិកភណ្ឌវប្បធម៌

**មាត្រា៦៦៦**._ លក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់សម្បត្តិវប្បធម៌ជាបេតិកភណ្ឌវប្បធម៌

លក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់សម្បត្តិវប្បធម៌ជាបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៦៧**._ បែបបទ និងនីតិវិធីនៃការធ្វើចំណាត់ថ្នាក់បេតិកភណ្ឌវប្បធម៌

បែបបទ និងនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ និងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ត្រូវអនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន ។

**មាត្រា៦៦៨ ._** ការអភិរក្សបេតិកភណ្ឌវប្បធម៌

សម្បត្តិវប្បធម៌ទាំងឡាយណា ដែលត្រូវបានចាត់ថ្នាក់ជាបេតិកភណ្ឌវប្បធម៌ពុំអាចផ្លាស់ប្ដូរ ទីកន្លែង ទទួលរងនូវការបំផ្លិចបំផ្លាញ កែប្រែរូបរាង រុះរើ វាយកម្ទេច ជួសជុលឡើងវិញ ឬស្ថាបនាឡើងវិញឡើយ លើកលែងតែមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៦៩ ._** កាតព្វកិច្ចក្នុងការថែរក្សាបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំផែនការគ្រប់គ្រង និងអភិរក្សបេតិកភណ្ឌវប្បធម៌ ដែលបានធ្វើចំណាត់ថ្នាក់ជាបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៧០ ._** ការជួសជុលឡើងវិញ

ការជួសជុលសម្បត្តិវប្បធម៌ ដែលត្រូវបានធ្វើចំណាត់ថ្នាក់ជាបេតិកភណ្ឌវប្បធម៌ ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវផ្ដល់អ្នកជំនាញ និងបច្ចេកទេស ក្នុងកិច្ចអន្តរាគមន៍ជួសជុលសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៦៨ ។

**មាត្រា៦៧១ ._** បដិភាគក្នុងការជួសជុលបេតិកភណ្ឌវប្បធម៌

ម្ចាស់កម្មសិទ្ធិសម្បត្តិវប្បធម៌ដែលត្រូវបានធ្វើចំណាត់ថ្នាក់ជាបេតិកភណ្ឌវប្បធម៌ ត្រូវទទួលបន្ទុកចំណាយលើការជួសជុល និងថែរក្សាសម្បត្តិវប្បធម៌ ដែលខ្លួនកាន់កាប់ ។

ក្នុងករណីបន្ទុកចំណាយក្នុងកថាខណ្ឌខាងលើនេះហួសសមត្ថភាពរបស់ម្ចាស់កម្មសិទ្ធិ នោះម្ចាស់កម្មសិទ្ធិ អាចស្នើសុំកិច្ចអន្តរាគមន៍ពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវដាក់លិខិតស្នើសុំការសម្រេចពីគណៈរដ្ឋមន្ត្រី ចំពោះការចំណាយទាំងស្រុងលើការងារជួសជុលសម្បត្តិវប្បធម៌ ដែលបានធ្វើចំណាត់ថ្នាក់ជាបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៧២ ._** ការលក់ ឬផ្ទេរសម្បត្តិវប្បធម៌

ម្ចាស់កម្មសិទ្ធិសម្បត្តិវប្បធម៌ ដែលបានចាត់ថ្នាក់ជាបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ក្នុងករណីមានការលក់ ឬផ្ទេរសម្បត្តិវប្បធម៌ ដែលខ្លួនកាន់កាប់ ។

## ជំពូកទី៨
## ការរៀបចំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌

**មាត្រា៦៧៣** ._ ការបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំបង្កើតឱ្យមានតំបន់ការពារបេតិកភណ្ឌវប្បធម៌ ដែលប្រមូលផ្តុំទៅដោយ ប្រាសាទបុរាណ សំណង់ស្ថាបត្យកម្ម ផ្ទះសំបែង រចនាសម្ព័ន្ធភូមិឋាន ឬក្រុង ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម ទីសក្ការបូជា ទីបញ្ចុះសព សំណល់វត្ថុបុរាណ ឬតំបន់ដទៃទៀត ដែលមានតម្លៃខាងបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម បុរាណវិទ្យា ជាតិពន្ធុវិទ្យា នរវិទ្យា វិទ្យាសាស្ត្រ សិល្បៈ ឬសាសនា ។

**មាត្រា៦៧៤** ._ ការបែងចែកតំបន់ការពារបេតិកភណ្ឌវប្បធម៌

តំបន់ការពារបេតិកភណ្ឌវប្បធម៌ ត្រូវបែងចែកជាប្រភេទ ដូចខាងក្រោម ៖

១- រមណីយដ្ឋានវប្បធម៌ ។

២- តំបន់បុរាណស្ថាន ។

៣- តំបន់សក្ការសហគមន៍ ។

៤- តំបន់បេតិកភណ្ឌទីក្រុង ។

តំបន់ការពារបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តតាមសំណើរបស់ក្រសួងទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៧៥** ._ ការរៀបចំលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ប្រភេទតំបន់ការពារបេតិកភណ្ឌវប្បធម៌

ការរៀបចំលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ប្រភេទតំបន់ការពារបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៧៦** ._ ការស្នើសុំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌

ការស្នើសុំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៧៣ ត្រូវផ្អែកតាមគោលបំណងនៃការគ្រប់គ្រង លក្ខណៈវិនិច្ឆ័យ លទ្ធផលនៃការសិក្សាស្រាវជ្រាវ សិទ្ធិកាន់កាប់ដីធ្លី និងកត្តាពាក់ព័ន្ធដទៃទៀត ។

**មាត្រា៦៧៧** ._ ឯកសារស្នើសុំបង្កើតតំបន់បេតិកភណ្ឌវប្បធម៌

ឯកសារស្នើសុំបង្កើតតំបន់បេតិកភណ្ឌវប្បធម៌ ត្រូវភ្ជាប់មកជាមួយនូវ ៖

១- ការអធិប្បាយអំពីសារៈសំខាន់ខាងបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម បុរាណវិទ្យា ជាតិពន្ធុវិទ្យា វិទ្យាសាស្ត្រ សិល្បៈ ឬសាសនា និងភាពចាំបាច់ក្នុងការការពារនិងអភិរក្សតំបន់ដែលត្រូវស្នើសុំ ។

២- ការអធិប្បាយអំពីក្របខ័ណ្ឌច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារថែរក្សា ការពារ និងអភិរក្ស ។

៣- ផែនទីមានមាត្រដ្ឋានកំណត់ច្បាស់លាស់ ដែលបង្ហាញអំពីទីតាំងភូមិសាស្ត្រ ព្រំប្រទល់ ទំហំផ្ទៃដីនៃតំបន់ត្រូវស្នើសុំ ។

៤- របាយការណ៍អំពីលទ្ធផលនៃការពិគ្រោះយោបល់ជាមួយស្ថាប័ន ភាគីពាក់ព័ន្ធ និងតំណាងសហគមន៍មូលដ្ឋាន ដែលមានទីតាំងនៅក្នុង ឬនៅក្បែរតំបន់ស្នើសុំ ។

**មាត្រា៦៧៨** ._ កិច្ចការពារតំបន់ការពារបេតិកភណ្ឌវប្បធម៌

តំបន់ការពារបេតិកភណ្ឌវប្បធម៌ ដែលត្រូវបានទទួលស្គាល់ ដូចមានចែងក្នុងមាត្រា៦៧៣ត្រូវទទួលបានកិច្ចការពារស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន។

## ជំពូកទី៩
## ការបង្កើតតំបន់បេតិកភណ្ឌទីក្រុង

**មាត្រា៦៧៩** ._ ការស្នើសុំបង្កើតតំបន់បេតិកភណ្ឌទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អាចលើកសំណើស្នើសុំទៅកាន់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីបង្កើតតំបន់បេតិកភណ្ឌទីក្រុង ។

ការស្នើសុំបង្កើតតំបន់បេតិកភណ្ឌទីក្រុង ត្រូវផ្អែកតាមគោលបំណងនៃការគ្រប់គ្រង លក្ខណៈវិនិច្ឆ័យ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីគុណតម្លៃនៃធនធានវប្បធម៌ ការរក្សាអត្តសញ្ញាណវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ការគោរពប្រណិប័តន៍ ការអភិរក្សស្នាដៃ និង/ឬគុណតម្លៃនៃការអភិវឌ្ឍទេសចរណ៍ ។

**មាត្រា៦៨០ .**_ តំបន់បេតិកភណ្ឌទីក្រុង

តំបន់បេតិកភណ្ឌទីក្រុងសំដៅលើ បណ្តុំនៃសំណង់ស្ថាបត្យកម្មប្រវត្តិសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ រួមទាំងលំហាបៃតង ដែលជាផ្នែកមួយ ឬទាំងស្រុងនៃទីប្រជុំជន ឬទីក្រុង ហើយដែលរក្សាបាននូវលក្ខណៈដើម និងបង្ហាញពីទេពកោសល្យ និងគំនិតច្នៃប្រឌិតក្នុងការរៀបចំតំបន់រស់នៅប្រកបដោយផាសុកភាព ។

**មាត្រា៦៨១ .**_ ការពិភាក្សាអំពីសំណើសុំបង្កើតតំបន់បេតិកភណ្ឌទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងធ្វើការពិភាក្សាអំពីសំណើសុំបង្កើតតំបន់បេតិកភណ្ឌទីក្រុង ។

ការបង្កើតតំបន់បេតិកភណ្ឌទីក្រុង ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៨២ .**_ ការរៀបចំផែនការតំបន់បេតិកភណ្ឌទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំផែនការសម្រាប់តំបន់បេតិកភណ្ឌទីក្រុង និងចំណាត់ថ្នាក់នៃទីតាំងនោះ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៦៨៣ .**_ ការហាមឃាត់ចំពោះការកែប្រែ ឬការធ្វើឱ្យខូចខាតសោភ័ណភាពតំបន់បេតិកភណ្ឌទីក្រុង

តំបន់ណាមួយ ឬតំបន់ទាំងមូលនៃទីប្រជុំជន ភូមិ ឬទីក្រុង ដែលត្រូវបានចាត់ថ្នាក់ជាតំបន់បេតិកភណ្ឌទីក្រុងមិនអាចកែប្រែ ផ្លាស់ប្តូររូបរាង ធ្វើឱ្យខូចខាតសោភ័ណភាព ឬទទួលរងនូវការបំផ្លិចបំផ្លាញដោយសកម្មភាពណាមួយឡើយ លុះត្រាតែមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៨៤**._ ការហាមឃាត់ចំពោះការកែប្រែ ឬការធ្វើឱ្យខូចខាតសោភ័ណភាពចំពោះសំណង់នៃ តំបន់បេតិកភណ្ឌទីក្រុង

សំណង់សាធារណៈ ឯកជន សាសនា ហេដ្ឋារចនាសម្ព័ន្ធ និងលំហាបៃតងនៃតំបន់បេតិកភណ្ឌទីក្រុងមិនត្រូវបានកែប្រែរូបរាង ផ្លាស់ប្តូររចនាបទ ឬក៏ធ្វើឱ្យខូចសោភ័ណភាពត្រង់កន្លែងណាមួយឡើយ លុះត្រាតែមានច្បាប់អនុញ្ញាត ពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៨៥**._ ការស្នើសុំការអនុញ្ញាតដើម្បីជួសជុល កែប្រែរូបរាង និងកម្ទេចចោលសំណង់ក្នុងតំបន់ បេតិកភណ្ឌទីក្រុង

ម្ចាស់កម្មសិទ្ធិនៃអចលនទ្រព្យ សំណង់ទូទៅ ឬលំនៅឋាន ដែលស្ថិតក្នុងតំបន់បេតិកភណ្ឌទីក្រុង ត្រូវសុំការអនុញ្ញាតមកក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ មុននឹងធ្វើការជួសជុល កែប្រែរូបរាង ឬកម្ទេចចោលសំណង់ទាំងនោះ ។

**មាត្រា៦៨៦**._ ការវាយតម្លៃបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវវាយតម្លៃបេតិកភណ្ឌវប្បធម៌ មុនសម្រេចឯកភាពឱ្យមានការសាងសង់ ជួសជុល ឬការកម្ទេចចោល ឬធ្វើការអភិវឌ្ឍឡើងវិញនៅក្នុងតំបន់បេតិកភណ្ឌទីក្រុងនោះ ។

## ជំពូកទី១០
## កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ
## ផ្នែកទោល
## ការប្រទះឃើញដោយចៃដន្យនូវសម្បត្តិវប្បធម៌

**មាត្រា៦៨៧**._ កាតព្វកិច្ចទូទៅចំពោះការរាយការណ៍

បុគ្គលគ្រប់រូប ដែលបានដឹង ឬប្រទះឃើញដោយចៃដន្យនូវ សំណង់ប្រាសាទបាក់បែក គ្រឹះប្រាសាទ ស្លាកស្នាមដែលបញ្ជាក់អំពីទីតាំងបុរាណស្ថាន វត្ថុបុរាណ ឬតំបន់បេតិកភណ្ឌវប្បធម៌ ត្រូវមានកាតព្វកិច្ចរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរដែនដី និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៦៨៨ .**_ កាតព្វកិច្ចរាយការណ៍អំពីការប្រទះឃើញដោយចៃដន្យ ក្នុងការធ្វើប្រតិបត្តិការសាងសង់

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រទះឃើញដោយចៃដន្យនូវវត្ថុបុរាណ ឬសម្បត្តិវប្បធម៌ ឬតំបន់បេតិកភណ្ឌវប្បធម៌ នៅក្នុងកំឡុងពេលប្រតិបត្តិការសាងសង់ ឬជីកកាស់កកាយស្តារហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដូចមានចែងក្នុងមាត្រា៦៣៦ នៃក្រមនេះ ត្រូវបញ្ឈប់ការងារសាងសង់ជាបណ្តោះអាសន្ន និងត្រូវរាយការណ៍ទៅកាន់អាជ្ញាធរមូលដ្ឋាន ។

**មាត្រា៦៨៩ .**_ ការកំណត់ជាបឋមនៃសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើការកំណត់ជាបឋមអំពីសារៈសំខាន់នៃសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ នៅក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ ក្រោយពេលទទួលបានការជូនដំណឹង ឬរបាយការណ៍ ។

រយៈពេលនេះ អាចពន្យារបានតែម្តងប៉ុណ្ណោះ ដោយមានរយៈពេល១៤ (ដប់បួន) ថ្ងៃបន្ថែម ។ ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់រូបវន្តបុគ្គល ឬនីតិបុគ្គល អំពីការពន្យារពេលនេះ ។

**មាត្រា៦៩០ .**_ សេចក្តីសម្រេចផ្អាកជាបណ្តោះអាសន្ន

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវចេញសេចក្តីសម្រេចផ្អាកជាបណ្តោះអាសន្នចំពោះទីតាំងទាំងឡាយណាដែលមានការប្រទះឃើញសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ ។ សេចក្តីសម្រេចផ្អាកបណ្តោះអាសន្ននេះ មានសុពលភាពរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបានធ្វើការកំណត់ជាបឋម ដូចមានចែងក្នុងមាត្រា៦៨៩ នៃក្រមនេះ ។

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ពុំបានចេញសេចក្តីសម្រេចថ្មី ក្រោយរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្តទៀតនោះទេ រូបវន្តបុគ្គល ឬនីតិបុគ្គល អាចបន្តសកម្មភាពការងាររបស់ខ្លួនបានជាប្រក្រតី ។

## ជំពូកទី១១
## ការធ្វើកំណាយ

**មាត្រា៦៩១** ._ ការហាមឃាត់ចំពោះការជីករុករក ឬស្រាវជ្រាវស្វែងរកសម្បត្តិវប្បធម៌

គ្មានជនណាម្នាក់មានសិទ្ធិជីករុករក ឬស្រាវជ្រាវ នៅលើដីកម្មសិទ្ធិរបស់ខ្លួន ឬរបស់អ្នកដទៃ ឬដីសាធារណៈ ក្នុងបំណងស្វែងរកវត្ថុផ្សេងៗ ឬស្លាកស្នាមភស្តុតាង ដែលមានសារៈសំខាន់ខាងបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ បុរាណវិទ្យា ជាតិពន្ធុវិទ្យា សិល្បៈ ឬវិទ្យាសាស្ត្រផ្សេងៗ ដោយគ្មានការអនុញ្ញាតជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ឡើយ ។

**មាត្រា៦៩២** ._ ការជីករុករក ឬស្រាវជ្រាវរបស់ស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ

ស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងជីករុករក ឬស្រាវជ្រាវនៅក្នុងដី ឬក្នុងទឹក ក្នុងបំណងសិក្សាស្រាវជ្រាវផ្នែកបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ បុរាណវិទ្យា ជាតិពន្ធុវិទ្យា ឬសិល្បៈ ត្រូវដាក់សំណើសុំដើម្បីទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៩៣** ._ ការចូលរួមជីករុករក ឬស្រាវជ្រាវរបស់មន្ត្រីជំនាញជាមួយស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ

រាល់ការជីករុករក ឬស្រាវជ្រាវ ដោយស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលទទួលបានច្បាប់អនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៩២ ត្រូវមានការចូលរួមពីមន្ត្រីជំនាញរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៩៤** ._ ការចាត់ទុកសម្បត្តិវប្បធម៌ជាសម្បត្តិរដ្ឋ

សម្បត្តិវប្បធម៌ដែលបានរកឃើញក្នុងពេលជីករុករក ឬស្រាវជ្រាវត្រូវចាត់ទុកជាសម្បត្តិរដ្ឋ ។

**មាត្រា៦៩៥** ._ ការបញ្ឈប់ជាបណ្ដោះអាសន្ន ឬដកហូតលិខិតអនុញ្ញាតចំពោះការមិនគោរពកាតព្វកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ មានសិទ្ធិបញ្ឈប់ជាបណ្ដោះអាសន្ន ឬដកហូតលិខិតអនុញ្ញាត ក្នុងករណីពិនិត្យឃើញថា ស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវនោះមិនគោរពតាមកាតព្វកិច្ច ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធស្ដីពីការជីករុករកវត្ថុបុរាណ ដែលនៅជាធរមាន ។

**មាត្រា៦៩៦**._ ការស្នើសុំលិខិតអនុញ្ញាតដើម្បីសិក្សាស្រាវជ្រាវ

ស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងស្រាវជ្រាវ ឬជីករុករកនៅក្នុងដី ឬក្នុងទឹក ក្នុងបំណងសិក្សាស្រាវជ្រាវផ្នែកសត្តវិទ្យា បាសាណីភូតវិទ្យា ភូតគាមវិទ្យា ជីវៈវិទ្យា ឬវិទ្យាសាស្ត្រពាក់ព័ន្ធដទៃទៀត ត្រូវដាក់សំណើសុំ ដើម្បីទទួលការអនុញ្ញាតទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៦៩៧**._ ការចូលរួមស្រាវជ្រាវពីមន្ត្រីជំនាញជាមួយស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវ ឬជីករុករកដោយស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលទទួលបានច្បាប់អនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៩៦ ត្រូវមានការចូលរួមពីមន្ត្រីជំនាញរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៦៩៨**._ បន្ទុកនៃការចំណាយលើការធ្វើកំណាយ

ការចំណាយលើការធ្វើកំណាយ ជាបន្ទុករបស់អ្នកស្នើសុំ ។

## ជំពូកទី១២
## កំណាយបង្ការ

**មាត្រា៦៩៩**._ ការស្នើសុំក្រុមឯកទេសបុរាណវិទ្យាពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងជីកកកាយ ឈូសឆាយ ពង្រាប ចាក់ដីបំពេញ ឬសាងសង់សំណង់ផ្សេងៗ ក្នុងតំបន់ដែលក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌មិនបានប្រកាសថាជាស្ថានីយបុរាណ ឬជាកន្លែងដែលសង្ស័យថាមានវត្ថុបុរាណ ត្រូវស្នើសុំក្រុមឯកទេសបុរាណវិទ្យា ពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដើម្បីពិនិត្យ ស្រាវជ្រាវ និងរិះរកវិធីបញ្ចៀសផលប៉ះពាល់ជាអវិជ្ជមានដល់ស្ថានីយបុរាណ ឬជាកន្លែងដែលសង្ស័យថាជាស្ថានីយបុរាណ ក្នុងករណីមិនអាចបញ្ចៀសបានទេ ត្រូវធ្វើកំណាយបង្ការ ។

**មាត្រា៧០០**._ ការហាមឃាត់ដាច់ខាតចំពោះការធ្វើឱ្យខូចខាតដល់សម្បត្តិវប្បធម៌

ត្រូវហាមឃាត់ដាច់ខាតចំពោះសកម្មភាពដែលបង្កឱ្យមានការខូចខាត ការបំផ្លិចបំផ្លាញ ឬធ្វើឱ្យគ្រោះថ្នាក់ដល់សម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៣៦ លើកលែងតែមានការអនុញ្ញាត ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា៧០១** ._ ការហាមឃាត់ចំពោះការផ្តល់លិខិតអនុញ្ញាតសាងសង់

ក្រសួង ស្ថាប័នមានសមត្ថកិច្ចមិនត្រូវផ្តល់ការអនុញ្ញាត លើគម្រោងសាងសង់ ដូចមានចែងក្នុងមាត្រា៦៩៩ លុះត្រាតែម្ចាស់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ឬសាងសង់នោះបានអនុវត្តការធ្វើកំណាយបង្ការជាមុនសិន ។

**មាត្រា៧០២** ._ កិច្ចសហការក្នុងការធ្វើកំណាយបង្ការ

កំណាយបង្ការត្រូវអនុវត្តដោយក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ឬសហការជាមួយស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្របុរាណវិទ្យា ។

**មាត្រា៧០៣** ._ ការស្នើសុំលិខិតអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬសំណង់ផ្សេងៗ

លិខិតសុំការអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬសំណង់ផ្សេងៗ ត្រូវមានភ្ជាប់ជាមួយនូវរបាយការណ៍វាយតម្លៃ របស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៧០៤** ._ បន្ទុកចំណាយលើការងារធ្វើកំណាយបង្ការ

ម្ចាស់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ឬគម្រោងសាងសង់ផ្សេងៗ ដែលធ្វើប្រតិបត្តិការនៅក្នុងតំបន់ដែលក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ បានប្រកាសថា ជាស្ថានីយបុរាណ ឬជាកន្លែងដែលសង្ស័យថាមានវត្ថុបុរាណ ត្រូវទទួលបន្ទុកលើការចំណាយសម្រាប់ការងារធ្វើកំណាយបង្ការ ។

**មាត្រា៧០៥** ._ ការហាមឃាត់ចំពោះការយកចេញ ឬបំផ្លាញបេតិកភណ្ឌ

ត្រូវហាមឃាត់ចំពោះការយកចេញ ឬបំផ្លិចបំផ្លាញនូវសម្បត្តិវប្បធម៌ ឬវត្ថុបុរាណណាមួយដែលមាននៅក្នុងទីតាំងដីកម្មសិទ្ធិឯកជន លើកលែងតែមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៧០៦ ._** កាតព្វកិច្ចធ្វើកំណត់ត្រា

រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវមានកាតព្វកិច្ច ក្នុងការធ្វើកំណត់ត្រា និងថតរូបសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ រួចបញ្ជូនទៅអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៧០៧ ._** ការហាមឃាត់ពាក់ព័ន្ធទៅនឹងការមិនបានអនុលោមតាម

ការខកខានមិនបានរាយការណ៍អំពីការប្រទះឃើញដោយចៃដន្យ ឬការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ឬ វត្ថុបុរាណណាមួយ មុនពេលធ្វើការកំណត់អំពីតម្លៃបេតិកភណ្ឌនោះ ត្រូវទទួលរងនូវការលុបចោលលិខិតអនុញ្ញាត ។

## ជំពូកទី១៣
## កិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

**មាត្រា៧០៨ ._** បេតិកភណ្ឌវប្បធម៌ក្រោមទឹក

បេតិកភណ្ឌវប្បធម៌ក្រោមទឹក សំដៅលើសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៣៥ ដែលលិចចូលទៅក្នុងទឹកដោយផ្នែក ឬទាំងស្រុង មួយរយៈកាល ឬជានិរន្តរ៍ អស់រយៈពេលយ៉ាងហោចណាស់ស្ថិតក្នុងបុរេប្រវត្តិសាស្ត្រ សម័យមុនអង្គរ សម័យអង្គរ សម័យក្រោយអង្គរ សម័យអាណាព្យាបាលបារាំង និងសម័យទំនើប រួមមាន ៖

១- ទីតាំង រចនាសម្ព័ន្ធ អគារ វត្ថុបុរាណ ឬសំណល់អដ្ឋិធាតុរបស់មនុស្ស និងសំណល់សត្វ ។

២- សំពៅ ទូក នាវា យន្តហោះ យានយន្តដទៃទៀត ឬបំណែករបស់វា និងវត្ថុផ្សេងទៀត ។

៣- វត្ថុនានាដែលមានតម្លៃផ្នែកបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ ឬសិល្បៈ ។

**មាត្រា៧០៩ ._** ការកំណត់ទីតាំងសម្បត្តិបេតិកភណ្ឌក្រោមទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ទីតាំងសម្បត្តិវប្បធម៌ក្រោមទឹកទាំងនោះ ទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ។

**មាត្រា៧១០** ._ កាតព្វកិច្ចរាយការណ៍

រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវមានកាតព្វកិច្ចរាយការណ៍ជូនក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អំពីវត្ថុក្រោមទឹកណាមួយ ដែលកំណត់អត្តសញ្ញាណជាសម្បត្តិវប្បធម៌ ដែលត្រូវបានប្រទះឃើញ ដើម្បីធ្វើការកំណត់ដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ។

**មាត្រា៧១១** ._ ការហាមឃាត់ចំពោះការធ្វើឱ្យខូចខាត ការស្រង់ ឬ ការរំខាន

រាល់សកម្មភាពដែលបង្កការខូចខាត ការបំផ្លិចបំផ្លាញ ការស្រង់ ឬការរំខាន ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវហាមឃាត់ ។

**មាត្រា៧១២** ._ ការការពារ ការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ និងការរុករកបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុញ្ញាតឱ្យមានការការពារ ការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ និងការរុករកបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។

**មាត្រា៧១៣** ._ ការចេញលិខិតអនុញ្ញាតចំពោះសកម្មភាពដែលបង្កផលប៉ះពាល់ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អាចចេញលិខិតអនុញ្ញាត ចំពោះសកម្មភាពដែលបង្កផលប៉ះពាល់ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

## ជំពូកទី១៤
## អង្គភាពជំនាញខាងបុរាណវិទ្យា

**មាត្រា៧១៤** ._ ការទទួលស្គាល់អង្គភាពជំនាញខាងបុរាណវិទ្យា

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អាចផ្តល់សិទ្ធិដល់ស្ថាប័នឯកជន ដែលមានជំនាញខាងបុរាណវិទ្យា ដើម្បីធ្វើការសិក្សាស្រាវជ្រាវ អភិរក្ស ជួសជុល អនុវត្តការធ្វើកំណាយបង្ការ ឬកំណាយសង្គ្រោះ លើបេតិកភណ្ឌវប្បធម៌ ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាដល់អង្គភាពជំនាញខាងបុរាណវិទ្យា ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៧១៥** ._ កាតព្វកិច្ចអង្គភាពជំនាញខាងបុរាណវិទ្យា

អង្គភាពជំនាញខាងបុរាណវិទ្យា ទទួលអនុវត្ត ៖

១- ការសិក្សាស្រាវជ្រាវលើបេតិកភណ្ឌវប្បធម៌ និងសហការជាមួយស្ថាប័នវិទ្យាសាស្ត្រជាតិ ឬអន្តរជាតិ ក្នុងការងារជួសជុល និងអភិរក្សបេតិកភណ្ឌវប្បធម៌ ។

២- ការធ្វើកំណាយបង្ការ ឬកំណាយសង្គ្រោះ និងរៀបចំរបាយការណ៍នៃការធ្វើកំណាយ ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

៣- ការកត់ត្រារាល់សម្បត្តិវប្បធម៌ ដែលបានរកឃើញ ឬជួបប្រទះ ហើយត្រូវប្រគល់សម្បត្តិវប្បធម៌ទាំងនោះទៅក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ នៅពេលបញ្ចប់ដំណាក់កាលនៃការធ្វើកំណាយនីមួយៗ ។

៤- ការផ្តល់របាយការណ៍ជាទៀងទាត់ ដល់អាជ្ញាធរមានសមត្ថកិច្ច ស្តីពីការអនុវត្តនៃការធ្វើកំណាយនីមួយៗ ។

៥- ការប្រមូល ចងក្រង និងបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវជូនសាធារណជន ។

**មាត្រា៧១៦** ._ លក្ខខណ្ឌតម្រូវ

អង្គភាពជំនាញខាងបុរាណវិទ្យា ត្រូវស្នើសុំការអនុញ្ញាតប្រកបអាជីវកម្មពី និងចុះបញ្ជីនៅក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

## ជំពូកទី១៥
## ការដោះស្រាយវិវាទ និងបទបញ្ញាបន្ទាន់

**មាត្រា៧១៧** ._ នីតិវិធីដោះស្រាយវិវាទ

នៅក្នុងករណីមានវិវាទកើតឡើង គូភាគីត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងនៅក្នុងគន្ថីទី៩ នៃក្រមនេះ ។

**មាត្រា៧១៨** ._ ការធ្វើជាតំណាងក្នុងការដោះស្រាយវិវាទ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើជាតំណាងនៅក្នុងនីតិវិធីដោះស្រាយវិវាទ ដែលមានផលប៉ះពាល់លើតម្លៃបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៧១៩** ._ ការចេញបទបញ្ជាបន្ទាន់ក្នុងការផ្អាកសកម្មភាពគំរាមកំហែង ឬគ្រោះថ្នាក់ដល់វត្ថុបេតិកភណ្ឌ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អាចចេញបទបញ្ជាបន្ទាន់ដើម្បីផ្អាកការងារ ការសាងសង់ ឬការឈូសឆាយ ក្នុងករណីដែលទីតាំង ឬសម្បត្តិវប្បធម៌កំពុងរងគ្រោះថ្នាក់ ឬបំផ្លិចបំផ្លាញ ទោះបីជាទីតាំង ឬសម្បត្តិវប្បធម៌នោះ បានឬមិនទាន់បានចុះនៅក្នុងបញ្ជីបេតិកភណ្ឌជាតិក៏ដោយ ។

អំឡុងពេលការផ្អាកសកម្មភាពការងារនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា៦៨៤ នៃក្រមនេះ ។

## ជំពូកទី១៦
## ការលើកកម្ពស់ និងការការពារបេតិកភណ្ឌវប្បធម៌អរូបី

**មាត្រា៧២០** ._ កិច្ចការពារ និងលើកកម្ពស់បេតិកភណ្ឌវប្បធម៌អរូបី

បេតិកភណ្ឌវប្បធម៌អរូបី ដូចមានចែងក្នុងមាត្រា៦៣៦ ត្រូវទទួលបាននូវកិច្ចការពារ និងលើកកម្ពស់ ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលនៅជាធរមាន ។

**មាត្រា៧២១** ._ វិធានការការពារ និងលើកកម្ពស់បេតិកភណ្ឌអរូបី

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីការពារ និងលើកកម្ពស់បេតិកភណ្ឌវប្បធម៌អរូបី ។

**មាត្រា៧២២** ._ ការចូលរួមផ្តល់យោបល់ជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវដាក់លិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងមាត្រា៧២០ ខាងលើនេះ ឱ្យសាធារណជនអាចស្វែងរកបាន ដើម្បីផ្តល់យោបល់ មុនពេលមានការឯកភាពពីក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ។

**មាត្រា៧២៣** ._ ការលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវជម្រុញ និងលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី តាមរយៈការអភិរក្សទំនៀមទម្លាប់ កិច្ចប្រតិបត្តិជំនឿផ្សេងៗ ដែលមាននៅទីតាំងស្រាប់ ការបង្កើតព្រឹត្តិការណ៍សំខាន់ៗដូចជា មហោស្រព ការសម្តែង ឬការតាំងពិព័រណ៌ជាអាទិ៍ ដែលមានលក្ខណៈថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ។

**មាត្រា៧២៤** ._ ការបណ្តុះបណ្តាលបន្តនូវទម្រង់វប្បធម៌អរូបី

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបន្តនូវទម្រង់វប្បធម៌អរូបីដែលជិតបាត់បង់ និងត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ និងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ ។

**មាត្រា៧២៥** ._ ការឧបត្ថម្ភដល់ការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយទម្រង់វប្បធម៌អរូបី

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ត្រូវជម្រុញឱ្យមាន និងឧបត្ថម្ភដល់ការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយនូវទម្រង់វប្បធម៌អរូបី ដែលបានបាត់បង់ ។

## ជំពូកទី១៧
## ការអប់រំ និងការយល់ដឹង

**មាត្រា៧២៦** ._ ការអប់រំ និងការយល់ដឹងជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ត្រូវរៀបចំកម្មវិធីអប់រំ និងការយល់ដឹងជាសាធារណៈ សម្រាប់ការអភិរក្ស ការអភិវឌ្ឍបេតិកភណ្ឌវប្បធម៌រូបី និងអរូបី ។

**មាត្រា៧២៧ ._** ថ្លៃសេវា និងបន្ទុកផ្សេងៗ

ផែនការគ្រប់គ្រងតំបន់បេតិកភណ្ឌវប្បធម៌ អាចដាក់បញ្ចូលនូវបទប្បញ្ញត្តិដែលចែងអំពីការបង់កម្រៃសេវា និងបន្ទុកផ្សេងៗ ដែលត្រូវយកមកប្រើប្រាស់សម្រាប់ការលើកកម្ពស់ និងកិច្ចការពារបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៧២៨ ._** ការរៀបចំក្របខ័ណ្ឌច្បាប់គ្រប់គ្រង និងការផ្ដល់អាជ្ញាប័ណ្ណ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីការផ្ដល់អាជ្ញាប័ណ្ណ និងការគ្រប់គ្រងសារមន្ទីរ និង/ឬ ស្ថាប័ន ឬអង្គការវប្បធម៌ ស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ ។

## ជំពូកទី១៨
## បទប្បញ្ញត្តិប្រឆាំងនឹងការជួញដូរសម្បត្តិវប្បធម៌

**មាត្រា៧២៩ ._** ការហាមឃាត់ចំពោះការនាំចេញសម្បត្តិវប្បធម៌

ត្រូវបានហាមឃាត់ដាច់ខាតនូវការនាំចេញសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៣៦ លើកលែងតែមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

បែបបទ និងនីតិវិធីនៃការអនុញ្ញាតនាំចេញសម្បត្តិវប្បធម៌ ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិដែលនៅជាធរមាន ។

**មាត្រា៧៣០ ._** កិច្ចសហការ និងការចាត់វិធានការប្រឆាំងការជួញដូរ និងការធ្វើចរាចរសម្បត្តិវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការប្រឆាំងការជួញដូរ និងការធ្វើចរាចរសម្បត្តិវប្បធម៌ ។

**មាត្រា៧៣១ ._** កិច្ចសហការអន្តរជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អង្គការមិនមែនរដ្ឋាភិបាល និងអង្គការប្រឆាំងការជួញដូរវត្ថុបុរាណ ត្រូវធ្វើការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយនូវសម្បត្តិវប្បធម៌ ដែលបាននាំចេញដោយខុសច្បាប់ ។

**មាត្រា៧៣២ .**_ វិធានសម្រាប់ការនាំយកមកវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការនាំមកវិញនូវសម្បត្តិវប្បធម៌ ដែលត្រូវបានយកចេញពីព្រះរាជាណាចក្រកម្ពុជា ដោយខុសច្បាប់ ។

**មាត្រា៧៣៣ .**_ ការចរចា ឬប្តឹងទាមទារឱ្យមានការបញ្ជូនត្រឡប់មកវិញនូវសម្បត្តិវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវចាត់វិធានការ និងនីតិវិធី ក្នុងការចរចា ឬប្តឹងទាមទារឱ្យមានការបញ្ជូនត្រឡប់មកវិញនូវសម្បត្តិវប្បធម៌ ដែលត្រូវបាននាំចេញដោយខុសច្បាប់ស្របតាមច្បាប់ជាតិ និងអន្តរជាតិ ។

## គន្ថីទី៦
## ការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុលបរិស្ថាន
## មាតិកាទី១
## បទប្បញ្ញត្តិទូទៅ
## ជំពូកទី១
## កាតព្វកិច្ចគ្រប់គ្រងសំណល់

**មាត្រា៧៣៤ .**_ កាតព្វកិច្ចគ្រប់គ្រងសំណល់

រូបវន្តបុគ្គល ឬនីតិបុគ្គល ម្ចាស់សំណល់ និងប្រតិបត្តិករសំណល់ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់របស់ខ្លួនឱ្យបានត្រឹមត្រូវតាមវិធានសុវត្ថិភាពបរិស្ថាន ដែលមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ។

**មាត្រា៧៣៥ .**_ កាតព្វកិច្ចបង់ថ្លៃសេវាសំណល់

រូបវន្តបុគ្គល ឬនីតិបុគ្គល ម្ចាស់សំណល់ មានកាតព្វកិច្ចទទួលខុសត្រូវបង់ថ្លៃសេវាសំណល់របស់ខ្លួន អនុលោមតាមការកំណត់នៃលិខិតបទដ្ឋានគតិយុត្តរបស់ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៧៣៦ .**_ ហាមឃាត់ការបញ្ចេញសំណល់មិនឆ្លើយតបស្តង់ដារបញ្ចេញ

ហាមឃាត់ជាដាច់ខាតចំពោះការបញ្ចេញសំណល់ ឬសារធាតុបំពុលក្នុងសំណល់ មិនឆ្លើយតបនឹងស្តង់ដារបញ្ចេញ ដែលមានចែងកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

រូបវន្តបុគ្គល ឬនីតិបុគ្គល ម្ចាស់សំណល់ ឬប្រតិបត្តិករសំណល់ ដែលធ្វើសកម្មភាពផ្ទាល់ ឬបញ្ជាឱ្យមានការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើ ត្រូវទទួលខុសត្រូវចំពោះបទល្មើសនេះ ។

**មាត្រា៧៣៧** ._ ការហាមឃាត់ការបោះបង់ចោលសំណល់ខុសពីគោលការណ៍កំណត់

ហាមឃាត់ជាដាច់ខាតចំពោះ ការបោះបង់ចោល ឬបញ្ចេញសំណល់ ល្មើសទៅនឹងគោលការណ៍កំណត់ ឬលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

រូបវន្តបុគ្គល ឬនីតិបុគ្គល ម្ចាស់សំណល់ ឬប្រតិបត្តិករសំណល់ ដែលធ្វើសកម្មភាពផ្ទាល់ ឬបញ្ជាឱ្យមានការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើ ត្រូវទទួលខុសត្រូវចំពោះបទល្មើសនេះ ។

## ជំពូកទី២
## ការទទួលខុសត្រូវការបំពុលបរិស្ថាន

**មាត្រា៧៣៨** ._ កាតព្វកិច្ចមិនបង្កការបំពុលបរិស្ថាន

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវធ្វើសកម្មភាពដែលនាំឱ្យមានការបំពុលបរិស្ថាន ទឹក ដី ខ្យល់ ឬបង្កផលប៉ះពាល់ដល់សុខភាពសាធារណៈ ឬផលប្រយោជន៍ពីភាពអាស្រ័យនឹងមជ្ឈដ្ឋានបរិស្ថាន ។

**មាត្រា៧៣៩** ._ កាតព្វកិច្ចមិនបង្កការរំខានដោយសំឡេង រំញ័រ ឬក្លិន

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវធ្វើសកម្មភាពបញ្ចេញសំឡេង រំញ័រ ឬក្លិន ដែលបង្កឱ្យមានការរំខានដល់ការរស់នៅ ឬបង្កឱ្យផលប៉ះពាល់ដល់សុខភាពសាធារណៈ ឬផលប្រយោជន៍នានា ។

**មាត្រា៧៤០** ._ ការទទួលខុសត្រូវលើបញ្ហាការបំពុលបរិស្ថាន ឬការបង្កគ្រោះថ្នាក់

រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវទទួលខុសត្រូវលើបញ្ហាការបំពុលបរិស្ថាន ការបង្កគ្រោះថ្នាក់ដល់បរិស្ថាន សុខភាព ជីវៈចម្រុះ ឬទ្រព្យសម្បត្តិ ពីសកម្មភាពបង្កដោយផ្ទាល់ខ្លួន ឬការបញ្ហាដែលនាំឱ្យមានការបំពុលបរិស្ថាន ឬគ្រោះថ្នាក់នានាកើតឡើង ទោះដោយចេតនា ឬអចេតនាក្តី ។

## ជំពូកទី៣
## វិធានការត្រួតពិនិត្យការបំពុលបរិស្ថាន
## ផ្នែកទី១
## ស្តង់ដារបរិស្ថាន

**មាត្រា៧៤១** ._ ការរៀបចំស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការរៀបចំស្តង់ដារបរិស្ថាន មានជាអាទិ៍ ស្តង់ដារគុណភាពបរិស្ថាន ស្តង់ដារបញ្ចេញ និងស្តង់ដារគ្រប់គ្រងសំណល់ និងសារធាតុគ្រោះថ្នាក់ ។

ស្តង់ដារគុណភាពបរិស្ថាន ស្តង់ដារបញ្ចេញ និងស្តង់ដារគ្រប់គ្រងសំណល់ និងសារធាតុគ្រោះថ្នាក់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៧៤២** ._ ការពិគ្រោះយោបល់លើការបង្កើតស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ នៅក្នុងដំណើរការរៀបចំស្តង់ដារបរិស្ថាន ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងត្រូវរៀបចំឱ្យមានការចូលរួមផ្តល់យោបល់ពីគ្រប់ភាគីពាក់ព័ន្ធ និងសាធារណជន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៧៤៣** ._ ការពិចារណា និងការបដិសេធលើមតិយោបល់របស់សាធារណជន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវពិចារណារាល់មតិយោបល់របស់ភាគីពាក់ព័ន្ធ និងសាធារណជន សម្រាប់ការរៀបចំសេចក្តីព្រាងស្តង់ដារបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្នុងករណីបដិសេធចំពោះមតិយោបល់របស់ភាគីពាក់ព័ន្ធ និងសាធារណជន លើការរៀបចំសេចក្តីព្រាងស្តង់ដារបរិស្ថាន ត្រូវធ្វើការពន្យល់អំពីមូលហេតុនៃការបដិសេធ ។

**មាត្រា៧៤៤** ._ ការធ្វើបច្ចុប្បន្នភាពស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើបច្ចុប្បន្នភាពស្តង់ដារគុណភាពបរិស្ថាន ស្តង់ដារបញ្ចេញ និងស្តង់ដារគ្រប់គ្រងសំណល់ និងសារធាតុគ្រោះថ្នាក់ ឱ្យស្របទៅតាមស្ថានភាពរីកចម្រើនសេដ្ឋកិច្ចជាតិ ស្ថានភាពបរិស្ថានជាតិ ឬលក្ខខណ្ឌតម្រូវនានា និងផលប្រយោជន៍សាធារណៈ ។

**មាត្រា៧៤៥** ._ សិទ្ធិទទួលបានព័ត៌មានអំពីស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំទិន្នន័យព័ត៌មានអំពីស្តង់ដារបរិស្ថាន ឱ្យគ្រប់ភាគីពាក់ព័ន្ធ និងសាធារណជនអាចស្វែងរក និងទទួលបាន ស្របតាមបទប្បញ្ញត្តិសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ដែលមានចែងនៅក្នុងក្រមនេះ ។

**មាត្រា៧៤៦** ._ ការបន្តអនុវត្តស្តង់ដារបរិស្ថានក្នុងអន្តរកាល

ស្តង់ដារបរិស្ថាន ដែលមានជាធរមានទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តអនុវត្តក្រោយពេលក្រមនេះចូលជាធរមាន រហូតដល់មានស្តង់ដារគុណភាពបរិស្ថាន ស្តង់ដារបញ្ចេញ និងស្តង់ដារគ្រប់គ្រងសំណល់ និងសារធាតុគ្រោះថ្នាក់ថ្មី ត្រូវបានបង្កើតឡើងនៅក្រោមបទប្បញ្ញត្តិនៃក្រមនេះ ។

## ផ្នែកទី២
## លិខិតអនុញ្ញាតសំណល់

**មាត្រា៧៤៧** ._ ការតម្រូវឱ្យសុំលិខិតអនុញ្ញាតសំណល់

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវធ្វើការប្រមូល ដឹកជញ្ជូន ធ្វើប្រព្រឹត្តកម្ម កែច្នៃ កម្ទេចចោល បោះបង់ ឬបញ្ចេញចោលសំណល់ ឬសារធាតុបំពុល លើកលែងតែមានលិខិតអនុញ្ញាតសំណល់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ។

ការបញ្ចេញសំរាម ឬទឹកកខ្វក់ពីប្រភពបង្កើត ត្រូវលើកលែងមិនតម្រូវឱ្យសុំលិខិតអនុញ្ញាតសំណល់ ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើឡើយ ។

**មាត្រា៧៤៨ ._** ការកំណត់លក្ខខណ្ឌតម្រូវអនុវត្តនៃលិខិតអនុញ្ញាតសំណល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវប្រើប្រាស់ស្តង់ដារបរិស្ថានដើម្បីកំណត់លក្ខខណ្ឌតម្រូវអនុវត្តនៃលិខិតអនុញ្ញាតសំណល់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចបន្ថែមនូវលក្ខខណ្ឌតម្រូវអនុវត្តនានានៃលិខិតអនុញ្ញាតសំណល់ អនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ។

**មាត្រា៧៤៩ ._** ការព្យួរ ឬដកហូតលិខិតអនុញ្ញាតសំណល់

លិខិតអនុញ្ញាតសំណល់ នឹងត្រូវព្យួរបណ្តោះអាសន្ន ឬដកហូតជាស្ថាពរ ប្រសិនបើ ៖

១- មានការរំលោភស្តង់ដារគុណភាពបរិស្ថាន ឬស្តង់ដារបញ្ចេញ ។

២- ខកខានមិនបានអនុវត្តលក្ខខណ្ឌតម្រូវអនុវត្ត ដែលមានកំណត់ក្នុងលិខិតអនុញ្ញាតសំណល់ ។

៣- កើតមានករណីការបំពុលបរិស្ថាន ឬការបង្កគ្រោះថ្នាក់ដល់សុខភាព បណ្តាលពីសកម្មភាពគ្រប់គ្រងសំណល់ដែលស្ថិតនៅក្រោមលិខិតអនុញ្ញាតសំណល់នោះ ។

## ផ្នែកទី៣
## ការបង់ថ្លៃបំពុលបរិស្ថាន និងការបង់អាករបរិស្ថាន

**មាត្រា៧៥០ ._** កាតព្វកិច្ចបង់ថ្លៃបំពុលបរិស្ថាន

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កឱ្យមានកំណើនបន្ទុកសារធាតុបំពុលនៅក្នុងបរិស្ថាន តាមរយៈការបញ្ចេញចោលសំណល់ ឬសារធាតុគ្រោះថ្នាក់ពីសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួន ត្រូវមានកាតព្វកិច្ចបង់ថ្លៃបំពុលបរិស្ថាន ។

ប្រភេទទីតាំងដែលតម្រូវឱ្យបង់ថ្លៃការបំពុលបរិស្ថាន និងអត្រាបង់ថ្លៃការបំពុលបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៧៥១ ._** កាតព្វកិច្ចបង់អាករបរិស្ថាន

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលនាំចូល ឬផលិតនូវផលិតផល គ្រឿងបរិក្ខារ ឬសម្ភារប្រើប្រាស់ ដែលអាចបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរដល់បរិស្ថាន ឬសុខភាពសាធារណៈ ក្រោយពេលក្លាយជាសំណល់ និងក្រោយពេលបោះបង់ចោល ត្រូវមានកាតព្វកិច្ចបង់អាករបរិស្ថាន ។

ប្រភេទផលិតផល គ្រឿងបរិក្ខារ ឬសម្ភារប្រើប្រាស់ដែលតម្រូវបង់អាករបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៧៥២ ._** ការប្រើប្រាស់ថវិកាពីការបង់ថ្លៃបំពុលបរិស្ថាន និងអាករបរិស្ថាន

ថវិកាដែលប្រមូលបានពីការបង់ថ្លៃបំពុលបរិស្ថាន និងអាករបរិស្ថាន ត្រូវប្រើប្រាស់សម្រាប់គោលដៅសិក្សាស្រាវជ្រាវ ការពារ និងការធ្វើឱ្យប្រសើរឡើងនូវគុណភាពបរិស្ថាន ឬការស្តារបរិស្ថានដែលទទួលរងការបំពុល ។

ការគ្រប់គ្រង និងការប្រើប្រាស់ថវិកាពីការបង់ថ្លៃបំពុលបរិស្ថាន និងអាករបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

## មាតិកាទី២
## ការត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៧៥៣ ._** វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះសកម្មភាពដែលបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ឬដែលបង្កឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាន និងសុខភាពសាធារណៈពីឥទ្ធិពលនៃសារធាតុគ្រោះថ្នាក់ ។

មាតិកានេះ មិនមានវិសាលភាពអនុវត្តចំពោះសារធាតុវិទ្យុសកម្ម និងសារធាតុគីមីដែលពាក់ព័ន្ធនឹងវិស័យការពារជាតិ ដែលស្ថិតនៅក្រោមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៧៥៤ ._** ស្ថាប័នទទួលខុសត្រូវការត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ជាស្ថាប័នទទួលខុសត្រូវ ត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៧៥៥**._ លិខិតបទដ្ឋានគតិយុត្តស្តីពីសារធាតុគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ជំរុញការអនុវត្តបទប្បញ្ញត្តិត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់នៃមាតិកានេះ និងសម្រាប់ដាក់បញ្ញត្តិលើបញ្ហាបំពុលបរិស្ថានពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ ។

**មាត្រា៧៥៦** ._ ការទទួលខុសត្រូវលើការខូចខាត

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កឱ្យមានការកំពប់ ឬការលេចធ្លាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ត្រូវទទួលខុសត្រូវលើការខូចខាតដល់ទ្រព្យសម្បត្តិ ឬបរិស្ថាន ការប៉ះពាល់ដល់សុខភាពសាធារណៈ និងការស្តារការបំពុលបរិស្ថាន ។

## ជំពូកទី២
## ការគ្រប់គ្រងការសាយភាយសារធាតុគ្រោះថ្នាក់

**មាត្រា៧៥៧**._ ផែនការយុទ្ធសាស្ត្រគ្រប់គ្រងការសាយភាយសារធាតុគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួល និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ។

**មាត្រា៧៥៨**._ កិច្ចសហការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ

ក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចលើការគ្រប់គ្រងសារធាតុគីមីតាមវិស័យ ត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថានឱ្យមានប្រសិទ្ធភាព ។

**មាត្រា៧៥៩ ._** បញ្ជីសារធាតុគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ដែលត្រូវហាមឃាត់ និងដែលអនុញ្ញាតដោយមានលក្ខខណ្ឌសម្រាប់ការផលិត ការនាំចូល ឬការប្រើប្រាស់ ។

ការរៀបចំបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវផ្អែកទៅលើសេចក្តីតម្រូវនៃលិខិតុបករណ៍អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក និងទៅលើតម្រូវការចាំបាច់ក្នុងការការពារសុខភាពសាធារណៈ និងបរិស្ថាន ។

**មាត្រា៧៦០ ._** ស្តង់ដារកម្រិតកំណត់បរិមាណសារធាតុគ្រោះថ្នាក់នៅក្នុងផលិតផល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារកម្រិតកំណត់បរិមាណសារធាតុគ្រោះថ្នាក់ ដែលអាចអនុញ្ញាតឱ្យមាននៅក្នុងផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេង ដោយត្រូវផ្អែកទៅលើសេចក្តីតម្រូវនៃលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក និងទៅលើតម្រូវការចាំបាច់ក្នុងការការពារសុខភាពសាធារណៈ និងបរិស្ថាន ។

**មាត្រា៧៦១ ._** គោលការណ៍ណែនាំបច្ចេកទេសសារធាតុគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេសសារធាតុគ្រោះថ្នាក់ អំពី ៖

១- ការដាក់ស្លាកសញ្ញាគ្រោះថ្នាក់ និងសញ្ញាព្រមានគ្រោះថ្នាក់ ។

២- វិធានការទប់ស្កាត់ការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ដែលត្រូវអនុវត្តចំពោះទីតាំង ឬសកម្មភាពដែលពាក់ព័ន្ធការផលិត ការនាំចូល ការដឹកជញ្ជូន ការស្តុក ការចែកចាយ ការប្រើប្រាស់ និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់ ។

**មាត្រា៧៦២ ._** ការសិក្សាស្រាវជ្រាវ តាមដាន និងត្រួតពិនិត្យការសាយភាយ ឬភាពបង្កហានិភ័យ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលខុសត្រូវចុះសិក្សាស្រាវជ្រាវ តាមដាន និងត្រួតពិនិត្យទីតាំងផលិត ស្តុក និងប្រើប្រាស់សារធាតុគ្រោះថ្នាក់ និងផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ សម្រាប់គោល

បំណងជំរុញការអនុវត្តវិធានការទប់ស្កាត់ការសាយភាយ ឬភាពបង្កហានិភ័យដល់សុខភាពសាធារណៈ និងបរិស្ថាន ។

**មាត្រា៧៦៣** ._ ការផ្តល់ព័ត៌មានអំពីសារធាតុគ្រោះថ្នាក់ជូនសាធារណជន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ និងផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## ជំពូកទី៣
## ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់ និងផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់

**មាត្រា៧៦៤** ._ ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់

បុគ្គលអ្នកផលិត នាំចូល ឬអ្នកចែកចាយសារធាតុ ឬផលិតផលសារធាតុគីមី ដែលជាប្រភេទសារធាតុគ្រោះថ្នាក់ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវធ្វើការចុះបញ្ជិកានៅក្រសួង ស្ថាប័នទទួលបន្ទុកតាមវិស័យ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ពិសេស ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ។

**មាត្រា៧៦៥** ._ ការផ្តល់ព័ត៌មានការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកតាមវិស័យ ត្រូវផ្តល់ព័ត៌មានអំពីការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់មកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្នុងគោលបំណងនៃការរៀបចំបញ្ជីសារពើភណ្ឌ ការអង្កេតតាមដាន ការវាយតម្លៃពីហានិភ័យ ការចាត់វិធានការបង្ការ ឬឆ្លើយតបនឹងហានិភ័យ និងការជូនព័ត៌មានដល់សាធារណជន ។

**មាត្រា៧៦៦** ._ ការចុះបញ្ជិកាផលិតផល ឬសម្ភារប្រើប្រាស់ វត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់

បុគ្គលអ្នកផលិត នាំចូល ឬអ្នកចែកចាយផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ ដូចមានចែងកំណត់ក្រោមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវធ្វើការចុះបញ្ជិកានៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នីតិវិធីនៃការចុះបញ្ជិកាផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ ដូចមានចែងកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៧៦៧**._ ការបដិសេធការស្នើសុំចុះបញ្ជិកា

ក្រសួង ស្ថាប័នទទួលបន្ទុកតាមវិស័យ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការបដិសេធលើការស្នើសុំចុះបញ្ជិកាសារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ក្នុងករណីដែល ៖

១- សារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលស្នើសុំចុះបញ្ជិកានោះ ស្ថិតក្នុងបញ្ជីហាមឃាត់នៅក្រោមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សម្រាប់ការផលិត ការនាំចូល ឬការប្រើប្រាស់ ។

២- សារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលស្នើសុំចុះបញ្ជិកានោះ ស្ថិតក្នុងការហាមឃាត់ការផលិត ឬប្រើប្រាស់ អនុលោមទៅតាមលិខិតុបករណ៍អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក ។

៣- មានការរកឃើញថាសារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលស្នើសុំចុះបញ្ជិកានោះ អាចនឹងបង្កឱ្យមានហានិភ័យខ្ពស់ដល់សុខភាពសាធារណៈ និងបរិស្ថាន ។

**មាត្រា៧៦៨**._ ការលុបចោលការចុះបញ្ជី

ក្រសួង ស្ថាប័នទទួលបន្ទុកតាមវិស័យ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវលុបចោលវិញ្ញាបនបត្រចុះបញ្ជិកាសារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ប្រសិនបើ ៖

១- មានការរកឃើញការប្រើប្រាស់ ឬការសាយភាយសារធាតុគ្រោះថ្នាក់នោះ បានបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬបរិស្ថាន ។

២- មានការហាមឃាត់ទាំងស្រុងដោយលិខិតបទដ្ឋានគតិយុត្តជាតិ ឬលិខិតុបករណ៍អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក ។

## ជំពូកទី៤
## ការដាក់ស្លាកសញ្ញាគ្រោះថ្នាក់

**មាត្រា៧៦៩** ._ ការដាក់ស្លាកសញ្ញាលើសម្ភារវេចខ្ចប់សារធាតុគ្រោះថ្នាក់

សារធាតុគ្រោះថ្នាក់ ដែលផលិត នាំចូល ឬចែកចាយ ដូចមានចែងកំណត់នៅក្រោមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវដាក់ស្លាកសញ្ញាគ្រោះថ្នាក់ និងសារព្រមានគ្រោះថ្នាក់នៅលើសម្ភារវេចខ្ចប់ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ពិសេស ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ។

**មាត្រា៧៧០** ._ ការដាក់សញ្ញាព្រមានគ្រោះថ្នាក់លើផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេង មានផ្ទុកសារធាតុគ្រោះថ្នាក់

ផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលផលិត នាំចូល ឬចែកចាយ ដូចមានចែងកំណត់នៅក្រោមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវដាក់សញ្ញាព្រមានគ្រោះថ្នាក់នៅលើផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងនោះ ។

សញ្ញាព្រមានគ្រោះថ្នាក់សម្រាប់ផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

## ជំពូកទី៥
## កាតព្វកិច្ចបុគ្គលពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់

**មាត្រា៧៧១** ._ កាតព្វកិច្ចផ្តល់ព័ត៌មានសារធាតុគ្រោះថ្នាក់

បុគ្គលដែលផលិត នាំចូល ឬចែកចាយសារធាតុគ្រោះថ្នាក់ និងប្រើប្រាស់សារធាតុគ្រោះថ្នាក់ក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ត្រូវមានកាតព្វកិច្ចផ្តល់ព័ត៌មាន និងរបាយការណ៍ប្រចាំឆ្នាំ ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ តាមគោលការណ៍កំណត់ដែលពាក់ព័ន្ធនឹង ៖

១- ប្រភេទ បរិមាណសារធាតុគ្រោះថ្នាក់ដែលបានផលិត នាំចូល ចែកចាយ ប្រើប្រាស់ ឬត្រូវបោះបង់ចោល ។

២- វិធានការ និងមធ្យោបាយសម្រាប់គ្រប់គ្រង និងទប់ស្កាត់ ការសាយភាយសារធាតុគ្រោះថ្នាក់ ឬការបង្កហានិភ័យដល់សុខភាពសាធារណៈ ឬបរិស្ថាន ។

**មាត្រា៧៧២** ._ កាតព្វកិច្ចផ្តល់ព័ត៌មានផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេង មានផ្ទុកសារធាតុគ្រោះថ្នាក់

បុគ្គលដែលផលិត នាំចូល ឬចែកចាយផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវមានកាតព្វកិច្ចផ្តល់ព័ត៌មាន និងរបាយការណ៍ប្រចាំឆ្នាំ ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ តាមគោលការណ៍កំណត់ដែលពាក់ព័ន្ធនឹង ៖

១- ប្រភេទ បរិមាណផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលបានផលិត នាំចូល ចែកចាយ ឬដែលត្រូវបោះបង់ចោល ។

២- ការអនុវត្តដាក់សញ្ញាព្រមានគ្រោះថ្នាក់នៅលើផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ ។

**មាត្រា៧៧៣** ._ ការជូនដំណឹងអំពីឧបទ្ទវហេតុលេចធ្លាយ ឬសាយភាយសារធាតុគ្រោះថ្នាក់

បុគ្គលដែលផលិត នាំចូល ដឹកជញ្ជូន ឬចែកចាយសារធាតុគ្រោះថ្នាក់ និងប្រើប្រាស់សារធាតុគ្រោះថ្នាក់ ក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ក្នុងករណីកើតមានគ្រោះថ្នាក់ ឬគ្រោះឧបទ្ទវហេតុលេចធ្លាយ ឬសាយភាយសារធាតុគ្រោះថ្នាក់ ត្រូវ ៖

១- បញ្ឈប់សកម្មភាពដែលទាក់ទងនឹងការលេចធ្លាយ ឬសាយភាយសារធាតុគ្រោះថ្នាក់ ។

២- រាយការណ៍ពីភាពគ្រោះថ្នាក់ជាបន្ទាន់ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ។

៣- ចាត់វិធានការ ស្របតាមផែនការទប់ស្កាត់ និងឆ្លើយតបជាបន្ទាន់ ដើម្បីកាត់បន្ថយផលប៉ះពាល់ចំពោះសុខភាពសាធារណៈ និងបរិស្ថាន ។

៤- សហការជាមួយស្ថាប័នមានសមត្ថកិច្ច ជូនដំណឹងជាបន្ទាន់ ទៅដល់សាធារណជនក្នុងតំបន់ អំពីហានិភ័យអាចកើតមានដល់សុខភាពសាធារណៈ ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

**មាត្រា៧៧៤** ._ ការទទួលខុសត្រូវលើសារធាតុគ្រោះថ្នាក់ខូចគុណភាព ឬក្លាយជាសំណល់

បុគ្គលគ្រប់រូបដែលពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ កម្ទេចចោល ឬបោះបង់ចោល សារធាតុគ្រោះថ្នាក់ដែលខូចគុណភាព ឬផុតកំណត់កាលប្រើប្រាស់ អនុលោមតាមបទប្បញ្ញត្តិការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ។

## ជំពូកទី៦
## ការហាមឃាត់

**មាត្រា៧៧៥** ._ ការហាមឃាត់សារធាតុគ្រោះថ្នាក់

បុគ្គលគ្រប់រូបមិនត្រូវផលិត នាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ដែល ៖

១- ស្ថិតក្នុងបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ហាមឃាត់ ។

២- ពុំមានចុះបញ្ជិកានៅក្រសួង ស្ថាប័នទទួលបន្ទុកតាមវិស័យ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ពិសេស ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ។

៣- ពុំមានដាក់ស្លាកសញ្ញាគ្រោះថ្នាក់នៅលើសម្ភារវេចខ្ចប់ ឬដាក់ស្លាកសញ្ញាគ្រោះថ្នាក់បន្លំ ឬក្លែងក្លាយ ។

៤- មានការរកឃើញពីភាពគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬបរិស្ថាន ។

**មាត្រា៧៧៦** ._ ការហាមឃាត់ផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់

បុគ្គលគ្រប់រូបមិនត្រូវផលិត នាំចូល ឬចែកចាយផលិតផល សម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ដែល ៖

១- ស្ថិតក្នុងបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ហាមឃាត់ ។

២- ពុំមានចុះបញ្ជិកានៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

៣- មានផ្ទុកសារធាតុគ្រោះថ្នាក់លើសកម្រិតស្តង់ដារអនុញ្ញាត ។

៤- ពុំមានដាក់ស្លាកសញ្ញាព្រមានគ្រោះថ្នាក់នៅលើសម្ភារវេចខ្ចប់ ។

៥- មានការរកឃើញពីភាពគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬបរិស្ថាន ។

**មាត្រា៧៧៧** ._ ការហាមឃាត់ការបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់

ហាមឃាត់ជាដាច់ខាតនូវសកម្មភាពទាំងឡាយណា ដែលបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន រួមមាន ៖

១- ការចាក់ ឬបោះបង់ចោលសារធាតុគ្រោះថ្នាក់នៅតាមទីសាធារណៈ ឬចូលទៅក្នុងប្រភពទឹកសាធារណៈ ។

២- ការកម្ទេចចោល ឬការដុតសារធាតុគ្រោះថ្នាក់នៅក្នុងដីកម្មសិទ្ធិ នៅតាមទីវាល ឬទីសាធារណៈ ។

៣- ការបង្កឱ្យមានការកំពប់ ឬលេចធ្លាយសារធាតុគ្រោះថ្នាក់ ។

**មាត្រា៧៧៨** ._ ការឃាត់ទុក និងរឹបអូសសារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានកិច្ចសហការជាមួយ អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិធ្វើការឃាត់ទុក ឬរឹបអូសនូវសារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលត្រូវបានហាមឃាត់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ការចំណាយលើការដឹកជញ្ជូន រក្សាទុក និងកម្ទេចចោលសារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ដែលរឹបអូស ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវទទួលខុសត្រូវដោយម្ចាស់សារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលត្រូវរឹបអូសផ្ទាល់ ។

## មាតិកាទី៣
## ការគ្រប់គ្រងសំណល់រឹង
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៧៧៩** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើសកម្មភាពពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ ការបង្កើត ការញែក ការទុកដាក់ ការវេចខ្ចប់ ការប្រមូលដឹកជញ្ជូន ការកែច្នៃ ការធ្វើប្រព្រឹត្តកម្ម ការកម្ទេចចោល និងការបោះចោលសំណល់រឹង ។

**មាត្រា៧៨០** ._ ផែនការយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងសំណល់រឹង ដែលត្រូវផ្ដោតទៅលើផែនការសកម្មភាពសំខាន់ៗដូចខាងក្រោម ៖

១- ការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ លើការអនុវត្តការងារគ្រប់គ្រងសំណល់រឹងនៅក្នុងដែនរដ្ឋបាល ឱ្យមានតម្លាភាព ប្រសិទ្ធភាព និងសុវត្ថិភាពបរិស្ថាន ។

២- ការជំរុញការអនុវត្តសកម្មភាពគ្រប់គ្រងសំណល់រឹង តាមវិធានសុវត្ថិភាពបរិស្ថាននៅតាមប្រភពបង្កើត រួមមាន ការកាត់បន្ថយការបង្កើត ការញែក ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ ឬការទាញយកធនធានសំណល់រឹង ។

៣- ការជំរុញការរៀបចំសេវាគ្រប់គ្រង កែច្នៃ ឬទាញយកធនធានពីសំណល់រឹង ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការជំរុញ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងសំណល់រឹង ។

**មាត្រា៧៨១** ._ លិខិតបទដ្ឋានគតិយុត្តសំណល់រឹង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ជំរុញការអនុវត្តបទប្បញ្ញត្តិគ្រប់គ្រងសំណល់រឹងនៃមាតិកានេះ និងសម្រាប់ដាក់បញ្ញត្តិលើបញ្ហាបំពុលបរិស្ថានពាក់ព័ន្ធនឹងសំណល់រឹង ។

**មាត្រា៧៨២** ._ ការហាមឃាត់ការបោះបង់ចោល និងការដុតសំណល់រឹង

បុគ្គលគ្រប់រូបមិនត្រូវធ្វើការបោះចោល ឬបញ្ជាឱ្យមានការបោះចោលសំរាមសំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ប្រឡាយទឹក ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធ ដែលមិនមែនជាទីតាំងអនុញ្ញាតឱ្យទុកដាក់បណ្ដោះអាសន្ន ឬបោះបង់ចោលជាដាច់ខាត ។

បុគ្គលគ្រប់រូបមិនត្រូវធ្វើការដុត ឬបញ្ជាឱ្យមានការដុតសំរាមសំណល់រឹងទីប្រជុំជន នៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ឬក្នុងដីកម្មសិទ្ធជាដាច់ខាត ។

**មាត្រា៧៨៣** ._ ការទទួលខុសត្រូវចំពោះការខូចខាត

បុគ្គលម្ចាស់សំណល់រឹង ឬប្រតិបត្តិករសេវាសំណល់រឹង ដែលបង្កឱ្យមានការបំពុលបរិស្ថានផលប៉ះពាល់ដល់សុខភាព ឬការខូចខាតទ្រព្យសម្បត្តិ បណ្ដាលពីសកម្មភាពគ្រប់គ្រងសំណល់រឹងរបស់ខ្លួន ត្រូវទទួលខុសត្រូវលើការខូចខាត និងការស្ដារការបំពុលបរិស្ថាន ។

## ជំពូកទី២
## ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
### ផ្នែកទី១
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៧៨៤**._ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវដឹកនាំនយោបាយគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងត្រួតពិនិត្យការអនុវត្តការងារគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា៧៨៥**._ រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវលើការអនុវត្តការងារគ្រប់គ្រងសំរាមសំណល់រឹង ទីប្រជុំជន ដែលស្ថិតនៅក្នុងដែនរដ្ឋបាលរបស់ខ្លួន លើតួនាទី និងភារកិច្ចដូចខាងក្រោម ៖

១- រៀបចំលិខិតបទដ្ឋានជំរុញការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ។

២- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងារគ្រប់គ្រង ការសម្អាត និងលុបបំបាត់ការចោលរាយប៉ាយនូវសំរាមសំណល់រឹងទីប្រជុំជន ។

៣- តាមដាន ត្រួតពិនិត្យសេវាគ្រប់គ្រង និងកែច្នៃ ឬទាញយកធនធានសំរាមសំណល់រឹងទីប្រជុំជន ។

៤- ធ្វើការអប់រំ ផ្សព្វផ្សាយ និងណែនាំប្រជាពលរដ្ឋសម្រាប់ការចូលសម្អាតអនាម័យបរិស្ថាន និងការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនតាមវិធានសុវត្ថិភាពបរិស្ថាន ។

### ផ្នែកទី២
### កាតព្វកិច្ចម្ចាស់សំរាមសំណល់រឹងទីប្រជុំជន

**មាត្រា៧៨៦**._ កាតព្វកិច្ចម្ចាស់សំរាមសំណល់រឹងទីប្រជុំជន

ម្ចាស់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានកាតព្វកិច្ចអនុវត្តតាមគោលការណ៍កំណត់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនរបស់ខ្លួន មានជាអាទិ៍ ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញ ការសម្អាត និងការប្រើប្រាស់ និងការបង់ថ្លៃសេវាសំរាមសំណល់រឹងទីប្រជុំជន ។

## ផ្នែកទី៣
## សេវាប្រមូលដឹកជញ្ជូន និងសេវាទីលានចាក់សំរាមសំណល់រឹងទីប្រជុំជន

**មាត្រា៧៨៧** ._ ការរៀបចំសេវាប្រមូល ដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជន

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការរៀបចំឱ្យមាន និងដំណើរការសេវាប្រមូលដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជន ដែលស្ថិតនៅក្នុងដែនរដ្ឋបាលរបស់ខ្លួន ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងសុវត្ថិភាពបរិស្ថាន ។

នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការងារសេវាប្រមូលដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៧៨៨** ._ ការអនុញ្ញាតបង្កើតសេវាទីលានចាក់សំរាមសំណល់រឹងទីប្រជុំជន

រាល់ការវិនិយោគបង្កើតសេវាទីលានចាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការឯកភាពជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ លើវិធានការការពារសុវត្ថិភាពបរិស្ថាននៃសេវាទីលាន ។

## ជំពូកទី៣
## ការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម

**មាត្រា៧៨៩** ._ ការគ្រប់គ្រង និងការត្រួតពិនិត្យសំណល់រឹងឧស្សាហកម្ម

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវត្រួតពិនិត្យលើការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម ចាប់ពីប្រភពបង្កើតរហូតដល់ទីតាំងប្រព្រឹត្តកម្ម ឬទីលានចាក់ចុងក្រោយ ។

**មាត្រា៧៩០** ._ កាតព្វកិច្ចម្ចាស់ទីតាំងបង្កើតសំណល់រឹងឧស្សាហកម្ម

បុគ្គលម្ចាស់ទីតាំងដែលបង្កើតសំណល់រឹងឧស្សាហកម្ម ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងសំណល់របស់ខ្លួន ស្របតាមវិធានសុវត្ថិភាពបរិស្ថាន ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្នុងការញែក ទុកដាក់ ដឹកជញ្ជូន និងបោះបង់ចោលនៅទីលានចាក់ ។

**មាត្រា៧៩១** ._ ការបញ្ចេញសំណល់រឹងឧស្សាហកម្ម

បុគ្គលម្ចាស់ទីតាំងដែលបង្កើតសំណល់រឹងឧស្សាហកម្ម ត្រូវសុំលិខិតអនុញ្ញាតសម្រាប់ការបញ្ចេញសំណល់រឹងឧស្សាហកម្មរបស់ខ្លួន ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយត្រូវប្រើប្រាស់សេវាប្រមូលដឹកជញ្ជូន និងសេវាទីលានចាក់សំណល់រឹងឧស្សាហកម្ម ដែលមានការអនុញ្ញាតត្រឹមត្រូវពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៧៩២** ._ ការអនុញ្ញាតសេវាប្រមូលដឹកជញ្ជូន និងសេវាទុកដាក់សំណល់រឹងឧស្សាហកម្ម

រាល់ការវិនិយោគលើការផ្តល់សេវាប្រមូលដឹកជញ្ជូន និងសេវាទីលានចាក់សំណល់រឹងឧស្សាហកម្ម ត្រូវសុំការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី៤
## ការទាញយកធនធាន កែច្នៃ ការនាំចេញ និងនាំចូលសំណល់រឹង

**មាត្រា៧៩៣** ._ លិខិតអនុញ្ញាតអាជីវកម្មទាញយកធនធាន និងកែច្នៃសំណល់រឹង

រាល់ការធ្វើអាជីវកម្មទាញយកធនធាន ឬកែច្នៃសំណល់រឹង ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៧៩៤** ._ការនាំចេញសំណល់រឹង ឬផលិតផលពីការកែច្នៃសំណល់រឹង

រាល់ការនាំចេញសំណល់រឹង ឬផលិតផលពីការកែច្នៃសំណល់រឹង ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិជាមុន ។

**មាត្រា៧៩៥** ._ ការនាំចូលសំណល់រឹង

ត្រូវហាមឃាត់ជាដាច់ខាតនូវការនាំចូលសំណល់រឹងពីបរទេសមកក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់គោលបំណងដុតកម្ទេចចោល ឬបោះបង់ចោល ។

ក្នុងករណីចាំបាច់ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចធ្វើការស្នើសុំគោលការណ៍ទៅរាជរដ្ឋាភិបាល អនុញ្ញាតឱ្យមានការនាំចូលសំណល់រឹងពីបរទេស សម្រាប់បំពេញបន្ថែមដល់ដំណើរការកែច្នៃ ឬការទាញយកធនធានសំណល់រឹងនៅក្នុងស្រុក ។

## មាតិកាទី៤
## ការគ្រប់គ្រងសំណល់គ្រោះថ្នាក់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៧៩៦** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើសកម្មភាពពាក់ព័ន្ធការបង្កើត ការទុកដាក់ ការវេចខ្ចប់ ការដឹកជញ្ជូន ការកែច្នៃ ការធ្វើប្រព្រឹត្តកម្ម ការកម្ទេចចោល ឬការបោះបង់ចោលសំណល់គ្រោះថ្នាក់រួមទាំងការនាំចូល ការនាំចេញ និងការដឹកឆ្លងកាត់ ។

**មាត្រា៧៩៧** ._ ស្ថាប័នទទួលខុសត្រូវគ្រប់គ្រងសំណល់គ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវត្រួតពិនិត្យលើសកម្មភាពពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ ចាប់ពីប្រភពបង្កើតរហូតដល់ទីតាំងប្រព្រឹត្តកម្ម ឬទីលានបោះបង់ចោលចុងក្រោយ ។

**មាត្រា៧៩៨** ._ ផែនការយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងសំណល់គ្រោះថ្នាក់ សម្រាប់គោលបំណងកាត់បន្ថយភាពគ្រោះថ្នាក់ទៅលើសុខភាពសាធារណៈ និងបរិស្ថានពីឥទ្ធិពលនៃសំណល់គ្រោះថ្នាក់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការជំរុញ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងសំណល់គ្រោះថ្នាក់ ។

**មាត្រា៧៩៩ ._** លិខិតបទដ្ឋានគតិយុត្តសំណល់គ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ជំរុញការអនុវត្តបទប្បញ្ញត្តិគ្រប់គ្រងសំណល់គ្រោះថ្នាក់នៃមាតិកានេះ និងសម្រាប់ដាក់បញ្ញត្តិលើបញ្ហាបំពុលបរិស្ថានពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ ។

**មាត្រា៨០០ ._** ការគ្រប់គ្រងសំណល់វិទ្យុសកម្ម និងសំណល់វេជ្ជសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដោយឡែក សម្រាប់ការគ្រប់គ្រងសំណល់វិទ្យុសកម្ម និងសំណល់វេជ្ជសាស្ត្រ ។

**មាត្រា៨០១ ._** ការហាមឃាត់

ត្រូវហាមឃាត់ជាដាច់ខាតនូវសកម្មភាពទុកដាក់ វេចខ្ចប់ ដឹកជញ្ជូន ឬបញ្ចេញចោល និងសកម្មភាពអាជីវកម្មសេវាសំណល់គ្រោះថ្នាក់ ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព ខូចខាតទ្រព្យសម្បត្តិ ឬបង្កការបំពុលបរិស្ថាន ។

**មាត្រា៨០២ ._** ការទទួលខុសត្រូវលើការខូចខាត

ម្ចាស់សំណល់គ្រោះថ្នាក់ ឬប្រតិបត្តិករសំណល់គ្រោះថ្នាក់ ដែលបង្កឱ្យមានការបំពុលបរិស្ថានផលប៉ះពាល់ដល់សុខភាព ឬការខូចខាតទ្រព្យសម្បត្តិ បណ្តាលពីសកម្មភាពគ្រប់គ្រងសំណល់គ្រោះថ្នាក់របស់ខ្លួន ត្រូវទទួលខុសត្រូវលើការខូចខាត និងការស្តារការបំពុលបរិស្ថាន ។

## ជំពូកទី២
## វិធានការគ្រប់គ្រងសំណល់គ្រោះថ្នាក់
### ផ្នែកទី១
### ការបង្កើតសំណល់គ្រោះថ្នាក់

**មាត្រា៨០៣ ._** ការជូនដំណឹងពីការបង្កើតសំណល់គ្រោះថ្នាក់

ម្ចាស់សំណល់គ្រោះថ្នាក់ ត្រូវធ្វើការជូនដំណឹងមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អំពីប្រភេទ លក្ខណៈ និងបរិមាណសំណល់គ្រោះថ្នាក់ដែលបានបង្កើត និងអំពីវិធានការគ្រប់គ្រងសំណល់គ្រោះថ្នាក់ដែលបានអនុវត្ត ។

ទម្រង់ និងបែបបទនៃការជូនដំណឹងការបង្កើតសំណល់គ្រោះថ្នាក់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៨០៤**._ លិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់

ម្ចាស់សំណល់គ្រោះថ្នាក់ ដែលមានបំណងធ្វើការបញ្ជូនសំណល់គ្រោះថ្នាក់ចេញពីទីតាំងក្នុងគោលបំណងណាមួយ ឬដើម្បីបោះបង់ចោល ត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នីតិវិធី និងបែបបទនៃការសុំលិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៨០៥**._ ការទទួលខុសត្រូវរបស់ម្ចាស់សំណល់គ្រោះថ្នាក់

ម្ចាស់សំណល់គ្រោះថ្នាក់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ វេចខ្ចប់ រក្សាទុក ការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញសំណល់គ្រោះថ្នាក់ ស្របតាមវិធានសុវត្ថិភាពបរិស្ថាននៃគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់ ។

## ផ្នែកទី២
## សេវាប្រមូល ដឹកជញ្ជូន កែច្នៃ ប្រព្រឹត្តកម្ម កម្ទេចចោល ឬបោះបង់ចោលសំណល់គ្រោះថ្នាក់

**មាត្រា៨០៦**._ លិខិតអនុញ្ញាតសេវាសំណល់គ្រោះថ្នាក់

ប្រតិបត្តិករសំណល់គ្រោះថ្នាក់ ដែលដំណើរការសេវាសំណល់គ្រោះថ្នាក់ ទាក់ទងនឹងការប្រមូល ដឹកជញ្ជូន កែច្នៃ ប្រព្រឹត្តកម្ម កម្ទេចចោល ឬបោះបង់ចោលសំណល់គ្រោះថ្នាក់ ត្រូវសុំការអនុញ្ញាតជាមុន ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នីតិវិធី និងលក្ខខណ្ឌនៃការសុំលិខិតអនុញ្ញាតសេវាសំណល់គ្រោះថ្នាក់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៨០៧ .**_ ការទទួលខុសត្រូវរបស់ប្រតិបត្តិករសំណល់គ្រោះថ្នាក់

ប្រតិបត្តិករសំណល់គ្រោះថ្នាក់ ទាក់ទងនឹងការប្រមូល ដឹកជញ្ជូន កែច្នៃ ប្រព្រឹត្តកម្ម កម្ទេចចោល ឬបោះបង់ចោលសំណល់គ្រោះថ្នាក់ ត្រូវទទួលខុសត្រូវ និងធានាថា ដំណើរការសេវាសំណល់គ្រោះថ្នាក់របស់ខ្លួន គឺបានអនុវត្តតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាត និងតាមវិធានសុវត្ថិភាពបរិស្ថាននៃគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ។

## ផ្នែកទី៣
## ការនាំចូល ការនាំចេញ និងការដឹកជញ្ជូនឆ្លងកាត់

**មាត្រា៨០៨ .**_ ការហាមឃាត់ការនាំចូលសំណល់គ្រោះថ្នាក់

ត្រូវហាមឃាត់ជាដាច់ខាត ការនាំសំណល់គ្រោះថ្នាក់ពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៨០៩ .**_ ការអនុញ្ញាតនាំចេញសំណល់គ្រោះថ្នាក់

ការនាំសំណល់គ្រោះថ្នាក់ពីព្រះរាជាណាចក្រកម្ពុជាចេញទៅក្រៅប្រទេស ត្រូវបានអនុញ្ញាតលុះត្រាតែបានបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

១- ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើការនាំចូលពីប្រទេសសាមី ដែលនាំសំណល់គ្រោះថ្នាក់ចូល ។

២- ត្រូវមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

៣- ត្រូវមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួង ស្ថាប័នទទួលបន្ទុកពាណិជ្ជកម្ម ។

៤- ត្រូវមានលិខិតធានារបស់អ្នកនាំចេញ មិនធ្វើការនាំត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ នូវសំណល់គ្រោះថ្នាក់ដែលបានអនុញ្ញាតឱ្យធ្វើការនាំចេញ ។

៥- ត្រូវបំពេញតាមនីតិវិធីនាំចេញសំណល់គ្រោះថ្នាក់ អនុលោមតាមបទប្បញ្ញត្តិលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ ដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក ។

**មាត្រា៨១០ .**_ ការអនុញ្ញាតដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឆ្លងកាត់

ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ពីប្រទេសមួយទៅប្រទេសមួយទៀត ដោយឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុញ្ញាត លុះត្រាតែបានបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

១- ត្រូវមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ ៣០ (សាមសិប) ថ្ងៃ មុនការដឹកឆ្លងកាត់ ។

២- ត្រូវបង់ថ្លៃសេវាឆ្លងកាត់ តាមការកំណត់របស់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣- ត្រូវមានកិច្ចសន្យាទទួលសងការខូចខាត និងសម្អាតបរិស្ថាន ក្នុងករណីមានគ្រោះថ្នាក់លេចធ្លាយសំណល់គ្រោះថ្នាក់ដោយចៃដន្យក្នុងពេលឆ្លងកាត់ ។

៤- អាចធ្វើការសំចតបណ្ដោះអាសន្នពេលដឹកឆ្លងកាត់ ក្នុងរយៈពេលយ៉ាងយូរត្រឹម ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃចូលដល់ព្រះរាជាណាចក្រកម្ពុជា ។

៥- ត្រូវបំពេញតាមនីតិវិធីនាំចេញសំណល់គ្រោះថ្នាក់ ដោយអនុលោមតាមបទប្បញ្ញត្តិលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ ដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក ។

## ផ្នែកទី៤
## ហេតុការណ៍កំពប់ ឬគ្រោះឧបទ្ទវហេតុលេចធ្លាយសំណល់គ្រោះថ្នាក់

**មាត្រា៨១១** ._ ការចាត់វិធានការករណីកំពប់ ឬលេចធ្លាយសំណល់គ្រោះថ្នាក់

ក្នុងករណីកើតមានហេតុការណ៍កំពប់ ឬគ្រោះឧបទ្ទវហេតុលេចធ្លាយសំណល់គ្រោះថ្នាក់ នៅលើទីតាំងបង្កើតសំណល់គ្រោះថ្នាក់ ឬក្នុងពេលប្រតិបត្តិការសេវាសំណល់គ្រោះថ្នាក់ ម្ចាស់សំណល់គ្រោះថ្នាក់ ឬប្រតិបត្តិករសេវាសំណល់គ្រោះថ្នាក់ត្រូវ ៖

១- ជូនដំណឹងជាបន្ទាន់មកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ ឬភ្នាក់ងារសេវាសង្គ្រោះ អំពីហេតុការណ៍ ឬគ្រោះឧបទ្ទវហេតុ និងស្នើសុំកិច្ចអន្តរាគមន៍ក្នុងករណីកើតមានគ្រោះអគ្គិភ័យ ឬប៉ះពាល់ដល់ជីវិតមនុស្ស សត្វ ។

២- ចាត់វិធានការជាបន្ទាន់ ដើម្បីរារាំង ឬបញ្ឈប់ការកំពប់ ឬការលេចធ្លាយ និងធ្វើការប្រមូល វេចខ្ចប់ និងសម្អាតសំណល់គ្រោះថ្នាក់ដែលបានកំពប់ ឬលេចធ្លាយ ។

៣- ផ្ដល់ព័ត៌មានលម្អិតទាក់ទងនឹងសំណល់គ្រោះថ្នាក់ដែលបានកំពប់ ឬលេចធ្លាយ ។

៤- ចូលរួមសហការជាមួយមន្ត្រីអធិការក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការសិក្សា និងវាយតម្លៃផលប៉ះពាល់ ឬគ្រោះថ្នាក់ទៅលើមនុស្ស សត្វ ឬបរិស្ថាន ពីករណីកំពប់ ឬលេចធ្លាយសំណល់គ្រោះថ្នាក់ ។

## ជំពូកទី៣
## ការត្រួតពិនិត្យការគ្រប់គ្រងសំណល់គ្រោះថ្នាក់

**មាត្រា៨១២** ._ សមត្ថកិច្ចត្រួតពិនិត្យ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យរាល់មធ្យោបាយគ្រប់គ្រងសំណល់គ្រោះថ្នាក់ នៅទីតាំងបង្កើតសំណល់គ្រោះថ្នាក់ និងទីតាំងសេវាសំណល់គ្រោះថ្នាក់ដែលតម្រូវឱ្យមានការបំពាក់ ស្របតាមវិធានសុវត្ថិភាពបរិស្ថាននៃគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតបញ្ចេញ ឬដំណើរការសេវាសំណល់គ្រោះថ្នាក់ ។

**មាត្រា៨១៣** ._ អធិការកិច្ចសំណល់គ្រោះថ្នាក់

ក្នុងករណីមានសេចក្តីរាយការណ៍ ឬបណ្តឹងពីការលួចបញ្ចេញចោលសំណល់គ្រោះថ្នាក់ ឬដំណើរការសេវាសំណល់គ្រោះថ្នាក់បង្កឱ្យមានផលប៉ះពាល់បរិស្ថាន សុខភាពមនុស្ស សត្វ ឬបង្កការខូចខាតទ្រព្យសម្បត្តិ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានការសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ អនុលោមតាមនីតិវិធីអធិការកិច្ចការបំពុលបរិស្ថាន ដូចមានចែងនៅក្នុងក្រមនេះ ។

ក្នុងករណីមានការរកឃើញថា ភាពបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថាន សុខភាពសាធារណៈ ឬទ្រព្យសម្បត្តិ បណ្តាលពីការលួចបញ្ចេញចោលសំណល់គ្រោះថ្នាក់ និងការទុកដាក់ ឬដំណើរការសេវាសំណល់គ្រោះថ្នាក់ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចេញលិខិតជាលាយលក្ខណ៍អក្សរ ផ្អាកសកម្មភាពលួចបញ្ចេញ ឬសកម្មភាពផលិតកម្ម សេវាកម្ម ដែលមានការពាក់ព័ន្ធនឹងការបង្កឱ្យមានគ្រោះថ្នាក់នោះ ជាបន្ទាន់ និងត្រូវចាត់ការតាមនីតិវិធីច្បាប់ជាបន្ត ។

## មាតិកាទី៥
## ការត្រួតពិនិត្យការបំពុលទឹក
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៨១៤ .**_ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើសកម្មភាពពាក់ព័ន្ធការបញ្ចេញសំណល់រាវ ទឹកកខ្វក់ ឬសារធាតុបំពុលពីប្រភពជាក់លាក់ និងប្រភពមិនជាក់លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈ ។

**មាត្រា៨១៥ .**_ សមត្ថកិច្ចត្រួតពិនិត្យការបំពុលទឹកពីប្រភពជាក់លាក់ និងមិនជាក់លាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យការបំពុលទឹកពីប្រភពជាក់លាក់ និងប្រភពមិនជាក់លាក់ ។

**មាត្រា៨១៦ .**_ លិខិតបទដ្ឋានគតិយុត្តបំពុលទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ជំរុញការអនុវត្តបទប្បញ្ញត្តិត្រួតពិនិត្យការបំពុលទឹកនៃមាតិកានេះ និងសម្រាប់ដាក់បញ្ញត្តិលើសកម្មភាពបង្កឱ្យមានការបំពុលទឹក ។

**មាត្រា៨១៧ .**_ ការហាមឃាត់

ហាមឃាត់ជាដាច់ខាតចំពោះសកម្មភាពបោះចោល ចាក់ចោល ឬបញ្ចេញចោលសំណល់គ្រប់ប្រភេទ ឬសារធាតុបំពុល ដែលនាំឱ្យមានការបំពុលទឹកនៃតំបន់ទឹកសាធារណៈលើដី ឬក្រោមដី ។

**មាត្រា៨១៨ .**_ ការទទួលខុសត្រូវចំពោះការខូចខាត

បុគ្គលដែលបញ្ចេញសំណល់រាវ ឬសារធាតុបំពុលពីប្រភពជាក់លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈលើដីឬក្រោមដី ឬធ្វើសកម្មភាពប្រើប្រាស់ដីដែលបង្កឱ្យមានការបំពុលទឹកពីប្រភពមិនជាក់លាក់ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

## ជំពូកទី២
## ការគ្រប់គ្រងការបំពុលទឹកតំបន់ទឹកសាធារណៈ

**មាត្រា៨១៩ ._** ផែនការយុទ្ធសាស្ត្រគ្រប់គ្រងការបំពុលទឹកតំបន់ទឹកសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងការបំពុលទឹកតំបន់ទឹកសាធារណៈ និងផែនការសកម្មភាពទប់ស្កាត់ ឬស្តារការបំពុលទឹកតំបន់ទឹកសាធារណៈ ។

**មាត្រា៨២០ ._** ការចាត់ថ្នាក់តំបន់ទឹកសាធារណៈ និងស្តង់ដារគុណភាពទឹកតំបន់ទឹកសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើចំណាត់ថ្នាក់តំបន់ទឹកសាធារណៈ និងបង្កើតស្តង់ដារគុណភាពទឹកនៃតំបន់ទឹកសាធារណៈទាំងនោះ សម្រាប់ការពារជីវៈចម្រុះ និងសុខភាពសាធារណៈ ។

**មាត្រា៨២១ ._** ការតាមដាន និងត្រួតពិនិត្យគុណភាពទឹកតំបន់ទឹកសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការតាមដាន និងត្រួតពិនិត្យគុណភាពទឹកនៃតំបន់ទឹកសាធារណៈឱ្យបានជាប់ជាប្រចាំ ដើម្បីធានាការចាត់វិធានការការពារ និងការស្តារគុណភាពទឹកនៃតំបន់ទឹកសាធារណៈ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំរបាយការណ៍វាយតម្លៃអំពីស្ថានភាពគុណភាពទឹកនៃតំបន់ទឹកសាធារណៈ រៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង ។

**មាត្រា៨២២ ._** ការចាត់វិធានការករណីការបំពុលទឹកសាធារណៈ

ក្នុងករណីស្ថានភាពគុណភាពទឹក ឬសមត្ថភាពស្វ័យសម្អាតនៃតំបន់ទឹកសាធារណៈ មានការថយចុះ ដែលអាចបង្កការបំពុលទឹកធ្ងន់ធ្ងរ ឬការប៉ះពាល់ដល់សុខភាពសាធារណៈ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវ ៖

១- សហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ក្នុងការកំណត់ ឬបង្កើនវិធានការទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈ និងស្តារគុណភាពទឹកតំបន់ទឹកសាធារណៈ ។

២- ពិនិត្យការបង្កើតស្តង់ដារបញ្ចេញសំណល់រាវ ឬទឹកកខ្វក់ដោយឡែក សម្រាប់អនុវត្តចំពោះតំបន់ទឹកសាធារណៈនោះ ។

## ជំពូកទី៣
## ការត្រួតពិនិត្យការបំពុលទឹកពីប្រភពជាក់លាក់

**មាត្រា៨២៣ .**_ ការហាមឃាត់ការបញ្ចេញសារធាតុបំពុលពីប្រភពជាក់លាក់

ហាមឃាត់ជាដាច់ខាត ចំពោះការបញ្ចេញសំណល់រាវ ឬសារធាតុបំពុលពីប្រភពជាក់លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈលើដី ឬក្រោមដី លើកលែងតែមានការអនុញ្ញាត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៨២៤ .**_ ការទទួលខុសត្រូវរបស់ម្ចាស់ប្រភពជាក់លាក់

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពជាក់លាក់ ត្រូវទទួលខុសត្រូវអនុវត្តការគ្រប់គ្រង និងការធ្វើប្រព្រឹត្តកម្មសំណល់រាវរបស់ខ្លួន មុនពេលបញ្ចេញចូលទៅក្នុងតំបន់ទឹកសាធារណៈ និងត្រូវទទួលខុសត្រូវលើសកម្មភាព ដូចខាងក្រោម ៖

១- បំពាក់ និងដំណើរការបរិក្ខារប្រព្រឹត្តកម្មសំណល់រាវ ដើម្បីឱ្យឆ្លើយតបនឹងស្តង់ដារបញ្ចេញ ។

២- អនុវត្តវិធានការស្វ័យត្រួតពិនិត្យ និងស្វ័យរាយការណ៍លើការបញ្ចេញសំណល់រាវ ។

៣- រៀបចំឱ្យមានផ្នែកបុគ្គលជំនាញវិជ្ជាជីវៈ សម្រាប់ប្រតិបត្តិការបរិក្ខារប្រព្រឹត្តកម្មសំណល់រាវ របស់ខ្លួន ។

**មាត្រា៨២៥ .**_ លិខិតអនុញ្ញាតក្នុងការបញ្ចេញចោល

ការបញ្ចេញសំណល់រាវ ឬសារធាតុបំពុលពីប្រភពជាក់លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈលើដី ឬក្រោមដី ត្រូវទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់លក្ខខណ្ឌតម្រូវអនុវត្ត ក្នុងលិខិតអនុញ្ញាតបញ្ចេញសំណល់រាវ ដើម្បីការពារគុណភាពទឹកនៃតំបន់ទឹកសាធារណៈ និងធានាថា

ប្រព័ន្ធអេកូឡូស៊ីនៅផ្នែកខាងក្រោមខ្សែទឹកនៃតំបន់ទឹកសាធារណៈ មិនទទួលរងផលប៉ះពាល់ពីការបញ្ចេញចោលសំណល់រាវ ឬសារធាតុបំពុល ។

នីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាត និងសុពលភាព ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៨២៦ .**_ លក្ខខណ្ឌតម្រូវក្នុងការជូនដំណឹង

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពជាក់លាក់ ដែលបានទទួលលិខិតអនុញ្ញាតបញ្ចេញសំណល់រាវ ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្នុងករណីមាន ៖

១- ការរំលោភបំពានទៅលើលក្ខខណ្ឌតម្រូវអនុវត្តនៃលិខិតអនុញ្ញាត ។

២- បញ្ហាជាមួយឧបករណ៍ស្វ័យតាមដានគុណភាពសំណល់រាវដែលបញ្ចេញ ។

៣- ដំណើរការមិនប្រក្រតីនៃបរិក្ខារប្រព្រឹត្តកម្មសំណល់រាវ ។

**មាត្រា៨២៧ .**_ ការធានាការអនុវត្តលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាត

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពជាក់លាក់ ដែលបានទទួលលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធានាថាការជ្រើសរើសសំណាកយកមកវិភាគ និងការអនុវត្តស្វ័យអង្កេតតាមដានការបញ្ចេញសំណល់រាវ បានធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវអនុវត្តនៃលិខិតអនុញ្ញាត ។

**មាត្រា៨២៨ .**_ ការចេញបទបញ្ជាតម្រូវធ្វើការអង្កេតតាមដានការបញ្ចេញ និងការផ្តល់របាយការណ៍

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចចេញបទបញ្ជាតម្រូវឱ្យប្រតិបត្តិករនៃប្រភពជាក់លាក់ ធ្វើការអង្កេតតាមដាន និងផ្តល់របាយការណ៍ពីការបញ្ចេញចោលសំណល់រាវ ។

**មាត្រា៨២៩ .**_ ការវិភាគសំណាកនៃការអង្កេតតាមដាន

សំណាកនៃការអង្កេតតាមដានទាំងអស់ ត្រូវវិភាគដោយមន្ទីរពិសោធន៍របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬមន្ទីរពិសោធន៍ផ្សេងទៀត ដែលមានការទទួលស្គាល់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពជាក់លាក់ ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាវិភាគសំណាកនៃការអង្កេតតាមដានរបស់ខ្លួន ។

**មាត្រា៨៣០** ._ វិធានការលុបបំបាត់ការបំពុល

ក្នុងករណីដែលការបញ្ចេញសំណល់រាវពីប្រភពជាក់លាក់ បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ផលិតកម្មកសិកម្ម ឬជលផល ឬសុវត្ថិភាពទឹកផឹកសាធារណៈ ម្ចាស់ ឬប្រតិបត្តិករប្រភពជាក់លាក់ ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ ឬផលប៉ះពាល់ និងត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិជាបន្ទាន់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្នុងករណីការបំពុលធ្ងន់ធ្ងរ ត្រូវបញ្ជាឱ្យផ្អាកផ្នែកខ្លះ ឬផ្អាកទាំងស្រុងនៃកិច្ចដំណើរការរបស់ប្រភពជាក់លាក់ ដែលទាក់ទងនឹងការបង្កឱ្យមានការបំពុលបរិស្ថាន ។

**មាត្រា៨៣១** ._ ការលើកទឹកចិត្តការប្រើប្រាស់ទឹកឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការលើកទឹកចិត្តដល់ម្ចាស់ ឬប្រតិបត្តិករប្រភពជាក់លាក់ ដែលបានអនុវត្តការប្រើប្រាស់ទឹកសំណល់ក្រោយការធ្វើប្រព្រឹត្តកម្មរួចតាមរយៈការផ្តល់វិញ្ញាបនបត្រប្រតិបត្តិករបរិស្ថានបៃតង និងគ្រឿងលើកទឹកចិត្តផ្សេងៗ ។

**មាត្រា៨៣២** ._ ការគ្រប់គ្រងសំណល់ភក់ពីអាងប្រព្រឹត្តកម្ម

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលខុសត្រូវគ្រប់គ្រងដំណើរការអាងប្រព្រឹត្តកម្មសំណល់រាវ ឬទឹកកខ្វក់ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ភក់ដែលកើតចេញពីដំណើរការប្រព្រឹត្តកម្មសំណល់រាវ ឬទឹកកខ្វក់ ស្របតាមបទប្បញ្ញត្តិគ្រប់គ្រងសំណល់គ្រោះថ្នាក់នៃក្រមនេះ ។

## ជំពូកទី៤
## ការត្រួតពិនិត្យប្រភពមិនជាក់លាក់

**មាត្រា៨៣៣** ._ ផែនការសកម្មភាពសម្រាប់ទប់ស្កាត់ការបំពុលទឹកពីប្រភពមិនជាក់លាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវរៀបចំផែនការសកម្មភាពបង្ការ និងទប់ស្កាត់ការបំពុលទឹកពីប្រភពមិនជាក់លាក់ ។

**មាត្រា៨៣៤ ._** ការចាត់វិធានការឆ្លើយតបការបំពុលទឹកពីប្រភពមិនជាក់លាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីកើតមានការបំពុលទឹកពីប្រភពមិនជាក់លាក់ ត្រូវចាត់វិធានការឆ្លើយតបជាក់ស្តែងជាបន្ទាន់ សម្រាប់ការកាត់បន្ថយ ឬការស្តារការបំពុលទឹកពីប្រភពមិនជាក់លាក់ ។

**មាត្រា៨៣៥ ._** គោលការណ៍ណែនាំបច្ចេកទេសពីកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរលើការគ្រប់គ្រងការបំពុលទឹកពីប្រភពមិនជាក់លាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេសពីកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរលើការគ្រប់គ្រងការបំពុលទឹកពីប្រភពមិនជាក់លាក់ ។

**មាត្រា៨៣៦ ._** លក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតចំពោះគម្រោង ឬសកម្មភាព

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដល់គម្រោង ឬសកម្មភាព ដែលពាក់ព័ន្ធ ឬអាចបង្កឱ្យមានការបំពុលទឹកពីប្រភពមិនជាក់លាក់ ត្រូវពិនិត្យនិងដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតគម្រោង ឬសកម្មភាព ឱ្យមានការអនុវត្តកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរលើការគ្រប់គ្រងការបំពុលទឹកពីប្រភពមិនជាក់លាក់ ។

**មាត្រា៨៣៧ ._** កាតព្វកិច្ចអនុវត្តកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ

បុគ្គលគ្រប់រូបដែលមានសកម្មភាពពាក់ព័ន្ធនឹងការប្រើប្រាស់ដី ឬការបង្កឱ្យមានការសាយភាយសារធាតុបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈពីប្រភពមិនជាក់លាក់ ត្រូវមានកាតព្វកិច្ចអនុវត្តកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ ក្នុងការទប់ស្កាត់ការបំពុលទឹកពីសកម្មភាពគម្រោង ឬអាជីវកម្មរបស់ខ្លួន ។

## ជំពូកទី៦
## ការត្រួតពិនិត្យការបំពុលសមុទ្រ

**មាត្រា៨៣៨ ._** ស្ថាប័នទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវការត្រួតពិនិត្យការបំពុលសមុទ្រ និងមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

១- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការបង្ការ ការទប់ស្កាត់ និងការកាត់បន្ថយការបំពុលសមុទ្រ ។

២- អនុវត្តការត្រួតពិនិត្យការបំពុលសមុទ្រ តាមរយៈការចុះយកសំណាកទឹកសមុទ្រ និងត្រួតពិនិត្យសកម្មភាពបំពុលនៅតាមគោលដៅលើដីគោក ដែនកោះ និងនាវា ។

៣- សម្របសម្រួលការរៀបចំ និងការអនុវត្តផែនការឆ្លើយតបបន្ទាន់ក្នុងករណីកើតមានការបំពុលសមុទ្រ ។

៤- អនុវត្តការអប់រំផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងដល់សាធារណជនពីផែនការ និងវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលសមុទ្រ ។

**មាត្រា៨៣៩** ._ ការសហការស្ថាប័ន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវសហការជាមួយក្រសួង ស្ថាប័ន និងយន្តការពាក់ព័ន្ធ ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងផែនការឆ្លើយតបបន្ទាន់ទាក់ទងនឹងការបំពុលសមុទ្រពីសកម្មភាពដឹកជញ្ជូនតាមនាវា អាជីវកម្មប្រេង ឬរ៉ែបាតសមុទ្រ និងការដោះស្រាយបញ្ហាបំពុលបរិស្ថានសមុទ្រឆ្លងដែន ។

**មាត្រា៨៤០** ._ ការហាមឃាត់ការប្រើប្រាស់សារធាតុគីមីពុល

ហាមឃាត់ជាដាច់ខាតចំពោះការប្រើប្រាស់សារធាតុពុល ឬសារធាតុគ្រោះថ្នាក់ ដែលបង្កឱ្យមានហានិភ័យដល់ជីវៈចម្រុះសមុទ្រ ។

**មាត្រា៨៤១** ._ ការហាមឃាត់ការបញ្ចេញសំណល់

ហាមឃាត់ជាដាច់ខាតចំពោះការបញ្ចេញសំណល់រឹង រាវ ឬទឹកកខ្វក់ ពីលើដីគោក ដែនកោះ នាវាចូលទៅក្នុងសមុទ្រ ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្មជាមុន ឬមិនមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

រាល់ការបញ្ចេញសំណល់រាវ ឬទឹកកខ្វក់ ពីគម្រោង ឬសកម្មភាពអភិវឌ្ឍន៍នៃដីគោក ដែនកោះ និងដែនសមុទ្រ ត្រូវមានលិខិតអនុញ្ញាតបញ្ចេញចោលសំណល់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៤២** ._ ការទទួលខុសត្រូវរបស់ម្ចាស់នាវា

ម្ចាស់នាវាដឹកជញ្ជូនទំនិញ និងនាវា ឬទូកទេសចរណ៍ ត្រូវទទួលខុសត្រូវក្នុងការបំពាក់ឧបករណ៍សម្រាប់ស្តុកសំណល់ និងឧបករណ៍ការពារសុវត្ថិភាពការកំពប់ ឬការលេចធ្លាយសំណល់ ឬសារធាតុបំពុលចូលទៅក្នុងសមុទ្រ ។

**មាត្រា៨៤៣** ._ ការទទួលខុសត្រូវរបស់ម្ចាស់គម្រោង អាជីវកម្មប្រេង ឬរ៉ែបាតសមុទ្រ

ម្ចាស់គម្រោង អាជីវកម្មប្រេង ឬរ៉ែបាតសមុទ្រ ត្រូវទទួលខុសត្រូវ ៖

១- រៀបចំផែនការឆ្លើយតបបន្ទាន់ សម្រាប់ករណីគ្រោះថ្នាក់កំពប់ លេចធ្លាយ ឬឆេះប្រេង ។

២- សហការ និងផ្តល់ព័ត៌មានបន្ទាន់មកក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងករណីកើតមានឧបទ្ទវហេតុគ្រោះថ្នាក់ ។

៣- ទុកដាក់ និងបញ្ចេញចោលសំណល់រុករក និងអាជីវកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៨៤៤** ._ ការទទួលខុសត្រូវរបស់អាជ្ញាធរកំពង់ផែ

អាជ្ញាធរកំពង់ផែ ដោយសហការជាមួយ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវត្រួតពិនិត្យលើឧបករណ៍បំពាក់សម្រាប់ស្តុកសំណល់ ឧបករណ៍ការពារសុវត្ថិភាព និងការបំពុលចេញពីនាវា ។

**មាត្រា៨៤៥** ._ ការទទួលខុសត្រូវរបស់ម្ចាស់ ឬប្រតិបត្តិករនាវា

ក្នុងករណីដែលមានការសាងសង់ ការជួសជុល ការរុះរើ ឬការលាងសម្អាតកប៉ាល់ ឬនាវា ម្ចាស់ ឬប្រតិបត្តិករនាវា ត្រូវទទួលខុសត្រូវដំឡើងឧបករណ៍សម្រាប់ផ្ទុក ឬប្រមូលសំណល់ប្រេង និងសំណល់ផ្សេងៗ និងធ្វើការសម្អាតសារធាតុបំពុលពីសកម្មភាពអាជីវកម្មរបស់ខ្លួន ។

**មាត្រា៨៤៦ .**_ ការបំពុលសមុទ្រឆ្លងដែន

ក្នុងករណីកើតមានការបំពុលសមុទ្រឆ្លងដែន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងស្ថាប័ន ឬយន្តការពាក់ព័ន្ធ ត្រូវចាត់វិធានការអន្តរាគមន៍ជាបន្ទាន់ អនុលោមតាមផែនការឆ្លើយតបបន្ទាន់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក ។

**មាត្រា៨៤៧ .**_ ការទទួលខុសត្រូវចំពោះសំណងខូចខាតពីការបំពុលសមុទ្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្ថាប័ន និងយន្តការពាក់ព័ន្ធ ត្រូវសហការក្នុងការកំណត់ពីវិសាលភាពនៃការខូចខាត ដែលបណ្ដាលមកពីការបំពុលសមុទ្រ ។

បែបបទ និងនីតិវិធីទូទាត់សំណងនៃការខូចខាតពីការបំពុលសមុទ្រ ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក ។

សំណងការខូចខាតពីការបំពុលសមុទ្រ ត្រូវអនុវត្តការទូទាត់សំណងដោយផ្ទាល់ពីអ្នកធានារ៉ាប់រង ។

## មាតិកាទី៦
## ការត្រួតពិនិត្យការបំពុលខ្យល់
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៨៤៨ .**_ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះប្រភពបំពុលខ្យល់ចល័ត និងអចល័ត ។

**មាត្រា៨៤៩ .**_ ការត្រួតពិនិត្យការបំពុលខ្យល់

ការត្រួតពិនិត្យការបំពុលខ្យល់ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៥០ .**_ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការកំណត់ផែនការសកម្មភាពសម្រាប់អនុវត្តនៅតាមវិស័យ ដើម្បីធានាប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់ ។

**មាត្រា៨៥១** ._ លិខិតបទដ្ឋានគតិយុត្តត្រួតពិនិត្យការបំពុលខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ជំរុញការអនុវត្តបទប្បញ្ញត្តិការត្រួតពិនិត្យការបំពុលខ្យល់នៃមាតិកានេះ និងសម្រាប់ដាក់បញ្ញត្តិលើសកម្មភាពបង្កឱ្យមានការបំពុលខ្យល់ ។

**មាត្រា៨៥២** ._ ការអភិវឌ្ឍបច្ចេកវិទ្យាកាត់បន្ថយ និងទប់ស្កាត់ការបំពុលខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវលើកកម្ពស់ និងគាំទ្រដល់កិច្ចការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា ដើម្បីប្រើប្រាស់ក្នុងការកាត់បន្ថយ និងទប់ស្កាត់ការបំពុលខ្យល់ពីប្រភពចល័ត និងអចល័ត ។

**មាត្រា៨៥៣** ._ ការហាមឃាត់ចំពោះសកម្មភាពបង្កការបំពុលខ្យល់

ហាមឃាត់ជាដាច់ខាតចំពោះរាល់សកម្មភាពទាំងឡាយណាដែលអាចនាំឱ្យឬបង្កឱ្យមានការបំពុលខ្យល់ ។

**មាត្រា៨៥៤** ._ ការទទួលខុសត្រូវលើការខូចខាត

បុគ្គលគ្រប់រូប ដែលបង្កឱ្យមានការបំពុលខ្យល់ពីប្រភពចល័ត ឬអចល័ត ត្រូវទទួលខុសត្រូវលើការខូចខាតចំពោះសុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

## ជំពូកទី២
## ការបំពុលខ្យល់ពីប្រភពចល័ត

**មាត្រា៨៥៥ ._** ការហាមឃាត់ការបញ្ចេញលើសស្តង់ដារបញ្ចេញ

ហាមឃាត់ជាដាច់ខាតចំពោះ ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត ដែលមិនឆ្លើយតបនឹងស្តង់ដារបញ្ចេញ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៨៥៦ ._** វិញ្ញាបនបត្របញ្ជាក់ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូល ឬលក់យានយន្តគ្រប់ប្រភេទ ដែលមានអាយុកាលប្រើប្រាស់លើសពី ៥ (ប្រាំ) ឆ្នាំ ក្រោយកាលបរិច្ឆេទនៃឆ្នាំផលិត ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការបញ្ចេញសារធាតុបំពុលខ្យល់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៥៧ ._** កាតព្វកិច្ចបំពាក់ឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូល ឬផលិតក្នុងស្រុក នូវយានយន្តគ្រប់ប្រភេទ ត្រូវបំពាក់ឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់ ដើម្បីឱ្យការបញ្ចេញសារធាតុបំពុលខ្យល់ឆ្លើយតបនឹងស្តង់ដារ ។

ម្ចាស់យានយន្តគ្រប់ប្រភេទ ត្រូវធ្វើការបំពាក់ និងថែទាំឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់ ដើម្បីឱ្យការបញ្ចេញសារធាតុបំពុលខ្យល់ឆ្លើយតបនឹងស្តង់ដារ ។

**មាត្រា៨៥៨ ._** ការត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់

យានយន្តគ្រប់ប្រភេទដែលម៉ាស៊ីនមានទំហំស៊ីឡាំងចាប់ពី ២៥០ (ពីររយហាសិប) សេសេ ត្រូវមានការត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

## ជំពូកទី៣
## ការបំពុលខ្យល់ពីប្រភពអចល័ត

**មាត្រា៨៥៩ ._** ការហាមឃាត់ចំពោះការបញ្ចេញសារធាតុបំពុលខ្យល់ ឬក្លិនស្អុយពីប្រភពអចល័ត

ហាមឃាត់ជាដាច់ខាតចំពោះការបញ្ចេញ ឬការបំភាយសារធាតុបំពុលខ្យល់ពីប្រភពអចល័តទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងស្តង់ដារបញ្ចេញ ។

ហាមឃាត់ជាដាច់ខាតចំពោះការបង្កើត ឬការបំភាយក្លិនស្អុយ ឬក្លិនអាក្រក់ ដែលរំខានដល់ការរស់នៅ ឬធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ។

**មាត្រា៨៦០ .**_ ការទទួលខុសត្រូវរបស់ម្ចាស់ និងប្រតិបត្តិករចំពោះការបញ្ចេញសារធាតុបំពុលខ្យល់

ម្ចាស់ ឬប្រតិបត្តិករទីតាំងអចលត័ត ត្រូវធ្វើការបំពាក់ និងដំណើរការម៉ាស៊ីន ឬគ្រឿងបរិក្ខារត្រួតពិនិត្យការបំពុលខ្យល់ មុនធ្វើការបញ្ចេញ ឬបំភាយចូលទៅក្នុងបរិយាកាស ដោយអនុលោមតាមការកំណត់របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៦១ .**_ លិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់

ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចលត័ត ត្រូវសុំលិខិតអនុញ្ញាតបញ្ចេញពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិជាមុន ។

នីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់ និងលក្ខខណ្ឌតម្រូវអនុវត្តនៃលិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៨៦២ .**_ កាតព្វកិច្ចក្នុងការធ្វើរបាយការណ៍នៃប្រភពអចលត័ត ដែលកាន់លិខិតអនុញ្ញាត

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចលត័ត ដែលកាន់លិខិតអនុញ្ញាតចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវជូនដំណឹងភ្លាមដល់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្នុងករណីមានបញ្ហាជាមួយឧបករណ៍ត្រួតពិនិត្យការបំពុលខ្យល់ខូចមិនដំណើរការ ឬការកើតមានករណីបញ្ហាការបំពុលខ្យល់បរិយាកាស នៅក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលដែលបញ្ហាទាំងអស់នេះបានកើតឡើង ។

**មាត្រា៨៦៣ .**_ ការខកខានមិនបានបំពេញតាមស្តង់ដារប្រភពបំពុលខ្យល់អចលត័ត

ក្នុងករណីមានការរកឃើញ មានការបញ្ចេញការបំពុលខ្យល់ពីប្រភពអចលត័ត មិនបានបំពេញតាមស្តង់ដារបញ្ចេញ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិត្រូវ ៖

១- ចេញបទបញ្ជាជាលាយលក្ខណ៍អក្សរ ឱ្យម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ធ្វើការកែតម្រូវសកម្មភាពដែលបំពាននោះ នៅក្នុងរយៈពេលមិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃ ។

២- និង/ឬចេញបទបញ្ជាជាលាយលក្ខណ៍អក្សរ ឱ្យម្ចាស់ ឬប្រតិបត្តិករ នៃប្រភពបំពុលខ្យល់អចល័ត បញ្ឈប់សកម្មភាពជាបណ្ដោះអាសន្ន រហូតដល់ពេលមានការកែតម្រូវចំពោះការបំពាន ក្នុងករណីដែលសកម្មភាពបំពាននោះអាចបង្កឱ្យមានការខូចខាតដល់បរិស្ថាន។

**មាត្រា៨៦៤ .**_ ការរក្សាទុក និងការរាយការណ៍ទិន្នន័យតាមដានការបញ្ចេញ

ម្ចាស់ ឬប្រតិបត្តិករទីតាំងអចល័ត ត្រូវរក្សាទុកទិន្នន័យតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ និងត្រូវផ្ដល់ទិន្នន័យមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ជំពូកទី៤

## ការត្រួតពិនិត្យសារធាតុបំពុលខ្យល់ក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល

**មាត្រា៨៦៥ .**_ ស្ថាប័នទទួលខុសត្រូវត្រួតពិនិត្យសារធាតុបំពុលខ្យល់នៅក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល

ការត្រួតពិនិត្យសារធាតុបំពុលនៅក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយត្រូវមានការចូលរួមសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ស្តង់ដារកម្រិតសារធាតុបំពុលខ្យល់នៅក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៦៦ .**_ ការហាមឃាត់

ហាមឃាត់ជាដាច់ខាតចំពោះការនាំចូល ការផលិត ការចែកចាយ និងការប្រើប្រាស់ធ្យូងថ្ម និងឥន្ធនៈផូស៊ីល លើកលែងតែស្របតាមស្តង់ដារកម្រិតសារធាតុបំពុលខ្យល់នៅក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល ។

**មាត្រា៨៦៧ .**_ ព័ត៌មានទាក់ទងការនាំចូល និងកំហាប់សារធាតុបំពុលខ្យល់ក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូលធ្យូងថ្ម និងឥន្ធនៈផូស៊ីល ត្រូវជូនដំណឹងអំពីការនាំចូលមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្របញ្ជាក់ពីកំហាប់សារធាតុបំពុលខ្យល់ដែលមាននៅក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនការនាំចូល ។

## ជំពូកទី៥
## ការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ

**មាត្រា៨៦៨** ._ ស្ថាប័នទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ រួមបញ្ចូលទាំងអគារលំនៅឋាន អគារសាធារណៈ និងកន្លែងការងារក្នុងទីតាំងផលិតកម្ម ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំស្តង់ដារ និងលក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងគុណភាពខ្យល់ក្នុងអគារ ។

**មាត្រា៨៦៩** ._ លក្ខខណ្ឌនៃការអនុម័តគម្រោងសាងសង់

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅក្នុងការអនុម័តគម្រោងស្នើសុំសាងសង់អគារទីតាំងផលិតកម្ម ឬសេវាកម្ម ត្រូវដាក់បញ្ចូលលក្ខខណ្ឌនានា ដើម្បីធានាអនុលោមតាមស្តង់ដារគុណភាពខ្យល់ក្នុងអគារការងារនៃទីតាំងផលិតកម្ម ។

**មាត្រា៨៧០** ._ ការហាមឃាត់ចំពោះការបញ្ចេញ ឬការបំភាយសារធាតុបំពុលខ្យល់ក្នុងអគារ

ត្រូវបានហាមឃាត់ ចំពោះការបញ្ចេញ ឬការបំភាយនូវសារធាតុបំពុលខ្យល់នៅក្នុងអគារដែលលើសស្តង់ដារគុណភាពខ្យល់ក្នុងអគារ ។

**មាត្រា៨៧១** ._ ការទទួលខុសត្រូវរបស់ម្ចាស់ ឬប្រតិបត្តិករ

ម្ចាស់ ឬប្រតិបត្តិករទីតាំង ត្រូវទទួលខុសត្រូវចំពោះការបញ្ចេញ ឬបំភាយសារធាតុបំពុលខ្យល់ ឬក្លិន នៅក្នុងអគារដែលអាចបង្កឱ្យមានផលប៉ះពាល់ចំពោះសុខភាពសាធារណៈ និងបរិស្ថាន ។

ម្ចាស់ ឬប្រតិបត្តិករទីតាំង ត្រូវទទួលខុសត្រូវក្នុងការធានាគុណភាពខ្យល់ក្នុងអគារឱ្យឆ្លើយតបនឹងស្តង់ដារ ។

**មាត្រា៨៧២** ._ លិខិតបញ្ជាក់គុណភាពខ្យល់ក្នុងអគារ

ម្ចាស់ ឬប្រតិបត្តិករទីតាំងអគារផលិតកម្ម ឬអាជីវកម្ម ត្រូវស្នើសុំមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ នូវលិខិតបញ្ជាក់គុណភាពខ្យល់នៅក្នុងអគារ ដើម្បីធានាការការពារសុខភាពសាធារណៈ និងបរិស្ថាន ។

នីតិវិធីសម្រាប់ការសុំលិខិតបញ្ជាក់គុណភាពខ្យល់ក្នុងអគារ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

## ជំពូកទី៦
## ការត្រួតពិនិត្យគុណភាពខ្យល់បរិយាកាស

**មាត្រា៨៧៣** ._ ការអង្កេតតាមដានគុណភាពខ្យល់បរិយាកាស

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការអង្កេតតាមដាន គុណភាពខ្យល់បរិយាកាស ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារគុណភាពខ្យល់បរិយាកាស និងនីតិវិធីសម្រាប់ការអង្កេតតាមដានគុណភាពខ្យល់បរិយាកាស ។

**មាត្រា៨៧៤** ._ ការត្រួតពិនិត្យគុណភាពបរិយាកាសជុំវិញប្រភពបំពុលខ្យល់អចល័ត

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ដែលទទួលបានលិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យគុណភាពខ្យល់បរិយាកាសជុំវិញទីតាំង និងផ្តល់របាយការណ៍ត្រួតពិនិត្យមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមលក្ខខណ្ឌតម្រូវអនុវត្តនៃលិខិតអនុញ្ញាត និងលក្ខខណ្ឌដទៃទៀតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៧៥** ._ ការអង្កេតតាមដានគុណភាពខ្យល់បរិយាកាសតំបន់ងាយទទួលរងការបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតស្ថានីយ៍តាមដានគុណភាពខ្យល់សាធារណៈ និងចុះត្រួតពិនិត្យគុណភាពខ្យល់នៅតំបន់ងាយទទួលរងការបំពុល និងជុំវិញប្រភពឬទីតាំងដែលមានសក្ដានុពលបំពុលខ្យល់បរិយាកាស ។

**មាត្រា៨៧៦** ._ ការបង្កើតសន្ទស្សន៍គុណភាពខ្យល់បរិយាកាសនៅតាមតំបន់សាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំបង្កើតសន្ទស្សន៍គុណភាពខ្យល់បរិយាកាសនៅតាមតំបន់សាធារណៈ ឬតំបន់ងាយទទួលរងការបំពុល ។

**មាត្រា៨៧៧** ._ ការគ្រប់គ្រង និងភាពអាចស្វែងរកបានទិន្នន័យគុណភាពខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរក្សាទុកទិន្នន័យដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការតាមដាន និងត្រួតពិនិត្យគុណភាពខ្យល់បរិយាកាស ដើម្បីប្រើប្រាស់ក្នុងការវាយតម្លៃស្ថានភាពគុណភាពខ្យល់បរិយាកាស ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន នូវព័ត៌មានទាក់ទងនឹងស្ថានភាពនៃគុណភាពខ្យល់បរិយាកាស ។

**មាត្រា៨៧៨** ._ ការជូនដំណឹងជាសាធារណៈអំពីការគំរាមកំហែងដល់បរិស្ថាន

ក្នុងករណីមានការរកឃើញថា មានតំបន់ណាមួយទទួលរងផលប៉ះពាល់ដោយការបំពុលខ្យល់ដែលអាចគំរាមកំហែងដល់សុខភាពសាធារណៈ ឬបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការជូនដំណឹងដល់សាធារណជនអំពីស្ថានភាពនៃការបំពុលខ្យល់ ភាពអាចបង្កគ្រោះថ្នាក់ និងវិធានការបង្ការ ឬការពារសុខភាព និងត្រូវចាត់វិធានការទប់ស្កាត់ការបំពុលខ្យល់ និងស្ដារគុណភាពខ្យល់ឡើងវិញ ។

## ជំពូកទី៧
## ការបំពុលខ្យល់ឆ្លងដែន

**មាត្រា៨៧៩** ._ ការបំពុលខ្យល់ឆ្លងដែន

ក្នុងករណីទទួលបានការជូនដំណឹង ការផ្តល់របាយការណ៍ ឬលទ្ធផលសិក្សាពីការបំពុលខ្យល់ដែលបានបញ្ចេញពីប្រទេសណាមួយ បង្កឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីអនុវត្តដំណើរការការទូត ដើម្បីជូនដំណឹង និងពិគ្រោះយោបល់ជាមួយប្រទេសដែលជាប្រភពនៃការបំពុលខ្យល់នោះ ស្វែងរកមធ្យោបាយក្នុងការកាត់បន្ថយផលប៉ះពាល់នៃសារធាតុបំពុលខ្យល់នោះ ។

**មាត្រា៨៨០** ._ ការបំពុលខ្យល់

ក្នុងករណីកើតមានការបំពុលខ្យល់ឆ្លងដែន ដែលមានប្រភពចេញពីព្រះរាជាណាចក្រកម្ពុជា ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវសហការជាមួយប្រទេសដែលទទួលរងការបំពុលខ្យល់ឆ្លងដែនដែលចេញពីព្រះរាជាណាចក្រកម្ពុជា ដើម្បីស្វែងរកមធ្យោបាយក្នុងការកាត់បន្ថយផលប៉ះពាល់នៃសារធាតុបំពុលខ្យល់ទាំងនោះ ដែលបានបង្កគ្រោះថ្នាក់ដល់បរិស្ថាននៅក្នុងប្រទេសនោះ ។

**មាត្រា៨៨១** ._ សិទ្ធិក្នុងការធ្វើបដិការ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តល់សិទ្ធក្នុងការធ្វើបដិការទាក់ទងនឹងការបំពុលខ្យល់ ដែលមានប្រភពនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានបង្កផលប៉ះពាល់ដល់ប្រទេសដទៃទៀត ដូចគ្នានឹងសិទ្ធិដែលប្រទេសនោះផ្តល់មកឱ្យព្រះរាជាណាចក្រកម្ពុជាដែរ ។

## ជំពូកទី៨
## សារធាតុបំផ្លាញស្រទាប់អូហ្សូន

**មាត្រា៨៨២** ._ ស្ថាប័នទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុក ឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុទាំងនេះ ។

**មាត្រា៨៨៣** ._ លិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីការគ្រប់គ្រង និងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុក ឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុទាំងនេះ ។

**មាត្រា៨៨៤** ._ ការហាមឃាត់

ការនាំចូល ការនាំចេញ និងការផលិតសារធាតុបំផ្លាញស្រទាប់អូហ្សូនដែលបានកំណត់ការលុបបំបាត់ដោយពិធីសារម៉ុងរ៉េអាល់ ត្រូវហាមឃាត់ជាដាច់ខាត ។

**មាត្រា៨៨៥** ._ ការត្រួតពិនិត្យ និងការធ្វើបច្ចុប្បន្នភាពលើលិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្ត ដែលកំណត់អំពីការគ្រប់គ្រងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុក ឬដែលត្រូវគេបង្កើតឡើងដើម្បីប្រើប្រាស់សារធាតុទាំងនេះ ត្រូវធ្វើបច្ចុប្បន្នភាពទៅតាមតម្រូវការចាំបាច់នៃលិខិតុបករណ៍អន្តរជាតិទាក់ទងនឹងកិច្ចការពារស្រទាប់អូហ្សូន និងសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលព្រះរាជាណាចក្រកម្ពុជា ជាសមាជិក ។

## មាតិកាទី៧
## ការត្រួតពិនិត្យសំឡេង និងរំញ័រ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៨៨៦** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះសកម្មភាពដែលបញ្ចេញសំឡេង និងរំញ័រ ។

**មាត្រា៨៨៧** ._ ក្រសួង ស្ថាប័នទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងការបញ្ចេញសំឡេង និងរំញ័រ ។

**មាត្រា៨៨** ._ ការទទួលខុសត្រូវចំពោះការខូចខាត

បុគ្គលគ្រប់រូប ដែលបង្កឱ្យមានការបញ្ចេញសំឡេង ឬរំញ័រ ត្រូវទទួលខុសត្រូវចំពោះការខូចខាតចំពោះសុខភាពមនុស្ស ទ្រព្យសម្បត្តិ និងបរិស្ថាន ។

## ជំពូកទី២
## ការគ្រប់គ្រងសំឡេង និងរំញ័រ

**មាត្រា៨៩** ._ ការរៀបចំស្តង់ដារកម្រិតលើការបញ្ចេញសំឡេង និងរំញ័រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារកម្រិតលើការបញ្ចេញសំឡេង និងរំញ័រ ។

ស្តង់ដារកម្រិតលើការបញ្ចេញសំឡេង និងរំញ័រ ត្រូវចាត់ថ្នាក់ការបញ្ចេញស្របតាមប្រភេទនៃប្រភពចល័ត និងអចល័ត មានជាអាទិ៍ ទីតាំងផលិតកម្ម គ្រឿងចក្រ បរិក្ខារសាងសង់ បរិក្ខារអាជីវកម្មរ៉ែ គ្រឿងម៉ាស៊ីន និងយានយន្ត ឬនាវា ។

ស្តង់ដារកម្រិតលើការបញ្ចេញសំឡេង និងរំញ័រ អាចដាក់បញ្ចូលស្តង់ដារតឹងរ៉ឹងចំពោះកន្លែងធ្វើការ ឬតំបន់សាធារណៈ ដែលអ្នករស់នៅតំបន់នោះងាយទទួលរងផលប៉ះពាល់ដោយសំឡេង និងរំញ័រ មានជាអាទិ៍ លំនៅឋាន សាលារៀន បណ្ណាល័យ មន្ទីរពេទ្យ សណ្ឋាគារ វត្តអារាម និងទីកន្លែងសាសនាផ្សេងទៀត ។

**មាត្រា៨៩០** ._ ការគោរពតាមស្តង់ដារ

ហាមឃាត់ជាដាច់ខាត ចំពោះសកម្មភាពដែលបង្កើតសំឡេង ឬរំញ័រ លើសស្តង់ដារសំឡេង និងរំញ័រ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៨៩១** ._ កាតព្វកិច្ចបំពាក់បរិក្ខារកាត់បន្ថយការបញ្ចេញសំឡេង ឬរំញ័រ

ម្ចាស់ ឬប្រតិបត្តិករទីតាំង ត្រូវទទួលខុសត្រូវក្នុងការបំពាក់គ្រឿងបរិក្ខារសម្រាប់កាត់បន្ថយការបញ្ចេញសំឡេង ឬរំញ័រ ដោយអនុលោមតាមការកំណត់របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៩២ ._** លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន ដើម្បីធានាបានការគោរពតាមស្តង់ដារបញ្ចេញសំឡេង និងរំញ័រ ។

លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន ត្រូវអនុវត្តចំពោះម្ចាស់ទីតាំងប្រភពអចល័ត និងដាក់បញ្ចូលទៅក្នុងលិខិតអនុញ្ញាត ឬការឯកភាពនានា រួមមាន លិខិតអនុញ្ញាតសាងសង់ដែលចេញដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច សម្រាប់សកម្មភាព ឬគម្រោងដែលបង្កឱ្យមានផលប៉ះពាល់ដោយសំឡេង ឬរំញ័រ ។

## មាតិកាទី៨

## ការស្តារឡើងវិញនូវទីតាំងទទួលរងការបំពុល

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា៨៩៣ ._** វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះសកម្មភាពស្តារឡើងវិញនូវផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរនៅទីតាំងទទួលរងការបំពុល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៨៩៤ ._** ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងការស្តារឡើងវិញទីតាំងទទួលរងបំពុល ។

**មាត្រា៨៩៥ ._** ការកំណត់ប្រភេទទីតាំងទទួលរងការបំពុល និងនីតិវិធីនៃការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហកាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីប្រភេទទីតាំងទទួលរងការបំពុល និងនីតិវិធីនៃការស្តារឡើងវិញនូវទីតាំងទទួលរងការបំពុល ដោយត្រូវដាក់បញ្ចូលនីតិវិធីសម្រាប់ ៖

១- កំណត់ការទទួលខុសត្រូវ សម្រាប់ការស្តារទីតាំងបំពុលឡើងវិញ ។

២- កំណត់លក្ខណៈវិនិច្ឆ័យ និងអត្តសញ្ញាណទីតាំងទទួលរងការបំពុលដែលត្រូវស្តារឡើងវិញ ។

៣- ការសិក្សា និងការវាយតម្លៃហានិភ័យ ។

៤- លក្ខខណ្ឌតម្រូវក្នុងការស្តារឡើងវិញ ។

៥- ការកំណត់លក្ខខណ្ឌតម្រូវសម្រាប់កិច្ចព្រមព្រៀងស្តារឡើងវិញចំពោះទីតាំងបំពុល ។

៦- ការកំណត់លក្ខខណ្ឌតម្រូវក្នុងការផ្តល់មូលនិធិក្នុងការអនុវត្តការស្តារឡើងវិញទីតាំងបំពុល ។

៧- ការតម្រូវនៃគុណវុឌ្ឍិនៃទីប្រឹក្សាពិគ្រោះយោបល់ស្តារឡើងវិញទីតាំងទទួលរងការបំពុល ។

៨- ការអង្កេតតាមដានលើការស្តារឡើងវិញទីតាំងទទួលរងការបំពុល ។

៩- ការផ្តល់ការឯកភាពលើការបញ្ចប់ការស្តារឡើងវិញទីតាំងទទួលរងការបំពុល ។

**មាត្រា៨៩៦** ._ ការកំណត់បុគ្គលទទួលខុសត្រូវចំពោះការស្តារទីតាំងទទួលរងការបំពុលឡើងវិញ

ការកំណត់អត្តសញ្ញាណបុគ្គលដែលត្រូវទទួលខុសត្រូវ ចំពោះការស្តារឡើងវិញនូវទីតាំងទទួលរងការបំពុល ត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសំណងការខូចខាត និងការស្តារឡើងវិញចំពោះការខូចខាតបរិស្ថាន នៃក្រមនេះ ។

**មាត្រា៨៩៧** ._ ព័ត៌មានស្តីពីទីតាំងទទួលរងការបំពុល

រាល់ព័ត៌មានពាក់ព័ន្ធនឹងទីតាំងទទួលរងការបំពុល ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៨៩៨** ._ ការរៀបចំបញ្ជីទីតាំងទទួលរងការបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំបញ្ជីទីតាំងទទួលរងការបំពុល ដែលត្រូវដាក់បញ្ចូលនូវទីតាំងទទួលរងការបំពុលទាំងអស់ និងលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការស្តារឡើងវិញ ។

បញ្ជីនៃទីតាំងទទួលរងការបំពុល និងលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការស្តារឡើងវិញ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៨៩៩ ._** គោលការណ៍ណែនាំបច្ចេកទេសស្តីពីការអនុវត្តការស្តារទីតាំងបំពុលឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេសស្តីពីការអនុវត្តការស្តារទីតាំងបំពុលឡើងវិញ ដែលអាចប្រើប្រាស់សម្រាប់ការរៀបចំការស្តារឡើងវិញនូវផលប៉ះពាល់បរិស្ថាននៅទីតាំងទទួលរងការបំពុល ។

## ជំពូកទី២
## ការកំណត់អត្តសញ្ញាណ និងការសិក្សាទីតាំងទទួលរងការបំពុល

**មាត្រា៩០០ ._** កាតព្វកិច្ចជូនដំណឹងពីទីតាំងទទួលរងការបំពុល ឬពីអ្នកបង្កការបំពុល

រូបវន្តបុគ្គល ឬអ្នកដែលបានដឹងអំពីទីតាំងទទួលរងការបំពុល ឬអំពីអ្នកដែលទទួលខុសត្រូវទីតាំងទទួលរងការបំពុល ត្រូវរាយការណ៍ជាបន្ទាន់ទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវជូនដំណឹងទៅក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អំពីការទទួលបានព័ត៌មានអំពីទីតាំងទទួលរងការបំពុល ។

**មាត្រា៩០១ ._** ការសិក្សាទីតាំងទទួលរងការបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសិក្សាទីតាំងទទួលរងការបំពុល និងធ្វើការវាយតម្លៃហានិភ័យ ដើម្បីការពារសុវត្ថិភាពទីតាំងទទួលរងការបំពុល កាត់បន្ថយហានិភ័យដែលកើតឡើងភ្លាមៗ និងវាយតម្លៃផលប៉ះពាល់បរិស្ថាន កំណត់ទំហំនៃការបំពុលដែលត្រូវស្តារឡើងវិញ និងជ្រើសរើសវិធីសាស្ត្រស្តារឡើងវិញដែលសមស្របបំផុត ។

## ជំពូកទី៣
## ការស្តារឡើងវិញ និងការអង្កេតតាមដាន

**មាត្រា៩០២ ._** លក្ខខណ្ឌតម្រូវសម្រាប់ការស្តារឡើងវិញទីតាំងទទួលរងការបំពុល

ការស្តារឡើងវិញនូវផលប៉ះពាល់បរិស្ថាននៅទីតាំងទទួលរងការបំពុល ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវ ដូចខាងក្រោម ៖

១- កាតព្វកិច្ចទូទៅសម្រាប់ត្រួតពិនិត្យការបំពុល ដូចមានចែងក្នុងក្រមនេះ ។

២- ស្តង់ដារបរិស្ថាន ដូចមានចែងក្នុងក្រមនេះ ។

៣- កម្រិតនៃហានិភ័យដែលបានរៀបចំឡើងនៅក្នុងការវាយតម្លៃហានិភ័យ ។

**មាត្រា៩០៣** ._ ការតម្រូវ និងការចុះកិច្ចព្រមព្រៀងក្នុងការស្តារទីតាំងបំពុលឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចតម្រូវឱ្យបុគ្គលបង្កឱ្យមានការបំពុលចុះកិច្ចព្រមព្រៀងស្តារទីតាំងបំពុលឡើងវិញ ដោយមានលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់អនុវត្តការស្តារទីតាំងទទួលរងការបំពុលឡើងវិញ ស្របតាមបទប្បញ្ញត្តិស្តីពីសំណងការខូចខាត និងការស្តារឡើងវិញនូវការខូចខាតបរិស្ថាន នៃក្រមនេះ ។

**មាត្រា៩០៤** ._ ការផ្តល់មូលនិធិសម្រាប់ការស្តារទីតាំងទទួលរងការបំពុលឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់លក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់មូលនិធិ ក្នុងការអនុវត្តការស្តារឡើងវិញនូវទីតាំងទទួលរងការបំពុល ស្របតាមបទប្បញ្ញត្តិស្តីពីសំណងការខូចខាត និងការស្តារឡើងវិញចំពោះការខូចខាតបរិស្ថាន នៃក្រមនេះ ។

**មាត្រា៩០៥** ._ លក្ខខណ្ឌតម្រូវសម្រាប់ទីប្រឹក្សាពិគ្រោះយោបល់ទីតាំងទទួលរងការបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចរៀបចំគុណវុឌ្ឍិជាក់លាក់សម្រាប់ទីប្រឹក្សាពិគ្រោះយោបល់ស្តារឡើងវិញទីតាំងទទួលរងការបំពុល ។

**មាត្រា៩០៦** ._ ការអង្កេតតាមដានការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវធ្វើការអង្កេតតាមដានលើការស្តារឡើងវិញទីតាំងទទួលរងការបំពុល ។

**មាត្រា៩០៧** ._ ការឯកភាពលើការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តល់ការឯកភាពលើការបញ្ចប់ការស្តារឡើងវិញទីតាំងទទួលរងការបំពុល ស្របតាមលក្ខខណ្ឌតម្រូវសម្រាប់ស្តារទីតាំងទទួលរងការបំពុលដូចមានចែងក្នុងក្រមនេះ ។

នីតិវិធីសម្រាប់ផ្តល់ការឯកភាពលើបញ្ចប់ការស្តារឡើងវិញទីតាំងទទួលរងការបំពុល ត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសំណងការខូចខាត និងការស្តារឡើងវិញចំពោះការខូចខាតបរិស្ថាន នៃក្រមនេះ ។

## មាតិកាទី៩
## ប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៩០៨ .**_ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះសារធាតុគីមី សារធាតុបំពុល ឬសំណល់ ដែលបានសាយភាយចូលទៅក្នុងបរិស្ថាន ខ្យល់ ទឹក និងដី ឬដែលបានដឹកជញ្ជូន ឬផ្លាស់ចេញពីទីតាំងណាមួយទៅទីតាំងណាមួយទៀត ។

**មាត្រា៩០៩ .**_ ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល ។

**មាត្រា៩១០ .**_ បញ្ជីនៃសារធាតុបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីបញ្ជីប្រភេទសារធាតុបំពុល នៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលទៅក្នុងបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើបច្ចុប្បន្នភាពលើបញ្ជី នៃសារធាតុបំពុលបរិស្ថាននៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល តាមការចាំបាច់ ។

## ជំពូកទី២
## ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល

**មាត្រា៩១១** ._ ការបង្កើតប្រព័ន្ធទិន្នន័យការសាយភាយ និងបន្លាស់ទីសារធាតុបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំបង្កើតប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលចេញពីទីតាំងផលិតកម្ម ឬអាជីវកម្មចូលទៅក្នុងបរិស្ថាន ។

ការបង្កើតប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៩១២** ._ កាតព្វកិច្ចផ្តល់របាយការណ៍ពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល

ទីតាំងផលិតកម្ម ឬអាជីវកម្មដែលសកម្មភាពអាចបង្កឱ្យមានការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលចូលទៅក្នុងបរិស្ថាន ត្រូវអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍អំពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល មកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ប្រភេទទីតាំងផលិតកម្ម ឬអាជីវកម្ម កម្រិតលក្ខខណ្ឌនានាសម្រាប់កំណត់ពីប្រតិបត្តិករទីតាំងទាំងឡាយ ដែលជាប់កាតព្វកិច្ចផ្តល់ទិន្នន័យរបាយការណ៍ពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលចូលក្នុងបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩១៣** ._ សិទ្ធិទទួលបានព័ត៌មានពីប្រព័ន្ធទិន្នន័យជាតិពីការសាយភាយ និងការបន្លាស់ទី

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវដាក់ឱ្យសាធារណជនអាចចូលមើល ឬទាញយកទិន្នន័យព័ត៌មានពីប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល ដោយមិនមានការបង់ថ្លៃ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាន នៃក្រមនេះ ។

# មាតិកាទី១០
# បុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថាន
## ជំពូកទោល
## បុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថាន

**មាត្រា៩១៤** ._ ការរៀបចំក្រុមបុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថាន

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ត្រូវរៀបចំក្រុមបុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថានរបស់ទីតាំង ចំនួនពី ២ (ពីរ) ទៅ ៤ (បួន) រូប សម្រាប់ទទួលអនុវត្តការងារគ្រប់គ្រង ប្រព្រឹត្តកម្ម និងការបញ្ចេញសំណល់របស់ទីតាំងផ្ទាល់ ។

**មាត្រា៩១៥** ._ ការចុះបញ្ជីបុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថាន

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ត្រូវបញ្ជូនបញ្ជីឈ្មោះក្រុមបុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថាន មកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ សម្រាប់ការចុះបញ្ជីបុគ្គលិកវិជ្ជាជីវៈគ្រប់គ្រងការបំពុលបរិស្ថាន ។

**មាត្រា៩១៦** ._ ការបណ្តុះបណ្តាលជំនាញគ្រប់គ្រងការបំពុលបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធការគ្រប់គ្រងសំណល់ និងបច្ចេកទេសប្រព្រឹត្តកម្មសំណល់ ដល់បុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថានរបស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលបានចុះបញ្ជីជាបុគ្គលិកវិជ្ជាជីវៈគ្រប់គ្រងការបំពុលបរិស្ថាន ។

**មាត្រា៩១៧** ._ ការព្យួរ ឬការដកហូតវិញ្ញាបនបត្រគ្រប់គ្រងការបំពុលបរិស្ថាន

ក្នុងករណីមានការរំលោភ ឬប្រព្រឹត្តបទល្មើសបំពុលបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងការបំពុលបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចធ្វើការព្យួរ ឬដកហូតវិញ្ញាបនបត្រវិជ្ជាជីវៈគ្រប់គ្រងការបំពុលបរិស្ថាន ពីបុគ្គលិកជំនាញគ្រប់គ្រងការបំពុលបរិស្ថាននៃទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ។

# គន្ទីទី៧
# ការអប់រំ ការស្រាវជ្រាវ និងការយល់ដឹងអំពីបរិស្ថាន
# មាតិកាគោល
# គោលនយោបាយ និងយុទ្ធសាស្ត្រអប់រំ និងការស្រាវជ្រាវបរិស្ថាន
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ
# ផ្នែកទី១
# វិសាលភាព និងក្រុមគោលដៅ

**មាត្រា៩១៨**._ វិសាលភាព

គន្ទីនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសិក្សា ស្រាវជ្រាវ អប់រំ បណ្តុះបណ្តាល ក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល ដែលមានការពាក់ព័ន្ធក្នុងការផ្តល់ការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវបរិស្ថាន និងការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន និងសកម្មភាពមេត្រីភាពបរិស្ថាន សំដៅឈានទៅសម្រេចបាននូវកម្មវត្ថុលើកកម្ពស់ការអប់រំបរិស្ថាន ដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែទូលំទូលាយអំពីអន្តរទំនាក់ទំនងរវាងបុគ្គលនីមួយៗ សង្គមជាតិ និងបរិស្ថាន ព្រមទាំងលើកកម្ពស់សីលធម៌បរិស្ថាន និងការទទួលខុសត្រូវបរិស្ថានរបស់ជាតិ ក្នុងការថែរក្សាឱ្យបាននូវតុល្យភាពប្រព័ន្ធអេកូឡូស៊ី គោរពនូវតម្លៃជីវិតមនុស្សសត្វ និងលើកកម្ពស់យុត្តិធម៌សង្គម និងបណ្តុះនូវស្មារតីយល់ដឹងពី បរិស្ថានក្នុងចំណោមប្រជាពលរដ្ឋ និងសហគមន៍នានា ដើម្បីឈានទៅសម្រេចបាននូវការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៩១៩**._ ក្រុមគោលដៅ

ក្រុមគោលដៅនៃការអប់រំបរិស្ថានសំដៅ ដល់ប្រជាពលរដ្ឋគ្រប់រូប គ្រប់កម្រិត សហគ្រិននានា ស្ថាប័នរដ្ឋ និងគ្រប់គ្រឹះស្ថានសិក្សាទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

# ផ្នែកទី២
# គោលនយោបាយអប់រំបរិស្ថាន

**មាត្រា៩២០ ._** គោលនយោបាយអប់រំបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំគោលនយោបាយអប់រំបរិស្ថានថ្នាក់ជាតិ សម្រាប់បញ្ជ្រាបទៅក្នុងផែនការអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវរបស់គ្រឹះស្ថានសិក្សាគ្រប់ភូមិសិក្សា ដើម្បីគាំទ្រដល់កម្មវិធីអប់រំ សិក្សា និងស្រាវជ្រាវអំពីបរិស្ថានសម្រាប់សិស្សានុសិស្ស និស្សិត គរុសិស្ស គ្រូបង្រៀនគ្រប់កម្រិតសិក្សា និងមន្ត្រីរាជការ តាមរយៈសកម្មភាពសិក្សានៅក្នុងថ្នាក់ និងក្រៅថ្នាក់ នៅតាមគ្រឹះស្ថានសិក្សា គ្រឹះស្ថានឧត្តមសិក្សា និងសកម្មភាពសិក្សារៀនសូត្រផ្សេងៗទៀត ព្រមទាំងលើកទឹកចិត្តដល់និស្សិតឧត្តមសិក្សាឱ្យចាប់យកវិជ្ជាជីវៈពាក់ព័ន្ធនឹងបរិស្ថាន ។

គោលនយោបាយអប់រំបរិស្ថានត្រូវពិនិត្យ និងកែសម្រួលឡើងវិញ រៀងរាល់ ១០ (ដប់) ឆ្នាំម្តងយ៉ាងតិច ។

**មាត្រា៩២១ ._** ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំបរិស្ថានថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំបរិស្ថាន ដោយកំណត់នូវក្របខ័ណ្ឌអប់រំបរិស្ថានសម្រាប់បញ្ជ្រាបចំណេះដឹងបរិស្ថាន និងជំនាញគ្រប់គ្រងបរិស្ថាន ដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងការដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងក្រសួង ស្ថាប័នសាមី ។

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផែនការសកម្មភាពអប់រំបរិស្ថានតាមវិស័យ នៅក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ បន្ទាប់ពីក្រមនេះចូលជាធរមាន ។

ផែនការសកម្មភាពអប់រំបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាព យ៉ាងហោចណាស់ ៥ (ប្រាំ) ឆ្នាំ ម្តង ។

**មាត្រា៩២២ ._** ផែនការសកម្មភាពអប់រំ និងផ្សព្វផ្សាយបរិស្ថានតាមវិស័យ និងនៅថ្នាក់ក្រោមជាតិ

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការសកម្មភាពអប់រំ និងផ្សព្វផ្សាយបរិស្ថាន ដោយឆ្លើយតបទៅនឹងវិស័យជំនាញរបស់ស្ថាប័នសាមី និងស្ថានភាពបរិស្ថាន នៅថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវរាយការណ៍ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពការងារប្រចាំឆ្នាំស្ដីពីការងារអប់រំ និងផ្សព្វផ្សាយបរិស្ថានតាមវិស័យជំនាញ ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

## ផ្នែកទី៣
## យន្តការអប់រំបរិស្ថាន

**មាត្រា៩២៣**._ គណៈកម្មាធិការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន

រាជរដ្ឋាភិបាល ត្រូវរៀបចំគណៈកម្មាធិការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថានតាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩២៤**._ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន

គណៈកម្មាធិការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

១- រៀបចំ និងគាំទ្រនូវកម្មវិធីអប់រំ បណ្ដុះបណ្ដាល និងស្រាវជ្រាវបរិស្ថាន និងកិច្ចប្រឹងប្រែងនានា ដោយធ្វើការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានធម្មជាតិ អំពីទំនាក់ទំនងរវាងធម្មជាតិ និងមនុស្ស រួមបញ្ចូលទាំងទិដ្ឋភាពជាសកលនៃការបំពុលបរិស្ថាន ។

២- គាំទ្រដល់ការរៀបចំ និងផ្សព្វផ្សាយនូវគំរូកម្មវិធីសិក្សា ឯកសារអប់រំបរិស្ថាន និងកម្មវិធីបណ្ដុះបណ្ដាលនានាសម្រាប់ថ្នាក់មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងក្រុមដែលមានចំណាប់អារម្មណ៍ផ្សេងទៀត រួមមានអ្នកធ្វើសេចក្ដីសម្រេច និងអ្នករៀបចំគោលនយោបាយ ជាអាទិ៍ ។

៣- សម្របសម្រួល និងធ្វើអភិបាលកិច្ចលើការផ្ដល់កម្មសិក្សា និងកម្មវិធីអាហារូបករណ៍ ។

៤- សម្របសម្រួល និងធ្វើអភិបាលកិច្ចលើការផ្ដល់រង្វាន់លើកទឹកចិត្តស្ដីពីសកម្មភាពសាលាមេត្រីបរិស្ថាន និងសកម្មភាពមេត្រីភាពបរិស្ថាននៅតាមគ្រឹះស្ថានសិក្សាទាំងសាធារណៈ និងឯកជន ។

៥- សម្របសម្រួល និងតម្រង់ទិសការងារអប់រំ និងស្រាវជ្រាវបរិស្ថាន ។

៦- សម្របសម្រួល កៀរគរ និងគ្រប់គ្រងមូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ស្របតាមបទប្បញ្ញត្តិ នៃគន្ថីទី៨ មាតិកាទី២ នៃក្រមនេះ សម្រាប់គាំទ្រដល់បុព្វហេតុការងារអប់រំ និងស្រាវជ្រាវបរិស្ថាន ។

**មាត្រា៩២៥** ._ ការគាំទ្រផ្នែកលិខិតបទដ្ឋានគតិយុត្ត ផ្នែកហិរញ្ញវត្ថុ និងផ្នែកអង្គការចាត់តាំង

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់បរិធានច្បាប់ហិរញ្ញវត្ថុ ការរៀបចំបង្កើតអង្គការចាត់តាំងសម្រាប់ការងារអប់រំ និងស្រាវជ្រាវផ្នែកបរិស្ថាន ។

លិខិតបទដ្ឋានគតិយុត្តទាំងនេះ ត្រូវដាក់បញ្ចូល ៖

១- ការកំណត់វិស័យអាទិភាព ជាក់លាក់ ដោយធ្វើការសហការជាមួយអ្នកពាក់ព័ន្ធ ។

២- ការបង្កើតយន្តការសម្របសម្រួលការអប់រំ និងការបណ្តុះបណ្តាល ស្តីពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព រវាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានអប់រំ ចាប់ពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់ក្រោយឧត្តមសិក្សា ។

៣- ការប្រើប្រាស់បរិធានផ្នែកសេដ្ឋកិច្ច និងអង្គការចាត់តាំង ដើម្បីលើកកម្ពស់ការដោះដូរការអប់រំ និងវិទ្យាសាស្ត្រជាអន្តរជាតិ និងកម្មវិធីអន្តរជាតិនានា សម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកវិទ្យាបរិស្ថាន ។

៤- និងការបង្កើតធនធានព័ត៌មាន ដើម្បីគាំទ្រលើការអប់រំបរិស្ថាន ។

## ជំពូកទី២
## ការអប់រំ និងការស្រាវជ្រាវបរិស្ថាន
### ផ្នែកទី១
### កម្មវិធីអប់រំ និងបណ្តុះបណ្តាលបរិស្ថាន

**មាត្រា៩២៦** ._ កម្មវិធីអប់រំ និងបណ្តុះបណ្តាលបរិស្ថាន

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដែលមានគ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទ ត្រូវបញ្ចូលកម្មវិធីអប់រំ និងបណ្តុះបណ្តាលបរិស្ថាន ទៅក្នុងកម្មវិធីសិក្សាគោល ឬកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈ នៅតាមអង្គភាពសាមីរបស់ខ្លួន ។

**មាត្រា៩២៧** ._ ការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងគរុសិស្ស

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងគរុសិស្ស ដោយផ្អែកលើបសិដ្ឋកម្មផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសវិទ្យានៃចំណេះដឹងដែលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៩២៨** ._ ការបណ្តុះបណ្តាលចំណេះដឹងបរិស្ថានទូទៅ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំផែនការបណ្តុះបណ្តាលចំណេះដឹងបរិស្ថានទូទៅ ដើម្បីធានាថា ខ្លឹមសារ វិធីសាស្ត្រ និងសម្ភារដែលទាក់ទងនឹងចំណេះដឹង និងជំនាញស្តីពីការអភិវឌ្ឍដោយចីរភាពត្រូវបានដាក់បញ្ចូលទៅក្នុងការបង្រៀន ការបណ្តុះបណ្តាល និងដំណើរការនៃការរៀន ឬសិក្សាផ្សេងៗទៀត របស់អង្គភាពក្រោមឱវាទរបស់ខ្លួន ។

**មាត្រា៩២៩** ._ ការកសាងសមត្ថភាពបរិស្ថានដល់មន្ត្រីជំនាញ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំផែនការនិងកម្មវិធីបណ្តុះបណ្តាលចំណេះដឹងបរិស្ថានជាក់លាក់ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាពសម្រាប់មន្ត្រីជំនាញក្រោមឱវាទរបស់ខ្លួន ។

**មាត្រា៩៣០** ._ ការរៀបចំសម្ភារបណ្តុះបណ្តាល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំសម្ភារបណ្តុះបណ្តាល និងកម្មវិធីសិក្សាស្តីពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៩៣១** ._ ការកំណត់អត្តសញ្ញាណទំហំតម្រូវការ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវកំណត់ទំហំតម្រូវការ ដើម្បីផ្តល់ឱកាសចំពោះការអប់រំ និងការបណ្តុះបណ្តាលស្តីពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាពដល់សហគមន៍មូលដ្ឋាន សង្គមស៊ីវិល និងវិស័យឯកជន ។

នីតិបុគ្គល អ្នកគ្រប់គ្រង អ្នកចាត់ការទូទៅ អ្នកតំណាងសហគ្រាសផលិត និងសេវាកកម្មគ្រប់ប្រភេទ ត្រូវទទួលបានការបណ្តុះបណ្តាលផ្នែកបរិស្ថាន ។

## ផ្នែកទី២
## មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថាន

**មាត្រា៩៣២** ._ មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថាន

ក្រសួងទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតមជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថាន ក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ ក្រោយក្រមនេះចូលជាធរមាន ។

មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថានមានការទទួលខុសត្រូវដូចខាងក្រោម ៖

១- សិក្សាស្រាវជ្រាវបរិស្ថានសម្រាប់ការធ្វើផែនការ និងការធ្វើសេចក្តីសម្រេច ។

២- ចងក្រងទិន្នន័យព័ត៌មានវិទ្យាសាស្ត្រផ្នែកបរិស្ថាន ។

៣- អប់រំ បណ្តុះបណ្តាល ស្រាវជ្រាវ និងផ្សព្វផ្សាយបរិស្ថាន ។

៤- ធ្វើជាមណ្ឌលធនធានព័ត៌មានបរិស្ថានសម្រាប់សាធារណជន និងអ្នកសិក្សាអំពីបរិស្ថាន ។

៥- កៀរគរធនធានសម្រាប់សិក្សាស្រាវជ្រាវបរិស្ថាន ។

**មាត្រា៩៣៣** ._ ការបណ្តុះបណ្តាលបុគ្គលិក

មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថាន ត្រូវផ្តល់ការអប់រំ សិក្សាស្រាវជ្រាវ និងការបណ្តុះបណ្តាល ព្រមទាំងផ្តល់ជូនវិញ្ញាបនបត្រវិជ្ជាជីវៈទៅកាន់មន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នាយកប្រចាំតំបន់ បុគ្គលិកដទៃទៀតនិងឧទ្យានុរក្សដែលបានទទួលការបណ្តុះបណ្តាលពីមជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថាន ។

**មាត្រា៩៣៤**._ ការកសាងសមត្ថភាពសម្រាប់បុគ្គលិកក្រសួង ស្ថាប័ន មានសមត្ថកិច្ច

មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថាន ត្រូវផ្តល់ការកសាង និងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈដល់មន្ត្រីរាជការក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិស្តីពីជំនាញគ្រប់គ្រងបរិស្ថាន និងមុខវិជ្ជាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៩៣៥**._ កម្មវិធីផ្តល់វិញ្ញាបនបត្រ

មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថាន ត្រូវផ្តល់នូវកម្មវិធីបណ្តុះបណ្តាល វិជ្ជាជីវៈបរិស្ថាន និងជំនាញមុខវិជ្ជាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាព ជូនមន្ត្រីរាជរដ្ឋាភិបាល បុគ្គលិករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ គណៈកម្មការគ្រប់គ្រងរួមគ្នា និងសមាជិកសហគមន៍ និងសាធារណជន ព្រមទាំងផ្តល់ជូនវិញ្ញាបនបត្របញ្ជាក់ការសិក្សា ។

មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថានត្រូវផ្តល់ការបណ្តុះបណ្តាលចំណេះដឹងបរិស្ថានដល់បុគ្គលិក កម្មកររោងចក្រ សហគ្រាស និងក្រុមវិជ្ជាជីវៈផ្សេងៗទៀត ព្រមទាំងចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សា ។ ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងសហគ្រាស សិប្បកម្ម ផលិតកម្ម និងឧស្សាហកម្ម ត្រូវទទួលការបណ្តុះបណ្តាលជំនាញគ្រប់គ្រងបរិស្ថានអប្បបរមា តាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៣៦**._ កម្មវិធីដទៃៗទៀត

មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវបរិស្ថាន ត្រូវបង្កើតកម្មវិធីដទៃទៀត ពាក់ព័ន្ធនឹងការស្រាវជ្រាវគោលនយោបាយ ស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទាក់ទងនឹងបរិស្ថាន ការសិក្សាអប់រំ ការដោះស្រាយវិវាទបរិស្ថាន និងការយល់ដឹងដែលចាំបាច់ដទៃទៀត ។

## ផ្នែកទី៣
## ការអប់រំបរិស្ថានក្នុងប្រព័ន្ធអប់រំ

**មាត្រា៩៣៧** ._ តម្រូវការសម្រាប់ចំណេះដឹងបរិស្ថាន និងនិរន្តរភាព

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានានូវការដាក់បញ្ចូល តម្រូវការសម្រាប់ចំណេះដឹងបរិស្ថាន និងនិរន្តរភាពទៅក្នុងលក្ខណៈវិនិច្ឆ័យគុណវុឌ្ឍិគ្រប់គ្រាន់ដែលរួមមាន ការផ្តល់វិញ្ញាបនបត្រ និងការចេញវិញ្ញាបនបត្របញ្ជាក់ឡើងវិញសម្រាប់អ្នកមានវិជ្ជាជីវៈ ក្នុងករណីចាំបាច់ ។

**មាត្រា៩៣៨** ._ សមាហរណកម្មចំណេះដឹងបរិស្ថានទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់សមាហរណកម្មចំណេះដឹងបរិស្ថានពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាព ទៅក្នុងកម្មវិធីសិក្សា អប់រំ ស្រាវជ្រាវ និងបណ្តុះបណ្តាលសម្រាប់អ្នកសិក្សានៅគ្រប់ភូមិសិក្សា រួមមាន ការអប់រំចំណេះទូទៅ ការអប់រំឧត្តមសិក្សា ការអប់រំក្រោយឧត្តមសិក្សា និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជាអាទិ៍ ។

**មាត្រា៩៣៩** ._ អាទិភាពក្នុងការអភិវឌ្ឍ និងភាពរីកចម្រើនផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបៃតង

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាថាការសិក្សា ស្រាវជ្រាវការបណ្តុះបណ្តាល និងការអប់រំពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាព បានឆ្លុះបញ្ចាំងពីអាទិភាពក្នុងការអភិវឌ្ឍ និងភាពរីកចម្រើនផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបៃតង ។

**មាត្រា៩៤០** ._ សម្ភារសិក្សាឧបទេស

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំ និង ធ្វើបច្ចុប្បន្នភាពសម្ភារសិក្សា ឧបទេសដែលបានបោះពុម្ពផ្សាយ មានជាអាទិ៍ ឯកសារសិក្សារៀនសូត្រផ្នែកគរុកោសល្យ ផ្នែកអប់រំ និងវិធីសាស្ត្រ សៀវភៅសិក្សាគោល និង

ឯកសារពាក់ព័ន្ធដទៃទៀត ដែលគាំទ្រដល់ដំណើរការបង្រៀន និងរៀន ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៩៤១** ._ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានានូវការគាំទ្រដល់ការបង្កើតប្រព័ន្ធ គ្រប់គ្រងបរិស្ថាននៅ សាលារៀន គ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានសិក្សាដទៃទៀត ។

**មាត្រា៩៤២** ._ លក្ខណៈវិនិច្ឆ័យគុណវុឌ្ឍិគ្រប់គ្រាន់

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលក្ខណៈវិនិច្ឆ័យគុណវុឌ្ឍិលម្អិត ទាក់ទងនឹងចំណេះដឹង និង ការបណ្ដុះបណ្ដាលអំពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយ និរន្តរភាព និងការអភិវឌ្ឍដោយចីរភាព សម្រាប់អ្នកសិក្សានៅគ្រប់កម្រិតភូមិសិក្សា ។

**មាត្រា៩៤៣** ._ សមត្ថកិច្ច វិធីសាស្ត្រ និងវិធាន

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និង ក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវសហការគ្នារៀបចំ និង គាំទ្របណ្ដាញជាតិ ស្ដីពីសមត្ថកិច្ច វិធីសាស្ត្រ និងវិធាន នៃកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយ និរន្តរភាព និងការអភិវឌ្ឍដោយចីរភាព ។

## ផ្នែកទី៤
## ការស្រាវជ្រាវ និងនវានុវត្តន៍

**មាត្រា៩៤៤** ._ កម្មវិធីអប់រំ និងស្រាវជ្រាវ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្រនូវការបង្កើត និងការអនុវត្តកម្មវិធីអប់រំ និងស្រាវជ្រាវរួមគ្នា ដើម្បីបង្កើតនូវដំណោះស្រាយចំពោះបញ្ហាប្រឈមទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៩៤៥**._ ការធ្វើបច្ចុប្បន្នភាពឯកសារសម្ភារឧបទេសអប់រំ និងបណ្ដុះបណ្ដាល

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ នូវសម្ភារឧបទេសសម្រាប់ការអប់រំ និងបណ្ដុះបណ្ដាល ដោយផ្អែកទៅលើចំណេះដឹងផ្នែកវិទ្យាសាស្ត្រចុងក្រោយបំផុត ។

**មាត្រា៩៤៦**._ ធនធាន និងការគាំទ្រសម្រាប់ការសិក្សា ការស្រាវជ្រាវ និងទស្សនកិច្ចសិក្សា

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្រពាល់ការសិក្សា និងការស្រាវជ្រាវ តាមរយៈការផ្ដល់ធនធាននានាសម្រាប់ការស្រាវជ្រាវ និងឱកាសសម្រាប់ការសិក្សា និងការធ្វើទស្សនកិច្ចសិក្សា ។

**មាត្រា៩៤៧**._ ការអភិវឌ្ឍចំណេះដឹងស្ដីពីគោលដៅអភិវឌ្ឍន៍ដោយចីរភាព

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលនយោបាយ និងផែនការ ដើម្បីធ្វើឱ្យចំណេះ ដឹងអំពីកិច្ចគាំពារបរិស្ថាន និងការប្រើប្រាស់ធនធានដោយនិរន្តរភាព មានសង្គតិភាពជាមួយនឹង ការអភិវឌ្ឍចំណេះដឹង និងជំនាញតាមវិស័យដទៃទៀតដែលពាក់ព័ន្ធទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ព្រះរាជាណាចក្រកម្ពុជា តាមរយៈ ៖

១- ការធានាបាននូវកិច្ចសហការជាមួយអ្នកមានចំណេះដឹងជាលក្ខណៈប្រពៃណី ។

២- ការគាំទ្រចំពោះកិច្ចសហការជាអន្តរវិស័យ ការជំរុញឱ្យមានអន្តរកម្ម រវាងវិទ្យាសាស្ត្រ ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា និងធុរកិច្ច និងការគាំទ្រចំពោះការអភិវឌ្ឍវិស័យបច្ចេកវិទ្យាសមស្របនានា ដែលមានផលប៉ះពាល់អវិជ្ជមានតិចតួចទៅលើបរិស្ថាន ។

៣- ការគាំទ្រចំពោះការអប់រំទៅវិញទៅមករវាងការស្រាវជ្រាវ និងនវានុវត្តន៍ ។

៤- និងការបង្កើតកម្មវិធីស្រាវជ្រាវដែលមានគោលដៅក្នុងការកំណត់អត្តសញ្ញាណដំណោះស្រាយនវានុវត្តន៍ ចំពោះបញ្ហាប្រឈមដែលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយចីរភាព ។

## ជំពូកទី៣
## ការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
### ផ្នែកទី១
### ការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន

**មាត្រា៩៤៨**._ ការយល់ដឹងអំពីបរិស្ថានរបស់ភាគីពាក់ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ទំនាក់ទំនង និងជូនព័ត៌មានដល់ភាគីពាក់ព័ន្ធ ទាក់ទិននឹងការរៀបចំគោលនយោបាយ និង គម្រោងនានា និងដំណើរការក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធផ្សេងៗទៀត ស្តីពីផលអវិជ្ជមាន ដែល អាចកើតមាននៃដំណើរការទាំងនេះទៅលើកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ ធនធានធម្មជាតិដោយនិរន្តរភាព និងការអភិវឌ្ឍដោយនិរន្តរភាព ស្របតាមគន្លឹះទី១ មាតិកាទី៣ នៃ ក្រមនេះ ។

**មាត្រា៩៤៩**._ ផែនការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផែនការ សម្រាប់យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន និងចូលរួម ជាសាធារណៈ ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិ ដោយនិរន្តរភាព និងការអភិវឌ្ឍដោយនិរន្តរភាព ។

**មាត្រា៩៥០**._ ការអប់រំបរិស្ថានក្រៅប្រព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវ រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយចំណេះដឹងបរិស្ថាន តាមគ្រប់មធ្យោបាយ និងរូបភាពដល់ប្រជាសហគមន៍ សមាគម សហជីព និងក្រុមគោលដៅផ្សេងៗទៀតដែលកំពុងប្រតិបត្តិការងារនៅព្រះរាជាណាចក្រ កម្ពុជា ។

**មាត្រា៩៥១**._ ការអប់រំបរិស្ថានឥតប្រព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកធម្មការ និងសាសនា ត្រូវរៀបចំ និងអនុវត្តកម្មវិធីអប់រំលើកកម្ពស់ការយល់ដឹងអំពី បរិស្ថាន ដោយបញ្ជ្រាបបញ្ញត្តិបរិស្ថានទៅក្នុងពិធីកម្មសាសនា និងព្រឹត្តិការណ៍សាសនានានា ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវប្បធម៌ ត្រូវរៀបចំ និងអនុវត្តកម្មវិធីអប់រំលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន ដោយ បញ្ជ្រាបបញ្ញត្តិបរិស្ថានទៅក្នុងភាពយន្ត តន្ត្រីចំរៀង និងទម្រង់នានានៃសិល្បៈបុរាណ និងសម័យ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកព័ត៌មាន និងឃោសនាការ ត្រូវរៀបចំ និងអនុវត្តកម្មវិធីអប់រំលើកកម្ពស់ការយល់ដឹងពីបរិស្ថាន តាមគ្រប់មធ្យោបាយ និងរូបភាព ដោយបញ្ជ្រាបបញ្ញត្តិបរិស្ថានទៅក្នុងការផ្សព្វផ្សាយតាមរលកធាតុអាកាស និងឯកសារបោះពុម្ពផ្សាយ យ៉ាងតិចប្រាំភាគរយនៃកម្មវិធីផ្សាយរបស់អង្គភាព ឬស្ថានីយ៍នីមួយៗ ។

**មាត្រា៩៥២** ._ សកម្មភាពចូលរួមការងារបរិស្ថាន

រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសិក្សា សហគ្រាសផលិត និងសេវាកម្មនានាត្រូវរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយបរិស្ថាន និងសកម្មភាពបរិស្ថាននានា តាមគ្រប់មធ្យោបាយ និងរូបភាព ឱ្យបានជាប្រចាំស្របតាមប្រតិទិនបរិស្ថានប្រចាំឆ្នាំ ។

**មាត្រា៩៥៣** ._ មជ្ឈមណ្ឌលធនធានបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំឱ្យមានមជ្ឈមណ្ឌលធនធានបរិស្ថានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមមានបណ្ណាល័យ សាលពិព័រណ៌ ឧទ្យាន សាលសោតទស្សន៍ និង/ឬសាលពហុមុខងារ សម្រាប់ប្រើប្រាស់ជាប្រយោជន៍ដល់ការសិក្សា ស្រាវជ្រាវ ស្វែងយល់ និងផ្សព្វផ្សាយចំណេះដឹង និងព័ត៌មានបរិស្ថានដល់សាធារណជន ។

## ផ្នែកទី២
## ការលើកទឹកចិត្តដល់សកម្មភាពបរិស្ថាននៅគ្រឹះស្ថានសិក្សា

**មាត្រា៩៥៤** ._ កម្មវិធីសាលាមេត្រីបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀតដែលមានគ្រឹះស្ថានសិក្សាក្រោមឱវាទ ត្រូវជំរុញការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន និងកម្មវិធីសកម្មភាពមេត្រីភាពបរិស្ថានផ្សេងៗទៀត នៅតាមគ្រឹះស្ថានសិក្សាក្រោមឱវាទ ។

**មាត្រា៩៥៥** ._ ការផ្តល់រង្វាន់លើកទឹកចិត្តដល់សកម្មភាពមេត្រីភាពបរិស្ថាននៅគ្រឹះស្ថានសិក្សា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ និង ក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀតដែលមានគ្រឹះស្ថានសិក្សាក្រោមឱវាទ ត្រូវរៀបចំទម្រង់នៃប្រភេទ រង្វាន់លើកទឹកចិត្ត និងផ្តល់រង្វាន់លើកទឹកចិត្តកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដល់គ្រឹះស្ថានសិក្សា គ្រប់ភូមិសិក្សា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តកម្មវិធីអប់រំបរិស្ថាន និងទម្រង់នានានៃសកម្មភាព មេត្រីភាពបរិស្ថាននៅតាមសាលារៀន ។

**មាត្រា៩៥៦** ._ ការផ្តល់រង្វាន់លើកទឹកចិត្តដល់សកម្មភាពបង្រៀន និងសិក្សាអំពីបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និង ក្រសួង ស្ថាប័នពាក់ព័ន្ធដទៃ ទៀតដែលមានគ្រឹះស្ថានសិក្សាក្រោមឱវាទ ត្រូវរៀបចំកម្មវិធីផ្តល់រង្វាន់ ដល់សិស្សានុសិស្សឆ្នើម ដែល បានចូលរួមក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងបរិស្ថានក្នុងតំបន់របស់ខ្លួន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលមានគ្រឹះស្ថានសិក្សាក្រោមឱវាទ ត្រូវរៀបចំកម្មវិធីផ្តល់រង្វាន់ដល់គ្រូបង្រៀនឆ្នើមគ្រប់ភូមិសិក្សា ដែលមានស្នាដៃល្អប្រសើរក្នុងការបង្រៀន និងដឹកនាំសិស្សានុសិស្សធ្វើសកម្មភាពសិក្សាស្រាវជ្រាវ បរិស្ថាន ឬសកម្មភាពការងារបរិស្ថាននៅតាមសាលារៀន និងសហគមន៍ជុំវិញសាលារៀន ។

## ផ្នែកទី៣
## ការលើកទឹកចិត្តសកម្មភាពមេត្រីភាពបរិស្ថាន

**មាត្រា៩៥៧** ._ ការលើកទឹកចិត្ត និងផ្តល់រង្វាន់មេត្រីភាពបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំកម្មវិធីលើកទឹកចិត្ត និង រង្វាន់មេត្រីភាពបរិស្ថាន សម្រាប់សកម្មភាពមេត្រីភាពបរិស្ថាន ។

យន្តការអង្កេតតាមដាន និងវាយតម្លៃសកម្មភាពមេត្រីភាពបរិស្ថាន និងការលើកទឹកចិត្ត និង ផ្តល់រង្វាន់មេត្រីភាពបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុក បរិស្ថាន និងធនធានធម្មជាតិ និងបទប្បញ្ញត្តិអំពីរង្វាន់លើកទឹកចិត្តដល់សកម្មភាពមេត្រីភាពបរិស្ថាន នៃក្រមនេះ ។

**មាត្រា៩៥៨** ._ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវលើកទឹកចិត្តដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានប្រតិបត្តិ ឬបង្ហាញការគាំទ្រដល់ សកម្មភាពមេត្រីភាពបរិស្ថាន និងបានចូលរួមអនុវត្តបច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៩៥៩**._ ការទទួលខុសត្រូវរបស់នីតិបុគ្គលសាធារណៈ និងឯកជន

នីតិបុគ្គលសាធារណៈ និងឯកជន ត្រូវរៀបចំធុរកិច្ចរបស់ខ្លួនឱ្យមានសង្គតិភាពជាមួយមេត្រីភាពបរិស្ថានដើម្បីទទួលបានការលើកទឹកចិត្ត និង ផ្តល់រង្វាន់មេត្រីភាពបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវការផ្នែកបច្ចេកទេស ។

**មាត្រា៩៦០**._ ស្តង់ដារនៃការលើកទឹកចិត្ត និងរង្វាន់មេត្រីភាពបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្តីពីស្តង់ដារនៃការលើកទឹកចិត្ត និងរង្វាន់មេត្រីភាពបរិស្ថាន និងត្រូវកៀរគរធនធាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ហើយរៀបចំប្រភេទរង្វាន់ និងការលើកទឹកចិត្ត ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រតិបត្តិតាមស្តង់ដារនៃការលើកទឹកចិត្ត និងរង្វាន់មេត្រីភាពបរិស្ថាន ។

**មាត្រា៩៦១**._ លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលបានការលើកទឹកចិត្ត និងរង្វាន់មេត្រីភាពបរិស្ថាន

នីតិបុគ្គលសាធារណៈ និងឯកជន ត្រូវរៀបចំសកម្មភាពការងាររបស់ខ្លួនដើម្បីទទួលបានការលើកទឹកចិត្ត និង ផ្តល់រង្វាន់មេត្រីភាពបរិស្ថាន ស្របតាមលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម ៖

១- មានការប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន សម្រាប់ផលិតកម្ម សេវាកម្ម និងការគ្រប់គ្រងសកម្មភាពអាជីវកម្មនានា ។

២- មានការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃផលិតផល សេវាផល និងប្រតិបត្តិផល ដែលទ្រទ្រង់បរិស្ថាន សេដ្ឋកិច្ច និងការលូតលាស់ ។

៣- មានការលើកកម្ពស់ផលប្រយោជន៍សង្គម ធានាបាននូវសន្តិសុខសុវត្ថិភាព សុខុមាលភាព និងផាសុកភាពសង្គម ។

៤- មានការលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ ការការពារប្រព័ន្ធអេកូឡូស៊ី រួមមាន ធនធានទឹក ដី បរិយាកាស និងជីវៈចម្រុះដោយរក្សាបាននូវបរិស្ថាន

ស្អាត កាត់បន្ថយ ឬលុបបំបាត់ការបំពុលបរិស្ថាន កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ចំពោះបរិស្ថាន និងធនធានធម្មជាតិ ។

៥- មានការលើកកម្ពស់ការថែរក្សាទំនៀមទម្លាប់ វប្បធម៌ ប្រពៃណី និងអត្តសញ្ញាណជាតិ ដោយរក្សាសិទ្ធិជាប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច និងអភិរក្សមរតកវប្បធម៌ផ្នែកចំណេះដឹងជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន នៅក្នុងផលិតកម្ម និងសេវាកម្មពាក់ព័ន្ធ ។

## គន្ថីទី៨
## វិធានសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃ និងមូលនិធិផ្នែកបរិស្ថាន
## មាតិកាទី១
## វិធានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ជំពូកទី១
## វិធានសេដ្ឋកិច្ច

**មាត្រា៩៦២ ._** ការវាយតម្លៃលើឱកាស និងយន្តការលើកទឹកចិត្តឱ្យមានការវិនិយោគផ្នែកបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដឹកនាំក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ដើម្បីធ្វើការវាយតម្លៃជាប្រចាំទៅលើឱកាស និងយន្តការលើកទឹកចិត្តឱ្យមានការវិនិយោគ ក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានធម្មជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផែនការ របាយការណ៍ និងលើកសំណើចំពោះវិធានសេដ្ឋកិច្ច ស្របតាមគោលនយោបាយ ជាអាទិភាពរបស់ក្រសួង ស្ថាប័នសាមី និងផ្ញើមកក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន ដើម្បីពិនិត្យ សហការ និងឯកភាព ឬក្នុងករណីចាំបាច់ ត្រូវដាក់ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសម្រេចចំពោះការលើកទឹកចិត្ត និងវិធានទាំងនេះ ។

**មាត្រា៩៦៣ ._** វិធានសេដ្ឋកិច្ចដើម្បីគាំទ្រគោលនយោបាយបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានជំនួយពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ស្ដីពីវិធានសេដ្ឋកិច្ច ក្នុងការគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព កិច្ចគាំពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងស្ដារឡើងវិញនូវធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពិសេសដោយឡែកពាក់ព័ន្ធនឹងពន្ធ និងលទ្ធកម្ម ។

ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវស្របតាមបទដ្ឋានទាំងឡាយដែលទទួលស្គាល់ជាអន្តរជាតិ និងត្រូវរៀបចំឱ្យមានវិធានសេដ្ឋកិច្ច ពាក់ព័ន្ធនឹង ៖

១- ការដាក់បញ្ចូលស្តង់ដារពាក់ព័ន្ធ ការអនុវត្តការងារបរិស្ថាន និងសង្គម និងការគ្រប់គ្រងហានិភ័យ ទៅក្នុងការធ្វើសេចក្ដីសម្រេចរបស់នីតិបុគ្គលពីវិស័យធុរកិច្ច និងហិរញ្ញវត្ថុ ។

២- ការវិនិយោគលើវិស័យឯកជន ពាក់ព័ន្ធនឹងបរិស្ថាន ។

៣- ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការលើកកម្ពស់ការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិ ។

៤- ការផលិតថ្យូង និងអុសដោយនិរន្តរភាព ។

៥- រុក្ខាប្រមាញ់ និងជលផលដោយនិរន្តរភាព ។

៦- ការអភិរក្សទឹកសាប រួមមានការលើកកម្ពស់ការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធផល និងការស្រាវជ្រាវដើម្បីបង្កើនគុណភាពទឹក និងកាត់បន្ថយសំណល់រាវ ។

៧- ការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍ រួមមានការលើកលែងអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀតលើប្រាក់ចំណូល ប្រាក់កម្រៃ ឬប្រាក់រួមវិភាគទានផ្សេងៗ ដែលទទួលបានពីការអនុវត្តការគ្រប់គ្រងរួមគ្នា ។

៨- ការអភិវឌ្ឍ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពលដោយនិរន្តរភាព រួមមានអគ្គិសនីខ្នាតតូច ។

៩- ការលើកកម្ពស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ រួមមានបន្ទះស្រូបពន្លឺព្រះអាទិត្យ អាគុយ និងថ្មពិលប្រើប្រាស់ពន្លឺព្រះអាទិត្យ និងគ្រឿងជំឡើងដទៃទៀត ។

១០- ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធផលដោយឧស្សាហកម្ម រួមមានការប្រើប្រាស់ថាមពលស្អាត ប្រភេទនៃផលិតកម្មដែលមានប្រសិទ្ធផលធនធាន និងមានការបញ្ចេញកាបូនតិច និងការកាត់បន្ថយការបំពុលពីប្រភពឧស្សាហកម្ម និងកសិកម្ម ។

១១- ការប្រើប្រាស់បច្ចេកវិទ្យាបរិស្ថានប្រសើរបំផុតដែលអាចស្វែងរកបាន និងដែលបានផ្ទៀងផ្ទាត់រួច ។

១២- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានាក្នុងគោលបំណងគាំពារបរិស្ថាន ។

១៣- ការបែងចែកដោយសមធម៌ នូវប្រាក់ចំណូលបានមកពីយន្តការទូទាត់ការបញ្ចេញកាបូន ដែលកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

១៤- ការបង់ថ្លៃលើការផលិត ឬការថែទាំសេវាកម្មធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ទៅកាន់រូបវន្តបុគ្គល និងសហគមន៍ ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

១៥- ការលើកកម្ពស់ការនាំចូល និងការទិញយានយន្តមេត្រីបរិស្ថាន និងទប់ស្កាត់ការនាំចូលយានយន្តដែលមានផលប៉ះពាល់ខ្ពស់ដល់បរិស្ថាន ។

១៦- ការលើកកម្ពស់ការប្រើប្រាស់ថាមពលដោយនិរន្តរភាព រួមមានការគាំទ្រដល់ការប្រើប្រាស់ក្នុងធុរកិច្ចនូវប្រភពថាមពលដោយនិរន្តរភាព ធុរកិច្ចដែលធ្វើពាណិជ្ជកម្ម ដំឡើង ឬផ្គត់ផ្គង់ផ្នែកបច្ចេកទេស ឬថែទាំឧបករណ៍ថាមពលដោយនិរន្តរភាព ធុរកិច្ចដែលនាំចូល ផលិត ចែកចាយ ឬលក់ឧបករណ៍ដែលផលិតថាមពលដោយនិរន្តរភាព ឬបង្កើនប្រសិទ្ធផលថាមពលដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងសុខភាព សុវត្ថិភាព និងបរិស្ថាន និងការនាំចូលឧបករណ៍សម្រាប់ផលិតថាមពលដោយនិរន្តរភាព ឬបង្កើនប្រសិទ្ធផលថាមពល ។

១៧- ការអភិរក្ស និងការការពារបេតិកភណ្ឌវប្បធម៌ ។

១៨- ការអភិរក្សថាមពល តាមរយៈការបង្កើនចំហេះ និងប្រសិទ្ធផលនៃការប្រើប្រាស់អគ្គិសនី ការទប់ស្កាត់ការបាត់បង់ថាមពល ការកែច្នៃសំណល់ថាមពល ការជំនួសមកវិញនូវថាមពលកកើតឡើងវិញ និងមធ្យោបាយនានានៃការអភិរក្សថាមពល ដែលបានកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

១៩- វិធានការសេដ្ឋកិច្ចពាក់ព័ន្ធដទៃទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីសម្រេចបានគោលបំណងនៃក្រមនេះ ។

**មាត្រា៩៦៤ .**_ សំណើសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិឯកជន និងសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ផ្ទាល់ ឬដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចចេញលិខិតស្នើសុំចំពោះសំណើសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិឯកជន និងសាធារណៈដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងក្រុមហ៊ុនសហកម្មសិទ្ធិឯកជន និងសាធារណៈ ។

ក្រសួង ស្ថាប័ន ទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចតម្រូវឱ្យអ្នកដាក់សំណើសុំ ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ដាក់បញ្ចូលភស្តុតាងស្តីពីធនធាន និងស្ថានភាពហិរញ្ញវត្ថុ ការសិក្សាទីផ្សារ ការប្រើប្រាស់ផែនការកំណត់ប្រភពដោយនិរន្តរភាព ការបង្ហាញពីការចូលវិភាគទានរបស់គម្រោង ចំពោះការអភិវឌ្ឍដោយចីរភាពដែលធន់ទ្រាំនឹងការបញ្ចេញកាបូនតិច និងសមត្ថភាពក្នុងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដែលកំពុងតែដំណើរការ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តតាមដំណើរការនៃលទ្ធកម្មដូចបានកំណត់នៅក្នុងគោលការណ៍ណែនាំនៃគោលនយោបាយពាក់ព័ន្ធនានា ស្តីពីក្រុមហ៊ុនសហកម្មសិទ្ធិឯកជន និងសាធារណៈ ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ឱ្យមានការដាក់បញ្ចូលអ្នកតំណាងសហគមន៍មូលដ្ឋានមួយរូប ដែលរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មពាក់ព័ន្ធនានា ទៅក្នុងគណៈកម្មការលទ្ធកម្ម នៅពេលអនុវត្តការងារដេញថ្លៃលទ្ធកម្ម ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន នៃក្រមនេះ។

**មាត្រា៩៦៥ .**_ ធនាគារអភិរក្ស ឬធនាគារកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ

ធនាគារជាតិនៃកម្ពុជា និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានជំនួយពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចបង្កើតធនាគារអភិរក្ស ឬធនាគារកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ ។

ព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចចុះកិច្ចព្រមព្រៀងរកស៊ីរួមគ្នា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ធនាគារអភិរក្ស ឬធនាគារ កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ ត្រូវមានសមាសភាគីគ្រប់គ្រងរួមគ្នា ។

## ជំពូកទី២
## ហិរញ្ញវត្ថុ

**មាត្រា៩៦៦**._ ការបង់ថ្លៃរាល់ប្រភេទចំណូល

ការបង់ថ្លៃរាល់ប្រភេទចំណូលទាំងអស់ ដែលមាននៅក្រោមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវបង់ចូលគណនីទោលរតនាគារ ឬធនាគារដៃគូ លើកលែងតែមានការព្រមព្រៀងដោយឡែករ វាងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ ។

**មាត្រា៩៦៧**._ ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំយន្តការសម្រាប់ការកំណត់បង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី ទៅឱ្យរូបវន្តបុគ្គល សហគមន៍ ឬនីតិបុគ្គល ដែលបានចូលរួមចំណែកក្នុងការត្រួតពិនិត្យ ការពារ ឬគ្រប់គ្រងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដោយផ្អែកលើទិន្នន័យ និងស្ថិតិប្រសើរបំផុតដែលអាចស្វែងរកបាន ពាក់ព័ន្ធនឹងស្ថានភាព និងតម្លៃនៃសេវាកម្ម ប្រព័ន្ធអេកូឡូស៊ីដែលបានវាយតម្លៃរួចរាល់ ។

យន្តការរួមគ្នារវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការកំណត់ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ត្រូវផ្អែកលើមូលដ្ឋានសមធម៌ និងសិទ្ធិរបស់សហគមន៍មូលដ្ឋាន ។

**មាត្រា៩៦៨**._ កិច្ចសហប្រតិបត្តិការរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ត្រូវគាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីរៀបចំ អនុវត្ត និងគ្រប់គ្រងយន្តការ ដូចមានចែងក្នុងមាត្រា៩៦៧ នៃក្រមនេះ ។

**មាត្រា៩៦៩**._ ការទទួលបានរបាយការណ៍ជាសាធារណៈ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្សព្វផ្សាយជាប្រចាំ និងដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវរបាយការណ៍ដែលបង្ហាញពីទិន្នន័យ និងស្ថិតិ ដែលបានរៀបចំ ពាក់ព័ន្ធនឹងស្ថានភាព និងតម្លៃនៃបរិស្ថាន និងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

## មាតិកាទី២
## ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាន
### ជំពូកទី១
### ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន

**មាត្រា៩៧០** ._ ការទទួលខុសត្រូវក្នុងការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន

បុគ្គលគ្រប់រូប ត្រូវទទួលបន្ទុកក្នុងការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន និងថ្លៃផ្សេងទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៧១** ._ ការរៀបចំប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានជំនួយពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីចំនួនទឹកប្រាក់ និងនីតិវិធី ការគ្រប់គ្រង និងការលើកលែងការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថានណាមួយ ដែលពាក់ព័ន្ធនឹងក្រមនេះ រួមមាន ៖

១- ការវាយតម្លៃ និងអង្កេតតាមដានបរិស្ថាន ។

២- យន្តការគ្រប់គ្រង និងនិរន្តរភាពបរិស្ថាន ។

៣- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។

៤- ការអភិរក្ស និងគ្រប់គ្រងបេតិភណ្ឌវប្បធម៌ ។

៥- ការគ្រប់គ្រងសំណល់ និងការបំពុល ។

៦- ការអប់រំ និងការយល់ដឹងពីបរិស្ថាន ។

៧- ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

៨- និងវិស័យដទៃទៀតពាក់ព័ន្ធណាមួយ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៧២** ._ ការទទួលខុសត្រូវសម្រាប់ប្រាក់កម្រៃផ្សេងទៀត

បុគ្គលគ្រប់រូប ត្រូវបន្តទទួលបន្ទុកក្នុងការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភទាំងឡាយស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា៩៧៣** ._ ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត អាចតម្រូវឱ្យបុគ្គលគ្រប់រូប ដែលទទួលបន្ទុកបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភ និងថ្លៃផ្សេងទៀត ផ្តល់ការធានាធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការបង់ថ្លៃទាំងនេះ នៅមុនពេលការចេញលិខិតអនុញ្ញាត ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការធានាចំពោះការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភ ។

## ជំពូកទី២
## ការបន្តមូលនិធិបរិស្ថានដែលមានស្រាប់ និងការគ្រប់គ្រងមូលនិធិ
### ផ្នែកទី១
### ការបន្តមូលនិធិបរិស្ថានដែលមានស្រាប់

**មាត្រា៩៧៤** ._ ការបង់មូលនិធិទាយជ្ជទានបរិស្ថាន

បុគ្គលគ្រប់រូប ត្រូវបន្តបង់មូលនិធិទាយជ្ជទានបរិស្ថាន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាននៃក្រមនេះ ។

**មាត្រា៩៧៥** ._ ការបន្តមូលនិធិតំបន់ការពារ

បុគ្គលគ្រប់រូប ត្រូវបន្តបង់មូលនិធិតំបន់ការពារស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និង សិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៃក្រមនេះ ។

**មាត្រា៩៧៦** ._ ការបន្តមូលនិធិបរិស្ថាន និងសង្គម

បុគ្គលគ្រប់រូប ត្រូវបង់មូលនិធិបរិស្ថាន និងសង្គម ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៃក្រមនេះ ។

## ផ្នែកទី២
## មូលនិធិបរិស្ថាន និងសង្គម

**មាត្រា៩៧៧** ._ ប្រភពចំណូលសម្រាប់មូលនិធិបរិស្ថាន និងសង្គម

ប្រភពចំណូលនៃមូលនិធិបរិស្ថាន និងសង្គមបានមកពីប្រភពដូចខាងក្រោម ៖

១- ប្រាក់ដែលបានមកពីការដោះស្រាយបណ្តឹងស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

២- ប្រាក់ដែលទទួលបានពីការអនុវត្តការស្តារបរិស្ថានឡើងវិញ ។

៣- ប្រាក់ដែលទទួលបានពីសំណងការខូចខាតបរិស្ថាន ។

៤- ប្រាក់ដែលទទួលបាន តាមរយៈហិរញ្ញប្បទានជាតិ និងអន្តរជាតិ ។

៥- និងប្រាក់ដែលទទួលបានតាមរយៈអំណោយសប្បុរសធម៌ពីអង្គការ និង សប្បុរសជននានា ។

**មាត្រា៩៧៨** ._ គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម

មូលនិធិបរិស្ថាន និងសង្គម ត្រូវគ្រប់គ្រងដោយគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ដែលបង្កើតឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ត្រូវរៀបចំយុទ្ធសាស្រ្តមួយ ដើម្បីគ្រប់គ្រងមូលនិធិរយៈពេលវែង ។ យុទ្ធសាស្រ្តនេះ ត្រូវដាក់បញ្ចូលការពិចារណាលើវិធីសាស្រ្តលទ្ធកម្ម ការគ្រប់គ្រង

មូលនិធិ ដែលរួមមាន មូលធនកម្ម និងការវិនិយោគ និងវិធានការរដ្ឋបាល វិធានការផ្លូវច្បាប់ និងគោលនយោបាយពាក់ព័ន្ធដទៃទៀត ។

ភារកិច្ច តួនាទី និងសមាសភាព របស់គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ការចំណាយពាក់ព័ន្ធនឹងការបំពេញភារកិច្ច និងតួនាទីរបស់គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាង ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី៣
## ការបង្កើត និងការគ្រប់គ្រងមូលនិធិបរិស្ថាន
### ផ្នែកទី១
### បរធនបាលកិច្ច

**មាត្រា៩៧៩** ._ សិទ្ធិ និងកាតព្វកិច្ចរបស់បរធនបាលទាយក

បរធនបាលទាយក មានសិទ្ធិជាអាទិ៍ ៖

១- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ច ដែលរួមមាន របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធផ្សេងទៀត ។

២- និងតែងតាំង និងបញ្ឈប់បរធនបាល ស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច ។

បរធនបាលទាយក មានកាតព្វកិច្ចជាអាទិ៍ ៖

១- ផ្ទេរបរធន ទៅឱ្យបរធនបាល ។

២- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះការកែប្រែបរធនបាលកិច្ច បរធនបាល អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច ។

៣- និងអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច ។

ក្នុងករណីដែលបរធនបាលទាយកពុំមានលទ្ធភាព ឬសមត្ថភាពជាស្ថាពរក្នុងការអនុវត្ត កាតព្វកិច្ចរបស់ខ្លួន ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបំពេញមុខងារ ជាបរធនបាលទាយកជំនួស ។

**មាត្រា៩៨០** ._ សិទ្ធិរបស់អត្ថគាហក

អត្ថគាហក មានសិទ្ធិជាអាទិ៍ ៖

១- ទទួលអត្ថប្រយោជន៍ ដូចមានចែងក្នុងលិខិតបរធនបាលកិច្ច ។

២- ទាមទារឱ្យបរធនបាលបំពេញកាតព្វកិច្ច ដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច ។

៣- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រង និងចាត់ចែងនៃបរធនបាលកិច្ច ។

៤- និងសិទ្ធិផ្សេងៗទៀត ដែលមានចែងក្នុងលិខិតបរធនបាលកិច្ច ។

ត្រូវសន្មតថា អត្ថគាហកទាំងនេះ ទទួលផលស្មើៗគ្នា ក្នុងករណីដែលគ្មានរបៀប ឬវិធីទទួលផល ដូចមានចែងក្នុងកថាខណ្ឌខាងលើ ។

**មាត្រា៩៨១** ._ សិទ្ធិ និងកាតព្វកិច្ចរបស់បរធនបាល

បរធនបាល មានសិទ្ធិជាអាទិ៍ ៖

១- ទទួលលាភការ ឬកម្រៃនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ច ដែលអាចប្រែប្រួលទៅតាមបទពិសោធការងារ និងគុណវឌ្ឍិវិជ្ជាជីវៈរបស់ខ្លួន ។

២- ស្វែងរកមូលនិធិ និងឱកាសវិនិយោគបន្ថែម ដើម្បីជាប្រយោជន៍របស់បរធនបាល ។

៣- តំណាងឱ្យបរធនបាលទាយក ឬអត្ថគាហកនៅចំពោះមុខច្បាប់ ឬអាជ្ញាធរមានសមត្ថកិច្ច ។

៤- គោរពតាមលក្ខខណ្ឌ ដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិ ជាធរមាន ។

៥- គ្រប់គ្រង និងចាត់ចែងបរធនតាមគោលបំណង និងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច និងដើម្បីជាប្រយោជន៍របស់អត្ថគាហក ។

៦- និងចំណាយក្នុងសកម្មភាពសង្គម ស្របតាមគោលបំណង និងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច ។

បរធនបាល មានកាតព្វកិច្ចជាអាទិ៍ ៖

១- ត្រូវដាក់ពាក្យចុះបញ្ជីបរធន តាមបែបបទ និងនីតិវិធីរបស់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- ត្រូវរាយការណ៍ និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ច ឱ្យបរធនបាលទាយក អត្ថគាហក និងបញ្ញត្តិករពាក់ព័ន្ធ ។

៣- រក្សាកំណត់ហេតុនៃកិច្ចប្រជុំ សម្រាប់ការគ្រប់គ្រងគណនីប្រចាំឆ្នាំ ។

៤- ឆ្លើយតបទៅនឹងបញ្ញត្តិករពាក់ព័ន្ធ ។

៥- បង់ពន្ធគ្រប់ប្រភេទដែលទាក់ទងនឹងទ្រព្យសម្បត្តិបរធនបាលកិច្ច លុះត្រាតែមានការលើកលែងពន្ធដែលកំណត់ដោយច្បាប់ ។

៦- ផ្តល់ផលប្រយោជន៍ ដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ចឱ្យអត្ថគាហក ។

៧- ចាត់វិធានការសមស្របក្នុងករណីរំលោភបំពានលើបរធន ។

៨- និងចុះកិច្ចសន្យាធានារ៉ាប់រងលើការទទួលខុសត្រូវ ក្នុងមុខងារជាបរធនបាល ។

បរធនបាលមិនអាចផ្ទេរមុខងាររបស់ខ្លួន ឱ្យទៅបុគ្គលផ្សេងទៀតបានឡើយ លើកលែងតែក្នុងកាលៈទេសៈដែលបរធនបាលនោះ ទទួលមរណភាព អសមត្ថភាព ឬខកខានក្នុងការបំពេញមុខងាររបស់ខ្លួនជាបរធនបាល ស្របតាមលិខិតបរធនបាលកិច្ច ។

**មាត្រា៩៨២** ._ ការទទួលខុសត្រូវរបស់បរធនបាល

បរធនបាល ត្រូវទទួលខុសត្រូវ ចំពោះសកម្មភាពដូចខាងក្រោម ៖

១- ការធ្វើឱ្យបាត់បង់ និងថយចុះនៃបរធនដោយគ្មានមូលហេតុត្រឹមត្រូវ ។

២- ការប្រើប្រាស់បរធន ខុសពីបំណងបរធនបាលកិច្ច ។

៣- កំហុសដែលបានប្រព្រឹត្តដោយចេតនា ឬអចេតនា ក្នុងការបំពេញការងាររបស់ខ្លួន ។

៤- ការចំណាយណាមួយ ផ្ទុយពីបំណងបរធនបាលកិច្ច ។

៥- បែងចែងឱ្យបានច្បាស់លាស់ រវាងទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិបរធនបាលកិច្ច ។

៦-ចាត់វិធានការសមស្របដើម្បីការពារទ្រព្យសម្បត្តិបរធនបាលកិច្ច និងអត្ថគាហកដោយមានមូលហេតុ ផ្អែកលើចំណេះដឹង ជំនាញ និងបទពិសោធន៍វិជ្ជាជីវៈ ។

៧- បំពេញតួនាទីដោយយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន រក្សាភាពស្មោះត្រង់ និងសុចរិត ថែរក្សា និងប្រុងប្រយ័ត្នដូចការងាររបស់ខ្លួនផ្ទាល់ដែរ ។

៨- ចៀសវាងទំនាស់ផលប្រយោជន៍ដោយផ្ទាល់ និងប្រយោល ដែលនាំឱ្យប៉ះពាល់ ឬខូចខាតដល់ប្រយោជន៍របស់បរធនបាលកិច្ច ។

៩- មិនអាចទទួលយកផលប្រយោជន៍ពីតតិយជនបានឡើយ ក្នុងករណីមានទំនាស់ផលប្រយោជន៍ ។

**មាត្រា៩៨៣** ._ ការគ្រប់គ្រងបរធនបាលកិច្ចបរិស្ថាន

បរធនបាលកិច្ចបរិស្ថាន ត្រូវបានផ្ទេរពីបរធនបាលទាយកទៅកាន់បរធនបាល ដើម្បីធ្វើការគ្រប់គ្រងសម្រាប់ជាផលប្រយោជន៍ដល់អត្ថគាហក ស្របតាមការកំណត់របស់បរធនបាលទាយក ។ បរធនបាលកិច្ចបរិស្ថាន មានជាអាទិ៍ បរធន សម្រាប់ការអភិរក្សសត្វព្រៃ អាកាសធាតុ និងព្រៃឈើ នីតិសម្បទា ការស្តារឡើងវិញ ការគ្រប់គ្រងរួមគ្នា និងទម្រង់ផ្សេងទៀតនៃការបែងចែងផលប្រយោជន៍ផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ច ។

**មាត្រា៩៨៤** ._ ការបង្កើត ការលុបចោល និងគោលបំណងនៃបរធនបាលកិច្ចបរិស្ថាន

បរធនបាលទាយក អាចធ្វើដោយខ្លួនឯង ឬដោយសហការជាមួយសមាគមក្នុងស្រុក ឬសមាគមបរទេស ដើម្បីបង្កើត ឬធ្វើប្រតិបត្តិការបរធនបាលកិច្ច ។

បរធនបរិស្ថាន អាចលុបចោលបាន ស្របតាមលក្ខខណ្ឌដែលបានកំណត់ ។

បរធនបាលកិច្ចបរិស្ថាន ត្រូវប្រើប្រាស់សម្រាប់សកម្មភាពដែលបានកំណត់ជាអាទិភាពនៅក្នុងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងរួមគ្នា និរន្តរភាព និងការអភិរក្ស និងក្នុងគោលបំណង ៖

១- គាំពារ អភិរក្ស និងស្តារឡើងវិញនូវបរិស្ថាន និងធនធានធម្មជាតិ ។

២- ការពារបេតិកភណ្ឌវប្បធម៌ ឬជីវៈចម្រុះ ។

៣- លើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដោយនិរន្តរភាព ។

៤- លើកកម្ពស់ការស្រាវជ្រាវ និងការអប់រំបរិស្ថាន ។

៥- អភិវឌ្ឍសមត្ថភាព ឬពង្រឹងស្ថាប័ន ។

៦- គាំទ្រទៅលើសហគមន៍ដែលរងផលប៉ះពាល់ដោយផ្ទាល់ពីការអភិវឌ្ឍ ។

៧- ឬក្នុងគោលបំណងដើម្បីប្រយោជន៍សាធារណៈ និងសម្រាប់ផលប្រយោជន៍បរិស្ថានណាមួយ ដែលកំណត់ដោយរដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

បរធនបាលកិច្ចបរិស្ថាន ត្រូវបានបង្កើតឡើងស្របតាមនីតិវិធី និងទម្រង់ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវចុះបញ្ជីនៅក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បរធនបាលទាយកដែលមានបំណងបង្កើត ឬធ្វើប្រតិបត្តិការបរធនបាលកិច្ចបរិស្ថាន ត្រូវរៀបចំលិខិតបរធនបាលកិច្ច និងចុះបញ្ជី នៅក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីបរធនបាលកិច្ច ។

**មាត្រា៩៨៥** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយសម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីវិធាន និងនីតិវិធីសម្រាប់ការបង្កើត គ្រប់គ្រង និងត្រួតពិនិត្យបរធនបាលកិច្ចបរិស្ថាន និងគណនីមូលនិធិនេះ ។

**មាត្រា៩៨៦** ._ ការចុះបញ្ជីនៃបរធនបាលកិច្ចបរិស្ថាន

បរធនបាលកិច្ចបរិស្ថានមានសុពលភាព លុះត្រាតែបានចុះបញ្ជីនៅក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើសេចក្តីសម្រេចលើពាក្យស្នើសុំចុះបញ្ជីនេះ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីទទួលបានពាក្យស្នើសុំ ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បដិសេធចំពោះពាក្យស្នើសុំចុះបញ្ជី ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ជាការពន្យល់ជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលបានពាក្យស្នើសុំ ។

**មាត្រា៩៨៧** ._ ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន

ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន អាចបង្កើតមកពី ៖

១- ថវិកាជាតិ ។

២- ជំនួយអភិវឌ្ឍន៍ជាផ្លូវការ ដែលបានផ្តល់ឱ្យដោយអង្គការជាតិ និងអន្តរជាតិ ។
៣- ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ។
៤- សេវាកម្មគ្រប់គ្រងធនធានធម្មជាតិ ។
៥- និងអំណោយផ្ទាល់ពីវិស័យឯកជន និងសប្បុរសជនដទៃទៀត ។

ប្រយោជន៍ទាំងអស់ដែលកើតចេញពីបរធនបាលកិច្ចបរិស្ថាន ត្រូវបង់ចូល និងត្រូវបង្កើតជាផ្នែកនៃបរធនបាលកិច្ចបរិស្ថាន ។

**មាត្រា៩៨៨ ._** ទំនាស់ផលប្រយោជន៍ចំពោះបរធនបាលកិច្ចបរិស្ថាន

ក្នុងអំឡុងពេលបំពេញ តួនាទី និងភារកិច្ចរបស់ខ្លួន បរធនបាលត្រូវរាយការណ៍អំពីទំនាស់ផលប្រយោជន៍ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភស្តុតាង និងហេតុផលគ្រប់គ្រាន់ ដែលអាចជឿជាក់ថា បរធនបាលកំពុងតែប្រព្រឹត្តអំពើដែលមានទំនាស់ផលប្រយោជន៍ចំពោះបរធនបាលកិច្ចបរិស្ថាន ឬកំពុងតែប្រព្រឹត្តផ្ទុយទៅនឹងផលប្រយោជន៍បរិស្ថាន ឬសាធារណៈ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីផ្តួចផ្តើមការស៊ើបអង្កេតទៅលើបញ្ហានេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវព្យួរការទទួលខុសត្រូវរបស់បរធនបាល ក្នុងករណីដែលការស៊ើបអង្កេតរកឃើញថា បរធនបាលមានទំនាស់ផលប្រយោជន៍ ជាមួយនឹងបរធនបាលកិច្ចរបស់ខ្លួន ។ ក្នុងករណីនេះ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងបរធនបាលបណ្តោះអាសន្ន ដោយគោរពតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ និងស្របតាមលិខិតបរធនបាលកិច្ច ។

**មាត្រា៩៨៩ ._** បញ្ជីរបាយការណ៍ប្រចាំឆ្នាំដែលសាធារណជនអាចស្វែងរកបាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរក្សាទុកបញ្ជីរបាយការណ៍ប្រចាំឆ្នាំ នៃគ្រប់បរធនបាលកិច្ចបរិស្ថាន ដែលអាចឱ្យសាធារណជនស្វែងរកបាន ។

**មាត្រា៩៩០ ._** ការប្រើប្រាស់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន

បរធនបាលអាចប្រើប្រាស់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន ដើម្បី ៖

១- ផ្តល់មូលនិធិដល់សកម្មភាព ឬគម្រោងនានា ដែលបំពេញតាមគោលបំណងនៃបរធនបាលកិច្ចបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

២- បង់ថ្លៃលើប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថាន ដែលរួមមានលាភការ របស់បរធនបាល និងថ្លៃចំណាយនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ចបរិស្ថាន ។

៣- ចំណាយទៅលើសកម្មភាពសង្គម ស្របតាមគោលបំណងនៃលិខិតបរធនបាលកិច្ច ។

៤- ធ្វើការបណ្តាក់ទុនលើការវិនិយោគ និងមូលបត្រដែលទទួលខុសត្រូវផ្នែកបរិស្ថាន និង សង្គម ។

**មាត្រា៩៩១** ._ ការបញ្ចប់បរធនបាលកិច្ចបរិស្ថាន

ដោយមានការយល់ព្រម និងអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បរធនបាលកិច្ចបរិស្ថាន ត្រូវបញ្ចប់មុនពេលកំណត់ ក្នុងករណីដូចខាងក្រោម ៖

១- សេចក្តីសម្រេចដោយឆន្ទានុសិទ្ធិ ឬភាគច្រើនដាច់ខាតនៃបរធនបាល ។

២- ការមកដល់នៃកាលវសាន ដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច ។

៣- ឬការរំលោភបំពានធ្ងន់ធ្ងររបស់បរធនបាលទៅលើបរធនបាលកិច្ច ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបាននូវការជូនដំណឹងគ្រប់ដំណាក់កាលទាំងអស់ នៃដំណើរការបញ្ចប់បរធនបាលកិច្ចនេះ ។

**មាត្រា៩៩២** ._ ការត្រួតពិនិត្យបរធនបាលកិច្ចបរិស្ថានដែលត្រូវបានបញ្ចប់

ក្នុងករណីដែលបរធនបាលកិច្ចបរិស្ថានត្រូវបានបញ្ចប់ ដូចមានចែងក្នុងមាត្រា៩៩១ នៃក្រមនេះ បរធនបាលទាយក ត្រូវតែងតាំងបុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ច ដែលមានវិជ្ជាជីវៈ ដើម្បីគ្រប់គ្រង និងវាយតម្លៃបរធននោះ ។ បុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ចនេះ ត្រូវមានការទទួលខុសត្រូវ ដូចខាងក្រោម ៖

១- បំពេញ និងបញ្ចប់កិច្ចការដែលនៅសល់របស់បរធនបាល ។

២- ប្រមូល និងសងបំណុលដែលនៅសល់ ។

៣- និងវាយតម្លៃបរធនដែលសល់ ។

នៅពេលបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះរួចរាល់ហើយ បុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ច ត្រូវផ្តល់នូវគណនេយ្យចុងក្រោយ និងរបាយការណ៍ឱ្យទៅក្រសួង ស្ថាប័ន ទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានដែលនៅសល់ ត្រូវបែងចែក ស្របតាមលិខិតបរធនបាលកិច្ចបរិស្ថាន ។

ប្រាក់កម្រៃសម្រាប់បុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ច ត្រូវបានគណនាដោយផ្អែកលើមូលដ្ឋាននៃអត្រាវិជ្ជាជីវៈស្តង់ដារ និងត្រូវបង់ដោយយកពីទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន ។

**មាត្រា៩៩៣** ._ លក្ខខណ្ឌតម្រូវនៅពេលបញ្ចប់បរធនបាលកិច្ចបរិស្ថាន

បរធនបាលកិច្ចបរិស្ថាន ត្រូវបញ្ចប់បន្ទាប់ពី ៖

១- បានសង បំណុលនៃបរធនបាលកិច្ចបរិស្ថាន ។

២- បានផ្ទេរមូលនិធិដែលនៅសល់ក្នុងគណនី នៃបរធនបាលកិច្ចបរិស្ថាន និងទ្រព្យសម្បត្តិបរធនបាលកិច្ចទាំងអស់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ស្តីពីបរធនបាលកិច្ចនានា ។

៣- និងបានដោះស្រាយ រាល់វិវាទទាំងអស់ ដែលទាក់ទងនឹងគណនេយ្យចុងក្រោយ ។

បន្ទាប់ពីការបញ្ចប់បរធនបាលកិច្ចបរិស្ថាន បរធនបាលនៅតែទទួលខុសត្រូវ ចំពោះការបាត់បង់ ឬខូចខាតដែលបានបង្កឡើង ឬដែលបណ្តាលមកពីកំហុសដោយចេតនា ការធ្វេសប្រហែស ការក្លែងបន្លំ ឬភាពមិនស្មោះត្រង់របស់បរធនបាល ។

**មាត្រា៩៩៤** ._ វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថាន

វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថាន ត្រូវដោះស្រាយតាមរយៈការផ្សះផ្សា ឬសន្ទានកម្មដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំពោះវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចដែលមិនបានមកចុះបញ្ជី ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានសិទ្ធិលុបចោលបរធនបាលកិច្ចនោះ ។

ភាគីណាមួយមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើបណ្តឹងតវ៉ា ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងគន្ថីទី១០ នៃក្រមនេះ ។

លទ្ធផលនៃនីតិវិធីដោះស្រាយវិវាទទាំងអស់ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៩៩៥ ._** ការគ្រប់គ្រង ឬការប្រើប្រាស់បរធនបាលកិច្ចបរិស្ថានមិនសមស្រប

បរធនបាលណាដែលគ្រប់គ្រង ឬប្រើប្រាស់បរធនបាលកិច្ចបរិស្ថានមិនសមស្រប ឬផ្ទុយពីគោលបំណងនៃបរធនបាលកិច្ចបរិស្ថាន ដែលបណ្តាលឱ្យមានការខូចខាតដល់បរិស្ថាន ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតស្តីពីបរធនបាលកិច្ច ។

**មាត្រា៩៩៦ ._** មូលនិធិសម្រាប់ការគ្រប់គ្រងរួមគ្នា

មូលនិធិសម្រាប់ការគ្រប់គ្រងរួមគ្នាមួយ ត្រូវបង្កើតឡើងដើម្បីផ្តល់ការគាំទ្រដល់សកម្មភាពនៃការគ្រប់គ្រងរួមគ្នា ដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងរួមគ្នានីមួយៗ ។ មូលនិធិនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការគ្រប់គ្រងរួមគ្នា នៃតំបន់គ្រប់គ្រងរួមគ្នា ដោយមានការតាមដានត្រួតពិនិត្យ និងវាយតម្លៃពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយតម្លាភាព ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។

គណៈកម្មការគ្រប់គ្រងរួមគ្នា អាចទទួលបានថវិកា និងរកចំណូលពីប្រភពដែលមានជាអាទិ៍ ៖

១- មូលនិធិសង្គម និងបរិស្ថាន ។

២- ប្រភពឯកជន និងសាធារណៈជាច្រើន ។

៣- សេវានានា ការយកថ្លៃជួល ថ្លៃប្រើប្រាស់ ថ្លៃកំសាន្ត ឬការយកថ្លៃចូលទស្សនាជាដើម ។

៤- វិភាគទាន អំណោយ និងជំនួយ ។

**មាត្រា៩៩៧ ._** ការប្រើប្រាស់ប្រាក់ចំណូលការចំណាយ ឬវិភាគទានផ្សេងៗ

ការប្រើប្រាស់ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗ ដែលទទួលបានតាមរយៈ ការអនុវត្តនៃការគ្រប់គ្រងរួមគ្នា ត្រូវបានប្រើប្រាស់សម្រាប់តែផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន ដែលរស់នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា សម្រាប់ការគាំទ្រដល់ការអនុវត្តលើការគ្រប់គ្រងរួមគ្នា និងសម្រាប់ការអភិរក្សនៃតំបន់គ្រប់គ្រងរួមគ្នា និងបណ្តាតំបន់នៅជាប់ ដែលមានការអភិរក្ស ។ វិធីសាស្ត្រច្បាស់លាស់

ក្នុងការបែងចែកប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗ ត្រូវមានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។

ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗដែលទទួលបានពីការងារគ្រប់គ្រងនៃសហគមន៍គ្រប់គ្រងរួមគ្នា ត្រូវទទួលនូវអាទិភាពលើកលែងពន្ធ អាករ និងបន្ទុកផ្សេងៗ ដូចបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

## ផ្នែកទី២
## មូលនិធិសម្រាប់ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៩៩៨** ._ មូលនិធិសម្រាប់ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ត្រូវបង្កើតមូលនិធិដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ នៅថ្នាក់ឃុំ សង្កាត់ ពាក់ព័ន្ធនឹងកម្រៃសេវាលើការបំពេញមុខងារជាសន្ធានការីបរិស្ថាន ដោយមានការចូលរួមពិនិត្យ និងឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតមូលនិធិដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិនៃគណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិពាក់ព័ន្ធនឹងកម្រៃសេវាលើការបំពេញមុខងាររបស់អ្នកជំនាញបច្ចេកទេសបរិស្ថាន ដោយមានការចូលរួមពិនិត្យ និងឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៩៩៩** ._ ប្រភពមូលនិធិ

ប្រភពមូលនិធិសម្រាប់ដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងនៅក្នុងមាត្រា៩៩៨ ខាងលើនេះ បានមកពី ៖

១- ថវិកាជាតិដែលបានផ្តល់ជូន ។

២- អំណោយពីនីតិបុគ្គលជាតិ និងអន្តរជាតិ ។

៣- វិភាគទានសប្បុរសធម៌ និងអំណោយផ្សេងទៀត ។

៤- ប្រភពផ្សេងៗទៀត ។

**មាត្រា១០០០** ._ ការប្រើប្រាស់មូលនិធិ

នីតិវិធីនៃការប្រើប្រាស់មូលនិធិ សម្រាប់ដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ។

## ផ្នែកទី៣
## មូលនិធិសម្រាប់លំហាបៃតង

**មាត្រា១០០១** ._ ការបង្កើតមូលនិធិលំហាបៃតង

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបង្កើតមូលនិធិ លំហាបៃតង សម្រាប់ការរៀបចំលំហាបៃតង ។ ការរៀបចំ គ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងមូលនិធិលំហាបៃតង ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាង ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពិសេសដោយឡែកស្តីពីហិរញ្ញវត្ថុ ។

**មាត្រា១០០២** ._ ប្រភពចំណូលនៃមូលនិធិលំហាបៃតង

មូលនិធិលំហាបៃតង មានប្រភពចំណូល ដូចខាងក្រោម ៖

១- ប្រាក់កម្រៃដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

២- មូលនិធិពីម្ចាស់ជំនួយ ។

៣- និងប្រភពផ្សេងៗទៀត ដែលបានកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ចំនួនទឹកប្រាក់ និងនីតិវិធីនៃការគណនា បុគ្គលទទួលខុសត្រូវ និងប្រភេទ និងទំហំនៃគម្រោងដែលតម្រូវឱ្យបង់ថ្លៃលើប្រាក់កម្រៃនានា ត្រូវកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត ស្តីពីមូលនិធិលំហាបៃតង ដូចមានចែងនៅក្នុងមាត្រា១០០១ ។

បុគ្គលទាំងអស់ដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត ស្តីពីមូលនិធិលំហាបៃតង ដូចមានចែងនៅក្នុងមាត្រា១០០១ ត្រូវទទួលខុសត្រូវចំពោះការបង់ថ្លៃលើមូលនិធិលំហាបៃតងនេះ ។

## ផ្នែកទី៤
## មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន

**មាត្រា១០០៣**._ កាបង្កើតមូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំបង្កើតមូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ដើម្បីបម្រើដល់ការងារអប់រំ និងបណ្តុះបណ្តាលបរិស្ថាន ឱ្យឆ្លើយតបទៅនឹងតម្រូវការនៃកិច្ចគាំពារបរិស្ថាន ទាំងនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងដើម្បីជួយសម្រួលដល់កិច្ចសហការ ការសម្របសម្រួល និងការចែករំលែកធនធានពីវិស័យសាធារណៈ និងឯកជន ។

មូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន ក៏ត្រូវជួយដល់ការបង្កើតប្រព័ន្ធអប់រំបរិស្ថានជឿនលឿនមួយ និងជួយជំរុញដល់ការបង្កើតភាពជាដៃគូរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យធុរកិច្ច វិស័យឧស្សាហកម្ម គ្រឹះស្ថានឧត្តមសិក្សា ក្រុមបរិស្ថាន សហគមន៍មូលដ្ឋាន និងអង្គការអន្តរជាតិនានា ។

មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ជាអង្គភាពទទួលជំនួយសប្បុរស និងមិនយកប្រាក់ចំណេញ ដែលចំណូលទាំងអស់សម្រាប់មូលនិធិនេះមិនជាប់ពន្ធ ហើយត្រូវបានលើកលែងពន្ធ ស្របទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ។

**មាត្រា១០០៤**._ គោលបំណងរបស់មូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន

មូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន ត្រូវបង្កើតឡើងក្នុងគោលបំណង ៖

១- ទទួលយករាល់អំណោយទាំងអស់ពីវិស័យសាធារណៈ និងឯកជន ដើម្បីយកមកបម្រើដល់សកម្មភាព និងសេវាកម្មការងារអប់រំបណ្តុះបណ្តាល និងស្រាវជ្រាវបរិស្ថាន ។

២- អនុវត្តរាល់សកម្មភាពអប់រំបរិស្ថាននានា ដែលនឹងជួយដល់ការបណ្តុះស្មារតីភ្ញាក់រលឹក និងការទទួលខុសត្រូវរបស់សាធារណជនលើបរិស្ថាន ក៏ដូចជាការបណ្តុះមនុស្សបរិស្ថានដ៏ល្អមួយ និងការបង្កើតប្រព័ន្ធអប់រំបរិស្ថានជឿនលឿនមួយ ។

៣- ចូលរួមជាមួយស្ថាប័នអន្តរជាតិ និងរូបវន្តបុគ្គលនានានៅក្នុងការសម្របសម្រួល និងអនុវត្តសកម្មភាពដែលនឹងផ្តល់កាលានុវត្តន៍ភាពសម្រាប់ការអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវបរិស្ថាន ដើម្បីដោះស្រាយបញ្ហាបរិស្ថាននានា ។

**មាត្រា១០០៥**._ ប្រភពចំណូលរបស់មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន

ប្រភពចំណូលរបស់មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថានមានដូចខាងក្រោម ៖

១- ចំណូលពីមូលនិធិបរិស្ថាននិងសង្គមដែលទទួលបាន ត្រូវចែករំលែកយ៉ាងតិច ១០ (ដប់) ភាគរយ បញ្ចូលទៅក្នុងមូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ។

២- ចំណូលពីការផាកពិន័យបទល្មើសបរិស្ថាន ដែលទទួលបាន ត្រូវចែករំលែកយ៉ាងតិច ១០ (ដប់) ភាគរយ បញ្ចូលទៅក្នុងមូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ។

៣- ចំណូលពីការប្រាក់របស់មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថានផ្ទាល់ ។

៤- អំណោយពីប្រជាពលរដ្ឋ សហគ្រាសឧស្សាហកម្ម សេវាកម្ម វិស័យឯកជន ឬពីសមាគម និងក្រុមនានា ។

៥- អំណោយផ្សេងៗទៀតពីដៃគូអភិវឌ្ឍន៍ ដៃគូសហការ ។

**មាត្រា១០០៦**._ លក្ខខណ្ឌស្តីពីអំណោយ

រាល់ប្រភេទអំណោយជាថវិកា ឧបករណ៍បរិក្ខារ ឬមរតក អាចទទួលយកបានដោយមូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ប្រសិនបើអំណោយទាំងនេះមិនមានជាប់លក្ខខណ្ឌ ភាពប្រទាំងប្រទើស ឬភ្ជាប់នូវកម្មវត្ថុ សម្រាប់ជាប្រយោជន៍របស់បុគ្គលណាមួយនាពេលបច្ចុប្បន្ន និងទៅអនាគត ប៉ុន្តែជាប្រយោជន៍សម្រាប់មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ។

**មាត្រា១០០៧**._ ការប្រើប្រាស់ មូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន

មូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន អាចត្រូវបានប្រើប្រាស់ដើម្បីបម្រើឱ្យសកម្មភាពការងារមួយចំនួនដូចខាងក្រោម ៖

១- រៀបចំសិក្ខាសាលា ឬការបណ្តុះបណ្តាលបរិស្ថាន ។

២- អនុវត្តកម្មវិធីយុទ្ធនាការ និងព្រឹត្តការណ៍បរិស្ថាន ។

៣- ចងក្រងឯកសារអប់រំបរិស្ថាន ឯកសារបង្រៀនពីបរិស្ថាន ខិត្តប័ណ្ណផ្សព្វផ្សាយ កូនសៀវភៅ ។

៤- អនុវត្តលើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍លើការងារអប់រំបរិស្ថាន ។

៥- ឧបត្ថម្ភធនទៅលើមធ្យោបាយអប់រំបរិស្ថាន ឬទីកន្លែងដែលរៀបចំព្រឹត្តការណ៍អប់រំបរិស្ថាន ។

៦- ឧបត្ថម្ភធនដល់អង្គភាព ឬភ្នាក់ងារអប់រំបរិស្ថានដែលបានជួលអ្នកអប់រំបរិស្ថានទៅបណ្តុះបណ្តាល ឬរៀបចំសិក្ខាសាលាបរិស្ថាន ។

៧- ឧបត្ថម្ភធនដល់កម្មវិធីអប់រំបរិស្ថាន ។

៨- ប្រើប្រាស់សម្រាប់បណ្តុះបណ្តាលដល់អ្នកអប់រំបរិស្ថាន ។

៩- និង សកម្មភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងការលើកកម្ពស់ការយល់ដឹង ការអប់រំ និងចូលរួមផ្នែកបរិស្ថាន ។

**មាត្រា១០០៨** ._ មូលនិធិរង្វាន់លើកទឹកចិត្តដល់សកម្មភាពមេត្រីភាពបរិស្ថាន

តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតមូលនិធិរង្វាន់លើកទឹកចិត្តដល់សកម្មភាពមេត្រីភាពបរិស្ថាន ដើម្បីឧបត្ថម្ភដល់សកម្មភាពមេត្រីភាពបរិស្ថាន ។

ការរៀបចំការគ្រប់គ្រង ការប្រើប្រាស់និងការបែងចែកមូលនិធិរង្វាន់លើកទឹកចិត្តដល់សកម្មភាពមេត្រីភាពបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដោយឡែកពាក់ព័ន្ធទៅនឹងហិរញ្ញវត្ថុ ដែលនៅជាធរមាន ។

**មាត្រា១០០៩** ._ ប្រភពចំណូលនៃមូលនិធិរង្វាន់លើកទឹកចិត្តដល់សកម្មភាពមេត្រីភាពបរិស្ថាន

មូលនិធិរង្វាន់លើកទឹកចិត្តដល់សកម្មភាពមេត្រីភាពបរិស្ថាន មានប្រភពចំណូល ដូចខាងក្រោម ៖

១- ថវិកាជាតិ ។

២- អំណោយសប្បុរសធម៌ពីនីតិបុគ្គលជាតិ និងអន្តរជាតិ ។

៣- វិភាគទានសប្បុរសធម៌ និងអំណោយដទៃទៀត ។

៤- និងប្រភពផ្សេងទៀតដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១០១០** ._ ការឧបត្ថម្ភដល់សកម្មភាពមេត្រីភាពបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវលើកទឹកចិត្តដល់សហគ្រិន វិនិយោគិន និងសប្បុរសជននានា ឱ្យធ្វើការបរិច្ចាគ និងផ្តល់ហិរញ្ញប្បទានសម្រាប់សកម្មភាពមេត្រីភាពបរិស្ថាន ។

## ជំពូកទី៤
## ហិរញ្ញប្បទានសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន

**មាត្រា១០១១ .**_ ធនធានហិរញ្ញវត្ថុសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន

ម្ចាស់នៃគម្រោងដែលបានស្នើសុំ ដែលតម្រូវឱ្យមានផែនការគ្រប់គ្រងបរិស្ថាន ស្របតាមបទប្បញ្ញត្តិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងមាតិកាទី២ គន្ថីទី២នៃក្រមនេះ ត្រូវផ្តល់ការធានាថា ខ្លួនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោងជាមុនសិន មុនពេលមានការចេញលិខិត ឬវិញ្ញាបនបត្រឯកភាពលើគម្រោងនេះ ។

យន្តការពិនិត្យ និងវាយតម្លៃ និងឯកភាពរួមគ្នាជាមុន រវាងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ពាក់ព័ន្ធនឹងប្រភេទ និងចំនួននៃការធានាផ្នែកហិរញ្ញវត្ថុនេះ ព្រមទាំងលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ដោះស្រាយ និងសម្រួលដល់ការអនុវត្តរបស់ម្ចាស់គម្រោងដែលមានស្រាប់ ដែលទទួលបានការឯកភាពពីរាជរដ្ឋាភិបាល ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា១០១២ .**_ ថវិកាសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន

ថវិកាលម្អិត សម្រាប់តម្លៃដែលត្រូវបានប៉ាន់ប្រមាណ ពាក់ព័ន្ធនឹងការអនុវត្តផែនការ គ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងបរិស្ថាន ។

ថវិកានេះ ត្រូវមានជាអាទិ៍ ៖

១- តម្លៃសម្រាប់វិធានការកាត់បន្ថយ ។

២- តម្លៃសម្រាប់ការអង្កេតតាមដាន ។

៣- តម្លៃពាក់ព័ន្ធនឹងយន្តការបណ្តឹង ពាក់ព័ន្ធនឹងប្រតិបត្តិការគម្រោង ។

៤- ការទទួលខុសត្រូវជាសក្តានុពលណាមួយសម្រាប់ការផ្លាស់ប្តូរទីតាំង និងសំណង ចំពោះបុគ្គលដែលរងផលប៉ះពាល់ដោយសារគម្រោង ។

៥- ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីណាមួយដែលតម្រូវ ។

៦- តម្លៃជាសក្តានុពលពាក់ព័ន្ធនឹងការបិទ ការស្តារឡើងវិញ នីតិសម្បទា ដំណោះស្រាយ ឬការបញ្ឈប់សកម្មភាពគម្រោង ។

៧- និងតម្លៃផ្សេងទៀតណាមួយ ពាក់ព័ន្ធនឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោង ។

**មាត្រា១០១៣**._ នីតិវិធីនៃការធានាផ្នែកហិរញ្ញវត្ថុ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការកំណត់អំពីការផ្តល់ការធានាផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននៃគម្រោងដែលបានស្នើសុំ មានជាអាទិ៍ ៖

១- វិសាលភាពនៃការធានាផ្នែកហិរញ្ញវត្ថុដែលតម្រូវសម្រាប់ការអនុវត្តផែនការ ។

២- ទម្រង់បែបបទនៃការធានាផ្នែកហិរញ្ញវត្ថុដែលអាចទទួលយកបាន ។

៣- ចំនួនទឹកប្រាក់សមស្របនៃការធានាផ្នែកហិរញ្ញវត្ថុ ដែលតម្រូវដោយផ្អែកលើ ទំហំខ្នាត ទីតាំង និងផលប៉ះពាល់ជាសក្តានុពល ។

៤- និងក្របខ័ណ្ឌពេលវេលាសម្រាប់ការប្តឹងចំពោះធនធានហិរញ្ញវត្ថុដែលយកមកដាក់ធានា ឬបើគ្មានការប្តឹងណាមួយទេ ត្រូវដាក់ឱ្យធនធានហិរញ្ញវត្ថុនេះ អាចស្វែងរកបាន ។

**មាត្រា១០១៤**._ ការធ្វើសវនកម្ម និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ម្ចាស់គម្រោង ដែលតម្រូវឱ្យផ្តល់ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងការធ្វើសវនកម្ម និងការរៀបចំរបាយការណ៍ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ស្តីពីការធ្វើសវនកម្ម និងការរៀបចំរបាយការណ៍ ។

ម្ចាស់គម្រោង ត្រូវធ្វើការពិនិត្យប្រចាំឆ្នាំឡើងវិញនូវការប៉ាន់ប្រមាណតម្លៃនានា ពាក់ព័ន្ធនឹងផែនការគ្រប់គ្រងបរិស្ថាន និងដាក់ជូនការប៉ាន់ប្រមាណនេះ មកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ ការប៉ាន់ប្រមាណនេះ ត្រូវធ្វើឡើងដោយអ្នកជំនាញការបច្ចេកទេសខាងវិស្វកម្ម ។

ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំ បង្ហាញថាពុំមានការគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការធានាផ្នែកហិរញ្ញវត្ថុ ម្ចាស់គម្រោងត្រូវជូនដំណឹងទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ។

ម្ចាស់គម្រោងត្រូវគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការធានាផ្នែកហិរញ្ញវត្ថុដែលបានធ្វើបច្ចុប្បន្នភាព ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីការជូនដំណឹងនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចតម្រូវឱ្យមានរបាយការណ៍ ឬឯកសារបន្ថែមទៀតបាន ។

ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំ បង្ហាញថា មានការធានាផ្នែកហិរញ្ញវត្ថុ ដែលលើសពីលក្ខខណ្ឌតម្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចដាក់សំណើមកក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុញ្ញាតសុំបង្វិលសងមូលនិធិដែលលើស តាមការស្នើសុំរបស់ម្ចាស់គម្រោង ។

## គន្ថីទី៩
## ការទទួលខុសត្រូវលើការខូចខាតបរិស្ថាន
## មាតិកាទោល
## ការស្តារឡើងវិញ និងសំណងលើការខូចខាតបរិស្ថាន
## ជំពូកទី១
## យន្តការវាយតម្លៃទំហំនៃការខូចខាតបរិស្ថាន

**មាត្រា១០១៥ .**_ ការបង្កើតយន្តការសម្រាប់ការស្តារបរិស្ថានឡើងវិញ និងកំណត់ទំហំនៃសំណងការខូចខាត

នីតិវិធី និងបែបបទនៃការបង្កើតយន្តការ ការវាយតម្លៃទំហំនៃការខូចខាតបរិស្ថាន ការស្តារបរិស្ថានឡើងវិញ និងការទូទាត់សងការខូចខាតបរិស្ថាន និងការទូទាត់ការខូចខាតផ្នែកហិរញ្ញវត្ថុ ដែលកើតចេញពីការខូចខាតបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១០១៦ .**_ ការទទួលខុសត្រូវក្នុងការស្តារបរិស្ថានឡើងវិញ ការទូទាត់សំណងការខូចខាត និង ការបាត់បង់

រូបវន្តបុគ្គល ឬនីតិបុគ្គលណា ដែលបានរកឃើញថា បានបង្កការខូចខាតបរិស្ថាន ឬការខូចខាតផ្នែកហិរញ្ញវត្ថុដែលកើតចេញពីការខូចខាតបរិស្ថាន ត្រូវទទួលខុសត្រូវក្នុងការស្តារបរិស្ថានឡើងវិញ ឬត្រូវទូទាត់សំណងការខូចខាត និងការបាត់បង់ទាំងអស់ដែលបានកើតឡើង ។

**មាត្រា១០១៧ .**_ ការចូលរួមក្នុងដំណើរការនៃស្តារការខូចខាតបរិស្ថានឡើងវិញ

ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច ជនជាតិដើមភាគតិច សង្គមស៊ីវិល នីតិបុគ្គល និងរូបវន្តបុគ្គលដែលទទួលរងផលប៉ះពាល់ទាំងអស់ ត្រូវផ្តល់ព័ត៌មានបច្ចេកទេស ចំណេះដឹង បទពិសោធន៍ និងក្តីកង្វល់ ដែលពាក់ពាក់ព័ន្ធទាំងឡាយ ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចក្នុងការស្តារឡើងវិញនូវការខូចខាតបរិស្ថាន ។

## ជំពូកទី២
## ការទទួលខុសត្រូវបរិស្ថាន

**មាត្រា១០១៨ .**_ គោលការណ៍នៃការទទួលខុសត្រូវសំណងផ្នែកបរិស្ថាន

រូបវន្តបុគ្គល នីតិបុគ្គល ឬមន្ត្រីរាជការ ត្រូវទទួលខុសត្រូវចំពោះសំណងបរិស្ថាន ដោយមិនតម្រូវឱ្យមានបង្ហាញពីធាតុចេតនា និងការដឹងនោះទេ  ក្នុងករណីដូចខាងក្រោម ៖

១- មិនបានធ្វើសកម្មភាព ឬការខកខានមិនបានចាត់វិធានការទប់ស្កាត់ ដែលបង្កឱ្យមានការខូចខាតបរិស្ថាន ។

២- បំពេញការងារលើសពីសិទ្ធិអំណាចរបស់ខ្លួន ឬប្រព្រឹត្តផ្ទុយនឹងក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលបង្កឱ្យមានការខូចខាតបរិស្ថាន ។

**មាត្រា១០១៩ .**_ ការរឹបអូសឧបករណ៍ដែលបង្កការខូចខាតបរិស្ថាន

រាល់ការប្រើប្រាស់ឧបករណ៍ដោយខុសច្បាប់ និងបង្កការខូចខាតបរិស្ថាន ត្រូវរឹបអូស និងប្រើប្រាស់សម្រាប់ការស្តារបរិស្ថានដែលទទួលរងការខូចខាតឡើងវិញ ស្របតាមនីតិវិធីដែលមានចែងក្នុងក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដោយឡែក ។

**មាត្រា១០២០**._ ការទទួលខុសត្រូវរបស់នីតិបុគ្គល

នាយកនៃនីតិបុគ្គល ត្រូវទទួលខុសត្រូវចំពោះសំណងផ្នែកបរិស្ថាន តាមលក្ខណៈ និងទំហំដូចគ្នាទៅនឹងការទទួលខុសត្រូវរបស់នីតិបុគ្គលនោះ ដូចមានចែងក្នុងមាត្រា១០១៨ នៃក្រមនេះ ។

**មាត្រា១០២១**._ កាតព្វកិច្ចសាមគ្គី

បុគ្គលគ្រប់រូបត្រូវមានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នា ចំពោះការខូចខាតបរិស្ថាន ក្នុងករណីដែលមានបុគ្គលទទួលខុសត្រូវលើសពី១ (មួយ) នាក់ ។ បុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវសងសំណងខូចខាតដោយពេញលេញ ដោយមិនគិតពីការចូលរួមចំណែកជាក់ស្តែងនៃបុគ្គលម្នាក់ៗ ដែលបង្កឱ្យមានការខូចខាតជាក់ស្តែងនោះទេ ។

## ជំពូកទី៣
## ការមិនទទួលខុសត្រូវចំពោះការខូចខាតបរិស្ថាន

**មាត្រា១០២២**._ ការមិនទទួលខុសត្រូវ

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវទទួលខុសត្រូវឡើយ ក្នុងករណីដែល ៖

១- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ ដែលមិនបានរំពឹងទុកមុន ឬសកម្មភាពនៃសង្គ្រាម ។

២- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែទង្វើ ឬការខកខានរបស់តតិយជនក្រៅពីបុគ្គលិកនិយោជិត ឬភ្នាក់ងាររបស់រូបវន្តបុគ្គល ឬនីតិបុគ្គលនោះ ។

៣- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែសកម្មភាពដែលបានអនុញ្ញាតយ៉ាងច្បាស់លាស់ដោយច្បាប់ ។

៤- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែសកម្មភាពដែលបានអនុញ្ញាតជាពិសេស និងដែលបានពណ៌នាពីភាពជាក់លាក់ ទាក់ទងនឹងប្រភេទ និងទំហំនៃការខូចខាតនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬ វិញ្ញាបនបត្រ និងលិខិតឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា១០២៣**._ ការលើកលែងចំពោះការមិនទទួលខុសត្រូវការខូចខាតបរិស្ថាន

ការមិនទទួលខុសត្រូវការខូចខាតបរិស្ថាន ដូចមានចែងក្នុងមាត្រា១០២២ នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដូចខាងក្រោម ៖

១- សកម្មភាពដែលបង្កឱ្យមានការខូចខាតនោះ ត្រូវបានអនុវត្តដោយមានការរំលោភបំពានទាំងស្រុង ឬផ្នែកណាមួយនៃក្រមបរិស្ថាន ឬលិខិតបទដ្ឋានគតិយុត្តណាមួយផ្សេងទៀត ។

២- សកម្មភាពដែលបង្កឱ្យមានការខូចខាត ត្រូវបានធ្វើឡើងយោងតាមលក្ខខណ្ឌសម្បទាន អាជ្ញាប័ណ្ណ ឬការអនុញ្ញាតជាក់ស្តែងផ្សេងទៀតដែលត្រូវបានផ្តល់ឱ្យ មិនស្របតាមលិខិតបទដ្ឋានគតិយុត្ត មានជាអាទិ៍ ការអនុញ្ញាតដែលចេញដោយមន្ត្រីដែលគ្មានសិទ្ធិក្នុងការផ្តល់ការអនុញ្ញាតនោះ ឬការខកខានមិនបានបំពេញតាមលក្ខខណ្ឌដែលច្បាប់តម្រូវ មុនពេលចេញការអនុញ្ញាតជាដើម ។

៣- សកម្មភាពដែលនាំឱ្យមានការខូចខាតបរិស្ថាន ត្រូវបានពិនិត្យឃើញថា មានចំនួនទំហំ ឬប្រភេទខុសៗគ្នា ក្រៅពីការកំណត់ចំនួន និងការអនុញ្ញាត ដែលបានកំណត់ជាក់លាក់នៅក្នុងផែនការគាំពារបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ផែនការគ្រប់គ្រងបរិស្ថាន ឬលិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៤- ការខូចខាតដែលបង្កឡើងដោយសារការធ្វេសប្រហែស អំពើទុច្ចរិត ឬសកម្មភាពខុសច្បាប់ ក្នុងការអនុវត្ត ការធ្វើប្រតិបត្តិការ ឬការបំពេញសកម្មភាពដែលត្រូវបានអនុញ្ញាត ។

៥- សកម្មភាពទាំងឡាយដែលផ្ទុយទៅនឹងខចែង និងលក្ខខណ្ឌនៃលិខិតអនុញ្ញាត កិច្ចសន្យា ការអនុញ្ញាត ឬឯកសារពាក់ព័ន្ធទាំងឡាយផ្សេងទៀត ព្រមទាំងការខកខានមិនបានអនុវត្តសកម្មភាពជាក់លាក់នានា ដែលតម្រូវក្នុងលិខិតអនុញ្ញាត ។

## ជំពូកទី៤
## សំណងការខូចខាតបរិស្ថាន

**មាត្រា១០២៤**._ សំណងការខូចខាតបរិស្ថាន

សំណងការខូចខាតបរិស្ថាន មានដូចខាងក្រោម ៖

១- ថ្លៃពេញលេញក្នុងការស្តារបរិស្ថានឡើងវិញឱ្យដូចស្ថានភាពដើម មុនពេលមានការខូចខាតកើតឡើង ។

២- ថ្លៃពេញលេញសម្រាប់ការអនុវត្តការស្តារឡើងវិញបន្ថែមទៀតដែលគ្រប់គ្រាន់ដើម្បីធ្វើការទូទាត់ចំពោះការខូចខាតទាំងមូល ដែលមិនបានទូទាត់សងដោយការស្តារឡើងវិញ ក្នុងចំណុចទី១ ខាងលើ ។

៣- តម្លៃនៃទិដ្ឋភាពនៃបរិស្ថានដែលទទួលរងការខូចខាត ដែលមិនអាចស្តារឡើងវិញបាន ក្នុងករណីដែលការស្តារឡើងវិញត្រូវបានធ្វើឡើង ប៉ុន្តែផ្នែក ឬទិដ្ឋភាពមួយចំនួននៃបរិស្ថានដែលទទួលរងការខូចខាត មិនងាយស្តារឡើងវិញបាន ។

៤- តម្លៃអេកូឡូស៊ី ឬតម្លៃមនុស្ស ដែលបានបាត់បង់ដោយសារការខូចខាតបរិស្ថាន មិនអាចត្រូវបានទូទាត់សងពេញលេញ ដោយសារកត្តាដែលមានក្នុងចំណុចទី១ ទី២ និងទី៣ ខាងលើ រួមមានតម្លៃសេដ្ឋកិច្ច ដែលកំណត់ដោយវិធីសាស្ត្រវាយតម្លៃសេដ្ឋកិច្ចលម្អិត ។

៥- ថ្លៃទាំងអស់ដែលដើមបណ្តឹងបានចំណាយក្នុងការប្តឹង ដើម្បីធ្វើការទាមទារសំណងសម្រាប់ការជួសជុលបរិស្ថាន ដែលរួមមាន ៖

- ថ្លៃជាក់ស្តែង និងថ្លៃចំណាយផ្សេងទៀត របស់ក្រុមការងាររៀបចំផែនការស្តារឡើងវិញ
- ថ្លៃចំណាយលើការវាយតម្លៃសំណងការខូចខាត និងការស្តារឡើងវិញ
- ថ្លៃចំណាយទាំងអស់ដែលក្រុមការងាររៀបចំផែនការស្តារឡើងបានចំណាយ
- និងថ្លៃចំណាយលើដំណើរការពិគ្រោះយោបល់ ។

៦- ថ្លៃអង្កេតតាមដាន និងថ្លៃធានាឱ្យបាននូវភាពជោគជ័យនៃសកម្មភាពស្តារឡើងវិញ ដូចបានកំណត់ពីមុនរួចមកហើយ ។

៧- ថ្លៃទូទាត់សងសម្រាប់ការបាត់បង់មុខរបរ និងសេដ្ឋកិច្ច ដែលបណ្តាលមកពីការខូចខាតបរិស្ថាន ។

៨- ថ្លៃទូទាត់សងតាមរយៈការស្តារឡើងវិញ ឬលើការបាត់បង់ស្ថិរភាពនៃការប្រើប្រាស់បរិស្ថាន ។

៩- ការបាត់បង់ថ្លៃសុទ្ធនៃស្វយសារ ប្រាក់ឈ្នួល កម្រៃនានា ឬការបាត់បង់ភាគហ៊ុននៃប្រាក់ចំណេញសុទ្ធដោយសារការខូចខាតនោះ ។

១០- ការបាត់បង់ប្រាក់ចំណេញ ឬឱនភាពនៃសមត្ថភាពរកចំណូលដោយសារការខូចខាត ។

១១- ថ្លៃសុទ្ធនៃការផ្តល់សេវាសាធារណៈដែលមានការកើនឡើង និងបន្ថែម ក្នុងការឆ្លើយតបទៅនឹងការខូចខាតបរិស្ថាន ។

១២- ប្រាក់ប្រដាប់ក្តី សោហ៊ុយ និងការចំណាយផ្សេងៗ ដែលកើតឡើងក្នុងដំណើរការនៃបណ្តឹង ។

១៣- ការខាតបង់សុទ្ធលើកម្រៃសេវា សួយសារ បុព្វលាភ ពន្ធ ឬប្រាក់ចំណូលផ្សេងទៀត ដែលត្រូវបង់ទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

១៤- ថ្លៃផ្តល់សេវាក្នុងការយាមល្បាត ដែលសមភាពទៅនឹងសេវាកម្មយាមល្បាតនានាក្នុងអំឡុងពេលនៃការចាប់ខ្លួន និងការកាត់ទោសទៅលើការរំលោភបំពាន ។

**មាត្រា១០២៥** ._ ការស្តារការខូចខាតបរិស្ថានឡើងវិញជាបន្ទាន់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខខណ្ឌតម្រូវ និងនីតិវិធីក្នុងការស្តារការខូចបរិស្ថានឡើងវិញជាបន្ទាន់ ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិយល់ឃើញថាមានភាពចាំបាច់ ដែលតម្រូវឱ្យមានការចាត់វិធានការជាបន្ទាន់ និងទាន់ពេលវេលា ។

## ជំពូកទី៥
## ការរៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញ

**មាត្រា១០២៦** ._ ក្រុមការងាររៀបចំផែនការស្តារឡើងវិញ

ក្នុងករណីមានបណ្តឹងទាមទារឱ្យមានការជួសជុលដោយការស្តារបរិស្ថានឡើងវិញ ដូចមានចែងក្នុងមាត្រា១០២៤ នៃក្រមនេះ ភាគីដែលមានសិទ្ធិធ្វើសកម្មភាពបណ្តឹង មានសិទ្ធិលើកជាសំណើទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដើម្បីបង្កើតក្រុមការងាររៀបចំផែនការស្តារឡើងវិញនូវការខូចខាតបរិស្ថាននោះ ។

បុគ្គលដែលបានចាត់តាំង រដ្ឋបាលថ្នាក់ក្រោមជាតិ រូបវន្តបុគ្គល តំណាងអង្គការសង្គមស៊ីវិលជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន និងបុគ្គលដទៃទៀត ដែលអាចទទួលរងផលប៉ះពាល់ដល់

ប្រយោជន៍របស់ខ្លួន អាចចូលរួមនៅក្នុងក្រុមការងាររៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញ ដូចមានចែងក្នុងកថាខណ្ឌខាងលើ ។

**មាត្រា១០២៧** ._ ភារកិច្ច និងតួនាទីរបស់ក្រុមការងាររៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញ

ភារកិច្ច និងតួនាទីរបស់ក្រុមការងាររៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញរួមមាន ៖

១- វាយតម្លៃពីបរិមាណធម្មជាតិ និងវិសាលភាពនៃការខូចខាតដោយប្រើព័ត៌មានដែលមានស្រាប់ ។ ដោយស្របតាមការវាយតម្លៃនេះ ក្រុមការងារត្រូវកំណត់ចំណាត់ការ ដូចខាងក្រោម ៖

- ធ្វើបណ្តឹងទាមទារសំណងលើការខូចខាតពីបុគ្គលមួយ ឬច្រើននាក់ ដែលអាចត្រូវទទួលខុសត្រូវតាមជំពូកទី២ នៃមាតិកានេះ

- បំពេញតាមលក្ខខណ្ឌតម្រូវ និងនីតិវិធីនៃការស្តារឡើងវិញ ដូចមានចែងក្នុងមាត្រា១០២៥ នៃក្រមនេះ

- ធ្វើការវាយតម្លៃពីសំណងការខូចខាតសម្រាប់ធ្វើការស្តារឡើងវិញ

- អនុវត្តជម្រើសនៃចំណាត់ការសមស្របទៅតាមស្ថានភាពជាក់លាក់នៃគ្រោះថ្នាក់ ឬការខូចខាត ។

២-បន្ទាប់ពីបានសម្រេចថាត្រូវរៀបចំធ្វើបណ្តឹងទាមទារឱ្យមានការជួសជុលបរិស្ថាននោះ ក្រុមការងារចាំបាច់ត្រូវ ៖

- បង្កើតសេចក្តីថ្លែងការណ៍អំពីឆន្ទៈក្នុងការរៀបចំបណ្តឹងទាមទារការជួសជុលបរិស្ថាន ដែលក្នុងនោះត្រូវមានចុះអំពីព័ត៌មានសង្ខេបអំពីហេតុការ និងការខូចខាត នាពេលខាងមុខ ឬដែលបានរំពឹងទុកជាមុន

- កំណត់អំពីការអនុវត្តនូវសិទ្ធិអំណាចរបស់មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិទាក់ទងទៅនឹងហេតុការណ៍

- ធ្វើការជូនដំណឹងដល់ភាគីដែលទទួលខុសត្រូវ ។

៣- រៀបចំប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងបណ្តឹងទាមទារការស្តារឡើងវិញនាពេលខាងមុខ ។

៤- ពាក់ព័ន្ធទៅនឹងការរៀបបណ្តឹងទាមទារឱ្យមានការស្តារឡើងវិញ ស្របតាមចរិតលក្ខណៈនៃគ្រោះថ្នាក់ ឬការខូចខាតដល់បរិស្ថាន ក្រុមការងារត្រូវបំពេញតាមដំណាក់កាលដូចខាងក្រោម ដោយ ៖

- កំណត់ពីអត្តសញ្ញាណ និងបរិមាណនៃការខូចខាត

- កំណត់ពីលក្ខណៈនៃការស្តារឡើងវិញ និង/ឬ ដំណោះស្រាយដោយសំណងជាប្រាក់ ដែលគិតទាំងសំណងការខូចខាតនាពេលខាងមុខផងដែរ

- បង្កើតការថ្លឹងថ្លែង និងការបង្ហាញពីទំនាក់ទំនងរវាងការខូចខាត និងសំណងបច្ចុប្បន្ន និងអនាគត

- បង្ហាញពីការស្តារឡើងវិញ និង/ឬ ជម្រើសនៃសំណងការខូចខាត ប្រាក់ ដែលគិតទាំងសំណងការខូចខាតនាពេលខាងមុខ ។

៥- ប្រើប្រាស់ជំនាញ និងឯកទេសនៃសមាជិកក្នុងក្រុមការងារ និងក្រៅក្រុមការងាររៀបចំផែនការស្តារឡើងវិញ និងជំនួយផ្នែកបច្ចេកទេសទៅតាមតម្រូវការ ក្នុងគ្រប់ដំណោះស្រាយ និងការរៀបចំបណ្តឹងទាមទារ ។

៦- កំណត់ពីភាពសមរម្យនៃភាគីដែលទទួលខុសត្រូវនាពេលខាងមុខ ក្នុងការអនុវត្តការស្តារឡើងវិញដែលបានឯកភាព ។

៧- ជូនដំណឹងដល់ភាគីដែលអាចទទួលខុសត្រូវ ឱ្យចូលរួមក្នុងដំណើរការនៃការចរចាអំពីការស្តារឡើងវិញ ដើម្បីផ្តល់ការទទួលខុសត្រូវតាមរយៈកិច្ចការស្តារឡើងវិញ ឬការបង់សំណងលើការខូចខាត ។

**មាត្រា១០២៨** ._ នីតិវិធីវាយតម្លៃលើសំណងការខូចខាតសម្រាប់ការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីវាយតម្លៃ សំណងការខូចខាតសម្រាប់ការស្តារឡើងវិញ និងសំណងការខូចខាតបរិស្ថាន ទៅតាមតំបន់ភូមិសាស្ត្រជាក់ស្តែងនីមួយៗ ។

**មាត្រា១០២៩** ._ ដំណើរការនៃកិច្ចចរចាអំពីការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខខណ្ឌតម្រូវនៃការទូទាត់ និងការចរចាអំពីការស្តារឡើងវិញ របស់ក្រុមការងាររៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញ និងភាគីដែលអាចទទួលខុសត្រូវ ។

## ជំពូកទី៦
## សិទ្ធិអំណាចនៃការចេញបទបញ្ជាផ្នែករដ្ឋបាល

**មាត្រា១០៣០ ._** បទបញ្ជារដ្ឋបាលទាក់ទងនឹងវិធានការហិរញ្ញវត្ថុ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានភារកិច្ចចេញបទបញ្ជាឱ្យភាគីដែលអាចទទួលខុសត្រូវ ផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុជាបន្ទាន់សម្រាប់ការងាររបស់ក្រុមការងាររៀបចំផែនការស្តារឡើងវិញ និងការបង្កើតឱ្យមាននូវការវាយតម្លៃអំពីការជួសជុលដោយការស្តារឡើងវិញ ក្នុងករណីដែលការខូចខាតបរិស្ថានស្ថិតនៅក្នុងកម្រិតនៃការខូចខាតបរិស្ថានធ្ងន់ធ្ងរ ។

**មាត្រា១០៣១ ._** បទបញ្ជារដ្ឋបាលទាក់ទងនឹងវិធានការស្តារបរិស្ថានឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានភារកិច្ចចេញបញ្ជាឱ្យភាគីដែលទទួលខុសត្រូវប្រតិបត្តិលើវិធានការស្តារឡើងវិញជាកិច្ចសង្គ្រោះបន្ទាន់ ក្រោមការដឹកនាំរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ បន្ទាប់ពីរកឃើញថា តម្រូវឱ្យមានការទប់ស្កាត់ជាបន្ទាន់លើការខូចខាតបរិស្ថាន ឬដើម្បីជៀសវាងពីការបាត់បង់ឱកាសសំខាន់ដល់ការស្តារឡើងវិញ ។

## ជំពូកទី៧
## ការទាមទារមកវិញនូវថ្លៃចំណាយលើការស្តារការខូចខាតបរិស្ថានឡើងវិញ

**មាត្រា១០៣២ ._** ការស្តារការខូចខាត និងការទាមទារមកវិញនូវថ្លៃចំណាយ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ អាចធ្វើការស្តារឡើងវិញ ដែលចាំបាច់ចំពោះការខូចខាតបរិស្ថាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអាចធ្វើការទាមទារមកវិញនូវថ្លៃចំណាយទាំងអស់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា១០៣៣**._ បណ្តឹងទាមទារសំណង និងថ្លៃចំណាយសម្រាប់ការស្តារការខូចខាតដល់បរិស្ថានឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិអនុវត្តសកម្មភាពបណ្តឹងទាមទារសំណង និងថ្លៃចំណាយផ្សេងៗ សម្រាប់ការស្តារការខូចខាតបរិស្ថានឡើងវិញ ពីភាគីដែលបង្កការខូចខាតបរិស្ថាន ។

**មាត្រា១០៣៤**._ ការបង់ថ្លៃ ឬការបង់សងវិញនូវថ្លៃ និងចំណាយដែលបានកើតឡើង

ថវិកាប្រមូលបានសម្រាប់ការបំពេញតួនាទី ដូចមានចែងក្នុងមាតិកានេះ ដែលជាការចំណាយ និងការបង់សងវិញចំពោះថ្លៃ និងការចំណាយសម្រាប់ការវាយតម្លៃការជួសជុលបរិស្ថាន ដោយការស្តារឡើងវិញ និងសកម្មភាពរបស់ក្រុមការងាររៀបចំផែនការស្តារបរិស្ថានឡើងវិញ ត្រូវបង់ជូនដោយផ្ទាល់ទៅកាន់ភាគីដែលបានធ្វើការចំណាយ ។

## គន្ថីទី១០

## នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

## មាតិកាទី១

## ការដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានចរិតលក្ខណៈរដ្ឋប្បវេណី និងរដ្ឋបាល

## ជំពូកទី១

## បណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា១០៣៥**._ បណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី ធ្វើឡើងក្នុងគោលដៅដើម្បីធានានូវសិទ្ធិក្នុងការទាមទារសំណងការខូចខាតផ្នែកសម្ភារ ផ្នែករូបរាងកាយ និងផ្លូវចិត្ត ។

ចំពោះបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងអាចប្រើប្រាស់សិទ្ធិ ដូចមានចែងក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១០៣៦**._ បណ្តឹងអាជ្ញា

បណ្តឹងអាជ្ញា ធ្វើឡើងក្នុងគោលដៅដើម្បីធានាដល់សណ្តាប់ធ្នាប់សាធារណៈ ឬផលប្រយោជន៍សង្គមទូទៅ ក្នុងករណីមានបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ជនរងគ្រោះ ឬសាធារណជនទូទៅមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចបាន ។

ចំពោះបែបបទ និងនីតិវិធីនៃការធ្វើបណ្តឹងអាជ្ញា ត្រូវអនុលោមតាមក្រមបរិស្ថាន និងធនធានធម្មជាតិ និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១០៣៧** ._ បណ្តឹងប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

បណ្តឹងប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ធ្វើឡើងក្នុងគោលដៅដើម្បីប្រឆាំងនឹងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដែលពាក់ព័ន្ធនឹងវិធានការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលរងគ្រោះ ឬសាធារណជនដែលរងផលប៉ះពាល់ដោយសារសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចប្រើប្រាស់សិទ្ធិក្នុងការប្តឹងតវ៉ាដោយអនុលោមតាមក្រមនេះ ។

**មាត្រា១០៣៨** ._ បណ្តឹងប្រឆាំងនឹងសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

បណ្តឹងប្រឆាំងនឹងសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ធ្វើឡើងក្នុងគោលដៅដើម្បីទាមទារសំណងការខូចខាតបរិស្ថាន ឬធនធានធម្មជាតិ ដែលកើតឡើងដោយសារការបំពេញមុខងាររបស់មន្ត្រីរាជការសាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ច ដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ក្នុងការធ្វើសកម្មភាព ចំណាត់ការ ឬវិធានការលើសកម្មភាពបរិស្ថាន ឬការគ្រប់គ្រងធនធានធម្មជាតិ ដែលបង្កព្យសនកម្ម ឬបំពុលបរិស្ថាន ឬការបំពានសិទ្ធិ ឬផលប្រយោជន៍ណាដល់ភាគីទទួលរងផលប៉ះពាល់ ។

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចប្រើប្រាស់សិទ្ធិក្នុងការដាក់ពាក្យបណ្តឹង ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ទៅអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការមានសមត្ថកិច្ចបាន ដោយអនុលោមតាមក្រមនេះ ។

**មាត្រា១០៣៩** ._ បណ្តឹងដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ

បណ្តឹងដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ធ្វើឡើងក្នុងគោលដៅដើម្បីការពារផលប្រយោជន៍សាធារណៈ ប្រឆាំងនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ឬការមិនអនុវត្តបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។

រូបវន្តបុគ្គល ឬនិតីបុគ្គល អាចប្រើប្រាស់សិទ្ធិក្នុងការដាក់ពាក្យបណ្តឹង ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ទៅតុលាការមានសមត្ថកិច្ច ឬស្ថាប័នមានសមត្ថកិច្ចដោយអនុលោមតាមក្រមនេះ ។

**មាត្រា១០៤០ ._** បណ្តឹងជាយុទ្ធសាស្ត្រប្រឆាំងការចូលរួមជាសាធារណៈ

បណ្តឹងជាយុទ្ធសាស្ត្រប្រឆាំងការចូលរួមជាសាធារណៈ ធ្វើឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងគោលដៅដើម្បីទប់ស្កាត់ ឬរារាំង ឬគាបសង្កត់បណ្តឹងរបស់សាធារណជនទាំងឡាយ ដែលមានចេតនាទុច្ចរិត ក្នុងការធ្វើសកម្មភាពបណ្តឹងដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ ឬខូចផលប្រយោជន៍ហិរញ្ញវត្ថុរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលនោះ ។

## ជំពូកទី២
## ភាគីនៃបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា១០៤១ ._** ភាគីដែលទទួលរងផលប៉ះពាល់ ឬសាធារណជន

បុគ្គលដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោល ពីបទល្មើសបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិដាក់ពាក្យបណ្តឹងទៅស្ថាប័ន ឬតុលាការមានសមត្ថកិច្ច ដើម្បីបញ្ឈប់ ឬរារាំងសកម្មភាពណាមួយ ឬទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្ត ដោយអនុលោមតាមក្រមនេះ និងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

បណ្តឹងនេះក៏អាចធ្វើឡើងដោយសហគមន៍ ដើម្បីប្រឆាំងនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ តាមរយៈតំណាងរបស់ខ្លួន ។ អ្នកតំណាងសហគមន៍នេះ ត្រូវមានភស្តុតាង ដែលបញ្ជាក់ថាមានការប្រគល់សិទ្ធិត្រឹមត្រូវពីសហគមន៍ ។

សាធារណជនទូទៅ អាចធ្វើសកម្មភាពបណ្តឹងប្រឆាំងនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ឬបណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចរដ្ឋបាល ឬទាមទារសំណងការខូចខាត ចំពោះការស្តារបរិស្ថានឡើងវិញ ក្នុងគោលដៅការពារប្រយោជន៍សាធារណៈ ទៅស្ថាប័ន ឬតុលាការមានសមត្ថកិច្ច ។

**មាត្រា១០៤២ ._** សមាគម ឬអង្គការដែលមាននីតិសម្បទា

គ្រប់សមាគម ឬអង្គការ ដែលបានចុះបញ្ជី និងទទួលស្គាល់ដោយអាជ្ញាធរស្របច្បាប់ត្រឹមត្រូវនៃព្រះរាជាណាចក្រកម្ពុជា អាចប្រើប្រាស់សិទ្ធិក្នុងការធ្វើបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិទៅស្ថាប័ន និងតុលាការមានសមត្ថកិច្ចបាន ។

បណ្ដឹងរបស់សមាគម ឬអង្គការទាំងនេះ ត្រូវធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ឈប់ ឬទប់ស្កាត់សកម្មភាពណាមួយ ឬទាមទារឱ្យមានការស្ដារបរិស្ថានឡើងវិញ ឬទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្តជូនជនរងគ្រោះ ឬសហគមន៍តែប៉ុណ្ណោះ ។

ក្នុងករណីដែលបណ្ដឹងដែលធ្វើឡើងក្នុងគោលដៅដើម្បីទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្ត ជូនជនរងគ្រោះ ឬសហគមន៍ ត្រូវមានមានភស្តុតាងបញ្ជាក់ថា បានទទួលការប្រគល់សិទ្ធិពីតំណាងសហគមន៍ ឬសហគមន៍ ។

**មាត្រា១០៤៣ ._** ភាពអាចទទួលយកបាននៃបណ្ដឹងរបស់សមាគម ឬអង្គការ

ក្នុងករណីដែលបណ្ដឹងដែលធ្វើឡើង ដូចមានចែងក្នុងមាត្រា១០៣៥ ខាងលើនេះ បណ្ដឹងរបស់សមាគម ឬអង្គការទាំងនោះ អាចទទួលយកបាន លុះត្រាតែមានភស្តុតាងដែលបញ្ជាក់ថា បានទទួលការយល់ព្រមពីជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់នៃជននេះ ឬសហគមន៍ ឬតំណាងសហគមន៍នេះ ចំពោះការទាមទារសំណងផ្នែករដ្ឋប្បវេណី ។

បណ្ដឹងរបស់សមាគម ឬអង្គការ ដែលមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចធ្វើទៅបានដោយពុំចាំបាច់មានភស្តុតាងដែលបញ្ជាក់ថា បានទទួលការយល់ព្រមពីជនរងគ្រោះ ឬ សហគមន៍ ឬតំណាងសហគមន៍ឡើយ នៅក្នុងករណីដែលបណ្ដឹងនោះធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យមានការបញ្ឈប់ ឬទប់ស្កាត់សកម្មភាពណាមួយ ឬទាមទារឱ្យមានកិច្ចការពារបរិស្ថាន អភិរក្សជីវៈចម្រុះ ឬការស្ដារបរិស្ថានឡើងវិញ ដើម្បីបម្រើផលប្រយោជន៍សាធារណៈទូទៅ ។

**មាត្រា១០៤៤ ._** បណ្ដឹងបរិស្ថាន និងធនធានធម្មជាតិដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធអាចប្រើប្រាស់សិទ្ធិក្នុងការធ្វើសកម្មភាពប្ដឹងទាមទារសំណងការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ឬស្ដារបរិស្ថានឡើងវិញ ឬប្ដឹងប្រឆាំងដើម្បីបញ្ឈប់ ឬទប់ស្កាត់សកម្មភាពណាមួយ ដែលបង្កផលប៉ះ

ពាល់ ឬការបំពុលបរិស្ថាន និងធនធានធម្មជាតិ ឬមិនអនុវត្តបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ទៅស្ថាប័ន ឬតុលាការមានសមត្ថកិច្ចបាន ។

## ជំពូកទី៣
## ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

**មាត្រា១០៤៥ ._** គោលបំណងនៃការដោះស្រាយបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ មានគោលបំណងកំណត់អំពីវិធានដើម្បីដោះស្រាយបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមានលក្ខណៈរដ្ឋប្បវេណីក្រៅប្រព័ន្ធតុលាការ ។

**មាត្រា១០៤៦ ._** វិសាលភាពនៃការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការចំពោះបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ មានវិសាលភាពអនុវត្តលើវិវាទបរិស្ថាន និងធនធានធម្មជាតិ ទៅលើបណ្ដឹងទាមទារ ដូចខាងក្រោម ៖

១- ការសងសំណងការខូចខាត ។

២- ការស្ដារការខូចខាតបរិស្ថានឡើងវិញ ។

៣- ការកំណត់ពីវិធានការដើម្បីធានាថានឹងមិនបង្កការបំពុលបរិស្ថាន ឬការធ្វើឱ្យខូចខាតបរិស្ថានសាជាថ្មីឡើងវិញដោយអ្នកបង្ក ។

៤- កំណត់វិធានការទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមាន ដែលកើតមានចំពោះបរិស្ថាន និងធនធានធម្មជាតិ ។

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ក្រៅប្រព័ន្ធតុលាការ ចំពោះបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ ពុំមានវិសាលភាពអនុវត្តលើបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈព្រហ្មទណ្ឌ ដែលបានកំណត់ដោយក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀតឡើយ ។

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ និងគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈរដ្ឋប្បវេណី ត្រូវដោះស្រាយក្រៅប្រព័ន្ធតុលាការជាមុនសិន មុនឈានដល់ការដោះស្រាយតាមផ្លូវតុលាការ ។

**មាត្រា១០៤៧** ._ ការដោះស្រាយវិវាទប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

បណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដែលកើតចេញពីសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ក្រោមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានផ្សេងទៀត ត្រូវស្ថិតក្រោមសមត្ថកិច្ចដោះស្រាយរបស់គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន  និងធនធានធម្មជាតិ ។

**មាត្រា១០៤៨** ._ គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

ត្រូវបង្កើតឱ្យមានគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិមួយ ដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈជាបណ្តឹងរដ្ឋប្បវេណីនៅសាលាឃុំ សង្កាត់របស់ខ្លួន ។

ការរៀបចំថវិកាសម្រាប់ដំណើរការលើសេវាកម្មដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ។

**មាត្រា១០៤៩** ._ សមត្ថកិច្ចរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

គណៈកម្មាធិការសន្ទានកម្មបបរិស្ថានថ្នាក់ឃុំ សង្កាត់ មានសមត្ថកិច្ចដូចខាងក្រោម ៖

១- ទទួលពាក្យបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ។

២- បញ្ជូនបន្តនូវបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ទៅកាន់អង្គភាព ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ឬគណៈកម្មាធិការជាតិដោះ

ស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ក្នុងករណីដែលបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ មិនអាចដោះស្រាយបាននៅដំណាក់កាលសន្ធានកម្ម ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

៣- បញ្ជូនបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ទៅកាន់គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ជាសមត្ថកិច្ច ឬតាមការស្នើសុំរបស់ភាគី ក្នុងករណីដែលភាគី មិនអាចផ្សះផ្សាគ្នាបាន ។

៤- ផ្តល់សេវាពិគ្រោះយោបល់វិវាទបរិស្ថាន និងធនធានធម្មជាតិ និងរក្សាការសម្ងាត់ ។

៥- ធ្វើការចុះពិនិត្យទីតាំងទំនាស់ ។

៦- ទទួលដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈរដ្ឋប្បវេណី។

៧- ធ្វើការផ្សះផ្សាវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

៨- រៀបចំកិច្ចព្រមព្រៀងតាមការឯកភាពរបស់គូភាគីវិវាទ និងតាមដានការអនុវត្តកិច្ចព្រមព្រៀងសះជា ។

៩- រក្សាទុកកំណត់ហេតុ ឬឯកសារ នៃដំណើរការរបស់គណៈកម្មាធិការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ដូចជាសំណុំបែបបទ កិច្ចព្រមព្រៀងសះជានានា ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

១០- បញ្ជូនសំណុំរឿង និងកិច្ចព្រមព្រៀងសះជាទៅគណៈកម្មាធិការជាតិដោះស្រាយវិវាទ ក្នុងករណីដែលគូភាគីមានវិវាទមិនអនុវត្តតាមកិច្ចព្រមព្រៀងសះជាដោយគណៈកម្មាធិការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

គណៈកម្មាធិការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មិនអាចធ្វើការផ្សះផ្សាទៅលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិណាមួយ ដែលបាន ឬកំពុងដោះស្រាយ ស្របតាមនីតិវិធីក្រោមច្បាប់ដែលនៅជាធរមានកន្លងមកឡើយ ទោះបីជាបណ្តឹងនោះស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់គណៈកម្មាធិការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិរបស់ខ្លួនក៏ដោយ ។

ដំណើរការរៀបចំ និងនីតិវិធីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិរបស់គណៈកម្មាធិការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ និងក្រសួង ស្ថាប័នទទួលបន្ទុកយុត្តិធម៌ តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១០៥០ .**_ សមាសភាពនៃគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មានសមាសភាពសមាជិកចំនួន៣ (បី) រូប ។

គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់នីមួយៗ អាចជ្រើសរើសអ្នកជំនាញការបច្ចេសទេសមួយរូប ឬច្រើន ធ្វើជាអ្នកប្រឹក្សាយោបល់ផ្នែកបច្ចេកទេស តាមការចាំបាច់អាស្រ័យតាមលក្ខណៈស្មុគស្មាញនៃវិវាទ ។ អ្នកជំនាញបច្ចេកទេសត្រូវបំពេញការងារត្រឹមតែតាមការស្នើសុំរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថានថ្នាក់ឃុំ សង្កាត់ និងផ្តល់សេចក្តីសន្និដ្ឋានបច្ចេកទេសជូនគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងភាគីតែប៉ុណ្ណោះ ។

នីតិវិធីនៃការជ្រើសរើស និងរៀបចំបញ្ជីឈ្មោះអ្នកជំនាញបច្ចេកទេសបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

នីតិវិធីនៃការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១០៥១ .**_ រយៈពេលនៃដំណើរការផ្សះផ្សារបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មានរយៈពេលយ៉ាងយូរបំផុត៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីធ្វើដំណើរការផ្សះផ្សាវិវាទបរិស្ថាន និងធនធានធម្មជាតិ ។ រយៈពេលនេះអាចពន្យារពេលបាន ក្នុងករណីដែលគូភាគីវិវាទបានព្រមព្រៀង តាមការស្នើសុំរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

ក្នុងករណីដែលដំណើរការនៃការផ្សះផ្សារបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មិនអាចសម្រេចទៅបានក្នុងរយៈពេល ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះទេ គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវបញ្ជូនបណ្តឹងនេះបន្តទៅគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដើម្បីធ្វើចំណាត់ការបន្ត យ៉ាងយូរបំផុតក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ។

**មាត្រា១០៥២**._ ការបញ្ចប់នៃដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

ដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានបញ្ចប់ដោយមូលហេតុ ដូចខាងក្រោម ៖

១- គូភាគីបានឯកភាពគ្នាបញ្ចប់នីតិវិធីនៃដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

២- ភាគីណាមួយមិនឯកភាព ឬមិនសហការក្នុងការដោះស្រាយវិវាទតាមនីតិវិធីសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

៣- គូភាគីមិនអាចឈានដល់ការឯកភាពគ្នាលើវិវាទបរិស្ថាន និងធនធានធម្មជាតិ ក្នុងរយៈពេល ៩៥ (សែសិបប្រាំ) ថ្ងៃ ឬក្នុងរយៈពេលដែលបានពន្យារតាមការព្រមព្រៀងរបស់គូភាគី បានកន្លងផុតទៅ ។

៤- គូភាគីបានឯកភាពលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ តាមការផ្សះផ្សារបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

កិច្ចព្រមព្រៀងសះជារបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មិនចងកាតព្វកិច្ចផ្លូវច្បាប់ឡើយ ។

**មាត្រា១០៥៣**._ ការប្តឹងជំទាស់ទៅនឹងកិច្ចព្រមព្រៀងសះជា របស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

សាធារណជនដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិប្តឹងជំទាស់នឹងកិច្ចព្រមព្រៀងសះជារបស់កម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ទៅគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធានធម្មជាតិ ដើម្បីពិនិត្យឡើងវិញនូវអង្គច្បាប់ និងនីតិវិធីទាក់ទងនឹងដំណើរការនៃការផ្សះផ្សា ។

**មាត្រា១០៥៤**._ ដំណោះស្រាយរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធានធម្មជាតិថ្នាក់ឃុំ សង្កាត់

កិច្ចព្រមព្រៀងនីមួយៗដែលត្រូវបានផ្សះផ្សាដោយគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ដោយមានការឯកភាពពីភាគីចូលរួម ត្រូវបញ្ចូលចំណុចមួយចំនួនដូចខាងក្រោម ៖

១- កំណត់អំពីប្រាក់សំណងសម្រាប់ការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ។

២- កំណត់អំពីវិធីសាស្ត្រនៅក្នុងការស្តារបរិស្ថាន និងធនធានធម្មជាតិឡើងវិញនៃការខូចខាតដែលបានកើតឡើង ។

៣- កំណត់អំពីវិធានការដើម្បីធានាថានឹងមិនមានគ្រោះថ្នាក់បន្ថែមទៀតទេ ចំពោះបរិស្ថាន និងធនធានធម្មជាតិ ។

៤- កំណត់អំពីវិធានដើម្បីទប់ស្កាត់ការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ។

ការវាយតម្លៃលើការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តស្របតាមមាត្រា ១០១៥ នៃក្រមនេះ ។

**មាត្រា១០៥៥** ._ គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការ នៅក្នុងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ។

គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិនេះ មានក្រុមប្រឹក្សាពីរដាច់ដោយឡែកពីគ្នា ។ ក្រុមប្រឹក្សាជាតិទី១ ដើរតួនាទីជាក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិដែលទទួលបន្ទុកដោះស្រាយបណ្តឹង ឬវិវាទបរិស្ថាន និងធនធានធម្មជាតិ ដែលបញ្ជូនមកពីគណៈកម្មាធិការសន្ទានកម្មថ្នាក់ឃុំ សង្កាត់ ។ ក្រុមប្រឹក្សាជាតិទី២ ដើរតួនាទីជាក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃនីតិវិធីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិរបស់គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋាន

គតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកយុត្តិធម៌ តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១០៥៦** ._ ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

សមាសភាពនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិខាងលើនេះ មានដូចខាងក្រោម ៖

១- មន្ត្រីជំនាញ នៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ជាប្រធាន ។

២- មន្ត្រីជំនាញ នៃក្រសួង ស្ថាប័នពាក់ព័ន្ធនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ជាសមាជិក ។

៣- ក្រុមអ្នកជំនាញបច្ចេកទេសវិទ្យាសាស្ត្រ តាមការចាំបាច់ ជាសមាជិក ។

៤- អង្គការសង្គមស៊ីវិលជាតិ ដែលធ្វើការពាក់ព័ន្ធបរិស្ថាន និងធនធានធម្មជាតិ តាមការចាំបាច់ ជាសមាជិក ។

សមាជិក នៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានអាណត្តិ៥ (ប្រាំ) ឆ្នាំ ត្រូវបានតែងតាំងសាជាថ្មី លើកលែងតែមានការលាលែង មរណភាព ដកហូតតំណែងដោយកំហុសណាមួយ ដែលមានចែងក្នុងក្រមប្រតិបត្តិ និងបទបញ្ជាផ្ទៃក្នុង ។

នីតិវិធី នៃការរៀបចំជ្រើសរើស និងកំណត់លក្ខណៈសម្បត្តិសន្ទានការីបរិស្ថាន និងធនធានធម្មជាតិនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ។

**មាត្រា១០៥៧** ._ សមត្ថកិច្ចនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានសមត្ថកិច្ចដូចខាងក្រោម ៖

១- ដោះស្រាយបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ ដែលបានបញ្ជូនមកពីគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

២- ដោះស្រាយពាក្យបណ្ដឹងរបស់ភាគីដែលមិនអាចផ្សះផ្សាបាន តាមរយៈគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

៣- បង្គាប់ឱ្យគូភាគីដាក់ ឬបង្ហាញឯកសារ ព័ត៌មានដែលពាក់ព័ន្ធនឹងចំណុចវិវាទ ។

៤- ស៊ើបអង្កេត និងសាកសួរព័ត៌មានពាក់ព័ន្ធនឹងវិវាទ ។

៥- ស្នើសុំជំនួយពីអ្នកជំនាញការផ្សេងៗពីក្រសួង ស្ថាប័ននានា ។

៦- ស្នើសុំឱ្យមានការសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

៧- ធ្វើការផ្សះផ្សា និងរៀបចំកិច្ចព្រមព្រៀងសះជា ដោយមានការឯកភាពពីគូភាគី លើបណ្ដឹងពាក់ព័ន្ធនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

៨- ចេញរូបមន្តអនុវត្តបញ្ជាក់លើកិច្ចព្រមព្រៀងសះជា ទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីដែលគ្មានការប្ដឹងជំទាស់នឹងកិច្ចព្រមព្រៀងសះជា ។

៩- រៀបចំ និងបង្កើតបទបញ្ជាផ្ទៃក្នុង និងក្រមប្រតិបត្តិ ។

**មាត្រា១០៥៨ ._** រយៈពេលនៃដំណើរការផ្សះផ្សារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានរយៈពេលយ៉ាងយូរបំផុត ៦ (ប្រាំមួយ) ខែ ដើម្បីដំណើរការផ្សះផ្សាវិវាទ ដែលរយៈពេលនេះគិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង ។

រយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចពន្យារពេលបាន ដោយមានការព្រមព្រៀងពីគូភាគី តាមការស្នើសុំរបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីដែលដំណើរការនៃការផ្សះផ្សារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មិនអាចសម្រេចបានក្នុងរយៈពេល ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះទេ ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬគូភាគីអាចប្ដឹងតវ៉ាទៅសាលាដំបូងដែលមានសមត្ថកិច្ច ដើម្បីដោះស្រាយទៅតាមនីតិវិធីច្បាប់ជាធរមាន ។ តុលាការមានសមត្ថកិច្ច ពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់ ដើម្បីចេញសេចក្ដីសម្រេច ។

**មាត្រា១០៥៩ ._** ការបញ្ចប់ដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានបញ្ចប់ដោយមូលហេតុដូចខាងក្រោម ៖

១- គូភាគីបានឯកភាពគ្នាបញ្ចប់នីតិវិធីនៃដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

២- ភាគីណាមួយមិនឯកភាព ឬមិនសហការក្នុងការដោះស្រាយតាមនីតិវិធីសន្ទានកម្មបរិស្ថាន ។

៣- គូភាគីមិនអាចឈានដល់ការឯកភាពគ្នាលើវិវាទបរិស្ថាន និងធនធានធម្មជាតិ ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ ឬក្នុងរយៈពេលដែលបានពន្យារពេល តាមការព្រមព្រៀងរបស់គូភាគី បានកន្លងផុតទៅ ។

៤- គូភាគីបានឯកភាពលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ តាមការផ្សះផ្សារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន ។

កិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវចងកាតព្វកិច្ចផ្លូវច្បាប់ ។

**មាត្រា១០៦០ .**_ ការចំណាយលើការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដោយគូភាគី

ក្នុងករណីដែលវិវាទបរិស្ថាន និងធនធានធម្មជាតិពាក់ព័ន្ធនឹងផលប្រយោជន៍បុគ្គលឯកជន គូភាគីនៃវិវាទត្រូវទទួលបន្ទុកលើការចំណាយ ចំពោះដំណើរការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិនេះ លើកលែងតែវិវាទនោះប្តឹងឡើងដោយអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ឬសាធារណជនទូទៅ ដើម្បីការពារផលប្រយោជន៍សាធារណៈ ឬសហគមន៍ ដែលត្រូវប្រើប្រាស់មូលនិធិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិខាងលើ ។

នីតិវិធីនៃការកំណត់ប្រភេទចំណាយ និងចំនួនទឹកប្រាក់ដែលត្រូវទូទាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ដោយពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា១០៦១ .**_ ឯករាជ្យភាព និងអព្យាក្រឹត្យភាពនៃសន្ទានការីបរិស្ថាន

សន្ធានការីបរិស្ថាន និងធនធនធានធម្មជាតិ ដែលបានទទួលការតែងតាំង ត្រូវបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងអព្យាក្រឹត្យ ក្នុងព្រំដែននៃវិសាលភាពសមត្ថកិច្ចរបស់ខ្លួន តាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា១០៦២** ._ កិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ

កិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានទម្រង់លាយលក្ខណ៍អក្សរ និងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា១០៦៣** ._ ការប្ដឹងជំទាស់ទៅនឹងកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន

គូភាគីវិវាទ មានសិទ្ធិប្ដឹងជំទាស់ទៅតុលាការមានសមត្ថកិច្ច ដើម្បីឱ្យពិនិត្យឡើងវិញលើអង្គច្បាប់ និងនីតិវិធីលើកិច្ចព្រមព្រៀងសះជា របស់គណៈកម្មាធិការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ដែលសម្របសម្រួលដោយក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពេលដែលដំណើរការសន្ធានកម្មបានបញ្ចប់ ។

ក្នុងករណីដែលគ្មានបណ្ដឹងជំទាស់ដែលធ្វើឡើង ក្នុងរយៈពេល ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះទេ ត្រូវចាត់ទុកថាកិច្ចព្រមព្រៀងសះជានេះចូលជាស្ថាពរ ហើយមានតម្លៃដូចកំណត់ហេតុសះជា ដែលក្លាយជាលិខិតអនុវត្តដោយបង្ខំ តាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា១០៦៤** ._ ដំណោះស្រាយលើវិធានការស្តារ និងជួសជុលបរិស្ថានឡើងវិញ

ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវជ្រើសរើសដំណោះស្រាយ និងវិធានការ ដែលមានចែងក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិនេះ ។

ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន ឬក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន ត្រូវពិចារណានូវជម្រើសជាអាទិភាព លើបញ្ហានៃការស្តារ និងជួសជុលបរិស្ថានឡើងវិញ ។

**មាត្រា១០៦៥** ._ អានុភាពនៃកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ

កិច្ចព្រមព្រៀងសះជារបស់ប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានតម្លៃដូចកំណត់ហេតុសះជា ដែលក្លាយជាលិខិតអនុវត្តដោយបង្ខំតាមផ្លូវតុលាការដូចមានចែងតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ក្នុងករណីដែលភាគីវិវាទមិនបានអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងសះជា ដោយស្ម័គ្រចិត្ត ។

**មាត្រា១០៦៦** ._ ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

សមាសភាពនៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិខាងលើនេះ មានដូចខាងក្រោម ៖

១- រដ្ឋមន្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង ជាប្រធាន ។

២- រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬតំណាង ជាអនុប្រធាន ។

៣- រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធពាក់ព័ន្ធនឹងវិវាទបញ្ហាបរិស្ថាន និងធនធានធម្មជាតិ ឬតំណាង ជាសមាជិក ។

៤- ក្រុមអ្នកជំនាញបច្ចេកទេសវិទ្យាសាស្ត្រ សម្រាប់ពិគ្រោះយោបល់បច្ចេកទេស តាមការចាំបាច់ ឬតាមការស្នើសុំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ជាសមាជិក ។

៥- សមាជិកផ្សេងតាមការចាំបាច់ អាស្រ័យតាមករណីវិវាទ ជាសមាជិក ។

សមាជិកនៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ មានអាណត្តិ៥ (ប្រាំ) ឆ្នាំ ត្រូវបានតែងតាំងសាជាថ្មី លើកលែងតែមានការលាលែង មរណភាព ដកហូតតំណែង ដោយកំហុសណាមួយ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ឬដោយបញ្ញត្តិច្បាប់ហាមឃាត់ ។

**មាត្រា១០៦៧** ._ សមត្ថកិច្ចក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ មានសមត្ថកិច្ចត្រួតពិនិត្យ និងចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធាន

ធម្មជាតិ ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ អាចជាសេចក្តីសម្រេចបដិសេធ ឬលុបចោល ឬទទួលស្គាល់ ឬកែប្រែ សេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធានធម្មជាតិ ឬសម្រេចលើបណ្តឹងទាមទារសំណងការខូចខាតបរិស្ថានរបស់ភាគីទទួលរងផលប៉ះពាល់ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។ សេចក្តីសម្រេចនេះ ត្រូវធ្វើឡើងជាទម្រង់លាយលក្ខណ៍អក្សរ និងមានបញ្ជាក់ហេតុផលឱ្យបានត្រឹមត្រូវតាមច្បាប់ ។

ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនដែលមានរយៈពេលយ៉ាងយូរបំផុត៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹងតវ៉ា ។

រយៈពេលដូចមានចែងក្នុងវាក្យខណ្ឌខាងលើនេះ អាចពន្យារពេលបានយ៉ាងយូរបំផុតមិនឱ្យលើសពី៣ (បី) ខែ ដោយមូលហេតុភាពស្មុគស្មាញនៃបច្ចេកទេសវិទ្យាសាស្ត្រ នៃសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិនោះ ។

**មាត្រា១០៦៨ ._** នីតិវិធីនៃការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើឡើងដោយឆ្លងកាត់សវនាការជាសាធារណៈ ។ ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយមតិភាគច្រើនក្នុងចំណោមសមាជិកវត្តមាន ។ សមាជិកក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវតែមានយ៉ាងតិច ៣ (បី) រូប ឬច្រើនរូប ប៉ុន្តែត្រូវតែជាចំនួនសេស ដែលចូលរួមក្នុងការធ្វើសវនាការជាសាធារណៈអាស្រ័យទៅតាមករណីប្រភេទ នៃបណ្តឹងលើសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិនីមួយៗ ដែលក្នុងនោះសមាជិកមកពីតំណាងគណៈរដ្ឋមន្ត្រីជាប្រធានដឹកនាំសវនាការជាសាធារណៈ ។

ការពិភាក្សាសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើជាសម្ងាត់ ប៉ុន្តែការប្រកាសសេចក្តីសម្រេចរបស់ខ្លួន ត្រូវធ្វើឡើងជាសាធារណៈ និងដោយមានសំអាងហេតុត្រឹមត្រូវនៅក្នុងសាលសវនាការសាធារណៈ ។

**មាត្រា១០៦៩ ._** ការប្តឹងជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ក្នុងករណីដែលគូភាគីវិវាទមិនយល់ព្រមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ភាគីវិវាទមានសិទ្ធិប្តឹងជំទាស់ទៅសាលាដំបូងឱ្យពិនិត្យអង្គហេតុ និងអង្គច្បាប់ និងសម្រេចឡើងវិញ ទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ឬនីតិវិធីរដ្ឋបាលជាធរមាន ក្នុងករណីមានច្បាប់នីតិវិធីរដ្ឋបាល ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចនោះ ។

ក្នុងករណីគ្មានបណ្តឹងជំទាស់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃខាងលើនេះ ត្រូវចាត់ទុកថាសេចក្តីសម្រេចនេះចូលជាស្ថាពរ ហើយមានអានុភាពអនុវត្តភ្លាម ។

**មាត្រា១០៧០ ._** កិច្ចសហការជាមួយគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហការ សម្របសម្រួល និងផ្តល់ជំនួយដល់ការអនុវត្តតួនាទីរបស់គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន ក្នុងករណីមានសំណើពីគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១០៧១ ._** ឯករាជ្យភាព និងអព្យាក្រឹត្យភាព នៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន

សមាជិកនៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដែលត្រូវបានទទួលការតែងតាំង ត្រូវបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងអព្យាក្រឹត្យ ក្នុងព្រំដែននៃវិសាលភាពសមត្ថកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

ក្នុងករណីដែលសមាជិកណាមួយបំពានមុខងាររបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ហើយប្រព្រឹត្តអំពើណាមួយដែលខុសនឹងច្បាប់ជាធរមាន សមាជិកនោះត្រូវទទួលខុសត្រូវទណ្ឌកម្មរដ្ឋបាល និង/ឬ ព្រហ្មទណ្ឌ ទៅតាមប្រភេទនៃកំហុសដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ជាធរមាន ។

## ជំពូកទី៤
## ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ក្នុងប្រព័ន្ធតុលាការ

**មាត្រា១០៧២ ._** តុលាការជំនាញបរិស្ថាន

ត្រូវមានតុលាការជំនាញបរិស្ថាននៅសាលាដំបូងរាជធានី ខេត្ត និងសភាជំនាញបរិស្ថាននៅសាលាឧទ្ធរណ៍ និងតុលាការកំពូល ដើម្បីទទួលបន្ទុកដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីមិនទាន់មានតុលាការជំនាញបរិស្ថាន តុលាការនៃនីតិរូប មានសមត្ថកិច្ចដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងនីតិវិធីច្បាប់ជាធរមាន ។

**មាត្រា១០៧៣ ._** សមត្ថកិច្ចរបស់តុលាការជំនាញបរិស្ថានលើវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានចរិតលក្ខណៈរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ

តុលាការជំនាញបរិស្ថានត្រូវចេញសេចក្តីសម្រេចចំពោះបណ្តឹងជំទាស់ ដែលបញ្ជូនមកដោយក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិ នៃក្រមនេះ និងនីតិវិធីរដ្ឋប្បវេណីជាធរមាន ។ តុលាការ មានសមត្ថកិច្ច ពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់ ។

ក្នុងករណីមានបណ្តឹងពាក់ព័ន្ធវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ដែលកំណត់ដោយក្រមនេះ និងបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត ការដំណើរការនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌនេះ ត្រូវអនុលោមតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

ការអនុវត្តនីតិវិធីក្នុងការដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានបទប្បញ្ញត្តិពិសេសដែលកំណត់ដោយក្រមនេះ ។

**មាត្រា១០៧៤ ._** ការដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

តុលាការរដ្ឋបាល ត្រូវចេញសេចក្តីសម្រេចចំពោះបណ្តឹងជំទាស់ដែលបញ្ជូនមកដោយគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ និងនីតិវិធីរដ្ឋបាល ។ តុលាការ មានសមត្ថកិច្ច ពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់ ។

ក្នុងករណីមិនទាន់មានតុលាការរដ្ឋបាល និងនីតិវិធីដោះស្រាយវិវាទរដ្ឋបាល តុលាការជំនាញបរិស្ថាន សភាជំនាញបរិស្ថាន មានសមត្ថកិច្ចដោះស្រាយបណ្តឹងជំទាស់ ដូចមានចែងនៅក្នុងកថា

ខណ្ឌខាងលើ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ និងនីតិវិធីរដ្ឋប្បវេណី ឬនីតិវិធីរដ្ឋបាលជាធរមាន ។

**មាត្រា១០៧៥**._ បណ្ដឹងជំទាស់ប្រឆាំងកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

សាធារណជនដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិប្ដឹងជំទាស់នឹងកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ទៅតុលាការជំនាញបរិស្ថាននៃសាលាដំបូង ដើម្បីពិនិត្យឡើងវិញនូវអង្គច្បាប់ និងនីតិវិធី ។

បុគ្គលគ្រប់រូបដែលមិនពេញចិត្តសាលក្រមរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង មានសិទ្ធិប្ដឹងឧទ្ធរណ៍នឹងសាលក្រម ទៅតុលាការជាន់ខ្ពស់បាន ។ ចំពោះបែបបទ និងនីតិវិធីនៃការប្ដឹង ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា១០៧៦**._ សមត្ថកិច្ចរបស់តុលាការជំនាញបរិស្ថានលើវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានចរិតលក្ខណៈរដ្ឋបាល

តុលាការជំនាញបរិស្ថាន មានសមត្ថកិច្ចពិនិត្យ ដូចខាងក្រោម ៖

១- អង្គហេតុ និងអង្គច្បាប់ ។

២- ពិចារណា វិធានការនិងដំណោះស្រាយនានាដែលបានកំណត់ក្នុងក្រមនេះ ត្រូវបានបញ្ចូលក្នុងកិច្ចព្រមព្រៀងសះជា ។

៣- ពិចារណាលើការស្ដារ និងជួសជុលបរិស្ថាន និងធនធានធម្មជាតិជាអាទិភាព ។

៤- ដំណោះស្រាយ និងវិធានការនានា ត្រូវស្របនឹងគោលការណ៍ទូទៅ ដូចមានចែងក្នុងក្រមនេះ ។

៥- កម្មវត្ថុវិវាទបរិស្ថាន និងធនធានធម្មជាតិ អាចដោះស្រាយតាមរយៈយន្តការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

៦- ខ្លឹមសារនៃកិច្ចព្រមព្រៀងសះជាបរិស្ថាន និងធនធានធម្មជាតិផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អរបស់សង្គម និងបទប្បញ្ញត្តិច្បាប់ផ្សេងៗទៀត ។

៧- ភាពត្រឹមត្រូវនៃនីតិវិធីនៃសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

៨- សង្គតិភាពទៅនឹងគោលនយោបាយសាធារណៈ របស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១០៧៧** ._ ការសម្រេចសេចក្តីរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង

តុលាការជំនាញបរិស្ថាននៃសាលាដំបូង ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងជំទាស់ ចំពោះកិច្ចព្រមព្រៀងសះជា របស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដោយសាលក្រមក្នុងរយៈពេលយ៉ាងយូរបំផុត៣ (បី) ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

រយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើនេះ មិនអាចពន្យារពេលបានឡើយ ។

**មាត្រា១០៧៨** ._ បណ្តឹងជំទាស់ប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

គូភាគី ឬសាធារណជនដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិប្តឹងជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិទៅតុលាការជំនាញបរិស្ថាននៃសាលាដំបូង ដើម្បីពិនិត្យឡើងវិញអំពីនីត្យានុកូលភាពនៃសេចក្តីសម្រេច ។

បុគ្គលគ្រប់រូបដែលមិនពេញចិត្តសាលក្រមរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង មានសិទ្ធិប្តឹងឧទ្ធរណ៍នឹងសាលក្រម ទៅតុលាការជាន់ខ្ពស់បាន ។ ចំពោះបែបបទ និងនីតិវិធីនៃការប្តឹង ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា១០៧៩** ._ សមត្ថកិច្ចពិនិត្យនីត្យានុកូលភាពនៃសេចក្តីសម្រេច ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

តុលាការជំនាញបរិស្ថាន មានសមត្ថកិច្ចពិនិត្យលើបញ្ហានីត្យានុកូលភាពដូចខាងក្រោម ៖

១- សុពលភាពនៃសេចក្តីសម្រេចរដ្ឋបាល មានជាអាទិ៍ សមត្ថកិច្ចចេញសេចក្តីសម្រេច វិការៈនៃទម្រង់ ឬនីតិវិធីនៃការចេញសេចក្តីសម្រេច ឬរំលោភអំណាច ។

២- ខ្លឹមសារជាសារវន្តនៃសេចក្តីសម្រេចដែលរំលោភគោលការណ៍ទូទៅនៃច្បាប់រួមមាន ការរំលោភច្បាប់ ឬបទបញ្ញាផ្សេងៗ ការភាន់ច្រឡំផ្លូវច្បាប់ អង្គហេតុ ឬមូលហេតុនៃការចេញសេចក្តីសម្រេច ជាអាទិ៍ ។

ការពិនិត្យនីត្យានុកូលភាពនៃសេចក្តីសម្រេច ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវស្របទៅនឹងបទប្បញ្ញត្តិនៃក្រមនេះ និងបទដ្ឋានគតិយុត្តផ្សេងៗ ។

**មាត្រា១០៨០** ._ រយៈពេលប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសារទុក្ខ ត្រូវធ្វើឡើងក្នុងអំឡុងពេល១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលបានការបញ្ជូនលិខិតសាលក្រម ឬសាលដីកា ។ នីតិវិធីនៃការដោះស្រាយបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសារទុក្ខ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានបទប្បញ្ញត្តិពិសេសចែងក្នុងក្រមនេះ ។

**មាត្រា១០៨១** ._ បណ្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង

សាលាឧទ្ធរណ៍ ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ លើសាលក្រមតុលាការជំនាញបរិស្ថាននៃសាលាដំបូង ដោយសាលដីកា ក្នុងរយៈពេលយ៉ាងយូរបំផុត៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹងឧទ្ធរណ៍ ។

រយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ មិនអាចពន្យារបានឡើយ ។

**មាត្រា១០៨២** ._ បណ្តឹងសារទុក្ខនឹងសាលដីការបស់សាលាឧទ្ធរណ៍

តុលាការកំពូល ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងសារទុក្ខ លើសាលដីការបស់សាលាឧទ្ធរណ៍ដោយសាលដីកា ក្នុងរយៈពេលយ៉ាងយូរបំផុត៩ (ប្រាំបួន) ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹងសារទុក្ខ ។ រយៈពេល៩ (ប្រាំបួន) ខែនេះ មិនអាចពន្យារបានឡើយ ។

សម្រាប់បណ្តឹងដែលមានគោលបំណងទាមទារសំណងផ្នែករដ្ឋប្បវេណី ឬសំណងខូចខាតបរិស្ថាន និងធនធានធម្មជាតិ ឬបណ្តឹងទាក់ទងនឹងវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ តុលាការកំពូល ត្រូវចេញសេចក្តីសម្រេចចុងក្រោយ ដោយមិនបញ្ជូនត្រឡប់មកឱ្យសាលាឧទ្ធរណ៍ធ្វើចំណាត់ការឡើងវិញទៅតាមនីតិវិធីដែលបានកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណីជាធរមានទេ លើកលែងតែបណ្តឹងពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិតលក្ខណៈព្រហ្មទណ្ឌ ទើបអាចបញ្ជូនត្រឡប់មកសាលាឧទ្ធរណ៍ឱ្យជំនុំជម្រះឡើងវិញបាន ។

**មាត្រា១០៨៣ .**_ នីតិវិធីនៃបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលរងការប្ដឹងចោទប្រកាន់ដោយមិនត្រឹមត្រូវពីរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើឱ្យទទួលរងផលប៉ះពាល់ដូចមានចែងក្នុងមាត្រា១០៨០ អាចដាក់ពាក្យបណ្ដឹងតប ដើម្បីទាមទារសំណងរដ្ឋប្បវេណីទៅតុលាការមានសមត្ថកិច្ច ។

**មាត្រា១០៨៤ .**_ លក្ខខណ្ឌនៃការទទួលយកបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈ

តុលាការជំនាញបរិស្ថាន ត្រូវត្រួតពិនិត្យលក្ខខណ្ឌនៃការទទួលយកបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈ ដូចខាងក្រោម ៖

១- សកម្មភាពនៃបណ្ដឹងតប មិនមានចេតនាក្នុងការបៀតបៀន ឬរារាំង ឬគាបសង្កត់ដល់ការចូលរួមរបស់សាធារណជនលើសកម្មភាពបណ្ដឹង ។

២- គ្មានភស្តុតាងត្រឹមត្រូវ ឬច្បាស់លាស់ថាបណ្ដឹងរបស់សាធារណជនជាបណ្ដឹងដែលមានចេតនាបរិហារកេរ្តិ៍ ឬរារាំង ជ្រៀតជ្រែកដោយគំនិតទុច្ចរិតដល់ម្ចាស់បណ្ដឹងតប ។

តុលាការជំនាញបរិស្ថាន ត្រូវសម្រេចលើកបណ្ដឹងចោលដោយដីកាសម្រេចក្នុងករណីដែលបណ្ដឹងពុំគោរពតាមលក្ខខណ្ឌ ដូចចែងក្នុងកថាខណ្ឌខាងលើនេះ ។

ភាគីដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចខាងលើនេះ មានសិទ្ធិប្ដឹងជំទាស់ទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។ ការសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់សាលាឧទ្ធរណ៍ បិទផ្លូវតវ៉ា ។

នីតិវិធីនៃការដោះស្រាយបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងការចូលរួមជាសាធារណៈ ត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានបទប្បញ្ញត្តិចែងជាពិសេសក្នុងក្រមនេះ ។

**មាត្រា១០៨៥ .**_ នីតិវិធីនៃការអនុវត្តសេចក្ដីសម្រេចរបស់តុលាការ

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ ត្រូវអនុវត្តតាមនីតិវិធីនៃការអនុវត្តដោយបង្ខំ ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

ការអនុវត្តសេចក្ដីសម្រេចនៃនីតិវិធីចាត់ចែងរក្សាការពារ ត្រូវអនុវត្តតាមនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះការចាត់ចែងរក្សាការពារ ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងសងជាប្រាក់ ជាការអនុវត្តដោយបង្ខំចំពោះសេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យប្រគល់វត្ថុរបី ឬបង្គាប់ឱ្យធ្វើ ឬមិនធ្វើសកម្មភាពណាមួយ ហើយត្រូវអនុវត្តទៅតាមនីតិវិធីអនុវត្តដោយបង្ខំ ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

## មាតិកាទី២
## ការចាត់ចែងរក្សាការពារក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា១០៨៦** ._ បទប្បញ្ញត្តិទូទៅ

នីតិវិធីនៃការចាត់ចែងរក្សាការពារ និងនីតិវិធីអនុវត្តរក្សាការពារ ត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានបទប្បញ្ញត្តិពិសេស ដែលមានចែងក្នុងក្រមនេះ ។

**មាត្រា១០៨៧** ._ មូលដ្ឋាននៃការសម្រេចលើពាក្យសុំដីកាសម្រេចរក្សាការពារ

តុលាការចេញសេចក្តីសម្រេចលើពាក្យសុំចេញដីការក្សាការពារ ត្រូវផ្អែកលើគោលការណ៍ទូទៅនៃក្រមបរិស្ថាន និងត្រូវពិចារណាចំណុចដូចខាងក្រោម ៖

១- មានមូលដ្ឋានច្បាប់គ្រប់គ្រាន់ដែលបង្ហាញពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលត្រូវរក្សាការពារ ។

២- មានការទទួលរងការខូចខាតដែលមិនអាចស្តារ ឬជួសជុសឡើងវិញបាន ពីអំពើដែលបានប្រព្រឹត្ត ។

៣- ផលប្រយោជន៍សាធារណៈធំជាងផលប្រយោជន៍ឯកជន ឬ ផលប្រយោជន៍រួម ឬ ផលប្រយោជន៍សម្ភូហភាពធំជាងផលប្រយោជន៍ឯកជន ។

**មាត្រា១០៨៨** ._ រយៈពេលនៃការសម្រេចសេចក្តីរបស់តុលាការ

តុលាការជំនាញបរិស្ថាន ត្រូវសម្រេចលើពាក្យសុំចេញដីកាសម្រេចរក្សាការពារ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។ ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការជំនាញបរិស្ថាន ត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលគូភាគីបានទទួលលិខិតនីតិវិធីរបស់តុលាការចាប់មានអានុភាព ។

តុលាការនៃបណ្តឹងជំទាស់ ត្រូវសម្រេចលើបណ្តឹងជំទាស់នឹងដីកាសម្រេចលើពាក្យសុំតវ៉ា នឹងដីកាសម្រេចរក្សាការពារ ឬដីកាសម្រេចលើកចោលពាក្យសុំចេញដីកាសម្រេចរក្សាការពារ ក្នុងរយៈពេលយ៉ាងយូរបំផុត ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលគូភាគីបានទទួលលិខិតនីតិវិធីរបស់តុលាការចាប់មានអានុភាព ។

**មាត្រា១០៨៩** ._ គោលការណ៍ការបញ្ជូន

នីតិវិធីនៃការបញ្ជូនត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានចែងជាពិសេសក្នុងក្រមនេះ ។

ការបញ្ជូន ត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ ក្នុងការកំណត់ពីវិធីនៃការបញ្ជូន ឬទីកន្លែងដែលត្រូវបញ្ជូន ហើយដែលចាត់ទុកថាមានអានុភាពតាមផ្លូវច្បាប់ថាគូភាគីបានទទួលដំណឹងអំពីនីតិវិធីតុលាការ ឬអ្នកដែលទទួលបន្ទុកនៃការបញ្ជូន ។

ទីកន្លែងជាអាសយដ្ឋានដែលជាលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការ ឬទីកន្លែងអាជីវកម្មរបស់នីតិបុគ្គលដែលគូភាគីបានបញ្ជាក់នៅក្នុងឯកសារជាផ្លូវការក្នុងការដាក់ពាក្យសុំ ឬពាក្យបណ្តឹង ។

**មាត្រា១០៩០** ._ ការដាក់ប្រាតិភោគ

តុលាការអាចសម្រេចឱ្យអ្នកដាក់ពាក្យសុំដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគដោយពិចារណាលើមូលហេតុ ដូចខាងក្រោម ៖

១- ពុំមានភស្តុតាង ឬមូលហេតុគ្រប់គ្រាន់ និងច្បាស់លាស់បង្ហាញពីទំហំនៃការខូចខាតបរិស្ថាន ឬផលប្រយោជន៍នៃភាគីដែលទទួលរងផលប៉ះពាល់ ។

២- លទ្ធភាពនៃធនធានសេដ្ឋកិច្ចរបស់ម្ចាស់បំណុល ។

៣- ឧត្តមភាពនៃកិច្ចការពារបរិស្ថាន ។

៤- កាលៈទេសៈផ្សេងៗទៀត ។

**មាត្រា១០៩១** ._ នីតិវិធីជំនួយផ្នែកច្បាប់ទៅវិញទៅមកផ្នែករដ្ឋប្បវេណី

នីតិវិធីនៃការអនុវត្តជំនួយផ្នែកច្បាប់ទៅវិញទៅមកផ្នែករដ្ឋប្បវេណី ត្រូវអនុវត្តតាមគោលការណ៍ទាំងឡាយ ដែលបានកំណត់ក្នុងអនុសញ្ញា ឬកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី និងច្បាប់ជាតិជាធរមាន ។

## មាតិកាទី៣
## នីតិវិធីដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិ
## ដែលមានចរិតលក្ខណៈព្រហ្មទណ្ឌ
### ជំពូកទី១
### នីតិវិធីនៃការស៊ើបអង្កេត ការស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះ

**មាត្រា១០៩២** ._ បទប្បញ្ញត្តិទូទៅ

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេត ការចោទប្រកាន់ បទល្មើសបរិស្ថាន និងធនធានធម្មជាតិ លើកលែងតែក្នុងករណីដែលមានចែងជាពិសេសក្នុងក្រមនេះ ។

**មាត្រា១០៩៣** ._ នីតិវិធីនៃការស៊ើបអង្កេត និងស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះ

នីតិវិធីនៃការស៊ើបអង្កេត ការស៊ើបសួរ និងការជំនុំជម្រះ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានចែងជាពិសេសក្នុងក្រមនេះ ។

**មាត្រា១០៩៤** ._ ចេតនាប្រព្រឹត្តបទល្មើសបរិស្ថាន និងធនធានធម្មជាតិដោយចេតនា

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងការចោទប្រកាន់បទល្មើសបរិស្ថាន និងធនធានធម្មជាតិ បទល្មើសមួយអាចកើតចេញពីលក្ខខណ្ឌដូចខាងក្រោម ៖

១- ចេទនាប្រព្រឹត្ត ឬបំណងប្រព្រឹត្ត ។

២- បានដឹងអំពីបទល្មើស ហើយគ្មានចាត់វិធានការទប់ស្កាត់ ។

៣- ការធ្វេសប្រហែស ឬខ្ជីខ្ជាក្នុងការបំពេញកាតព្វកិច្ចតាមច្បាប់កំណត់ ។

៤- មិនអនុវត្តតាមបទប្បញ្ញត្តិច្បាប់ ឬលក្ខខណ្ឌតម្រូវរបស់ច្បាប់ ឬបទបញ្ជាផ្សេងៗ ។

### ជំពូកទី២
### ភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា១០៩៥ ._** ការពិនិត្យភស្តុតាងក្នុងបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិតលក្ខណៈ រដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ការពិនិត្យភស្តុតាងក្នុងបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិតលក្ខណៈរដ្ឋប្បវេណី និងរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើឡើងដោយសេរី ។

ការពិនិត្យភស្តុតាងក្នុងបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិតលក្ខណៈព្រហ្មទណ្ឌ ត្រូវអនុលោមតាមវិធានភស្តុតាង ដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១០៩៦ ._** លក្ខខណ្ឌចាំបាច់នៃភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ

ភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានភស្តុតាងចាំបាច់ដាច់ខាត ជាសេចក្តីសន្និដ្ឋានរបស់ជំនាញបច្ចេកទេសវិទ្យាសាស្ត្រមកធ្វើជាមូលដ្ឋានក្នុងការពិចារណា និងសម្រេចសេចក្តី ។

**មាត្រា១០៩៧ ._** នីតិវិធីនៃការដាក់ភស្តុតាង និងការពិនិត្យភស្តុតាង

នីតិវិធីលម្អិតនៃការដាក់ភស្តុតាង និងការពិនិត្យភស្តុតាង ដែលទាក់ទងនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកយុត្តិធម៌ ។

**មាត្រា១០៩៨ ._** វត្ថុតាងដែលរឹបអូសបាន

វត្ថុតាងដែលរឹបអូសបាន ត្រូវគ្រប់គ្រង និងអនុវត្តតាមនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានចែងជាពិសេសនៅក្នុងក្រមនេះ ។

**មាត្រា១០៩៩ ._** បទប្បញ្ញត្តិដែលត្រូវអនុវត្តក្នុងរឿងបត្យាប័ន

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ត្រូវយកមកអនុវត្តក្នុងរឿងបត្យាប័នពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិតលក្ខណៈព្រហ្មទណ្ឌ ។

**មាត្រា១១០០ ._** ជំនួយផ្នែកច្បាប់ទៅវិញទៅមក

ក្នុងករណីមានបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈព្រហ្មទណ្ឌ អាជ្ញាធរតុលាការនៃព្រះរាជាណាចក្រកម្ពុជា អាចប្រគល់អំណាចឱ្យទៅអាជ្ញាធរខាងតុលាការមានសមត្ថកិច្ចនៃ

រដ្ឋបរទេសណាមួយ និងអាចទទួលអំណាចពីអាជ្ញាធរតុលាការ នៃរដ្ឋបរទេសណាមួយតាមរយៈក្រសួងយុត្តធម៌ ដើម្បី ៖

១- ប្រមូលយកសក្ខីភាព ឬចម្លើយដែលឆ្លើយតាមផ្លូវតុលាការ ។

២- ឱ្យដំណឹងពីលិខិតផ្សេងៗរបស់តុលាការ ។

៣-ធ្វើការឆែកឆេរ ឃាត់ទុក និងដកហូត ។

៤- ធ្វើការពិនិត្យវត្ថុតាង និងទីកន្លែង ។

៥- ផ្តល់ព័ត៌មាន និងវត្ថុតាង ។

៦- ផ្តល់ឯកសារកំណត់ហេតុជាច្បាប់ដើម ឬសេចក្តីចម្លងដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃឯកសារ និងសំណុំរឿង ។

៧- បង្ហាញ ឬផ្តល់សាក្សី អ្នកជំនាញ ឬជនដទៃទៀត រាប់ទាំងជនជាប់ឃុំខ្លួន ដែលយល់ព្រមជួយក្នុងការស៊ើបអង្កេត ឬយល់ព្រមចូលរួមក្នុងនីតិវិធី ។

៨- កំណត់អត្តសញ្ញាណ ឬស្រាវជ្រាវរកធនធាន ទ្រព្យសម្បត្តិ បរិក្ខារ និងសម្ភារទាំងដែលបានមកពីការប្រព្រឹត្តបទល្មើសដោយចេតនា និងមធ្យោបាយបទល្មើស ។

៩- ដាក់ក្រោមវិធានការរក្សាទុកជាបណ្តោះអាសន្ននូវផលិតផល និងទ្រព្យសម្បត្តិដែលបានមកពីបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលមានទាំងបរិក្ខារ សម្ភារដែលប្រើប្រាស់ ឬទុកសម្រាប់ប្រើប្រាស់ ដើម្បីប្រព្រឹត្តបទល្មើសបរិស្ថាន និងធនធានធម្មជាតិដោយចេតនាដែលមានលក្ខណៈព្រហ្មទណ្ឌ ។

១០- ចាត់ឱ្យអនុវត្តសេចក្តីសម្រេចដែលបញ្ជាឱ្យធ្វើការរឹបអូស ដកហូត ឬយកមកវិញនូវផលិតផល ទ្រព្យសម្បត្តិ បរិក្ខារ សម្ភារទាំងឡាយ ដែលបានមកពីការប្រព្រឹត្តបទល្មើសបរិស្ថានដោយចេតនា ដែលមានលក្ខណៈព្រហ្មទណ្ឌ ។

១១- បញ្ជាឱ្យធ្វើការរឹបអូសវត្ថុទាំងឡាយ ដែលមានចែងក្នុងចំណុចខាងលើ ។

១២- ឱ្យដំណឹងអំពីការចោទប្រកាន់តាមនីតិវិធីព្រហ្មទណ្ឌ ។

១៣- សួរចម្លើយជនត្រូវចោទតាមនីតិវិធីព្រហ្មទណ្ឌ ។

១៤- រកឱ្យឃើញ និងកំណត់អត្តសញ្ញាណសាក្សី និងជនសង្ស័យ ។

# មាតិកាទី៤
# មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន និង ធនធានធម្មជាតិ
## ជំពូកទី១
## នគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

**មាត្រា១១០១**._ មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ដែលកំណត់ដោយក្រមនេះ និងច្បាប់ពិសេសផ្សេងទៀត ត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១១០២**._ សមាសភាព និងលក្ខណៈសម្បត្តិមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីសមាសភាព និងមន្ត្រីរាជការសាធារណៈដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១១០៣**._ នីតិវិធីក្នុងការទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ ដើម្បីទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។ សម្បថមិនចាំបាច់ធ្វើសាជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិនៅពេលក្រោយទៀត ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត អន្តរក្រសួងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកយុត្តិធម៌ ។

ចំពោះរូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកយុត្តិធម៌ ។

**មាត្រា១១០៤ .**_ បេសកកម្មមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

បេសកកម្មរបស់មន្ត្រីរាជការសាធារណៈ ឬមន្ត្រីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានចែងជាពិសេសនៅក្នុងក្រមនេះ ឬច្បាប់ពិសេសដទៃទៀតជាធរមាន ។

**មាត្រា១១០៥ .**_ សិទ្ធិអំណាចនៃការប្រើប្រាស់អាវុធ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិប្រើប្រាស់អាវុធ ក្នុងអំឡុងពេលប្រតិបត្តិការរបស់ខ្លួន ។

ការប្រើប្រាស់អាវុធ ត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ។

**មាត្រា១១០៦ .**_ នីតិវិធីស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ

នីតិវិធីក្នុងការកសាងសំណុំរឿងរបស់មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

ទម្រង់ និងបែបបទ ក្នុងការធ្វើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកយុត្តិធម៌ ។

**មាត្រា១១០៧ .**_ កាតព្វកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធក្នុងការសហការចំពោះការស៊ើបអង្កេតបទល្មើសបរិស្ថាន និងធនធានធម្មជាតិ

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ត្រូវបង្កភាពងាយស្រួល ជួយសម្រួល និងជួយផ្តល់កម្លាំងសហការក្នុងការស្រាវជ្រាវ ស៊ើបអង្កេត ត្រួតពិនិត្យ

បទល្មើស និងបង្ក្រាបបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ក្នុងករណីមានការស្នើសុំពីមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១១០៨** ._ ការប្រើប្រាស់អត្តសញ្ញាណក្នុងការស៊ើបអង្កេតលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវមានឯកសណ្ឋាន និងប័ណ្ណសម្គាល់អត្តសញ្ញាណច្បាស់លាស់ នៅពេលចុះបំពេញបេសកកម្មក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១១០៩** ._ សិទ្ធិរបស់រូបវន្តបុគ្គល និងសហគមន៍មូលដ្ឋាន

រូបវន្តបុគ្គល ឬសហគមន៍មូលដ្ឋាន មានសិទ្ធិចូលរួមក្នុងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដូចខាងក្រោម ៖

១- ធ្វើការឃ្លាំមើលល្បាត ដោយមានការសហការជាមួយមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ។

២- ធ្វើការឃាត់ទុកជនល្មើសក្នុងបទល្មើសជាក់ស្តែង និងឃាត់វត្ថុតាងនៃបទល្មើស រួចបញ្ជូនទៅមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ។

៣- ផ្តល់វត្ថុតាង របាយការណ៍ និងព័ត៌មានដទៃទៀតពាក់ព័ន្ធនឹងបទល្មើសទៅកាន់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

៤- ផ្តល់វត្ថុតាង និងព័ត៌មានពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិទៅឱ្យស្ថាប័នតុលាការមានសមត្ថកិច្ច ។

## ជំពូកទី២
## មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា១១១០** ._ ការតែងតាំងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិត្រូវចាត់តាំងមន្ត្រីដោយឡែក ដើម្បីទទួលបន្ទុកកិច្ចការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ ស្របតាមក្រមនេះ ច្បាប់ពិសេសដោយឡែក និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ផ្សេងទៀត ។

**មាត្រា១១១១**._ ភារកិច្ច និងតួនាទីរបស់មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ មានភារកិច្ច និងតួនាទី ដូចខាងក្រោម ៖

១- ធ្វើអធិការកិច្ច តាមដាន និងត្រួតពិនិត្យការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ។

២- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ចដាក់ជូនថ្នាក់ដឹកនាំដើម្បីពិនិត្យ និងសម្រេច ។

៣- ចាត់វិធានការចាំបាច់ក្នុងករណីមានការបំពានក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

៤- ចេញបទបញ្ជានានាតាមការចាំបាច់ ក្នុងករណីមានការគំរាមកំហែងដល់បរិស្ថាន និងធនធានធម្មជាតិកើតឡើង ។

ក្រៅពីភារកិច្ច និងតួនាទីដែលកំណត់ក្នុងក្រមនេះ មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិត្រូវអនុវត្តភារកិច្ច និងតួនាទីរបស់ខ្លួន ដូចមានចែងក្នុងច្បាប់ពិសេសដោយឡែក និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតផងដែរ ។

**មាត្រា១១១២**._ កិច្ចសហការចំពោះការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ

ម្ចាស់គម្រោង ឬប្រតិបត្តិករ ឬស្ថាប័នពាក់ព័ន្ធ ត្រូវមានកាតព្វកិច្ចសហការជាមួយមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ក្នុងការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១១១៣**._ ការប្រើប្រាស់ឯកសណ្ឋានក្នុងការបំពេញភារកិច្ច និងតួនាទីជាមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានលិខិតអនុញ្ញាត និងពាក់ប័ណ្ណសម្គាល់អត្តសញ្ញាណច្បាស់លាស់ និងពាក់ឯកសណ្ឋាន នៅពេលចុះបំពេញភារកិច្ច និងតួនាទីរបស់ខ្លួន ។

## គន្ថីទី១១
## ទោសប្បញ្ញត្តិ
## មាតិកាទី១
## បទប្បញ្ញត្តិទូទៅ
## ជំពូកទោល
## ទណ្ឌកម្ម

**មាត្រា១១១៤ .**_ ប្រភេទនៃទណ្ឌកម្ម

ប្រភេទនៃទណ្ឌកម្ម ដែលកំណត់នៅក្នុងក្រមនេះ មានជាអាទិ៍ ការព្រមានជាលាយលក្ខណ៍អក្សរ ការលុបចោល ការផ្អាកការឯកភាព ឬលិខិតអនុញ្ញាត ការពិន័យអន្តរការណ៍ ការផ្តល់សំណងការខូចខាត និងទោសព្រហ្មទណ្ឌ ។

**មាត្រា១១១៥ .**_ ការផ្អាក ឬលុបចោលលិខិតអនុញ្ញាត និងសំណងខូចខាតបរិស្ថាន

ការព្រមានជាលាយលក្ខណ៍អក្សរ ការផ្អាក ឬការលុបចោលវិញ្ញាបនបត្រចុះបញ្ជី ឬលិខិតអនុញ្ញាត ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ដូចមានចែងក្នុងក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។

សំណងការខូចខាតចំពោះការស្តារបរិស្ថាន និងធនធានធម្មជាតិឡើងវិញ និងសំណងការខូចខាតបរិស្ថាន ក្រោមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា១១១៦ .**_ ការពិន័យអន្តរការណ៍

ក្រសួង ស្ថាប័នទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ មានសិទ្ធិក្នុងការអនុវត្តការពិន័យអន្តរការណ៍ ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។ ការពិន័យអន្តរការណ៍ ត្រូវអនុវត្តក្នុងករណីដែលជនល្មើសសារភាពកំហុស និងយល់ព្រមបង់ថ្លៃពិន័យអន្តរការណ៍ ស្របតាមបទប្បញ្ញត្តិនៃ

ក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។ ការបង់ថ្លៃពិន័យអន្តរការណ៍នាំឱ្យរលត់បណ្តឹងអាជ្ញា ។

ក្នុងករណីដែលជនល្មើសបដិសេធមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួង ស្ថាប័នទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ អាចដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីទាមទារប្រាក់ពិន័យអន្តរការណ៍នោះបាន ។

ចំនួននៃប្រាក់ពិន័យអន្តរការណ៍ នីតិវិធី និងបែបបទស្តីពីការពិន័យអន្តរការណ៍ ត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា១១៧** ._ ប្រាក់ចំណូលដែលបានមកពីការពិន័យ

ប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ពិន័យដោយតុលាការ ឬវត្ថុផ្សេងទៀតដែលតុលាការបានសម្រេចឱ្យរឹបអូសលក់ ត្រូវបង់ចូលទៅក្នុងថវិកាជាតិ ។

ប្រាក់ចំណូលដែលទទួលបានដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចប្រើប្រាស់សម្រាប់ផ្តល់ជារង្វាន់ជូនមន្ត្រីរាជការ និងប្រជាពលរដ្ឋ ដែលចូលរួមក្នុងសកម្មភាពពង្រឹងការអនុវត្តច្បាប់ ។

នីតិវិធីនៃការកំណត់ការផ្តល់ប្រាក់រង្វាន់ និងប្រាក់ពិន័យ ដែលត្រូវបង់ចូលថវិកាជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា១១៨** ._ ការអនុវត្តសកម្មភាពបណ្តឹងរដ្ឋប្បវេណី

ក្នុងករណីមានបណ្តឹងអាជ្ញាធ្វើឡើង ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ពិសេសផ្សេងទៀតនៅតុលាការមានសមត្ថកិច្ច ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬរូបវន្តបុគ្គល ឬនីតិបុគ្គលអាចធ្វើសកម្មភាពបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណងការខូចខាត ឬការស្តារការខូចខាតបរិស្ថានឡើងវិញ ប្រឆាំងទៅនឹងភាគីដែលបង្កការខូចខាត នៅតុលាការរដ្ឋប្បវេណីដោយឡែក ។

បណ្តឹងទាមទារសំណងការខូចខាត និងស្តារបរិស្ថានឡើងវិញនេះ ត្រូវតែដំណើរការចាត់ការទៅតាមនីតិវិធីរដ្ឋប្បវេណី ឬទៅតាមនីតិវិធីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដែលកំណត់ក្នុងក្រមនេះ ដោយមិនរង់ចាំការសម្រេចសេចក្តីជាស្ថាពរពីតុលាការព្រហ្មទណ្ឌឡើយ ។

**មាត្រា១១១៩** ._ ការស្តារបរិស្ថានឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិធ្វើសកម្មភាពបណ្តឹងទៅកាន់តុលាការ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីទាមទារសំណងការខូចខាតលើការស្តារបរិស្ថានឡើងវិញ ឬទ្រព្យសម្បត្តិសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា១១២០** ._ មន្ត្រីសាធារណៈដែលខកខានមិនបានបំពេញភារកិច្ច

មន្ត្រីសាធារណៈដែលបំពាន ឬខកខានមិនបានបំពេញភារកិច្ច ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាល ដោយមិនទាន់គិតដល់ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

ជនផ្តើមគំនិត ឬសមគំនិត ត្រូវទទួលទណ្ឌកម្មដូចគ្នានឹងចារីដែរ ។

**មាត្រា១១២១** ._ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់មន្ត្រីរាជការ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីកងកម្លាំងប្រដាប់អាវុធ ដែលទទួលខុសត្រូវលើការគ្រប់គ្រង ឬប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈ ដើម្បីចូលរួមក្នុងការប្រព្រឹត្តបទល្មើសដោយចេតនា ក្នុងគោលបំណងទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន ដោយគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមបទល្មើសដែលខ្លួនបានចូលរួមប្រព្រឹត្ត ។

**មាត្រា១១២២** ._ បទល្មើសដែលមិនតម្រូវឱ្យមានចេតនាប្រព្រឹត្ត

បទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានចរិតលក្ខណៈព្រហ្មទណ្ឌ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ អាចកើតចេញពីការខ្វះការប្រុងប្រយ័ត្ន ការធ្វេសប្រហែស ការខ្ជីខ្ជា ឬការខកខានមិនបានបំពេញកាតព្វកិច្ច ទោះបីជាមាន ឬគ្មានចេតនា ក្នុងការប្រព្រឹត្តបទល្មើសក៏ដោយ ។

បទល្មើសបរិស្ថាន និងធនធានធម្មជាតិ មិនតម្រូវឱ្យមានភស្តុតាងនៃចេតនាប្រព្រឹត្តបទល្មើសទេ លើកលែងតែមានចែងជាក់លាក់នៅក្នុងបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា១១២៣** ._ ការទទួលខុសត្រូវរបស់នីតិបុគ្គល

នីតិបុគ្គលត្រូវទទួលខុសត្រូវចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលប្រព្រឹត្តឡើង ដោយភ្នាក់ងារ ឬតំណាងរបស់នីតិបុគ្គល ក្នុងនាមផលប្រយោជន៍របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវរបស់នីតិបុគ្គល ត្រូវធ្វើឡើងតាមរយៈតំណាង ឬភ្នាក់ងាររបស់ខ្លួន ។

**មាត្រា១១២៤** ._ ទោសបន្ថែមចំពោះរូបវន្តបុគ្គល

ប្រភេទទោសបន្ថែមដែលកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ត្រូវយកមកអនុវត្តផងដែរ ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលប្រព្រឹត្តដោយរូបវន្តបុគ្គល ដូចមានចែងក្នុងក្រមនេះ និងច្បាប់ពិសេសផ្សេងទៀត ។

**មាត្រា១១២៥** ._ ទោសបន្ថែមចំពោះនីតិបុគ្គល

ប្រភេទទោសបន្ថែម ត្រូវយកមកអនុវត្តចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលប្រព្រឹត្តដោយនីតិបុគ្គល មានដូចខាងក្រោម ៖

១- ការរំលាយនីតិបុគ្គល ។

២- ការលុបចោលលិខិតអនុញ្ញាត ឬសិទ្ធិអនុញ្ញាត ។

៣- ការផ្អាកលិខិតអនុញ្ញាត ឬសិទ្ធិអនុញ្ញាត ។

៤- ការលុបចោលវិញ្ញាបនបត្រឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៥- ការផ្អាកសម្បទានដីសេដ្ឋកិច្ចណាមួយ ឬសម្បទានដទៃទៀត ។

៦- ការលុបចោលសម្បទានដីសេដ្ឋកិច្ចណាមួយ ឬសម្បទានដទៃទៀត ។

៧- ការរឹបអូសបរិក្ខារពាក់ព័ន្ធនឹងបទល្មើស ។

៨- ការរឹបអូសគ្រប់ផលចំណេញ ឬផលចំណេញនីមួយៗដែលកើតចេញពីបទល្មើស ។

៩- ការផ្សព្វផ្សាយបទល្មើស និងទោសទណ្ឌ ។

ក្រៅពីទោសបន្ថែម ដែលកំណត់ខាងលើនេះ ទោសបន្ថែមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌជាធរមាន ក៏ត្រូវយកមកអនុវត្តផងដែរ ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលប្រព្រឹត្តដោយនីតិបុគ្គល ។

**មាត្រា១១២៦** ._ ចំណាត់ថ្នាក់នៃបទល្មើសបរិស្ថាន និងធនធានធម្មជាតិ

បទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលកំណត់ក្នុងក្រមនេះ ត្រូវបែងចែកជា ៣ ថ្នាក់ រួមមានបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ស្របតាមក្រមព្រហ្មទណ្ឌជាធរមាន ។

បទឧក្រិដ្ឋបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានចាត់ថ្នាក់ជា ២ថ្នាក់ គឺថ្នាក់ទី១ និងទី២ ។

បទមជ្ឈិមបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានចាត់ថ្នាក់ជា ២ថ្នាក់ គឺថ្នាក់ទី៣ និងទី៤ ។

បទលហុបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានចាត់ថ្នាក់ជា ១ថ្នាក់ គឺថ្នាក់ទី៥ ។

**មាត្រា១១២៧** ._ ថ្នាក់នៃបទល្មើស

បទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលកំណត់ក្នុងក្រមនេះ ត្រូវបែងចែកជា ៥ ថ្នាក់ ដូចខាងក្រោម ៖

១- បទល្មើសថ្នាក់ទី១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ និងពិន័យជាប្រាក់ពី ៤០០ ០០០ ០០០ (បួនរយលាន) រៀល ទៅ ៨០០ ០០០ ០០០ (ប្រាំបីរយលាន) រៀល ។

២- បទល្មើសថ្នាក់ទី២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់១០ (ដប់) ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ២០០ ០០០ ០០០ (ពីររយលាន) រៀល ទៅ ៤០០ ០០០ ០០០ (បួនរយលាន) រៀល ។

៣- បទល្មើសថ្នាក់ទី៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០ (ម្ភៃលាន) រៀល ដល់ ២០០ ០០០ ០០០ (ពីររយលាន) រៀល ។

៤- បទល្មើសថ្នាក់ទី៤ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ទៅ ១ (មួយ) ឆ្នាំ និង/ឬ ពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ដល់ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

៥- បទល្មើសថ្នាក់ទី៥ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និង/ឬ ពិន័យជាប្រាក់ពី ២០ ០០០ (ម្ភៃពាន់) រៀល ដល់ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

**មាត្រា១១២៨** ._ ការចាត់ចែងប្រាក់សំណងពីសកម្មភាពបណ្តឹងរដ្ឋប្បវេណីដើម្បីការពារផលប្រយោជន៍សាធារណៈ

ប្រាក់សំណង ដែលបានមកពីការធ្វើសកម្មភាពបណ្តឹងរដ្ឋប្បវេណីដែលមានគោលបំណងការពារផលប្រយោជន៍សាធារណៈ ត្រូវប្រើប្រាស់សម្រាប់ការស្តារបរិស្ថានឡើងវិញ និងស្តារជីវភាពរស់នៅរបស់សហគមន៍ ដែលទទួលរងផលប៉ះពាល់ជាអវិជ្ជមានឡើងវិញ ។

**មាត្រា១១២៩** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រង និងការបែងចែកសំណងការខូចខាត

ការគ្រប់គ្រង និងការបែងចែកប្រាក់សំណងការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១១៣០** ._ អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី

សិទ្ធិទាមទារសំណងការស្តារបរិស្ថានឡើងវិញ និងសំណងការខូចខាតផ្សេងទៀត ត្រូវគិតអាជ្ញាយុកាល ដូចខាងក្រោម ៖

១- ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលបានដឹងពីព្រឹត្តិការណ៍ដែលបង្កឱ្យ មានការខូចខាតបរិស្ថាន ឬពីថ្ងៃទទួលបានព័ត៌មានអំពីការបង្កឱ្យមានការជួសជុលបរិស្ថាន ឬការខូចខាតផ្សេងទៀត ។

២- ឬ ១០ (ដប់) ឆ្នាំ គិតចាប់ពីថ្ងៃដែលសកម្មភាព ឬហេតុការណ៍នៃការខូចខាតបរិស្ថានបានកើតឡើង ។

**មាត្រា១១៣១** ._ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា

ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិតលក្ខណៈ ជាប្រភេទបទល្មើសនិរន្តរ៍ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ត្រូវគិតចាប់ពីថ្ងៃរកឃើញបទល្មើស ។

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមព្រហ្មទណ្ឌជាធរមាន ។

## មាតិកាទី២
## បទល្មើសពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ

## ជំពូកទី១
## បទល្មើសពាក់ព័ន្ធនឹងការចូលរួមជាសាធារណៈ

**មាត្រា១១៣២** ._ ការរារាំងសិទ្ធិក្នុងការចូលរួមជាសាធារណៈ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៥ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលរារាំងសិទ្ធិក្នុងការចូលរួមជាសធារណៈ ដូចមានចែងក្នុងមាត្រា២២ នៃក្រមនេះ ។

ក្នុងករណីដែលអំពើរាំងនោះ ប្រព្រឹត្តដោយមន្ត្រីរាជការសាធារណៈ ឬមន្ត្រីរាជការមានសមត្ថកិច្ចដោយរំលោភអំណាច ឬប្រើប្រាស់សិទ្ធិដោយបំពាន ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ។

**មាត្រា១១៣៣** ._ អំពើរាំង ឬគំរាមកំហែងចំពោះការចូលរួមជាសាធារណៈ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ រាល់អំពើគំរាមកំហែង ឬសងសឹកតាមគ្រប់មធ្យោបាយរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលរាំង ឬគំរាមកំហែង ចំពោះសកម្មភាពនៃការចូលរួមជាសាធារណៈ ដូចមានចែងក្នុងមាត្រា២៣ នៃក្រមនេះ ។

ក្នុងករណីដែលអំពើរាំង ឬគំរាមកំហែង ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ធ្វើឱ្យប៉ះពាល់ដល់បូរណភាពរូបរាងកាយធ្ងន់ធ្ងរ ឬទ្រព្យសម្បត្តិ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះអំពើប្រព្រឹត្ត ដូចមានចែងក្នុងកថាខណ្ឌទី២ ខាងលើនេះ ធ្វើឱ្យបាត់បង់អាយុជីវិត ។

**មាត្រា១១៣៤** ._ កាតព្វកិច្ចក្នុងការបង្ហាញព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនអនុវត្តកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះ ដែលចែងអំពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីដែលរូបវន្តបុគ្គល ឬនីតិបុគ្គលនៅតែបន្តប្រព្រឹត្តបទល្មើស ត្រូវពិន័យជាប្រចាំថ្ងៃ មួយថ្ងៃ ២ ០០០ ០០០ (ពីរលាន) រៀល ។

**មាត្រា១១៣៥** ._ បញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានរបស់រូបវន្តបុគ្គល ឬមន្ត្រីរាជការសាធារណៈ ឬមន្ត្រីរាជការមានសមត្ថកិច្ចដែលអនុវត្តតួនាទីដោយបំពានក្នុងការមិនផ្តល់ឱ្យសារធារណជនអាចស្វែងរកបាននូវបញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព ដូចមានចែងក្នុងមាត្រា៤៩ ។

**មាត្រា១១៣៦ ._** បញ្ជីសវនកម្មបរិស្ថាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានរបស់រូបវន្តបុគ្គល ឬមន្ត្រីរាជការ សាធារណៈ ឬមន្ត្រីរាជការមានសមត្ថកិច្ចដែលអនុវត្តតួនាទីដោយបំពានក្នុងការមិនផ្តល់ឱ្យសារធារណជនអាចស្វែងរកបាន នូវបញ្ជីសវនកម្មបរិស្ថាន ដូចមានចែងក្នុងមាត្រា៥៣ ។

## ជំពូកទី២
## បទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថាន

**មាត្រា១១៣៧ ._** អំពើរារាំង ឬមិនអនុញ្ញាតដល់មន្ត្រីអធិការកិច្ច

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ចំពោះម្ចាស់គម្រោង ឬម្ចាស់ទីកន្លែង ដែលបញ្ជា ឬបង្ខំឱ្យបុគ្គលិក ឬអ្នកនៅក្រោមឱវាទរបស់ខ្លួនធ្វើការរារាំង ឬមិនអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ច ចូលបំពេញភារកិច្ច និងតួនាទីស្របតាមបទប្បញ្ញត្តិ នៃមាត្រា៩០ និងមាត្រា១១១១ នៃក្រមនេះ ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សាធ្វើឱ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ក្នុងករណីអំពើនោះប្រព្រឹត្តដោយហិង្សា បណ្តាលឱ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ។

**មាត្រា១១៣៨ ._** ការបំពានកាតព្វកិច្ចនៃការជូនដំណឹង

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ចំពោះម្ចាស់គម្រោងដែលមិនបានអនុវត្តការជូនដំណឹង ដូចមានចែងក្នុងមាត្រា៩២ ។

**មាត្រា១១៣៩ ._** ការបំពានលក្ខខណ្ឌការងារដោយក្លែងបន្លំ ឬលួចចម្លងទិន្នន័យ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះម្ចាស់គម្រោង ឬក្រុមហ៊ុនទីប្រឹក្សាដែលបំពានលក្ខខណ្ឌការងារដែលទទួលបានការឯកភាព ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយក្លែងបន្លំ ឬលួចចម្លងទិន្នន័យអ្នកដទៃ ដើម្បីទទួលបានលិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាត្រា៩៤ ។

**មាត្រា១១៤០ ._** ការប្រកបវិជ្ជាជីវៈរបស់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមិនបានចុះបញ្ជី

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ ពី ៣០ ០០០ ០០០ (សាមសិបលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល ចំពោះក្រុមហ៊ុនទីប្រក្សាដែលពុំទាន់បានចុះបញ្ជី ឬទទួលស្គាល់ ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ហើយបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមមាត្រា៩៥ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារក្នុងបទល្មើសថ្នាក់ទី៣ ។

**មាត្រា១១៤១ ._** អំពើមិនអនុវត្តតាមលក្ខខណ្ឌតម្រូវ

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ពីមន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះម្ចាស់គម្រោងទាំងឡាយណា ដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃកិច្ចសន្យាការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា៩៨ នៃក្រមនេះ ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៣០ ០០០ ០០០ (សាមសិបលាន) រៀល និង/ឬ ផ្អាកសកម្មភាពគម្រោង ។

ក្នុងករណីដែលមិនគោរពលក្ខខណ្ឌខាងលើ ហើយបណ្តាលឱ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ត្រូវទទួលការផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។ ការព្រមានជាលាយលក្ខណ៍អក្សរ មិនត្រូវអនុវត្តចំពោះករណីនេះឡើយ ។

ក្នុងករណីដែលមិនគោរពលក្ខខណ្ឌខាងលើ ហើយធ្វើឱ្យប៉ះពាល់ដល់ជីវិតសត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោង ត្រូវសងសំណងខូចខាតតាមសមាមាត្រនឹងទំហំនៃការខូចខាត ។

ក្នុងករណីដែលការប៉ះពាល់ ដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើនេះ មានលក្ខណៈធ្ងន់ធ្ងរ ម្ចាស់គម្រោង អាចទទួលរងទណ្ឌកម្មបន្ថែម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្ដោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងអាចទទួលការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។ នីតិបុគ្គល អាចត្រូវប្រកាសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសបន្ថែម ស្របតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ។

**មាត្រា១១៤២** ._ ការធ្វើសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង បំពានការហាមឃាត់

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល និង/ឬ ផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ និងត្រូវជួសជុល ស្តារការខូចខាត ដែលបានបង្កឡើងចំពោះម្ចាស់គម្រោងដែលបានប្រព្រឹត្តល្មើសនឹងមាត្រា១០៦ នៃក្រមនេះ ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមាន ដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ និងត្រូវសងសំណងខូចខាត ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែម ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១១៤៣** ._ ដំណើរការសាងសង់ ឬប្រតិបត្តិការគម្រោងចំពោះគម្រោងមានស្រាប់ ឬកំពុងដំណើរការ

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល និង/ឬ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ និងត្រូវជួសជុល ស្តារការខូចខាតដែលបានបង្កឡើង ចំពោះម្ចាស់គម្រោងដែលមានស្រាប់ ឬកំពុងដំណើរការដែលបានប្រព្រឹត្តល្មើសនឹងមាត្រា១០៨ នៃក្រមនេះ ចាប់ពីក្រមនេះចូលជាធរមាន ។ ការចោទប្រកាន់ចំពោះបទល្មើស

ព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្ដឹងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមានដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោង ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ និងត្រូវសងសំណងការខូចខាតតាមទំហំខូចខាតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្ដោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែម ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១១៤៤** ._ ការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យដោយក្លែងបន្លំ

ត្រូវផ្ដន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះអំពើប្រព្រឹត្តរបស់ទីប្រឹក្សារៀបចំរបាយការណ៍ហានិភ័យបរិស្ថាន ដោយក្លែងបន្លំ ដូចមានចែងក្នុងមាត្រា១១៦ ។

**មាត្រា១១៤៥** ._ ការមិនធ្វើការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែន

ត្រូវផ្ដន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល និង/ឬ ត្រូវផ្ដន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ និងត្រូវជួសជុល ស្ដារការខូចខាតដែលបានបង្កឡើង ចំពោះម្ចាស់គម្រោងដែលបានប្រព្រឹត្តល្មើសនឹងមាត្រា១២៦ នៃក្រមនេះ ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្ដឹងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមានដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោង ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ និងត្រូវសងសំណងខូចខាតតាមទំហំខូចខាតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែម ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្តនៅពេលដែលមានកិច្ចព្រមព្រៀងទ្វេភាគី ឬសន្ធិសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគី ។

**មាត្រា១១៤៦ ._** ការបំពានកាតព្វកិច្ចក្នុងការដាក់ព័ត៌មានឱ្យសាធារណជនអាចស្វែងរកបាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានដាក់ឱ្យសាធារណជនស្វែងរកបានព័ត៌មាន ដូចមានចែងក្នុងមាត្រា១៣២ ។

**មាត្រា១១៤៧ ._** ការបំពានចំពោះការរៀបចំ និងបញ្ជូនរបាយការណ៍អង្កេតតាមដានបរិស្ថាន

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះម្ចាស់គម្រោង ដោយបង្គាប់ឱ្យរៀបចំរបាយការណ៍អង្កេតតាមដានគម្រោង និងបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ដូចមានកំណត់ក្នុងមាត្រា១៣៥ មាត្រា១៣៧ និងមាត្រា១៣៨ នៃក្រមនេះ ។ ក្នុងករណីដែលម្ចាស់គម្រោង មិនបានរៀបចំ និងបញ្ជូនរបាយការណ៍មកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រោយពីទទួលការព្រមាននេះទេ ម្ចាស់គម្រោង ត្រូវទទួលទណ្ឌកម្ម ជាការពិន័យអន្តរការណ៍ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ឬផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ ។

**មាត្រា១១៤៨ ._** ការរារាំងក្នុងការអនុវត្តការធ្វើសវនកម្មបរិស្ថាន

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើរារាំង ឬមិនអនុញ្ញាតឱ្យមន្ត្រីសវនកម្មបរិស្ថានចូលធ្វើសវនកម្ម ដូចមានចែងក្នុងមាត្រា១៤៣ ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សា ធ្វើឱ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សាបណ្តាលឱ្យបាត់បង់អាយុជីវិត ឬពិការអចិន្ត្រៃយ៍ ត្រូវផ្តន្ទាទោសថ្នាក់ទី២ ។

**មាត្រា១១៤៩ .**_ ការបំពាននឹងសេចក្ដីសម្រេចបង្គាប់ឱ្យបង់ថ្លៃចំណាយ

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះម្ចាស់គម្រោង ដោយបង្គាប់ឱ្យបង់ថ្លៃចំណាយ ដូចមានចែងក្នុងមាត្រា១៩២ និងមាត្រា៩៧០ នៃក្រមនេះ ។

ក្នុងករណីដែលម្ចាស់គម្រោងមិនបានបង់ប្រាក់ ក្រោយពីទទួលការព្រមាននេះ ម្ចាស់គម្រោង ត្រូវទទួលទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្ដោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ រួមទាំងពិន័យជាប្រាក់ចំនួន ៣ (បី) ដង នៃចំនួនទឹកប្រាក់ដែលត្រូវបង់ ។

**មាត្រា១១៥០ .**_ ការខកខានមិនបានផ្ដល់ព័ត៌មានដល់សាធារណៈ

ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការខកខានមិនបានដាក់របាយការណ៍សវនកម្មបរិស្ថាន ឱ្យសាធារណជនអាចស្វែងរកបាន ដូចមានចែងក្នុងមាត្រា១៩៤ ។

## ជំពូកទី៣
## បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងយន្តការថវិកាភាព

**មាត្រា១១៥១ .**_ ការធ្វើសកម្មភាព មិនស្របតាមផែនការប្រើប្រាស់ដីធ្លី

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើសកម្មភាព មិនស្របតាមផែនការប្រើប្រាស់ដីដែលទទួលបានការឯកភាព ដូចមានចែងក្នុងមាត្រា២២៣ ។

ក្នុងករណីដែលការធ្វើសកម្មភាព មិនស្របតាមផែនការប្រើប្រាស់ដីដែលទទួលបានការឯកភាព ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ បង្កឱ្យមានផលប៉ះពាល់ដល់បូរណភាពរូបរាងកាយមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន ត្រូវសងសំណងខូចខាតតាមសមាមាត្រនឹងទំហំនៃការខូចខាតជាក់ស្ដែង ។

ក្នុងករណីដែលការធ្វើសកម្មភាព មិនស្របតាមផែនការប្រើប្រាស់ដីដែលទទួលបានការឯកភាព ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ មានលក្ខណៈធ្ងន់ធ្ងរ រូបវន្តបុគ្គល ឬនីតិបុគ្គល អាចទទួលរងទណ្ឌកម្មបន្ថែម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្ដោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងអាចទទួលការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ដូចមានកំណត់ក្នុងបទប្បញ្ញត្តិនៃច្បាប់ដោយឡែកផ្សេងទៀត ។ នីតិបុគ្គល អាច

ត្រូវប្រកាសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសបន្ថែម ស្របតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១១៥២** ._ ការហាមឃាត់មិនឱ្យមានគម្រោងថាមពលនៅក្នុងតំបន់ហាមឃាត់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការដំឡើងសម្ភារបរិក្ខារសម្រាប់ផលិតអគ្គិសនី ការបញ្ជូនអគ្គិសនី ឬការចែកចាយអគ្គិសនី នៅក្នុងតំបន់ដែលមានតម្លៃអភិរក្សខ្ពស់ ដូចមានចែងក្នុងមាត្រា២៨១ ។

**មាត្រា១១៥៣** ._ គម្រោងឧស្សាហកម្មនិស្សារណកម្មនៅក្នុងតំបន់ហាមឃាត់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពគម្រោងឧស្សាហកម្មនិស្សារណកម្ម ដែលស្ថិតនៅក្នុងតំបន់ហាមឃាត់ ដូចមានចែងក្នុងមាត្រា២៧២ ។

**មាត្រា១១៥៤** ._ ការមិនអនុវត្តបច្ចេកវិទ្យាល្អបំផុតដែលអាចស្វែងរកបាន ដើម្បីបញ្ចៀសការខូចខាតបរិស្ថាន

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះម្ចាស់គម្រោងដែលមិនបានប្រើប្រាស់បច្ចេកវិទ្យាល្អបំផុតដែលអាចស្វែងរកបាន និងទម្លាប់អនុវត្តល្អៗ ដើម្បីបញ្ចៀសការខូចខាតបរិស្ថាន ដូចមានចែងក្នុងមាត្រា២៧៣ ។

ក្នុងករណីដែលការមិនបានប្រើប្រាស់បច្ចេកវិទ្យាល្អបំផុត ដែលអាចស្វែងរកបាន និងទម្លាប់អនុវត្តល្អៗ ដើម្បីបញ្ចៀសការខូចខាតបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ បង្កឱ្យមានផលប៉ះពាល់ដល់បូរណភាពរូបរាងកាយមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន ត្រូវសងសំណងខូចខាតតាមសមាមាត្រនឹងទំហំនៃការខូចខាតជាក់ស្តែង ។

ក្នុងករណីដែលការមិនបានប្រើប្រាស់បច្ចេកវិទ្យាល្អបំផុត ដែលអាចស្វែងរកបាន និងទម្លាប់អនុវត្តល្អៗ ដើម្បីបញ្ចៀសការខូចខាតបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើនេះ មានលក្ខណៈធ្ងន់ធ្ងរ ម្ចាស់គម្រោង អាចទទួលរងទណ្ឌកម្មបន្ថែម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងអាចទទួលការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ដូចមានកំណត់ក្នុងបទប្បញ្ញត្តិនៃច្បាប់ដោយ

ឡែកផ្សេងទៀត ។ ម្ចាស់គម្រោង អាចត្រូវប្រកាសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសបន្ថែម ស្រប តាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១១៥៥ ._** ការមិនអនុវត្តបច្ចេកវិទ្យាល្អបំផុតដែលមាននៅក្នុងបញ្ជី ដើម្បីបញ្ចៀសការខូចខាត បរិស្ថាន

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះម្ចាស់គម្រោងដែលមិនបានអនុវត្តតាម លក្ខខណ្ឌតម្រូវ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាល្អបំផុតដែលមាននៅក្នុងបញ្ជី ដើម្បីបញ្ចៀសការខូចខាត បរិស្ថាន ដូចមានចែងក្នុងមាត្រា២៧៦ ។

ក្នុងករណីដែលការមិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាល្អបំផុត ដែលមាននៅក្នុងបញ្ជី ដើម្បីបញ្ចៀសការខូចខាតបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ បង្កឱ្យមានផលប៉ះពាល់ដល់បូរណភាពរូបរាងកាយមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន ត្រូវសង សំណងខូចខាតតាមសមាមាត្រនឹងទំហំនៃការខូចខាតជាក់ស្តែង ។

ក្នុងករណីដែលការមិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងការប្រើប្រាស់បច្ចេកវិទ្យាល្អបំផុត ដែលមាននៅក្នុងបញ្ជី ដើម្បីបញ្ចៀសការខូចខាតបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី២ ខាងលើនេះ បង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សត្វ ទ្រព្យសម្បត្តិ និងជីវិតមនុស្ស ត្រូវផ្តន្ទាទោសក្នុងបទល្មើស ថ្នាក់ទី២ ។

ក្នុងករណីដែលការមិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងការប្រើប្រាស់បច្ចេកវិទ្យាល្អបំផុត ដែលមាននៅក្នុងបញ្ជី ដើម្បីបញ្ចៀសការខូចខាតបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី៣ ខាងលើនេះ មានលក្ខណៈធ្ងន់ធ្ងរ ម្ចាស់គម្រោង អាចទទួលរងទណ្ឌកម្មបន្ថែម ជាអាទិ៍ ការផ្អាកគម្រោងជា បណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូត អាជ្ញាប័ណ្ណ និងអាចទទួលការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ដូចមានកំណត់ក្នុងបទ ប្បញ្ញត្តិនៃច្បាប់ដោយឡែកផ្សេងទៀត ។ ម្ចាស់គម្រោង អាចត្រូវប្រកាសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសបន្ថែម ស្របតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី៤
## បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព

**មាត្រា១១៥៦ ._** សកម្មភាពពាណិជ្ជកម្ម ឬសកម្មភាពអភិវឌ្ឍន៍នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពពាណិជ្ជកម្ម ឬ សកម្មភាពអភិវឌ្ឍន៍នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលមិនទាន់បានបញ្ចប់ក្នុងការរៀបចំផែនការប្រើប្រាស់ដី ការកំណត់បែងចែកតំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់ និងការរៀបចំផែនការគ្រប់គ្រង ដូចមានចែងក្នុងមាត្រា២៩០ ។

ក្នុងករណីដែលសកម្មភាពខាងលើ ធ្វើឱ្យខូចខាតធ្ងន់ធ្ងរចំពោះបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ដោយមិនរាប់បញ្ចូលសំណងការខូចខាតលើការស្តារបរិស្ថានឡើងវិញ និងការខូចខាតជាក់ស្តែងដទៃទៀត ។

**មាត្រា១១៥៧ ._** សកម្មភាពអភិវឌ្ឍន៍ដែលហាមឃាត់នៅក្នុងតំបន់គ្រប់គ្រងនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី១ ចំពោះការអនុញ្ញាតឱ្យមានសកម្មភាពអភិវឌ្ឍន៍នៅក្នុងតំបន់ស្នូលនៃតំបន់គ្រប់គ្រងនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា ៣២៨ ។

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ចំពោះការធ្វើសកម្មភាពនៅក្នុងតំបន់អភិរក្សនៃតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣២៨ ។

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការធ្វើសកម្មភាពនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣២៨ ។

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការធ្វើសកម្មភាពនៅក្នុងតំបន់សហគមន៍នៃតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣២៨ ។

**មាត្រា១១៥៨ ._** ការហាមឃាត់ចំពោះសកម្មភាពបង្កឱ្យមានភ្លើងឆេះព្រៃនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះអំពើដែលបង្កឱ្យមានភ្លើងឆេះព្រៃនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣៣២ ។

ក្នុងករណីការបង្កឱ្យមានភ្លើងឆេះព្រៃនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ បណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ។

**មាត្រា១១៥៩ .**_ ការហាមឃាត់ចំពោះសកម្មភាពនេសាទនៅក្នុងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពនេសាទនៅក្នុងតំបន់ស្នូល នៃតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣៣៣ ។

ក្នុងករណីសកម្មភាពនេសាទនៅក្នុងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ បង្កឱ្យមានការខូចខាតធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ។

**មាត្រា១១៦០ .**_ ការការពារប្រឆាំងនឹងការបំផ្លិចបំផ្លាញ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពដែលបង្កការខូចខាត ឬគ្រោះថ្នាក់បណ្តាលមកពីការទន្ទ្រានយកដីដោយខុសច្បាប់ ការប្រមូល ការឈូសឆាយ ការធ្វើអាជីវកម្ម ការបំពុលនៅក្នុងតំបន់ដែលមានធនធានជីវៈចម្រុះដែលមានតម្លៃ ភ្លើងឆេះព្រៃ ការធ្វើកសិកម្មពនេចរ និងសកម្មភាពបែបពាណិជ្ជកម្ម ការចម្លងជំងឺ និងសត្វល្អិតចង្រៃ ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣៣៤ ។

**មាត្រា១១៦១ .**_ ការកែច្នៃ និងប្រតិបត្តិការលើធនធានធម្មជាតិដែលត្រូវហាមឃាត់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពកែច្នៃ និងប្រតិបត្តិការលើធនធានធម្មជាតិនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣៣៥ ។

**មាត្រា១១៦២ .**_ ការហាមឃាត់ចំពោះការប្រមូលផលជ័រឈើ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពប្រមូលផលជ័រឈើនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣៣៦ ។

**មាត្រា១១៦៣ .**_ សកម្មភាពហាមឃាត់ដែលប៉ះពាល់ដល់ទីជម្រកប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពបំផ្លិចបំផ្លាញ ឬធ្វើឱ្យប្រែប្រួលទីជម្រកធម្មជាតិរបស់ប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែងដោយផ្ទាល់ ឬប្រយោល ដូចមានចែងក្នុងមាត្រា៤១១ ។

**មាត្រា១១៦៤**._ សកម្មភាពហាមឃាត់ចំពោះប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះសកម្មភាពប្រមូល បំផ្លិចបំផ្លាញ ប្រើប្រាស់ លក់ ធ្វើជំនួញ ឬដឹកជញ្ជូនរុក្ខជាតិព្រៃ ឬបំណែករុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី១ ដូចមានចែងក្នុងមាត្រា៤០៧ និងមាត្រា៤១២ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពប្រមូល បំផ្លិចបំផ្លាញ ប្រើប្រាស់ លក់ ធ្វើជំនួញ ឬដឹកជញ្ជូនរុក្ខជាតិព្រៃ ឬបំណែករុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដូចមានចែងក្នុងមាត្រា៤០៧ និងមាត្រា៤១២ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះសកម្មភាពប្រមូល បំផ្លិចបំផ្លាញ ប្រើប្រាស់ លក់ ធ្វើជំនួញ ឬដឹកជញ្ជូនរុក្ខជាតិព្រៃ ឬបំណែករុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៣ ដូចមានចែងក្នុងមាត្រា៤០៧ និងមាត្រា៤១២ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៥ ចំពោះសកម្មភាពប្រមូល បំផ្លិចបំផ្លាញ ប្រើប្រាស់ លក់ ធ្វើជំនួញ ឬដឹកជញ្ជូនរុក្ខជាតិព្រៃ ឬបំណែករុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៤ ដូចមានចែងក្នុងមាត្រា៤០៧ និងមាត្រា៤១២ ។

**មាត្រា១១៦៥**._ សកម្មភាពហាមឃាត់នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពប្រមូល ឬបំផ្លិចបំផ្លាញរុក្ខជាតិព្រៃនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៤១៣ ។

ក្នុងករណីសកម្មភាពប្រមូល ឬបំផ្លិចបំផ្លាញរុក្ខជាតិព្រៃនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ។

**មាត្រា១១៦៦**._ ការនាំចូលប្រភេទរុក្ខជាតិព្រៃដែលរាតត្បាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការនាំចូលប្រភេទរុក្ខជាតិព្រៃដែលរាតត្បាតណាមួយ ចូលទៅក្នុងបរិស្ថានធម្មជាតិក្រៅពីតំបន់ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៤៣១ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការនាំចូលប្រភេទរុក្ខជាតិព្រៃដែលរាតត្បាតណាមួយ ចូលទៅក្នុងផ្នែកណាមួយនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៤៣១ ។

**មាត្រា១១៦៧**._ ការហាមឃាត់ទូទៅ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការបរបាញ់ ការទាក់ ការដាក់អន្ទាក់ ការចាប់ ការបំពុល ការសម្លាប់សត្វព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី១ នៅលើដីឯកជននៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៥៥៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបរបាញ់ ការទាក់ ការដាក់អន្ទាក់ ការចាប់ ការបំពុល ការសម្លាប់សត្វព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ នៅលើដីឯកជននៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៥៥៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៥ ចំពោះការបរបាញ់ ការទាក់ ការដាក់អន្ទាក់ ការចាប់ ការបំពុល ការសម្លាប់សត្វព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៣ នៅលើដីឯកជននៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៥៥៣ ។

**មាត្រា១១៦៨**._ ការហាមឃាត់ចំពោះការបរបាញ់ ការទាក់ ការចាប់ ការបំពុល និងការសម្លាប់សត្វព្រៃក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះការបរបាញ់ ការទាក់ ការចាប់ ការបំពុល និងការសម្លាប់សត្វព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី១ ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌទី១ និងទី៣ នៃមាត្រា៥៥៤ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការបរបាញ់ ការទាក់ ការចាប់ ការបំពុល និងការសម្លាប់សត្វព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌទី១ និងទី៣ នៃមាត្រា៥៥៤ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបរបាញ់ ការទាក់ ការចាប់ ការបំពុល និងការសម្លាប់សត្វព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៣ ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌទី២ និងទី៣ នៃមាត្រា៥៥៤ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ឬទី៥ ចំពោះសកម្មភាពដូចមានចែងក្នុងកថាខណ្ឌទី៤ ទី៥ ទី៦ ទី៧ និងទី៨ នៃមាត្រា៥៥៤ ។

**មាត្រា១១៦៩**._ ការចាប់សត្វព្រៃរស់សម្រាប់គោលដៅអភិរក្ស

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការចាប់សត្វព្រៃរស់តាមប្រភេទ ដូចបានកំណត់

ក្នុងចំណាត់ថ្នាក់ណាមួយសម្រាប់គោលដៅបង្កាត់ពូជអភិរក្ស ឬការគ្រប់គ្រងលើការងារអភិរក្ស ដោយពុំមានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៤៦២ ។

**មាត្រា១១៧០** ._ ការបន្លាស់ទីកន្លែង និងការចាប់សត្វព្រៃសម្រាប់ការបង្កាត់ពូជដើម្បីអភិរក្ស ឬគ្រប់គ្រងលើការងារអភិរក្ស

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការបន្លាស់ទីកន្លែង និងការចាប់សត្វព្រៃសម្រាប់ការបង្កាត់ពូជដើម្បីអភិរក្ស ឬគ្រប់គ្រងលើការងារអភិរក្ស ប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី១ ឬចំណាត់ថ្នាក់ទី២ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៤៦៤ ។

**មាត្រា១១៧១** ._ ការហាមឃាត់ចំពោះការបរបាញ់ ការទាក់ ការចាប់ ការបំពុល ឬការប្រមូលសត្វព្រៃពីព្រៃធម្មជាតិ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការបរបាញ់ ការទាក់ ការចាប់ ការបំពុល ឬការប្រមូលសត្វព្រៃពីព្រៃធម្មជាតិ នូវប្រភេទដូចបានកំណត់ក្នុងចំណាត់ថ្នាក់ទី១ និងចំណាត់ថ្នាក់ទី២ នៃបញ្ជីចំណាត់ថ្នាក់សត្វព្រៃ សម្រាប់បម្រើឱ្យគ្រឹះស្ថានឧទ្យានសត្វព្រៃ ដូចមានចែងក្នុងមាត្រា៤៦៩ ។

**មាត្រា១១៧២** ._ ការហាមឃាត់ចំពោះការបរបាញ់សត្វព្រៃ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបរបាញ់សត្វព្រៃ ដូចបានកំណត់នៅក្នុងបញ្ជីចំណាត់ថ្នាក់ទី៣ ដូចមានចែងក្នុងមាត្រា៤៧២ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៥ ចំពោះការបរបាញ់សត្វព្រៃ ដូចបានកំណត់នៅក្នុងបញ្ជីចំណាត់ថ្នាក់ទី៤ ដូចមានចែងក្នុងមាត្រា៤៧២ ។

**មាត្រា១១៧៣** . _ ការហាមឃាត់ចំពោះការទិញ ទទួល ឬធ្វើលទ្ធកម្មសត្វព្រៃរស់ ឬស្លាប់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះការទិញ ទទួល ឬធ្វើលទ្ធកម្មសត្វព្រៃរស់ ឬសត្វព្រៃស្លាប់ បំណែកសរីរាង្គសត្វព្រៃ ឬសាច់សត្វព្រៃក្នុងចំណាត់ថ្នាក់ទី១ ដូចមានចែងក្នុងមាត្រា៤៧៩ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការទិញ ទទួល ឬធ្វើលទ្ធកម្មសត្វព្រៃរស់ ឬសត្វព្រៃស្លាប់ បំណែកសរីរាង្គសត្វព្រៃ ឬសាច់សត្វព្រៃក្នុងចំណាត់ថ្នាក់ទី២ ដូចមានចែងក្នុងមាត្រា ៤៧៩ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការទិញ ទទួល ឬធ្វើលទ្ធកម្មសត្វព្រៃរស់ ឬសត្វព្រៃស្លាប់ បំណែកសរីរាង្គសត្វព្រៃ ឬសាច់សត្វព្រៃក្នុងចំណាត់ថ្នាក់ទី៣ ដូចមានចែងក្នុងមាត្រា៤៧៩ ។

**មាត្រា១១៧៤** ._ ការហាមឃាត់ចំពោះការធ្វើពាណិជ្ជកម្មក្នុងស្រុក

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះការធ្វើពាណិជ្ជកម្មក្នុងស្រុកទៅលើប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ និងចំណាត់ថ្នាក់ទី៣ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ និងទី២ នៃមាត្រា៤៨០ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាព ដូចមានចែងនៅក្នុងកថាខណ្ឌទី៣ និងទី៤ នៃមាត្រា៤៨០ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះសកម្មភាព ដូចមានចែងនៅក្នុងកថាខណ្ឌទី៥ នៃមាត្រា៤៨០ ។

**មាត្រា១១៧៥** ._ សកម្មភាពពាណិជ្ជកម្មអន្តរជាតិដោយគ្មានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះសកម្មភាពពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិទៅលើប្រភេទ ឬសំណាកសត្វព្រៃក្នុងចំណាត់ថ្នាក់ទី១ ដូចមានចែងក្នុងមាត្រា៤៨១ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិទៅលើប្រភេទ ឬសំណាកសត្វព្រៃក្នុងចំណាត់ថ្នាក់ទី២ ដូចមានចែងក្នុងមាត្រា៤៨១ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះសកម្មភាពពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិទៅលើប្រភេទ ឬសំណាកសត្វព្រៃក្នុងចំណាត់ថ្នាក់ទី៣ ដូចមានចែងក្នុងមាត្រា៤៨១ ។

**មាត្រា១១៧៦** ._ ការហាមឃាត់ចំពោះការបង្ខាំង ការចិញ្ចឹម ការបម្រើការងារ ឬលម្អនូវប្រភេទសត្វព្រៃ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបង្ខាំង ការចិញ្ចឹម ការបម្រើការងារ ឬលម្អនូវប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ចំណាត់ថ្នាក់ទី៣ ចំណាត់ថ្នាក់ទី៤ នៅក្រៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សហ្សែន ឬគ្រឹះស្ថានឧទ្យានសត្វព្រៃដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៤៩៥ ។

**មាត្រា១១៧៧** ._ ការហាមឃាត់ចំពោះការរក្សាទុកសត្វព្រៃដោយគ្មានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សធនធានហ្សែន មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ ដែលមានផែនការរក្សាទុកសត្វព្រៃគ្រប់ប្រភេទ ដូចមានចែងក្នុងមាត្រា៤៩៦ ។

**មាត្រា១១៧៨ .**_ ការផ្ទេរ ឬការប្តូរទីតាំងសត្វព្រៃដោយគ្មានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការផ្ទេរ ឬការប្តូរទីតាំងសត្វព្រៃក្នុងចំណាត់ថ្នាក់ទី១ ចំណាត់ថ្នាក់ទី២ ចំណាត់ថ្នាក់ទី៣ ចំណាត់ថ្នាក់ទី៤ ដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា ៥០០ ។

**មាត្រា១១៧៩ .**_ ការបោះបង់ចោល ឬរក្សាទុកបំណែកសរីរាង្គ សាច់ សំណាក ឬវត្ថុតាំងលម្អនៃសត្វព្រៃដែលបង្ខាំង ឬចិញ្ចឹម

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបោះបង់ចោល ឬរក្សាទុកបំណែកសរីរាង្គ សាច់ សំណាក ឬវត្ថុតាំងលម្អនៃសត្វព្រៃដែលបង្ខាំង ឬចិញ្ចឹម ដូចមានចែងក្នុងមាត្រា៥០១ ។

**មាត្រា១១៨០ .**_ ការដោះលែងសត្វព្រៃ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះសកម្មភាពដោះលែងសត្វព្រៃដែលល្មើសនឹង មាត្រា៥០៦ ។

**មាត្រា១១៨១ .**_ ការហាមឃាត់ចំពោះសកម្មភាពរបស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពហាមឃាត់ដែលធ្វើឡើងដោយកសិដ្ឋាន ចិញ្ចឹមសត្វព្រៃ ដូចមានចែងក្នុងមាត្រា៥១១ ។

**មាត្រា១១៨២ .**_ ការបើកកសិដ្ឋានចិញ្ចឹមសត្វព្រៃដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះកសិដ្ឋានចិញ្ចឹមសត្វព្រៃក្នុងគោលបំណងពាណិជ្ជកម្មដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥១២ ។

**មាត្រា១១៨៣ .**_ ការបំពានកាតព្វកិច្ចរបស់ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ដែលមិនបានអនុវត្ត កាតព្វកិច្ច ដូចមានចែងក្នុងមាត្រា៥១៣ ។

**មាត្រា១១៨៤** ._ ការលក់សត្វព្រៃចិញ្ចឹម និងផលិតផលសត្វព្រៃដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការលក់ ការដូរ ការទិញ ឬការធ្វើអាជីវកម្មសត្វព្រៃ ដែលបានចិញ្ចឹម និងផលិតផលសត្វព្រៃ ដូចមានចែងក្នុងមាត្រា៥១៦ ។

**មាត្រា១១៨៥** ._ ការថែទាំសត្វព្រៃមិនស្របតាមលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃដែល ថែទាំសត្វព្រៃ មិនស្របតាមលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥១៩ ។

**មាត្រា១១៨៦** ._ ការទប់ស្កាត់ការរត់គេចសត្វព្រៃ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ដែល ធ្វេសប្រហែសបណ្តោយឱ្យសត្វព្រៃរបស់ខ្លួនរួច ឬគេចពីការបង្ខាំង ឬព្រលែងចូលទៅក្នុងព្រៃ ដូចមាន ចែងក្នុងមាត្រា៥២០ ។

**មាត្រា១១៨៧** ._ ការសម្លាប់សត្វព្រៃចិញ្ចឹមដោយអសត្វធម៌

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការសម្លាប់សត្វព្រៃចិញ្ចឹមដោយអសត្វធម៌ ដូច មានចែងក្នុងមាត្រា៥២១ ។

**មាត្រា១១៨៨** ._ ការដឹកជញ្ជូនសត្វព្រៃ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះប្រតិបត្តិករ ឬម្ចាស់កសិដ្ឋានសត្វព្រៃ ដឹកជញ្ជូន សត្វព្រៃដែលត្រូវបង្ខាំង មិនស្របតាមនីតិវិធី និងលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងមាត្រា៥២២ ។

**មាត្រា១១៨៩** ._ ការបង្ខាំងសត្វព្រៃដោយខ្សែក

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការប្តូរទីតាំង ឬផ្ទេរសត្វព្រៃរវាងទីបង្ខាំង និងតំបន់ ព្រៃ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងមាត្រា៥២៧ ។

**មាត្រា១១៩០ .**_ សកម្មភាពហាមឃាត់នៅតំបន់ឆ្នេរ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពសាងសង់ ហេដ្ឋារចនាសម្ព័ន្ធ អាជីវកម្មរ៉ែ និងគម្រោងវិនិយោគដែលបង្កឱ្យមានការបាត់បង់ ឬការខូចខាតធនធានតំបន់ឆ្នេរសមុទ្រ តំបន់កោះ និងសមុទ្រ ដូចមានចែងក្នុងមាត្រា៥៨០ ។

**មាត្រា១១៩១ .**_ សកម្មភាពដែលតម្រូវឱ្យមានការផ្តល់ការអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះសកម្មភាពទាំងឡាយ ដែលគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៨៣ ។

**មាត្រា១១៩២ .**_ ការចុះអធិការកិច្ចដោយគ្មានវិញ្ញាបនបត្រ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការចុះអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចដោយគ្មានវិញ្ញាបនបត្រ ដូចមានចែងក្នុងមាត្រា៦១៣ ។

**មាត្រា១១៩៣ .**_ ការផ្គត់ផ្គង់ និងប្រើប្រាស់ទឹកដោយគ្មានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការយក ការផ្គត់ផ្គង់ ឬការប្រើប្រាស់ទឹក ដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦១៧ ។

**មាត្រា១១៩៤ .**_ ការបំពានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះអ្នកផ្គត់ផ្គង់ទឹក ឬអ្នកប្រើប្រាស់ទឹក មិនស្របតាមលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦១៨ ។

**មាត្រា១១៩៥ .**_ ការហាមឃាត់មិនឱ្យមន្ត្រីមានសមត្ថកិច្ចចូលបរិវេណដីឯកជន

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ដីឯកជន ដែលបដិសេធ មិនឱ្យមន្ត្រីមានសមត្ថកិច្ចចូលបរិវេណដីឯកជនរបស់ខ្លួន ដើម្បីធ្វើការសិក្សាផ្នែកបច្ចេកទេស ការវាយតម្លៃ ឬការអង្កេតតាមដាន ដូចមានចែងក្នុងមាត្រា៦១៩ ។

## ជំពូកទី៥
## បទល្មើសពាក់ព័ន្ធនឹងការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ

**មាត្រា១១៩៦** . _ គម្រោង និងសកម្មភាពដែលតម្រូវឱ្យមានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះគម្រោង ឬសកម្មភាពទាំងឡាយណា ដែលអាចបង្កផលប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌ ឬបេតិកភណ្ឌធម្មជាតិ ដែលបានចុះក្នុងបញ្ជី ឬមិនទាន់បានចុះនៅក្នុងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ និងទីតាំងដែលសង្ស័យថាមានបេតិកភណ្ឌវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៣៧ ។

**មាត្រា១១៩៧** . _ ការហាមឃាត់ចំពោះការធ្វើឱ្យខូចខាត ឬការបំផ្លិចបំផ្លាញ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះសកម្មភាពដែលបង្កឱ្យមានការខូចខាត ឬការបំផ្លិចបំផ្លាញបេតិកភណ្ឌវប្បធម៌ ឬវត្ថុបុរាណ ដែលមានចុះនៅក្នុងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៣៨ ។

**មាត្រា១១៩៨** . _ ការអភិរក្សបេតិកភណ្ឌវប្បធម៌ដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការបំផ្លិចបំផ្លាញ កែប្រែរូបរាង រុះរើ វាយកម្ទេច ជួសជុលឡើងវិញ ឬស្ថាបនាឡើងវិញនូវសម្បត្តិវប្បធម៌ទាំងឡាយណា ដែលត្រូវបានចាត់ថ្នាក់ជាបេតិកភណ្ឌវប្បធម៌ ដូចមានចែងក្នុងមាត្រា៦៦៨ ។

**មាត្រា១១៩៩** . _ ការជួសជុលឡើងវិញដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការជួសជុលសម្បត្តិវប្បធម៌ ដែលត្រូវបានធ្វើចំណាត់ថ្នាក់ជាបេតិកភណ្ឌវប្បធម៌ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៧០ ។

**មាត្រា១២០០** ._ ការលក់ ឬផ្ទេរសម្បត្តិវប្បធម៌

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់កម្មសិទ្ធិសម្បត្តិវប្បធម៌ ដែលបានចាត់ថ្នាក់ជាបេតិកភណ្ឌវប្បធម៌ ក្នុងករណីមានការលក់ ឬផ្ទេរសម្បត្តិវប្បធម៌ដែលខ្លួនកាន់កាប់ ដូចមានចែងក្នុងមាត្រា៦៧២ ។

**មាត្រា១២០១** ._ ការហាមឃាត់ចំពោះការកែប្រែ ឬការធ្វើឱ្យខូចខាតសោភ័ណភាពតំបន់បេតិកភណ្ឌទីក្រុង

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការកែប្រែ ផ្លាស់ប្តូររូបរាង ធ្វើឱ្យខូចខាតសោភ័ណភាព ឬទទួលរងនូវការបំផ្លិចបំផ្លាញតំបន់ណាមួយ ឬតំបន់ទាំងមូលនៃទីប្រជុំជន ភូមិ ឬទីក្រុង ដែលត្រូវបានចាត់ថ្នាក់ជាតំបន់បេតិកភណ្ឌទីក្រុង ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៨៣ ។

**មាត្រា១២០២** ._ ការហាមឃាត់ការប្រែរូបរាង ផ្លាស់ប្តូររចនាបទ ឬធ្វើឱ្យខូចខាតសោភ័ណភាពចំពោះសំណង់នៃតំបន់បេតិកភណ្ឌទីក្រុង

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះកែប្រែរូបរាង ផ្លាស់ប្តូររចនាបទ ឬធ្វើឱ្យខូចខាតសោភ័ណភាពត្រង់កន្លែងណាមួយនៃសំណង់សាធារណៈ ឯកជន សាសនា ហេដ្ឋារចនាសម្ព័ន្ធ និងលំហាបៃតងនៃតំបន់បេតិកភណ្ឌទីក្រុង ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៨៤ ។

**មាត្រា១២០៣** ._ ការជួសជុល កែប្រែរូបរាង និងកម្ទេចចោលសំណង់ក្នុងតំបន់បេតិកភណ្ឌទីក្រុងដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះម្ចាស់កម្មសិទ្ធិនៃអចលនទ្រព្យ សំណង់ទូទៅ ឬលំនៅឋាន ដែលស្ថិតក្នុងតំបន់បេតិកភណ្ឌទីក្រុងដែលបានធ្វើការជួសជុល កែប្រែរូបរាង ឬកម្ទេចចោលសំណង់នៅក្នុងតំបន់បេតិកភណ្ឌទីក្រុង ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៨៥ ។

**មាត្រា១២០៤** . _ ការមិនអនុវត្តកាតព្វកិច្ចរាយការណ៍

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះបុគ្គលគ្រប់រូបដែលបានដឹង ឬប្រទះឃើញដោយចៃដន្យនូវសំណង់ប្រាសាទបាក់បែក គ្រឹះប្រាសាទ ស្លាកស្នាមដែលបញ្ជាក់អំពីទីតាំងបុរាណស្ថាន វត្ថុបុរាណ ឬតំបន់បេតិកភណ្ឌវប្បធម៌ មិនអនុវត្តកាតព្វកិច្ចរាយការណ៍ ដូចមានចែងក្នុងមាត្រា៦៨៧ ។

**មាត្រា១២០៥**._ កាតព្វកិច្ចរាយការណ៍អំពីការប្រទះឃើញដោយចៃដន្យក្នុងការធ្វើប្រតិបត្តិការសាងសង់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រទះឃើញដោយចៃដន្យនូវវត្ថុបុរាណ ឬសម្បត្តិវប្បធម៌ ឬតំបន់បេតិកភណ្ឌវប្បធម៌ នៅក្នុងអំឡុងពេលប្រតិបត្តិការសាងសង់ ឬជីកគាស់កកាយ ស្តារហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ មិនបានបញ្ឈប់ការងារសាងសង់ជាបណ្តោះអាសន្ន និងមិនរាយការណ៍ទៅកាន់អាជ្ញាធរមូលដ្ឋាន ដូចមានចែងក្នុងមាត្រា៦៨៨ ។

**មាត្រា១២០៦**._ ការហាមឃាត់ចំពោះការជីករុករក ឬស្រាវជ្រាវស្វែងរកសម្បត្តិវប្បធម៌

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះជនណាម្នាក់ដែលបានជីករុករក ឬស្រាវជ្រាវ នៅលើដីកម្មសិទ្ធិរបស់ខ្លួន ឬរបស់អ្នកដទៃ ឬដីសាធារណៈ ក្នុងបំណងស្វែងរកវត្ថុផ្សេងៗ ឬស្លាកស្នាមភស្តុតាងដែលមានសារៈសំខាន់ខាងបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ បុរាណវិទ្យា ជាតិពន្ធុវិទ្យា សិល្បៈ ឬវិទ្យាសាស្ត្រផ្សេងៗ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៩១ ។

**មាត្រា១២០៧**._ ការហាមឃាត់ចំពោះការជីករុករក ឬស្រាវជ្រាវរកសម្បត្តិវប្បធម៌ដោយស្ថាប័ន វិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលបានជីករុករក ឬស្រាវជ្រាវនៅក្នុងដី ឬក្នុងទឹក ក្នុងគោលបំណងសិក្សាស្រាវជ្រាវ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៩២ ។

**មាត្រា១២០៨**._ ការហាមឃាត់ចំពោះការធ្វើឱ្យខូចខាតដល់សម្បត្តិវប្បធម៌

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះសកម្មភាពដែលធ្វើឱ្យខូចខាតដល់សម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៧០០ ។

**មាត្រា១២០៩**._ ការហាមឃាត់ចំពោះយកចេញ ឬបំផ្លាញបេតិកភណ្ឌ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានយកចេញ ឬបំផ្លាញសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ នៅក្នុងទីតាំងដីកម្មសិទ្ធិឯកជន ដូចមានចែងក្នុងមាត្រា៧០៥ ។

**មាត្រា១២១០**._ កាតព្វកិច្ចរាយការណ៍

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនរាយការណ៍ជូនក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អំពីវត្ថុក្រោមទឹកណាមួយ ដែលកំណត់អត្តសញ្ញាណជាសម្បត្តិវប្បធម៌ ដែលត្រូវបានប្រទះឃើញ ដូចមានចែងក្នុងមាត្រា៧១០ ។

**មាត្រា១២១១** ._ ការហាមឃាត់ចំពោះការធ្វើឱ្យខូចខាត ការស្រង់ ឬការរំខាន

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពដែលបង្កការខូចខាត ការបំផ្លិចបំផ្លាញ ការស្រង់ ឬការរំខាន ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដូចមានចែងក្នុងមាត្រា៧១១ ។

**មាត្រា១២១២** ._ ការហាមឃាត់ចំពោះការនាំចេញសម្បត្តិវប្បធម៌

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការនាំចេញសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៧២៩ ។

## ជំពូកទី៦
## បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុលបរិស្ថាន

**មាត្រា១២១៣** ._ ការតម្រូវឱ្យសុំលិខិតអនុញ្ញាតសំណល់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការប្រមូល ដឹកជញ្ជូន ធ្វើប្រព្រឹត្តកម្ម កែច្នៃ កម្ទេចចោល បោះបង់ ឬបញ្ចេញចោលសំណល់ ឬសារធាតុបំពុល ដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៧៤៧ ។

**មាត្រា១២១៤** ._ ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះបុគ្គលដែលផលិត នាំចូល ឬចែកចាយសារធាតុ ឬផលិតផលសារធាតុគីមីដែលជាប្រភេទសារធាតុគ្រោះថ្នាក់ ដែលមិនបានធ្វើការចុះបញ្ជិកា ដូចមានចែងក្នុងមាត្រា៧៦៤ ។

**មាត្រា១២១៥** ._ ការចុះបញ្ជិកាផលិតផល ឬសម្ភារប្រើប្រាស់ វត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះបុគ្គលដែលផលិត នាំចូល ឬចែកចាយផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ មិនបានធ្វើការចុះបញ្ជិកា ដូចមានចែងក្នុងមាត្រា៧៦៦ ។

**មាត្រា១២១៦**. _ ការដាក់ស្លាកសញ្ញាលើសម្ភារវេចខ្ចប់សារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការមិនដាក់ស្លាកសញ្ញាគ្រោះថ្នាក់លើសារធាតុគ្រោះថ្នាក់ ដែលផលិត នាំចូល ឬចែកចាយ និងសារព្រមានគ្រោះថ្នាក់នៅលើសម្ភារវេចខ្ចប់ ដូចមានចែងក្នុងមាត្រា៧៦៩ ។

**មាត្រា១២១៧** ._ កាតព្វកិច្ចផ្តល់ព័ត៌មានសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះបុគ្គលដែលផលិត នាំចូល ឬចែកចាយសារធាតុគ្រោះថ្នាក់ និងប្រើប្រាស់សារធាតុគ្រោះថ្នាក់ក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម មិនបានផ្តល់ព័ត៌មាន និងរបាយការណ៍ប្រចាំឆ្នាំ ដូចមានចែងក្នុងមាត្រា៧៧១ ។

**មាត្រា១២១៨** ._ កាតព្វកិច្ចផ្តល់ព័ត៌មានផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះបុគ្គលដែលផលិត នាំចូល ឬចែកចាយផលិតផល ឬសម្ភារប្រើប្រាស់ និងវត្ថុក្មេងលេងមានផ្ទុកសារធាតុគ្រោះថ្នាក់ មិនបានផ្តល់ព័ត៌មាន និងរបាយការណ៍ប្រចាំឆ្នាំ ដូចមានចែងក្នុងមាត្រា៧៧២ ។

**មាត្រា១២១៩** ._ ការជូនដំណឹងអំពីឧបទ្ទវហេតុលេចធ្លាយ ឬសាយភាយសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះបុគ្គលដែលផលិត នាំចូល ដឹកជញ្ជូន ឬចែកចាយសារធាតុគ្រោះថ្នាក់ និងប្រើប្រាស់សារធាតុគ្រោះថ្នាក់ ក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម មិនបានជូនដំណឹង ក្នុងករណីកើតមានគ្រោះថ្នាក់ ឬគ្រោះឧបទ្ទវហេតុលេចធ្លាយ ឬសាយភាយសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៧៧៣ ។

**មាត្រា១២២០** ._ ការទទួលខុសត្រូវលើសារធាតុគ្រោះថ្នាក់ខូចគុណភាព ឬក្លាយជាសំណល់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះបុគ្គលដែលពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ ទុកដាក់ កម្ទេចចោល ឬបោះបង់ចោលសារធាតុគ្រោះថ្នាក់ដែលខូចគុណភាព ឬផុតកំណត់កាលប្រើប្រាស់ ដូចមានចែងក្នុងមាត្រា៧៧៤ ។

**មាត្រា១២២១** ._ ការហាមឃាត់សារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះបុគ្គលដែលផលិត នាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៧៧៥ ។

**មាត្រា១២២២** ._ ការហាមឃាត់ផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះបុគ្គលដែលផលិត នាំចូល ឬចែកចាយផលិតផល សម្ភារប្រើប្រាស់ និងវត្ថុក្មេងលេង មានផ្ទុកសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៧៧៦ ។

**មាត្រា១២២៣** ._ ការហាមឃាត់ការបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពដែលបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ដូចមានចែងក្នុងមាត្រា៧៧៧ ។

**មាត្រា១២២៤** ._ ការហាមឃាត់ការបោះបង់ចោល និងការដុតសំណល់រឹង

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះបុគ្គលដែលបោះចោល ឬបញ្ជាឱ្យមានការបោះបង់ចោលសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកល្ង ប្រឡាយទឹក ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធ ដូចមានចែងក្នុងមាត្រា៧៨២ ។

**មាត្រា១២២៥** ._ កាតព្វកិច្ចម្ចាស់ទីតាំងបង្កើតសំណល់រឹងឧស្សាហកម្ម

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះបុគ្គលម្ចាស់ទីតាំងដែលបង្កើតសំណល់រឹងឧស្សាហកម្ម ដែលមិនបានគ្រប់គ្រងសំណល់របស់ខ្លួន ស្របតាមវិធានសុវត្ថិភាពបរិស្ថាន ដូចមានចែងក្នុងមាត្រា៧៨២ ។

**មាត្រា១២២៦** ._ ការបញ្ចេញសំណល់រឹងឧស្សាហកម្ម

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះបុគ្គលម្ចាស់ទីតាំងដែលបង្កើតសំណល់រឹងឧស្សាហកម្ម ដែលបញ្ចេញសំណល់រឹងឧស្សាហកម្មរបស់ខ្លួន ដោយគ្មានការអនុញ្ញាតត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា៧៩១ ។

**មាត្រា១២២៧** ._ ការអនុញ្ញាតសេវាប្រមូលដឹកជញ្ជូន និងសេវាទុកដាក់សំណល់រឹងឧស្សាហកម្ម

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការផ្តល់សេវាប្រមូលដឹកជញ្ជូន និងសេវាទីលានចាក់សំណល់រឹងឧស្សាហកម្ម ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៧៩២ ។

**មាត្រា១២២៨** ._ លិខិតអនុញ្ញាតអាជីវកម្មទាញយកធនធាន និងកែច្នៃសំណល់រឹង

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការធ្វើអាជីវកម្មទាញយកធនធាន ឬកែច្នៃសំណល់រឹង ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៧៩៣ ។

**មាត្រា១២២៩** ._ ការនាំចេញសំណល់រឹង ឬផលិតផលពីការកែច្នៃសំណល់រឹង

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការនាំចេញសំណល់រឹង ឬផលិតផលពីការកែច្នៃសំណល់រឹង ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៧៩៤ ។

**មាត្រា១២៣០** ._ ការហាមឃាត់ការនាំចូលសំណល់រឹង

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះការនាំចូលសំណល់រឹងពីបរទេសមកក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់គោលបំណងដុតកម្ទេចចោល ឬបោះបង់ចោល ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៧៩៥ ។

**មាត្រា១២៣១** ._ ការជូនដំណឹងពីការបង្កើតសំណល់គ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់សំណល់គ្រោះថ្នាក់ ដែលមិនបានជូនដំណឹងអំពីប្រភេទ លក្ខណៈ និងបរិមាណសំណល់គ្រោះថ្នាក់ ដែលបានបង្កើត និងអំពីវិធានការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៨០៣ ។

**មាត្រា១២៣២**._ ការបញ្ចេញសំណល់គ្រោះថ្នាក់ដោយគ្មានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់សំណល់គ្រោះថ្នាក់ ដែលបញ្ជូនសំណល់គ្រោះថ្នាក់ចេញពីទីតាំង ក្នុងគោលបំណងណាមួយ ឬដើម្បីបោះបង់ចោល ដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៨០៤ ។

**មាត្រា១២៣៣**._ ការទទួលខុសត្រូវរបស់ម្ចាស់សំណល់គ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់សំណល់គ្រោះថ្នាក់ ដែលទុកដាក់ វេចខ្ចប់ រក្សាទុក ធ្វើប្រព្រឹត្តកម្ម និងបញ្ចេញសំណល់គ្រោះថ្នាក់ មិនស្របតាមវិធានសុវត្ថិភាពបរិស្ថាន នៃគោលការណ៍ណែនាំបច្ចេកទេស ស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៨០៥ ។

**មាត្រា១២៣៤**._ លិខិតអនុញ្ញាតសេវាសំណល់គ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះប្រតិបត្តិករសំណល់គ្រោះថ្នាក់ ដែលដំណើរការសេវាសំណល់គ្រោះថ្នាក់ទាក់ទងនឹងការប្រមូល ដឹកជញ្ជូន កែច្នៃ ប្រព្រឹត្តកម្ម កម្ទេចចោល ឬបោះបង់ចោលសំណល់គ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៨០៦ ។

**មាត្រា១២៣៥**._ ការទទួលខុសត្រូវរបស់ប្រតិបត្តិករសំណល់គ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះប្រតិបត្តិករសំណល់គ្រោះថ្នាក់ ទាក់ទងនឹងការប្រមូល ដឹកជញ្ជូន កែច្នៃ ប្រព្រឹត្តកម្ម កម្ទេចចោល ឬបោះបង់ចោលសំណល់គ្រោះថ្នាក់ ដែលមិនទទួលខុសត្រូវលើដំណើរការសេវាសំណល់គ្រោះថ្នាក់របស់ខ្លួន ឱ្យស្របតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាត និងតាមវិធានសុវត្ថិភាពបរិស្ថាននៃគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៨០៧ ។

**មាត្រា១២៣៦**._ ការហាមឃាត់ដាច់ខាតចំពោះការនាំចូលសំណល់គ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះការនាំសំណល់គ្រោះថ្នាក់ពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា៨០៨ ។

**មាត្រា១២៣៧** ._ ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឆ្លងកាត់ដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ពីប្រទេសមួយទៅប្រទេសមួយទៀត ដោយឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៨១០ ។

**មាត្រា១២៣៨** ._ ការមិនចាត់វិធានការចំពោះករណីកំពប់ ឬលេចធ្លាយសំណល់គ្រោះថ្នាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះម្ចាស់សំណល់គ្រោះថ្នាក់ ឬប្រតិបត្តិករសេវាសំណល់គ្រោះថ្នាក់ ដែលមិនចាត់វិធានការ ក្នុងករណីកើតមានហេតុការណ៍កំពប់ ឬគ្រោះឧបទ្ទវហេតុលេចធ្លាយសំណល់គ្រោះថ្នាក់ នៅលើទីតាំងបង្កើតសំណល់គ្រោះថ្នាក់ ឬក្នុងពេលប្រតិបត្តិការសេវាសំណល់គ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៨១១ ។

**មាត្រា១២៣៩** ._ ការហាមឃាត់ការបញ្ចេញសារធាតុបំពុលពីប្រភពជាក់លាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបញ្ចេញសំណល់រាវ ឬសារធាតុបំពុលពីប្រភពជាក់លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈលើដី ឬក្រោមដី ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៨២៣ ។

**មាត្រា១២៤០** ._ ការបញ្ចេញសំណល់រាវ ឬសារធាតុបំពុលពីប្រភពជាក់លាក់ដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបញ្ចេញសំណល់រាវ ឬសារធាតុបំពុលពីប្រភពជាក់លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈលើដី ឬក្រោមដី ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៨២៥ ។

**មាត្រា១២៤១** ._ ការមិនបានជូនដំណឹង

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់ ឬប្រតិបត្តិករនៃប្រភពជាក់លាក់ដែលបានទទួលលិខិតអនុញ្ញាតបញ្ចេញសំណល់រាវ ដែលមិនបានជូនដំណឹងជាបន្ទាន់ ក្នុងករណីដូចមានចែងក្នុងមាត្រា៨២៦ ។

**មាត្រា១២៤២** ._ ការមិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់ ឬប្រតិបត្តិករនៃប្រភពជាក់លាក់ ដែលបានទទួលលិខិតអនុញ្ញាត មិនបានជ្រើសរើសសំណាកយកមកវិភាគ និងមិនបានអនុវត្តស្វ័យអង្កេតតាមដានការបញ្ចេញសំណល់រាវ ឱ្យស្របតាមលក្ខខណ្ឌតម្រូវអនុវត្តនៃលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៨២៧ ។

**មាត្រា១២៤៣** ._ ការមិនគ្រប់គ្រងសំណល់ភក់ពីអាងប្រព្រឹត្តកម្ម

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលខុសត្រូវគ្រប់គ្រងដំណើរការអាងប្រព្រឹត្តិកម្មសំណល់រាវ ឬទឹកកខ្វក់ ដែលមិនបានគ្រប់គ្រងសំណល់ភក់ដែលកើតចេញពីដំណើរការប្រព្រឹត្តកម្មសំណល់រាវ ឬទឹកកខ្វក់ ដូចមានចែងក្នុងមាត្រា៨២៧ ។

**មាត្រា១២៤៤** ._ ការហាមឃាត់ការប្រើប្រាស់សារធាតុគីមីពុល

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការប្រើប្រាស់សារធាតុគីមីពុល ឬសារធាតុគ្រោះថ្នាក់ ដែលបង្កឱ្យមានហានិភ័យដល់ជីវៈចម្រុះសមុទ្រ ដូចមានចែងក្នុងមាត្រា៨៤០ ។

**មាត្រា១២៤៥** ._ ការហាមឃាត់ការបញ្ចេញសំណល់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការបញ្ចេញសំណល់រឹង រាវ ឬទឹកកខ្វក់ ពីលើដីគោក ដែនកោះ នាវាចូលទៅក្នុងសមុទ្រ ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្មជាមុន ឬមិនមានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៨៤១ ។

**មាត្រា១២៤៦** ._ ការមិនទទួលខុសត្រូវរបស់ម្ចាស់នាវា

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះម្ចាស់នាវាដឹកជញ្ជូនទំនិញ និងនាវា ឬទូកទេសចរណ៍ ដែលមិនបំពាក់ឧបករណ៍សម្រាប់ស្តុកសំណល់ និងឧបករណ៍ការពារសុវត្ថិភាពនៃការកំពប់ ឬការលេចធ្លាយសំណល់ ឬសារធាតុបំពុលចូលទៅក្នុងសមុទ្រ ដូចមានចែងក្នុងមាត្រា៨៤២ ។

**មាត្រា១២៤៧** ._ ការមិនទទួលខុសត្រូវរបស់ម្ចាស់ ឬប្រតិបត្តិករនាវា

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់ ឬប្រតិបត្តិករនាវាដែលមិនដំឡើងឧបករណ៍សម្រាប់ផ្ទុក ឬប្រមូលសំណល់ប្រេង និងសំណល់ផ្សេងៗ និងធ្វើការសម្អាតសារធាតុបំពុលពី

សកម្មភាពអាជីវកម្មរបស់ខ្លួន ក្នុងករណីដែលមានការសាងសង់ ការជួសជុល ការរុះរើ ឬការលាងសម្អាតកប៉ាល់ ឬនាវា ដូចមានចែងក្នុងមាត្រា៨៥៥ ។

**មាត្រា១២៤៨** ._ ការហាមឃាត់ការបញ្ចេញលើសស្តង់ដារបញ្ចេញ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត ដែលមិនឆ្លើយតបនឹងស្តង់ដារបញ្ចេញ ដូចមានចែងក្នុងមាត្រា៨៥៥ ។

**មាត្រា១២៤៩** ._ ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័តដោយគ្មានវិញ្ញាបនបត្របញ្ជាក់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូល ឬលក់យានយន្តគ្រប់ប្រភេទ ដែលមានអាយុកាលប្រើប្រាស់លើសពី៥ (ប្រាំ) ឆ្នាំ ក្រោយកាលបរិច្ឆេទនៃឆ្នាំផលិត ដោយគ្មានវិញ្ញាបនបត្របញ្ជាក់ការបញ្ចេញសារធាតុបំពុលខ្យល់ ដូចមានចែងក្នុងមាត្រា៨៥៦ ។

**មាត្រា១២៥០** ._ ការមិនបំពាក់ឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូល ឬផលិតក្នុងស្រុក នូវយានយន្តគ្រប់ប្រភេទ ដោយមិនបំពាក់ឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់ ដើម្បីឱ្យការបញ្ចេញសារធាតុបំពុលខ្យល់ឆ្លើយតបនឹងស្តង់ដារ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៨៥៧ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់យានយន្តគ្រប់ប្រភេទដែលមិនបំពាក់ និងថែទាំឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់ ដើម្បីឱ្យការបញ្ចេញសារធាតុបំពុលខ្យល់ឆ្លើយតបនឹងស្តង់ដារ ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា៨៥៧ ។

**មាត្រា១២៥១** ._ ការហាមឃាត់ចំពោះការបញ្ចេញសារធាតុបំពុលខ្យល់ ឬក្លិនស្អុយពីប្រភពអចល័ត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការបញ្ចេញ ឬការបំភាយសារធាតុបំពុលខ្យល់ពីប្រភពអចល័តទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបស្តង់ដារបញ្ចេញ ឬការបង្កើត ឬការបំភាយក្លិនស្អុយ ឬក្លិនអាក្រក់ ដែលរំខានដល់ការរស់នៅ ឬធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ដូចមានចែងក្នុងមាត្រា៨៥៨ ។

**មាត្រា១២៥២**._ ការបញ្ចេញសារធាតុបំពុលខ្យល់ដោយមិនអនុលោមតាមការកំណត់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់ ឬប្រតិបត្តិករទីតាំងអចល័តដែលធ្វើការបំពាក់ និងដំណើរការម៉ាស៊ីន ឬគ្រឿងបរិក្ខារត្រួតពិនិត្យការបំពុលខ្យល់ មុនធ្វើការបញ្ចេញ ឬបំភាយចូលទៅក្នុងបរិយាកាស ដោយអនុលោមតាមការកំណត់ ដូចមានចែងក្នុងមាត្រា៨៦០ ។

**មាត្រា១២៥៣**._ ការបញ្ចេញសារធាតុបំពុលខ្យល់ដោយគ្មានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័តដោយគ្មានលិខិតអនុញ្ញាតបញ្ចេញ ដូចមានចែងក្នុងមាត្រា៨៦១ ។

**មាត្រា១២៥៤**._ ការមិនរបាយការណ៍នៃប្រភពអចល័ត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលមិនបានជូនដំណឹងភ្លាម ក្នុងករណីមានបញ្ហាជាមួយឧបករណ៍ត្រួតពិនិត្យការបំពុលខ្យល់ខូចមិនដំណើរការ ឬការកើតមានករណីបញ្ហាការបំពុលខ្យល់បរិយាកាស ដូចមានចែងក្នុងមាត្រា៨៦២ ។

**មាត្រា១២៥៥**._ ការរក្សាទុក និងការរាយការណ៍ទិន្នន័យតាមដានការបញ្ចេញ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៥ ចំពោះម្ចាស់ ឬប្រតិបត្តិករទីតាំងអចល័តដែលមិនបានរក្សាទុកទិន្នន័យតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ និងមិនបានផ្តល់ទិន្នន័យ ដូចមានចែងក្នុងមាត្រា៨៦៤ ។

**មាត្រា១២៥៦**._ ការហាមឃាត់ចំពោះការនាំចូល ការផលិត ការចែកចាយ និងការប្រើប្រាស់ធ្យូងថ្ម និងឥន្ធនៈផូស៊ីល

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការនាំចូល ការផលិត ការចែកចាយ និងការប្រើប្រាស់ធ្យូងថ្ម និងឥន្ធនៈផូស៊ីល ដែលមិនស្របតាមស្តង់ដារកម្រិតសារធាតុបំពុលខ្យល់ នៅក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល ដូចមានចែងក្នុងមាត្រា៨៦៦ ។

**មាត្រា១២៥៧**._ ការមិនបានជូនដំណឹងអំពីការនាំចូល និងកំហាប់សារធាតុបំពុលខ្យល់ក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលនាំចូលធ្យូងថ្ម និងឥន្ធនៈផូស៊ីល មិនបានជូនដំណឹងអំពីការនាំចូល និងមិនបានភ្ជាប់មកជាមួយនូវវិញ្ញាបនបត្របញ្ជាក់ពីកំហាប់សារធាតុបំពុលខ្យល់ដែលមាននៅក្នុងធ្យូងថ្ម និងឥន្ធនៈផូស៊ីល ដូចមានចែងក្នុងមាត្រា៨៦៧ ។

**មាត្រា១២៥៨** ._ ការហាមឃាត់ចំពោះការបញ្ចេញ ឬការបំភាយសារធាតុបំពុលខ្យល់ក្នុងអគារ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបញ្ចេញ ឬការបំភាយនូវសារធាតុបំពុលខ្យល់នៅក្នុងអគារដែលលើសស្តង់ដារគុណភាពខ្យល់ក្នុងអគារ ដូចមានចែងក្នុងមាត្រា៨៧០ ។

**មាត្រា១២៥៩** ._ ការហាមឃាត់ចំពោះការនាំចូល ការនាំចេញ និងការផលិតសារធាតុបំផ្លាញស្រទាប់អូហ្សូន

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការនាំចូល ការនាំចេញ និងការផលិតសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលបានកំណត់ការលុបបំបាត់ដោយពិធីសារម៉ុងរ៉េអាល់ ដូចមានចែងក្នុងមាត្រា៨៨៤ ។

**មាត្រា១២៦០** . _ ការមិនគោរពតាមស្តង់ដារ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះសកម្មភាពដែលបង្កើតសំឡេង ឬរំញ័រដែលលើសស្តង់ដារសំឡេង និងរំញ័រ ដូចមានចែងក្នុងមាត្រា៨៩០ ។

**មាត្រា១២៦១** . _ ការមិនបំពាក់បរិក្ខារកាត់បន្ថយការបញ្ចេញសំឡេង ឬរំញ័រ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់ ឬប្រតិបត្តិករទីតាំង ដែលមិនបំពាក់គ្រឿងបរិក្ខារសម្រាប់កាត់បន្ថយការបញ្ចេញសំឡេង ឬរំញ័រ ដោយអនុលោមតាមការកំណត់ ដូចមានចែងក្នុងមាត្រា៨៩១ ។

**មាត្រា១២៦២** . _ ការមិនជូនដំណឹងពីទីតាំងទទួលរងការបំពុល ឬពីអ្នកបង្កការបំពុល

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬអ្នកដែលបានដឹងអំពីទីតាំងទទួលរងការបំពុល ឬអំពីអ្នកដែលទទួលខុសត្រូវទីតាំងទទួលរងការបំពុល ដែលមិនបានរាយការណ៍ ដូចមានចែងក្នុងមាត្រា៩០០ ។

**មាត្រា១២៦៣** ._ ការមិនបានផ្តល់របាយការណ៍ពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះទីតាំងផលិតកម្ម ឬអាជីវកម្ម ដែលសកម្មភាពរបស់ខ្លួន អាចបង្កឱ្យមានការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលចូលទៅក្នុងបរិស្ថាន ដែលមិនបានផ្តល់របាយការណ៍អំពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុល ដូចមានចែងក្នុងមាត្រា៩១២ ។

## ជំពូកទី៧
## បទល្មើសពាក់ព័ន្ធនឹងមន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា១២៦៤** ._ ការមិនបំពេញភារកិច្ច និងតួនាទីរបស់មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាលចំពោះមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ដែលប្រព្រឹត្តបំពាន ឬមិនបំពេញភារកិច្ច និងតួនាទីរបស់ខ្លួន ដូចមានចែងក្នុងមាត្រា១១១ ដោយមិនរាប់បញ្ចូលការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដទៃទៀត ។

# គន្ថីទី១២
# អន្តរប្បញ្ញត្តិ
## ជំពូកទោល
## អន្តរប្បញ្ញត្តិ

**មាត្រា១២៦៥** ._ ការអនុវត្តបទប្បញ្ញត្តិនៃក្រមនេះ

បទប្បញ្ញត្តិនៃច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តដោយឡែក ដែលពាក់ព័ន្ធតាមវិស័យនីមួយៗ ដែលកំពុងនៅជាធរមាន នៅតែមានអានុភាពអនុវត្ត ។

ក្នុងករណីបទប្បញ្ញត្តិនៃច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តដោយឡែក ដែលពាក់ព័ន្ធតាមវិស័យនីមួយៗដែលកំពុងនៅជាធរមាន មិនស្របគ្នានឹងបទប្បញ្ញត្តិនៃក្រមនេះក្រោយពេលក្រមនេះចូលជាធរមាន បទប្បញ្ញត្តិនៃក្រមនេះ មានអានុភាពអនុវត្តជាអាទិភាព ។

**មាត្រា១២៦៦** ._ ការអនុវត្តនីតិវិធី និងយន្តការផ្សេងៗនៃក្រមនេះ

រាល់គម្រោងដែលទទួលបានការឯកភាពពីរាជរដ្ឋាភិបាលមុនពេលក្រមនេះចូលជាធរមាន នៅតែមានអនុភាពអនុវត្ត លើកលែងតែប្រភេទគម្រោងដែលកំណត់ដោយបទប្បញ្ញត្តិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងគន្ថីទី២ មាតិកាទី២ នៃក្រមនេះ ។

នីតិវិធី និងយន្តការផ្សេងៗដែលបានបង្កើតឡើងក្រោមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវអនុវត្តបន្ទាប់ពីក្រមនេះចូលជាធរមាន ។

## គន្ថីទី១៣

## អវសានប្បញ្ញត្តិ

## ជំពូកទោល

## អវសានប្បញ្ញត្តិ

**មាត្រា១២៦៧** ._ និរាករណ៍នៃបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងក្រមនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១២៦៨** ._ ការអនុវត្តក្រមនេះ

ក្រោយពីក្រមនេះចូលជាធរមានទូទាំងព្រះរាជាណាចក្រកម្ពុជា ក្រមនេះ ត្រូវផ្សព្វផ្សាយរយៈពេល ៦ (ប្រាំមួយ) ខែ ទើបអនុវត្ត លើកលែងតែបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ ដែលត្រូវមានអានុភាពអនុវត្តភ្លាម ។

ក្រមនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី .......ខែ....... ឆ្នាំ............ នាសម័យប្រជុំរដ្ឋសភា
លើកទី......... នីតិកាលទី........ ។

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ...........ឆ្នាំ២០១៨

**ប្រធានរដ្ឋសភា**